សៀវភៅណែនាំសិក្សា

# ច្បាប់រដ្ឋប្បវេណី

## (ករណីប្រទេសជប៉ុន)

និពន្ធដោយ អ៊ីកិដា ម៉ាសាអូ

ប្រែសម្រួលដោយ គង់ ទេលី

សៀវភៅណែនាំសិក្សា

# ច្បាប់រដ្ឋប្បវេណី

## (ករណីប្រទេសជប៉ុន)

និពន្ធដោយ អ៊ីកិដា ម៉ាសាអូ

ប្រែសំរួលដោយ គង់ ទេលី

សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា

មជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍

# PREFACE

The Japan Jurists League for Cambodia was established by a group of lawyers and scholars who made their first trip to Cambodia in 1993 when Cambodia just started its journey towards peace and democracy ending more than 20 years of internal strife. The greatest concern shared by all members at that time was how Cambodia could be ensured that the experience of the unfortunate internal conflicts would never return, and towards that end what kind of cooperation we could manage to offer. At that time, the United Nations Transitional Authorities in Cambodia (UNTAC) was dispatched by the United Nations to Cambodia. Unlike other peace-keeping missions of the kind, UNTAC had a Human Rights Component, made up of legal experts from different countries. These experts were devoted to helping create a system that would safeguard human rights thought and human rights protection in this country. The message which we got directly from these experts was that “it is important to establish in this country a system that can ensure that disputes will not be solved by guns but by resorting to law”.

We also consulted Cambodian officials from the judicial sector, people in charge of training institutions for legal professions, and students struggling to join the circle of legal professions. They basically gave us the same message.

Since then, we have been visiting this country every year. We have been offering our cooperation for the sake of legal education in Cambodia, training of the legal professions and the development of the legal infrastructure in small but scrupulous steps.

One of the core activities in this cooperation has been the translation into Khmer of introductory Japanese textbooks on basic laws and their subsequent distributions to Cambodian students, researchers and practitioners. In order to direct our cooperation towards promoting Cambodia’s development as a member of the international community committing to a market economy, we considered it in particular a highly significant attempt to present to you the translation of an introductory book on Japanese Civil Code which had been created by efforts to apply European systems on an Asian environment.

The greatest chance came when we received the cooperation extended by Professor Ikeda Masao, a renounced Japanese scholar in Civil Code. Thus since year 2000, we have been making Khmer translation of the property law parts of the introductory Japanese Civil Code textbook called "An invitation to the Civil Code" written by Professor Ikeda. The translation has been completed on different chances and the products were distributed to you on a few separate occasions.

Since 1999, the Japanese government has been assisting Cambodia in drafting a Civil Code with the cooperation from many Cambodian and Japanese legal professionals. The new Cambodian Civil Code was then adopted last year. On this background, we thought it worth the effort to complete the full translation of Professor Ikeda Masao's textbook for distributing to students of Cambodian law and officials working in the judicial sector.

The many years of our efforts finally bear fruits. The complete translation of Professor Ikeda Masao's book on "An Invitation to the Civil Code – The Third Edition with Additional Revisions" emerges together with timely updates on the subsequent amendment of Japanese Civil Code. We are therefore now able to present it to you as our publication in cerebrating the 15th year of the establishment of the Japan Jurists League for Cambodia.

We would like to express herewith once again our heartfelt gratitude to Professor Ikeda Masao of the Keio University for his quick consent to the translation and publication of his book, to Associate Professor Kuong Teilee for his devotion to the translation of the book, to Mr. Yasumoto Kenmori for making funds available for the publications. Together with that, we also expect that this book will hereafter play a significant role in Cambodia, where a new Civil Code has most recently been adopted.

March 27, 2008

Japan Jurists League for Cambodia
Co-representatives: Attorney Kimura Shinsuke
Attorney Sakuragi Kazuyo

# ACKNOWLEDGEMENT

Thanks to the Japan Jurists League for Cambodia, I was brought into this translation project at the beginning of the 21$^{st}$ century. It has not been an easy attempt, but with time it has given me a certain level of confidence and courage. It is by no means the confidence in the quality of the work, but the usage which the book will prove to those who have some interests in the field of private law.

This is the first ever Khmer translation of a Japanese textbook on Japanese Civil Code. It will be an important invitation, surely not the only one, to those who want to know what Japanese students learn about their own Civil Code. In addition, given the close relationship between the new Cambodia Civil Code and the Japanese experience of more than a century, something like this small book will be a good inviting appeal to more attentions on a comparative understanding of the two systems and, through that, a hopeful window for the dynamic development of the new nascent Cambodian Civil Code.

However, since I am not really an expert in this area, the work represents the limits of my knowledge and capacity in this subject. Much thus remains to be done to improve this translation and to promote more work of this sort. Despite its many defects and weaknesses, I hope that this book will be one significant gateway to the promotion of active Cambodian access to the world of Japanese laws and legal thoughts.

Finally, I would like to thank friends and colleagues in Phnom Penh and Nagoya who have guided and assisted me in the process. They include H.E. Hy Sophea, Judge You Bunleng, Judge Mong Monichariya and Judge Pen Pichsaly who helped read the earlier version of the translation on chapters dealing with personal rights. Half of this final product is based on those earlier pieces. I would also like to express my gratitude to Mr. Phin Sovath, Ms. Ly Sopheap, Ms. Seng Hun, Ms. Kork Boren, Mr. Tep Vichet, Mr. Heng Chhay and other Cambodian researchers and former students at the Nagoya University in Japan who helped me with the initial translation of

some parts of the book and its subsequent compilation and printing. This final product would not have been possible without the devotion and technical supports from all of them.

Last but not least, Mr. Lao Kim Leang's preceding involving in this translation project has undoubtedly given me a very important place to start. Having benefited greatly from all of their efforts, to all of them I am indebted and for all mistakes I alone should be responsible.

(*The online version of the book will be available from May 2008 at* masaoikeda.com)

March 2008

Associate Professor at Nagoya University

Dr. Kuong Teilee

# បុព្វកថាក្នុងការបោះពុម្ពជាភាសាខ្មែរ

សៀវភៅនេះ បានសរសេរឡើងសំរាប់ជាការណែនាំអំពីការសិក្សានូវចំណុចសំខាន់ៗក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ។ សៀវភៅដើម (បោះពុម្ពលើកទីមួយនាឆ្នាំ ១៩៩៧ និងលើកទីបី នាឆ្នាំ ២០០៥) មានខ្លឹមសារពន្យល់អំពីក្រមរដ្ឋប្បវេណីទាំងមូលរបស់ប្រទេសជប៉ុន ដែលមាន ៥ គន្ថីស្តីពី បទបញ្ញត្តិទូទៅ សិទ្ធិប្រត្យក្ស សិទ្ធិលើបំណុល ញាតិ និងសន្តតិកម្ម ។ សៀវភៅសរសេរ ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលនូវសៀវភៅដើមជាភាសារជប៉ុននោះ ។

នៅខែវិច្ឆកាឆ្នាំ ២០០១ សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា (តំណាងដោយលោកស្រីមេធាវី សាគូរ៉ាហ្គិ កាហ្សុយ៉ូ និងលោកមេធាវី គីមូរ៉ា ស៊ីនស៊ូកេ) ក្នុងការអនុវត្តន៍សកម្មភាពរបស់ខ្លួន បានបកប្រែផ្នែកនៃសៀវភៅនេះដែលទាក់ទងនឹងច្បាប់ស្តីពីទ្រព្យសម្បត្តិ ឱ្យទៅជាភាគ ១ នៃសៀវភៅសរសេរជាភាសាខ្មែរ (ប្រែសំរួលដោយលោក ឡៅ គឹម លាង) ហើយចែកជូនជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងស្ថាប័នមួយចំនួនដទៃទៀត ។ បន្ទាប់មក ភាគ ២ ហើយនិងផ្នែកស្តីពីសិទ្ធិលើបំណុលទាំងមូលក៏ត្រូវបានបោះពុម្ពជាភាសារខ្មែរដែរ (ប្រែសំរួលដោយ លោក គង់ ទេលី បច្ចុប្បន្នជាសាស្ត្រាចារ្យរងនៅសាកលវិទ្យាល័យណាហ្គូយ៉ា) ដើម្បីយកទៅចែកជូន សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងស្ថាប័នដទៃទៀតរួមមាន សាលាភូមិន្ទបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងព្រះរាជអាជ្ញា និងគណៈមេធាវី ។

លើកនេះ ដោយសារមានកិច្ចប្រឹងប្រែងរបស់លោក គង់ ទេលី ការប្រែសំរួលសៀវភៅទាំងមូលជាភាសាខ្មែរត្រូវបានសំរេច ដែលមានរួមបញ្ចូលទាំងច្បាប់ស្តីពីញាតិ និងសន្តតិកម្មផងជាផ្នែកដែលមិនបានបកប្រែកាលពីមុនព្រោះយល់ឃើញថា វិស័យទាំងនេះឆ្លុះបញ្ចាំងនូវវប្បធម៌ដោយឡែករបស់ប្រទេសនិមួយៗ ។ មិនតែប៉ុណ្ណោះ ការបោះពុម្ពលើកនេះ គឺជាសៀវភៅប្រែសំរួលទាំងមូល ដែលឆ្លុះបញ្ចាំងទាំងខ្លឹមសារនៃការកែប្រែបន្ថែម (ឆ្នាំ ២០០៨) លើការបោះពុម្ពលើកទី ៣ ជាភាសាជប៉ុននោះ ដោយមានរៀបរាប់ផងដែរអំពីវិសោធនកម្មថ្មីៗបំផុតលើក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ។ ស្នាដៃនេះក៏ជា ចំណែកមួយនៃកិច្ចអបអរសាទរចំពោះខួបទី ១៥ នៃសកម្មភាពរបស់សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជាផងដែរ ។

សៀវភៅដើមជាភាសាជប៉ុន បានសរសេរឡើងជាសៀវភៅសិក្សា សំរាប់ជាការប្រើប្រាស់របស់និស្សិតដែលសិក្សានៅមហាវិទ្យាល័យរបស់ជប៉ុន ឬអ្នកធ្វើការ ដែលទើបនឹងចាប់ផ្តើមសិក្សាអំពីក្រមរដ្ឋប្បវេណី ។ ក្រមរដ្ឋវេណីរបស់ប្រទេសជប៉ុន ដែលបានអនុម័តនាឆ្នាំ ១៨៩៨ ត្រូវបានព្រាងឡើងដោយមានការទទួលឥទ្ធិពលពីសេចក្តីព្រាងនៃក្រមរបស់ប្រទេសបារាំង និងអាឡឺមង់ ។ ដូច្នេះ ការប្រែសំរួលនិងបោះពុម្ពសៀវភៅនេះ គឺផ្អែកលើការយល់ឃើញថាច្បាប់របស់ប្រទេសជប៉ុនមានចំណុចច្រើន ដែលអ្នកសិក្សាច្បាប់នៅប្រទេសកម្ពុជាអាចយកមកធ្វើជាឯកសារសំរាប់ពិគ្រោះ ។ ក្រោមមក ខ្ញុំក៏មានការរីករាយយ៉ាងខ្លាំងដែរដោយដឹងថា សៀវភៅនេះត្រូវបានយកមកបម្រើការសិក្សានៅក្នុងថ្នាក់រៀននៃមហាវិទ្យាល័យនៅក្រុងភ្នំពេញ ។

កន្លងមក ប្រទេសកម្ពុជាបានប្រទះនូវការរីកចម្រើនយ៉ាងឆាប់រហ័ស ។ ថ្ងៃនេះ ពេលដែលសៀវភៅប្រែសំរួលទាំងមូលត្រូវបានបោះពុម្ពផ្សាយ ប្រទេសកម្ពុជាក៏អនុម័តក្រមរដ្ឋប្បវេណីថ្មីរបស់ខ្លួនដែរ ។ ខ្ញុំសូមសំដែងនូវការគោរពសរសើចំពោះកិច្ចប្រឹងប្រែងរបស់ប្រជាពលរដ្ឋកម្ពុជា ។ ហើយខ្ញុំក៏សូមជូនពរដល់អ្នកទាំងអស់គ្នាផងដែរ ចំពោះព្រឹត្តការណ៍អនុម័តក្រមរដ្ឋប្បវេណីថ្មីដ៏វិសេសវិសាលនោះ ។

ខ្ញុំសង្ឃឹមថា ពីនេះតទៅ សៀវភៅប្រែសំរួលនេះនឹងមានតួនាទីថ្មីមួយទៀត ក្នុងការណែនាំឱ្យអ្នកទាំងអស់បានស្គាល់នឹងក្រមរដ្ឋប្បវេណីមួយ ក្នុងចំណោមក្រមរដ្ឋប្បវេណីបរទេសទាំងឡាយ ដែលធ្លាប់មានអិទ្ធិពលមកលើការអនុម័តក្រមរដ្ឋប្បវេណីថ្មីរបស់ប្រទេសកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសូមសំដែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក គង់ ទេលី ដែលបានប្រឹងប្រែងបញ្ចប់ការប្រែសំរួលទាំងមូលនេះ ហើយនិងចំពោះសមាជិកទាំងអស់របស់សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា ហើយក្នុងឱកាសនេះ ខ្ញុំក៏សូមបួងសួងឱ្យប្រទេសកម្ពុជាមានការរីកចម្រើនរឹតតែខ្លាំងក្លាទៅមុខទៀតផងដែរ ។

ខែធ្នូឆ្នាំ ២០០៧

**ម៉ាសារូ អ៊ីកិដា**

សាស្ត្រាចារ្យវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យកិយ៉ូ

និងជាសមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់ប្រទេសជប៉ុន

# បុព្វកថាក្នុងការបោះពុម្ពជាភាសាជប៉ុន

ក្រមរដ្ឋប្បវេណីជាច្បាប់មូលដ្ឋានក្នុងវិស័យនីតិឯកជនទាំងមូល ហើយមិនមែនជាច្បាប់ដែលមានលក្ខណៈអាចយកមកកែប្រែបានច្រើននោះទេ ។ ប៉ុន្តែសព្វថ្ងៃនេះ យើងកំពុងប្រទះនឹងការធ្វើវិសោធនកម្មទ្រង់ទ្រាយធំ។ ការបោះពុម្ពលើកទីបីនេះគឺជាការកែសំរួលទាំងមូលទៅលើការបោះពុម្ពលើកមុនៗដោយផ្អែកលើវិសោធនកម្មក្រមរដ្ឋប្បវេណីនាឆ្នាំ ២០០៤ ។

ក្នុងការធ្វើវិសោធនកម្មឆ្នាំ ២០០៤ នេះ គេបានបញ្ជូនសេចក្តីព្រាងច្បាប់ពីរទៅរដ្ឋសភា ។ សេចក្តីព្រាងទីមួយហៅថាជាសេចក្តីព្រាងនៃវិសោធនកម្មមួយផ្អែកលើក្រមរដ្ឋប្បវេណី។ ក្នុងសេចក្តីព្រាងនេះគេបានរួមបញ្ចូលនូវការកែប្រែពាក្យពេជន៍ឱ្យស្របទៅតាមការប្រើប្រាស់នាសម័យបច្ចុប្បន្ន ហើយនិងការដាក់កម្រិតចំពោះការធានាបំណុលអណ្តែតបុគ្គល ។ សេចក្តីព្រាង មួយទៀតសំដៅធ្វើវិសោធនកម្មមួយផ្អែកលើច្បាប់ពិសេសស្តីពីអនុប្បទានសិទ្ធិលើបំណុល។ ខ្លឹមសារនៃសេចក្តីព្រាងនេះ គឺសំរាប់បង្កើតប្រព័ន្ធចុះបញ្ជីទាក់ទងនឹងអនុប្បទានចលនទ្រព្យអាស្រ័យ ក្រមរដ្ឋប្បវេណីហើយនិងការពង្រីកឱកាសសំរាប់ប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអនុប្បទានសិទ្ធិលើបំណុល។ដោយចៃដន្យខ្ញុំមានការពាក់ព័ន្ធក្នុងការងារកែប្រែពាក្យពេចន៍ និងការធ្វើវិសោធនកម្មលើច្បាប់ពិសេសស្តីពីអនុប្បទានសិទ្ធិលើបំណុលផងដែរនោះ ដូច្នេះខ្ញុំមានគំនិតចង់រៀបចំការកែប្រែបោះពុម្ពសៀវភៅនេះសារជាថ្មីដើម្បីឆ្លុះបញ្ចាំងនូវវិសោធនកម្មទាំងនោះឱ្យបានឆាប់រហ័ស សំរាប់ជាប្រយោជន៍ដល់អ្នកអាន ។

លើកលែងផ្នែកវិសោធនកម្មជាសារធាតុទាក់ទងនឹងការធានានោះចេញ ការសម្រាយពាក្យពេចន៍នៃក្រមរដ្ឋប្បវេណីដោយប្រើភាសាបច្ចុប្បន្ននេះត្រូវបានអនុវត្តក្នុងភាពស្មោះត្រង់មិនឱ្យមានការប្រែប្រួលក្នុងរបៀបបកស្រាយបញ្ញត្តិនៃមាត្រាទេ ក៏ប៉ុន្តែក្នុងនោះមានប្រមាណជា ១០ ចំណុច ត្រូវបានកែប្រែត្រឹមកំរិតដែលអាចសំរួលដល់មាត្រាទាំងនោះឆ្លុះបញ្ចាំងផងដែរនូវទ្រឹស្តីទូទៅ ដែលបានបង្កើតឡើងដោយយុត្តិសាស្ត្រតុលាការ។ ម្យ៉ាងទៀតគេក៏បានព្យាយាមមិនឱ្យមានការផ្លាស់ប្តូរលេខមាត្រាខ្លាំងពេក។ ប៉ុន្តែ ដើម្បីជាការរៀបចំប្រយោគបន្ទាប់បន្សំនានា លេខរៀងនៃមាត្រាខ្លះត្រូវបានផ្លាស់ប្តូរ (សូមយកចិត្តទុកដាក់អានពីមាត្រា ១ ដល់មាត្រា ២២) ។

មូលហេតុនៃការប្រែប្រួលក្នុងសភាពការណ៍សង្គម ដែលនាំដល់ការកែប្រែក្រមរដ្ឋប្បវេណីជាច្បាប់មូលដ្ឋាននោះ អាចលើកឡើងជាកត្តាបីយ៉ាង។ ពោលគឺ ពតិមានូបនីយកម្ម (ដោយប្រើមធ្យោបាយអេឡិចត្រូនិច) អន្តរជាតូបនីយកម្ម និងកំណើននៃមនុស្សចាស់ជរា ។ ចំពោះកត្តាទី ៣ ទាក់ទងនឹងកំណើននៃមនុស្សចាស់ជរាគឺក្រៅអំពីកំណើននៃអាយុរបស់ពលរដ្ឋចេញយើងពិចារណាឃើញថាសង្គមស៊ីវិល និងលទ្ធិប្រជាធិបតេយ្យសេរីក្នុងប្រទេសនេះ ក៏មានភាពចាស់ទុំហើយដែរ ។ ខ្ញុំគិតថា ការសិក្សាច្បាប់រដ្ឋប្បវេណីដោយមានការចាប់អារម្មណ៍លើបញ្ហាថាតើកត្តាទាំង ៣ នេះត្រូវបានឆ្លុះបញ្ចាំងតាមវិធីយ៉ាងដូចម្តេចខ្លះ ក្នុងការធ្វើវិសោធនកម្មជាចំណែកនោះនឹងជំរុញឱ្យយើងយល់បានច្រើនអំពីក្រមរដ្ឋប្បវេណី ។

ក្រៅពីនេះការបោះពុម្ពលើកទី៣មានបន្ថែមចំនួននៃការពន្យល់អំពីពាក្យគន្លឹះចំពោះចំណុចទាំងឡាយណាដែលអ្នកសិក្សាដំបូងអាចងាយស្រួលនឹងមានការយល់ច្រឡំ។វាក៏អាចជំរុញឱ្យសៀវភៅនេះបង្កើនន្ធូវភាពសមស្របសំរាប់បំរើមុខងារជាសៀវភៅសិក្សានៅតាមមហាវិទ្យាល័យប្រភេទផ្សេងៗ ។ ខ្ញុំក៏គិតដែរថាបើសិនជាសៀវភៅមួយក្បាលនេះ អាចដើរតួនាទីជាសៀវភៅណែនាំដល់អ្នកទាំងឡាយណាដែលមិនធ្លាប់សិក្សាច្បាប់នៅឯមហាវិទ្យាល័យទេប៉ុន្តែមានបំណងចង់ប្រឡងចូលទៅសិក្សានៅសាលាវិជ្ជាជីវៈខាងច្បាប់នោះ អាចសិក្សាដោយខ្លួនឯងហើយយល់អំពីទិដ្ឋភាពរួមនៃក្រមរដ្ឋប្បវេណីបាននោះគឺជាការល្អប្រសើរ ។

នៅពេលដែលទើបតែបានបោះពុម្ពជាលើងដំបូង សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា (តំណាងដោយលោកស្រីមេធាវី សាគូរ៉ាហ្គី កាហ្សុយ៉ូ និងលោកមេធាវី គីមូរ៉ា ស៊ីនស៊ូកេ) បានយកសៀវភៅនេះទៅបកប្រែជាភាសាខ្មែរ (លោក ឡៅ គឹម លាង គឺជាអ្នកប្រែសំរួលភាសានាពេលនោះ) ។ ចាប់តាំងពីខែធ្នូឆ្នាំ ២០០០ មក ការប្រែសំរួលត្រូវបានរៀបចំឡើងជា ៣ លើកលើផ្នែកខ្លះនៃសៀវភៅទាំងមូលដើម្បីយកទៅចែក ជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគណៈមេធាវី ដើម្បីចូលរួមចំណែកក្នុងការរៀបចំឡើងវិញនូវវិស័យ អប់រំផ្នែកច្បាប់ ។ នាខែ មិនាឆ្នាំ ២០០៤ ការប្រែសំរួលផ្នែកនៃច្បាប់ស្តីពិទ្រព្យសម្បត្តិត្រូវបាន បញ្ចប់ហើយប្រគល់ជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងសេដ្ឋកិច្ច និងស្ថាប័នដទៃទៀតរួមមានក្រសួងយុត្តិធម៌ គណៈមេធាវី សាលាភូមិន្ទបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងព្រះរាជអាជ្ញា ។ ល ។ ខ្ញុំសូមសំដែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក គង់ ទេលី (បច្ចុប្បន្នជាសាស្ត្រាចារ្យរង

នៅសាកលវិទ្យាល័យណាហ្គូយ៉ា) ដែលជាអ្នកពិនិត្យនិងប្រែសំរួលភាសាខ្មែរលើកចុងក្រោយនេះ ហើយជាអ្នកជួយបកប្រែភាសាគ្រប់រាល់សន្ទរកថារបស់ខ្ញុំនៅប្រទេសកម្ពុជាហើយ និងអំណរគុណចំពោះសហការីទាំងអស់ដែលពាក់ព័ន្ធ ។

ខែវិច្ឆិកា ឆ្នាំ ២០០៤

## អំពីការកែប្រែបន្ថែមលើការបោះពុម្ពលើកទី ៣

បញ្ញត្តិស្តីពីនីតិបុគ្គលនៃក្រមរដ្ឋប្បវេណី ត្រូវបានកែប្រែយ៉ាងច្រើនដោយសារច្បាប់ទាំង ៣ (គ្រោងនឹងចាប់អនុវត្តនៅខែធ្នូឆ្នាំ ២០០៨) ទាក់ទងនឹងកំណែទម្រង់លើប្រព័ន្ធនីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ ដែលបានប្រកាសឱ្យប្រើនាខែមិថុនាឆ្នាំ ២០០៦ ។ ការកែប្រែបន្ថែមលើសៀវភៅនេះ គឺដើម្បីបង្ហាញអំពីចំណុចផ្លាស់ប្តូរនោះ ។

ខែមករាឆ្នាំ ២០០៨

**ម៉ាសារ៉ូ អ៊ីកិដា**

សាស្ត្រាចារ្យវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យកិយ៉ូ

និងជាសមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់ប្រទេសជប៉ុន

# មាតិកា

**Preface**............................................................................. i-ii

**Acknowledgement**............................................................................ i-ii

បុព្វកថាក្នុងការបោះពុម្ពជាភាសាខ្មែរ........................................ ..........i-iii

បុព្វកថាក្នុងការបោះពុម្ពជាភាសាជប៉ុន..................................................i-iv

ជំពូកទី១លំនាំសិក្សាច្បាប់រដ្ឋប្បវេណី...................................................១

I. វិសាលភាពនៃច្បាប់រដ្ឋប្បវេណី..................................................២

II. ទម្រង់ទូទៅនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន..........................៣

១. ការបែងចែកជាគន្ថីនៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន.....៣

២. សិទ្ធិប្រត្យ័ក្ស និងសិទ្ធិលើបំណុល..................................៤

៣. កំណើត និងដំណើរវិវត្តន៍នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន....៥

III. ឋានៈនៃក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធនៃច្បាប់ទាំងមូល.....................៧

១. ក្រមរដ្ឋប្បវេណីក្នុងឋានៈជាច្បាប់មូលដ្ឋាននៃនីតិឯកជន............៧

២. ច្បាប់ទូទៅ និងច្បាប់ពិសេស......................................៧-៨

IV. លក្ខណៈពិសេសនៃច្បាប់រដ្ឋប្បវេណី គោលការណ៍ស្វ័យភាពខាងឆន្ទៈ.......៩

១. គោលការណ៍ស្វ័យភាពខាងឆន្ទៈ និង គោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា

២. បទបញ្ញត្តិតាមការស្ម័គ្រចិត្ត និងបទបញ្ញតិដោយបង្ខំ.............១០-១១

V. គោលគំនិតក្នុងការសិក្សាច្បាប់រដ្ឋប្បវេណី.....................................១២

ជំពូកទី២ បទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី..........................................១៣
I. ចរិតលក្ខណៈនៃបទបញ្ញត្តិទូទៅ និងលំដាប់លំដោយក្នុងការសិក្សា.........១៤_១៥
II. ចំពោះការសិក្សាបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី...........................១៦
១. ការសិក្សាចំណុចសំខាន់ៗនៃបទបញ្ញាត្តិទូទៅ និងលំដាប់សិក្សា....១៦_១៧
២. បញ្ញត្តិដំបូងនៃបទបញ្ញត្តិទូទៅ..................................១៨_១៩
III. ការសិក្សាចំណុចសំខាន់ៗក្នុងបទបញ្ញាត្តិទូទៅនៃក្រមរដ្ឋប្បវេណី...............១៩
១. ការសំដែងឆន្ទៈ និងសកម្មភាពគតិយុត្ត...........................១៩_២២
២. ការការពារជនដែលត្រូវបានកំរិតសមត្ថភាព.....................២២_២៩
៣. ការបង្ហាញឆន្ទៈប្រកបដោយបញ្ហា...............................៣០_៣៦
៤. តំណាង តំណាងគ្មានសិទ្ធិ តំណាងដែលមានលក្ខណៈជារូបភាព..៣៧_៣៩
៥. មោឃភាព និងការលុបចោល.......................................៣៩_៤១
៦. ល័ក្ខខ័ណ្ឌ និងការកំណត់ពេល.......................................៤១_៤៣
៧. អាជ្ញាយុកាល..........................................................៤៣_៤៨
៨. នីតិបុគ្គល................................................................៤៩_៥៥
៩. លំនៅដ្ឋាន និងការបាត់ខ្លួន.......................................៥៥_៥៧

ជំពូកទី៣ ច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស (១) ទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស................៥៨
I. សព្វទស្សន៍នៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស..........................................៥៩
១. វត្ថុជាទ្រព្យសម្បត្តិ និងសិទ្ធិប្រត្យ័ក្ស.............................៦០_៦១
២. និយមន័យនៃសិទ្ធិប្រត្យ័ក្សនិងគោលការណ៍កំណត់សិទ្ធិប្រត្យ័ក្សដោយច្បាប់
៣. ប្រភេទនៃសិទ្ធិប្រត្យ័ក្ស...........................................៦២_៦៤
៤. ការប្រៀបធៀបរវាងទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស..........៦៥_៦៦
II. ការសិក្សាចំណុចសំខាន់ៗក្នុងទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស.............៦៦
១. សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យ័ក្ស..............................៦៦

២. ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស....................៦៧-៧៩
៣. កម្មសិទ្ធិ.....................................................................៨០-៨៧
៤. សិទ្ធិប្រត្យ័ក្សប្រើប្រាស់ និងអាស្រ័យផល...........................៨៧-៨៩
៥. សិទ្ធិកាន់កាប់...............................................................៨៩-៩៣

ជំពូកទី៤ ច្បាប់ស្តីពីសិទ្ធិលើបំណុល អំពីកិច្ចសន្យា..........................................៩៤
I. ទម្រង់ច្បាប់ស្តីពីសិទ្ធិលើបំណុល (កាតព្វកិច្ច)..........................................៩៥
១. សិទ្ធិលើបំណុលក្នុងន័យជាសិទ្ធិទៅលើបុគ្គល...........................៩៥
២. សិទ្ធិលើបំណុលក្នុងន័យជាទ្រព្យធន ......................................៩៦
៣. វចនាសម្ព័ន្ធនៃច្បាប់ស្តីពីសិទ្ធិលើបំណុល និងលំដាប់សិក្សា.............៩៧
II. ការសិក្សាចំណុចសំខាន់ៗអំពីទិដ្ឋភាពទូទៅនៃកិច្ចសន្យា..........................៩៨
១. ការបង្កើតកិច្ចសន្យា.......................................................៩៨-៩៩
២. ប្រភេទនៃកិច្ចសន្យា...................................................១០០-១០២
៣. សុពលភាពនៃកិច្ចសន្យា ............................................១០៣-១០៧
៤. ការមិនអនុវត្តកាតព្វកិច្ច និងការរំលាយកិច្ចសន្យា.............១០៨-១១២
III. ការសិក្សាចំណុចសំខាន់ៗអំពីទិដ្ឋភាពលំអិតនៃកិច្ចសន្យា......................១១២
១. កិច្ចសន្យាលក់.........................................................១១២-១១៦
២. កិច្ចសន្យាប្រទានកម្ម (កិច្ចសន្យាធ្វើអំណោយ)................១១៧-១១៩
៣. កិច្ចសន្យាជួល (ភតិសន្យា)......................................១១៩-១២១
៤. កិច្ចសន្យាខ្ចីប្រើ ..........................................................១២២
៥. កិច្ចសន្យាខ្ចីបរិភោគ.......................................................១២២
៦. កិច្ចសន្យាមៅការ.......................................................១២៣-១២៥
៧. កិច្ចសន្យាអាណត្តិ .....................................................១២៥-១២៧
៨. កិច្ចសន្យាបញ្ញើ ...........................................................១២៧
៩. កិច្ចសន្យាបង្កើតក្រុមហ៊ុន.........................................១២៧-១២៨

១០. កិច្ចសន្យាធម្មតាដទៃទៀត...................................១២៨-១៣០
១១. ការការពារអ្នកប្រើប្រាស់ និងរយៈវេលាអាចរំលាយកិច្ចសន្យាបាន...១៣១

ជំពូកទី៥ ច្បាប់ស្តីពីសិទ្ធិលើបំណុល ច្បាប់ស្តីពីអំពើអនីត្យានុកូល.......................១៣២
I. ប្រភពនៃការកកើតមានសិទ្ធិលើបំណុលក្រៅកិច្ចសន្យា ......................១៣៣
II. ការសិក្សាអំពីចំណុចសំខាន់នៃអំពើអនីត្យានុកូល ............................១៣៣
១. តើអំពើអនីត្យានុកូលជាអ្វី?............................................១៣៣
២. គោលស្តីពីសំណងខូចខាតបណ្តាលមកពីអំពើអនីត្យានុកូល..........១៣៤
៣. ល័ក្ខខ័ណ្ឌកំណត់នៃអំពើអនីត្យានុកូល..........................១៣៥-១៣៩
៤. អានុភាពនៃអំពើអនីត្យានុកូល..................................១៤០-១៤១
៥. អំពើអនីត្យានុកូលពិសេស ......................................១៤១-១៤៤
៦. បទបញ្ញត្តិដទៃផ្សេងទៀតស្តីពីអំពើអនីត្យានុកូល .....................១៤៥
៧. ច្បាប់ស្តីពីការធានាសំណងជំងឺចិត្តពាក់ព័ន្ធនឹងរថយន្ត................១៤៥
៨. ច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល ................១៤៦-១៤៨
II. ការសិក្សាអំពីចំណុចសំខាន់នៃការគ្រប់គ្រងដោយឈឺឆ្អាល
និងសេចក្តីចំរើន ដោយឥតហេតុ ....................................១៤៩
១. ការគ្រប់គ្រងដោយឈឺឆ្អាល............................១៤៩-១៥១
២. សេចក្តីចំរើនដោយឥតហេតុ..........................១៥១-១៥៤

ជំពូកទី៦ ច្បាប់ស្តីពីសិទ្ធិលើបំណុល ទិដ្ឋភាពទូទៅ.....................................១៥៥
I. ទម្រង់នៃទិដ្ឋភាពទូទៅអំពីសិទ្ធិលើបំណុល ..................................១៥៥
១. អត្ថន័យទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល.............................១៥៥
២. លក្ខណៈជាមូលដ្ឋាននៃសិទ្ធិលើបំណុល.......................១៥៦-១៥៧
៣. សារសំខាន៉នៃបញ្ញត្តិនៅក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល
សារៈសំខាន់នៅក្នុងការអនុវត្តន៍កិច្ចការអាជីវកម្មជាក់ស្តែង .........១៥៨

II. ការសិក្សាចំនុចសំខាន់ៗក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល ................១៥៩
១. ប្រភេទនៃសិទ្ធិលើបំណុល....................................១៥៩-១៦២
២. ការមិនអនុវត្តកាតព្វកិច្ច.......................................១៦៣-១៦៧
៣. ការថែរក្សាទ្រព្យធននៅក្រោមការទទួលខុសត្រូវ..............១៦៨-១៧២
៤. ទំនាក់ទំនងនៅក្នុងសិទ្ធិលើបំណុលដែលមានពហុភាគី .......១៧៣-១៨៤
៥. អនុប្បទានសិទ្ធិលើបំណុល....................................១៨៥-១៩០
៦. ការរលត់សិទ្ធិលើបំណុល......................................១៩១-១៩៧
III. ក្រមរដ្ឋប្បវេណីនៅក្នុងកិច្ចការផ្លូវច្បាប់នៃសហគ្រាស...................១៩៨-១៩៩

ជំពូកទី៧ ច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស ច្បាប់ស្តីពីសិទ្ធិប្រាតិភោគបត្យ័ក្ស .....................២០០
I. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស.............................២០១
១. និយមន័យនិងលក្ខណៈទូទៅនៃសិទ្ធិប្រាតិភោគប្រត្យ័ក្ស.២០១-២០៣
២. តួនាទីនៃសិទ្ធិប្រាតិភោគប្រត្យ័ក្ស និងឋានៈនៃច្បាប់ស្តីពី សិទ្ធិប្រាតិភោគប្រត្យ័ក្ស.................................២០៤-២០៦
II. ការសិក្សាពីចំនុចសំខាន់ៗនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យក្ស................២០៧
១. សិទ្ធិប្រាតិភោគប្រត្យក្សដែលកំណត់ដោយការសន្យា...........២០៧-២១៨
២. សិទ្ធិប្រាតិភោគប្រត្យក្សដែលច្បាប់បានកំណត់.................២១៩-២២១
៣. ប្រាតិភោគវិសាមញ្ញ..........................................២២២-២២៨

ជំពូកទី៨ ច្បាប់ស្តីអំពីញាតិ .......................................................២២៩
I. អត្ថន័យ និងមុខងារនៃច្បាប់គ្រួសារ.........................................២៣០
II. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីញាតិ..............................................២៣១
១. ខ្លឹមសារស្តីពីច្បាប់ស្តីពីញាតិ..........................................២៣១
៣. ទស្សនៈទូទៅស្តីពីញាតិ.......................................២៣២-២៣៣

III. ការសិក្សាអំពីចំណុចសំខាន់ៗរបស់ច្បាប់ស្ដីពីញាតិ..........................២៣៤
១. អាពាហ៍ពិពាហ៍...............................................២៣៤-២៤២
២. ការលែងលះគ្នា................................................២៤៣-២៤៥
៣. ទំនាក់ទំនងរវាងឪពុកម្ដាយ កូនបង្កើត និងកូនចិញ្ចឹម.........២៤៦-២៤៩
៤. អំណាចមេបា អំណាចអាណាព្យាបាលៈ ហិតូបត្ថម្ភ និងអ្នកជំនួយ.២៥០-២៥៨

ជំពូកទី៩ ច្បាប់ស្ដីអំពីសន្តតិកម្ម.................................................២៥៩
I. ទិដ្ឋភាពទូទៅនៃច្បាប់ស្ដីពីសន្តតិកម្ម.........................................២៦០
១. វចនាសម្ព័ន្ធនៃសន្តតិកម្ម......................................២៦០-២៦២
II. ការសិក្សាអំពីចំនុចសំខាន់ៗរបស់ច្បាប់សន្តតិកម្ម............................២៦៣
១. សន្តតិកម្មតាមច្បាប់...........................................២៦៣-២៦៩
២. ការយល់ព្រម និងការបោះបង់សន្តតិកម្ម......................២៧០-២៧១
៣. ការបែងចែកមតិក...............................................២៧២
៤. សន្តតិកម្មតាមមតកសាសន៍...............................២៧៣-២៨០
៥. ការបំបែកទ្រព្យសម្បត្តិ...........................................២៨១
៦. នត្ថិភាពនៃសន្តតិកម្ម............................................២៨២

**Author's Profile**.......................................................................................................

# ជំពូកទី ១
# លំនាំសិក្សាច្បាប់រដ្ឋប្បវេណី

I. វិសាលភាពនៃច្បាប់រដ្ឋប្បវេណី
II. ទម្រង់ទូទៅនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន
១. ការបែងចែកជាគន្ថីនៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន
២. សិទ្ធិប្រត្យ័ក្ស និងសិទ្ធិលើបំណុល
៣. កំណើត និងដំណើរវិវត្តនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន
III. ឋានៈនៃក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធនៃច្បាប់ទាំងមូល
១. ក្រមរដ្ឋប្បវេណីក្នុងឋានៈជាច្បាប់មូលដ្ឋាននៃនីតិឯកជន
២. ច្បាប់ទូទៅ និងច្បាប់ពិសេស
IV. លក្ខណៈពិសេសនៃច្បាប់រដ្ឋប្បវេណី - គោលការណ៍ស្វ័យភាពនៃឆន្ទៈ -
១. គោលការណ៍ស្វ័យភាពខាងឆន្ទៈ និងគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា
២. បទបញ្ញត្តិតាមការស្ម័គ្រចិត្ត និងបទបញ្ញត្តិដោយបង្ខំ
V. គោលគំនិតក្នុងការសិក្សាច្បាប់រដ្ឋប្បវេណី

# I. វិសាលភាពនៃច្បាប់រដ្ឋប្បវេណី

ច្បាប់រដ្ឋប្បវេណី ពុំមែនជាច្បាប់ដែលពិបាកយល់ឬក៏ជាច្បាប់នៅឆ្ងាយដាច់ស្រឡះពីយើងម្នាក់ៗនោះឡើយ ផ្ទុយទៅវិញគឺជាច្បាប់ដែលនៅជាប់ស្អិតនឹងជីវភាពយើងរាល់គ្នាជានិច្ច។ ដូច្នេះហើយបានជាយើងអាចសន្និដ្ឋានថាច្បាប់រដ្ឋប្បវេណីគឺជាច្បាប់មួយមានសារៈសំខាន់ជាទីបំផុត។

ឥឡូវចូរយើងនាំគ្នាក្រឡេកមើលអំពីទំនាក់ទំនងជាក់ស្តែងនៅក្នុងមួយជីវិតនៃមនុស្សជាមួយនឹងច្បាប់រដ្ឋប្បវេណីជាមុនសិន។ មនុស្សយើងម្នាក់ៗចាប់ពីថ្ងៃដែលមានកំណើតមកត្រូវបានទទួលស្គាល់ថាមានសិទ្ធិជាមូលដ្ឋាន (សមត្ថភាពទទួលសិទ្ធិ) សំរាប់រស់រាននៅក្នុងសង្គម របស់ខ្លួនរួចស្រេចទៅហើយ។ យើងអាចប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃទៅតាមឆន្ទៈរបស់ខ្លួនបង្កបង្កើតនូវទំនាក់ទំនងក្នុងសង្គមជាមួយអ្នកដទៃ (ការបង្ហាញឆន្ទៈ)បាន។ ប៉ុន្តែនៅក្នុងវ័យកុមារដោយពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើតចំណងផ្លូវច្បាប់ (សមត្ថភាពក្នុងការធ្វើសកម្មភាព) នៅឡើយនោះ ការបង្កើតទំនាក់ទំនងក្នុងសង្គមតាមរយៈឆន្ទៈកុមារត្រូវដាក់ឱ្យស្ថិតនៅក្រោមសេចក្តីគាំពារតាមរូបភាពមួយចាំបាច់ ដូចជាយោលទៅតាមសេចក្តីយល់ព្រមពីឪពុកម្តាយជាដើម (ការការពារជនដែលត្រូវបានកម្រិតសមត្ថភាព)។ បន្ទាប់មក មនុស្សយើងម្នាក់ៗក៏ចាប់មានរបស់របរប្រើប្រាស់ចាត់ចែងដោយសេរីទៅតាមចិត្តរបស់ខ្លួន (សិទ្ធិប្រត្យ័ក្ស) បន្តិចម្តងៗ។ ហើយនៅពេលធ្វើការសន្យា (កិច្ចសន្យា) ជាមួយអ្នកដ៏ទៃតាមការព្រមព្រៀងគ្នាដោយសេរីទៅតាមឆន្ទៈរៀងៗខ្លួន ដែលនឹងអាចបង្កើតបានជាអានុភាពច្បាប់ក្នុងកំរិតមួយ យើងនឹងអាចមានសិទ្ធិទាមទារ (សិទ្ធិលើបំណុល) ឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យាអនុវត្តសកម្មភាពអ្វីម៉្យាងបាន។ ក្រៅពីនេះ ក៏ប្រហែលជាមានអ្នកខ្លះពើបប្រទះនឹងគ្រោះថ្នាក់ចរាចរ ហើយទាមទារឱ្យសងការខូចខាតកើតចេញពីអំពើអនីត្យានុកូលក៏មាន។ ជាការពិតណាស់ មនុស្សលោកពុំមែនអស្ចារ្យឥតខ្ចោះ ហើយក៏ពុំមានជីវិតអមតៈនោះដែរ ដូច្នេះដើម្បីនឹងអាចប្តឹងទាមទារឱ្យគេធ្វើសកម្មភាពអ្វីមួយ ឬទាមទារសំណងពីអ្នកដទៃបាននោះ ក៏គង់ស្ថិតនៅក្រោមការកំណត់នៃពេលវេលាដែរ (អាជ្ញាយុកាល)។ ហើយជាទូទៅមនុស្សយើង ភាគច្រើននឹងជួបប្រសព្វគូស្រកររួមរស់ជាមួយគ្នា(អាពាហ៍ពិពាហ៍)ទៀត ។នៅពេលក្រោយរៀបការហើយគូស្វាមីភរិយាខ្លះក៏បង្កើតកូន (កូនបង្កើត) ហើយគូស្វាមីភរិយាខ្លះទៀតក៏សុំកូនគេមកចិញ្ចឹម(កូនចិញ្ចឹម)ដែរ។

បន្ទាប់ពីការប្រឹងប្រែងរស់អស់មួយជីវិត ហើយនៅពេលស្លាប់ទៅ ទ្រព្យសម្បត្តិទាំងអស់នឹងត្រូវធ្លាក់ទៅសហព័ទ្ធ និងកូនដែលជាអ្នកទទួលស្នងមតិក (សន្តតិកម្ម) ឬមួយក៏ត្រូវចាត់ចែងទៅតាមឆន្ទៈរបស់មតិកជនដែលបានសរសេរជាសំបុត្រស្នាមទុកជាមុនកាលគេនៅរស់ (មតិកសាសន៍ ឬបណ្តាំ)។

សេចក្តីរៀបរាប់ទាំងប៉ុន្មានខាងលើនេះ គឺជារង្វង់ការពារនៃច្បាប់រដ្ឋប្បវេណី (ពាក្យដែលសរសេរក្នុងវង់ក្រចកគឺជាវាក្យស័ព្ទក្នុងក្រមរដ្ឋប្បវេណី) ។ ខ្ញុំជឿថាយុវនិស្សិតនិងមិត្តអ្នកអានប្រាកដជានឹងយល់ថាច្បាប់រដ្ឋប្បវេណី ពិតជាច្បាប់ដែលជួយដោះស្រាយរឿងរ៉ាវនៃជីវភាពយើងម្នាក់ៗក្នុងសង្គមនេះមែន ។

## II. ទម្រង់ទូទៅនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន

### ១. ការបែងចែកជាគន្ថីនៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន

បើយើងបើកមើលសៀវភៅកម្រងច្បាប់របស់ប្រទេសជប៉ុន យើងឃើញថាក្នុងសៀវភៅភាគច្រើនគេប្រមូលច្បាប់ទាំងឡាយទាក់ទងនឹងរដ្ឋធម្មនុញ្ញ និងនីតិរដ្ឋបាល ដាក់នៅផ្នែកខាងមុខបន្ទាប់មកគឺជាច្បាប់ដែលទាក់ទងនឹងរដ្ឋប្បវេណី ។ ក្រមរដ្ឋប្បវេណី មានមាត្រាចំនួនជាងមួយពាន់គឺជាក្រមមួយធំដែលមានមាត្រាច្រើន ។ នេះក៏ព្រោះតែវាមានវិសាលភាពទូលំទូលាយ គ្របដណ្តប់លើជីវភាពរបស់យើងគ្រប់ៗគ្នាក្នុងសង្គម ។ ដោយហេតុថា មាត្រាភាគច្រើនចែងអំពីការយល់ដឹងជាទូទៅក្នុងសង្គម ដូច្នេះការចាប់ផ្តើមសិក្សាច្បាប់រដ្ឋប្បវេណីមិនចាំបាច់ត្រូវមានការបារម្ភអំពីបញ្ហាមាត្រាច្រើននោះទេ ។

ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនត្រូវបានរៀបរៀងឡើងដោយចែកចេញជា ៥ គន្ថី អំពីបទបញ្ញត្តិទូទៅ សិទ្ធិប្រត្យក្ស សិទ្ធិលើបំណុល ញាតិ និងសន្តតិកម្ម។ អាស្រ័យហេតុនេះ ក្នុងការសិក្សាគេនិយមឱ្យឈ្មោះគន្ថីចំនួន ៣ ខាងដើម ថាជាច្បាប់ស្តីពីទ្រព្យសម្បត្តិ ហើយឱ្យឈ្មោះ គន្ថី ២ ទៀតផ្នែកខាងចុងថាជាច្បាប់ស្តីពីគ្រួសារ ឬច្បាប់ស្តីពីឋានៈបុគ្គល។ បទបញ្ញត្តិទូទៅក្នុង គន្ថីទី ១ មានចំណងជើងហាក់ដូចជាទាក់ទងទៅនឹងក្រមរដ្ឋប្បវេណីទាំងមូលក៏ដោយ ក៏ប៉ុន្តែតាមពិតសេចក្តីនៅក្នុងគន្ថីទី ១ នេះពាក់ព័ន្ធទៅនឹងគន្ថីទី ២ និងទី ៣ ស្តីពីសិទ្ធប្រត្យក្ស និងសិទ្ធិលើបំណុលទៅវិញទេ ដូច្នេះត្រូវចាត់ទុកថាជាបទបញ្ញត្តិទូទៅដែលទាក់ទងនឹងច្បាប់ស្តីពីទ្រព្យសម្បត្តិទើបជាការសមស្រប។

នៅក្នុងសៀវភៅសិក្សានេះ ថ្វីត្បិតតែយើងផ្ដោតខ្លាំងលើការបកស្រាយច្បាប់ស្ដីពីទ្រព្យសម្បត្តិក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ក៏ខ្ញុំនឹងធ្វើការណែនាំឱ្យបានចប់អំពីផ្នែកនីតិគ្រួសារ (ដោយរាប់បញ្ចូលនូវអាពាហ៍ពិពាហ៍ កូនបង្កើត កូនចិញ្ចឹម សន្តតិកម្ម និងមតកសាសន៍ ដែលមានលើកជាឧទាហរណ៍នៅខាងលើ) ។

## ២. សិទ្ធិប្រត្យ័ក្ស និងសិទ្ធិលើបំណុល

ដូចបានរៀបរាប់ខាងលើស្រាប់ គន្ថីស្ដីពី "បទបញ្ញត្តិទូទៅ" កំណត់នូវបទបញ្ញត្តិទាំងឡាយដែលជាបញ្ញត្តិរួមសំរាប់គន្ថីស្ដីពី "សិទ្ធិប្រត្យ័ក្ស" និងគន្ថីស្ដីពី "សិទ្ធិលើបំណុល" (តួយ៉ាងដូចជាឧទាហណ៍ខាងលើដែលយើងឃើញថា សមត្ថភាពទទួលសិទ្ធិ ការការពារជនដែលត្រូវបានកម្រិតសមត្ថភាព ការបង្ហាញឆន្ទៈ ហើយនិងអាជ្ញាយុកាលជាដើម ត្រូវបានបញ្ចូលទៅក្នុងគន្ថីស្ដីពី បទបញ្ញត្តិទូទៅនេះឯង)។ ហើយគន្ថីស្ដីពី "សិទ្ធិប្រត្យ័ក្ស" កំណត់នូវ "សិទ្ធិគ្រប់គ្រងរបស់មនុស្ស ទៅលើវត្ថុដោយផ្ទាល់"។ កម្មសិទ្ធិគឺជារូបភាពតំណាងពេញលេញនៃសិទ្ធិប្រត្យ័ក្ស។ កម្មសិទ្ធិករអាចប្រើប្រាស់វត្ថុជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីទទួលចំណេញពីវត្ថុនេះ ហើយអាចមានសេរីភាពពេញទីក្នុងការចាត់ចែងទៀតផង។សិទ្ធិប្រត្យ័ក្សគឺជាសិទ្ធិដាច់ខាតនិងជាសិទ្ធិដែលអាចប្រកាសជាឧឡារិកបាននៅចំពោះមុខគ្រប់បុគ្គលទាំងអស់ (អាចបដិសេធប្រឆាំងនឹងរាល់អំពើរារាំង និងជ្រៀតជ្រែករបស់អ្នកដទៃបាន)។ ហេតុដូច្នេះហើយបានជាក្រមរដ្ឋប្បវេណីបានកំណត់នូវប្រភេទនៃសិទ្ធិប្រត្យ័ក្សនេះយ៉ាងច្បាស់លាស់ (គោលការណ៍កំណត់សិទ្ធិប្រត្យ័ក្សដោយច្បាប់) ហើយដែលយើងម្នាក់ៗមិនអាចបង្កើតនូវប្រភេទថ្មីដទៃផ្សេងទៀតនៃសិទ្ធិប្រត្យ័ក្សនេះទៅតាមទំនើងចិត្តបានឡើយ។ បន្ថែមពីលើនេះ នៅផ្នែកខាងចុងនៃគន្ថីស្ដីពី "សិទ្ធិប្រត្យ័ក្ស" ច្បាប់មិនកំណត់ត្រឹមតែ "សិទ្ធិកាន់កាប់ទ្រព្យ" ប៉ុណ្ណោះទេ គឺថែមទាំងបានចែងអំពីមធ្យោបាយសំរាប់រក្សាធានាសិទ្ធិលើបំណុលដែលអាចទាមទារចំពោះបុគ្គលដទៃទៀតបានដោយកំណត់អំពីសិទ្ធិប្រត្យ័ក្សដែលយកមកធ្វើជា "ប្រាតិភោគ" សំរាប់គ្រប់គ្រងលើតម្លៃដោះដូរនៃវត្ថុ (ឧទាហរណ៍ គេអាចយកវត្ថុដាក់ធានាជាប្រាតិភោគនេះ ទៅលក់ឡាយឡុងហើយប្រមូលលុយមកវិញ បើសិនជាកូនបំណុលមិនអាចសងប្រាក់កម្ចីមកវិញបានទេនោះ)។ បន្ទាប់មក នៅផ្នែកខាងដើមនៃគន្ថីស្ដីពី "សិទ្ធិលើបំណុល" ច្បាប់បានកំណត់នូវលក្ខណៈផ្សេងៗរបស់សិទ្ធិលើបំណុលនេះ និងអំពីដំណើរការចាប់ពីការបង្កើត សិទ្ធិលើបំណុលរហូតដល់ការ

វលត់នៃសិទ្ធិនេះទេវិញ (ផ្នែកនេះជា"បទបញ្ញត្តិទូទៅ"នៃគន្ថីស្តីពី សិទ្ធិលើបំណុលដែលគេនិយម យកមកបកស្រាយក្នុងមេរៀនអំពីទ្រឹស្តីរួមនៃសិទ្ធិលើបំណុល)។ រីឯផ្នែកខាងចុងនៃគន្ថីស្តីពីសិទ្ធិលើ បំណុលវិញគេបានកំណត់នូវបុព្វហេតុដែលនាំឱ្យកើតមានសិទ្ធិលើបំណុលនេះ (គេបកស្រាយអំពី បញ្ហានេះក្នុងមេរៀនស្តីពីទ្រឹស្តីលំអិតនៃសិទ្ធិលើបំណុល)។ សិទ្ធិលើបំណុលគឺជា "សិទ្ធិដែលបុគ្គល ម្នាក់ដែលអាចទាមទារបុគ្គលម្នាក់ទៀតឱ្យបំពេញនូវកិច្ចការជាក់លាក់អ្វីមួយ"។ ប៉ុន្តែ យើងសង្កេត ឃើញថាបុព្វហេតុនៃការកកើតសិទ្ធិលើបំណុលនេះ មានចែកចេញជា ៤ ប្រភេទ ហើយបុព្វហេតុ ដែលធំជាងគេបំផុតនោះគឺ កិច្ចសន្យា (ក្រៅពីនេះ មានអំពើអនីត្យានុកូលជាដើម)។ សិទ្ធិលើបំណុល មានអានុភាពទៅលើតែភាគីជាដៃគូប៉ុណ្ណោះទេ។ តាមរយៈភ្ជាប់កិច្ចសន្យាជាមួយគ្នាដោយសេរី យើងម្នាក់ៗអាចកំណត់សេចក្តីផ្សេងៗនៅក្នុងសិទ្ធិលើបំណុលនេះបានដោយសេរី (ឱ្យតែមិនមាន លក្ខណៈប្រឆាំងនឹងសង្គមទេនោះ) (នេះជាគោលការណ៍ សេរីភាពនៃកិច្ចសន្យា និងជាលក្ខណៈ នៃសិទ្ធិលើបំណុលដែលអាចបង្កើតឡើងបានដោយសេរី) ។

## ៣. កំណើត និងដំណើរវិវត្តនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន

ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ ១៨៩៦ ហើយចូលជាធរមាន នៅឆ្នាំ ១៨៩៨។ ផ្នែកនីតិគ្រួសារ (ចាប់ពីមាត្រា ៧២៥) ត្រូវបានធ្វើវិសោធនកម្មទាំងស្រុងនៅឆ្នាំ ១៩៤៧ បន្ទាប់ពីការបញ្ចប់សង្គ្រាមលោកលើកទីពីរមក។ ប៉ុន្តែ ចំពោះច្បាប់ស្តីពីទ្រព្យ ដែលមាន ក្នុងគន្ថីចំនួន ៣ នៅផ្នែកខាងដើមវិញ (រាប់ដល់មាត្រា ៧២៤) គឺសឹងតែបានរក្សាភាពដើមដូចពេល ប្រកាសឱ្យប្រើនោះ រហូតមកទល់ពេលថ្មីៗនេះ (ហេតុដូច្នេះ មាត្រាទាំងអស់នោះធ្លាប់បានរក្សា ពាក្យពេចន៍និងលំនាំសរសេរតាមបែបបុរាណ)។ នៅទីបំផុត គេបានកែប្រែពាក្យពេចន៍ និងលំនាំ សរសេរទាំងអស់នៃគន្ថីទាំង ៣ នោះទៅតាមភាសាសម័យបច្ចុប្បន្ននៅឆ្នាំ ២០០៤។

ការបែងចែកជាគន្ថី ដោយដាក់បទបញ្ញត្តិទូទៅនៅផ្នែកខាងដើមបង្អស់នេះ គឺយកតាមលំនាំ ក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ (ពោលឱ្យត្រឹមត្រូវគឺតាមសេចក្តីព្រាងនៃក្រមនោះ) មានឈ្មោះ ហៅថាប្រព័ន្ធផាន់ដេកទេន (Pandekten)។ ក៏ប៉ុន្តែ មិនអាចនិយាយបានថា ខ្លឹមសារនៅក្នុងក្រម រដ្ឋប្បវេណីនៃប្រទេសជប៉ុនដូចគ្នានឹងក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ទាំងស្រុងនោះទេ។ ជា

ទូទៅយើងអាចពោលបានថា ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន បានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ផង និងក្រមរដ្ឋប្បវេណីរបស់ប្រទេសបារាំងផង សឹងតែថាពាក់កណ្ដាលម្នាក់ ។ ហើយមានចំណុចខ្លះ យើងឃើញយ៉ាងច្បាស់នូវឥទ្ធិពលពីក្រមរដ្ឋប្បវេណីនៃប្រទេសបារាំង ខ្លាំងជាងឥទ្ធិពល ពីក្រមនៃប្រទេសអាល្លឺម៉ង់ទៅទៀត។

ក្រមរដ្ឋប្បវេណីសម័យទំនើបដែលបានរៀបចំឡើងដំបូងបង្អស់ក្នុងប្រទេសជប៉ុន សព្វថ្ងៃនេះគេឱ្យឈ្មោះថាជាក្រមចាស់នោះ បានត្រូវរៀបរៀងឡើងដោយនីតិវិទូបារាំងឈ្មោះ ប៊័ស្សូណាដ (Gustave Emil Boissonade) ដែលរដ្ឋាភិបាលមីជីជំនាន់នោះបានជួលមក។ លោកបានចងក្រងតាមលំនាំក្រមរដ្ឋប្បវេណីនៃប្រទេសបារាំង (ក្រមណាប៉ូឡេអុងឆ្នាំ ១៨០៤) (នៅក្នុងការចងក្រងនេះលោកក៏បានលើកយកក្រមរដ្ឋប្បវេណីនៃបទេសអ៊ីតាលី និងក្រមរដ្ឋប្បវេណីនៃប្រទេសដទៃទៀតដែលអនុវត្តតាមប្រព័ន្ធច្បាប់បារាំងនោះរួមជាមួយនឹងយុត្តិសាស្ត្រច្បាប់និងទ្រឹស្ដីសិក្សាផ្សេងៗដែលបានមកពីការអនុវត្តក្រមរដ្ឋប្បវេណីនៃប្រទេសបារាំង ប្រមាណពាក់កណ្ដាលសតវត្សមកហើយ នោះមកពិចារណាផងដែរ។ រីឯផ្នែកស្ដីពីនីតិគ្រួសារវិញ គឺត្រូវបានព្រាងឡើងដោយសមាជិកជនជាតិជប៉ុនក្នុងគណៈកម្មការរៀបចំសេចក្ដីព្រាង)។ ក្រមរដ្ឋប្បវេណីចាស់ (ដែលបានប្រកាសឱ្យប្រើជាដំបូងនៅឆ្នាំ ១៨៩០) បានត្រូវពន្យាពេលហើយព្យួរចោលមិនបានយកមកអនុវត្តទេ បន្ទាប់ពីមានការវិវាទចំរូងចំរាស់កើតឡើងទាក់ទងនឹងក្រមនោះ។ ហើយក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនសព្វថ្ងៃនេះ ត្រង់គន្ថីពី ១ ដល់ ៣ នៅផ្នែកខាងដើម គឺជាផ្នែកកែប្រែនៃច្បាប់ចាស់ ។ ការកែប្រែនេះត្រូវបានអនុវត្តឡើងដោយយោងតាមគំរូនៃសេចក្ដីព្រាងក្រមរដ្ឋប្បវេណីនៃប្រទេស អាល្លឺម៉ង់ដែលមានលក្ខណៈថ្មីជាងគេនាពេលនោះ។ ថ្វីត្បិតតែការបែងចែកជាគន្ថីមានរូបភាពដូចក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ក៏ដោយក៏ខ្លឹមសារភាគច្រើននៅរក្សាអត្ថបទដើមនៃក្រមរដ្ឋប្បវេណីចាស់របស់លោក ប៊័ស្សូណាដ ដដែល ។ ពាក់ព័ន្ធក្នុងការកែប្រែនេះ មានលោក ហូហ្ស៊ូមុិ ណូប៊ូស៊ីហ្គេ (Hozumi Nobushige) (ជនជាតិជប៉ុនដំបូងបង្អស់ដែលទទួលបានការអនុញ្ញាតិឱ្យប្រកបវិជ្ជាជីវៈជាមេធាវីប្រចាំតុលាការនៅប្រទេសអង់គ្លេស) ជាមួយគ្នានឹងលោក អ៊ូមេ ខេនជីរ៉ូ (Ume Kenjiro) និងលោក តូមី ម៉ាសាអាគីរ៉ា (Tomii Masaakira) ដែលធ្លាប់ទៅសិក្សានៅប្រទេសបារាំង ។ ហើយលោកទាំង ៣ នាក់នេះគឺជាសមាជិកនៃគណៈកម្មការរៀបចំសេចក្ដីព្រាង ។

# III. ឋានៈនៃក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ទាំងមូល

## ១. ក្រមរដ្ឋប្បវេណីក្នុងឋានៈជាច្បាប់មូលដ្ឋាននៃនីតិឯកជន

បន្ទាប់មកនេះ យើងក្រឡេកមកមើលឋានៈនៃក្រមរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ទាំងមូលម្តង។ នៅក្នុងលោកយើងនេះមានច្បាប់ច្រើនបែបច្រើនយ៉ាងណាស់ តួយ៉ាងដូចជារដ្ឋធម្មនុញ្ញ ឬច្បាប់រដ្ឋបាលជាដើម ដែលនិយាយសរុបទៅគឺជាច្បាប់ទាក់ទងទៅនឹងរបបគ្រប់គ្រងរដ្ឋ ឬទំនាក់ទំនងរវាងរដ្ឋនិងបុគ្គល ដែលគេឱ្យឈ្មោះថា នីតិសាធារណៈ ។ ផ្ទុយទៅវិញ ច្បាប់ដែលកំណត់នូវទំនាក់ទំនងក្នុងជីវភាពរស់នៅរវាងបុគ្គលនិងបុគ្គល ត្រូវបានគេហៅថានីតិឯកជន ។ ជាការប្រាកដណាស់ដែលថា តាមផ្លូវច្បាប់ សហគមន៍មួយដូចជាក្រុមហ៊ុនជាដើម ដែលប្រព្រឹត្តសកម្មភាពផ្សេងៗត្រូវបានច្បាប់ចាត់ទុកដូចជាបុគ្គលដែរ ដោយឱ្យឈ្មោះថាជា នីតិបុគ្គល ។ ដូចនេះ ច្បាប់ពាណិជ្ជកម្មដែលកំណត់នូវបទបញ្ញត្តិទាក់ទងទៅនឹងក្រុមហ៊ុន ក៏ត្រូវរាប់បញ្ចូលថាជានីតិឯកជនដែរ ។ ថ្វីត្បិតតែមានច្បាប់ជាច្រើននៅក្នុងវិស័យនីតិឯកជនក៏ពិតមែន ក្រមរដ្ឋប្បវេណីនៅតែគឺជាគ្រឹះមូលដ្ឋាននៃច្បាប់ទាំងអស់នោះ ហើយត្រូវចាត់ទុកថាជាច្បាប់មូលដ្ឋាននៃនីតិឯកជន ។

## ២. ច្បាប់ទូទៅ និងច្បាប់ពិសេស

តើពាក្យនេះមានន័យដូចម្តេចដែរ? ឥឡូវយើងនាំគ្នាពិចារណានូវឧទាហរណ៍មួយស្តីពីការដែលយើងសន្យាគ្នាទិញនិងលក់វត្ថុមួយដោយបង់ប្រាក់។ សកម្មភាពនេះបានត្រូវក្រមរដ្ឋប្បវេណីចាត់ទុកថាជាកិច្ចសន្យាលក់។ ជាបឋម បទបញ្ញត្តិទាំងឡាយទាក់ទងដល់កិច្ចសន្យាលក់នេះ ត្រូវបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។ ក៏ប៉ុន្តែប្រសិនបើអ្នកធ្វើកិច្ចសន្យាជាអ្នកជំនួញ ឬក៏ក្រុមហ៊ុន ហើយការលក់ដូរនេះគឺសំរាប់អាជីវកម្មរបស់អ្នកជំនួញ ឬក្រុមហ៊ុននោះ ថ្វីត្បិតតែកិច្ចសន្យាលក់នេះមានលក្ខណៈដូចគ្នានឹងកិច្ចសន្យាលក់ខាងលើក៏ដោយ ក៏វាត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ពាណិជ្ជកម្ម។ ជាឧទាហរណ៍មួយទៀត ចូរយើងពិនិត្យអំពីករណីរបស់អ្នកលក់ដែលបានមកលក់ទំនិញដល់ផ្ទះយើងម្នាក់ៗជាប្រជារាស្ត្រសាមញ្ញ ហើយបានធ្វើឱ្យមានកិច្ចសន្យាលក់រវាងយើង និងអ្នកលក់នោះ។ ទោះបីនេះជាការលក់ដូចខាងលើក៏ដោយ ក៏កិច្ចសន្យានេះត្រូវស្ថិតនៅក្នុងវង្វង់នៃ

ការអនុវត្តន៍ច្បាប់ស្តីពីការជួញដូរតាមវិធីដោយឡែក (ច្បាប់ស្តីពីការដើរលក់ទំនិញតាមផ្ទះមុនការធ្វើវិសោធនកម្មនាឆ្នាំ២០០០)។ ដូច្នេះថ្វីត្បិតតែជាការទិញលក់ធម្មតាក៏ដោយបើគូភាគីជាពាណិជ្ជករសុទ្ធសាធគឺគេត្រូវអនុវត្តច្បាប់ពាណិជ្ជកម្ម ហើយបើការទិញលក់បានត្រូវធ្វើឡើងក្នុងរូបភាពជាការដើរលក់ទំនិញតាមផ្ទះនិមួយៗវិញគឺគេត្រូវអនុវត្តច្បាប់ស្តីពីការជួញដូរតាមវិធីដោយឡែក។ នៅក្នុងកាលៈទេសៈនេះ ពាក់ព័ន្ធទៅនឹងការទិញនិងការលក់ ក្រមរដ្ឋប្បវេណីមានតួនាទីជាច្បាប់ទូទៅ ចំណែកច្បាប់ពាណិជ្ជកម្ម និងច្បាប់ស្តីពីការជួញដូរតាមវិធីដោយឡែក គឺជាច្បាប់រដ្ឋប្បវេណីពិសេស។ ច្បាប់ពិសេសមានអាទិភាពទៅលើច្បាប់ទូទៅជាដរាប ។ នេះគឺជា វិធានដែលអនុវត្តនៅគ្រប់វិស័យច្បាប់ទាំងមូល។ ពោលគឺមានន័យថាជាបឋមគេត្រូវអនុវត្តច្បាប់ពិសេសជាមុនសិន ហើយវៀរលែងតែគ្មានបទបញ្ញត្តិនៅក្នុងច្បាប់ពិសេសនោះទេ ទើបត្រូវងាកមកអនុវត្តបទបញ្ញត្តិជាមូលដ្ឋាននៅក្នុងច្បាប់ទូទៅ។ បានសេចក្តីថា ចំពោះឧទាហរណ៍ខាងលើនេះ ប្រសិនបើគ្មានបទបញ្ញត្តិចែងក្នុងច្បាប់ពាណិជ្ជកម្មទេនោះគេត្រូវត្រឡប់មករកគោលការណ៍ពីក្នុងក្រមរដ្ឋប្បវេណីវិញ។ ហើយប្រសិនបើគេអនុវត្តច្បាប់ស្តីពីការជួញដូរតាមវិធីដោយឡែកប្រទះនឹងចំណុចដែលពុំមានចែងជាបទបញ្ញត្តិទេនោះគេត្រូវប្រើបទបញ្ញត្តិស្តីពីការលក់វត្ថុដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។តាមរយៈឧទាហរណ៍ខាងលើ យើងឃើញថាក្រមរដ្ឋប្បវេណី គឺជាច្បាប់មូលដ្ឋានក្នុងវិស័យនីតិឯកជន ហើយជាគ្រឹះសំរាប់វិធានជាច្រើន និងជា ប្រភពនៃគោលគំនិតទាំងឡាយនៅក្នុងវិស័យនីតិឯកជន ។ ហេតុដូច្នេះ ដើម្បីសិក្សាអំពីនីតិឯកជនឱ្យបានសំរេចផល គឺគេពិតជាត្រូវចាប់ផ្តើមពីការសិក្សាក្រមរដ្ឋប្បវេណីនេះ ។

ជាការពិតណាស់ដែលថា ការពន្យល់ទាំងអម្បាលមាណខាងលើពុំមែនមានន័យថា ការសឹក្សាក្រមរដ្ឋប្បវេណីមានប្រៀបជាងការសឹក្សាច្បាប់ពាណិជ្ជកម្ម។ល។ នោះទេ ព្រោះថាក្រមរដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្ម មានលក្ខណៈពិសេសដោយឡែកទីទៃពីគ្នា។ ច្បាប់ពាណិជ្ជកម្មប្រកបទៅដោយកំរិតបច្ចេកទេសខ្ពស់ជាងក្រមរដ្ឋប្បវេណី ហើយមានការលូតលាស់យ៉ាងរហ័សទៅតាមដំណើរវិវត្តន៍នៃបែបបទធ្វើជំនួញនៅក្នុងវិស័យពាណិជ្ជកម្មទៀតផង។ រីឯក្រមរដ្ឋប្បវេណីវិញយើងពុំឃើញមានសក្តានុពលលោតផ្លោះរបៀបនេះឡើយ។ ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណីមានលក្ខណៈជាច្បាប់មូលដ្ឋាន ហើយជាគ្រឹះនៃគោលគំនិតនៅក្នុងច្បាប់ពិសេសជាច្រើន ដូច្នេះក្រម

នេះមានលក្ខណៈមិនត្រូវផ្លាស់ប្តូរប្រែប្រួលញឹកញយទេ (វាអាចកែប្រែបាន លុះត្រាតែមានការប្រែប្រួលយ៉ាងខ្លាំងក្នុងសង្គម)។ អាស្រ័យហេតុនេះ ច្បាប់នីមួយៗរមែងមានចរិត និងគោលគំនិតផ្សេងៗពីគ្នា ដែលតម្រូវឱ្យយើងសិក្សាសំរបទៅតាមនោះជាដរាប ។

## IV. លក្ខណៈពិសេសនៃក្រមរដ្ឋប្បវេណី

## ~គោលការណ៍ស្វ័យភាពខាងឆន្ទៈ(ស្វ័យភាពនៃបុគ្គលឯកជន)~

### ១. គោលការណ៍ស្វ័យភាពខាងឆន្ទៈ និងគោលការណ៍សេរីភាពនៃកិច្ចសន្យា

នៅទីនេះ យើងលើកយកលក្ខណៈពិសេសចំបងរបស់ក្រមរដ្ឋប្បវេណីមកពិចារណាម្តង ។ ដូចបានរៀបរាប់រួចមកហើយថា អ្វីដែលក្រមរដ្ឋប្បវេណីចាត់ទុកថាមានសារៈសំខាន់បំផុតនោះ គឺ "ឆន្ទៈ"របស់យើងម្នាក់ៗដែលជាភាគីក្នុងរឿងរដ្ឋប្បវេណី ។ ពោលគឺយើងម្នាក់ៗដែលជាពលរដ្ឋមិនមែនរស់ដោយគោរពតាមវិធានដែលអ្នកដទៃបានកំណត់ឱ្យនោះទេ ។ យ៉ាងហោចណាស់ក៏នៅក្នុងការកសាង "ទំនាក់ទំនងជីវភាពរវាងបុគ្គលនិងបុគ្គល" យើងនឹងបង្កើតវិធានទៅតាមឆន្ទៈរបស់ខ្លួន ហើយគ្រប់គ្រងជីវភាពរបស់ខ្លួនដោយខ្លួនឯងដែរ ។ នេះត្រូវចាត់ទុកថាជាឧត្តមគតិរបស់យើង ។ នេះគេហៅថា គោលការណ៍ស្វ័យភាពខាងឆន្ទៈ ឬហៅថាគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ។ ជាការជាក់ស្តែង វិធាននីមួយៗ (ដែលទាក់ទងទៅនឹងសិទ្ធិលើបំណុល) អាចបង្កើតឡើងបានដោយសេរី កុំឱ្យតែប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អនៅក្នុងសង្គម ។ នេះគេឱ្យឈ្មោះថាជា "គោលការណ៍សេរីភាពនៃកិច្ចសន្យា" ។

លើសពីនេះទៅទៀត គេពុំត្រឹមតែអាចបង្កើតវិធានបានដោយសេរីប៉ុណ្ណោះទេ វិធាននេះនឹងមានតួនាទីជំនួសច្បាប់ ហើយមានអាទិភាពលើបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីថែមទៀត នៅក្នុងទំនាក់ទងរវាងភាគីដែលបានបង្កើតវិធាននេះឡើង ។ ឧទាហរណ៍ដូចជាក្នុងជម្លោះស្តីពីកិច្ចសន្យាលក់ជាដើម ក្រមរដ្ឋប្បវេណីមានបញ្ញត្តិសំរាប់ដោះស្រាយបញ្ហាថា "តើគេត្រូវធ្វើយ៉ាងណាបើសិនជាបន្ទាប់ពីបានទិញវត្ថុហើយ គេរកឃើញមានវិការៈនៅលើវត្ថុដែលពីមុនគេមើលមិនឃើញទេនោះ?" ។ នេះគេហៅថាជាការទទួលខុសត្រូវក្នុងការធានាវិការៈ ។ ទាក់ទងដល់ការទទួលខុសត្រូវក្នុងការធានាវិការៈនេះ មាត្រា ៥៧០ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា បើសិនជាបន្ទាប់

ពីបានទិញវត្ថុហើយ គេរកឃើញមានវិការៈនៅលើវត្ថុដែលពីមុនគេមើលមិនឃើញទេនោះ អ្នកទិញអាចទាមទារសំណងចំពោះការខូចខាត ឬក៏រំលាយកិច្ចសន្យាចោលបាន ក្នុងកំឡុងពេលមួយឆ្នាំបន្ទាប់ពីបានប្រទះឃើញវិការៈនោះ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើនៅក្នុងកិច្ចសន្យារបស់ខ្លួន គូភាគីបានសន្យាគ្នាខុសពីបទបញ្ញត្តិនៃមាត្រាដែលបានរៀបរាប់ខាងលើនោះ គឺកិច្ចសន្យានឹងមានអាទិភាពជាង ។ ពោលគឺ វៀរលែងតែគ្មានការសន្យាផ្សេងពីនេះទេ ទើបគេអាចយកបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមកអនុវត្តបាន ។ ដើម្បីឱ្យបានយល់ច្បាប់ជាងនេះ យើងអាចលើកឧទាហរណ៍មួយទៀតបានដោយឧបមាថា មានការលក់ទំនិញបញ្ចុះថ្លៃជាដើម ក្នុងករណីដែលយើងយល់ព្រមទិញអាវមួយមានបិទផ្លាកថា "មានការខូចខាតខ្លះ តែពុំអាចទទួលការដូរ ឬសងវិញបានទេ" នោះមានន័យថា ក្នុងការលក់និងការទិញនេះ គូភាគីបានព្រមព្រៀងគ្នាឱ្យរួចពីការទទួលខុសត្រូវក្នុងការធានាវិការៈរួចទៅហើយ ។ កិច្ចសន្យាលក់បែបនេះពុំមានប៉ះពាល់នឹងបញ្ហាអ្វីទេ ហើយមានសុពលភាពពេញលេញ ។

## ២. បទបញ្ញត្តិតាមការស្មគ្រ័ចិត្ត និងបទបញ្ញត្តិដោយបង្ខំ

អ្នកអានខ្លះប្រហែលជាយល់ថា យោងទៅតាមឧទាហរណ៍ខាងលើ គេពុំដឹងគួរធ្វើដូចម្ដេចទេក្រៅពីគោរពតាមឆន្ទៈនៃគូភាគីក្នុងការបដិសេធមិនអនុវត្តតាមច្បាប់ណាមួយនោះ ក៏ប៉ុន្តែសូមបញ្ជាក់ថាពុំមែនសុទ្ធតែដូច្នេះទេ ។ បើគូភាគីបានកំណត់នូវវិធានអ្វីមួយហើយ វិធាននោះនឹងត្រូវយកមកអនុវត្ត ប៉ុន្តែចំពោះចំណុចណាដែលមិនបានកំណត់នោះ គេត្រូវយកបទបញ្ញតិនៃច្បាប់រដ្ឋប្បវេណីមកអនុវត្តដើម្បីបំពេញភាពខ្វះចន្លោះ ។ ឧទាហរណ៍ដូចជាក្នុងករណីថាបានកំណត់តម្លៃទំនិញមែន ប៉ុន្តែពុំបានសំរេចថាតើអ្នកណាជាអ្នកត្រូវបង់ថ្លៃឈ្នួលដឹកទំនិញទេ ឬក៏ថានៅពេលប្រទះឃើញមានវិការៈ (ស្លាកស្នាម) នៅលើទំនិញ តើគេត្រូវសំរេចយ៉ាងណានោះជាដើម ។

អាស្រយ័ហេតុនេះ បទបញ្ញត្តិដែលអនុញ្ញាតឱ្យសេចក្ដីព្រមព្រៀងរបស់គូភាគីមានអាទិភាពជាងសេចក្ដីចែងនៅក្នុងមាត្រានៃច្បាប់រដ្ឋប្បវេណីនេះ គេហៅថាបទបញ្ញត្តិតាមការស្មគ្រ័ចិត្ត ។ ផ្ទុយទៅវិញ ចំពោះបទបញ្ញត្តិដែលកំណត់ថា ទោះជាគូភាគីបានព្រមព្រៀងគ្នាកំណត់យកតាមវិធានផ្សេងយ៉ាងណាក្ដី ក៏ពុំអាចប្ដូរសារន័យនៅក្នុងមាត្រានៃច្បាប់បានជាដាច់ខាតទេនោះ គេ

ឱ្យឈ្មោះថាជាបទបញ្ញត្តិដោយបង្ខំ ។ នៅក្នុងផ្នែកច្បាប់ស្តីពីសិទ្ធិលើបំណុលនៃក្រមរដ្ឋប្បវេណី មានបទបញ្ញត្តិតាមការស្មគ្រ័ចិត្តជាច្រើន ។ ជាការពិតណាស់ដែលថានៅក្នុងក្រមរដ្ឋប្បវេណី មានគូយ៉ាងដូចជាការចែងអំពីប្រភេទនៃសិទ្ធិប្រត្យ័ក្សជាដើម ដែលជាសិទ្ធិផ្តាច់មុខអនុញ្ញាតឱ្យគេអាចប្រកាសនូវសិទ្ធិគ្រប់គ្រងវត្ថុដាច់ខាត តតាំងនឹងគ្រប់តតិយជនទាំងអស់លើលោកនេះបាននោះ បើបណ្តោយឱ្យមនុស្សម្នាក់ៗអាចកំណត់សិទ្ធិដ៏ខ្លាំងនេះបានតាមតែទំនើងចិត្តខ្លួននោះ វានឹងនាំឱ្យអ្នកជិតខាងរងអំពល់ដោយសារខ្លួនជាពុំខាន ។ ដូច្នេះយើងម្នាក់ៗមិនអាចចេះតែបង្កើតវិធានណាដែលខុសពីមាត្រាក្នុងច្បាប់បានតាមចិត្តឡើយ (គេហៅថាជា "គោលការណ៍កំណត់សិទ្ធិប្រត្យ័ក្សដោយច្បាប់") ។ ប៉ុន្តែ យ៉ាងហោចណាក៏នៅក្នុងផ្នែកសំខាន់ៗនៃច្បាប់ស្តីពីសិទ្ធិលើបំណុល បទបញ្ញត្តិទាំងឡាយដែលមានចែងក្នុងកម្រងច្បាប់ មិនមែនសុទ្ធតែមានន័យដាច់ខាតនោះទេ ។

នេះគឺខុសគ្នាទាំងស្រុងទៅនឹងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់ចរាចរផ្លូវគោក ។ ល ។ ដែលជាពពួកច្បាប់នៅក្នុងវិស័យនីតិសាធារណៈ ។ ចូរយើងលើកឧទាហរណ៍ច្បាប់ចរាចរមកនិយាយ ។ ច្បាប់នេះបានកំណត់ឱ្យមនុស្សគ្រប់គ្នាឈប់ដើរនៅពេល "ឃើញភ្លើងពណ៌ក្រហម" ហើយ "បើឃើញភ្លើងពណ៌ខៀវត្រូវបន្តដំណើរទៅមុខ"។ ដូច្នេះប្រជាពលរដ្ឋរាល់រូបត្រូវតែគោរពតាមជាដាច់ខាតបើពុំនោះទេ គេមិនអាចរក្សាសណ្តាប់ធ្នាប់ចរាចរបាន ហើយនឹងបណ្តាលឱ្យមានគ្រោះថ្នាក់ពាសពេញប្រទេសជាពុំខាន ។ ហេតុនេះ ជាការពិតណាស់ដែលយើងម្នាក់ៗមិនអាចកំណត់ដាក់ពណ៌ខៀវឱ្យឈប់ហើយដាក់ពណ៌ក្រហមឱ្យទៅបានតាមស្រេចតែចិត្តនោះទេ ។ ក៏ប៉ុន្តែ ចំពោះក្រមរដ្ឋប្បវេណី ជាពិសេសត្រង់ច្បាប់ស្តីពីសិទ្ធិលើបំណុលវិញ មានកន្លែងខ្លះ"វិធានដែលគូភាគីបានបង្កើតនោះមានអានុភាពខ្លាំងជាងច្បាប់" ប៉ុន្តែនេះមិនមានន័យថា "មិនគោរពច្បាប់" នោះទេ ។

ចំពោះបញ្ហាពាក់ព័ន្ធរវាងបុគ្គលនិងច្បាប់ ច្បាប់មិនមានឋានៈជាអំណាចដាច់ខាតទៅលើបុគ្គលទេ ។ ប៉ុន្តែច្បាប់រក្សាទុកសេរីភាពទូលំទូលាយឱ្យបុគ្គលអាចបង្កើតវិធានផ្សេងៗ យោលទៅតាមឆន្ទៈរបស់ខ្លួន លើកលែងតែក្នុងករណីដែលមិនមានការបង្កើតវិធានដោយបុគ្គលនោះទេ ទើបគេយកច្បាប់មកអនុវត្តដើម្បីជួយបំពេញការខ្វះចន្លោះ ។ នេះគឺជាលក្ខណៈពិសេសជាចំបងនៃក្រមរដ្ឋប្បវេណី (ផ្នែកស្តីពីសិទ្ធិលើបំណុល) ។ ជាការធម្មតាទេដែលសេរីភាពក្នុងការបង្កើតវិធាននេះមានតែក្នុងទំនាក់ទំនងរវាងគូភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ពោលគឺសេរីភាពនៅតែក្នុងវង្វង់ពិភព

មួយដ៏តូច ។ ថ្វីត្បិតតែនៅក្នុងពិភពដ៏តូចដូច្នេះដ៏ដោយ បច្ចុប្បន្ននេះដោយហេតុថាមានកើតឡើងនូវបញ្ហាបាត់បង់សមភាពរវាងបុគ្គលនិងបុគ្គលនោះ គេត្រូវការបញ្ចូលបន្ថែមនូវគោលការណ៍កែតម្រូវខ្លះផងដែរ (ការដាក់កំរិតលើគោលការណ៍សេរីភាពនៃកិច្ចសន្យា) ។ ក៏ប៉ុន្តែ ក្នុងការសិក្សាក្រមរដ្ឋប្បវេណី គេចាំបាច់ត្រូវតែផ្តោតអារម្មណ៍ទៅលើគោលគំនិតជាមូលដ្ឋានរបស់ក្រមនេះ ដែលមានតួនាទីជួយបំពេញភាពខ្វះចន្លោះទៅលើវិធានដែលបុគ្គលបានបង្កើត ។

## V. សេចក្តីសង្ខេប - គោលគំនិតក្នុងការសិក្សាក្រមរដ្ឋប្បវេណី

ជាការពិតណាស់ក្រមរដ្ឋប្បវេណីគឺជាច្បាប់ដែលមានវិធានកំណត់ច្បាស់លាស់។ ពោលគឺជាវិធានដែល"មានខ្លឹមសារជាស្នូល"របស់ខ្លួន។ ក៏ប៉ុន្តែវិធានទាំងនេះ មានតិចតួចណាស់បើប្រៀបទៅនឹងច្បាប់ផងទាំងពួង។នៅក្នុងផ្នែកស្តីពីបទបញ្ញត្តិទូទៅនិងសិទ្ធិប្រត្យក្សយើងឃើញថាវិធានទាំងនេះមានអត្ថន័យសំខាន់ណាស់ដែរ។ ប៉ុន្តែចំពោះផ្នែកទាក់ទងនឹងកិច្ចសន្យាក្នុងច្បាប់ស្តីពីសិទ្ធិលើបំណុលវិញយើងអាចពោលបានថាបទបញ្ញត្តិទាំងឡាយនោះគ្រាន់តែជាការប្រមូលផ្តុំនូវវិធាននៃការបង្កើតកិច្ចសន្យាផ្សេងៗ ដែលមានជាទំលាប់អនុវត្តន៍ហូរហែពីមុនមកហើយបានដាក់បញ្ចូលទៅក្នុងក្រមដើម្បីកំណត់ជាបទដ្ឋានសំរាប់ធ្វើការវិនិច្ឆ័យលើការសំរេចឆន្ទៈរបស់គូភាគីតែប៉ុណ្ណោះ។ ប្រសិនបើមានឆន្ទៈរបស់គូភាគីច្បាស់លាស់គេត្រូវគោរពនូវឆន្ទៈនោះ ហើយប្រសិនបើឆន្ទៈនោះមិនច្បាស់លាស់ទេ គេត្រូវយកបទបញ្ញត្តិទាំងឡាយនៅក្នុងច្បាប់ដែលត្រូវបានសន្មត់តាមធម្មតាថាជាឆន្ទៈរបស់ភាគីនៃកិច្ចសន្យានោះមកអនុវត្ត ។ ត្រង់នេះហើយដែលគេមិន ដាក់វិធានបង្ខិតបង្ខំទេ ។

ដូច្នេះ យើងអាចនិយាយបានថា ចំណុចសំខាន់ក្នុងការសិក្សាក្រមរដ្ឋប្បវេណី មិនមែនការ"ទន្ទេញឱ្យចាំរត់មាត់នូវអ្វីៗដែលជាវិធានត្រូវគោរពជាដាច់ខាត"នោះទេ ប៉ុន្តែយើង"ត្រូវពិនិត្យពិចារណាអំពីខ្លឹមសារនៃវិធានផ្សេងៗ ដែលមានចែងជាបទដ្ឋានសំរាប់ការថ្លឹងថ្លែងរកយុត្តិធម៌ជូនភាគីដែលពាក់ព័ន្ធ" ។

ខ្ញុំសូមបញ្ចប់លំនាំសិក្សានៅទីនេះ ។ តទៅទៀត យើងនឹងចាប់ផ្តើមសិក្សាអំពីខ្លឹមសារនៃក្រមរដ្ឋប្បវេណី ។

# ជំពូកទី ២

# បទបញ្ញត្តិទូទៅ

# នៃ

# ក្រមរដ្ឋប្បវេណី

I. ចរិតលក្ខណៈនៃបទបញ្ញត្តិទូទៅ និងលំដាប់លំដោយក្នុងការសិក្សា

II. ចំពោះការសិក្សាបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី

១) ចំណុចសំខាន់ៗនៃបទបញ្ញត្តិទូទៅ និងលំដាប់សិក្សា

២) បញ្ញត្តិដំបូងនៃបទបញ្ញត្តិទូទៅ

III. ការសិក្សាចំណុចសំខាន់ៗក្នុងបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី

១) ការសំដែងឆន្ទៈ និងសកម្មភាពគតិយុត្ត

២) ការការពារជនដែលត្រូវបានកំរិតសមត្ថភាព

៣) ការបង្ហាញឆន្ទៈប្រកបដោយបញ្ហា

៤) តំណាង តំណាងគ្មានសិទ្ធិ តំណាងដែលមានលក្ខណៈជារូបភាព

៥) មោឃភាព និងការលុបចោល

៦) ល័ក្ខខ័ណ្ឌ និងការកំណត់ពេល

៧) អាជ្ញាយុកាល

៨) នីតិបុគ្គល

៩) លំនៅដ្ឋាន និងការបាត់ខ្លួន

# I. ចរិតលក្ខណៈនៃបទបញ្ញត្តិទូទៅ និងលំដាប់លំដោយក្នុងការសិក្សា

ជំពូកមុនបានរៀបរាប់អំពីរចនាសម្ព័ន្ធរៀបរៀងក្រមរដ្ឋប្បវេណី និងបានពន្យល់ថាក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ត្រូវបានចែកចេញជា ៥ គន្ថី ដែលមាន បទបញ្ញត្តិទូទៅ សិទ្ធិប្រត្យក្ស សិទ្ធិលើបំណុល ញាតិ និងសន្តតិកម្ម។ ហើយចំពោះគន្ថីទាំង ៥ នេះ ក្នុងការសិក្សា គេហៅគន្ថី ៣ នៅផ្នែកខាងដើមថាជា ច្បាប់ស្តីពីទ្រព្យសម្បត្តិចំណែកឯគន្ថី ២ នៅផ្នែកខាងចុងត្រូវបានហៅថាជាច្បាប់ស្តីពីគ្រួសារ ឬច្បាប់ស្តីពីឋានៈបុគ្គល។ នៅត្រង់នេះ ក៏មានការអធិប្បាយថាបទបញ្ញត្តិទូទៅក្នុងគន្ថីទី ១ មានចំណងជើងហាក់ដូចជាទាក់ទងទៅនឹងក្រមរដ្ឋប្បវេណីទាំងមូលក៏ដោយ ក៏ប៉ុន្តែតាមពិតសេចក្តីនៅក្នុងគន្ថីទី ១ នេះពាក់ព័ន្ធទៅនឹងគន្ថីទី ២ និងទី ៣ ស្តីពី សិទ្ធប្រត្យក្ស និងសិទ្ធិលើបំណុលទៅវិញទេ ដូច្នេះត្រូវចាត់ទុកថាជាបទបញ្ញត្តិទូទៅដែលទាក់ទងនឹងច្បាប់ស្តីពីទ្រព្យសម្បត្តិទើបជាការសមស្រប។ ដូច្នេះ យើងអាចគិតថាតាមលំដាប់លំដោយក្នុងការសិក្សាគេត្រូវចាប់ផ្តើមពីបទបញ្ញត្តិទូទៅនេះមុន (ក្នុងសៀវភៅសិក្សា គេនិយមហៅថា បទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី) ទើបជាការសមហេតុសមផល។ ហើយតាមការពិតនៅតាមមហាវិទ្យាល័យជាច្រើន គេបានរៀបចំកម្មវិធីសិក្សាស្របតាមវិធីនេះ។ ក៏ប៉ុន្តែ មានបញ្ហាពិបាកមួយ គឺថាការសិក្សាក្រមរដ្ឋប្បវេណីដោយចាប់ផ្តើមពីបទបញ្ញត្តិទូទៅនេះមិនសូវជាទីជក់ចិត្តប៉ុន្មានទេ។ ខ្ញុំមានអារម្មណ៍បែបនេះ ចាប់តាំងពីពេលនៅជានិស្សិតនៅឡើយ។ សព្វថ្ងៃនេះ ក៏មាននិស្សិតចំនួនមិនតិចទេដែលបានរៀបរាប់អំពីការចាប់អារម្មណ៍នេះ។ ហើយរឿងនេះ មិនមែនថាគ្មានហេតុផលសមស្របទេ ។

ក្នុងជំពូកមុន មានការរៀបរាប់ហើយថា ការចែកជាគន្ថី ដោយកំណត់បទបញ្ញត្តិទូទៅនៅខាងដើមនេះ គឺជាការយកតាមទម្រង់របស់ក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ (ពោលឱ្យត្រឹមត្រូវគឺយកតាមសេចក្តីព្រាងនៃក្រមនោះ) មានឈ្មោះហៅថាប្រព័ន្ធផាន់ដេកទេន (Pandekten) ។ នៅពេលដែលតាក់តែងក្រមរដ្ឋប្បវេណីបច្ចុប្បន្ននៃប្រទេសជប៉ុន កាលពីចុងសតវត្សទី ១៩ (ជាការកែសំរួលលើក្រមរដ្ឋប្បវេណីចាស់របស់លោក បឺស្សូណាដ) នោះ គេបានអនុមតិយកតាមប្រព័ន្ធចែកគន្ថី ដែលមានក្នុងសេចក្តីព្រាងក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ ដែលកំពុងត្រូវបានរៀបចំឡើងជាក្រមរដ្ឋប្បវេណីទំនើបបំផុតនាសម័យនោះ (ប៉ុន្តែក្នុងជំពូកមុនក៏មានការរៀបរាប់រួចហើយដែរគឺគេមិនអាចនិយាយបានថា ខ្លឹមសារនៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនមានភាពដូចគ្នានឹង

ក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ទាំងស្រុងនោះទេ។ ជាទូទៅ យើងអាចពោលបានថា ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន បានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ផង និងក្រមរដ្ឋប្បវេណីរបស់ប្រទេសបារាំងផង សឹងតែថាពាក់កណ្តាលម្នាក់។ ហើយមានចំណុចខ្លះ យើងឃើញយ៉ាងច្បាស់នូវឥទ្ធិពលពីក្រមរដ្ឋប្បវេណីនៃប្រទេសបារាំង ជាងក្រមនៃប្រទេសអាល្លឺម៉ង់ទៅទៀត)។ ជាការប្រាកដណាស់ ប្រព័ន្ធកំណត់បទបញ្ញត្តិរួមនៅផ្នែកខាងដើមនៃក្រមនេះ មាន លក្ខណៈស្របតាមតក្កវិជ្ជាមែន។ប៉ុន្តែបើសិនជាគេត្រូវសិក្សាអំពីបទបញ្ញត្តិទូទៅនេះជាមេរៀនដំបូងនោះគឺបានសេចក្តីថា ជាការសិក្សាអំពីបទបញ្ញត្តិរួមមុននឹងមានចំណេះយល់ដឹងអំពីរបៀបដោះស្រាយបញ្ហាជាក់ស្តែងនីមួយៗទៅទៀត។ ដូច្នេះ និស្សិតក៏មិនមានជំរើសអ្វីក្រៅអំពីការចាប់អារម្មណ៍ថាការបកស្រាយមេរៀនខ្វះភាពជាក់ស្តែង ហើយជាការសិក្សាដែលមិននាំមកឱ្យមានការយល់ដឹងអំពីភាពពិតជាក់ស្តែងទេ ។

ដើម្បីជៀសវាងនូវបញ្ហានេះ មានមតិមួយយល់ឃើញថា ការចាប់ផ្តើមពីមេរៀនទាក់ទងនឹងកិច្ចសន្យា (ពោលគឺសិទ្ធិលើបំណុល) ដែលជាប្រភពនាំមកឱ្យមានទំនាក់ទំនងនៃសិទ្ធិក្នុងរូបភាពជាក់ស្តែង ដូចបានធ្លាប់លើកឡើងនៅក្នុងជំពូកមុនសំរាប់បកស្រាយអំពីចំណុចពិសេសបំផុតនៃក្រមរដ្ឋប្បវេណីនោះ គឺជាវិធីដែលធ្វើឱ្យស្រួលយល់ ហើយប្រកបដោយភាពជាក់ស្តែងផង ។ គេនឹងសិក្សាអំពីបញ្ហានៃកិច្ចសន្យាក្នុងការលក់និងការទិញនូវវត្ថុអ្វីមួយ ហើយទន្ទឹមនឹងពេលនោះធ្វើការសិក្សាបន្តិចម្តងៗអំពីខ្លឹមសារដែលមានចែងក្នុងបទបញ្ញត្តិទូទៅ ដែលប្រើរួមសំរាប់ទាំងសិទ្ធិប្រត្យ័ក្សនិងសិទ្ធីលើបំណុលផងនោះ (ខ្ញុំធ្លាប់សរសេរសៀវភៅមួយក្បាល់ មានចំណងជើងថា "ចំណុចចាប់ផ្តើមនៃសិទ្ធិលើបំណុល" នៅ ១៩៩៥ ដែលជាសៀវភៅសំរាប់ចាប់ផ្តើមសិក្សាក្រមរដ្ឋប្បវេណីដោយយកតាមគំនិតខាងលើនេះ )។ ប៉ុន្តែ ទោះជាយើងនិយាយយ៉ាងនេះក៏ដោយ កុំថាឡើយក្នុងមុខវិជ្ជាសិក្សាអំពីរឿងរដ្ឋប្បវេណីនៅក្នុងសាលានិតិសាស្ត្រនៃមហាវិទ្យាល័យ សូម្បីតែក្នុងសាលាសេដ្ឋកិច្ច និងសាលាពាណិជ្ជសាស្ត្រក៏គេកំណត់យកបទបញ្ញត្តិទូទៅទុកជាផ្នែកទីមួយដែរ ។ ហេតុដូច្នេះ បើសិនជាក្នុងករណីដែលនិស្សិតទាំងឡាយត្រូវរៀនក្រមរដ្ឋប្បវេណី ដោយផ្អែកតាមកម្មវិធីសិក្សារបស់សាលានោះ គឺមានតែវិធីសិក្សាដោយចាប់ផ្តើមពីបទបញ្ញត្តិទូទៅនេះទេ ដែលអាចជៀសវាងបាននូវការខាតបង់ពេលវេលា។ ម្ល៉ោះហើយ ក្នុងជំពូកនេះ ខ្ញុំនឹងបកស្រាយមេរៀន

ដោយយកចិត្តទុកដាក់លើបញ្ហាថា តើយើងត្រូវចាប់អារម្មណ៍លើចំណុចណា ហើយត្រូវសិក្សាតាមលំដាប់បែបដូចម្តេច ដើម្បីឱ្យមានការងាយយល់និងចាប់ចិត្តបាន បើសិនណាយើងត្រូវសិក្សាក្រមរដ្ឋប្បវេណីដោយចាប់ផ្តើមពីបទបញ្ញត្តិទូទៅនេះ ។

វាមានពីចំណុច។ ទីមួយ បើយើងយកតាមអ្វីដែលបានសរសេរខាងលើ ហើយគិតបញ្ច្រាសមកវិញ យើងយល់ថាយើងត្រូវសិក្សាបទបញ្ញត្តិទូទៅដោយជានិច្ចកាលនឹកគិតដល់ឧទាហរណ៍ជាក់ស្តែង។ ទីពីរ យើងត្រូវធ្វើការសិក្សាដោយស្វែងយល់ថា តើបទបញ្ញត្តិរួមទាំងនេះ មានសារៈសំខាន់និងឋានៈយ៉ាងណាដែរនៅក្នុងក្របខ័ណ្ឌនៃក្រមរដ្ឋប្បវេណីទាំងមូល។ ប៉ុន្តែ ទោះជានិយាយយ៉ាងនេះក៏ដោយ តាមពិតទៅ សៀវភៅសិក្សាអំពីបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ដែលមានការចាប់អារម្មណ៍គ្រប់គ្រាន់លើចំណុចទាំងពីរនេះហាក់ដូចជាមិនមានច្រើនទេ។ ហេតុដូច្នេះជាបន្តទៅទៀត ខ្ញុំនឹងធ្វើការបញ្ជាក់បំភ្លឺអំពីលំដាប់លំដោយ និងភាពចាំបាច់។ល។ ក្នុងការសិក្សាអំពីបទបញ្ញត្តិទូទៅតាមដែលខ្ញុំយល់ឃើញ ហើយទន្ទឹមគ្នានោះ ខ្ញុំនឹងសាកល្បងធ្វើការបកស្រាយដោយយកចិត្តទុកដាក់អំពីចំណុចទាំងពីរដែលបានជំរាបជូនខាងលើ។ ជាការជាក់ស្តែង ខ្ញុំនឹងធ្វើការបកស្រាយពន្យល់ ដោយលើកឡើងជាឧទាហរណ៍អំពីកិច្ចសន្យាលក់នៅក្នុងបរិបទផ្សេងៗជាច្រើនតាមដែលអាចធ្វើទៅបាន ។

# II. ចំពោះការសិក្សាបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី

## ១. ចំណុចសំខាន់ៗនៃបទបញ្ញត្តិទូទៅ និងលំដាប់សិក្សា

ខ្ញុំសូមរំលឹកមកវិញនូវអត្ថន័យនៃជំពូកទី ១ ស្តីពីលំនាំសិក្សា។ ក្រមរដ្ឋប្បវេណីផ្តល់អាទិភាពទីមួយទៅលើគោលការណ៍ស្វ័យភាពនៃឆន្ទៈរបស់យើងម្នាក់ៗ។ អាស្រ័យហេតុនេះ ក្នុងចំណោមបញ្ញត្តិទាំងឡាយនៃគន្ថីស្តីពីបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី យើងត្រូវសិក្សាអំពីបញ្ហាដូចតទៅ ។ ទី១ "សមត្ថភាពក្នុងការបង្ហាញឆន្ទៈ" របស់បុគ្គលម្នាក់ៗ ហើយនិង "សមត្ថភាពក្នុងការអនុវត្តសកម្មភាពនានាដែលបង្កើតជាទំនាក់ទំនងតាមផ្លូវច្បាប់ជាមួយអ្នកដទៃ" ។ ក្នុងចំណុចនេះ ចំពោះ

ជនដែលគ្មានសមត្ថភាពធ្វើការវិនិច្ឆ័យដោយខ្លួនឯង គេមានវិធានការជួយការពារដល់ជនទាំងនោះ ដោយអាស្រ័យលើអ្នកដ៏ទៃផ្សេងទៀតដែលជួយបំពេញបង្គ្រប់ការបង្ហាញឆន្ទៈ ។

ទី២ បញ្ហាផ្សេងៗដែលកើតមានឡើងពីការភ្ជាប់ទំនាក់ទំនងគតិយុត្ត តាមរយៈការបង្ហាញឆន្ទៈទៅវិញទៅមក រវាងជនដែលមានសមត្ថភាពធ្វើការវិនិច្ឆ័យដោយខ្លួនឯង ។ នេះអាចជាផ្នែកដែលមានសារៈសំខាន់ជាងគេបំផុត នៅក្នុងគន្ថីស្តីពីបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី ។ ពីព្រោះផ្នែកនេះចាប់ផ្តើមពីបញ្ញត្តិចែងអំពីសកម្មភាពគតិយុត្ត ដែលអាចនាំឱ្យកើតមានឡើងនូវអនុភាពច្បាប់ស្របតាមគោលបំណងដើម សំរេចដោយអំណាចនៃឆន្ទៈដែលបុគ្គលបានបង្ហាញឱ្យឃើញនោះ ។ ហើយនឹងមានបញ្ញត្តិចែងអំពីវិធីដោះស្រាយរាល់បញ្ហាផ្សេងៗ ដែលចោទថាតើគេត្រូវធ្វើយ៉ាងដូចម្តេចក្នុងករណីនៃជនណាម្នាក់ ដែលថ្វីត្បិតតែគេមានសមត្ថភាពធ្វើការវិនិច្ឆ័យដោយខ្លួនឯងក៏ដោយ តែបានបង្ហាញឆន្ទៈរបស់ខ្លួនដោយសារការភ័ន្តច្រឡំ (កំហុស) ឬក៏ត្រូវបានអ្នកដទៃបោកឱ្យបង្ហាញឆន្ទៈដែលខុសពីចិត្តគំនិតដើមរបស់ខ្លួន (ការឆបោក) (ជាឧទាហរណ៍ជាក់ស្តែង វិធីដោះស្រាយគឺមានការចែងជាបញ្ញត្តិស្តីពីអានុភាពនៃការចាត់ទុកជាមោឃៈ ឬការលុបចោល ។ នៅទីនេះពាក្យថា "អានុភាព" ដែលមានប្រើក្នុងក្រមរដ្ឋប្បវេណីជាដើម គឺសំដៅទៅលើលទ្ធផលអ្វីម៉្យាងដែលកើតមានឡើងក្នុងករណីអនុវត្តបទបញ្ញត្តិ ឬរបបច្បាប់ណាមួយនោះ មិនមែនសំដៅលើបញ្ហាប្រសិទ្ធិភាពនៃច្បាប់ទេ) ។ ក្រៅពីនេះ ក៏មានការចែងនូវបញ្ញត្តិទាក់ទងនឹងការបង្ហាញឆន្ទៈជំនួសអ្នកដទៃទៀតផងដែរ ដែលហៅថាជារបបអ្នកតំណាង ។

ទី៣ បញ្ហាពាក់ព័ន្ធនឹងអាជ្ញាយុកាល ។ ដោយហេតុថាអាជ្ញាយុកាលនេះកើតមានចំពោះសិទ្ធិប្រត្យ័ក្សផង និងចំពោះសិទ្ធិលើបំណុលផងនោះ ក្រមរដ្ឋប្បវេណីបានកំណត់បញ្ញត្តិរួមស្តីពីអាជ្ញាយុកាលនេះ នៅក្នុងបទបញ្ញត្តិទូទៅ ។ ហើយនិង ទី៤ បញ្ហាពាក់ព័ន្ធនឹងនីតិបុគ្គល ។ តាមពិតទៅ បញ្ញត្តិពាក់ព័ន្ធនឹងបញ្ហានេះមានកំរិតស្មុគស្មាញហួសពីបញ្ញត្តិដទៃទៀតនៅក្នុងបទបញ្ញត្តិទូទៅ ដែលសូម្បីតែនិស្សិតទូទៅនៃសាលានិតិសាស្ត្រក៏ដោយ ក៏ខ្ញុំយល់ថាគប្បីទុកវាធ្វើជាមេរៀនចុងក្រោយក្នុងការសិក្សាអំពីបទបញ្ញត្តិទូទៅនេះទើបប្រសើរ ។ ក៏ប៉ុន្តែចំពោះនិស្សិតនៃសាលាសេដ្ឋកិច្ច ឬសាលាពាណិជ្ជសាស្ត្រដែលសិក្សាអំពីសហគ្រាស និងចំពោះជនទាំងឡាយដែលមានចំណាប់អារម្មណ៍ខ្លាំងទៅលើច្បាប់ទាក់ទងនឹងពាណិជ្ជកម្មវិញ ប្រហែលជាអាចចាប់យល់អំពីផ្នែកនេះងាយ

ស្រួលជាងនិស្សិតនៅសាលាច្បាប់ក៏មិនដឹង ។ ដោយគិតថា វានឹងមានទំនាក់ទំនងជាប់ទៅនឹងការសិក្សានាអនាគតផងនោះ យើងគួរទុកផ្នែកនេះសំរាប់សិក្សាឱ្យបានហ្មត់ចត់នៅទីចុងក្រោយ ។

## ២. បញ្ញត្តិដំបូងនៃបទបញ្ញត្តិទូទៅ

បន្ទាប់ពីបានចាំទុកក្នុងចិត្តនូវចំណុចសំខាន់ៗសំរាប់សិក្សាហើយ ខ្ញុំនឹងលើកយកបញ្ញត្តិចែងជាដំបូងនៅក្នុងបទបញ្ញត្តិទូទៅ ពោលគឺមាត្រាទី ១ និងមាត្រាទី ២ នៃក្រមរដ្ឋប្បវេណី មកពន្យល់ត្រួសៗទុកជាមុនសិន ។ នៅទីនេះ មានចែងជាបញ្ញត្តិផ្តល់ជាមនោគតិ និងបញ្ញត្តិជាមូលដ្ឋានហើយមានលក្ខណៈជាទូទៅ សំរាប់យកមកអនុវត្តនៅក្នុងករណីដែលបញ្ញត្តិដ៏ទៃទៀតពុំអាចដោះស្រាយបញ្ហាឱ្យបានដាច់ស្រឡះតែឯងទេនោះ ។ បទបញ្ញត្តិផ្តល់ជាមនោគតិ (ដែលមានចែងក្នុងមាត្រា ១ កថាខ័ណ្ឌទី ១ ថា "សិទ្ធិឯកជនត្រូវអនុវត្តឱ្យបានស្របទៅតាមសុខមាលភាពសាធារណៈ" និងមាត្រា ២ ថា "ច្បាប់នេះ ត្រូវបកស្រាយក្នុងគោលបំណងគោរពភាពថ្លៃថ្នូររបស់បុគ្គលនិងភាពស្មើគ្នាពិតប្រាកដរវាងជនទាំងពីរភេទ") ទាំងនេះមានសារៈសំខាន់ ប៉ុន្តែពុំសូវទាក់ទងនឹងការបកស្រាយជាក់ស្តែងប៉ុន្មានទេ។ ត្រង់នេះ ពាក្យថាសិទ្ធិឯកជនត្រូវអនុវត្តឱ្យបានស្របទៅតាមសុខមាលភាពសាធារណៈ គឺជាការអះអាងថា ការទទួលនិងអនុវត្តសិទ្ធិរបស់បុគ្គលដោយសេរីគួរតែសម្របសម្រួលទៅនឹងការរីកចំរើនសមស្របរបស់សង្គម ប៉ុន្តែពុំមែននិយាយថាអំណាចសាធារណៈអាចប្រើដើម្បីកំរិតសិទ្ធិរបស់បុគ្គលនោះទេ ។ ចំណែកមាត្រា ២ វិញ គឺជាបញ្ញត្តិដែលចាំបាច់ត្រូវចែងទុក ។

រីឯបញ្ញត្តិជាមូលដ្ឋានហើយមានលក្ខណៈជាទូទៅ ពោលគឺ មាត្រា ១ កថាខ័ណ្ឌទី ២ ដែលឈរលើគោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់ និងមាត្រា ១ កថាខ័ណ្ឌទី ៣ ដែលជាបញ្ញត្តិឈរលើគោលការណ៍ទាក់ទងនឹងការប្រើសិទ្ធិដោយបំពានវិញ គឺនិយាយអំពីទ្រឹស្តីទូទៅ (ហៅថា "មាត្រាទូទៅ") ។ នាពេលបកស្រាយជាក់ស្តែង មាត្រានេះរមែងយកមកអនុវត្តជាវិធីបកស្រាយចុងក្រោយបង្អស់ ដើម្បីសម្រួលកិច្ចការនៅក្នុងករណីដែលបញ្ញត្តិជាក់លាក់នីមួយៗពុំអាចដោះស្រាយបញ្ហាចប់សព្វគ្រប់បាន (ឧទាហរណ៍ដូចជាការអះអាងថា "នៅក្នុងស្ថានភាពយ៉ាងនេះ មិនត្រូវអនុញ្ញាតឱ្យប្រើច្បាប់ដោយវិធីនេះបានទេ ព្រោះវាមានលក្ខណៈប្រឆាំងនឹងគោលការណ៍នៃភាព

សុចរិតនិងភាពស្មោះត្រង់" ឬក៏ថា "នៅក្នុងស្ថានភាពនេះ មិនត្រូវអនុញ្ញាតឱ្យប្រើសិទ្ធិបែបនេះបានទេ ព្រោះវាជាការប្រើសិទ្ធិដោយបំពាន") ។ ជាពិសេសនៅក្នុងការអនុវត្តជាក់ស្តែង គោលការណ៍នៃភាពសុចរិត (គោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់) ត្រូវបានយកមកបកស្រាយជាញឹកញយ ហើយចោទជាបញ្ហាសំខាន់ខ្លះ ដូចជាថាតើគេគប្បីពឹងផ្អែកទៅលើ "មាត្រាទូទៅ" នេះដល់កំរិតណានៅក្នុងការអនុវត្តតាមបច្ចេកទេសច្បាប់? នៅទីនេះ យើងសិក្សាត្រឹមតែឱ្យបានយល់ជាសង្ខេបប៉ុណ្ណោះសិន ។

សូមបញ្ជាក់ថា មាត្រា ១ និង មាត្រា ២ នេះ បានត្រូវដាក់បញ្ចូលជាដំបូងនៅក្នុងគន្ថីស្តីពីបទបញ្ញត្តិទូទៅ នាពេលមានការកែប្រែទាំងមូលនូវគន្ថីទី ៤ និងគន្ថីទី ៥ នៃក្រមរដ្ឋប្បវេណីនៅឆ្នាំ ១៩៤៧ ។ ពេលនោះ គេបានចែងជាមាត្រា ១ និងមាត្រា ១ ភាគ ២ ប៉ុន្តែតាមរយៈនៃការកែសម្រួលពាក្យពេចន៍ប្តូរជាភាសាបច្ចុប្បន្នក្នុងឆ្នាំ ២០០៤ គេបានប្តូរមកជាមាត្រា ១ និង មាត្រា ២ វិញ ។(ក្នុងការបន្ថែមមាត្រាថ្មីនេះ ដើម្បីចៀសវាងការលោតលេខរៀងនៃមាត្រាដទៃទៀតក្នុងក្រមទាំងមូលទើបគេសំរេចបង់លេខជាមាត្រា ១ ភាគ ២ ដូច្នោះ ។ មាត្រា ១ នៃក្រមរដ្ឋប្បវេណីនាពេលអនុម័តដំបូងក្នុងឆ្នាំ ១៨៩៦ ដែលចែងថា "សិទ្ធិឯកជនត្រូវទទួលបានចាប់ផ្តើមពីពេលចាប់កំណើត" នោះ បានក្លាយទៅជាមាត្រា ៣ កថាខ័ណ្ឌទី ១ នៃក្រមបច្ចុប្បន្ន) ។

# III. ការសិក្សាចំណុចសំខាន់ៗក្នុងបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី

## ១. ការបង្ហាញឆន្ទៈ និងសកម្មភាពគតិយុត្ត

បន្តទៅនេះ យើងនឹងលើកយកចំណុចសំខាន់ៗដែលត្រូវសិក្សាជាចាំបាច់នៅក្នុងបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី មកធ្វើអត្ថាធិប្បាយទៅតាមលំដាប់លំដោយនៃលំនាំសិក្សាដូចដែលយើងបានរៀបរាប់ស្រាប់ (ថ្វីត្បិតតែមានការខុសគ្នាបន្តិចបន្តួចពីលំដាប់លេខរៀងនៃមាត្រាក្នុងក្រមរដ្ឋប្បវេណីក៏ដោយ) ។

## ១.១. ការបង្ហាញឆន្ទៈ

ជាដំបូង យើងនាំគ្នាសិក្សាជាមុនសិននូវពាក្យថា *ការបង្ហាញឆន្ទៈ* ដែលប្រើជាញឹកញយនៅក្នុងក្រមរដ្ឋប្បវេណី ។ ការប្រាប់ ឬបង្ហាញ ចេតនារបស់ខ្លួនទៅដៃគូ ក្នុងការព្យាយាមបង្កើតជាទំនាក់ទំនងជាក់លាក់តាមផ្លូវច្បាប់នោះ ហៅថាជា *ការបង្ហាញឆន្ទៈ* ។ ចូរចងចាំថា ការណ៍ដែលក្នុងក្រមរដ្ឋប្បវេណីហៅថាជា ការបង្ហាញឆន្ទៈ នោះ គឺសំដៅលើអ្វីដែលមានអានុភាពក្នុងការបង្កើតឡើងជាទំនាក់ទំនងផ្លូវច្បាប់ស្របទាំងស្រុងទៅតាមឆន្ទៈដែលត្រូវបានបង្ហាញ ។ ដូច្នេះ មិនមែនថារាល់ការប្រាប់នូវអ្វីៗដែលខ្លួនយល់ឃើញទៅដៃគូទាំងប៉ុន្មាន សុទ្ធតែជាការបង្ហាញឆន្ទៈ ក្នុងន័យនៃក្រមរដ្ឋប្បវេណីនោះទេ ។ ឧទាហរណ៍ថា យើងបានពោលពាក្យពេចន៍ស្នេហារៀបរាប់នូវមនោសញ្ចេតនាទៅសង្សាររបស់ខ្លួន នៅពេលនោះ ទោះបីជាយើងបាននិយាយដោយមានការសំរេចចិត្តមោះមុតយ៉ាងណាក៏ដោយ ទាំងនេះមិនមែនមានន័យថាជាការបង្ហាញឆន្ទៈដូចដែលបានធ្វើអត្ថាធិប្បាយនោះទេ ។ ផ្ទុយទៅវិញ ក្នុងករណីដែលយើងបានហុចប្រាក់ ១000 រៀលទៅឱ្យម្ចាស់តូបលក់អីវ៉ាន់នៅឯស្ថានីយ៍រតភ្លើង ហើយនិយាយថា "ឱ្យស្ករនេះមកខ្ញុំ" នេះគឺជាការបង្ហាញឆន្ទៈដ៏គ្រប់លក្ខណៈ ។ ពីព្រោះថា វាជាសំណើដើម្បីបង្កើតកិច្ចសន្យាទិញស្ករក្នុងតំលៃ ១000 រៀល ប្រសិនបើអ្នកលក់យល់ព្រមតាមសំណើនេះ គឺកិច្ចសន្យាត្រូវបានបង្កើតឡើង ហើយចំណងជាផ្លូវច្បាប់ក៏នឹងកើតមានឡើងរវាងអ្នកលក់និងអ្នកទិញ នាំមកឱ្យមានកាតព្វកិច្ចនិងសិទ្ធិលើបំណុលរវាងភាគីទាំងពីរ ។ មានន័យថា សំណើទិញស្ករក្នុងតម្លៃ ១000 រៀលក៏ជាការបង្ហាញឆន្ទៈ ហើយការយល់ព្រមលក់តាមសំណើនេះក៏ជាការបង្ហាញឆន្ទៈដែរ ។ ហើយចំពោះការបង្ហាញឆន្ទៈតាមរយៈសំបុត្រស្នាមជាដើម នឹងចាត់ទុកថាមានអានុភាពចាប់ពីពេលដែលសំបុត្រនោះទៅដល់ភាគីដែលជាដៃគូ (គោលការណ៍ផ្ញើដល់ ។ មាត្រា ៩៧ កថាខ័ណ្ឌទី ១) ។

## ១.២. សកម្មភាពគតិយុត្ត

បន្ទាប់មកទៀត យើងសិក្សាអំពីពាក្យថា *សកម្មភាពគតិយុត្ត* ម្តង។ ពាក្យនេះយើងរមែងប្រទះជាញឹកញយនៅក្នុងការសិក្សាក្រមរដ្ឋប្បវេណី ក៏ប៉ុន្តែមិនមែនជាពាក្យដែលពិបាកយល់ណាស់ទេ ។ *សកម្មភាពគតិយុត្ត* ត្រូវយកការបង្ហាញឆន្ទៈដែលមានរៀបរាប់ខាងលើមកធ្វើជាធាតុផ្សំ

ពោលគឺជា សកម្មភាព ដែលបង្កើតឱ្យមានអនុភាពតាមផ្លូវច្បាប់ ដោយអនុលោមទៅតាមឆន្ទៈដែលត្រូវបានបង្ហាញ ។ អាស្រ័យហេតុនេះ តួយ៉ាងដូចជា *កិច្ចសន្យា* ដែលបានរៀបរាប់ខាងលើ ត្រូវចាត់ទុកថាជា*សកម្មភាពគតិយុត្ត* ។ ចំពោះកិច្ចសន្យា ដោយមានការសុខចិត្តទិញវត្ថុនេះក្នុងតំលៃប៉ុណ្ណេះ និងសុខចិត្តលក់វត្ថុនេះថ្លៃប៉ុណ្ណេះ គឺជាសកម្មភាពគតិយុត្តកើតឡើងដោយសារការបង្ហាញឆន្ទៈពីរ មកពីទិសផ្ទុយគ្នា ហើយបានរមូលល្អួតជាមួយគ្នា ។ ក្រៅពីនេះនៅមានសកម្មភាពគតិយុត្តដែលជា សកម្មភាពឯកតោភាគីផងដែរ តួយ៉ាងដូចជាមតិកសាសន៍ជាដើម ។ គេហៅសកម្មភាពនេះថាជា សកម្មភាពឯកតោភាគី ពីព្រោះថាអនុភាពតាមផ្លូវច្បាប់នឹងកើតឡើងដោយស្របទាំងស្រុងទៅតាមឆន្ទៈនៃម្ចាស់បណ្តាំ ដែលបានបង្ហាញតែម្នាក់ឯង នៅក្នុងសំបុត្របណ្តាំរបស់ខ្លួនថា នឹងប្រគល់វត្ថុទៅឱ្យអ្នកនេះ ឬអ្នកនោះ ។ រួចហើយនៅមានប្រភេទមួយទៀតក្នុងសកម្មភាពគតិយុត្តគឺ សកម្មភាពរួម ។ សកម្មភាពនេះ ឧបមាដូចជាការមូលមតិគ្នារវាងបុគ្គលច្រើនរូប ដែលបានបង្ហាញឆន្ទៈផ្សេងៗក្នុងគោលបំណងតែមួយដូចគ្នា ដើម្បីបង្កើតក្រុមហ៊ុនជាដើម ។ ដូច្នេះ ពាក្យថាសកម្មភាពគតិយុត្តនេះ សំដៅទៅលើកិច្ចសន្យាផង សកម្មភាពឯកតោភាគីផង និងសកម្មភាពរួមផង ក៏ប៉ុន្តែភាគច្រើនគឺនិយាយអំពីកិច្ចសន្យា ។ ដូច្នេះហើយយើងឃើញថា ថ្វីត្បិតតែយើងកំពុងស្ថិតនៅក្នុងដំណាក់កាលសិក្សាអំពីបញ្ញត្តិសំខាន់ៗនៅក្នុងបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីក៏ដោយ ជាការជាក់ស្តែង យើងជៀសមិនផុតពីការគិតដល់បញ្ហានៃកិច្ចសន្យានៅក្នុងច្បាប់ស្តីពីកាតព្វកិច្ចនោះទេ ។

## ១.៣. សកម្មភាពគតិយុត្តផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ

ដូចបានរៀបរាប់រួចហើយថា យោលទៅតាមគោលការណ៍សេរីភាពនៃកិច្ចសន្យា យើងរាល់គ្នាអាចកំណត់ខ្លឹមសារនៃកិច្ចសន្យា និងបង្កើតនូវសិទ្ធិលើបំណុលផ្សេងៗ បានដោយសេរីក៏ពិតមែន ក៏ប៉ុន្តែមិនអាចភ្ជាប់កិច្ចសន្យាដែលមានន័យប្រឆាំងនឹងសង្គមបានឡើយ ។ ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីបានកំណត់ក្នុងមាត្រា ៩០ នៃគន្ថីស្តីពីបទបញ្ញត្តិទូទៅ ដោយចែងថាសកម្មភាពគតិយុត្តណាដែលមានគោលបំណងផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ នឹងត្រូវចាត់ទុកជាមោឃៈ ។ ក្នុងការគិតពិចារណាអំពីឧទាហរណ៍ជាក់ស្តែង ស្តីពីការផ្ទុយនឹងមាត្រា ៩០ នេះ

គប្បីយកចិត្តទុកដាក់ប្រុងប្រយ័ត្នថា សកម្មភាពដូចជាការជក់គ្រឿងញៀនជាដើម គឺពិតជាការប្រឆាំងនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ក៏ប៉ុន្តែនេះមិនមែនជាសកម្មភាពគតិយុត្ត ដែលកើតឡើងដោយមានការបង្ហាញឆន្ទៈជាធាតុផ្សំនោះឡើយ ។ មានន័យថា វាគ្រាន់តែជាអំពើ ឬជាសកម្មភាពដែលកើតឡើងជាក់ស្តែងតែប៉ុណ្ណោះ ។ ដោយហេតុថា កិច្ចសន្យាគឺជាបញ្ហាតំណាង នៃសកម្មភាពគតិយុត្ត ឥឡូវនេះចូរយើងលើកយកឧទាហរណ៍ជាក់ស្តែងអំពីកិច្ចសន្យាដែលផ្ទុយនឹង សណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អមកពិចារណាម្តង ។ ឧទាហរណ៍ដូចជាកិច្ចសន្យា ប្រគល់ប្រាក់ ដោយបង្គាប់ឱ្យជនម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬកិច្ចសន្យាទិញឬលក់គ្រឿងញៀន ដែលត្រូវហាមឃាត់ជាដើម ទាំងនេះគឺជាសកម្មភាពគតិយុត្តផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិង ទំនៀមទំលាប់ល្អទាំងអស់ (ការលើកឧទាហរណ៍ថាៈ "ការជក់គ្រឿនញៀនដែលច្បាប់ហាមឃាត់" ជាសកម្មភាពល្មើសមាត្រា ៩០ នៃច្បាប់រដ្ឋប្បវេណីនោះមិនត្រឹមត្រូវទេ "ការភ្ជាប់កិច្ចសន្យាលក់ គ្រឿងញៀនដែលច្បាប់ហាមឃាត់" ទើបជាចម្លើយត្រឹមត្រូវ) ។ ហើយកិច្ចសន្យាភ្នាល់គ្នាដាក់ លុយលេងល្បែងស៊ីសង ក៏ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទំលាប់ល្អដែរ ។ កិច្ចសន្យា ទាំងនេះជាកិច្ចសន្យាមោឃៈ ដូច្នេះពុំមានការកើតចេញជាសិទ្ធិលើបំណុលអ្វីឡើយ ។ នេះបាន សេចក្តីថា បើទោះជាគេបានសន្យាថានឹងបង់ប្រាក់នៅពេលចាញ់ល្បែងស៊ីសងក៏ដោយ តាមផ្លូវ ច្បាប់គឺពុំមានការកើតឡើងនូវកាតព្វកិច្ចឱ្យបង់ប្រាក់នោះឡើយ ។

## ២. ការការពារជនដែលត្រូវបានកំរិតសមត្ថភាព

### ២.១. សមត្ថភាពបង្ហាញឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព

ឥឡូវយើងសិក្សាអំពីពាក្យថា សមត្ថភាពបង្ហាញឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព ម្តង ។ ដូចបានធ្វើអត្ថាធិប្បាយរួចមកហើយថា មនុស្សយើងម្នាក់ៗដើម្បីនឹងរស់ជាមនុស្សដូចគេឯង ចាប់ពីពេលកើតមកភ្លាម គឺច្បាប់បានទទួលស្គាល់ថាមានសមត្ថភាពទទួលសិទ្ធិ ពោលគឺមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ សំរាប់ធ្វើជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចតាមផ្លូវច្បាប់។ ប៉ុន្តែ បន្ថែម លើនេះ យើងម្នាក់ៗត្រូវការនូវសមត្ថភាពក្នុងការសំរេចឆន្ទៈដោយខ្លួនឯង ដើម្បីប្រាប់ទៅអ្នកដទៃ អំពីឆន្ទៈរបស់ខ្លួនដែលបានធ្វើឡើងដោយសេរីនោះ ក្នុងបំណងបង្កើតទំនាក់ទំនងតាមផ្លូវច្បាប់ ។

ក្នុងក្រមរដ្ឋប្បវេណី គេអោយឈ្មោះសមត្ថភាពនេះថាជា សមត្ថភាពខាងឆន្ទៈ ។ ចំពោះជនដែលមានវិបត្តិសតិ មិនអាចពិចារណាយល់ដឹងដូចធម្មតាបាន ពោលគឺជនគ្មានសមត្ថភាពខាងឆន្ទៈនោះ ក្រមរដ្ឋប្បវេណីបានកំណត់ថាជា *អសមត្ថជនខាងឆន្ទៈ* ។ ក្នុងករណីដែលអសមត្ថជនខាងឆន្ទៈបានធ្វើកិច្ចសន្យាជាមួយអ្នកដទៃក៏ដោយ កិច្ចសន្យានេះនឹងពុំមានសុពលភាពឡើយ ។ មានន័យថា គ្មានការកើតឡើងនូវទំនាក់ទំនងផ្លូវច្បាប់ណាមួយតាមរយៈកិច្ចសន្យានេះទេ ។

ក៏ប៉ុន្តែ ប្រសិនបើគេត្រូវតែលើកយកគ្រប់ករណីនិមួយៗ មកពិចារណាបញ្ជាក់ថា តើបុគ្គលណាម្នាក់មាន ឬគ្មានសមត្ថភាពបង្ហាញឆន្ទៈទេនោះ គេនឹងត្រូវធ្វើកិច្ចការច្រើនឥតគណនា ហើយនឹងជួបប្រទះជាមួយករណីដែលធ្វើការវិនិច្ឆ័យសំរេចមិនកើតផងជាពុំខាន ។ នៅទីនេះ ក្រមរដ្ឋប្បវេណីបានកំណត់នូវបទបញ្ញត្តិស្តីពីបទដ្ឋានជាក់លាក់ សំរាប់បែងចែកជនដែលមាន និងជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាព ពោលគឺជាសមត្ថភាពសំរេចនូវសកម្មភាពគតិយុត្តរបស់ខ្លួនដោយខ្លួនឯង។ ជនដែលខ្វះសមត្ថភាពបង្ហាញឆន្ទៈ ឬជនដែលខ្វះសមត្ថភាពធ្វើការវិនិច្ឆ័យ ដោយខ្លួនឯង ត្រូវបានចាត់ទុកថាជាជនដែលត្រូវបានកំរិតសមត្ថភាព។ ក្នុងគោលបំណងការពារជនប្រភេទនេះ គេទទួលស្គាល់ឱ្យជនដែលត្រូវបានកំរិតសមត្ថភាពទាំងនេះអនុវត្តនូវសកម្មភាពគតិយុត្តត្រឹមតែមួយចំណែកប៉ុណ្ណោះ ឬមិនឱ្យអនុវត្តបានទេប្រសិនបើគ្មានការយល់ព្រម ឬការជ្រោមជ្រែងពីអ្នកណាម្នាក់ផ្សេងទៀតទេនោះ (ចាប់ពីមាត្រា ៥ ដល់មាត្រា ១៩ តទៅនេះ មាត្រាដែលបង្ហាញនៅក្នុងវង្ងង់ក្រចកគឺជាមាត្រានៅក្នុងក្រមរដ្ឋប្បវេណីទាំងអស់)។ ប៉ុន្តែម្យ៉ាងទៀត ច្បាប់ក៏ចាំបាច់ត្រូវតែចែងទុកជាបញ្ញត្តិផងដែរ សំដៅការពារអ្នកដែលបានធ្វើកិច្ចសន្យាជាមួយជនណាដែលខ្លួនពុំបានដឹងថាជាជនដែលត្រូវបានកំរិតសមត្ថភាពទេនោះ (សូមអាន មាត្រា ២០ និងមាត្រា ២១) ។

### សមត្ថភាពទទួលសិទ្ធិ

ជាការពិតណាស់ មនុស្សយើងម្នាក់ៗ ចាប់តាំងពីពេលកើតមក ត្រូវបានទទួលស្គាល់ថាមានសមត្ថភាពទទួលសិទ្ធិ ដែលជាលក្ខណៈសម្បត្តិសំរាប់ក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ។ នេះមានន័យថា ទារកដែលនៅក្នុងពោះម្តាយពុំទាន់មានសិទ្ធិទទួលមត៌កបានឡើយ ក្នុងករណីដែលឪពុកខ្លួនទទួលមរណៈភាពនៅមុនពេលទារកចាប់កំណើតនោះ (សូមអានជំពូកទី ៩ ស្តីពីសន្តតិកម្ម) ។ ម្យ៉ាងទៀត ក្នុងករណីដែលមរណៈភាពនៃឪពុកនោះ កើតឡើងដោយគ្រោះថ្នាក់ចរាចរបណ្តាលមកពីអំពើអនីត្យានុកូល (សូមអានជំពូកទី ៥ ) ជាដើមក្តី ក៏ទារកដែលមិនទាន់ប្រសូតនោះ ពុំអាចទៅជាប្រធាននៃការប្តឹងទាមទារសំណងចំពោះការខូចខាតនោះបានដែរទេ ។ ដើម្បីដោះស្រាយបញ្ហាដូចនេះ ក្រមរដ្ឋប្បវេណីបានចាត់ទុកទារកដែលនៅក្នុងពោះម្តាយ ថាដូចជាទារកដែលបានប្រសូតរួចហើយដែរ នៅក្នុងករណីនៃសំណងខូចខាតមកពីអំពើអនីត្យានុកូល (មាត្រា ៧២១) សន្តតិកម្ម (មាត្រា ៨៨៦) និងអច្ច័យទាន (មាត្រា ៩៦៥) ។ សូមបញ្ជាក់ថា ជាគោលការណ៍សមត្ថភាពទទួលសិទ្ធិនេះក៏ត្រូវបានទទួលស្គាល់ចំពោះជនជាតិបរទេសផងដែរ (មាត្រា ៣ កថាខ័ណ្ឌទី ២) ។

ជនដែលត្រូវបានកំរិតសមត្ថភាព ដែលនឹងមានរៀបរាប់តទៅនេះ គ្រាន់តែសំដៅលើការកំរិតចំពោះសមត្ថភាពក្នុងការធ្វើសកម្មភាពប៉ុណ្ណោះ មិនមែនការដាក់កំរិតលើសមត្ថភាពទទួលសិទ្ធិនោះទេ ។

## ២.២. ជនដែលត្រូវបានកំរិតសមត្ថភាព

ជនដែលត្រូវបានកំរិតសមត្ថភាព ដែលក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងជាក់ស្តែង មានជា ៤ ប្រភេទ : អនីតិជន (មាត្រា ៤ កំណត់ថាជាជនមានអាយុតិចជាង ២០ ឆ្នាំ) នីតិជននៅក្រោមអាណាព្យាបាល ជននៅក្រោមហិតូបត្ថម្ភ និងជននៅក្រោមការទំនុកបំរុង ។ នៅត្រង់ចំណុចនេះ រហូតមកទល់ខែមេសាឆ្នាំ ២០០០ ក្រមរដ្ឋប្បវេណីបានកំណត់ជន ៣ ប្រភេទគឺ អនីតិជន ជនដែលត្រូវបានកំរិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យ និងជនដែលប្រហាក់ប្រហែលនឹងជនត្រូវបានកំរិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យ ដោយហៅថាជា អសមត្ថជនក្នុងការធ្វើសកម្មភាព ។ ជនដែលត្រូវបានកំរិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យ មានន័យថាជា ជនដែលទទួលការហាមឃាត់

មិនអោយចាត់ចែង ឬគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួន ចំណែកឯជនដែលប្រហាក់ប្រហែលនឹងជនត្រូវបានកំរិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យ គឺជាជនដែលកំពុងស្ថិតក្នុងស្ថានភាពប្រហាក់ប្រហែលនឹងជនដែលត្រូវបានកំរិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យ ។ ប៉ុន្តែការប្រើពាក្យទាំងនេះហាក់ដូចជាមានលក្ខណៈជ្រួលបន្តិច ពុំសូវជាប្រពៃរ៍ឡើយ ព្រមទាំងខ្វះលក្ខណៈជារបបមួយដែលផ្តល់កិច្ចការពារដល់ជនទាំងនោះផង ។ បន្ថែមលើនេះ ស្របគ្នានឹងពេលដែលប្រជាជនចាស់ជរាកំពុងមានចំនួនកើនឡើងក្នុងសង្គមនោះ ភាពចាំបាច់ក្នុងកិច្ចការពារជនជរាដែលថមថយកំលាំងស្មារតីក្នុងការវិនិច្ឆ័យរបស់ខ្លួន ក៏បានចោទជាបញ្ហាដែរ ។ ដោយយល់ឃើញដូច្នេះ និងក្នុងគោលបំណងបង្កើនសុខុមាលភាពចំពោះជនជរានិងជនមានវិបត្តិទាំងនេះ ទើបមានការធ្វើវិសោធនកម្មលើក្រមរដ្ឋប្បវេណី សំដៅបង្កើតរបបអាណាព្យាបាលសំរាប់នីតិជន (សំរេចនៅខែធ្នូ ឆ្នាំ១៩៩៩ ចាប់អនុវត្តនៅខែមេសា ឆ្នាំ២០០០) ។ តាមរយៈនៃវិសោធនកម្មនេះ ពាក្យថា " អសមត្ថជនក្នុងការធ្វើសកម្មភាព" បានត្រូវប្តូរមកជា "ជនដែលត្រូវបានកំរិតសមត្ថភាព " វិញ ។

បន្ទាប់ពីវិសោធនកម្មមក(ពាក្យអនីតិជនទុកនៅដដែល) ជនដែលត្រូវបានកំរិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យ ត្រូវបានប្តូរមកជា នីតិជននៅក្រោមអាណាព្យបាល ហើយជនដែលប្រហាក់ប្រហែលនឹងជនត្រូវបានកំរិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យ ត្រូវបានប្តូរមកជា ជននៅក្រោមហិត្វូបត្ថម្ភ ហើយបានបន្ថែមក្របខ័ណ្ឌថ្មីមួយទៀតសំរាប់ជននៅក្រោមការទំនុកបំរុង ។ សរុបទាំងអស់គេហៅថាជា ជនដែលត្រូវបានកំរិតសមត្ថភាព ។ ឧទាហរណ៍ដូចជាចំពោះជនដែលមានវិបត្តិស្មារតី ពុំអាចវិនិច្ឆ័យលើកិច្ចការអ្វីបាន តុលាគ្រួសារត្រូវវិនិច្ឆ័យកំណត់កិច្ចចាប់ផ្តើមធ្វើអាណាព្យាបាលសំរាប់ជននោះ ប្រសិនបើមានការស្នើសុំពីសាមីខ្លួន សហព័ទ្ធ ឬសាច់ញាតិជិតណាម្នាក់ជាដើម ។ បន្ទាប់ពីការសំរេចរបស់តុលាការមក ជននោះត្រូវហៅថា នីតិជននៅក្រោមអាណាព្យបាល ហើយត្រូវមានអ្នកអាណាព្យាបាលសំរាប់នីតិជន ម្នាក់អមជាមួយ ។ អ្នកអាណាព្យាបាលសំរាប់នីតិជន រូបនេះ អាចលុបចោលសកម្មភាពគតិយុត្តរបស់ នីតិជននៅក្រោមអាណាព្យបាលបាន (មាត្រា ៨-១០) ។ មួយវិញទៀត ទោះបីជាមិនដល់ថ្នាក់ត្រូវចាត់ទុកថាជានីតិជននៅក្រោមអាណាព្យបាលក៏ដោយ ចំពោះជនដែលច្បាស់ជាមានការខ្វះខាតខាងការវិនិច្ឆ័យកិច្ចការដោយខ្លួនឯង អាស្រ័យទៅតាមសេចក្តីសំរេចរបស់តុលាការកំណត់ឱ្យចាប់ផ្តើមហត្ថូបត្ថម្ភ

ជននោះត្រូវបានចាត់ទុកជាជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវមានហិតូបត្ថម្ភកៈអមជាមួយ ។ ជននេះត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈជាចាំបាច់ មុននឹងអនុវត្តសកម្មភាពមួយចំនួនដែលច្បាប់បានកំណត់ ។ ចំពោះសកម្មភាពណា ដែលគ្មានការយល់ព្រមនេះទេ សកម្មភាពនោះអាចនឹងត្រូវបានលុបចោល (មាត្រា ១១ មាត្រា ១២ និងមាត្រា ១៣) ។ ហើយចំពោះជនដែលខ្វះខាតការវិនិច្ឆ័យក្នុងលក្ខណៈស្រាលវិញ ដោយអាស្រ័យទៅតាមសេចក្តីសំរេចរបស់តុលាការ ជននោះអាចនឹងក្លាយទៅជាជននៅក្រោមការទំនុកបំរុង ហើយត្រូវមានអ្នកជំនួយអមជាមួយផង ។ នៅក្នុងករណីការអនុវត្តសកម្មភាពគតិយុត្តមួយចំនួនដែលគូភាគីបានកំណត់ទុកជាមុននោះ គេអាចតម្រូវឱ្យជននៅក្រោមការទំនុកបំរុងទទួលការយល់ព្រមពីអ្នកជំនួយក៏បានដែរ (មាត្រា ១៥-១៧) ។

## ២.៣. ការការពារជនដែលត្រូវបានកំរិតសមត្ថភាព

### ២.៣.១.ការលុបចោលសកម្មភាពរបស់ជនដែលត្រូវបានកំរិតសមត្ថភាព

ជាមធ្យោបាយជាក់ស្តែងក្នុងការការពារជនដែលត្រូវបានកំរិតសមត្ថភាព ច្បាប់បានកំណត់នូវបទបញ្ញត្តិស្តីពីការអាចលុបចោលបាននូវសកម្មភាពគតិយុត្ត របស់ជនដែលត្រូវបានកំរិតសមត្ថភាព។ ការលុបចោល ដូចដែលមានធ្វើអត្ថាធិប្បាយខាងក្រោមនេះ មានន័យថាជាការសើរើត្រឡប់ថយក្រោយវិញ ដោយចាត់ទុកថាសកម្មភាពនោះមិនបានកើតឡើងតាំងពីដំបូងទី (សូមអានវគ្គទី ៥ : *មោឃភាព* និង*ការលុបចោល*) ។ ជាបឋម បើនិយាយអំពីអនីតិជន តើគេត្រូវដោះស្រាយដូចម្តេច ប្រសិនបើសិស្សវិទ្យាល័យម្នាក់បានធ្វើកិច្ចសន្យាទិញវត្ថុមួយមានតម្លៃរហូតដល់ទៅរាប់ពាន់ដុល្លា ដោយសារការអន្ទងពីអ្នកលក់? បើយើងពិចារណាឧទាហរណ៍នេះ ដោយយោងលើមាត្រា ៥ នៃក្រមរដ្ឋប្បវេណី យើងនឹងដឹងថាអនីតិជនដែលប្រព្រឹត្តសកម្មភាពគតិយុត្តណាមួយ តួយ៉ាងដូចជាកិច្ចសន្យាជាដើម ត្រូវតែទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ជាដាច់ខាត ពោលគឺ ឪពុកម្តាយ (ជនមានអំណាចមេបា ។ ក្នុងករណីមិនមានជនមានអំណាចមេបាទេ ត្រូវធ្លាក់ទៅអ្នកអាណាព្យាបាល) ។ ក្នុងករណីប្រព្រឹត្តសកម្មភាពគតិយុត្តដោយគ្មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ទេនោះ សាមីខ្លួន ឬឪពុកម្តាយរបស់សាមីខ្លួន អាចលុបចោលដោយចាត់ទុកថាគ្មានសកម្មភាពនេះតាំងពីដំបូងទីបាន (ចំពោះជនដែល

អាចលុបសកម្មភាពនេះចោលបាន ពោលគឺ ជនមានសិទ្ធិលុបចោល មាត្រា ១២០ បានកំណត់ថា គឺជនដែលត្រូវបានកំរិតសមត្ថភាពខ្លួនឯងផ្ទាល់ និងអ្នកតំណាង ប្រតិសិទ្ធិ ឬអ្នកមានសិទ្ធិយល់ព្រម) ។ ដោយហេតុថា អ្នកមានអំណាចមេបា គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ គេពុំត្រឹមតែមានអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួនប៉ុណ្ណោះទេ ។ ជននេះអាចតំណាងអោយសាមីខ្លួន ដោយអនុវត្តសកម្មភាពគតិយុត្ត (ដូចជាធ្វើកិច្ចសន្យាជាដើម) ទៅលើទ្រព្យសម្បត្តិរបស់សាមីខ្លួនជាជំនួសបាន (នឹងមានការរៀបរាប់អំពី តំណាង នៅខាងក្រោយ ក្នុងវគ្គទី៤ : ការតំណាង ការតំណាងដោយគ្មានសិទ្ធិ នឹងការតំណាងដែលមានលក្ខណៈជារូបភាព) ។ ជាពិសេស អនីតិជន អាចប្រើប្រាស់ដោយសេរីតាមទំនើងចិត្តខ្លួនបាន នូវទ្រព្យសម្បត្តិដែលឪពុកម្តាយអនុញ្ញាតឱ្យប្រើប្រាស់ ទោះបីជាមានការដាក់ទិសដៅថាអោយធ្វើនេះ ឬធ្វើនោះ ឬគ្មានការដាក់ទិសដៅយ៉ាងណាក៏ដោយ ដូចជាករណីនៃការផ្តល់ប្រាក់ចាយវាយបន្តិចបន្តួចជាដើម (មាត្រា ៥ កថាខ័ណ្ឌទី ៣) ។ អនីតិជនដែលរៀបអាពាហ៍ពិពាហ៍ហើយ នឹងត្រូវចាត់ទុកជានីតិជន (មាត្រា ៧៥៣) ។

ម្យ៉ាងទៀត ដូចបានធ្វើអត្ថាធិប្បាយខាងលើស្រាប់ ចំពោះនីតិជននៅក្រោមអាណាព្យាបាល នឹងមានអ្នកអាណាព្យាបាលអមជាមួយ ចាត់ជាអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ៨) ។ សកម្មភាពគតិយុត្តរបស់នីតិជននៅក្រោមអាណាព្យាបាលក៏អាចលុបចោលបានដែរ (ក៏ប៉ុន្តែ ការទិញប្រដាប់ប្រដាប្រើប្រាស់ប្រចាំថ្ងៃ និងសកម្មភាពពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃទាំងប៉ុន្មាន មិនអាចលុបចោលបានឡើយ ។ មាត្រា ៩) ។ ចំពោះជននៅក្រោមហិត្តូបត្ថម្ភ នឹងមានហិត្តូបត្ថម្ភកៈអមជាមួយ (មាត្រា ១២) ។ ក្នុងករណីរបស់ជននៅក្រោមហិត្តូបត្ថម្ភ សាមីខ្លួនអាចអនុវត្តសកម្មភាពមួយភាគបានដោយខ្លួនឯង ក៏ប៉ុន្តែក្នុងករណីអនុវត្តសកម្មភាពសំខាន់ៗពាក់ព័ន្ធនឹងទ្រព្យសម្បត្តិវិញ ត្រូវតែមានការយល់ព្រមពីហិត្តូបត្ថម្ភកៈ (មាត្រា ១៣ កថាខ័ណ្ឌ ១) ។ ក្នុងករណីដែលសកម្មភាពណាមួយប្រព្រឹត្តឡើងដោយគ្មានការយល់ព្រមពីហិត្តូបត្ថម្ភកៈ ឬគ្មានសេចក្តីអនុញ្ញាតពីតុលាការជាជំនួសការយល់ព្រមទេនោះ សកម្មភាពនេះ អាចលុបចោលបានដូចគ្នា (មាត្រា ១៣ កថាខ័ណ្ឌទី ៤) ។ វិសោធនកម្មក្រមរដ្ឋប្បវេណីនៅឆ្នាំ ១៩៩៩ បានផ្តល់អំណាចលុបចោលទៅហិត្តូបត្ថម្ភកៈ ក្នុងករណីដែលជននៅក្រោមហិត្តូបត្ថម្ភអនុវត្តសកម្មភាពដែលតំរូវឱ្យមានការទទួលការយល់ព្រម តែបែរជាធ្វើតាមទំនើងចិត្តខ្លួនទៅវិញ (មាត្រា ១២០ កថាខ័ណ្ឌទី ១) ។ បន្ថែមលើនេះ

តាមរយៈនៃការសំរេចរបស់តុលាការ សិទ្ធិតំណាងក៏នឹងត្រូវផ្តល់ទៅហិត្ថូបត្ថម្ភកៈផងដែរ នៅក្នុងករណីដែលសាមីភាគីពាក់ព័ន្ធបានស្នើសុំ នឹងធ្វើការជ្រើសរើសកំណត់ នូវសកម្មភាពគតិយុត្តមួយចំនួន ប្រគល់ទៅតំណាងនោះ (សកម្មភាពនេះ ប្រសិនបើស្នើសុំដោយអ្នកដទៃក្រៅពីសាមីខ្លួននោះត្រូវទទួលការយល់ព្រមពីសាមីខ្លួនជាចាំបាច់ ។ សូមអានមាត្រា ៨៧៦ ភាគ ៤ កថាខ័ណ្ឌទី ១ និងទី ២) ។ នៅក្នុងរបបទំនុកបំរុងដែលបានបង្កើតថ្មីនេះ ចំពោះសកម្មភាពគតិយុត្តណាមួយ ដែលសាមីខ្លួនបានស្នើសុំ និងធ្វើការជ្រើសរើសកំណត់ហើយនោះ តុលាការអាចសំរេចផ្តល់សិទ្ធិតំណាង ឬសិទ្ធិយល់ព្រម (សិទ្ធិលុបចោល) ដល់អ្នកជំនួយបាន (មាត្រា ១៧ កថាខ័ណ្ឌទី ១ មាត្រា ៨៧៦ ភាគ ៩ កថាខណ្ឌទី ១ ។ ដោយសារឈរលើទស្សនៈគោរពសិទ្ធិសំរេចដោយខ្លួនឯង នេះក៏តំរូវឱ្យមានលក្ខខ័ណ្ឌនៃការស្នើសុំ ឬការយល់ព្រម ពីសាមីខ្លួនផងដែរ ។ មាត្រា ១៧ កថាខ័ណ្ឌទី ២ និងមាត្រា ៨៧៦ ភាគ ៩ កថាខ័ណ្ឌទី ២) ។

### ២.៣.២.ការការពារភាគីម្ខាងទៀតរបស់ជនដែលត្រូវបានកំរិតសមត្ថភាព

បើដូច្នេះ ភាគីម្ខាងទៀតដែលបានធ្វើកិច្ចសន្យារួចទៅហើយ តែមិនបាននឹកភ្នកសោះថា អ្នកដែលខ្លួនបានធ្វើកិច្ចសន្យាជាមួយនោះជាជនដែលត្រូវបានកំរិតសមត្ថភាពឡើយ ត្រូវវងចាំទាំងកង្វល់ ដោយពុំដឹងថាតើជនដែលត្រូវបានកំរិតសមត្ថភាពនឹងលុបចោលកិច្ចសន្យាឬយ៉ាងណាទេនោះ ។ នេះនឹងនាំឱ្យភាគីដែលបានធ្វើជំនួញជាមួយជនដែលត្រូវបានកំរិតសមត្ថភាពនោះ ត្រូវធ្លាក់ក្នុងស្ថានភាពគ្មានលំនឹងជាអង្វែងពុំលែងឡើយ ។ ដើម្បីជៀសវាងស្ថានភាពចាញ់ប្រៀបនេះ ក្រមរដ្ឋប្បវេណីបានដាក់បញ្ញត្តិ ទុកលទ្ធភាពឱ្យភាគីដែលជាដៃគូនៃជនដែលត្រូវបានកំរិតសមត្ថភាពនោះអាចតឿនបង្ខំឱ្យជនដែលត្រូវបានកំរិតសមត្ថភាពបញ្ជាក់តាមក្រោយថា ទទួលស្គាល់ ឬមិនទទួលស្គាល់ ចំពោះអនុភាពកិច្ចសន្យាដែលបានធ្វើនោះ ។

ជាបឋម ក្នុងករណីដែលក្រោយមកជនដែលត្រូវបានកំរិតសមត្ថភាពនោះក្លាយជាសមត្ថជនវិញ (ឧទាហរណ៍ដូចជានៅពេលធ្វើកិច្ចសន្យា ជននោះជាអនីតិជននៅឡើយទេ តែក្រោយមកពេញអាយុជានីតិជនជាដើម) គេអាចដាស់តឿនឱ្យជននោះឆ្លើយថាផ្តល់ ឬមិនផ្តល់ សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាននោះ ក្នុងអំឡុងពេលលើសពីមួយខែបន្ទាប់ពីបានក្លាយទៅជាសមត្ថជន ។ ប្រសិនបើគ្មានការឆ្លើយតបក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាជននោះបាន

ផ្ដល់សច្ចានុមតិលើសកម្មភាពនោះរួចហើយ (មាត្រា ២០ កថាខ័ណ្ឌទី ២) ។ ចំពោះករណីដែលជនត្រូវបានកំរិតសមត្ថភាពនោះ នៅបន្តជាជនដែលត្រូវបានកំរិតសមត្ថភាពដដែល គេអាចធ្វើការដាស់តឿនដូចគ្នាបានដែរ ទៅអ្នកតំណាងដែលច្បាប់បានកំណត់ ហិតូបត្ថម្ភកៈ ឬអ្នកជំនួយ អំពីសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់អ្នកទាំងនេះ ។ ហើយប្រសិនបើគ្មានការឆ្លើយតបទេ ត្រូវចាត់ទុកថាបានផ្ដល់សច្ចានុមតិដូចគ្នាដែរ (មាត្រា ២០ កថាខ័ណ្ឌទី ២) ។ បន្ថែមលើនេះ ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិតូបត្ថម្ភ ឬជននៅក្រោមការទំនុកបំរុង ដែលបានទទួលសេចក្ដីសំរេចរបស់តុលាការស្របតាមមាត្រា ១៦ នោះ ទទួលយកសច្ចានុមតិពីហិតូបត្ថម្ភកៈ ឬអ្នកជំនួយរបស់ខ្លួន ក្នុងអំឡុងពេលលើសពីមួយខែ ។ ប្រសិនបើជននៅក្រោមហិតូបត្ថម្ភ ឬជននៅក្រោមការទំនុកបំរុងមិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា សកម្មភាពនោះត្រូវបានលុបចោល (មាត្រា ២០ កថាខ័ណ្ឌទី ៤) ។

ម្យ៉ាងទៀត ប្រសិនបើជនដែលត្រូវបានកំរិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឱ្យភាគីជាដៃគូជឿថា ខ្លួនជាសមត្ថជននោះ ច្បាប់បានបទបញ្ញត្តិថាសកម្មភាពនេះមិនអាចលុបចោលបានទេ (មាត្រា ២១) ។

## ២.៣.៣.ប្រព័ន្ធអាណាព្យាបាលតាមការស្ម័គ្រចិត្ត

ព្រមពេលជាមួយនឹងការធ្វើវិសោធនកម្មលើក្រមរដ្ឋប្បវេណី ដែលបានសំរេចនៅឆ្នាំ១៩៩៩ "ច្បាប់ស្ដីពីកិច្ចសន្យាអាណាព្យាបាលតាមការស្ម័គ្រចិត្ត" (ច្បាប់ស្ដីពីអាណាព្យាបាលតាមការស្ម័គ្រចិត្ត) ត្រូវបានអនុម័ត ហើយដាក់អោយអនុវត្តនៅខែមេសា ឆ្នាំ២០០០ ដូចគ្នា ។ នេះបានសេចក្ដីថា លើទស្សនៈគោរពសិទ្ធិសំរេចដោយខ្លួនឯង បុគ្គលអាចឆ្លៀតពេលនៅមានកំលាំងគ្រប់គ្រាន់សំរាប់ធ្វើការវិនិច្ឆ័យដោយខ្លួនឯងនោះ សំរេចរើសយកជនណាដែលអាចប្រគល់ភារកិច្ចឱ្យទទួលកិច្ចការអាណាព្យាបាលបាននៅពេលដែលខ្លួនត្រូវបាត់បង់កំលាំងវិនិច្ឆ័យនាថ្ងៃអនាគត (អ្នកអាណាព្យាបាលតាមការស្ម័គ្រចិត្ត) ហើយធ្វើកិច្ចសន្យាជាមួយជននោះទុកជាមុនសិន ។ គេក៏អាចសំរេចផ្ដល់នូវសិទ្ធិអំណាចអ្វីខ្លះទៅឱ្យជននោះបានតាមចិត្តដែរ តាមរយៈនៃកិច្ចសន្យានេះ ។ នេះគេហៅថា *ប្រព័ន្ធអាណាព្យាបាលតាមការស្ម័គ្រចិត្ត* ។

# ៣. ការបង្ហាញឆន្ទៈប្រកបដោយបញ្ហា

## ៣.១. សេចក្ដីផ្ដើម

សូម្បីតែនីតិជនទូទៅ ដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាព ហើយអាចធ្វើការវិនិច្ឆ័យដោយពុំមានបញ្ហាក៏ដោយ ក៏គង់មានពេលខ្លះបង្ហាញឆន្ទៈដែលពុំច្បាស់លាស់ត្រឹមត្រូវ ដូចជាករណីមានវិការៈច្រើនពេកក្នុងការបង្ហាញឆន្ទៈ ឬក៏ករណីពុំមានឆន្ទៈអ្វីទាល់តែសោះដែលទាក់ទងទៅនឹងការសំដែងនោះជាដើម ។ នៅក្នុងករណីទាំងអស់នេះ គេមិនត្រូវទទួលស្គាល់នូវសុពលភាពនៃការបង្ហាញឆន្ទៈនេះបានទេ ។ ក្រមរដ្ឋប្បវេណីបានកំណត់ទុកនូវវិធានសំរាប់លុបចោល និងការពារកុំឱ្យកើតមានសុពលភាពចំពោះការបង្ហាញឆន្ទៈនេះ ។

## ៣.២. ការបង្ហាញឆន្ទៈតាមការឆបោក ឬតាមការគម្រាមកំហែង

ជាបឋម គេអាចលុបចោលបាននូវការបង្ហាញឆន្ទៈ ដែលកើតមានឡើងដោយសារការឆបោក ឬការគម្រាមកំហែង ដូចជាក្នុងករណីពោលពាក្យថានឹងលក់ផ្ទះដែលខ្លួនគ្មានបំណងនឹងលក់សោះជាដើម (មាត្រា ៩៦ កថាខ័ណ្ឌទី ១) ។ ប្រសិនបើការបង្ហាញឆន្ទៈត្រូវបានលុប ចោលឧទាហរណ៍ដូចជាកិច្ចសន្យាលក់ផ្ទះ ដែលជាកិច្ចសន្យាកើតឡើងពីភាពត្រូវរ៉ូវគ្នារវាង ការបង្ហាញឆន្ទៈពីរ គឺការ"សុខចិត្តទិញក្នុងតំលៃប៉ុណ្ណេះ" និងការ"សុខចិត្តលក់ក្នុងតំលៃប៉ុណ្ណេះ" ហើយដោយសារការបង្ហាញឆន្ទៈម្ខាងត្រូវបានលុបចោល ដូច្នេះគេត្រូវគិតត្រឡប់ថយក្រោយវិញ ដោយចាត់ទុកថាគ្មានកិច្ចសន្យាអ្វីសោះតាំងពីដំបូងទី ។ នេះបានន័យថា កិច្ចសន្យាលក់មិនបានកើត មានឡើងទេ ។ ដោយហេតុថា កិច្ចសន្យាមិនបានកើតមានទេនោះ ប្រសិនបើបានប្រគល់ផ្ទះទៅហើយ គឺការប្រគល់នេះនឹងត្រូវលុបចោលវិញ ឬប្រសិនបើបានបង់ប្រាក់ថ្លៃផ្ទះទៅហើយ គឺត្រូវសងប្រាក់នោះមកវិញ (នេះគេហៅថា ការធ្វើបដិទាន បានន័យថាការធ្វើឱ្យដូចស្ថានភាព ដើមមកវិញ) ។

ត្រង់នេះគួរបញ្ជាក់ផងដែរថា ពាក់ព័ន្ធនឹងការបង្ហាញឆន្ទៈដែលកើតមកពីលទ្ធផលនៃការឆបោក ឬការគម្រាមកំហែងនេះ ក្រមរដ្ឋប្បវេណីមានកំណត់បទបញ្ញត្តិត្រឹមប៉ុណ្ណឹង ។ បានជាប្រើពាក្យថា"ត្រឹមប៉ុណ្ណឹង" គឺមកពីថា ជនដែលឆបោក ឬគម្រាមកំហែង គឺជាជនទុច្ចរិត ដូច្នេះប្រាកដជាមានមតិខ្លះថាគួរផ្ដន្ទាទោសជនទាំងនោះ ។ ក៏ប៉ុន្តែ សូមបញ្ជាក់ថានេះមិនមែនជាបញ្ហារបស់ក្រមរដ្ឋប្បវេណីទេ (បើជារឿងឆបោក គឺវាស្ថិតនៅក្រោមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌមាត្រា

២៤៦ ដែលត្រូវលើកមកពិភាក្សាថាត្រូវជាបទឆបោកមែន ឬមិនមែន ហើយប្រសិនបើជាបទឆបោកមែន គេធ្វើការផ្តន្ទាទោសទៅតាមនោះ) ។ យើងគួរយល់ថា ព្រោះតែគោលដៅរបស់ក្រមរដ្ឋប្បវេណីគឺស្ថិតនៅត្រង់ស្វ័យភាពខាងឆន្ទៈរបស់សាមីខ្លួន ដូច្នេះបើសិនជាការបង្ហាញឆន្ទៈនេះបានអាស្រ័យលើឆន្ទៈសំរេចដោយសេរីរបស់សាមីខ្លួន គឺគេចាត់ទុកថាមានសុពលភាព បើពុំបានអាស្រ័យលើឆន្ទៈនោះទេ គឺគេនឹងដាក់កំហិតចំពោះសុពលភាពនោះទៅវិញ ។

មួយវិញទៀត តាមធម្មតាភាគច្រើននៃការឆបោកតែងកើតមានឡើងដោយភាគីម្ខាងទៀតក្នុងការជួញដូរជាមួយគ្នា (ឧបមាដូចជាឈ្មោះ x បោកឈ្មោះ y ឱ្យលក់ផ្ទះមកខ្លួនក្នុងតំលៃថោកជាដើម) ប៉ុន្តែនៅក្នុងករណីខ្លះ តតិយជន ពោលគឺជនផ្សេងដោយឡែក ជាអ្នកឆបោកក៏មានដែរ (ឧបមាដូចជាឈ្មោះ z បោកបញ្ឆោតឈ្មោះ y ឱ្យលក់ផ្ទះទៅឈ្មោះ x ដោយតំលៃថោក) ។ នៅក្នុងករណីនេះ លុះត្រាតែភាគីជាដៃគូ (ប្រសិនបើការបង្ហាញឆន្ទៈប្រកបទៅដោយបញ្ហា ជារបស់ឈ្មោះ y ភាគីជាដៃគូត្រូវជាឈ្មោះ x) បានដឹងអំពីរឿងឆបោករួចស្រេចជាមុន ទើបការលុបចោលនោះអាចធ្វើទៅបាន (មាត្រា ៩៦ កថាខ័ណ្ឌទី ២) ។

លើសពីនេះទៅទៀត មានការកំណត់ថា ការបង្ហាញឆន្ទៈតាមការឆបោកមិនអាចយកមកដើម្បីតតាំងនឹងតតិយជនដែលសុទ្ធចិត្តបានឡើយ (មាត្រា ៩៦ កថាខ័ណ្ឌទី ៣) ។ នៅទីនេះ ពាក្យថា "តតិយជនដែលសុទ្ធចិត្ត" គឺជនដទៃផ្សេងទៀតដែលមិនបានដឹងអំពីអង្គហេតុដែលកើតឡើង (សូមអានការពន្យល់ពាក្យគន្លឹះ "សុចរិត និងទុច្ចរិត") ។ ឧបមាដូចជា ឈ្មោះ A ត្រូវចាញ់បោកឈ្មោះ B ហើយលក់អចលនទ្រព្យរបស់ខ្លួនឱ្យទៅឈ្មោះ B ព្រមទាំងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិទៀតផងរីឯឈ្មោះ B វិញ ថ្វីត្បិតតែបាននិយាយថានឹងបង់ប្រាក់ថ្លៃអចលនទ្រព្យនោះក៏ដោយ ក៏នៅតែមិនបង់ឱ្យដដែល ។ ទោះជាឈ្មោះA លើកយកការឆបោកនេះមកធ្វើជាមូលហេតុលុបចោលកិច្ចសន្យាហើយក្តី ឈ្មោះ B បានយកអចលនទ្រព្យនោះទៅបង្កើតហ៊ីប៉ូតែកដាក់ជាប្រាតិភោគដើម្បីខ្ចីប្រាក់ពីឈ្មោះ C ដោយចាត់ទុកថាអចលនទ្រព្យនោះជាកម្មសិទ្ធិរបស់ខ្លួន ។ នៅក្នុងករណីនេះ បើឈ្មោះ C មិនបានដឹងអំពីការបោករបស់ឈ្មោះ B ទេនោះ ឈ្មោះ A មិនអាចយកអនុភាពនៃការលុបចោល មកតតាំងជាមួយនឹងឈ្មោះ C បានទេ (ដោយហេតុតែគេមិនអាចនិយាយទៅកាន់ឈ្មោះ C ថាបានលុបចោលកិច្ចសន្យារួចហើយនោះ ដូច្នេះមិនអាច

បដិសេធសិទ្ធិរបស់ឈ្មោះ C ទៅលើហ៊ីប៉ូតែកបានទេ) ។ យើងយល់ថា ប្រហែលជានឹងមានមតិខ្លះគិតថា បើយ៉ាងដូច្នេះមែន គឺវាជាការគួឱ្យអាណោចអាធម្មពេកហើយ ចំពោះជនណាដែលត្រូវគេឆបោក ក៏ប៉ុន្តែផ្ទុយទៅវិញគេក៏ត្រូវតែការពារឈ្មោះ C ផងដែរ ដែលបានធ្វើជំនួញដោយពុំបានដឹងរឿងអ្វីសោះ ហើយដែលបានគិតថាអចលនទ្រព្យនោះជារបស់ឈ្មោះ B មែន (មានទាំងការចុះបញ្ជីផ្ទេរកម្មសិទ្ធិថែមទៀតផង) ។ គេគួរគិតថា អ្នកដែលអ្នកដែលត្រូវគេឆបោកនោះ ក៏មានការធ្វេសប្រហែសខ្លះដែរ ។ នៅក្នុងករណីនេះ ក្រមរដ្ឋប្បវេណីបានកំណត់នូវបទបញ្ញត្តិទាំងឡាយ ដោយឈរលើការស្វែងរកយុត្តិធម៌សំរាប់សាមុីជនដែលពាក់ព័ន្ធទាំងអស់ (នៅក្នុងករណីនេះ គេត្រូវការពារភាគីទទួលការឆបោកបន្តិចក៏ពិតមែន ប៉ុន្តែក៏មិនត្រូវការពារអ្នកនោះច្រើនជ្រុល រហូតទាល់តែធ្វើឱ្យតតិយជនដែលបានធ្វើជំនួញដោយដឹងអំពីរឿងឆបោកអ្វីបន្តិចឡើយនោះទទួលរងពលិកម្មផងដែរទេ ។ រីឯការគម្រាមកំហែងវិញ គេពិបាកនឹងគិតថាជនដែលត្រូវគេគម្រាមកំហែងនោះមានការធ្វេសប្រហែស ឬ មានកំហុសដែរឬទេនោះណាស់ ទោះបីជនទី ៣ ជាតតិយជនប្រកបដោយសុទ្ធចិត្តក៏ដោយ ។ គេត្រូវតែការពារជនដែលបានបង្ហាញឆន្ទៈដោយការគម្រាមកំហែងនោះជាដាច់ខាត ។ ដោយសារហេតុនេះហើយ ដែលមាត្រា ៩៦ កថាខ័ណ្ឌទី ៣ កំណត់នូវបទបញ្ញត្តិទៅលើតែការឆបោកតែប៉ុណ្ណោះ) ។

## សុចរិត និងទុច្ចរិត

នៅក្នុងពិភពច្បាប់ អ្វីដែលហៅថា សុច្ចរិត គឺការមិនបានដឹងនូវរឿងហេតុអ្វីសោះឡើយ រីឯទុច្ចរិតវិញ គឺការបានដឹងបានឮអំពីរឿងហេតុដែលបានកើតឡើង (នៅក្នុងករណីខ្លះ សុច្ចរិតមិនសំដៅត្រឹមតែការមិនបានដឹងរឿងហេតុប៉ុណ្ណោះទេ គឺមានរហូតដល់ការជឿទុកចិត្តទៀតផង (ឧបមាដូចជាការជឿថាភាគីដែលខ្លួនធ្វើជំនួញជាមួយនោះ ជាជនមានសិទ្ធិពិតប្រាកដជាដើម) ដោយសារពុំបានដឹងរឿងហេតុដែលកើតឡើងនោះ ។ ដូច្នេះ ជនសុច្ចរិត នៅទីនេះមិនមែនសំដៅលើជនប្រកបដោយចិត្តល្អវិសេសវិសាលនោះឡើយ ។ ផ្ទុយទៅវិញ ទឹកចិត្តក្នុងគោលបំណងធ្វើឱ្យអ្នកដទៃរងទុក្ខព្រួយ នោះមិនហៅថាទុច្ចរិតទេ ហៅថា "ឆន្ទៈព្យាបាទ" ។ ល ។ ទោះជាពុំមានបំណងសកម្មក្នុងការធ្វើឱ្យអ្នកដទៃទទួលរងគ្រោះក៏ដោយ ប៉ុន្តែបើសនជាបានដឹងថាជនដទៃផ្សេងទៀតបានធ្វើកិច្ចសន្យារួចទៅហើយដើម្បីទិញវត្ថុអ្វីមួយ ហើយថ្វីត្បិតតែមានការយល់ច្បាស់ថាការដណ្តើមទិញវត្ថុដែលនោះអាចនឹងធ្វើឱ្យអ្នកទិញមុននោះរងអំពល់ក៏ដោយ ក៏នៅតែដណ្តើមទិញយកទៀត ។ នេះគេហៅថាជា "ទុច្ចរិតដែលរំលោភលើទំនុកចិត្ត" ។

## ៣.៣. ការបង្ហាញឆន្ទៈដោយភ័ន្តច្រឡំ

តើគេដោះស្រាយយ៉ាងដូចម្ដេច ចំពោះករណីដែលមានបញ្ហារឹតតែធ្ងន់ធ្ងរជាងនេះទៅទៀត ដូចជាករណីដែលសាមីខ្លួនបានបង្ហាញឆន្ទៈដែលមិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួនទេ ដោយសារមានការយល់ខុសទាំងស្រុងចំពោះរឿងអ្វីមួយនោះ? ក្រមរដ្ឋប្បវេណីហៅនេះថាជាការភ័ន្តច្រឡំ ។ ក្នុងករណីដែលបានបង្ហាញឆន្ទៈដោយគ្មានចេតនាអ្វីសោះនោះ ឧទាហរណ៍ដូចជាករណីលក់វត្ថុដោយសរសេរតម្លៃខ្វះលេខសូន្យមួយខ្ទង់ជាដើម ការបង្ហាញឆន្ទៈនេះត្រូវចាត់ទុកជាមោឃៈ (មាត្រា ៩៥) ។ ដោយឈរលើជំហរគោរពស្វ័យភាពខាងឆន្ទៈរបស់សាមីខ្លួន បើសិនជាសេចក្ដីបង្ហាញមានការខ្វះទាំងស្រុងនូវភាពស៊ីគ្នានឹងឆន្ទៈពិតប្រាកដរបស់សាមីខ្លួន (គេហៅថាជា *ការខ្វះឆន្ទៈ*) គេចាត់ទុកនេះជាការបង្ហាញឆន្ទៈដែលគ្មានអានុភាពតាំងពីដំបូងទី (បើប្រៀបធៀបទៅនឹងការបង្ហាញឆន្ទៈតាមការឆបោកដែលបានរៀបរាប់ខាងលើ យើងឃើញថានៅក្នុងករណីនៃការឆបោក ការពោលពាក្យថា "នឹងលក់វត្ថុនេះ" គឺជាការចង្អុលឱ្យឃើញនូវវត្តមាននៃឆន្ទៈរបស់អ្នកពោលពាក្យនោះនៅក្នុងចិត្តផងខ្លួនរួចជាស្រេច (ហៅថា*ឆន្ទៈមានអានុភាពជាអត្តនោមតិ* ថា "នឹងលក់វត្ថុនេះ" ទោះបីជាការបង្ហាញនេះកើតឡើងពីការឆបោកក៏ដោយ ។ ផ្ទុយទៅវិញ ចំពោះការភ័ន្តច្រឡំវិញ គឺពុំមានវត្តមាននៃឆន្ទៈដែលមានអានុភាពជាអត្តនោមតិ នៅក្នុងចិត្តរបស់សាមីខ្លួនដូចតាមសេចក្ដីដែលបានបង្ហាញចេញនោះទេ ដូច្នេះហើយទើបច្បាប់កំណត់អំពីមោឃៈភាពដែលមានអានុភាពច្បាប់ខ្លាំងជាងការលុបចោលទៅទៀត) ។ ក៏ប៉ុន្តែ ដោយហេតុថា ការបង្ហាញឆន្ទៈបែបនេះជះឥទ្ធិពលខ្លាំងទៅលើភាគីជាដៃគូ ច្បាប់មិនអាចទទួលស្គាល់ដោយងាយស្រួលនូវមោឃភាពបណ្ដាលមកពីការភ័ន្តច្រឡំនេះបានឡើយ ។ មាត្រា ៩៥ បានដាក់ល័ក្ខខ័ណ្ឌកំណត់ថា នៅពេលដែលមានកត្តាភ័ន្តច្រឡំនៅក្នុងធាតុផ្សំនៃសកម្មភាពគតិយុត្ត (ភាគច្រើនគឺកិច្ចសន្យា) ការបង្ហាញឆន្ទៈនោះត្រូវចាត់ទុកជាមោឃៈ ។ ហើយនៅក្នុងបដិញ្ញត្តិនៃមាត្រាដដែលបានចែងថា នៅពេលដែលអ្នកបង្ហាញឆន្ទៈបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ អ្នកនោះមិនអាចអះអាងអំពីមោឃភាពនៃការបង្ហាញឆន្ទៈរបស់ខ្លួនដោយខ្លួនឯងបានឡើយ (ប៉ុន្តែពុំមានចោទជាបញ្ហាទេ ប្រសិនបើភាគីម្ខាងទៀតមានបំណងចាត់ទុកការបង្ហាញឆន្ទៈនេះជាមោឃៈ) ។

អាស្រ័យហេតុនេះ ដើម្បីបញ្ជាក់ថានេះជាការបង្ហាញឆន្ទៈដោយភ័ន្តច្រឡំនោះ ជាដំបូង គេត្រូវបង្ហាញជាចាំបាច់នូវអ្វីដែលមានភាពជាក់ស្តែងច្បាស់លាស់ សំគាល់អំពីកត្តាភ័ន្តច្រឡំមាន នៅក្នុងធាតុផ្សំនៃសកម្មភាពគតិយុត្ត ពោលគឺការបញ្ជាក់ថា គង្វាងរវាងឆន្ទៈនិងការបង្ហាញ ឆន្ទៈបានកើតមានឡើងមែន ធ្វើឱ្យឃើញថា បើមិនមានការភ័ន្តច្រឡំទេនោះ គឺគេមុខជាមិន បង្ហាញឆន្ទៈយ៉ាងដូច្នេះទេ ។ រួចហើយគេចាំបាច់ត្រូវបង្ហាញថែមទៀតនូវភាពគ្មានកំហុសអ្វីធ្ងន់ធ្ងរ កុំឱ្យតែមានការចោទថា ប្រសិនបើអ្នកបង្ហាញឆន្ទៈពិតជាបានធ្វើការប្រុងប្រយ័ត្នតែបន្តិចនោះ គឺពុំមានធ្លោះធ្លោយដូច្នេះទេ ។ លុះត្រាតែមានការបំពេញតាមគ្រប់ល័ក្ខខ័ណ្ឌទាំងពីរនេះហើយ ទើបគេអាចសន្និដ្ឋានបានថាមានមោឃភាពដោយហេតុមកពីការភ័ន្តច្រឡំពិតមែន។

ការភ័ន្តច្រឡំមានដូចជា ការផ្តល់តាវកាលិកដោយច្រឡំ ឬក៏ការសរសេរអក្សរខុសជាដើម ។ ប៉ុន្តែមានការចោទឡើងជាបញ្ហាចំពោះការភ័ន្តច្រឡំម្យ៉ាង ដែលគេហៅថាជាការភ័ន្តច្រឡំខាង មូលហេតុ ។ ឧទាហរណ៍ដូចជាក្នុងករណីនៃការទិញសេះមួយក្បាល់ ដែលអ្នកទិញបានគិតថា សេះនេះមានផ្ទៃពោះ (ដោយមូលហេតុនេះហើយ ទើបបានជាទិញសេះនោះ) ប៉ុន្តែតាមពិតទៅ សេះនោះគ្មានផ្ទៃពោះទេ (បើដឹងជាយ៉ាងដូច្នេះមែន គឺគេមិនទិញសេះនោះទេ) ។ យុត្តិសាស្ត្រ ច្បាប់ក៏បានចាត់ទុកការភ័ន្តច្រឡំបែបនេះថា អាចក្លាយជាការភ័ន្តច្រឡំនៃធាតុផ្សំបានដែរប្រសិន បើមានការបង្ហាញអំពីមូលហេតុនេះជាមុន ។ ការគិតដូច្នេះក៏បានទទួលនូវការរិះគន់ផងដែរ ។ ដោយហេតុថា យ៉ាងហោចណាស់ក៏គេត្រូវការពារភាគីម្ខាងទៀតដែរដែលមិនបានទទួលការជូន ដំណឹងអំពីមូលហេតុនៃកិច្ចសន្យាទេនោះ ដូច្នេះគំនិតដែលអះអាងថាការភ័ន្តច្រឡំនេះអាចក្លាយ ទៅជាការភ័ន្តច្រឡំនៃធាតុផ្សំបាន ទំនងជាមានន័យត្រឹមត្រូវ លុះត្រាតែក្នុងករណីដែលមានការ បង្ហាញទុកជាមុនថា"ទិញសេះនេះព្រោះវាមានផ្ទៃពោះ" ។

**លក្ខខ័ណ្ឌ និងអានុភាព**

នៅក្នុងពិភពច្បាប់ ស្ថានភាពយ៉ាងណាមួយដែលត្រូវមានជាចាំបាច់ ដើម្បីអាចអនុវត្តបាននូវបទបញ្ញត្តិណាមួយ (ដើម្បីឱ្យបញ្ញត្តិច្បាប់នោះអាចប្រើការបាន) គេហៅថាជា លក្ខខ័ណ្ឌ (ភាសាជប៉ុនហៅថា "យ៉ោកេន") ។ លក្ខខ័ណ្ឌសំរាប់ធ្វើការអះអាងនូវមោឃភាពដោយហេតុនៃការភ័ន្តច្រឡំនោះ គឺចាំបាច់ត្រូវមានការភ័ន្តច្រឡំជាធាតុផ្សំ ហើយនិងគ្មានកំហុសអ្វីធ្ងន់ធ្ងរពីអ្នកបង្ហាញឆន្ទៈ (រីឯពាក្យថា "លក្ខខ័ណ្ឌ" ក្នុងន័យមួយផ្សេងទៀត ដែលភាសាជប៉ុនអានថា "ត្យ៉ូកេន" នោះវិញ គឺសំដៅលើការកំណត់លក្ខខ័ណ្ឌតាមច្បាប់ក្នុងទំរង់ឃ្លាថា "ប្រសិនបើ" ដូចជាការពោលពាក្យថា "ប្រសិនបើប្រឡងជាប់មហាវិទ្យាល័យយើងនឹង ជូនរថយន្តនេះជារង្វាន់" ជាដើម) ។ "អានុភាព"គឺជាអ្វីដែលនឹងត្រូវកើតមានឡើងបន្ទាប់ពីពេលដែលបានបំពេញចប់រួចរាល់ទៅតាមលក្ខខ័ណ្ឌចាំបាច់ទាំងឡាយ និងបានអនុវត្តតាមច្បាប់បញ្ញត្តិហើយនោះ ។ ដូចនេះ ពាក្យថា"អានុភាព"(ជាភាសាជប៉ុនហៅថា "ឃោកា" ប្រើក្នុងច្បាប់មិនមានន័យ ដូចពាក្យថា "គីគីម៉េ" ក្នុងភាសាជប៉ុន ដែលមានន័យថា "ប្រសិទ្ធិភាព" ដូចក្នុងករណីពោលពាក្យថា "មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយទំងន់" នោះជាដើម ។

## ៣.៤.ថបនីយផ្លូវចិត្ត

មួយវិញទៀតមនុស្សយើងក៏មានការនិយាយភូតភរដោយមានចិត្តចេតនាផងដែរ ។ ចំពោះករណីនេះ តើជាការត្រឹមត្រូវដែរឬទេដែលចាត់ទុកការបង្ហាញឆន្ទៈបែបនេះថាពុំមានអានុភាពទេនោះ? នៅក្នុងករណីនេះ ភាគីដៃគូដែលមិនបានដឹងអំពីរឿងរ៉ាវអ្វីទាល់តែសោះ មុខជានឹងជឿទៅលើពាក្យពេចន៍ទាំងនោះជាពុំខាន ។ ក្រមរដ្ឋប្បវេណីហៅបញ្ហានេះថា ជាថបនីយផ្លូវចិត្ត (មានន័យថាមានការបំរុងទុកជាស្រេចនៅក្នុងចិត្ត) ហើយចាត់ទុកការតាំងចិត្តនិយាយលេង កំប្លែង ឬភូតភរ ដោយដឹងថាគេនឹងជឿលើសំដីរបស់ខ្លួននោះ ថាជាការបង្ហាញឆន្ទៈប្រកបដោយ

សុពលភាព ។ ក៏ប៉ុន្តែ ប្រសិនបើភាគីជាដៃគូបានដឹងជាមុនថាពាក្យពេចន៍ទាំងនេះជាការនិយាយលេងកំប្លែងនោះ គឺត្រូវចាត់ទុកថាគ្មានសុពលភាពទេ (មាត្រា៩៣ រួមនឹងបដិបញ្ញត្តិ) ។

## ៣.៥.ការបង្ហាញឆន្ទៈមិនពិតដោយឃុបឃិតគ្នា

ក្នុងកំរិតមួយដែលរិតតែស៊ីជម្រៅទៅទៀត សាមីខ្លួនអាចឃុបឃិតគ្នាជាមួយនឹងដៃគូពិគ្រោះគ្នាហើយបង្ហាញឆន្ទៈដោយមានការភូតភរ ។ ឧទាហរណ៍ដូចជា នៅក្នុងទំនាក់ទំនងរវាងឈ្មោះ A និងឈ្មោះ B ដើម្បីដោះខ្លួនឱ្យរួចពីការទាមទារនៃម្ចាស់បំណុលរបស់ឈ្មោះ A ពោលគឺក្នុងបំណងឱ្យគេយល់ច្រឡំថា ទ្រព្យសម្បត្តិរបស់ឈ្មោះ A មានតិចតួចទេនោះ ទាំងពីរនាក់បានឃុបឃិតគ្នាធ្វើជាថាបានលក់ដីកម្មសិទ្ធិរបស់ឈ្មោះ A ទៅជាឱ្យឈ្មោះ B ជាដើម ។ នេះគេហៅថាជា *ការបង្ហាញឆន្ទៈមិនពិត* (ការបង្ហាញឆន្ទៈមិនពិតដោយឃុបឃិតគ្នា) ហើយត្រូវចាត់ទុកជាមោឃៈ (មាត្រា៩៤ កថាខ័ណ្ឌ១) ។ ក៏ប៉ុន្តែនៅក្នុងករណីនេះ ប្រសិនបើឈ្មោះ C ដែលជាជនសុចរិតម្នាក់បានជឿសំដីទាំងនេះ និងបានទិញដីពីឈ្មោះ B រួចទៅហើយនោះ បើចាត់ទុកថាការលក់ទិញរវាងឈ្មោះ A និងឈ្មោះ B គ្មានសុពលភាពទេ គឺវានឹង នាំឱ្យឈ្មោះ C ទទួលរងការខូចខាតជាពុំខាន ។ នៅក្នុងករណីនេះ ឈ្មោះ A និងឈ្មោះ B ពុំអាចចាត់ទុកការបង្ហាញឆន្ទៈដោយភូតភរនេះជាមោឃៈ ហើយលើកយកទៅតទល់ជាមួយឈ្មោះ C ដែលជាតតិយជនសុចរិតនោះបានឡើយ (មាត្រា៩៤ កថាខ័ណ្ឌ២) ។ អត្ថន័យដើមនៃបទបញ្ញត្តិនេះគឺដើម្បីអនុវត្តទៅលើតែសាមីភាគីនៃកិច្ចព្រមព្រៀងតែប៉ុណ្ណោះ ទោះបីជាមានការព្រមព្រៀងគ្នាខុសពីរូបភាពក្រៅ (នៃកិច្ចសន្យាជាដើម) ក៏ដោយ ប៉ុន្តែសព្វថ្ងៃនេះត្រូវបានគេចាត់ទុកជា *បទបញ្ញត្តិការពារជនដែលបានជឿទុកចិត្តលើរូបភាពក្រៅ* ដែលមានសារៈសំខាន់ជាពិសេសនៅក្នុង"ការអនុវត្តន៍ច្បាប់ដោយវិធីប្រៀបប្រដូច"ទៅលើវិវាទជាក់ស្តែងដែលកើតមាននៅក្នុងការលក់ទិញអចលនវត្ថុជាដើម (សូមអានអំពីការប្រែប្រួលសិទ្ធប្រត្យ័ក្សនៅ*ជំពូកទី ៣ ស្តីពីប្រត្យ័ក្ស(១) -លក្ខណៈទូទៅ-,២.២,ង)* ។

# ៤. តំណាង, តំណាងគ្មានសិទ្ធិ, តំណាងដែលមានលក្ខណៈជារូបភាព

## ៤.១.ស្វ័យភាពខាងឆន្ទៈ និងរបបដាក់តំណាង

ឈរនៅលើគោលការណ៍ស្វ័យភាពខាងឆន្ទៈ យើងរាល់គ្នាអាចបង្កើនទំនាក់ទំនងជាផ្លូវច្បាប់ជាមួយគ្នា ទៅតាមឆន្ទៈរបស់ខ្លួនម្នាក់បានដោយសេរី ។ ក៏ប៉ុន្តែវិសាលភាពនៃសកម្មភាពរបស់យើងម្នាក់ៗរមែងមានព្រំដែន ។ ម្យ៉ាងទៀត ដូចបានរៀបរាប់រួចហើយថាចំពោះជនដែលត្រូវបានកំរិតសមត្ថភាព ដោយហេតុថាជននេះខ្លួនឯងផ្ទាល់មិនអាចប្រព្រឹត្តិអ្វីមួយដោយឆន្ទៈបរិបូរណ៍កើតនោះ ជាចាំបាច់ត្រូវមានអ្នកណាម្នាក់ជួយបំពេញបង្គ្រប់ឆន្ទៈនោះជាដាច់ខាត ។ ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីបានបង្កើតរបបមួយឱ្យជនម្នាក់ទៀតបង្ហាញឆន្ទៈជំនួសម្ចាស់សិទ្ធិបាន ដោយចាត់ទុកការបង្ហាញឆន្ទៈជំនួសនេះថា ជាការបង្ហាញឆន្ទៈរបស់ម្ចាស់សិទ្ធិផ្ទាល់ ហើយមានអានុភាពផ្លូវច្បាប់ទៅតាមនោះ ។ នេះគឺជាការតំណាង ។ ដូច្នេះ យើងអាចនិយាយបានថា ការតំណាងគឺជារបបមួយសំរាប់បំពេញបន្ថែមនូវស្វ័យភាពខាងឆន្ទៈ។

## ៤.២.តំណាងដែលច្បាប់បានកំណត់ និងតំណាងតាមការស្ម័គ្រចិត្ត

តំណាងចែកចេញជាពីរ គឺតំណាងដែលច្បាប់បានកំណត់ និង តំណាងតាមការស្ម័គ្រចិត្ត ។ ចំពោះអនីតិជន ឳពុកម្តាយគឺជាអ្នកតំណាងដែលច្បាប់បានកំណត់ ដោយសារច្បាប់បានប្រគល់ឋានៈជាអ្នកតំណាង ។ ប៉ុន្តែជាធម្មតា តំណាងរមែងធ្វើឡើងដោយកិច្ចសន្យាប្រគល់សិទ្ធតំណាងទៅជនណាម្នាក់ សំរាប់ធ្វើជាអ្នកតំណាងតាមការស្ម័គ្រចិត្ត ។ ជនដែលទៅជាអ្នកតំណាងត្រូវតែបញ្ជាក់ឱ្យច្បាស់ថាខ្លួននឹងប្រព្រឹត្តិដើម្បីជាប្រយោជន៍ដល់ម្ចាស់សិទ្ធិជាដាច់ខាត ។ រាល់សកម្មភាពគតិយុត្តដែលអ្នកតំណាងបានអនុវត្តនឹងមានប្រសិទ្ធិភាពធ្លាក់ទៅលើម្ចាស់សិទ្ធិ ពោលគឺត្រូវទុកដូចម្ចាស់សិទ្ធិបានអនុវត្តដូច្នេះដែរ (មាត្រា៩៩) ។ ផ្ទុយទៅវិញ បើពុំមានការបញ្ជាក់ច្បាស់លាស់ទេ (ហើយយោងតាមមជ្ឈដ្ឋានជុំវិញក៏មិនដឹងថាម្ចាស់សិទ្ធិជាអ្នកណាផងដែរនោះ) ក្នុងគោលបំណងដើម្បីការពារភាគីម្ខាងទៀត ការបង្ហាញឆន្ទៈរបស់អ្នកតំណាងនឹងត្រូវចាត់ថាជាការអនុវត្តដើម្បីផលប្រយោជន៍របស់អ្នកតំណាងផ្ទាល់ខ្លួន រួចហើយអានុភាពនឹងមានទៅលើអ្នកតំណាងខ្លួនឯងផ្ទាល់តែម្តង (មាត្រា១០០) ។ ក៏ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតដឹងបានថា នេះជាឆន្ទៈតំណាង

(ធ្វើដើម្បីម្ចាស់សិទ្ធិ) របស់អ្នកតំណាងនោះ អានុភាពនៃទង្វើនឹងធ្លាក់ទៅលើម្ចាស់សិទ្ធិវិញ (មាត្រា ១០០ បដិញ្ញា) ។

មួយវិញទៀត ដោយហេតុថាអានុភាពនៃការតំណាងនេះនឹងធ្លាក់ទៅលើម្ចាស់សិទ្ធិ ដូច្នេះ អ្នកតំណាងពុំត្រូវទទួលរងការខាតបង់ផលប្រយោជន៍អ្វីបន្តិចសោះឡើយ ។ សូម្បីតែជនដែលត្រូវបានកម្រិតសមត្ថភាពដូចបានរៀបរាប់ខាងលើ ក៏អាចធ្វើជាតំណាងរបស់ជនដទៃទៀតបានដែរ (មាត្រា ១០២) ។ ក៏ប៉ុន្តែ ជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលកំពុងតែធ្វើជាអ្នកតំណាងឱ្យគេនោះ នឹងត្រូវបញ្ចប់ឋានៈជាតំណាងនេះ ប្រសិនបើខ្លួនត្រូវតុលាការសំរេចឱ្យដាក់នៅក្រោមរបបអាណាព្យាបាលដូចមានរៀបរាប់ខាងលើ ។ ជាការដូចគ្នាដែរ ចំពោះករណីដែលអ្នកតំណាងត្រូវទទួលធនក្ស័យ ឬម្ចាស់សិទ្ធិទទួលមរណភាព ឬអ្នកតំណាងទទួលមរណៈភាព (មាត្រា ១១១ កថាខ័ណ្ឌទី ១) ។ ថ្វីត្បិតតែអានុភាពនៃការតំណាង ត្រូវចងចំពោះម្ចាស់សិទ្ធិ ក៏ពិតមែន ប៉ុន្តែជាការជាក់ស្តែងការបង្ហាញឆន្ទៈគឺធ្វើឡើងដោយអ្នកតំណាង ។ ដូច្នេះក្នុងករណីដែលមានចោទជាបញ្ហាកើតចេញពីវិការៈ ឬពីភាពសុចរិត្ត ឬភាពទុច្ចរិត នៅក្នុងការបង្ហាញឆន្ទៈនោះ ជាគោលការណ៍ គឺត្រូវធ្វើការវិនិច្ឆ័យទៅតាមករណីរបស់អ្នកតំណាងនិមួយៗ (មាត្រា ១០១ កថាខ័ណ្ឌទី ១) ។

ការក្លាយទៅជាអ្នកតំណាងឱ្យភាគីម្ខាងទៀតរបស់ខ្លួន (ការចុះកិច្ចសន្យាជាមួយខ្លួនឯង) ឬអ្នកតំណាងឱ្យគូភាគទាំងសងខាង សំរាប់សកម្មភាពគតិយុត្តតែមួយ (ការតំណាងឱ្យភាគីទាំងពីរ) មិនអាចធ្វើបានទេ លុះត្រាតែមានការអនុញ្ញាតពីសាមីខ្លួនទុកជាមុនសិន (មាត្រា ១០៨)។

## ៤.៣. តំណាងគ្មានសិទ្ធិ និងតំណាងដែលមានលក្ខណៈជារូបភាព

តើនឹងទៅជាយ៉ាងណាដែរ ប្រសិនបើជនដទៃណាម្នាក់ដែលពុំបានទទួលសិទ្ធិជាតំណាង (សិទ្ធិឱ្យធ្វើជាតំណាង) សោះឡើយនោះ បានភូតភរថាខ្លួនជាអ្នកតំណាង ដើម្បីធ្វើកិច្ចសន្យាជាដើម? នេះគេហៅថា ការតំណាងដោយគ្មានសិទ្ធិ ហើយបើគ្មានការទទួលស្គាល់តាមក្រោយពីម្ចាស់សិទ្ធិទេ គឺពុំអាចកើតមានសុពលភាពបានឡើយ (មាត្រា ១១៣ កថាខ័ណ្ឌទី១) ។ ការកំណត់បែបនេះក៏ជាការត្រឹមត្រូវដែរ ដើម្បីការពារម្ចាស់សិទ្ធិ ។ ក្នុងករណីនេះ ភាគីម្ខាងទៀតអាចទាមទារ

ឱ្យអ្នកតំណាងដោយគ្មានសិទ្ធិនេះអនុវត្តកិច្ចសន្យាជំនួសម្ចាស់សិទ្ធិ ឬសងជំងឺចិត្តបាន (មាត្រា ១១៧ កថាខ័ណ្ឌទី ១) ។

ក៏ប៉ុន្តែ ទោះជាផ្ទុយនឹងការពិតក៏ដោយ ប្រសិនបើម្ចាស់សិទ្ធិបានបង្ហាញថាបានប្រគល់សិទ្ធិជាតំណាងដល់ជននោះ ឬក៏ថាបានប្រគល់សិទ្ធិជាតំណាងទៅជននោះមែនប៉ុន្តែជននោះបានធ្វើសកម្មភាពជាតំណាងដោយហួសព្រំដែននៃសិទ្ធិដែលបានប្រគល់ ឬក៏ថាកាលពីមុនបានប្រគល់សិទ្ធិជាតំណាងនេះដល់ជននោះមែន ប៉ុន្តែមិនបានប្រាប់ជននោះថាសិទ្ធិជាតំណាងត្រូវបានរលត់ហើយជាដើម ក្នុងករណីនេះ គេចាំបាច់ត្រូវការពារភាគីម្ខាងទៀតដែលបានជឿទុកចិត្តលើការតំណាងអាស្រ័យលើរូបភាពខាងក្រៅនោះ ។ ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីបានបង្កើតរបបមួយហៅថាតំណាងដែលមានលក្ខណៈជារូបភាព ដោយកំណត់ឱ្យម្ចាស់សិទ្ធិទទួលខុសត្រូវក្នុងករណីដែលភាគីម្ខាងទៀតមានការជឿទុកចិត្តលើរូបភាពខាងក្រៅនេះ ដោយភាពសុចរិតនិងមិនមានកំហុសអ្វីសោះ ។ មាត្រា ១០៩ ចែងអំពីតំណាងដែលមានលក្ខណៈជារូបភាព ក្រោយការបញ្ជាក់អំពីការប្រគល់សិទ្ធិជាតំណាង មាត្រា ១១០ ចែងអំពីតំណាងដែលមានលក្ខណៈជារូបភាព អាស្រ័យការអនុវត្តហួសព្រំដែននៃអំណាច ហើយមាត្រា ១១២ ចែងអំពីតំណាងដែលមានលក្ខណៈជារូបភាព ក្រោយការរលត់សិទ្ធិជាតំណាង ។ (មាត្រា ១០៩ ចាស់មិនមានចែងច្បាស់អំពីលក្ខខ័ណ្ឌនៃភាពសុចរិត និងការមិនមានកំហុសនោះទេ ប៉ុន្តែបញ្ញត្តិចែងអំពីលក្ខខ័ណ្ឌនេះត្រូវបានបញ្ចូលបន្ថែមនៅពេលធ្វើវិសោធនកម្មឆ្នាំ ២០០៤ ។ម្យ៉ាងទៀត ភាពសុចរិតនិងការមិនមានកំហុសណាមួយបង្កឡើងដោយភាគីជាជនទី ៣ ទេនោះ ក៏ត្រូវបានបូកបញ្ចូលទៅក្នុងពាក្យថា "មូលហេតុសមស្រប" ដែលមានចែងក្នុងមាត្រា ១១០) ។

## ៥. មោឃភាព និងការលុបចោល

នៅក្នុងក្រមរដ្ឋប្បវេណី ពាក្យថាមោឃៈ មានន័យថាគ្មានការកកើតសុពលភាពតាំងពីដំបូងទី ។ មោឃៈចែកជាពីរទៀត ទីមួយ គឺករណីដែលច្បាប់ចាត់ទុកជាដាច់ខាតថាមោឃៈ ដូចជាសកម្មភាពគតិយុត្តទាំងឡាយណាដែលប្រឆាំងនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់នៃសង្គមនៅក្នុងមាត្រា ៩០ មួយទៀតគឺករណីដែលភាគីពាក់ពន្ធ័ទាំងឡាយ ចាត់ទុកជាមោឃៈ

ដូចជាករណីនៃការភ័ន្តច្រឡំ ដែលមានការខ្វះខាតទាំងស្រុងនូវឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈជាដើម ។ រីឯ ការលុបចោល មានន័យថាមានសុពលភាពពីដំបូង រហូតមកទល់ពេលលុបចោល ។ បន្ទាប់ពីបានលុបចោលហើយ គឺគេសន្មត់ថាគ្មានសុពលភាពតាំងពីដំបូងទីមក (មាត្រា ១២១) ពោលគឺសើរើត្រឡប់ថយក្រោយវិញ ដោយចាត់ទុកថាគ្មានឥទ្ធិពលអ្វីឡើយចាប់ពីដើមទីមក (ហៅថាមានអានុភាពប្រតិសកម្ម) ។ ហេតុដូច្នេះហើយ គេអាចទទួលស្គាល់ការយល់ព្រមតាមក្រោយនូវសកម្មភាពដែលអាចលុបចោលបាន តួយ៉ាងដូចជាកិច្ចសន្យាលក់ដែលបានធ្វើឡើងដោយគ្មានការយល់ព្រមពីឪពុកម្ដាយជាដើម ឪពុកម្ដាយអាចទទួលយល់ព្រមតាមក្រោយចំពោះកិច្ចសន្យានេះបាន (ហៅថា ការទទួលយល់ព្រមតាមក្រោយ) ហើយការទទួលយល់ព្រមនេះក៏មានអានុភាពប្រតិសកម្មដែរ (មាត្រា ១២២) ។ ក៏ប៉ុន្តែ សកម្មភាពមោឃៈដែលជាសកម្មភាពគ្មានសុពលភាពតាំងពីដំបូងទីនោះ គេមិនអាចទទួលយល់ព្រមតាមក្រោយធ្វើឱ្យមានសុពលភាពបានឡើយ (មាត្រា ១១៩) ។ ហេតុដូច្នេះ ប្រសិនបើមានការយល់ព្រមចាត់ទុកការបង្ហាញឆន្ទៈដោយការភ័ន្តច្រឡំឱ្យនៅដដែលនោះ ករណីនេះមិនមែនជាការយល់ព្រមតាមក្រោយទេ តែត្រូវចាត់ថានេះជាការបង្ហាញឆន្ទៈជាថ្មីមួយទៀត (មាត្រា ១១៩ បដិញ្ញត្តិ) ។ រួចហើយ ក្រមរដ្ឋប្បវេណីបានចែងកំណត់អំពីជនដែលអាចធ្វើការលុបចោលបាន (អ្នកមានសិទ្ធិលុបចោល) នៅក្នុងមាត្រា ១២០ (គឺបានតែជនដែលត្រូវបានកម្រិតសមត្ថភាពជាសាមីខ្លួនផ្ទាល់ ដូចជាអនិតិជនជាដើម ឬជនដែលបានបង្ហាញឆន្ទៈដោយសារការឆបោក ព្រមទាំងអ្នកតំណាងឬប្រតិសិទ្ធិរបស់ជនទាំងនេះ) ។ម្យ៉ាងទៀត សកម្មភាពមោឃៈមិនអាចទៅជាមានសុពលភាពនាអនាគតកាល ដោយសារពេលវេលាបានកន្លងផុតទៅមុខនោះបានឡើយ ក៏ប៉ុន្តែសកម្មភាពដែលសមនឹងលុបចោលបាន អាចនឹងទៅជាពុំអាចលុបចោលបាននាពេលអនាគត ដោយសារពេលវេលាបានកន្លងផុតទៅ ហើយជាលទ្ធផលគេត្រូវកំណត់ថាមានសុពលភាពក៏មានដែរ (បើពុំបានអនុវត្តសិទ្ធិលុបចោលក្នុងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីពេលទទួលបាននូវការយល់ប្រមតាមក្រោយមក ឬ ២០ ឆ្នាំ បន្ទាប់ពីពេលអនុវត្តសកម្មភាពនោះមកទេ សិទ្ធិលុបចោលនឹងរលត់ដោយអាជ្ញាយុកាល ។(មាត្រា ១២៦ សូមអានផ្នែកទី ៧ ក្នុងជំពូកនេះអំពីអាជ្ញាយុកាល)។

**ការសន្មត់ និការចាត់ទុក**

ក្នុងពាក្យច្បាប់ ការសន្មត់ មានន័យថាជាការសន្មត់ជាបណ្តោះអាសន្នថាវាយ៉ាងដូច្នេះសិន ហើយគេអនុញ្ញាតឱ្យសាមីខ្លួនរកភស្តុតាមបញ្ជាក់ ពោលគឺបញ្ជាក់អះអាងថាវាខុសនឹងការពិតហើយលុបចោលការសន្មត់នោះ ។ ផ្ទុយទៅវិញ ការចាត់ទុក មានន័យថាជាការកំណត់ដោយច្បាប់ថាយ៉ាងនេះ ហើយមិនអាចលុបចោលដោយបញ្ជាក់អះអាងផ្ទុយពីនោះបានទេ ។

## ៦.១.សេចក្តីផ្តើម

នៅក្នុងករណីអនុវត្តសកម្មភាពគតិយុត្ត ភាគីពាក់ពន្ធ័អាចមិនឱ្យសកម្មភាពនោះចាប់មានសុពលភាពភ្លាមបាន ដោយកំណត់ថាចាំដល់ពេលណាមួយនាអនាគតកាល ឬក៏ថាទាល់តែមានហេតុការណ៍ណាមួយកើតមានឡើងក្នុងពេលអនាគត ទើបឱ្យមានសុពលភាព (ឬផ្ទុយទៅវិញឱ្យអស់សុពលភាព) ក៏បាន ។ នេះជាបញ្ហាទាក់ទងទៅនឹង ល័ក្ខខ័ណ្ឌនិងការកំណត់ពេល ។ ភាពខុសគ្នារវាងល័ក្ខខ័ណ្ឌ និងការកំណត់ពេល ស្ថិតនៅត្រង់ចំណុចថា ល័ក្ខខ័ណ្ឌគឺទាក់ទងនឹងហេតុការណ៍មិនច្បាស់ថាកើតមាន ឬមិនកើតមាននោះឡើយ ឧបមាដូចជាការដាក់លក្ខខ័ណ្ឌថាប្រសិនបើជាប់វិញ្ញាបនប័ត្រគណនេយ្យករជាដើម រីឯការកំណត់ពេលវិញគឺឱកាសដែលច្បាស់ជានឹងមកដល់ពិតប្រាកដ (ការសំរេចនៃព្រឹត្តិការណ៍) ឧបមាដូចជាការកំណត់ថាចាប់ពីដើមឆ្នាំក្រោយ ឬក៏ថារហូតដល់ពេលគ្រប់វ័យជានីតិជនជាដើម ។

## ៦.២.ល័ក្ខខ័ណ្ឌ

ល័ក្ខខ័ណ្ឌមានពីរបែប ។ ល័ក្ខខ័ណ្ឌណាដែលធ្វើឱ្យមានសុពលភាពកើតឡើងនៅពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ (ពោលគឺរហូតមកទល់ពេលនោះ សុពលភាពត្រូវបានបង្អង់មិនឱ្យកើតមានឡើង) ហៅថាជា ល័ក្ខខ័ណ្ឌបង្អង់ ។ រីឯល័ក្ខខ័ណ្ឌណាដែលធ្វើឱ្យរលត់សុពលភាពដែលកើតមានរួចហើយតាំងពីពេលចាប់ផ្តើមសកម្មភាពគតិយុត្តមក ហៅថាជា ល័ក្ខខ័ណ្ឌរំលាយ (មាត្រា ១២៧) ។ ការដាក់ល័ក្ខខ័ណ្ឌថា "ប្រសិនបើប្រឡងជាប់មហាវិទ្យាល័យ យើងនឹង

ឱ្យអាហាររូបករណ៍" គឺជាការភ្ជាប់ល័ក្ខខ័ណ្ឌបង្អង់ទៅនឹងកិច្ចសន្យាប្រទានកម្ម ហើយការដាក់ល័ក្ខខ័ណ្ឌថា "ឱ្យនាឡិកានេះទៅអ្នកមែន ប៉ុន្តែបើពុំបានឡើងថ្នាក់ទេត្រូវសងមកយើងវិញ" គឺជាការភ្ជាប់ល័ក្ខខ័ណ្ឌរំលាយទៅនឹងកិច្ចសន្យាប្រទានកម្ម ។ ចំពោះករណីនៃល័ក្ខខ័ណ្ឌដែលគ្មានលទ្ធភាពនឹងបំពេញបាន (ហៅថា ល័ក្ខខ័ណ្ឌដែលគ្មានលទ្ធភាពនឹងបំពេញ) ល័ក្ខខ័ណ្ឌបង្អង់មិនអាចកើតមានអានុភាពបានទេ ដូចនេះត្រូវទុកជាមោឃៈ រីឯល័ក្ខខ័ណ្ឌរំលាយក៏មិនមានលទ្ធភាពលុបចោលសុពលភាពនៃកិច្ចសន្យាបានទេដែរ ដូច្នេះត្រូវក្លាយជាគ្មានល័ក្ខខ័ណ្ឌទៅវិញ (មាត្រា ១៣៣) ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលជនត្រូវទទួលរងការខូចផលប្រយោជន៍ដោយសារល័ក្ខខ័ណ្ឌត្រូវបានបំពេញ បានរារាំងដោយចេតនាមិនឱ្យមានការបំពេញល័ក្ខខ័ណ្ឌទៅបាននោះ ភាគីម្ខាងទៀតអាចចាត់ទុកថាល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញចប់រួចអស់ហើយ (មាត្រា ១៣០) ។

## ៦.៣.ការកំណត់ពេល

ការកំណត់ពេល ទាក់ទងទៅនឹងព្រឹត្តិការណ៍ពិតប្រាកដដែលនឹងឈានមកដល់ ។ ប៉ុន្តែការកំណត់ពេលនេះក៏មានការគិតជាពីរបែបដែរ ។ ការកំណត់ពេលប្រាកដប្រជា ដូចជាថា គិតចាប់ពីខែមេសាឆ្នាំក្រោយតទៅជាដើម ពោលគឺនិយាយពីរយៈពេលដែលមានការកំណត់ជាក់លាក់នូវពេលវេលាដែលនឹងមកដល់ ។ រីឯការកំណត់ពេលមិនប្រាកដប្រជា គឺដូចជាថា នៅពេលមានខ្យល់ព្យុះ ឬទឹកជំនន់ជាដើម ពោលគឺព្រឹត្តិការណ៍នោះពិតមែនជានឹងកើតមានឡើង ប៉ុន្តែមិនដឹងជាពេលណាទើបកើតមានឡើងឡើយ ។ ផលប្រយោជន៍ដែលភាគីពាក់ព័ន្ធទទួលបានមុននឹងការមកដល់នៃពេលកំណត់ ហៅថាជា ប្រយោជន៍នៃការកំណត់ពេល ។ ឧទាហរណ៍ថា ក្នុងករណីដែលគេបានកំណត់យកចុងខែមិនាជាថ្ងៃសងបំណុល នោះកូនបំណុលនឹងទទួលបានប្រយោជន៍នៃការកំណត់ពេល ដោយមិនបាច់សងបំណុលទេរហូតដល់ចុងខែមិនា ។ ប្រយោជន៍នៃការកំណត់ពេលនេះអាចនឹងបោះបង់ចោលបាន បើមិនធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀតទេនោះ (ថ្វីត្បិតតែចុងខែមិនាជាថ្ងៃណាត់សងបំណុលក៏ដោយ បើសងនៅចុងខែកុម្ភៈក៏មិនទាស់ដែរ មាត្រា ១៣៦ កថាខ័ណ្ឌទី ២ ) ។ ប្រយោជន៍នៃការកំណត់ពេលនេះ ត្រូវបានសន្និដ្ឋានថាជាផលប្រយោជន៍សំរាប់កូនបំណុល (មាត្រា ១៣៦ កថាខ័ណ្ឌទី ១) ក៏ប៉ុន្តែក្នុងករណីដែលមាន

ព្រឹត្តិការណ៍ ឬសកម្មភាពណាមួយធ្វើឱ្យបាត់បង់ជំនឿទៅលើកូនបំណុល នោះប្រយោជន៍នៃការកំណត់ពេលក៏នឹងត្រូវចាត់ទុកថាបាត់បង់ដែរ (មាត្រា ១៣៧) ។ ក្រមរដ្ឋប្បវេណីមានចែងកំណត់អំពីសកម្មភាពខ្លះ ដូចជាការប្រកាសធនក្ស័យរបស់កូនបំណុលជាដើម ប៉ុន្តែក្នុងករណីខ្លះគូភាគីក៏អាចដាក់បញ្ចូលទៅក្នុងកិច្ចសន្យានូវការព្រមព្រៀងគ្នាជាមុនដែរ អំពីករណីអ្វីខ្លះដែលកូនបំណុលនឹងត្រូវបាត់បង់ប្រយោជន៍នៃការកំណត់ពេល (ហៅថា លក្ខន្តិកៈស្តីពីការបាត់បង់ប្រយោជន៍នៃការកំណត់ពេល) ។

# ៧. អាជ្ញាយុកាល

## ៧.១. អាជ្ញាយុកាលនៃការរំលត់ និងអាជ្ញាយុកាលនៃលទ្ធកម្ម

បន្ទាប់តទៅនេះ យើងនឹងអធិប្បាយអំពីអាជ្ញាយុកាលម្តង ។ យើងប្រហែលជាធ្លាប់ដឹងលីខ្លះហើយអំពីអាជ្ញាយុកាលក្នុងច្បាប់ព្រហ្មទ័ណ្ឌ តាមរយៈរឿងល្ខោនដែលមានបញ្ចាំងក្នុងទូរទស្សន៍ជាដើម ។ រីឯក្នុងក្រមរដ្ឋប្បវេណីក៏មានអាជ្ញាយុកាលដែរ ទាក់ទងទៅនឹងសិទ្ធិលើបំណុលនិងសិទ្ធិប្រត្យក្ស ហើយដែលមានចែងនៅក្នុងគន្ថីស្តីពីបទបញ្ញតិទូទៅ ។ អាជ្ញាយុកាលចែកចេញជាពីរបែបគឺ អាជ្ញាយុកាលនៃការរំលត់ និង អាជ្ញាយុកាលនៃលទ្ធកម្ម ។ អាជ្ញាយុកាលនៃការរំលត់ប្រហែលជាមានអត្ថន័យស្រួលយល់ជាង ។ ឧទាហរណ៍ដូចជា មាត្រា ១៦៧ នៃក្រមរដ្ឋប្បវេណីបានចែងថា ចំពោះសិទ្ធិលើបំណុលធម្មតា (ដូចជាសិទ្ធិលើបំណុលមកពីការខ្ចីប្រាក់រវាងក្រុមមនុស្សទូទៅជាដើម) បើទុកចោលចំនួន ១០ ឆ្នាំ នឹងត្រូវផុតអាជ្ញាយុកាល ហើយពុំអាចទាមទារការសងបានឡើយ ។ ហើយចំពោះសិទ្ធិលើបំណុលពិសេសវិញ ច្បាប់ក៏បានចែងអំពីអាជ្ញាយុកាលនៃការរំលត់ដែលមានរយៈពេលខ្លីផងដែរ ដូចជាចំពោះសិទ្ធិទាមទារប្រាក់ថ្លៃពេទ្យព្យាបាលជំងឺគឺមាន ៣ ឆ្នាំ ហើយចំពោះប្រាក់កំរៃជួលមេធាវីគឺមានតែ ២ ឆ្នាំជាដើម (មាត្រា ១៧០ និងមាត្រា ១៧២) ។

ផ្ទុយទៅវិញដែលហៅថា អាជ្ញាយុកាលនៃលទ្ធកម្ម គឺថាបើប្រើប្រាស់វត្ថុរបស់អ្នកដទៃដោយគិតថាជាវត្ថុរបស់ខ្លួនរាប់ឆ្នាំជារហូតរៀងមកនោះ វត្ថុនោះនឹងទៅជារបស់ខ្លួនតែម្តង ពោលគឺកម្មសិទ្ធិករដើមនៃវត្ថុនោះមិនអាចទាមទារការសងវិញបានឡើយ ។ មាត្រា ១៦២ នៃក្រម

រដ្ឋប្បវេណីបានចែងថា ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ បើកាន់កាប់វត្ថុអ្នកដទៃដោយសន្តិវិធីនិងជាសាធារណៈ (មានន័យថាគ្មានកើតរឿងរ៉ាវ ហើយនរណាក៏ដឹងលឺដែរ) ប្រកបដោយឆន្ទៈថាជារបស់ខ្លួន និងបានកាន់កាប់ ពោលគឺដាក់នៅក្រោមការគ្រប់គ្រងរបស់ខ្លួន ហើយប្រើប្រាស់ជាប់ជារហូតចំនួន ២០ ឆ្នាំហើយនោះ នឹងទទួលបាននូវកម្មសិទ្ធិ ។ បន្ថែមលើនេះនៅក្នុងករណីអចលនវត្ថុ បើការចាប់ផ្តើមកាន់កាប់មុនដំបូងនោះធ្វើឡើង ដោយសុចរិតព្រមទាំងគ្មានកំហុស (ដែលថាដោយសុចរិតនេះ ដូចដែលបានអធិប្បាយរួចមកហើយ គឺមិនមែនដោយចិត្តល្អនោះទេ តែនៅក្នុងន័យថាមិនដឹងរឿងហេតុសោះឡើយ សូមអានពាក្យគន្លឹះ សុចរិត និងទុច្ចរិត) ហើយនៅពេលកាន់កាប់ជាដំបូងនោះមិនបានដឹងថា ខ្លួនពុំមែនជាម្ចាស់ពិតប្រាកដនៃអចលនទ្រព្យនោះសោះឡើយ រួចហើយចំពោះការមិនបានដឹងជាមុននេះទៀតសោត ក៏មិនមែនមកពីកំហុសរបស់ខ្លួនដែរ ពោលគឺនៅក្នុងស្ថានភាពមួយដែលមិនមានវិធីអ្វីដើម្បីបានដឹងអំពីការពិតនោះទេ ។ បើយ៉ាងដូច្នេះមែន បន្ទាប់ពីរយៈពេល ១០ ឆ្នាំទៅ គេអាចនឹងធ្វើលទ្ធកម្មដោយអាជ្ញាយុកាលបាន (មាត្រាដដែល កថាខ័ណ្ឌទី ២) ។

ត្រង់នេះ ចូរប្រយ័ត្នឱ្យច្បាស់ថា ចំពោះកម្មសិទ្ធិគឺមិនមានការផុតអាជ្ញាយុកាលនៃការរំលត់នោះទេ (ប្រភេទសិទ្ធិប្រត្យ័ក្សផ្សេងទៀតត្រូវផុតអាជ្ញាយុកាលនៃការរំលត់រយៈពេល ២០ ឆ្នាំ) ។ ហេតុដូច្នេះ ឧបមាថា ទោះបីជាឈ្មោះ A បានទុកចោលដីធ្លីរបស់ខ្លួនរាប់សិបឆ្នាំក៏ដោយ កម្មសិទ្ធិរបស់ឈ្មោះ A លើដីនោះមិនរលត់ដោយឯកឯងឡើយ ។ ទោះបីជាស្លាប់ទៅដោយទុកដីនោះទំនេរគ្មានធ្វើអ្វីក៏ដោយ ដីនោះនឹងត្រូវស្នងដោយសហព័ទ្ធឬកូនរបស់ជននោះប្រសិនបើមាន ។ ក៏ប៉ុន្តែ ប្រសិនបើឈ្មោះ B ចូលទៅរស់នៅលើដីរបស់ឈ្មោះ A ហើយគ្មានការតវ៉ាពីឈ្មោះ A មិនតែប៉ុណ្ណោះឈ្មោះ B បានដើរតួដូចជាកម្មសិទ្ធិកររស់ជាង ២០ ឆ្នាំទៀតផង នោះឈ្មោះ B នឹងទទួលបានដីនោះដោយអាជ្ញាយុកាល ។ ដូចនេះ ជាលទ្ធផលឈ្មោះ A មិនអាចប្រាប់ឱ្យឈ្មោះ B សងដីខ្លួនមកវិញបានឡើយ ហើយឥទ្ធិពលនេះនឹងជះត្រឡប់ទៅឈ្មោះ A ធ្វើឱ្យបាត់បង់កម្មសិទ្ធិតែម្តង ។

## ៧.២. ការគណនាអំឡុងពេលអាជ្ញាយុកាល

លើកលែងតែករណីមួយភាគចេញ ជាទូទៅ ការគណនាអំឡុងពេលធ្វើឡើងទៅតាមបទបញ្ញត្តិចែងនៅក្នុងគន្ថីទី ១ ជំពូកទី ៥ នៃក្រមរដ្ឋប្បវេណី (មាត្រា ១៣៨ ។ ករណីមួយភាគដែលត្រូវលើកលែងនោះ គឺករណីដែលកំណត់ដោយច្បាប់ដទៃផ្សេងទៀត ករណីដែលសំរេចដោយបញ្ជារបស់តុលាការ ករណីដែលបានកំណត់ទុកជាមុនដោយភាគីពាក់ព័ន្ធក្នុងសកម្មភាពគតិយុត្តរួមមានកិច្ចសន្យាជាដើម) ។

ជាគោលការណ៍ វិធីគណនាអំឡុងពេលធ្វើដូចតទៅ: ឧទាហរណ៍ដូចជាថា នៅល្ងាចថ្ងៃនេះបានឱ្យ "ខ្ចីប្រាក់ចំនួន ១ ខែ" ក្នុងករណីនេះ គេត្រូវគណនាដោយរាប់ចាប់ពីថ្ងៃស្អែកទៅ ពោលគឺផាត់ចោលចំនួនម៉ោងសេសសល់ទាំងប៉ុន្មាននៅក្នុងថ្ងៃនេះចេញ (មាត្រា ១៤០) ។ ការគិតបែបនេះ គេហៅថា "គោលការណ៍មិនគណនាបញ្ចូលថ្ងៃដំបូង" ។ ក៏ប៉ុន្តែ ត្រូវលើកលែងចេញចំពោះករណីដូចជាថា "ចំនួន ៣ ថ្ងៃចាប់ពីថ្ងៃទីបីខែក្រោយទៅ"ជាដើម ករណីបែបនេះគេត្រូវគិតបញ្ចូលទាំងថ្ងៃទី៣ ដែលជាថ្ងៃដំបូងផង ពោលគឺត្រូវរាប់ចាប់ពីថ្ងៃទី ៣ ដល់ថ្ងៃទី ៥ (មាត្រា ១៤០ បដិញ្ញត្តិ) ។

រួចហើយក្នុងករណីគណនាអំឡុងពេលគិតជាសប្តាហ៍ ជាខែ ឬជាឆ្នាំ គេត្រូវគោរពទៅតាមប្រក្រតិទិន (ដោយមិនគិតថាចំនួនថ្ងៃមានការប្រែប្រួលទៅតាមខែឡើយ) (មាត្រា ១៤៣ កថាខ័ណ្ឌទី១) ។ ប្រសិនបើការគណនានោះមិនចាប់រាប់ពីថ្ងៃដំបូងនៃសប្តាហ៍ ខែ ឬឆ្នាំទេ គឺអំឡុងពេលនោះត្រូវចប់ពេញលេញនៅក្នុងសប្តាហ៍ ខែ ឬឆ្នាំចុងក្រោយ នាមួយថ្ងៃមុនថ្ងៃចាប់ផ្តើមការគណនា ។ (មាត្រាដដែល កថាខ័ណ្ឌទី ២) ។

ពាក្យពេចន៍រៀបរាប់ទាំងនេះហាក់បីដូចជាធ្វើឱ្យពិបាកយល់ណាស់ ក៏ប៉ុន្តែជាការងាយស្រួលសោះ។ ឧទាហរណ៍ថា ប្រាក់ខ្ចីធម្មតាដែលត្រូវសងនៅថ្ងៃទី ៣១ ខែមិនាឆ្នាំ ១៩៩០ បើចេះតែទុករហូត មិនបានសងអ្វីទេដោយគ្មានការទារពីអ្នកឱ្យខ្ចីផងនោះ អាជ្ញាយុកាល ១០ ឆ្នាំត្រូវរាប់ចាប់ពីថ្ងៃបន្ទាប់ ពោលគឺចាប់ពីថ្ងៃទី ១ ខែមេសា ដែលជាថ្ងៃចាប់ផ្តើមគណនា រហូតទល់ថ្ងៃមុនថ្ងៃទី ១ ខែមេសានៃ ១០ ឆ្នាំក្រោយ មានន័យថាអាជ្ញាយុកាលនេះត្រូវចប់ជាស្ថាពរនៅថ្ងៃទី ៣១ ខែមិនាឆ្នាំ ២០០០ ។

## ៧.៣. ការផ្អាក និងការបង្អង់អាជ្ញាយុកាល

អាជ្ញាយុកាល គឺជា មធ្យោបាយកំណត់ការផ្តល់សិទ្ធិ ឬការរំលត់សិទ្ធិ ឈរលើមូលដ្ឋានគោរពស្ថានភាពជានិរន្តន៍នៃហេតុការណ៍ណាមួយ ។ ដូច្នេះ នៅក្នុងករណីដែលមានការអះអាងអំពីសិទ្ធិពីសំណាក់អ្នកមានសិទ្ធិពិតប្រាកដ ទាមទារឱ្យសងឬទាមទារឱ្យរឹបអូស ឬក្នុងករណីអ្នកដែលពុំមែនជាជនមានសិទ្ធិប៉ុន្តែហៀបនឹងបានធ្វើលទ្ធកម្មដោយអាជ្ញាយុកាល ឬកូនបំណុលដែលមិនបានសងបំណុល បានទទួលស្គាល់នូវសិទ្ធិរបស់អ្នកមានសិទ្ធិពិតប្រាកដនោះ អាជ្ញាយុកាលនឹងត្រូវផ្អាក ព្រោះថាគេលែងត្រូវការវាយតម្លៃទៅលើស្ថានភាពជានិរន្តន៍នៃហេតុការណ៍នោះទៀតហើយ (មាត្រា ១៤៧) ។

ចូរកត់ចំណាំថា បើត្រូវផ្អាកអាជ្ញាយុកាលហើយ ទ្រនិចនៃការគណនាអាជ្ញាយុកាលនឹងវិលមកលេខសូន្យវិញ ហើយនៅពេលនោះ បើពុំមានការប្រើសិទ្ធិណាមួយទេ ការគណនាអាជ្ញាយុកាលនឹងត្រូវចាប់ដើរពីលេខសូន្យម្តងទៀត ។ មានន័យថា បើអាជ្ញាយុកាលនៃការរំលត់ ដែលមានរយៈពេល ១០ ឆ្នាំ ត្រូវផ្អាកបន្ទាប់ពីចាប់ផ្តើមបាន ៤ ឆ្នាំមក ។ ទោះបីជាក្រោយមកបានបន្តថែម ៦ ឆ្នាំទៀតក៏ដោយ អាជ្ញាយុកាលអាចនឹងចប់ជាស្ថាពរបាន លុះត្រាតែបន្ថែម ៤ ឆ្នាំបន្តពីនោះទៀត ។ មួយវិញទៀត ដែលហៅថាការទាមទារនៅទីនេះ គឺចង្អុលលើការទាមទារតាមផ្លូវតុលាការ ពោលគឺនៅក្នុងករណីបើគ្រាន់តែផ្ញើរលិខិតទាមទារ ដោយតឿនបង្ខំតែប៉ុណ្ណោះ (ពាក្យច្បាប់ហៅថា "ការជូនដំណឹង") ហើយបើគ្មានការទាមទារតាមផ្លូវតុលាការជាដើមនៅក្នុងរយៈពេល ៦ ខែទេនោះនឹងពុំមានអនុភាពផ្អាកអាជ្ញាយុកាលឡើយ (មាត្រា ១៥៣) ។ ចំណុចនេះក៏ត្រូវចំណាំទុកផងដែរ ។

រួចហើយក៏មានរបបមួយទៀតស្រដៀងនឹងការផ្អាកអាជ្ញាយុកាលនេះដែរ គឺការបង្អង់អាជ្ញាយុកាល (ចាប់ពីមាត្រា ១៥៨ ទៅ) ។ នេះគឺជារបបព្យួរមិនឱ្យអាជ្ញាយុកាលចប់ជាស្ថាពរកើតនៅក្នុងករណីដែលកម្មសិទ្ធិករត្រូវស្ថិតក្នុងស្ថានភាពមួយ មិនអាចធ្វើឱ្យផ្អាកអាជ្ញាយុកាលបាននាពេលដែលអាជ្ញាយុកាលហៀបនឹងចប់ពេញលេញទៅហើយនោះ ។ នៅពេលនេះ ទ្រនិចនាឡិកាគ្រាន់តែឈប់ស្ងៀមមួយរយៈប៉ុណ្ណោះ មិនវិលមកលេខសូន្យទេ។

**ការផ្អាក**

គេច្រើនតែងាយស្រួលនឹងយល់ច្រឡំណាស់ចំពោះពាក្យថា "ផ្អាក" ។ ការផ្អាកអាជ្ញាយុកាលមិនមែនជាការបង្អង់មួយរយៈពេលនោះទេ ។ ព្រោះតែម្ចាស់សិទ្ធិបានចាត់សកម្មភាព សមនឹងឋានៈខ្លួនជាម្ចាស់សិទ្ធិនោះ ដំណើរការនៃអាជ្ញាយុកាលត្រូវវិលមកភាពដើមម្តងសិន ។ ប្រសិនបើការអនុវត្តសិទ្ធិនេះមិនបានឈានដល់ទីបញ្ចប់ទេ ការគណនីត្រូវចាប់រាប់ពីកន្លែងសូន្យឡើងវិញជាថ្មីទៀត ។

## ៧.៤. ការលើកឡើង និងការបោះបង់ចោលនូវអាជ្ញាយុកាល

ចំនុចមួយទៀតដែលត្រូវចងចាំ គឺថាអាជ្ញាយុកាលក្នុងក្រមរដ្ឋប្បវេណីនឹងត្រូវចប់ជាស្ថាពរក្រោយការកន្លងផុតនៃអំឡុងពេលដែលបានកំណត់ក៏ពិតមែនហើយ ក៏ប៉ុន្តែលក្ខខណ្ឌត្រឹមប៉ុណ្ណេះមិនអាចធ្វើឱ្យរំលត់សិទ្ធិ ឬទទួលបានសិទ្ធិដោយស្វ័យប្រវត្តិនោះទេ ។ ជាដាច់ខាត អ្នកដែលទទួលផលប្រយោជន៍ពីអាជ្ញាយុកាលនោះ ចាំបាច់ត្រូវអះអាងអំពីអាជ្ញាយុកាលដើម្បីជាប្រយោជន៍ដល់ខ្លួនឯងដោយនិយាយថាខ្លួននឹងមិនសងទេ ពីព្រោះសិទ្ធិទាមទារត្រូវបានរំលត់ដោយអាជ្ញាយុកាលហើយ ឬក៏ថាវត្ថុនោះបានក្លាយទៅជារបស់ផងខ្លួន ពីព្រោះអាជ្ញាយុកាលនៃលទ្ធកម្មបានចប់ពេញលេញរួចហើយជាដើម ។ នេះគេហៅថាការលើកឡើងនូវអាជ្ញាយុកាល ។ ចៅក្រមមិនអាចកាត់ថាមានអនុភាពអាជ្ញាយុកាលបានឡើយ ប្រសិនបើសាមីខ្លួនមិនបានលើកឡើងទេនោះ (មាត្រា ១៤៥) ។ លើសពីនេះទៅទៀត នៅក្រោយពេលអាជ្ញាយុកាលបានចប់ជាស្ថាពរហើយក្តី គេក៏អាចបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាលបានដែរ (មាត្រា ១៤៦) ។ ឧទាហរណ៍ដូចជាថាបានខ្ចីប្រាក់ជាង ១០ ឆ្នាំមកហើយ ក៏ប៉ុន្តែខ្លួនចង់សងវិញពីព្រោះម្ចាស់បំណុលជាអ្នកមានគុណលើរូបខ្លួនជាដើមនោះ ចំពោះករណីនេះគេអាចសងប្រាក់ទាំងនោះដោយបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលបានតាមចិត្ត ។

## ៧.៥. អត្ថន័យសំរាប់វត្តមាននៃរបបអាជ្ញាយុកាល

មូលដ្ឋាននៃការរៀបចំឱ្យមានរបបអាជ្ញាយុកាលនេះមានជាអាទិ៍ គោលបំណងចង់ធ្វើឱ្យមានលំនឹងនៃទំនាក់ទំនងផ្លូវច្បាប់នៅក្នុងសង្គមដោយទទួលស្គាល់និរន្តរភាពនៃព្រឹត្តិការណ៍ ឬការមិនផ្តល់កិច្ចគាំពារចំពោះជនណាដែលដេកស្ងៀមនៅលើសិទ្ធិ ។ ល ។ ហើយក៏មានមូលហេតុថាទោះជាយ៉ាងណាក៏ដោយ ទន្ទឹមនឹងពេលវេលាកន្លងផុតទៅ ការបញ្ជាក់អំពីសិទ្ធិនឹងជួបការលំបាកជាពុំខាន ។ ចំពោះការដែលថាតើក្នុងចំណោមយោបល់ទាំងនេះ ត្រូវលើកយកយោបល់មួយណាមកអះអាងនោះ វាអាស្រ័យទៅនឹងទស្សនៈអំពីអាជ្ញាយុកាលរបស់អ្នកសិក្សាម្នាក់ៗ ។ ពាក់ព័ន្ធនឹងអត្ថន័យនិងលក្ខណៈផ្លូវច្បាប់នៃអាជ្ញាយុកាលនេះ យើងសង្កេតឃើញមានទ្រឹស្តីជាច្រើន ។

## ៧.៦. រយៈពេលកំណត់ទុកជាមុន

ជាបញ្ចប់ យើងនឹងនិយាយអំពី រយៈពេលកំណត់ទុកជាមុន ម្តងដែលពុំមានឃើញនៅក្នុងក្រមរដ្ឋប្បវេណី ។ នេះមានន័យស្រដៀងនឹងអាជ្ញាយុកាលដែរ ។ ប៉ុន្តែរយៈពេលកំណត់ទុកជាមុនត្រូវបានប្រើសំរាប់ដោះស្រាយវិវាទឱ្យបានឆាប់រហ័ស តួយ៉ាងដូចជាការទាមទារសំណងខូចខាតនៅក្នុងករណីបានទិញវត្ថុមានស្នាមឆ្កូតជាដើម ឧទាហរណ៍ដូចជាក្នុងករណីថា "ការទាមទារសំណងត្រូវធ្វើឡើងនៅក្នុងរយៈពេល ១ ឆ្នាំ"យ៉ាងដូច្នេះ ដែលជារយៈពេលបានកំណត់ទុកជាមុន (មាត្រា ៤៦៦ កថាខ័ណ្ឌទី ៣ ។ ល ។) ។ ការកំណតរយៈពេលនេះ ខុសគ្នានឹងអាជ្ញាយុកាលត្រង់ថារយៈពេលដែលបានកំណត់ទុកជាមុននេះ ពុំអាចអូសបន្លាយឱ្យបានយូថែមទៀតតាមវិធីផ្អាកបានឡើយ ។ ហើយក្នុងការសំរេចរបស់តុលាការ ក៏ពុំចាំបាច់ត្រូវការឱ្យមានការលើកឡើងពីសាមីខ្លួននោះទេ ។

# ៨. នីតិបុគ្គល

## ៨.១. សេចក្តីផ្តើម

ក្រមរដ្ឋប្បវេណីបានប្រដូចសហគ្រាស ។ ល ។ ទៅនឹងបុគ្គល ដោយឱ្យឋានៈជា "នីតិបុគ្គល" និងទទួលស្គាល់ថាជា ប្រធាននៃសកម្មភាពតាមផ្លូវច្បាប់ (មួយវិញទៀត ក្នុងការប្រៀបធៀបទៅនឹងនីតិបុគ្គល ច្បាប់ហៅបុគ្គលយើងម្នាក់ៗថាជា "រូបវន្តបុគ្គល") ។ ការទទួលស្គាល់ថាជានីតិបុគ្គលនេះ គឺជាការប្រគល់បុគ្គលភាពដល់នីតិបុគ្គល ប៉ុន្តែការទទួលស្គាល់អំពីលក្ខណៈជានីតិបុគ្គលនេះ គឺបានសេចក្តីថា នីតិបុគ្គលអាចនឹងក្លាយទៅជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចដោយឯករាជ ដូចរូបវន្តបុគ្គលដែរ ។ ទាក់ទងនឹងនីតិបុគ្គលនេះ ក្រមរដ្ឋប្បវេណីកន្លងមកបានកំណត់នូវមាត្រាជាច្រើននៅក្នុងគន្លឹស្តីពីបទបញ្ញត្តិទូទៅ ។ ក៏ប៉ុន្តែ តាមរយៈនៃច្បាប់ចំនួនបី ដែលបានប្រកាសឱ្យប្រើនាខែមិថុនាឆ្នាំ ២០០៦ ដើម្បីកែទម្រង់ប្រព័ន្ធនៃនីតិបុគ្គលបម្រើប្រយោជន៍សាធារណៈដែលនឹងមានរៀបរាប់នៅខាងក្រោមនោះ បញ្ញត្តិស្តីពីនីតិបុគ្គលក្នុងក្រមរដ្ឋប្បវេណីត្រូវបានកែប្រែមួយកំរិតធំ ។ គឺគេបន្សល់ទុកត្រឹម ៥ មាត្រាតែប៉ុណ្ណោះ ដោយប្រគល់បញ្ញត្តិដទៃទៀតទៅឱ្យច្បាប់ស្តីពីនីតិបុគ្គលមូលនីធិនិងនីតិបុគ្គលសាជីវកម្មទូទៅ ដែលជាច្បាប់មួយក្នុងចំណោមច្បាប់ទាំង ៣ នោះ (ច្បាប់ទាំង ៣ នេះ នឹងចូលជាធរមាននៅដំណាច់ឆ្នាំ ២០០៨) ។

## ៨.២. នីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិ

នីតិបុគ្គលនៅក្នុងវិស័យច្បាប់ឯកជនចែកចេញជា នីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិ ។ បើនិយាយក្នុងន័យទូលាយ សាជីវកម្មគឺជាការប្រមូលផ្តុំនៃមនុស្ស ហើយមូលនិធិគឺជាការប្រមូលផ្តុំនៃទ្រព្យធន (ជាធម្មតាទេដែលថា មូលនិធិក៏ត្រូវការមានមនុស្សរៀបចំឡើងជាអង្គការដើម្បីគ្រប់គ្រងប្រើប្រាស់ទ្រព្យធននោះដែរ) ។ ចំពោះសាជីវកម្ម បើលើកយកឧទាហរណ៍ក្រុមហ៊ុនមកពិចារណា យើងនឹងឃើញថា សាជីវកម្មជាក្រុមនៃមនុស្សដែលចាំបាច់ត្រូវចាត់ទុកថាជាប្រធាននៃច្បាប់ មានលក្ខណៈដោយឡែកពីបុគ្គលដែលជាអ្នកតំណាងនៃក្រុមនោះ (លើកយកកិច្ចសន្យាលក់តែមួយមុខមកនិយាយ ក៏យើងឃើញថា មិនមែនអ្នកតំណាងជាបុគ្គលទេដែលទិញវត្ថុនោះ ពោលគឺគេត្រូវទទួលស្គាល់ថាមានករណីក្រុមហ៊ុនបានក្លាយជាអ្នកទិញតែម្តង) ។ ក៏ប៉ុន្តែ

ក្រុមនៃមនុស្សនេះមិនមែនសុទ្ធតែទៅជាសាជីវកម្មទាំងអស់ទេ (មានការប្រមូលផ្តុំមនុស្សតាមរបៀបផ្សេងទៀតដូចជាក្រុមហ៊ុនជាដើម ដែលមានការបង្ហាញអំពីបុគ្គលិកលក្ខណៈរបស់បុគ្គលជាអ្នកចូលរួមខ្លាំងជាងក្នុងសាជីវកម្ម ។ សូមអានជំពូកទី ៤) ។ ចុះហេតុអ្វីបានជាគេចាំបាច់ត្រូវផ្តល់លក្ខណៈជានីតិបុគ្គលទៅឱ្យអង្គការប្រមូលផ្តុំទ្រព្យធន? នេះមិនមែនដោយគិតអំពីករណីប្រមូលប្រាក់ឱ្យប្រកបមុខរបរដើម្បីរកចំណេញនោះទេ គឺគិតអំពីករណីប្រើប្រាស់ទ្រព្យធនមួយចំនួនសំរាប់កិច្ចការសប្បុរសធម៌ដើម្បីផលប្រយោជន៍សាធារណៈ (ដើម្បីផលប្រយោជន៍មនុស្សច្រើនគ្នាដោយមិនរើសមុខ) មានដូចជាសាលារៀន ឬមន្ទីរពេទ្យជាដើម ។ ពោលគឺផ្តល់នូវលក្ខណៈជាប្រធាននៃច្បាប់ដែលឯករាជ ឱ្យទៅអង្គការនិងមូលនិធិទាំងឡាយណាដែលបំរើដល់គោលបំណងកំណត់ខាងលើ ដើម្បីសំរួលដល់ការបំពេញសកម្មភាពរបស់គេ ។

ជាងនេះទៅទៀត នីតិបុគ្គលសាជីវកម្មចែកចេញជា នីតិបុគ្គលសាជីវកម្មរកកំរៃ និងនីតិបុគ្គលសាជីវកម្មបំរើកិច្ចការសាធារណៈ ។ ករណីទីមួយ គឺសំដៅលើនីតិបុគ្គលសាជីវកម្មដែលមានគោលបំណងរកចំណេញ តួយ៉ាងដូចជាក្រុមហ៊ុនជាដើម ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីធ្លាប់បានអនុវត្តចំពោះនីតិបុគ្គលសាជីវកម្មដែលមានគោលបំណងបម្រើផលប្រយោជន៍សាធារណៈ និងនីតិបុគ្គលមូលនិធិ ។ បន្ថែមលើនេះនៅមាននីតិបុគ្គលជាច្រើនលើសលប់ ដែលទទួលស្គាល់ដោយច្បាប់ពិសេសផ្សេងៗ ក្រៅពីក្រមរដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្មផងដែរ ។ ហើយនីតិបុគ្គលបម្រើប្រយោជន៍ សាធារណៈបានត្រូវឱ្យនិយមន័យថាជានីតិបុគ្គលមានគោលបំណងបំរើផលប្រយោជន៍ជនភាគច្រើន ដោយមិនរើសមុខ អនុវត្តកិច្ចការទាំងឡាយពាក់ព័ន្ធនឹងបុណ្យទាន សាសនា សប្បុរសធម៌ វិជ្ជាសិក្សាស្រាវជ្រាវ និងបច្ចេកវិជ្ជាជាដើម ។

វិធានជាមូលដ្ឋានសំរាប់ដឹកនាំនីតិបុគ្គលសាជីវកម្មហៅថា លក្ខន្តិកៈ ។ ក្នុងលក្ខន្តិកៈនេះយ៉ាងហោចណាស់ ក៏ត្រូវមានចែងនូវគោលបំណង នាមករណ៍ ទីស្នាក់ការ បញ្ញត្តិស្តីពីទ្រព្យធន បញ្ញត្តិស្តីពីការតែងតាំងនិងផ្លាស់ប្តូរអភិបាល បញ្ញត្តិស្តីពីការទទួលបាននិងបាត់បង់លក្ខណៈសម្បត្តិជាសមាជិក (មាត្រា ៣៧ ក្នុងបញ្ញត្តិចាស់នៃក្រមរដ្ឋប្បវេណី) ។ ចំពោះនីតិបុគ្គលមូលនិធិវិញ លិខិតកំណត់នូវវិធានជាមូលដ្ឋាន ក៏ត្រូវបានចែងក្នុងបទបញ្ញត្តិចាស់ថាជា "សកម្មភាពបរិច្ចាគ" ដែរ

ប៉ុន្តែច្បាប់ថ្មីហៅលិខិតនេះថាជា លក្ខន្តិកៈ ដែលត្រូវកំណត់អំពីគោលបំណង នាមករណ៍ ទីស្នាក់ការ បញ្ញត្តិស្តីពីទ្រព្យធន បញ្ញត្តិស្តីពីការតែងតាំងនិងផ្លាស់ប្តូរអភិបាល (មាត្រា ៣៩) ។

## ៨.៣. នីតិបុគ្គលសាជីវកម្មទូទៅ និងនីតិបុគ្គលមូលនិធិទូទៅ

នីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈ ដែលស្ថិតនៅក្រោមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវទទួលបាននូវរបបអនុគ្រោះខាងពន្ធ ។ ល ។ ដោយសារហេតុនេះ សភាពការណ៍នៃការអនុវត្ត ដោយបំពានលើនីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី បាន កើតមានឡើងដោយសារភាពស្លៀវក្លានៃសកម្មភាពសេដ្ឋកិច្ច បណ្តាលឱ្យមានបញ្ហាសង្គម ។ ដូច្នេះ គេបានធ្វើឱ្យមានការកែប្រែនូវទស្សនៈជាមូលដ្ឋានស្តីពីនីតិបុគ្គលក្នុងក្រមរដ្ឋប្បវេណី ហើយថែមទាំង ធ្វើនីតិកម្មបង្កើតនូវអ្វីដែលហៅថា ច្បាប់ទាំងបីសំរាប់កំណែទម្រង់របបនីតិបុគ្គលបម្រើប្រយោជន៍ សាធារណៈ (ប្រកាសឱ្យប្រើនៅឆ្នាំ ២០០៦) ក្នុងរូបភាពជាច្បាប់ស្តីពីការរៀបចំសហគមន៍ ដែលមានកំណត់បទបញ្ញត្តិឱ្យបានលំអិតជាងមុន ។ បទបញ្ញត្តិភាគច្រើនលើសលប់ ត្រូវបានផ្ទេរ ចេញពីក្រមរដ្ឋប្បវេណី ។ ច្បាប់ទីមួយ គឺជា "ច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្មទូទៅ និងនីតិបុគ្គល មូលនិធិទូទៅ" ។ ច្បាប់ទីពីរ គឺជា "ច្បាប់ស្តីពីការទទួលស្គាល់នីតិបុគ្គលសាជីវកម្មបម្រើប្រយោជន៍ សាធារណៈ និងនីតិបុគ្គលមូលនិធិបម្រើប្រយោជន៍សាធារណៈ" (ហៅកាត់ថា "ច្បាប់ស្តីពីការទទួល ស្គាល់នីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ") ។ ហើយច្បាប់ទីបី គឺជាច្បាប់ស្តីពីការរៀបចំច្បាប់ ទាំងឡាយដែលពាក់ព័ន្ធ (ហៅកាត់ថា "ច្បាប់ស្តីពីការរៀបចំ") ។

តាមរយៈនេះ គេបានធ្វើការកែប្រែលើប្រព័ន្ធអនុញ្ញាតការបង្កើតនីតិបុគ្គលបម្រើប្រយោជន៍ សាធារណៈ ដែលកន្លងមកត្រូវអាស្រ័យលើឆន្ទានុសិទ្ធិរបស់ស្ថាប័នរដ្ឋដែលមានសមត្ថកិច្ច (មាត្រា ២៤ ចាស់នៃក្រមរដ្ឋប្បវេណី) ក្នុងគោលបំណងដើម្បីជំរុញឱ្យមានការអភិវឌ្ឍន៍យ៉ាងល្អប្រសើរ នូវសកម្មភាពមិនរកកំរៃដោយមជ្ឈដ្ឋានក្រៅរដ្ឋាភិបាល ។ ជាបឋម ការកែប្រែទីមួយ គឺការបង្កើង នូវប្រព័ន្ធមួយដែលសំរួលឱ្យនីតិបុគ្គល រួមមាននីតិបុគ្គលសាជីវកម្មទូទៅនិងនីតិបុគ្គលមូលនិធីទូទៅ អាចត្រូវបង្កើតឡើងបាន ដោយវិធីចុះបញ្ជីត្រឹមត្រូវតាមការបញ្ញាតតែប៉ុណ្ណោះ ។ បន្ទាប់មកទៀត គឺការរៀបចំបង្កើតនូវប្រព័ន្ធដោយឡែកមួយទៀត សំរាប់ធ្វើការទទួលស្គាល់នូវលក្ខណៈបម្រើ

ប្រយោជន៍សាធារណៈ ដែលចាំបាច់សំរាប់ប្រែក្លាយទៅជានីតិបុគ្គលបម្រើប្រយោជន៍សាធារណៈនោះ (ពោលគឺថា ការបង្កើតនីតិបុគ្គលអាចធ្វើទៅបានយ៉ាងងាយស្រួល ប៉ុន្តែដើម្បីឱ្យបានទទួលស្គាល់ថាជានីតិបុគ្គលបម្រើប្រយោជន៍សាធារណៈនោះ គេបានកំណត់ថា ចាំបាច់ត្រូវទទួលបាននូវការទទួលស្គាល់ដោយឡែកមួយទៀត ដែលមានលក្ខណៈតឹងរឹង) ។

## ៨.៤. អង្គភាពនៃនីតិបុគ្គល

ថ្វីត្បិតតែត្រូវបានប្រដូចថាជាបុគ្គលក៏ដោយ សាជីវកម្ម ឬមូលនិធិ ដែលជានីតិបុគ្គលនោះមិនអាចធ្វើសកម្មភាពដោយខ្លួនឯងផ្ទាល់កើតនោះទេ ពោលគឺត្រូវមានរចនាសម្ព័ន្ធប្រតិបត្តិមួយ ។ ស្ថាប័នដែលពាក់ព័ន្ធនឹងការងារនេះ ហៅថា អង្គភាពនៃនីតិបុគ្គល ។

(១) ចំពោះសាជីវកម្ម អង្គភាពធ្វើសេចក្តីសំរេច គឺជា"មហាសន្និបាតសមាជិក" បើកឡើងដោយ"សមាជិក"នៃសាជីវកម្ម ។ រីឯករណីនៃនីតិបុគ្គលមូលនិធិវិញ (ដោយហេតុថាជាការប្រមូលផ្តុំនៃទ្រព្យធននោះ) ដោយសារគ្មានគោលគំនិតស្តីពីសមាជិក ឬមហាសន្និបាតសមាជិកទេ សេចក្តីសំរេចនានាត្រូវយោលទៅតាមឆន្ទៈរបស់អ្នកបង្កើត ។ (២) អង្គភាពអនុវត្តការងារ ទាំងនៅក្នុងនីតិបុគ្គលសាជីវកម្មនិងនីតិបុគ្គលមូលនិធិ ត្រូវជាការងាររបស់អភិបាល ។ អង្គភាពនេះត្រូវតែរៀបចំឱ្យមានជាដាច់ខាត (មាត្រា ៥២ នៃបទបញ្ញត្តិចាស់) ។ (៣) អង្គភាពត្រួតពិនិត្យ គឺអ្នកត្រួតពិនិត្យ ។ អង្គភាពត្រួតពិនិត្យនេះ មិនមែនត្រូវតែចាត់តាំងដោយខានពុំបាននោះទេ (មាត្រា ៥៨ នៃបទបញ្ញត្តិចាស់) ។

### សមាជិក

នៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្ម ពាក្យថាសមាជិកមានន័យថា "អ្នកចូលរួមបង្កើតសាជីវកម្ម" ។ ពោលគឺពុំមែនសំដៅមកលើនិយោជិត ដែលជាអ្នកត្រូវក្រុមហ៊ុនជួលដោយចេញបៀវត្សអោយនោះទេ ។ ឧទាហរណ៍ដូចជា បើនិយាយអំពី "សមាជិក" នៃក្រុមហ៊ុនដែលជានីតិបុគ្គលរកកំរៃ នេះគឺសំដៅទៅលើ "ម្ចាស់ហ៊ុន" ។

## ៨.៥. របបស្ដីពីការបង្កើតនីតិបុគ្គល

ចំពោះការបង្កើតនីតិបុគ្គលទាំងប៉ុន្មានដូចដែលបានរៀបរាប់មកនេះ មានគោលការណ៍មួយចំនួនបែកចេញផ្សេងៗគ្នា យោលទៅតាមកំរិតដែលរដ្ឋធ្វើអន្តរាគមន៍ក្នុងកិច្ចការបង្កើតនេះ ។ បើយើងលើកយករបបង្កើតនីតិបុគ្គល ដោយរៀបទៅតាមលំដាប់តឹងរឹងនៃអន្តរាគមន៍ពីរដ្ឋនោះ យើងឃើញដូចតទៅ: (១) របបចេញអាជ្ញាប័ណ្ណពិសេស ដោយបង្កើតច្បាប់ពិសេសសំរាប់រាល់ការយល់ព្រមឱ្យបង្កើតនីតិបុគ្គលណាមួយ ។ មានករណីនៃធនាគារជប៉ុនជាដើម ដែលបានបង្កើតឡើងយោងតាមរបបនេះ ។ (២) របបផ្ដល់ការអនុញ្ញាត ដែលស្ថាប័នចំបងមានសមត្ថកិច្ចត្រួតពិនិត្យនឹងចេញការអនុញ្ញាតឱ្យបង្កើត ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។ នេះគឺជាជំហររបស់ក្រមរដ្ឋប្បវេណីកន្លងមក ទាក់ទងនឹងនីតិបុគ្គល (មាត្រា ៣៤ នៃបទបញ្ញត្តិចាស់) ។ (៣) របបទទួលស្គាល់ ដែលស្ថាប័នមានសមត្ថកិច្ច ត្រួតពិនិត្យចាំបាច់ត្រូវទទួលស្គាល់នូវការបង្កើត ប្រសិនបើគេបានបំពេញតាមគ្រប់ល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់ទុកជាមុនហើយ ។ ការបង្កើតសាលារៀនឯកជន គឺស្ថិតនៅក្នុងរបបនេះ (យោងតាមច្បាប់ស្ដីពីការបង្កើតសាលារៀនឯកជន) ។ (៤) របបអនុលោមតាមច្បាប់ ដែលតម្រូវឱ្យមានការទទួលស្គាល់ទាំងស្រុង ដោយមិនមានការពិនិត្យជាមុនពីសំណាក់ស្ថាប័នរដ្ឋឡើយ ប្រសិនបើបានរៀបចំរចនាសម្ព័ន្ធទាំងឡាយដែលបានកំណត់ដោយច្បាប់ ហើយបានចុះបញ្ជីរួច ។ ការបង្កើតក្រុមហ៊ុននៅក្នុងច្បាប់ពាណិជ្ជកម្ម និងការបង្កើតសហជីព ត្រូវស្ថិតនៅក្នុងរបបនេះ ។ នីតិបុគ្គលសាជីវកម្មទូទៅ និងនីតិបុគ្គលមូលនិធិទូទៅ ដែលកំណត់ក្នុងច្បាប់ថ្មីក៏អនុលោមតាមរបបនេះដែរ ។

## ៨.៦.អំពើអនីត្យានុកូលរបស់នីតិបុគ្គល

ដោយហេតុថា នីតិបុគ្គលបានត្រូវប្រដូចថាជាបុគ្គល ហើយត្រូវបានទទួលស្គាល់ថាមានសមត្ថភាពក្នុងការធ្វើសកម្មភាពដែរនោះ ជាធម្មតាទេគេត្រូវកំណត់បញ្ញត្តិអំពីសមត្ថភាពក្នុងការធ្វើអំពើអនីត្យានុកូល (អំពើខុសច្បាប់ដែលធ្វើឱ្យខូចខាតដល់អ្នកដទៃ ដោយចេតនាឬដោយកំហុស) របស់នីតិបុគ្គល (មាត្រា ៤៤ បទបញ្ញត្តិចាស់នៃក្រមរដ្ឋប្បវេណីបានចែងថា នៅពេលដែលអភិបាល

ឬអ្នកតំណាងដទៃទៀត (ស្ថាប័នតំណាង) នៃនីតិបុគ្គលបានប្រព្រឹត្តអំពើអនីត្យានុកូល នីតិបុគ្គលនោះត្រូវទទួលខុសត្រូវ ។ ប៉ុន្តែតាមរយៈនៃច្បាប់ថ្មីដែលបានលើកឡើងខាងលើ គេបានលុបបទបញ្ញត្តិនេះចេញពីក្រមរដ្ឋប្បវេណី ហើយដាក់បញ្ចូលបញ្ញត្តិដូចគ្នាទៅក្នុងច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិទូទៅវិញ) ។ ប៉ុន្តែត្រង់ ចំណុចនេះ បើពុំទាន់បានសិក្សាអំពីអំពើអនីត្យានុកូល (ចាប់ពីមាត្រា ៧០៩ តទៅ) នៃច្បាប់ស្តីពីកាតព្វកិច្ចនៅឡើយទេ គឺប្រាកដជានឹងមិនអាចយល់បានច្បាស់ទេ ។

## ៨.៧.ទ្រឹស្តីសិក្សាអំពីនីតិបុគ្គល

នៅក្នុងការសិក្សា មានទស្សនៈយល់ផ្សេងៗគ្នាជាច្រើនអំពីបញ្ហានីតិបុគ្គល ។ មានទស្សនៈពីរខ្វែងគ្នា ។ ទស្សនៈមួយយល់ថា អត្ថិភាពនៃនីតិបុគ្គលគឺគ្រាន់តែជាការប្រឌិតតាមផ្លូវគតិយុត្តយកតាមគំរូនៃរូបវន្តបុគ្គលតែប៉ុណ្ណោះ ។ នេះជាទ្រឹស្តីនីតិបុគ្គលប្រឌិត ។ ហើយនិងទស្សនៈមួយទៀតយល់ថា អត្ថិភាពនៃនីតិបុគ្គលមានពិតមែន ។ នេះជាទ្រឹស្តីនីតិបុគ្គលមានអត្ថិភាពពិត ។ ទស្សនៈខុសគ្នានេះជះឥទ្ធិពលខ្លះៗទៅលើការបកស្រាយ និងការធ្វើអត្ថាធិប្បាយ នូវបទបញ្ញត្តិទាំងឡាយទាក់ទងនឹងនីតិបុគ្គល ។ ក៏ប៉ុន្តែសិក្ខាកាមដែលទើបនឹងចាប់ផ្តើមថ្មី មិនត្រូវវីរវល់ជាមួយរឿងនេះខ្លាំងពេកទេ គួរតាំងចិត្តចាប់យកឱ្យបានជាមុនសិននូវអត្ថន័យទូទៅ (ការបង្កើត សមត្ថភាព អង្គការការរំលត់ ។ល ។) នៃបទបញ្ញត្តិស្តីពីនីតិបុគ្គលក្នុងក្រមរដ្ឋប្បវេណី ។

## ៨.៨.សាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិ និងនីតិបុគ្គលថ្នាក់កណ្តាល

នៅមានក្រុមមួយប្រភេទទៀតដែលមិនមានគោលបំណងរកកំរៃ ហើយក៏មិនមានបំណងបំរើកិច្ចការសាធារណៈដែរទេ គឺមានតែគិតគូរអំពីផលប្រយោជន៍របស់ក្រុមអ្នកដោយឡែកមួយក្រុមដែលជាសមាជិកចូលរួមក្នុងការបង្កើតក្រុម (មានដូចជាសមាគមស្វ័យភាពរបស់និស្សិត សមាគមនៃអតីតនិស្សិត និងសហគមន៍អ្នកជិតខាងក្នុងសង្កាត់តែមួយ ។ល ។) ។ កន្លងមកដោយហេតុថាមិនមានបញ្ញត្តិនៃច្បាប់ពិសេសអ្វីសំរាប់អនុវត្តនោះ ក្រុមទាំងអស់នេះមិនអាចក្លាយទៅជានីតិបុគ្គលបានទេ ដូច្នេះក្រុមនេះត្រូវ ដំណើរក្នុងឋានៈជា“សាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិ”

(ទោះជាក្នុងក្រមរដ្ឋប្បវេណី មិនមានបទបញ្ញត្តិចែងអំពីសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិក៏ដោយ ក៏ច្បាប់យុត្តិសាស្ត្រ និងទ្រឹស្តីសិក្សា ចាត់ទុកថាសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិ អាចទៅជាប្រធាននៃជំនួញឬការប្តឹងប្តល់បានដោយឯករាជ្យ ប៉ុន្តែត្រូវស្ថិតនៅក្នុងទំនាក់ទំនងពិសេស តួយ៉ាងដូចជាក្នុងករណីទិញអចលនទ្រព្យ គឺត្រូវចុះបញ្ជីដោយប្រើឈ្មោះអ្នកតំណាងជាដាច់ខាត ។ ហើយប្រសិនជាសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិនេះ ត្រូវជាប់ជំពាក់បំណុលដោយសារការធ្វើជំនួញ ក៏គេមិនអាចទាមទារដល់ទៅចែកទ្រព្យធនរបស់បុគ្គលដែលជាសមាជិកនោះដែរ ។ លើសពីនេះទៅទៀត ក្នុងករណីដែលសមាជិកលាលែងចេញពីសាជីវកម្ម សមាជិកនោះមិនអាចទាមទារឱ្យសងដើមទុនដែលខ្លួនគេបានវិនិយោគនោះឡើយ) ។ ច្បាប់ស្តីពីនីតិបុគ្គលថ្នាក់កណ្តាលដែលបានរៀបចំនៅឆ្នាំ ២០០១ គឺជាច្បាប់ដែលអនុញ្ញាតឱ្យក្រុមទាំងនេះទទួលបានលក្ខណៈសម្បត្តិជានីតិបុគ្គល ក្នុងឋានៈជា"នីតិបុគ្គលថ្នាក់កណ្តាល" សំរួលឱ្យក្រុមទាំងនេះអាចធ្វើការគ្រប់គ្រងលើទ្រព្យសម្បត្តិ របស់ខ្លួន ដូចជាអចលនទ្រព្យជាដើម ។ ក៏ប៉ុន្តែក្រុមទាំងនេះត្រូវបានលុបចោលដោយច្បាប់ថ្មីនាឆ្នាំ ២០០៦ ។ នីតិបុគ្គលថ្នាក់កណ្តាល ត្រូវក្លាយជានីតិបុគ្គលសាជីវកម្មទូទៅ ដើម្បីបន្តទៅថ្ងៃខាងមុខទៀត ។

## ៩. លំនៅឋាន និងការបាត់ខ្លួន

### ៩.១. លំនៅឋាន

បទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីក៏មានចែងអំពីលំនៅឋានដែរ ។ បានជាបទបញ្ញត្តិទូទៅចែងអំពីលំនៅឋាននេះ គឺព្រោះតែថាលំនៅឋានជាមូលដ្ឋានសំរាប់ធ្វើការសំរេចថា តើត្រូវអនុវត្តកាតព្វកិច្ចនៅទីណា? (មាត្រា ៤៨៤) តើសន្តតិកម្មត្រូវចាប់ផ្តើមនៅទីណា? (មាត្រា ៨៨៣) ជាដើម ។ បទបញ្ញត្តិនេះបានចែងថា កន្លែងដែលជាទីតាំងនៃជីវភាពរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន (មាត្រា ២២) ។ ក្នុងករណីដែលមិនអាចដឹងនូវលំនៅឋានបានទេនោះ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន (មាត្រា ២៣) (មានការពន្យល់ទៀតថា ដែលហៅថាទីសំណាក់គឺជាទីកន្លែងដែលបុគ្គលបានស្នាក់អាស្រ័យនៅជាប់រហូតមួយរយៈ ដោយគ្មានលក្ខណៈជាប់ស្អិតជាមួយទឹកដីនោះដូចក្នុងករណីនៃលំនៅឋាននោះទេ) ។ នៅមានការជជែកគ្នាទៀតថាតើ "កន្លែង

ដែលជាទីតាំងនៃជីវភាព"មានតែមួយ ឬក៏មានច្រើន? ត្រង់នេះ ទ្រឹស្តីកំណត់លំនៅឋានច្រើនកន្លែង ត្រូវបានទទួលស្គាល់ជាទូទៅ ។ ឧទាហរណ៍ដូចជាបុគ្គលម្នាក់រស់នៅជាមួយគ្រួសារនៅទីក្រុងតូក្យូ ហើយធ្វើការឱ្យក្រុមហ៊ុនមួយដែលមានការិយាល័យនៅ អូសាកា ជាដើម ។ ក្នុងករណីនេះ លំនៅឋានទាំងពីរត្រូវបានទទួលស្គាល់ អាស្រ័យទៅលើទំនាក់ទំនងគតិយុត្តនីមួយៗ ។ ដូចជានៅក្នុងទំនាក់ទំនងគតិយុត្តទាក់ទងនឹងការងារ គេចាត់ទុកអូសាកាថាជាលំនៅឋាន ។ លំនៅឋាននេះក៏ចោទឡើងជាបញ្ហាដែរក្នុងទំនាក់ទំនងជាមួយសិទ្ធិបោះឆ្នោត ។ ច្បាប់យុត្តិសាស្ត្ររបស់តុលាការកំពូល បានចាត់ទុកថា លំនៅឋាននៃនិស្សិតដែលជួលបន្ទប់នៅជាមួយម្ចាស់ផ្ទះ គឺទីកន្លែងធ្វើការសិក្សា (ដូច្នេះមិនបាច់ត្រឡប់ទៅស្រុកកំនើតនៅរាល់ពេលបោះឆ្នោតនោះទេ ។ ក៏ប៉ុន្តែជាធម្មតាទេ ដែលនិស្សិតត្រូវទៅចុះបញ្ជីប្តូរយកប័ណ្ណបញ្ជាក់ទីលំនៅថ្មីរបស់ខ្លួនជាចាំបាច់នោះ) ។

## ៩.២.ការបាត់ខ្លួន (ការគ្រប់គ្រងទ្រព្យធនរបស់បុគ្គលដែលអវត្តមាន)

បុគ្គលដែលបានចេញពីលំនៅឋាន ឬទីសំណាក់របស់ខ្លួន ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលទេនោះ ហៅថាជាបុគ្គលដែលអវត្តមាន ។ ចំពោះបុគ្គលដែលអវត្តមាន ប្រសិនបើទ្រព្យសម្បត្តិរបស់ខ្លួនត្រូវទុកចោលមិនមានការគ្រប់គ្រងទេ គឺមិនប្រពៃឡើយចំពោះសាមីខ្លួន ក៏ដូចជាចំពោះម្ចាស់បំណុល និងជនដែលត្រូវបានសន្មត់ថាជាសន្តតិជនដែរ ។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីបានចែងថា ក្នុងករណីដែលបុគ្គលអវត្តមានមិនបានចាត់តាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនទេនោះ តុលាការគ្រួសារអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬចាត់វិធានការចាំបាច់ផ្សេងៗបាន តាមការស្នើសុំពីជនដែលត្រូវបានសន្មត់ថាជាសន្តតិជន ឬពីបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ដូចជាម្ចាស់បំណុលជាដើម ឬពីតំណាងអយ្យការ (មាត្រា ២៥ កថាខ័ណ្ឌទី ១ ផ្នែកខាងដើម) ។

ប្រសិនបើមិនដឹងថា តើបុគ្គលអវត្តមាននោះនៅរស់ ឬទទួលមរណភាព ក្នុងអំឡុងពេល ៧ ឆ្នាំ តុលាការគ្រួសារអាចប្រកាសការបាត់ខ្លួនរបស់ជននោះបាន តាមការស្នើសុំពីបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ (មាត្រា ៣០ កថាខ័ណ្ឌទី ១) ។ ក្នុងករណីដែលបុគ្គលបានជួបប្រទះនឹងគ្រោះថ្នាក់ ដូចជាជិះនាវាដែលបានលិចជាដើម ហើយពុំមានដំណឹងច្បាស់

លាស់ថានៅរស់ ឬទទួលមរណភាពទេ ក្នុងអំឡុងពេល ១ ឆ្នាំក្រោយពីគ្រោះថ្នាក់បានកន្លងផុតទៅនោះ ក៏ត្រូវអនុវត្តដូចគ្នាដែរ (មាត្រា ៣០ កថាខ័ណ្ឌទី ២) ។ បើសិនជាមានការប្រកាសអំពីការបាត់ខ្លួនហើយ គេត្រូវចាត់ទុកថាបុគ្គលដែលអវត្តមាននោះបានទទួលមរណភាព ចាប់គិតពីពេលដែលមិនបានមានដំណឹងច្បាស់លាស់ថានៅរស់ ឬទទួលមរណភាព អស់អំឡុងពេល ៧ ឆ្នាំមកហើយនោះ ឬពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ (មាត្រា ៣១) ។

ពាក្យថា "ចាត់ទុក" នេះខុសពីពាក្យថា " សន្មត់" (សូមអានពាក្យគន្លឹះនៅ ៣. ៥). ខាងលើ) ។ ទោះបីជាសាមីខ្លួននៅរស់ក៏ដោយ បើគ្មានការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួនទេនោះ អនុភាពនៃការប្រកាសនេះនឹងមិនបាត់បង់ឡើយ ។ នៅក្នុងករណីនេះ ប្រសិនបើតុលាការគ្រួសារលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមការស្នើសុំរបស់សាមីខ្លួន ឬបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នោះ ការប្រកាសនឹងត្រូវសើរើត្រឡប់ថយក្រោយដោយចាត់ថាគ្មានតាំងពីដំបូងទីមក ។ ដូច្នេះ ជាគោលការណ៍ សកម្មភាពគតិយុត្តិដែលបានអនុវត្តដោយសន្និដ្ឋានលើការស្លាប់នេះនឹងទៅជាមោឃៈ ក៏ប៉ុន្តែដោយហេតុថា គេមិនត្រូវធ្វើឱ្យមានការខូចខាតដែលមិនអាចស្មានទុកជាមុនបាន ទៅដល់ជនដែលបានទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន ហើយបានរៀបអាពាហ៍ពិពាហ៍ ឬបានធ្វើកិច្ចសន្យាជាដើម ដូច្នេះមានការកំណត់ថា សកម្មភាពណាដែលបានធ្វើដោយសុចរិតនៅក្នុងអំឡុងពេលបន្ទាប់ពីមានការប្រកាសការបាត់ខ្លួន រហូតទល់ពេលមុនការលុបចោលវិញនោះ នឹងចាត់ទុកថាមានសុពលភាពដដែល (មាត្រា ៣២ កថាខ័ណ្ឌទី ១ បដិបញ្ញា) ។ បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយសារការប្រកាសអំពីការបាត់ខ្លួននេះ ត្រូវសងត្រឹមតែកំរិតនៃផលប្រយោជន៍ដែលខ្លួនកំពុងទទួលពិតប្រាកដតែប៉ុណ្ណោះ (មាត្រាដដែល កថាខ័ណ្ឌទី ២) ។

# ជំពូកទី ៣
# ច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស (១)
# ~ ទ្រឹស្ដីទូទៅនៃច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស

I. សព្វទស្សន៍នៃច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស

១. "វត្ថុ"ជាទ្រព្យសម្បត្តិ និង សិទ្ធិប្រត្យ័ក្ស

២. និយមន័យនៃសិទ្ធិប្រត្យ័ក្ស និងគោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់

៣. ប្រភេទនៃសិទ្ធិប្រត្យ័ក្ស

៤. ការប្រៀបធៀបរវាងទ្រឹស្ដីទូទៅនៃច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស និងច្បាប់ស្ដីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

II. ការសិក្សាចំណុចសំខាន់ៗក្នុងទ្រឹស្ដីទូទៅនៃច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស

១. សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យ័ក្ស

២. ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស

៣. កម្មសិទ្ធិ

៤. សិទ្ធិប្រត្យ័ក្សប្រើប្រាស់ និងអាស្រ័យផល

៥. សិទ្ធិកាន់កាប់

# I. សព្វទស្សន៍នៃច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស

## ១. "វត្ថុ"ជាទ្រព្យសម្បត្តិ និងសិទ្ធិប្រត្យ័ក្ស

ក្រមរដ្ឋប្បវេណី ចែងអំពីបទបញ្ញត្តិបែងចែកសិទ្ធិដែលយើងទាំងអស់គ្នាកាន់កាប់ ជាសិទ្ធិដែលមានទៅលើវត្ថុ និងសិទ្ធិដែលមានទៅលើបុគ្គល ។ នៅក្នុងក្រមរដ្ឋប្បវេណី ត្រង់គន្ថីទី ២ ស្ដីពីសិទ្ធិប្រត្យ័ក្ស មានចែងនូវបញ្ញត្តិស្ដីពីសិទ្ធិដែលមានទៅលើវត្ថុ គេហៅថាជាច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស ។

ដើម្បីឱ្យងាយយល់សម្រាប់អ្នកសិក្សាខាងផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ឬគណនេយ្យវិទ្យា យើងនឹងចាប់ផ្ដើមពីពាក្យថាទ្រព្យសម្បត្តិ ។ ឧទាហរណ៍ ពាក្យថាទ្រព្យសម្បត្តិនៅក្នុងន័យគណនេយ្យវិទ្យា ហាក់បីដូចជាសំដៅទៅលើសមត្ថភាពរបស់សហគ្រាសក្នុងការរកចំណូលនៅពេលអនាគត ។ ប៉ុន្តែ នៅទីនេះ យើងនឹងមិនគិតដល់ចំណុចពិបាកយ៉ាងនេះទេ ។ ចូរយើងគិតពីចំណុចមូលដ្ឋាននៃទ្រព្យសម្បត្តិដែលបុគ្គលម្នាក់មាន ។ ទ្រព្យសម្បត្តិរបស់បុគ្គល រួមមានអចលនវត្ថុដូចជា ដីធ្លី អាគារ និង ចលនវត្ថុដូចជាគ្រឿងសង្ហារឹម អលង្ការ ផ្ទាំងគំនូរ ជាដើម ។ ហើយលើសពីនេះទៀត គេមានសិទ្ធិលើបំណុល ក្រោមរូបភាពជាប័ណ្ណភាគហ៊ុន គណនីលក់ជឿកម្ចី ប្រាក់បញ្ញើ ជាដើម ។ ក្រៅពីនេះ គេក៏អាចមានប្រាក់កាក់ផងដែរ ។ យោងតាមក្រមរដ្ឋប្បវេណី ក្នុងចំណោមទ្រព្យសម្បត្តិទាំងអស់នេះ វត្ថុទាំងឡាយដែលមានរូបរាងជាប្រភេទអចលនវត្ថុ និងចលនវត្ថុ គេហៅថា វត្ថុ (និយមន័យនៃវត្ថុ មានចែងនៅក្នុងមាត្រា ៨៥ នៃបទបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណី) (សូមអានពាក្យគន្លឹះ : វត្ថុចម្បង វត្ថុចំណុះ វត្ថុដើម ផល) ។ ហើយសិទ្ធិគ្រប់គ្រង ដែលបុគ្គលម្នាក់មានដោយផ្ទាល់ទៅលើវត្ថុនោះ គេហៅថា សិទ្ធិប្រត្យ័ក្ស ។ អាស្រ័យហេតុនេះហើយ នៅក្នុងវិសាលភាពនៃច្បាប់ស្ដីពីសិទ្ធិប្រត្យ័ក្ស យើងមិនធ្វើការពិភាក្សាទៅលើវត្ថុដែលជាទ្រព្យសម្បត្តិនោះទេ គឺយើងនឹងពិភាក្សាអំពីបទបញ្ញត្តិដែលចែងថា តើបុគ្គលម្នាក់មានសិទ្ធិគ្រប់គ្រងបែបណាខ្លះទៅលើវត្ថុ ។

ពាក់ព័ន្ធទៅនឹងរឿងនេះ ក្រមរដ្ឋប្បវេណីជប៉ុន ចាត់ទុកដី និងអាគារដែលមាននៅលើដីនោះ ថាជាអចលវត្ថុដែលមានលក្ខណៈឯករាជពីគ្នា (នៅប្រទេសខ្លះ គេចាត់ទុកដី និងអាគារថាជាអចលវត្ថុរួមគ្នាតែមួយ) ។ ចំពោះករណីនេះ ដើមឈើដែលដុះនៅលើដី ជាគោលការណ៍

ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃដី (មាត្រា ៨៦ ស្តីពីវត្ថុភ្ជាប់) លើកលែងតែក្នុងករណីដែលបទបញ្ញត្តិនៃច្បាប់ ឬឆន្ទៈរបស់ភាគី កំណត់ថា ដើមឈើដែលជាកម្មវត្ថុនៃការជួញដូរគឺជាអចលនវត្ថុដាច់ដោយឡែកពីដី ។

**វត្ថុចម្បង វត្ថុចំណុះ វត្ថុដើម ផល**

នៅពេលដែលវត្ថុពីរមានទំនាក់ទំនងគ្នាជាវត្ថុចម្បងនិងវត្ថុបន្ទាប់បន្សំរបស់វត្ថុចម្បង ក្នុងន័យសេដ្ឋកិច្ច និងអាស្រ័យកត្តាសត្យានុមតិ (ឧទាហរណ៍ វាំងផ្ទះនិងទ្វាបង្អួចខាងក្នុងផ្ទះ ជាដើម) នោះគេហៅថាជា វត្ថុចម្បងនិងវត្ថុចំណុះ ។ ត្រឹមកម្រិតដែលមិនប៉ះពាល់ដល់សិទ្ធិរបស់តតិយជន វត្ថុចំណុះត្រូវភ្ជាប់ជាផ្នែកមួយនៃវត្ថុចម្បងតាមផ្លូវច្បាប់ (ឧទាហរណ៍ បើលក់វត្ថុចម្បងនោះវត្ថុចំណុះក៏ត្រូវលក់ជាមួយគ្នាដែរ) ។ វត្ថុចម្បងនិងវត្ថុចំណុះ មិនអាចជាកម្មសិទ្ធិនៃម្ចាស់ផ្សេងគ្នាបានទេ បើទោះជាវត្ថុចំណុះត្រូវជារបស់ឯករាជពីវត្ថុចម្បងក៏ដោយ (គេមិនអាចចាត់ទុកទ្វារ ឬទ្វារសំណាញ់ ដែលជាផ្នែកខាងក្រៅនៃអាគារ ថាជាវត្ថុឯករាជពីអាគារដែលជាវត្ថុចម្បងនោះបានឡើយ) ។ វត្ថុដែលកើតចេញពីវត្ថុមួយទៀត ដោយមានអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចនោះ គេហៅថា ផល ។ ចំណែកវត្ថុដែលបង្កើតផលហៅថាវត្ថុដើម ។ ប៉ុន្តែគួរកត់សំគាល់ថា ផលមិនមែនសំដៅតែទៅលើផ្លែឈើប៉ុណ្ណោះទេ ។ វត្ថុដែលកើតចេញពីវត្ថុដើម តាមធម្មជាតិ ឬដោយវិធីសិប្បនិម្មិត បន្ទាប់ពីមានការប្រើប្រាស់នូវវត្ថុដើមនោះសមស្របតាមលក្ខណៈសេដ្ឋកិច្ចរួចមក គេហៅថា ផលធម្មជាតិ (ដូចជា ស៊ុត ផ្លែឈើ រោមចៀម អិដ្ឋ រ៉ែ ដីឥដ្ឋ ខ្សាច់ ជាដើម) (មាត្រា ៨៨ កថាខ័ណ្ឌទី ១ ) ។ ចំណែកឯប្រាក់ ឬ វត្ថុផ្សេងទៀតដែលទទួលបានជាថ្នូរទៅនឹងការប្រើប្រាស់វត្ថុដើម គេហៅថា ផលស៊ីវិល (ដូចជា ថ្លៃឈ្នួលផ្ទះ ឬការប្រាក់ជាដើម) (មាត្រា ៨៨ កថាខ័ណ្ឌទី ២) ។

## ២. និយមន័យនៃសិទ្ធិប្រត្យក្ស និងគោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់

យើងបានធ្វើការពន្យល់រួចហើយ អំពីចំណុចសំខាន់ៗលើនិយមន័យនៃសិទ្ធិប្រត្យក្ស (ជំពូកទី ១ វគ្គ II.២) ។ ឧទាហរណ៍ បើបុគ្គលណាម្នាក់មានកម្មសិទ្ធិលើនាឡិកាដៃមួយ បុគ្គលនោះអាចប្រើប្រាស់នាឡិកានោះដោយសេរី អាចទទួលផលចំណេញពីនាឡិកា និងអាច ចាត់ចែងនាឡិកានោះដោយសេរីបាន (សិទ្ធិដែលបុគ្គលម្នាក់អាចគ្រប់គ្រងដោយផ្ទាល់ទៅលើវត្ថុអ្វីមួយ ហៅ

ថាសិទ្ធិប្រត្យ័ក្ស) ។ អាស្រយហេតុនេះ សិទ្ធិប្រត្យ័ក្សដែលជាសិទ្ធិគ្រប់គ្រងដោយផ្ទាល់ទៅលើវត្ថុអ្វីមួយនោះ ត្រូវមានលក្ខណៈជាសិទ្ធិដែលអាចយកទៅតតាំងជាមួយអ្នកដទៃ មិនឱ្យធ្វើការលំខានដល់ការគ្រប់គ្រងនោះ ហើយអាចយកទៅអះអាងចំពោះអ្នកណាក៏បានដែរនៅក្នុងសង្គម ។ នេះគេហៅថា ភាពដាច់ខាតនិងភាពផ្តាច់មុខនៃសិទ្ធិប្រត្យ័ក្ស ។ ដោយសារតែសិទ្ធិដែលអាចយកទៅតតាំងជាមួយនរណាក៏បាននៅក្នុងសង្គម នឹងធ្វើឱ្យមានឥទ្ធិពលទៅលើមនុស្សជុំវិញ បើសិនជាមនុស្សម្នាអាចកំណត់ខ្លឹមសាររបស់សិទ្ធិនោះបានតាមអំពើចិត្តរបស់ខ្លួន ការកំណត់ខ្លឹមសារនេះនឹងធ្វើឱ្យកើតជាបញ្ហាមិនខាន ។ ហេតុនេះហើយបានជាមាត្រា ១៧៥ នៃក្រមរដ្ឋប្បវេណីចែងថា "សិទ្ធិប្រត្យ័ក្សមិនអាចបង្កើតបានឡើយ ក្រៅពីការកំណត់ដោយបទបញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនិងច្បាប់ដទៃផ្សេងទៀត"។ នេះមានន័យថា កិច្ចសន្យាជាដើមមិនអាចបង្កើតឱ្យមានសិទ្ធិប្រត្យ័ក្សប្រភេទផ្សេងពីបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីនិងច្បាប់ផ្សេងទៀតបានទេ ហើយក៏មិនអាចកំណត់ខ្លឹមសារនៃសិទ្ធិប្រត្យ័ក្ស ឱ្យខុសពីអ្វីដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនិងច្បាប់ផ្សេងទៀតនោះបានទេដែរ ។ នេះគេហៅថា គោលការណ៍កំណត់សិទ្ធិប្រត្យ័ក្សដោយច្បាប់ ។ អាស្រ័យហេតុនេះហើយ បទបញ្ញត្តិដែលទាក់ទងទៅនឹងខ្លឹមសារ និងប្រភេទនៃសិទ្ធិប្រត្យ័ក្សគឺជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ហើយតាមរយៈនោះ ភាគីមិនអាចធ្វើការកែប្រែតាមឆន្ទៈរបស់ខ្លួនបានឡើយ ។ ចំណុចនេះ ខុសគ្នាស្រឡះពីការណីដែលសិទ្ធិលើបំណុលអាចត្រូវបានបង្កើតដោយសេរី តាមកិច្ចសន្យាជាអាទិ៍ (សិទ្ធិលើបំណុលអាចត្រូវបានបង្កើតឡើង ក្រោមរូបភាពបែបណាក៏បានដែរ អាស្រ័យលើកិច្ចសន្យា កុំឱ្យតែផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ ។ ដោយសារតែសិទ្ធិលើបំណុលមានអានុភាពដោយធៀបដែលចងចំពោះតែភាគីក្នុងកិច្ចសន្យាប៉ុណ្ណោះ ដូច្នេះការណ៍ដែលទុកឱ្យភាគីអាចបង្កើតសិទ្ធិនេះដោយខ្លួនឯងបានគឺជាការប្រសើរ) ។

# ៣. ប្រភេទនៃសិទ្ធិប្រត្យ័ក្ស

## ៣.១. កម្មសិទ្ធិ

ឥឡូវនេះ ចូរយើងពិនិត្យមើលអំពីប្រភេទនៃសិទ្ធិប្រត្យ័ក្ស ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី (ប្រភេទនៃសិទ្ធិគ្រប់គ្រងដែលបុគ្គលម្នាក់មានទៅលើវត្ថុ) ។ ប្រភេទមួយដែលយើងស្គាល់គ្រប់គ្នានោះ គឺកម្មសិទ្ធិ ។ កម្មសិទ្ធិករនៃនាឡិកាដៃមួយ មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងនាឡិកានោះ ដោយសេរីអាស្រ័យលើឆន្ទៈ ។ នេះមានន័យថា កម្មសិទ្ធិ គឺជាសិទ្ធិប្រត្យ័ក្សដែលមានលក្ខណៈពេញលេញនិងទូលំទូលាយ ។ រួចចុះសិទ្ធិប្រត្យ័ក្សដែលពុំមានលក្ខណៈពេញលេញនិងទូលំទូលាយវិញនោះ តើជាអ្វីទៅ ?

## ៣.២. សិទ្ធិប្រត្យ័ក្សមានកម្រិតផ្សេងទៀតក្រៅពីសិទ្ធិលើកម្មសិទ្ធិ

ឧទាហរណ៍ថា លោក A មានកម្មសិទ្ធិលើវត្ថុអ្វីមួយ ។ ក្នុងករណីនេះ លោក B ដែលជាបុគ្គលដទៃ ក៏អាចមានសិទ្ធិមួយផ្នែកទៅលើវត្ថុនោះដែរ ។ នៅត្រង់ចំណុចនេះ គួរកត់សំគាល់ថា ជាធម្មតា ចំពោះវត្ថុមួយ គេអាចមានសិទ្ធិប្រត្យ័ក្សប្រភេទដូចគ្នាតែមួយប៉ុណ្ណោះទៅលើវត្ថុនោះ (នេះគេហៅថា គោលការណ៍វត្ថុមួយសិទ្ធិមួយ) ។ ឧទាហរណ៍ ក្នុងករណីដែលបងប្អូន (ពីរនាក់) កាន់កាប់វត្ថុមួយរួមគ្នា កម្មសិទ្ធិនោះជាកម្មសិទ្ធិតែមួយរួមគ្នា មិនអាចបំបែកចេញបានជាកម្មសិទ្ធិរបស់រៀង១ខ្លួននោះឡើយ ។ ហើយការណ៍ដែលកំណត់ថា សំរាប់វត្ថុមួយគឺមានតែកម្មសិទ្ធិមួយទេនោះ គឺមានសេចក្តីថាកម្មសិទ្ធិមានមុខងាររួមបញ្ចូលគ្នានូវសិទ្ធិទាំងអស់ រួមមានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងផង ប៉ុន្តែមួយផ្នែកនៃសិទ្ធិទាំងនេះអាចបែងចែកឱ្យបុគ្គលផ្សេងគ្នាកាន់កាប់បាន (ឧទាហរណ៍ ករណីដែលលោក A ជាម្ចាស់កម្មសិទ្ធិលើដីមួយកន្លែង តែលោក B មានសិទ្ធិប្រើប្រាស់ដីនោះសម្រាប់ការដាំដុះ) ។ នេះគេហៅថា សិទ្ធិប្រត្យ័ក្សមានកម្រិត ឬសិទ្ធីប្រត្យ័ក្សផ្សេងទៀតក្រៅពីសិទ្ធិលើកម្មសិទ្ធិ ។

## ៣.៣. សិទ្ធិប្រត្យ័ក្សប្រើប្រាស់និងអាស្រ័យផល

ប្រភេទនៃសិទ្ធិប្រត្យ័ក្សក្រៅពីកម្មសិទ្ធិ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ជាបឋម មានសិទ្ធិលើផ្ទៃដី (Superficies) ដែលតាមរយៈនេះ បុគ្គលម្នាក់អាចសាងសង់និងប្រើប្រាស់ដោយសេរី នូវអាគារ ឬសំណង់ផ្សេងទៀត ដែលមាននៅលើដីរបស់អ្នកដទៃ (ចាប់ពីមាត្រា ២៦៥) ។ ក្រៅពីនេះមានសិទ្ធិបង្កបង្កើនផលជាអចិន្ត្រៃយ៍ (Emphytesis) ដែលតាមរយៈនេះបុគ្គលម្នាក់អាចប្រើប្រាស់ដីរបស់អ្នកដ៏ទៃបានដើម្បីដាំដុះ ឬចិញ្ចឹមសត្វ (ចាប់ពីមាត្រា ២៧០) ។ ហើយមានសិទ្ធិសេវភាព ដែលតាមរយៈនោះបុគ្គលម្នាក់មានសិទ្ធិឆ្លងកាត់ ឬបង្ហូរទឹក តាមដីរបស់អ្នកដ៏ទៃដើម្បីផលប្រយោជន៍នៃដីរបស់ខ្លួនបាន (ចាប់ពីមាត្រា ២៨០) ។ មានសិទ្ធិប្រើប្រាស់សម្បត្តិសាធារណៈ (Commonage) ដែលតាមរយៈនេះមនុស្សមួយក្រុមកំណត់ អាចប្រើប្រាស់ដីរួមគ្នាបាន (មាត្រា ២៦៣ មាត្រា ២៩៤) ។ ខាងលើនេះ គឺជាសិទ្ធិប្រត្យ័ក្សមានកម្រិតទាំងបួនប្រភេទ ដែលទាក់ទងទៅនឹងការប្រើប្រាស់វត្ថុរបស់អ្នកដ៏ទៃ ។ ជាទូទៅ នេះគេហៅថា សិទ្ធិប្រត្យ័ក្សប្រើប្រាស់និងអាស្រ័យផល ។ ដូច្នេះ សិទ្ធិប្រត្យ័ក្សប្រើប្រាស់និងអាស្រ័យផល ត្រូវគេហៅថាជាសិទ្ធិប្រត្យ័ក្សមានកម្រិត ដែលមានខ្លឹមសារអនុញ្ញាតឱ្យប្រើប្រាស់និងអាស្រ័យផល លើវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដ៏ទៃ ។ ការអនុវត្តន៍ត្រូវមានកម្រិតកំណត់ក្នុងក្របខណ្ឌនៃការប្រើប្រាស់និងអាស្រ័យផលនេះ ហើយនិងមានការដាក់កម្រិតទៅលើសិទ្ធិលើកម្មសិទ្ធិ ឱ្យបានសមស្រងតាមក្របខណ្ឌនេះទៀតផង ។

## ៣.៤. សិទ្ធិប្រាតិភោគប្រត្យ័ក្ស

ផ្ទុយពីចំណុចដែលបានរៀបរាប់ខាងលើ ក៏មានបទបញ្ញត្តិដែលចែងអំពីសិទ្ធិប្រត្យ័ក្សមានកម្រិតមួយទៀត ដែលតាមរយៈនោះ បុគ្គលដែលមិនមែនជាកម្មសិទ្ធិករមិនធ្វើការកាន់កាប់វត្ថុដោយជាក់ស្ដែងទេ គឺគ្រាន់តែប្រើប្រាស់តម្លៃនៃវត្ថុនោះតែប៉ុណ្ណោះ ។ ជាក់ស្ដែង ដើម្បីជាការធានាដល់ការអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួន នៅពេលឱ្យប្រាក់ទៅកូនបំណុលខ្ចី ម្ចាស់បំណុលអាចទាមទារការគ្រប់គ្រងលើតម្លៃនៃវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលបាន ។ នេះគេហៅថា សិទ្ធិប្រាតិភោគប្រត្យ័ក្ស (មានន័យថា នៅពេលខ្ចីប្រាក់ពីគេ កូនបំណុលយកទ្រព្យសម្បត្តិ

របស់ខ្លួនទៅដាក់ធានា ហើយបើហួសរយៈពេលកំណត់ហើយខ្លួននៅតែមិនទាន់សងប្រាក់ទៀត ម្ចាស់បំណុលអាចលក់វត្ថុដែលដាក់បញ្ចាំ រួចដកប្រាក់ដែលលក់បានដើម្បីទូទាត់បំណុលនោះ ។ ការធ្វើរបៀបនេះគេហៅថា សិទ្ធិប្រាតិភោគប្រត្យ័ក្ស) ។ សិទ្ធិប្រាតិភោគប្រត្យ័ក្ស ដែលមានចែង នៅក្នុងក្រមរដ្ឋប្បវេណី ចែកចេញជាពីរប្រភេទ គឺសិទ្ធិប្រាតិភោគប្រត្យ័ក្សតាមកិច្ចសន្យាដែល កើតឡើងតាមកិច្ចសន្យារវាងភាគី និងសិទ្ធិប្រាតិភោគប្រត្យ័ក្សតាមច្បាប់ ដែលច្បាប់ធ្វើការកំណត់ នៅពេលមានកាលៈទេសៈពិសេសណាមួយ ។ នៅក្នុងករណីជាច្រើន សិទ្ធិប្រាតិភោគប្រត្យ័ក្ស តាមកិច្ចសន្យា គឺជាសិទ្ធិលើការបញ្ចាំ ដែលត្រូវបានបង្កើតលើចលនវត្ថុ (ចាប់ពីមាត្រា ៣៤២ តទៅ ។ សិទ្ធិលើការបញ្ចាំ ក៏អាចត្រូវបានបង្កើតលើអចលនវត្ថុ និង សិទ្ធិលើបំណុលជាអាទិ៍ ផងដែរ) និង ហ៊ីប៉ូតែក ដែលត្រូវបានបង្កើតលើអចលនវត្ថុ ដូចជាដីឬអាគារជាដើម (ចាប់ពីមាត្រា ៣៦៩) ។ ហើយសិទ្ធិប្រាតិភោគប្រត្យ័ក្សតាមច្បាប់ មានចែកជាសិទ្ធិឃាត់ទុក (ចាប់ពីមាត្រា ២៩៥) និង ឯកសិទ្ធិ (ចាប់ពីមាត្រា ៣០៣) ។

## ៣.៥. សិទ្ធិកាន់កាប់

នៅមានសិទ្ធិមួយទៀតដែលជាខ្សែស្រឡាយនៃសិទ្ធិប្រត្យ័ក្សដែរនោះ គឺសិទ្ធិកាន់កាប់ ។ ជាបឋម បញ្ញត្តិដែលចែងនៅផ្នែកដំបូងនៃគន្ថីស្តីពីសិទ្ធិប្រត្យ័ក្ស មិនមែនជាបញ្ញត្តិស្តីពីកម្មសិទ្ធិទេ តែគឺជាបញ្ញត្តិស្តីពីសិទ្ធិកាន់កាប់ (សិទ្ធិកាន់កាប់ មានចែងនៅក្នុងបទបញ្ញត្តិចាប់ពីមាត្រា ១៨០ តទៅ) ។ សិទ្ធិកាន់កាប់ មានលក្ខណៈខុសប្លែកគ្នាបន្តិចបន្តួច អំពីសិទ្ធិប្រត្យ័ក្សផ្សេងទៀត ។ ពិព្រោះ សិទ្ធិប្រត្យ័ក្សទាំងទឡាយដែលមានឋានៈក្រោមកម្មសិទ្ធិ គឺជាតំណាងនិមិត្តរូបនៃសិទ្ធិជាសារធាតុ អាស្រ័យច្បាប់ (សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តិ) ដែលបុគ្គលម្នាក់មានទៅលើវត្ថុណាមួយ ដោយមិនគិតថាតើវាជាសិទ្ធិដែលមានវិសាលភាពទូលំទូលាយ ឬវិសាលភាពមួយផ្នែកនោះទេ ។ ដោយឡែកសិទ្ធិកាន់កាប់វិញ មិនមែនដូច្នោះទេ ។ នៅក្នុងសិទ្ធិកាន់កាប់ គេមិនចាំបាច់ត្រូវដឹងថា តើបុគ្គលនោះមានសិទ្ធិជាសារធាតុ ឬពុំមាននោះទេ ។ វាគ្រាន់តែជា ប្រព័ន្ធសំរាប់រក្សាស្ថានភាព បច្ចុប្បន្នកាលជាក់ស្តែង នៃការគ្រប់គ្រងទៅលើវត្ថុតែប៉ុណ្ណោះ (យើងនឹងពិនិត្យអំពីចំណុចនេះ បន្ថែមទៀតនៅផ្នែក II.៥) ។

អាស្រ័យហេតុនេះហើយបានជាគន្ថីស្តីពីសិទ្ធិប្រត្យ័ក្សនៃក្រមរដ្ឋប្បវេណី មានចែងនូវបទបញ្ញត្តិផ្សេងៗ តាមលំដាប់លំដោយចាប់ផ្តើមអំពីសិទ្ធិកាន់កាប់ រួចហើយអំពីកម្មសិទ្ធិ សិទ្ធិប្រើប្រាស់និងអាស្រ័យផល និងសិទ្ធិប្រាតិភោគប្រត្យ័ក្ស ។ មុខវិជ្ជាសិក្សាដែលចាប់ពីសិទ្ធិកាន់កាប់ កម្មសិទ្ធិ រហូតដល់សិទ្ធិប្រត្យ័ក្សប្រើប្រាស់និងអាស្រ័យផល គេហៅថាជាច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្សតាមន័យចង្អៀត ឬថាជាទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស ។ ចំណែកឯមុខវជ្ជាសិក្សាស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្សវិញ គេហៅថាជាច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស ដោយចាត់ទុកវាជាផ្នែកមួយឯករាជ ។

## ៤. ការប្រៀបធៀបរវាងទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស និងច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

ផ្នែកដែលនិយាយអំពីទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស មានខ្លឹមសារជាទ្រឹស្តីច្រើនជាងហើយបទបញ្ញត្តិទាំងឡាយមានលក្ខណៈពិសេស ជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ។ ផ្ទុយទៅវិញ ច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស មានលក្ខណៈពិសេសជាបញ្ញត្តិប្រតិបត្តិ ឬបច្ចេកទេស ។ គេអាចនិយាយបានថាវាជាផ្នែកមួយដ៏សំខាន់នៃការអនុវត្តជាក់ស្តែង នៅក្នុងប្រតិបត្តិការជំនួញហិរញ្ញវត្ថុជាអាទិ៍ (នៅក្នុងការអនុវត្តជាក់ស្តែងផ្នែកហិរញ្ញវត្ថុ មានបញ្ហាជាច្រើនបានកើតឡើងជាញឹកញាប់ ទាក់ទងទៅនឹងផ្នែកច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស និងទ្រឹស្តីទូទៅនៃសិទ្ធិលើបំណុល) ។ បើពោលឱ្យស្រួលយល់ នៅក្នុងផ្នែកដែលនិយាយអំពីទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស គេសិក្សាដោយផ្តោតទៅលើចំណុចសំខាន់ថា តើសិទ្ធិប្រត្យ័ក្សគឺជាអ្វី ។ ដោយឡែកនៅក្នុងច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្សវិញ គេសិក្សាថាតើគេអាចធ្វើអ្វីបានចំពោះសិទ្ធិប្រត្យ័ក្សទាំងនោះ ដើម្បីធានាបាននូវការអនុវត្តសិទ្ធិលើបំណុល និងប្រមូលមកវិញបាននូវបំណុលជាប្រាក់ឈ្នួល ឬប្រាក់ជឿនោះ ។ ហេតុដូច្នេះហើយ បើមិនយល់ច្បាស់អំពីការអនុវត្តជាក់ស្តែងនៃប្រតិបត្តិការជួញដូរទេនោះ គេនឹងមានការលំបាកក្នុងការស្វែង យល់ពីអត្ថន័យពិតប្រាកដនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស ។ អាស្រ័យហេតុនេះ ជាលំដាប់លំដោយនៃការសិក្សាលើក្រមរដ្ឋប្បវេណី យើងអាចសិក្សាអំពីផ្នែកទាក់ទងនឹងទ្រឹស្តីទូទៅ នៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្សបានជាមុនសិន ។ ចំណែកឯច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស គួរទុកសិក្សាក្រោយ ទើបជាការល្អ ។

ជាអនុសាស៍មួយទៅលើរបៀបនៃការសិក្សា ជាបឋម គេគួរតែស្វែងយល់អំពីចំណុចមូលដ្ឋាននៃទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្សជាមុនសិន រួចពីនោះសឹមងាកទៅសិក្សាអំពីច្បាប់ស្តីពីសិទ្ធីប្រាតិភោគប្រត្យ័ក្ស តាមរយៈការស្វែងយល់អំពីទំនាក់ទំនងរបស់សិទ្ធិនេះជាមួយនឹងទ្រឹស្តីទូទៅនៃសិទ្ធិលើបំណុល ។ ជាការពិត នៅទីនេះយើងគ្រាន់តែធ្វើការបង្ហាញអំពីចំណុចងាយៗមួយចំនួនប៉ុណ្ណោះ ទាក់ទងទៅនឹងច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស ។ ចំណែកឯចំណុចលំអិត នឹងមានពន្យល់នៅជំពូកទី ៧ បន្ទាប់ពីបានសិក្សាច្បាប់ស្តីពីសិទ្ធិលើបំណុលសិន ។

## II. ការសិក្សាចំណុចសំខាន់ៗក្នុងទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស

### ១. សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យ័ក្ស

ដូចដែលបានពោលរួចមកហើយ ដោយសារថាសិទ្ធិប្រត្យ័ក្សគឺជាសិទ្ធិគ្រប់គ្រងលើវត្ថុដោយផ្ទាល់មុខនិងដាច់ខាត សិទ្ធិនេះអាចយកទៅតតាំងជាមួយនឹងនរណាក៏បានដែរ នៅក្នុងសង្គម ។ អាស្រ័យហេតុនេះ បើមានបុគ្គលណាម្នាក់មករំលោភបំពានទៅលើសិទ្ធិប្រត្យ័ក្សរបស់អ្នកដទៃ គេអាចរារាំងការបំពាននោះ ទាមទារឱ្យសងមកវិញនូវវត្ថុដែលត្រូវបានយកទៅបាត់ និងអាចហាមប្រាមមិនឱ្យមានការបំពានកើតឡើងទៀតបាន ដោយផ្អែកលើលក្ខណៈជាមូលដ្ឋាននៃសិទ្ធិប្រត្យ័ក្ស ។ នេះគេហៅថា សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យ័ក្ស ។ សិទ្ធីទាមទារដោយផ្អែកលើសិទ្ធីប្រត្យ័ក្សនេះ មានលក្ខណៈខុសពីសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិលើបំណុល ដែលតាមរយៈនោះបុគ្គលម្នាក់អាចធ្វើការទាមទារអ្វីមួយពីបុគ្គលម្នាក់ទៀតបាន ដោយយោងតាមកិច្ចសន្យាជាដើម (ឧទាហរណ៍ ការទាមទារប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ជាដើម) ។ សិទ្ធិទាមទារ ដោយផ្អែកលើសិទ្ធិប្រត្យ័ក្សកើតឡើងពីការកាន់កាប់សិទ្ធិប្រត្យ័ក្ស (នៅក្នុងករណីនេះ ឱ្យតែការរំលោភបំពានមានលក្ខណៈផ្ទុយពីច្បាប់យ៉ាងជាក់ស្តែង គេអាចអនុវត្តសិទ្ធិទាមទារនេះ ដោយពុំចាំបាច់គិតថា តើអ្នករំលោភបំពាននោះបានប្រព្រឹត្តដោយចេតនា ឬដោយកំហុសនោះទេ) ។ ឧទាហរណ៍ ក្នុងករណីរបស់កម្មសិទ្ធិករណាម្នាក់ បើមានបុគ្គលដ៏ទៃផ្សេងទៀត មកកាន់កាប់វត្ថុដែលជាកម្មសិទ្ធីរបស់ខ្លួន ដោយបំពាន (ឬដោយធ្វេសប្រហែស) កម្មសិទ្ធិករអាចប្រាប់បុគ្គលនោះឱ្យប្រគល់

វត្ថុមកខ្លួនវិញបាន ឬបើអ្នកណាម្នាក់បានចូលមកក្នុងបរិវេណដីរបស់ខ្លួន ដោយគ្មានការអនុញ្ញាត កម្មសិទ្ធិករអាចបណ្តេញអ្នកនោះចេញទៅវិញបាន (សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង ដោយផ្អែកលើកម្មសិទ្ធិ) ។ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យ័ក្ស ក៏អាចយកទៅអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិប្រត្យ័ក្សមានកម្រិតផ្សេងទៀត ដូចជាសិទ្ធិលើផ្ទៃដីជាដើម សមស្របទៅតាមវិសាលភាពនៃសិទ្ធិប្រត្យ័ក្សនីមួយៗនោះ (សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យ័ក្ស ដែលជាសិទ្ធិប្រាតិភោគប្រត្យ័ក្សវិញ ដូចជាហ៊ីប៉ូតែកជាដើម នឹងមានពន្យល់នៅជំពូកទី ៧) ។

## ២. ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស

សិទ្ធិប្រត្យ័ក្សដែលមានទៅលើចលនវត្ថុក្តី អចលនវត្ថុក្តី អាចត្រូវបានផ្ទេរតាមរយៈ កិច្ចសន្យា ដូចជាការលក់និងការទិញ ឬប្រទានកម្មជាដើម ហើយក៏អាចត្រូវបានផ្ទេរដោយមូលហេតុសន្តតិកម្មជាផងដែរ ។ ចំណុចសំខាន់បំផុតក្នុងទ្រឹស្តីទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស គឺការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្សនេះឯង ដែលជាបញ្ហាចោទឡើងនៅក្នុងករណីដែលមានការផ្ទេរសិទ្ធិប្រត្យ័ក្សពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ នៅត្រង់ចំណុចនេះ មានទឡ្ហីករណ៍មួយចំនួនច្រើន ហើយបានបង្កើតចេញជាទ្រឹស្តីផ្សេងៗ ។ អ្នកដែលចាប់ផ្តើម សិក្សាដំបូងមិនត្រូវមើលរំលងសមាសភាគនៃខ្លឹមសារជាសារវ័ន្ត ដោយសារការចាប់អារម្មណ៍ច្រើនពេកលើទឡ្ហីករណ៍ដ៏សគ្រស្មាញទាំងនោះឡើយ ។ បន្តទៅទៀតនេះ យើងនឹងផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើរចនាសម្ព័ន្ធជាមូលដ្ឋាននៃបទបញ្ញត្តិ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន ។

### ២.១. គោលការណ៍នៃការបង្ហាញជាសាធារណៈ

ជាបឋម សិទ្ធិប្រត្យ័ក្សគឺជាសិទ្ធិដែលអាចយកទៅតតាំងជាមួយនរណាក៏បាននៅក្នុងសង្គម ។ និយាយត្រឡប់ទៅវិញ បើសិនជាមនុស្សជុំវិញមិនមានវិធីអ្វីដើម្បីដឹងបានថា តើនរណាជាម្ចាស់សិទ្ធិទេនោះ វានឹងកើតមានជាបញ្ហាមិនខាន ។ ដោយហេតុនេះហើយ ការជូនតំណឹង

ឱ្យគេដឹងជាសាធារណៈអំពីអត្ថិភាពនៃសិទ្ធិប្រត្យ័ក្ស តាមវិធីមួយដែលគេហៅថាវិធីបង្ហាញជាសាធារណៈ គឺជាការចាំបាច់ណាស់ ។ គោលគិតដែលកំណត់ថា ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស ចាំបាច់ត្រូវតែអមជាមួយនឹងការបង្ហាញជាសាធារណៈនោះ គេហៅថាជាគោលការណ៍នៃការបង្ហាញជាសាធារណៈ ។ សព្វថ្ងៃនេះ ការតម្រូវឱ្យបង្ហាញជាសាធារណៈរបៀបនេះ គឺជាចំណុចរួមដែលនៅប្រទេសដទៃទៀតក៏អនុវត្តដូចគ្នាដែរ ។ បញ្ហាដែលចោទឡើងគឺនៅត្រង់អត្ថន័យខុសៗគ្នានៃការបង្ហាញជាសាធារណៈនេះឯង ។

## ២.២. គោលការណ៍នៃល័ក្ខខ័ណ្ឌតតាំង

### ២.២.១. ទ្រឹស្តីទូទៅ

ក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន បទបញ្ញត្តិស្តីពីការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធីប្រត្យ័ក្ស អនុវត្តនូវគោលការណ៍នៃល័ក្ខខ័ណ្ឌតតាំង ដែលជាគោលការណ៍ឬវចនាសម្ព័ន្ធជាមូលដ្ឋាន ដូចគ្នាទៅនឹងការផ្ទេរសិទ្ធិលើបំណុលធម្មតាដែរ ដែលនឹងមានពន្យល់នៅពេលក្រោយ ។ តាមរយៈគោលការណ៍នេះ ការផ្ទេរសិទ្ធិប្រត្យ័ក្សអាចធ្វើទៅបាន ដោយយោងទៅលើការបង្ហាញឆន្ទៈរបស់ភាគីពាក់ព័ន្ធតែប៉ុណ្ណោះ (មាត្រា ១៧៦ ។ នេះគេហៅថា គោលការណ៍នៃការបង្ហាញឆន្ទៈក្នុងការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធីប្រត្យ័ក្ស ។ ហេតុនេះហើយ មានតែការបង្ហាញឆន្ទៈរបស់ភាគីតែប៉ុណ្ណោះ ដែលជាល័ក្ខខ័ណ្ឌចាំបាច់ សំរាប់ធ្វើឱ្យការផ្ទេរសិទ្ធិប្រត្យ័ក្សមានសុពលភាព) ។ ក៏ប៉ុន្តែ ដើម្បីអាចតតាំងបានជាមួយនឹងបុគ្គលដទៃទៀត ក្រៅពីភាគីដែលពាក់ព័ន្ធ គេត្រូវអនុវត្តតាមនីតិវិធីដើម្បីតតាំងដែលត្រូវកំណត់ដោយច្បាប់ ពោលគឺល័ក្ខខ័ណ្ឌតតាំង ។ (ពាក្យគន្លឹះ : ល័ក្ខខ័ណ្ឌតតាំង) នៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន ល័ក្ខខ័ណ្ឌតតាំងសំរាប់អចលនវត្ថុ គឺការចុះបញ្ជី (មាត្រា ១៧៧) ចំណែកល័ក្ខខ័ណ្ឌតតាំងសំរាប់ចលនវត្ថុ គឺការប្រគល់វត្ថុនោះ (មាត្រា ១៧៨) ។ (គួរកត់ចំណាំថា ដោយសារភាពខុសគ្នាទៅនឹងសិទ្ធិប្រត្យ័ក្សជាក់លាក់ដូចជាកម្មសិទ្ធិជាដើម សិទ្ធិកាន់កាប់ ដែលថ្វីត្បិតតែមានលក្ខណៈជាសិទ្ធិប្រត្យ័ក្សក្តី ក៏វាគ្រាន់តែជួយរក្សាស្ថានភាពជាក់ស្តែងនៃការគ្រប់គ្រងលើវត្ថុតែប៉ុណ្ណោះ ទោះបីជាសាមីខ្លួនកំពុងកាន់កាប់អចលនវត្ថុក៏ដោយ ក៏គេពុំអាចចុះបញ្ជីសិទ្ធិកាន់កាប់នោះបានទេ) ។

នេះមានសេចក្តីថា ឧបមាថានៅពេលដែលលោក A លក់ដីដែលជាកម្មសិទ្ធិរបស់ខ្លួនទៅឱ្យលោក B ការបង្ហាញឆន្ទៈទៅវិញទៅមកថា ខ្លួនព្រមលក់និងព្រមទិញ ធ្វើឱ្យកើតជាកិច្ចសន្យាមួយ ដែលតាមរយៈនេះ រវាងអ្នកទាំងពីរ ដីរបស់លោក A បានក្លាយទៅជាដីរបស់លោក B ។ ក៏ប៉ុន្តែ ដើម្បីអាចតតាំងជាមួយមនុស្សជុំវិញដូចជាលោក C លោក D លោក E ជាដើម ថាដីនោះបានក្លាយទៅជាកម្មសិទ្ធិរបស់ខ្លួនហើយនោះ លោក B ត្រូវឱ្យលោក A ផ្ទេរឈ្មោះម្ចាស់កម្មសិទ្ធិមកឱ្យខ្លួនវិញសិន ។ នៅទីនេះ តាមរយៈការប្តូរនាម (ពីលោក A ) ទៅជាលោក B ការចុះបញ្ជីមានន័យថា ជាការបង្ហាញជាសាធារណៈថាលោក B គឺជាម្ចាស់សិទ្ធិពិតប្រាកដ ។ ហេតុដូច្នេះហើយ នៅប្រទេសជប៉ុន វិធីបង្ហាញជាសាធារណៈអំពីសិទ្ធិប្រត្យ័ក្សលើអចលនវត្ថុ គឺការចុះបញ្ជី ចំណែកវិធីបង្ហាញជាសាធារណៈអំពីសិទ្ធិប្រត្យ័ក្សលើចលនវត្ថុវិញ គឺការប្រគល់វត្ថុ ។ ទោះបីជាការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស អាចប្រព្រឹត្តទៅបានតែតាមការបង្ហាញឆន្ទៈរបស់ភាគីក៏ដោយ ការចុះបញ្ជីអំពីការផ្ទេរ ឬការប្រគល់វត្ថុ គឺជាល័ក្ខខ័ណ្ឌតតាំងដែលតម្រូវឱ្យអនុវត្តដោយខានមិនបាន ។

### ល័ក្ខខ័ណ្ឌតតាំង

នៅប្រទេសជប៉ុន ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្សលើអចលនវត្ថុ ឬចលនវត្ថុក្តី ការធ្វើអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះក្តី ត្រូវគោរពទៅតាមគោលការណ៍នៃល័ក្ខខ័ណ្ឌតតាំង ។ យើងគួរធ្វើការបែងចែកឱ្យបានត្រឹមត្រូវរវាងល័ក្ខខ័ណ្ឌនៃសុពលភាព និងល័ក្ខខ័ណ្ឌតតាំងទាក់ទងនឹងការផ្ទេរសិទ្ធិ ។ ល័ក្ខខ័ណ្ឌតតាំងចំពោះតតិយជន នៅក្នុងករណីនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ តម្រូវឱ្យមានការធ្វើសេចក្តីជូនដំណឹងទៅកាន់កូនបំណុល ឬការយល់ព្រមពីកូនបំណុល ក្រោមរូបភាពជាលិខិត ដែលមានកាលបរិច្ឆេទស្លាក (មាត្រា ៤៦៧ កថាខ័ណ្ឌទី ២ ។ សូមអានជំពូកទី ៦ វគ្គ II. ៥.២) ។

### ២.២.២. និតិប្រៀបធៀប

ការដែលកំណត់ថា ការផ្ទេរសិទ្ធិប្រត្យ័ក្សអាចធ្វើទៅបានដោយគ្រាន់តែមានការព្រមព្រៀងរវាងភាគី ហើយថាការចុះបញ្ជី ឬការប្រគល់វត្ថុ ត្រូវចាត់ទុកថាជាល័ក្ខខ័ណ្ឌតតាំងនោះ គឺជាទ្រឹស្ដីតាមប្រព័ន្ធបារាំង ។ ផ្ទុយទៅវិញ នៅក្នុងប្រព័ន្ធអាល្លឺម៉ង់ ការបង្ហាញឆន្ទៈតែម្យ៉ាងមិនអាចធ្វើឱ្យមានការផ្ទេរសិទ្ធិប្រត្យ័ក្សបានទេ ។ ចំពោះអចលនវត្ថុ គេត្រូវចុះបញ្ជីជាមុនសិន ទើបការផ្ទេរសិទ្ធិប្រត្យ័ក្សអាចកើតឡើងបាន ហើយចំពោះចលនវត្ថុវិញ គេត្រូវប្រគល់វត្ថុជាមុនសិន ទើបការផ្ទេរសិទ្ធិប្រត្យ័ក្សអាចកើតឡើងបាន ។ នេះមានន័យថា នៅប្រទេសអាល្លឺម៉ង់ ការចុះបញ្ជីមិនមែនជាល័ក្ខខ័ណ្ឌតតាំងទេ វាគឺជាល័ក្ខខ័ណ្ឌដែលធ្វើឱ្យមានការបង្កើតការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស ហើយក៏ជាល័ក្ខខ័ណ្ឌនៃសុពលភាពដែរ ។ តាមការពិត វិធីសាស្ត្រក្នុងការចុះបញ្ជីតាមរបៀបបារាំង និងតាមរបៀបអាល្លឺម៉ង់ មានលក្ខណៈខុសគ្នា ។ នៅប្រទេសជប៉ុន ច្បាប់ស្ដីពីការចុះបញ្ជីបានកំណត់យកតាមវិធីសាស្ត្រចុះបញ្ជីប្រទេសអាល្លឺម៉ង់ ។ ដោយសារមូលហេតុនេះផង ហើយនិងដោយសារប្រព័ន្ធអាល្លឺម៉ង់មានភាពងាយយល់ ដោយកំណត់ថាឱ្យតែបានចុះបញ្ជីហើយគឺសិទ្ធីប្រត្យ័ក្សត្រូវកើតមានឡើងនោះ ទើបបានជាអ្នកសិក្សាជប៉ុនមួយចំនួនបានលើកឡើងទ្រឹស្ដីខ្លះៗដែលទាញទៅរកការបកស្រាយអំពីការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស តាមបែបអាល្លឺម៉ង់ទៅវិញ ។ ដោយសារថាទឡ្ហីករណ៍ទាំងនេះ មានខ្លឹមសារស្មុគស្មាញពិបាកយល់ដូច្នេះនៅទីនេះ យើងគ្រាន់តែត្រូវចាំទុកថា បទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនអនុវត្តតាមគោលការណ៍នៃល័ក្ខខ័ណ្ឌតតាំងតាមបែបបារាំង ។

## ២.៣. បញ្ហានៃការតតាំង

ប្រសិនបើលោក A ធ្វើកិច្ចសន្យាលក់ដីដែលជាកម្មសិទ្ធិរបស់ខ្លួនទៅឱ្យលោក B ។ នៅក្នុងដំណាក់កាលនោះ កម្មសិទ្ធិលើដីរបស់លោក A ត្រូវបានទៅលោក B ។ ប៉ុន្តែ បើសិនជាបញ្ជីឈ្មោះកម្មសិទ្ធិដីនៅតែជារបស់លោក A ហើយនៅមិនទាន់ផ្ទេរឈ្មោះទៅឱ្យលោក B ទេនោះគឺលោក B មិនអាចអះអាងតតាំងជាមួយអ្នកដទៃថា ខ្លួនជាម្ចាស់កម្មសិទ្ធិបានឡើយ ។ ឧប្បមាថាក្នុងស្ថានភាពនេះ ប្រសិនបើលោក A លក់ដីដដែលនេះទៅឱ្យលោក C ទៀត គឺនឹងកើត

មានការលក់ដីនោះពីរដងត្រួតគ្នា ។ នេះជាករណីដែលគេមិនចង់ឱ្យកើតមានឡើង ប៉ុន្តែដោយសារមានហេតុការណ៍ផ្សេងៗអាចនាំឱ្យវាកើតមានឡើងបាន ។ ក្នុងករណីនេះ ប្រសិនបើលោក C បានទទួលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិពីលោក A មុន គឺលោក C អាចតតាំងជាមួយអ្នកដទៃបានដោយអះអាងថាខ្លួនជាម្ចាស់កម្មសិទ្ធិ ហើយដីនោះត្រូវក្លាយទៅជារបស់លោក C ។ ក្នុងករណីដែលមានមនុស្សច្រើនគ្នា អះអាងអំពីសិទ្ធិដែលមិនសមនឹងកើតមានឡើងនៅពេលជាមួយគ្នាបានដូចមានរៀបរាបក្នុងឧទាហរណ៍ខាងលើស្តីពីការលក់ដីពីរដងត្រួតគ្នាទេនោះ អាទិភាពនៃសិទ្ធិត្រូវសម្រេចដោយផ្អែកលើល័ក្ខខ័ណ្ឌនៃការតតាំង ។ បញ្ហានេះ គេហៅថាបញ្ហានៃការតតាំង ។

ផ្ទុយទៅវិញ ប្រសិនបើលោក C ដឹងច្បាស់ថាលោក A បានធ្វើកិច្ចសន្យាលក់ដីនោះទៅឱ្យលោក B រួចទៅហើយ ប៉ុន្តែខ្លួននៅតែមានបំណងចង់ដណ្តើមទិញដីនោះ ហើយបានឱ្យផ្ទេរឈ្មោះមកខ្លួនទៀត ដើម្បីកុំឱ្យលោក B យកដីនោះបាន បើសិនជាយើងចេះតែឱ្យលោក C ទទួលបាននូវអត្ថប្រយោជន៍យ៉ាងនេះទៀត គឺនឹងមានបញ្ហាកើតឡើង ។ យោងតាមយុត្តិសាស្ត្ររបស់តុលាការ គេអាចចាត់ទុកករណីរបស់លោក C ថាជាជនមានចេតនាអាក្រក់រំលោភលើទំនុកចិត្តអ្នកដទៃ ហើយសម្រេចទៅតាមករណីលើកលែងដោយទុកឱ្យលោក B ជាកម្មសិទ្ធិករទៅលើដីនោះ បើទោះណាជាលោក B ពុំបានចុះបញ្ជីដីក៏ដោយ ។

អ្នកសិក្សាបានវែកញែកស្វែងរកទ្រឹស្តីមួយចំនួន ដើម្បីបកស្រាយអំពីលទ្ធភាពដែលអាចធ្វើឱ្យមានការផ្ទេរត្រួតគ្នានេះ ។ គេបានលើកឡើងនូវបញ្ហាថា នៅពេលដែលលោក A លក់ដីនោះទៅឱ្យលោក B គឺកម្មសិទ្ធិរបស់លោក A ត្រូវបាត់អស់ ។ ដូច្នេះលោក A មិនអាចមានសិទ្ធិលក់ដីដដែលនោះម្តងទៀតទៅឱ្យលោក C បានឡើយ ។ នេះជាបញ្ហាមួយស្មុគ្រស្មាញក្នុងការសិក្សាអំពីទ្រឹស្តី ។ នៅទីនេះ យើងត្រូវការតែចំណាំទុកសិនថា ផ្អែកលើបញ្ញត្តិស្តីពីគោលការណ៍នៃការតតាំង ក្នុងតំណាក់កាលដែលលោក B ទិញបានដីពីលោក A ហើយគឺមានការផ្ទេរលទ្ធកម្មសិទ្ធិយ៉ាងពិតប្រាកដមែន រវាងលោក A និង លោក B ។ ប៉ុន្តែសិទ្ធិនេះនៅមិនទាន់មានការធានាគ្រប់គ្រាន់សំរាប់តតាំងជាមួយតតិយជនបាននៅឡើយទេ (ក្នុងន័យនេះ នៅមិនទាន់មានលក្ខណៈជាសិទ្ធិពេញលេញនៅឡើយ) ។ នៅពេលនោះ ប្រសិនបើមានលោក C ចូលមកពាក់ព័ន្ធនៅក្នុងការលក់ដូររវាងលោក A និងលោក B ហើយថែមទាំងបានបំពេញតាមលក្ខខ័ណ្ឌនៃការតតាំងទៀតផងនោះ ជាលទ្ធផល គឺលោក C អាចតតាំងជាមួយលោក B បាន

ប៉ុន្តែលោក B បែរជាមិនអាចតតាំងជាមួយលោក C បានឡើយ ក្នុងការធ្វើលទ្ធកម្មនៃសិទ្ធិ ។ នេះជាប្រព័ន្ធមួយដែលនាំទៅរកការបដិសេធមិនឱ្យលោក B ទទួលសិទ្ធិនោះបាន (ជាការពិតប្រាកដណាស់ ជាលទ្ធផល ថ្វីត្បិតតែលោក B មិនអាចធ្វើលទ្ធកម្មនៃសិទ្ធិក៏ដោយ ក៏លោក B អាចប្តឹងទាមទារសំណងពីលោក A ដោយឈរលើទិដ្ឋភាពនៃកិច្ចសន្យា ដែលលោក A មិនបានបំពេញតាមកាតព្វកិច្ចនោះ ។ ចំណុចនេះនឹងមានបកស្រាយនៅជំពូកទី ៦ វគ្គទី II. ២.២) ។

## ២.៤.លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្សលើអចលនវត្ថុ

### ២.៤.១. ទ្រឹស្តីជាមូលដ្ឋាន

បន្តពីនេះ យើងនឹងធ្វើការពន្យល់លំអិតបន្ថែម អំពីការចុះបញ្ជីសិទ្ធិ ដែលជាលក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្សលើអចលនវត្ថុ ។ មាត្រា ១៧៧ នៃក្រមរដ្ឋប្បវេណីចែងថា "ការធ្វើលទ្ធកម្ម ការបាត់បង់ និងការកែប្រែសិទ្ធិប្រត្យ័ក្សលើអចលនវត្ថុ មិនអាចយកទៅតតាំងជាមួយតតិយជនបានទេ ប្រសិនបើមិនមានការចុះបញ្ជីសិទ្ធិនោះទៅតាមច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ និងច្បាប់ដទៃទៀតស្តីពីការចុះបញ្ជីសិទ្ធិនោះទេ" ។ មានន័យថា ថ្វីត្បិតតែការធ្វើលទ្ធកម្ម ការបាត់បង់ និងការកែប្រែសិទ្ធិប្រត្យ័ក្សលើអចលនវត្ថុតាមច្បាប់ អាចកើតឡើងបាន ឱ្យតែមានការបងាញឆន្ទៈយ៉ាងដូច្នេះក៏ពិតមែន ប៉ុន្តែប្រសិនបើពុំបានចុះបញ្ជីសិទ្ធិទេនោះ គឺមិនអាចតតាំងទប់ស្កាត់នឹងការទាមទាររបស់តតិយជនបានទេ ។ ហេតុដូច្នេះ ការចុះបញ្ជីសិទ្ធិ គឺគ្រាន់តែជាមធ្យោបាយដើម្បីតតាំងនឹងតតិយជនតែប៉ុណ្ណោះ ។ ប្រសិនជា ពុំបានចុះបញ្ជីទេ ក៏ការផ្ទេរសិទ្ធិអាចសំរេចបានដែរ ។ ត្រង់នេះ យើងអាចយល់ឃើញករណីពីរដូចតទៅ ។ ករណីទីមួយ គឺអាចបណ្តាលមកពីម្ចាស់សិទ្ធិពុំបានទៅចុះបញ្ជីសិទ្ធិរបស់ផងខ្លួន ។ ប៉ុន្តែផ្ទុយទៅវិញ បើសិនជាមានការចុះបញ្ជីដោយសេចក្តីភូតកុហកទាំងស្រុងពុំមានឆន្ទៈព្រមព្រៀងគ្នាទេនោះ គឺការចុះបញ្ជីសិទ្ធិនោះនឹងមិនមានសុពលភាពទេ ដោយហេតុថាសិទ្ធិពិតប្រាកតអាចស្ថិតនៅជាមួយអ្នកផ្សេងទៀត ។ ករណីទីពីរ គេអាចចោទសួរថា បើមិនបានចុះបញ្ជីទេនោះ គឺគេមិនអាចតតាំងនឹងគ្រប់តតិយជនណាទាំងអស់ មែនដែរឬទេ ។ ក្នុងសំនួរនេះ ការណ៍ដែលមិនបានចុះបញ្ជីនោះ

ហាក់ដូចជាមិនមានន័យថាគេមិនអាចតតាំងនឹង ការទាមទារសិទ្ធិរបស់តតិយជនគ្រប់គ្នានៅលើពិភពលោកនោះទេ ។ ចំពោះចំណុចទាំងអស់នេះ យើងនឹងធ្វើការបកស្រាយដូចតទៅ ។

## ២.៤.២.ការសន្មត់នៃការចុះបញ្ជី និងការជឿជាក់នៅលើការចុះបញ្ជី

ដោយហេតុថា ការចុះបញ្ជីគឺដើម្បីបំពេញនូវល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្ស មិនមែនដើម្បីបំពេញនូវល័ក្ខខ័ណ្ឌសំរាប់បង្កើត ផ្ទេរ និងកែប្រែសិទ្ធីប្រត្យ័ក្សទេនោះ (ពោលគឺមានករណីខ្លះ គេទុកឱ្យនៅគ្មានការចុះបញ្ជីក៏បានដែរ ។ ប៉ុន្តែ បើសិនណាមានការផ្ទេរកម្មសិទ្ធិផ្ទួនគ្នាពីរដង ឬការរឹបអូសបែបណាមួយកើតឡើង ម្ចាស់បំណុលក្នុងការរឹបអូស និងអនុប្បទានិកថ្មី អាចនឹងឈ្នះ) ។ ប៉ុន្តែតាមពិត បើសិនជាមានការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្សហើយនោះ ជាធម្មតាគេត្រូវទៅចុះបញ្ជី ។ ត្រង់នេះហើយដែលមានការសន្មត់នៃការចុះបញ្ជី ។ ពោលគឺ យុត្តិសាស្ត្ររបស់តុលាការក៏បានចាត់ទុកដែរថា ល្គិកណាដែលពុំមានការបង្ហាញនូវភស្តុតាងផ្ទុយទេនោះ គេត្រូវសន្មត់ថាទំនាក់ ទំនងនៃសិទ្ធិត្រូវមានលក្ខណៈដូចដែលបានចុះក្នុងបញ្ជីនោះមែន ។ (តាមពិត នេះគ្រាន់តែហៅថាជាការសន្មត់តែប៉ុណ្ណោះ បើសិនជាការតវ៉ាអំពីភាពមិនត្រឹមត្រូវនៃខ្លឹមសារក្នុងការចុះបញ្ជី មានភស្តុតាងសំរាប់បង្ហាញអំពីលក្ខណៈមិនច្បាស់លាស់នៃខ្លឹមសារនោះ គឺការសន្មត់ត្រូវទៅជាគ្មានអានុភាព) ។

ប៉ុន្តែគេមិនទទួលស្គាល់ទេ អំពីអានុភាពនៃការជឿទុកចិត្តថាបើមានការចុះបញ្ជីហើយគឺត្រូវជឿថាមានសិទ្ធិប្រត្យ័ក្សស្របច្បាប់នោះ ។ (ចំពោះករណីនៃប្រទេសអាល្លឺម៉ង់វិញ ដូចបានរៀបរាប់ជូនរួចហើយ ថាបើពុំមានការចុះបញ្ជីទេគឺការផ្ទេរសិទ្ធិពុំអាចកើតមានឡើងបានឡើយ ។ ដូច្នេះនៅប្រទេសអាល្លឺម៉ង់ គេទទួលស្គាល់ឱ្យមានការជឿទុកចិត្តថា បើមានការចុះបញ្ជីហើយគឺត្រូវមានសិទ្ធិ ។ ដូចបានលើកឡើងរួចហើយថា នៅប្រទេសជប៉ុនក៏មានទ្រឹស្តីសិក្សាមួយចំនួនយល់ស្របតាមច្បាប់ប្រទេសអាល្លឺម៉ង់ដែរ) ។ ដោយសារហេតុនេះ បើសិនជាមានការលក់ដូរណាមួយ ដែលធ្វើឡើងដោយសារមានការជឿទុកចិត្តលើការចុះបញ្ជីមិនពិត ដែលមិនមានភាពត្រឹមត្រូវតាមទំនាក់ទំនងជាក់ស្តែងទេនោះ គឺពុំអាចទទួលបាននូវសិទ្ធិដែលមានកំណត់ក្នុងចុះបញ្ជីនោះឡើយ ។ ប៉ុន្តែ យុត្តិសាស្ត្រច្បាប់របស់តុលាការបានបង្ហាញឱ្យឃើញថា ទោះជាក្នុងករណីដែលមានការចុះបញ្ជីមិនត្រឹមត្រូវតាមទំនាក់ទំនងជាក់ស្តែងដ៏ដោយ បើសិនជាបុគ្គលដែលមានសិទ្ធិ

ពិតប្រាកដត្រូវទទួលបន្ទុកផងដែរ ចំពោះការមិនអើពើនឹងការចុះបញ្ជីមិនពិតនោះ ហើយប្រសិនបើភាគីម្ខាងទៀតក្នុងការលក់ដូរ ដែលបានជឿជាក់លើការចុះបញ្ជីនេះបានអនុវត្តសមស្របតាមល័ក្ខខ័ណ្ឌសុចរិត គឺតុលាការនឹងកែតម្រូវផ្នែកខ្វះនៃការខ្វះខាតក្នុងចំណុចនេះ ដោយជួយការពារដល់អ្នកទិញ តាមវិធីអនុវត្តប្រៀបប្រដូចទៅនឹងបញ្ញត្តិស្ដីពីការសមគំនិតក្នុងការបង្ហាញឆន្ទៈមិនពិត ដូចដែលមានចែងក្នុងមាត្រា ៩៤ កថាខ័ណ្ឌទី ២ ។ (ដើមឡើយ បញ្ញត្តិនេះមិនមានកម្មវត្ថុចែងកំណត់អំពីបញ្ហានេះទេ ប៉ុន្តែដោយសារតែវត្ថុបំណងដូចគ្នា គេក៏យកបញ្ញត្តិនេះមកអនុវត្តតាមវិធីប្រៀបប្រដូចដើម្បីរកដំណោះស្រាយសំរាប់បញ្ហានេះ) ។ ពោលគឺថា ឧបមាបើសិនជា A ដែលជាម្ចាស់កម្មសិទ្ធិពិតប្រាកដ បានផ្ទេរឈ្មោះទៅឱ្យ B ហើយទុករឿងនេះចោលដោយមិនរវីរវល់ ។ ក្រោយមក B បានលក់អចលនវត្ថុដដែលនោះទៅឱ្យ C ដែលមិនបានដឹងឮពីហេតុការណ៍អ្វីទាល់តែសោះ ។ ចំពោះករណីនេះ គេចាត់ទុការមិនរវីរវល់របស់ A ដែលបានចុះបញ្ជីផ្ទេឈ្មោះទៅឱ្យ B ទុកចោលជាសិទ្ធិករនោះ ថាវាដូចគ្នាទៅនឹងការបង្ហាញឆន្ទៈមិនពិតរវាង A និង B ។ ដូច្នេះ ដោយផ្អែកលើមាត្រា ៩៤ កថាខ័ណ្ឌទី ២ A មិនអាចតតាំងនឹង C ដែលមានសុចរិតនេះបានឡើយ បើសិនជា A ចង់អះអាងថាការចុះបញ្ជីរបស់ B គ្រាន់តែជាលក្ខណៈខាងក្រៅហើយត្រូវចាត់ទុកជាមោឃៈនោះ ។ ( C អាចធ្វើលទ្ធកម្មបានដោយមានសុពលភាព) ។

## ២.៤.៣. ការចុះបញ្ជី និងតតិយជន

មាត្រា ១៧៧ មានចែងថា តតិយជនសំដៅទៅលើបុគ្គលក្រៅពីភាគីពាក់ព័ន្ធ និងអ្នកទទួលមរតក ។ ប៉ុន្តែប្រសិនបើឈ្មោះ x ជាកម្មសិទ្ធិករពិតប្រាកដ ប្ដឹងទាមទារឱ្យលុបចោលការចុះបញ្ជីរបស់ឈ្មោះ Y ដែលបានទទួលការផ្ទេឈ្មោះដោយវិធីបន្លំឯកសារ ពេលនោះនឹងមានបញ្ហាពិបាកមួយកើតឡើង ដោយគេអាចនឹងបដិសេធមិនព្រមទទួលស្គាល់ការប្ដឹងរបស់កម្មសិទ្ធិករព្រោះកម្មសិទ្ធិ x នេះមិនបានចុះបញ្ជីទេ ។ នេះធ្វើឱ្យយើងគិតឃើញថា ពាក្យថា តតិយជនក្នុងករណីនេះត្រូវបានទទួលអត្ថន័យរិតត្បិតមួយចំនួន (ទ្រឹស្ដីរិតត្បិត) ។

អនុលោមតាមយុត្តិសាស្ត្រច្បាប់របស់តុលាការ តតិយជនក្នុងបញ្ហានេះមានពីរប្រភេទ ។ តតិយជនដែលគេអាចតតាំងជាមួយបាន លុះត្រាតែបានចុះបញ្ជីរួចហើយនោះ ត្រូវបានបកស្រាយថាជា"ជនដែលមានផលប្រយោជន៍សមហេតុផល ក្នុងការអះអាងតវ៉ាអំពីលក្ខណៈខ្វះខាតក្នុងការ

ចុះបញ្ជី" ។ តាមការជាក់ស្តែង ជនទាំងនោះរួមមានអ្នកទទួលសិទ្ធិប្រត្យ័ក្សលើអវលនចត្ថុតែមួយ អ្នកជួល ម្ចាស់សិទ្ធិលើបំណុលដែលធ្វើការរឹបអូស ជាដើម ។ ផ្ទុយទៅវិញ យើងគិតថា តតិយជន ដែលគេអាចតតាំងជាមួយបានទោះបីជាមិនបានចុះបញ្ជីក៏ដោយ (ពោលគឺ ជនទាំងឡាយដែល មិនមានផលប្រយោជន៍សមហេតុផលទេ ក្នុងការតវ៉ាអំពីការខ្វះខាតនៃការចុះបញ្ជី) រួមមាន

ក. ករណីរបស់ជនពីរប្រភេទ ដែលច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ បានចែងច្បាស់ថា បដិសេធមិនទទួលស្គាល់ឱ្យធ្វើការតវ៉ាទេនោះ ។ ទីមួយគឺអ្នកដែលបានរារាំងដល់ការចុះបញ្ជី ដោយ ប្រើវិធីឆបោកឬគំរាមកំហែង (មាត្រា ៤ នៃច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ) និងទីពីរគឺអ្នក ដែលមានករណីយកិច្ចតំណាងឱ្យអ្នកដទៃក្នុងការសុំចុះបញ្ជី (រួមមានដូចជា អ្នកតំណាងដែលច្បាប់ កំណត់ អ្នកគ្រប់គ្រងទ្រព្យធនក្ស័យ អាណត្តិគាហក ។ ល ។) (មាត្រា ៥ នៃច្បាប់ស្តីពីការចុះបញ្ជី អចលនវត្ថុ) ។ ជាឧទាហរណ៍នៃករណីទីពីរនេះ ឧបមាថាលោក A បានលក់អចលនទ្រព្យទៅ ឱ្យលោក B ប៉ុន្តែនៅពេលទៅចុះបញ្ជីផ្ទេរឈ្មោះ លោក C ដែលជាអ្នកតំណាងឱ្យលោក B នោះ បែរជាចុះឈ្មោះរបស់ខ្លួនឯងទៅវិញ ។ ក្នុងករណីនេះលោក B អាចតតាំងជាមួយលោក C បាន បើទោះណាជាខ្លួនពុំបានចុះបញ្ជីក៏ដោយ ។

ខ. ករណីនៃជនដែលមានចេតនាអាក្រក់រំលោភលើទំនុកចិត្តអ្នកដទៃ ។ បើគ្រាន់តែជា រឿងទុច្ចរិត (មានការដឹងឮអំពីព្រឹត្តិការណ៍ទុកជាមុន) គឺគេនៅមានការអនុគ្រោះឱ្យបាន ក្នុង វិសាលភាពនៃការប្រគួតប្រជែងដោយសេរី ប៉ុន្តែករណីនេះគឺសំដៅលើជនមានចេតនាអាក្រក់ ហើយបានរំលោភលើទំនុកចិត្តអ្នកដទៃ ដែលមានកំរិតធ្ងន់ធ្ងរស្មើនឹងករណីដែលមានចែងក្នុងមាត្រា ៤ និង ៥ នៃច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ (ពោលគឺ ជនដែលបានប្រព្រឹត្តអំពើដែលមិន អាចអនុគ្រោះឱ្យបានតាមគោលការណ៍នៃសេចក្តីទុកចិត្ត ដោយសារគេបានធ្វើសកម្មភាពជួញដូរ ដោយទុច្ចរិត ក្នុងគោលបំណងចង់ធ្វើទុក្ខដល់អ្នកដែលជាសិទ្ធិករពិតប្រាកដ) ។ ចំពោះការ បដិសេធជនដែលមានចេតនាអាក្រក់រំលោភលើទំនុកចិត្តអ្នកដទៃនេះ យុត្តិសាស្ត្ររបស់តុលាការ ធ្លាប់បានបញ្ជាក់រួចជាស្រេច ហើយទ្រឹស្តីសិក្សាមួយភាគច្រើនក៏បានឯកភាពតាមនោះដែរ ។

គ. ករណីរបស់អ្នកដែលបានតាំងទីលំនៅខុសច្បាប់ និងអ្នកដែលប្រព្រឹត្តអំពើអនិត្យានុកូល ។ ល ។ (ទាក់ទងនឹងអំពើអនិត្យានុកូល សូមអានជំពូកទី ៥) ។

# ២.៥. ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែ សិទ្ធិប្រត្យ័ក្សលើចលនវត្ថុ

## ២.៥.១.ទ្រឹស្តីជាមូលដ្ឋាន

មាត្រា ១៧៨ ចែងថា អនុប្បទាននៃសិទ្ធិប្រត្យ័ក្សលើចលនវត្ថុ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំមានការផ្ទេរចលនវត្ថុនោះ ។ ហេតុដូច្នេះហើយ ប្រសិនបើលោក A បានចុះកិច្ចសន្យាលក់កុំព្យូទ័រទៅឱ្យលោក B ហើយលោក B បានប្រគល់ប្រាក់ទៅឱ្យលោក A តែលោក B ពុំទាន់បានទទួលវត្ថុទេ ប៉ុន្តែក្រោយមកលោក A បានលក់កុំព្យូទ័រដដែលនោះទៅឱ្យលោក C ហើយបានប្រគល់កុំព្យូទ័រនោះទៅឱ្យលោក C ទៀតផង ។ ក្នុងករណីនេះ អ្នកដែលមានសិទ្ធិតតាំងជាមួយតតិយជនបានគឺលោក C មិនមែនលោក B ទេ ។ ដូច្នេះ លោក B មិនអាចទាមទារលោក C ឱ្យប្រគល់កុំព្យូទ័រនោះមកវិញបានទេ ។ នេះជាបញ្ហានៃការតតាំងទាក់ទងនឹងចលនវត្ថុ ។ (ជាការពិតណាស់ លោក B អាចប្តឹងទាមទារឱ្យលោក A ប្រគល់កុំព្យូទ័រមួយផ្សេងដែលដូចគ្នានោះ មកខ្លួនវិញបើសិនជាមាន ឬអាចទាមទារសំណងការខូចខាតជាប្រាក់ក៏បានដែរ ។ យើងនឹងសិក្សាអំពីរឿងទាំងនេះក្នុងច្បាប់ស្តីពីសិទ្ធិលើបំណុល) ។

## ២.៥.២.ចលនវត្ថុដែលជាកម្មវត្ថុនៃមាត្រា ១៧៨

តាមក្រមរដ្ឋប្បវេណី ចលនវត្ថុសំដៅទៅលើដី និងវត្ថុដែលភ្ជាប់នឹងដី (ពោលគឺវត្ថុក្រៅពីអចលនវត្ថុ) (មាត្រា ៨៦ កថាខ័ណ្ឌទី ២) ។ ប៉ុន្តែ គេចែកចលនវត្ថុជាពីរប្រភេទ ដោយយោងទៅតាមល័ក្ខខ័ណ្ឌតតាំង ។ ប្រភេទទីមួយគឺចលនវត្ថុដែលមានប្រព័ន្ធនៃល័ក្ខខ័ណ្ឌតតាំងពិសេស និងប្រភេទទីពីរគឺចលនវត្ថុដែលមានលក្ខណៈមិនសមស្របនឹងចាត់ទុកការប្រគល់វត្ថុថាជាល័ក្ខខ័ណ្ឌតតាំងនោះ ។ ចលនវត្ថុប្រភេទទីពីរនេះ ពុំស្ថិតនៅក្រោមការអនុវត្តនៃមាត្រា ១៧៨ ឡើយ ។ ឧទាហរណ៍ នាវា គ្រឿងយន្តសំណង់ រថយន្ត យន្តហោះ គឺជាចលនវត្ថុដែលមានប្រព័ន្ធចុះបញ្ជី ។ គ្រឿនយន្តទាំងឡាយណាដែលបានចុះបញ្ជីហើយ ការចុះបញ្ជីនោះគឺជាល័ក្ខខ័ណ្ឌតតាំង ។ ចលនវត្ថុដែលនៅជាប់ជាមួយនឹងអចលនវត្ថុ (ឧទាហរណ៍ កម្រាលឥដ្ឋ គ្រឿងសង្ហារឹម) ត្រូវមានវាសនារួមជាមួយនឹងអចលនវត្ថុ ដូច្នេះបើសិនជាគេបានចុះបញ្ជីលើការផ្ទេ

អចលនវត្ថុនោះហើយ គឺគេចាត់ទុកថាចលនវត្ថុទាំងនោះក៏ត្រូវបានបង្ហាញជាសាធារណៈតាមនោះដែរ ។

ក្រៅពីនេះ មានវត្ថុខ្លះទៀតដែលចំរូងចំរះ ។ សិទ្ធិលើបំណុលដែលមិនមានកត់ត្រាឈ្មោះអ្នកកាន់កាប់ ត្រូវចាត់ទុកជាចលនវត្ថុ (សំបុត្រកុន សំបុត្រចូលទស្សនាការប្រកួតកីឡា ។ ល ។ ដែលមិនមានបង្ហាញថា តើអ្នកណាជាសិទ្ធិករនោះទេ ប៉ុន្តែអ្នកដែលកាន់សំបុត្រនោះក្នុងដៃមាន សិទ្ធិលើបំណុលអាចទាមទារការចូលទៅមើលកុន ឬចូលទៅទស្សនាការប្រកួតកីឡាបាន) (មាត្រា ៨៦ កថាខ័ណ្ឌទី ៣) ដូច្នេះត្រូវជាកម្មវត្ថុនៃមាត្រា ១៧៨ ។ ការប្រគល់វត្ថុនេះក្លាយជាល័ក្ខខ័ណ្ឌនៃ ការ ។ ផ្ទុយទៅវិញ ប្រាក់មិនត្រូវបានរាប់បញ្ចូលទៅក្នុងចលនវត្ថុដែលមានល័ក្ខខ័ណ្ឌតតាំងឡើយ ព្រោះមានច្បាប់ពិសេសសម្រាប់អនុវត្តចំពោះប្រាក់ (ម៉្យាងទៀត ការមានកម្មសិទ្ធិនិងការកាន់កាប់ប្រាក់ គឺជាកត្តាតែមួយ ហើយគេយល់ថាមិនមែនជា កម្មវត្ថុនៃមាត្រា ១៧៨ នោះទេ) ។

## ២.៥.៣.ទម្រង់នៃការប្រគល់ចលនវត្ថុ

ការប្រគល់ចលនវត្ថុ បើយើងនិយាយតាមវិធីមួយផ្សេងទៀត គឺជាការផ្ទេរនូវស្ថានភាពមួយដែលច្បាប់ហៅថាជា"ការកាន់កាប់"នោះ ឱ្យចេញពីកន្លែងមួយទៅកន្លែងមួយទៀត ។ បញ្ហាស្ថិតនៅត្រង់ទម្រង់នៃការប្រគល់ចលនវត្ថុ ។ ជាការពិតណាស់ តាមការក់ស្តែង ការយកវត្ថុទៅឱ្យភាគីម្ខាងទៀត គឺជាការប្រគល់ (ហៅថាជាការ"ប្រគល់ជាក់ស្តែង" ។ មាត្រា ១៨២ កថាខ័ណ្ឌទី ១) ប៉ុន្តែក្នុងក្រមរដ្ឋប្បវេណី មានការកំណត់អំពីវិធីប្រគល់ចលនវត្ថុ (វិធីផ្ទេរការកាន់កាប់) ជាបីប្រភេទផ្សេងទៀត ។ ប្រភេទទីមួយ គឺការប្រគល់សាមញ្ញ (មាត្រា ១៨២ កថាខ័ណ្ឌទី ២) ។ ឧទាហរណ៍ ក្នុងករណីដែលលោក B ទិញវត្ថុមួយពីលោក A ដែលខ្លួនបានខ្ចីមកពីលោក A រួចស្រេចហើយនោះ ។ ដោយសារវត្ថុនោះស្ថិតនៅជាមួយលោក B រួចហើយ ដូច្នេះការប្រគល់ត្រូវចាត់ទុកថាបានចប់សព្វគ្រប់ (គេពុំចាំបាច់បង្វែរវត្ថុទៅលោក A វិញសិននោះទេ) ។ ប្រភេទទីពីរ គឺការប្តូរលក្ខណៈនៃការកាន់កាប់ (មាត្រា ១៨៣) ។ ឧទាហរណ៍ លោក A លក់វត្ថុដែលខ្លួនកាន់កាប់ទៅឱ្យលោក B ។ ប៉ុន្តែបន្ទាប់ពីលក់ហើយ លោក A នៅតែបន្តការកាន់កាប់វត្ថុនោះដដែល ដោយមានការយល់ព្រមពីលោក B ។ ក្នុងករណីនេះក៏លោក B ត្រូវចាត់

ទុកថាបានទទួលការប្រគល់វត្ថុពីលោក A រួចហើយដែរ ។ (គេពន្យល់ថា ក្នុងករណីនេះ លោក B ទទួលបានការកាន់កាប់ ហើយលោក A ដើរតួជាអ្នកតំណាងរបស់លោក B ក្នុងការកាន់កាប់វត្ថុ ។ ការកាន់កាប់របស់លោក B នេះ ហៅថាជាការកាន់កាប់ដោយប្រយោល) ។ ប្រភេទទីបី គឺការផ្ទេរការកាន់កាប់ដោយសេចក្តីបង្គាប់ (មាត្រា ១៨៤) ។ ឧទាហរណ៍ លោក A ផ្ញើវត្ថុនៅនឹងលោក C រួចហើយបានលក់វត្ថុផ្ញើនោះទៅឱ្យលោក B ។ ក្រោយមក តាមការយល់ព្រមរបស់លោក B លោក A បានបញ្ជារឱ្យលោក C កាន់កាប់វត្ថុនោះជំនួសលោក B សិន ។ ដូច្នេះលោក B បានទទួលនូវការប្រគល់វត្ថុ (ទទួលបានការកាន់កាប់ ។ ក្នុងករណីនេះ លោក B ក៏ជាអ្នកកាន់កាប់ដោយប្រយោលដែរ ចំណែកលោក C ធ្វើការកាន់កាប់ដោយចំពោះក្នុងឋានៈជាអ្នកតំណាងរបស់លោក B ។ ក្នុងករណីទាំងបីនេះ ការលក់ដូរពុំចាំបាច់ទាល់តែធ្វើការបង្វែរចលនវត្ថុទៅឱ្យម្ចាស់ដើមសិននោះទេ ។ ដូច្នេះ វិធីទាំងបីសុទ្ធតែមានលក្ខណៈសមហេតុសមផល ។ ប៉ុន្តែប្រភេទទីពីរ ដែលទាក់ទងទៅនឹងការប្តូរលក្ខណៈនៃការកាន់កាប់ ហាក់បីដូចជាអាចបង្កើតឱ្យមានបញ្ហាពិបាកជាងគេ ។ ព្រោះថា ទោះជាវត្ថុរបស់លោក A បានផ្ទេរទៅលោក B ហើយលោក B បានទទួលការគ្រល់ទៀតផងដែលជាល័ក្ខខ័ណ្ឌនៃការតតាំងនោះក៏ដោយ ក៏វត្ថុនោះនៅតែឋិតក្រោមការកាន់កាប់របស់កម្មសិទ្ធិករចាស់ គឺលោក A ដដែល ។ តាមការបកស្រាយរបស់តុលាការនិងទ្រឹស្តីទូទៅ ការប្តូរលក្ខណៈនៃការកាន់កាប់នេះ អាចទទួលស្គាល់បានថាជាល័ក្ខខ័ណ្ឌនៃការតតាំង ដូចគ្នានឹងការប្រគល់វត្ថុដែរ ។ ប៉ុន្តែ ប្រសិនបើលោក C បានទិញវត្ថុ (ដែលតាមពិតគឺជារបស់លោក B នោះ) ពីលោក A ដោយមានការជឿទុកចិត្តលើលក្ខណៈខាងក្រៅ (ដោយគិតថាលោក A ជាកម្មសិទ្ធិករនោះ) តើនឹងមានបញ្ហាអ្វីកើតឡើង ? ការការពារឱ្យលោក C នេះត្រូវបានគិតគូរក្នុងបញ្ញត្តិបន្ទាប់ទៀតស្តីពីលទ្ធកម្មភ្លាមៗ (លទ្ធកម្មដោយសុចរិត) ។

## ២.៦. ការកាន់កាប់ និងលទ្ធកម្មភ្លាមៗនូវចលនវត្ថុ

យើងបាននិយាយអំពីសិទ្ធិកាន់កាប់រួចមកហើយ ។ ពោលគឺ សិទ្ធិកាន់កាប់ គឺជាសិទ្ធិដែលត្រូវបានទទួលការការពារក្នុងកំរិតមួយ ចំពោះស្ថាភាពនៃព្រឹត្តការណ៍ដែលបុគ្គលម្នាក់កំពុកធ្វើការគ្រប់គ្រងលើវត្ថុអ្វីមួយ ទោះបីជាយើងមិនដឹងថាតើបុគ្គលនោះមាន ឬពុំមានសិទ្ធិប្រត្យ័ក្សពិតប្រាកដទេក៏ដោយ ។ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណីចែងថា ត្រូវសន្មត់ថាសិទ្ធិដែលអ្នកកាន់កាប់

កំពុងអនុវត្តលើវត្ថុក្រោមការកាន់កាប់របស់ខ្លួន គឺជាសិទ្ធិដែលមានលក្ខណៈស្របច្បាប់ ។ មានន័យថា បើមានបុគ្គលណាម្នាក់អនុវត្តសិទ្ធិដែលមានលក្ខណៈជាសិទ្ធិរបស់កម្មសិទ្ធិករ ទៅលើវត្ថុណាមួយ បុគ្គលនោះត្រូវបានសន្មត់សិនថាជាកម្មសិទ្ធិករ ។ ប៉ុន្តែមិនត្រូវភ្លេចថា ពាក្យថាសន្មត់ តាមរបៀបប្រើប្រាស់ក្នុងច្បាប់ គឺអាចនាំទៅដល់លទ្ធផលបដិសេធទៅវិញបាន បើសិនជាមានការបញ្ជាក់ភស្តុតាងផ្ទុយពីនេះ (ផ្ទុយទៅវិញ ក្នុងករណីដែលគេថា "ចាត់ទុក" គឺមានសេចក្តីថាជាការសំរេចដោយច្បាប់ មិនអាចអនុញ្ញាតិឱ្យមានការបង្ហាញភស្តុតាងផ្ទុយទៀតទេ ។ សូមអានពាក្យគន្លឹះ "ការសន្មត់"និង"ការចាត់ទុក" ។ អាស្រ័យហេតុនេះ បើសិនជាមានបុគ្គលម្នាក់ ចេញមកប្រកាសថាខ្លួនជាកម្មសិទ្ធិករនៃវត្ថុនោះ ហើយថែមទាំងអាចបញ្ជាក់បានអំពីកម្មសិទ្ធិរបស់ខ្លួនទៀតនោះ គឺវានឹងនាំឱ្យបដិសេធចោលសិទ្ធិរបស់អ្នកកាន់កាប់ ។ ប៉ុន្តែ ចំពោះការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យ័ក្សលើចលនវត្ថុវិញ មានការចែងនូវបញ្ញត្តិការពារខ្លាំងជាងនេះទៅទៀត ។ នោះគឺជាបញ្ញត្តិស្តីពីលទ្ធកម្មភ្លាមៗ (ក៏មានការហៅថាជា "លទ្ធកម្មដោយសុចរិត"ដែរ) ។

មាត្រា ១៩២ ចែងថា អ្នកដែលចាប់ធ្វើការកាន់កាប់ចលនវត្ថុ ដោយសុចរិត សន្តិវិធី និងគ្មានកំហុស អាស្រ័យសកម្មភាពជំនួញ ត្រូវធ្វើលទ្ធកម្មសិទ្ធិសំរាប់ប្រត្តិបតិការលើចលនវត្ថុនោះភ្លាមៗ ។ តើនេះមានន័យយ៉ាងដូចម្តេច? ដោយហេតុថាជំនួញនៃចលនវត្ថុត្រូវបានអនុវត្តជារៀងរាល់ថ្ងៃ វាអាចមានករណីខ្លះដែលអ្នកទិញបានទិញវត្ថុពីអ្នកដែលមិនមានសិទ្ធិចាត់ចែងវត្ថុនោះដោយមិនបានដឹងមុន ។ ឧទាហរណ៍ វាអាចកើតមានឡើងនូវករណីថា ថ្វីត្បិតតែអ្នកលក់ពិតជាមិនមែនកម្មសិទ្ធិករនៃទំនិញទេ គឺគ្រាន់តែជាទំនិញដែលកម្មសិទ្ធិករបានផ្ញើទុកប៉ុណ្ណោះក៏ដោយ ប៉ុន្តែអ្នកលក់បានធ្វើឱ្យគេជឿថាជាទំនិញរបស់ខ្លួនហើយលក់វាទៅបាត់ជាដើម ។ ប៉ុន្តែ ប្រសិនបើតម្រូវឱ្យអ្នកទិញធ្វើការស្រាវជ្រាវសព្វបែបយ៉ាងថា តើអ្នកលក់មានសិទ្ធិត្រឹមត្រូវសំរាប់លក់ទំនិញនេះដែរឬទេនោះ នឹងនឹងនាំឱ្យមានការលំបាកមិនអាចបង្កើតកិច្ចសន្យាលក់បានទេ ។ ដូច្នេះក្នុងករណីនេះគេត្រូវការពារអ្នកទិញ ដែលបានជឿទុកចិត្តលក្ខណៈខាងក្រៅរបស់អ្នកលក់ ។ ដើម្បីធានាសុវត្ថិភាពក្នុងការធ្វើជំនួញ ក្នុងករណីចលនវត្ថុ ប្រសិនបើអ្នកទិញបានទិញវត្ថុដោយសុចរិត (យើងយល់ថាសុចរិតនៅក្នុងបរិបទនេះ មិនត្រឹមតែមានន័យថា មិនបានដឹងអំពីព្រឹត្តការណ៍អ្វីសោះនោះទេ គឺថែមទាំងបានជឿទុកចិត្តថាភាគីម្ខាងទៀតជាសិទ្ធិករត្រឹមត្រូវទៀតផង) និងបានចាប់ផ្តើមកាន់កាប់វត្ថុហើយ នោះក្រមរដ្ឋប្បវេណីបានកំណត់ថា ទោះបីអ្នកលក់មិនមែនជាសិទ្ធិករត្រឹមត្រូវក៏ដោយ

ក៏អ្នកទិញបានធ្វើលទ្ធកម្មសិទ្ធិ (ឬលទ្ធកម្មកម្មសិទ្ធិ ក្នុងករណីនៃការលក់និងទិញ) នៅខណៈពេលប្រគល់វត្ថុនោះ ។ ការគិតរបៀបនេះ គឺឈរនៅលើគោលការណ៍នៃការជឿទុកចិត្តផងដែរ ។ គោលការណ៍សំដៅការពារបុគ្គលដែលទទួលបានការកាន់កាប់ ដោយសារកត្តាជឿទុកចិត្ត ក៏ប៉ុន្តែតាមការពិតគោលការណ៍នៃការជឿទុកចិត្តនេះ រកបដិសេធចោលនូវសិទ្ធិរបស់សិទ្ធិករដើម ជាឯកតោភាគី (ដោយមិនគិតថា តើសិទ្ធិករដើមនោះមានបន្ទុកទទួលខុសត្រូវ ឬមិនមានទេ) ។ ហេតុដូច្នេះ វាមានលក្ខណៈជាវិធានដែលលំអៀងក្នុងបរិបទខ្លះ ។ ក្នុងក្រមរដ្ឋប្បវេណី ការទទួលស្គាល់យ៉ាងចំហចំពោះគោលការណ៍នេះ គឺមានតែក្នុងបញ្ញត្តិនេះឯង ។

ម្យ៉ាងទៀត មាត្រា ១៩២ ក៏មានចែងអំពី ករណីលើកលែងផងដែរ ។ ចំពោះករណីនៃវត្ថុដែលត្រូវបានគេលួចឬវត្ថុបាត់ ការដែលចាត់ទុកថាកម្មសិទ្ធិករត្រូវបាត់បង់សិទ្ធិរបស់ខ្លួននោះ គឺមានលក្ខណៈជ្រុលពេក ។ ដូច្នេះ ជនរងគ្រោះឬម្ចាស់វត្ថុបាត់ អាចទាមទារឱ្យអ្នកកាន់កាប់សងមកវិញនូវវត្ថុដែលត្រូវគេលួច ឬវត្ថុដែលបាត់នោះ ក្នុងអំឡុងពេលពីរឆ្នាំ ក្រោយពីវត្ថុនោះត្រូវបានគេលួចឬបាត់ (មាត្រា ១៩៣)។

# ៣. កម្មសិទ្ធិ

## ៣.១. និយមន័យ និងខ្លឹមសារនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត (មាត្រា ២០៦) ។ ការប្រើប្រាស់ គឺការប្រើវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ។ ការអាស្រ័យផល មានន័យថាវត្ថុដែលផ្តល់ផ្លែផ្កាមកហើយ អាចយកផ្លែផ្កានោះធ្វើជាកម្មសិទ្ធិរបស់ខ្លួនបាន ។ ការជួលវត្ថុកម្មសិទ្ធិទៅឱ្យអ្នកដទៃហើយទទួលបានថ្លៃជួលនោះ ក៏មានន័យថាជាការអាស្រ័យផលដែរ (គេហៅថា ផលស៊ីវិល) ។ ការចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន មានពីររបៀប ។ របៀបទីមួយ គឺការចាត់ចែងតាមរបៀបរូបវិទ្យា (ការប្រើប្រាស់ ការកែច្នៃ ការបំផ្លាញ ការកំទេចចោលជាដើម) ។ របៀបទីពីរ គឺការចាត់ចែងតាមរបៀបច្បាប់ (ការផ្ទេរ ការប្រើប្រាស់និងអាស្រ័យផល ការបញ្ចាំវត្ថុ ជាដើម) ។

កម្មសិទ្ធិ គឺជាសិទ្ធិប្រត្យ័ក្សដែលពេញលេញ ហើយអាចបែងចែកមួយផ្នែកទៅឱ្យអ្នកដទៃដើម្បីប្រើប្រាស់និងអាស្រ័យផលក្នុងលក្ខណៈជាសិទ្ធិលើផ្ទៃដី និងការបញ្ចាំក្នុងលក្ខណៈជាសិទ្ធិប្រាតិភោគប្រត្យក្សបាន ។ ប៉ុន្តែនៅពេលដែលរយៈពេលបញ្ចាំបានផុតទៅ ហើយបំណុលក៏បានសងរួចនោះ កម្មសិទ្ធិអាចក្លាយទៅជាសិទ្ធិប្រត្យ័ក្សពេញលេញវិញបាន ។

កម្មសិទ្ធិដីត្រូវមានអានុភាពទាំងផ្នែកលើដី និងផ្នែកក្រោមដី នៅក្នុងទំហំនៃការកម្រិតដែលច្បាប់និងបទបញ្ញាបានកំណត់ (មាត្រា ២០៧) ។ ហេតុដូច្នេះ ពេលដែលអូសខ្សែភ្លើងលើដី ឬក៏ជីកដីធ្វើផ្លូវក្រោមដី ត្រូវសុំការយល់ព្រមពីកម្មសិទ្ធិករនៃដី ។ បើមិនដូច្នោះទេ សកម្មភាពទាំងនេះនឹងក្លាយទៅជា កម្មវត្ថុនៃការបញ្ឈប់និងបង្កាលើការរារាំងជាមិនខាន ។ ប៉ុន្តែ ផ្នែកលើ និងផ្នែកក្រោម មានការកម្រិតសមហេតុផលរបស់វា ។ ឧទាហរណ៍ ការណ៍ដែលយន្តហោះហោះលើអាកាស មិនអាចនិយាយថាជាការរំលោភកម្មសិទ្ធិលើដីបានឡើយ ។

## ៣.២. ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា

លើសពីនេះទៀត ដោយសារមានដីដែលនៅជាប់គ្នា វាមានការចាំបាច់ដែលត្រូវឱ្យមានគោលការណ៍ចំពោះដីរួមនោះ ។ ទំនាក់ទំនងនេះ គេហៅថា ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នាដែលមានចែងលំអិតចាប់ពីមាត្រា ២០៩ តទៅ ។ ឧទាហរណ៍ ករណីដែលដីបិទជិតត្រូវបានព័ទ្ធជុំវិញដោយដីអ្នកដទៃ ហើយគ្មានច្រកចេញចូលទៅផ្លូវសាធារណៈ កម្មសិទ្ធិករនៃដីបិទជិតនោះមានសិទ្ធិស្នើសុំឆ្លងកាត់ដីអ្នកជិតខាងបាន (មាត្រា ២១០ កថាខ័ណ្ឌទី ១) ។ ម៉្យាងទៀត អ្នកដែលមានកម្មសិទ្ធិលើដី មិនអាចទប់ស្កាត់មិនឱ្យទឹកដែលហូរតាមធម្មជាតិ (មិនមែនទឹកដែលអ្នកផ្សេងបង្ហូរមកនោះទេ) ពីដីជាប់គ្នានោះបានទេ (មាត្រា ២១៤) ។ ខ្ញុំសូមមិនរៀបរាប់លំអិតនៅទីនេះទេ ។

## ៣.៣. លទ្ធកម្មនៃកម្មសិទ្ធិ

### ៣.៣.១. ទ្រឹស្តីជាមូលដ្ឋាន

ជាទូទៅ លទ្ធកម្មនៃកម្មសិទ្ធិ អាចត្រូវបានធ្វើឡើងដោយកិច្ចសន្យា និងសន្តតិកម្ម ។ ក្រៅពីករណីទាំងពីរខាងលើ លទ្ធកម្មនៃកម្មសិទ្ធិ អាចត្រូវបានកើតឡើងចំពោះវត្ថុគ្មានម្ចាស់ វត្ថុបាត់

កំណប់ និងការជាប់គ្នានៃវត្ថុ ។ ករណីទាំងបីខាងមុខ គឺជាករណីលើកលែង ។ ប៉ុន្តែ ករណីនៃការជាប់គ្នានៃវត្ថុ ជាពិសេសអចលនវត្ថុ មានសារៈសំខាន់ណាស់ ។ ក្រៅពីនេះ លទ្ធកម្មនៃកម្មសិទ្ធិ អាចកើតមានឡើងដោយអាជ្ញាយុកាលបានដែរ ។ ប៉ុន្តែ កម្មសិទ្ធិមិនបាត់បង់ដោយសារអាជ្ញាយុកាលបានហួសពេលកំណត់ទេ ។ ទោះបីជាដីរបស់ខ្លួនត្រូវបានទុកចោលយូរឆ្នាំក៏ដោយ ក៏កម្មសិទ្ធិមិនត្រូវបានបាត់បង់ដោយការផុតកំណត់នៃអាជ្ញាយុកាលដែរ ។ ប៉ុន្តែប្រសិនបើមានអ្នកដ៏ទៃទៅរស់នៅលើដីនោះរយៈពេលយូរឆ្នាំ ដោយសន្តិវិធី និងដោយមានការដឹងឮជាសាធារណៈ ពេលនោះអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ អាចកើតមានឡើងបាន ។ (មាននិយាយលំអិតនៅជំពូកទី ២ វគ្គ III.៧.១) ។

### ៣.៣.២. កម្មសិទ្ធិនៃវត្ថុគ្មានម្ចាស់

ចលនវត្ថុដែលគ្មានម្ចាស់ ត្រូវជាកម្មសិទ្ធិរបស់អ្នកកាន់កាប់មុនគេ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ (មាត្រា ២៣៩ កថាខ័ណ្ឌទី ១) ។ ឧទាហរណ៍ដូចជាការចាប់បានសត្វព្រៃជាដើម ។ ម៉្យាងទៀត ចលនវត្ថុដែលកម្មសិទ្ធិករបោះបង់ចោល (ពោលគឺបានបោះចោលដោយសារមានឆន្ទៈចង់បោះបង់កម្មសិទ្ធិចោល) ក៏ជាកម្មវត្ថុនៃកម្មសិទ្ធិនៃវត្ថុគ្មានម្ចាស់ដែរ ។ ផ្ទុយទៅវិញ អចលនវត្ថុដែលគ្មានម្ចាស់ ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ (មាត្រា ២៣៩ កថាខ័ណ្ឌទី ២) ។ ឧទាហរណ៍ ជនដែលបានស្លាប់ទៅ ហើយគ្មានសាច់ញាតិ ឬអ្នកមើលខុសត្រូវ ទ្រព្យសម្បត្តិរបស់ជននោះ ត្រូវចាត់ទុកជារបស់រដ្ឋ ។

### ៣.៣.៣. កម្មសិទ្ធិលើវត្ថុបាត់

អ្នកដែលរើសវត្ថុដែលអ្នកដទៃបានបាត់ ត្រូវប្រគល់វត្ថុនោះជូនប្រធានប៉ុស្តិ៍នគរបាល ដើម្បីស្វែងរកកម្មសិទ្ធិករ (ច្បាប់ស្តីពីវត្ថុបាត់ មាត្រា ១ និងមាត្រា ១០) ។ ប៉ុន្តែ ក្រោយពេលប្រកាសជាសាធារណៈរយៈពេល ៦ ខែ នៅតែរកកម្មសិទ្ធិករមិនឃើញ អ្នកដែលរើសវត្ថុដែលអ្នកដទៃបានបាត់ អាចទទួលបានកម្មសិទ្ធិលើវត្ថុនោះ (មាត្រា ២៤០) ។

ចំណុចដែលត្រូវប្រុងប្រយ័ត្នគឺថា វត្ថុដែលអ្នកដទៃទុកចោល ឬភ្លេច ត្រូវបានចាត់ទុកជាវត្ថុបាត់ (មាត្រា ១២ នៃច្បាប់ស្តីពីវត្ថុបាត់) ។ វត្ថុបាត់ មិនមែនមានន័យថាកម្មសិទ្ធិករបោះបង់

ចោលវត្ថុនោះទេ ។ ដូច្នេះ គេមិនអាចចាត់ទុកវត្ថុនោះថាជាវត្ថុគ្មានម្ចាស់បានឡើយ ។ អាស្រ័យហេតុនេះ ទូរទស្សន៍ដែលគេបោះចោលនៅក្នុងធុងសម្រាម អាចរើសយកមកប្រើបានតាមចិត្ត ប៉ុន្តែកង់ដែលគេទុកចោល មិនអាចយកមកប្រើបានឡើយ (ច្បាប់ព្រហ្មទណ្ឌ មាត្រា ២៥៤) ។

### ៣.៣.៤. កម្មសិទ្ធិលើកំណប់

កម្មសិទ្ធិលើវត្ថុបាត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះកំណប់ (ដូច្នេះបើសិនជាមិនមានអ្នកណាអះអាងថាខ្លួនជាកម្មសិទ្ធិករ បន្ទាប់ពីមានការប្រកាសជាសាធារណៈហើយនោះ គឺត្រូវក្លាយជាវត្ថុរបស់អ្នករកឃើញ) ។ ប៉ុន្តែក្នុងករណីនៃ កំណប់ដែលមិនដឹងច្បាស់អំពីកម្មសិទ្ធិករ ត្រូវបានរកឃើញនៅក្នុងដីរបស់អ្នកដទៃជាដើម អ្នករកឃើញ និងកម្មសិទ្ធិករនៃវត្ថុនោះ ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើកំណប់នោះពាក់កណ្តាលម្នាក់ (មាត្រា ២៤១ ។ ឬមាត្រា ១៣ នៃច្បាប់ស្តីពីវត្ថុបាត់)។

### ៣.៣.៥. ឧបាគមន៍

កម្មសិទ្ធិករដែលមានវត្ថុពីរ ឬច្រើនផ្សេងគ្នា តែជាប់គ្នានិងលាយច្របល់គ្នា ដែលមិនអាចបំបែកចេញបាន វត្ថុនោះត្រូវចាត់ទុកជាវត្ថុមួយ (ចាប់ពីមាត្រា ២៤៣ តទៅ) ពីព្រោះការបំបែកវត្ថុនោះដោយបង្ខំ នឹងធ្វើឱ្យខូចប្រយោជន៍ដល់សេដ្ឋកិច្ចនិងសង្គម ។ នេះគេហៅថាជា ឧបាគមន៍ ។ ម្យ៉ាងទៀត ការប្រើប្រាស់វត្ថុធាតុដើមរបស់អ្នកដទៃ មកកែច្នៃដើម្បីបង្កើតវត្ថុផ្សេងទៀត ក៏ជាប្រភេទមួយដែលគេចាត់ទុកជាការជាប់គ្នា និងការលាយច្របល់គ្នានៃវត្ថុដែរ ។ ក្រៅពីការភ្ជាប់ ឬលាយច្របល់វត្ថុចូលជាមួយគ្នា នៅមានការកែច្នៃ ដោយធ្វើការលើវត្ថុធាតុដើមរបស់អ្នកដទៃដើម្បីផលិតចេញជាវត្ថុប្រភេទផ្សេង ។ ដោយសារគេចាត់ទុកការកែច្នៃថាដូចគ្នានឹងការជាក់គ្នា និងការលាយច្របល់គ្នាដែរ ដូច្នេះក្នុងឧបាគមន៍មានចែកចេញជា ការជាប់គ្នា ការលាយច្របល់គ្នា និងការកែច្នៃ ។ ក្នុងនោះ ការជាប់គ្នានូវអចលនវត្ថុ អាចបង្កើតនូវបញ្ហាច្រើនជាងគេ ។

ការជាប់គ្នានិងការលាយច្របល់គ្នានៃចលនវត្ថុ មានចែងក្នុងមាត្រា ២៤៣ ថាក្នុងករណីដែលចលនវត្ថុជាច្រើនបានជាប់គ្នា ហើយមិនអាចបំបែកចេញបានដោយមិនបំផ្លាញចោលទេនោះ កម្មសិទ្ធិនៃវត្ថុជាប់គ្នានេះ ត្រូវធ្លាក់ទៅលើកម្មសិទ្ធិករនៃចលនវត្ថុដែលជាចំណែកចម្បង ។

(បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលត្រូវចំណាយសោហ៊ុយហួសហេតុ សម្រាប់ការបំបែក ។ ពោលគឺថា កម្មសិទ្ធិករនៃចលនវត្ថុបន្ទាប់បន្សំ មិនអាចទាមទារមកវិញនូវវត្ថុដែលលាយចូលគ្នាហើយនោះទេ ។ បើសិនជាកម្មសិទ្ធិករនៃចលនវត្ថុជាចំណែកចម្បងនោះទទួលបានសេចក្តីចំរើនដោយឥតហេតុ ពីការជាប់គ្នានិងការលាយច្របល់គ្នានៃចលនវត្ថុនោះ កម្មសិទ្ធិករនៃចលនវត្ថុបន្ទាប់បន្សំ អាចធ្វើការប្តឹងអំពីសេចក្តីចំរើនដោយឥតហេតុនោះបានតាមមាត្រា ២៤៨ ។ នៅពេលដែលមិនអាចកំណត់អំពីចំណែកចម្បង ឬចំណែកបន្ទាប់បន្សំ ចំពោះចលនវត្ថុដែលជាប់គ្នា កម្មសិទ្ធិករនៃវត្ថុនីមួយៗត្រូវមានសហកម្មសិទ្ធិលើវត្ថុនោះ តាមសមាមាត្រនៃតម្លៃវត្ថុនីមួយៗដែលមាននៅពេលវត្ថុចាប់ផ្តើមជាប់ជាមួយគ្នា ។ បញ្ញត្តិស្តីពីការជាប់គ្នានៃចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលចលនវត្ថុជាច្រើនត្រូវបានលាយច្របល់គ្នា ហើយមិនអាចបំបែកចេញបាន ។ ឧទាហរណ៍ ការលាយច្របល់ប្រេងជាដើម ។

មាត្រា ២៤៦ កថាខ័ណ្ឌទី ១ ចែងថា ទោះមានបុគ្គលណាម្នាក់បានផលិតចលនវត្ថុមួយថ្មីដោយយកវត្ថុធាតុដើមរបស់អ្នកដទៃមកកែច្នៃ ឬកែប្រែដ៏ដោយ កម្មសិទ្ធិលើផលិតផលនោះត្រូវជារបស់ម្ចាស់នៃវត្ថុធាតុដើម ។ ប៉ុន្តែ ប្រសិនបើតម្លៃបានកើនឡើងដោយការកែច្នៃ ឬកែប្រែនោះមានច្រើនលើសលប់ហួសឆ្ងាយពីតម្លៃវត្ថុធាតុដើមនោះ អ្នកកែឆ្នៃត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុកែច្នៃ (ក្នុងករណីនេះ ម្ចាស់នៃវត្ថុធាតុដើមដែលត្រូវបាត់បង់កម្មសិទ្ធិ អាចទាមទារសំណងបានដោយផ្អែកលើមាត្រា ២៤៨) ។

## ៣.៣.៦. ការជាប់គ្នានៃអចលនវត្ថុ

មាត្រា ២៤២ ចែងថា កម្មសិទ្ធិករនៃអចលនវត្ថុ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើ "វត្ថុដែលបានក្លាយជាផ្នែកមួយនៃអចលនវត្ថុ ដោយការជាប់ជាមួយនឹងអចលនវត្ថុនោះ" កម្មសិទ្ធិលើអចលនវត្ថុនោះ ។ ប៉ុន្តែបដិញ្ញានៃមាត្រាដដែលកំណត់ថា "ប៉ុន្តែ មិនត្រូវរារាំងដល់សិទ្ធិរបស់បុគ្គលណាផ្សេងទៀត ដែលជាអ្នកភ្ជាប់វត្ថុនោះដោយប្រើប្រភពសិទ្ធិត្រឹមត្រូវរបស់ខ្លួនគេ" ។ ពោលគឺថាក្នុងករណីដែលអ្នកដទៃមកដាំដើមឈើលើដីរបស់ម្ចាស់ដី កម្មសិទ្ធិនៃដើមឈើនោះគឺជាកម្មសិទ្ធិរបស់ម្ចាស់ដី ។ ប៉ុន្តែប្រសិនបើអ្នកដាំដើមឈើ គឺជាអ្នកដែលមានសិទ្ធិជួលដីនោះត្រឹមត្រូវ (ដោយ

ហេតុថាអ្នកជួលមានប្រភពសិទ្ធិសំរាប់ប្រើប្រាស់ដីបានដោយសេរី) អ្នកដាំដើមឈើត្រូវជាកម្មសិទ្ធិករនៃ ដើមឈើ ។

ប៉ុន្តែសូមប្រយ័ត្នថា នៅប្រទេសជប៉ុន ដី និងអាគារនៅលើដីនោះ ជាអចលនវត្ថុពីរផ្សេងគ្នា ។ ដូចនេះ មាត្រា ២៤២ មិនអាចយកមកអនុវត្តក្នុងទំនាក់ទំនងរវាងដីនិងអាគារនោះទេ ។ ឧទាហរណ៍ផ្សេងទៀតនៃមាត្រា ២៤២ គឺមានករណីនៃវត្ថុដែលគេយកមកបិតភ្ជាប់ទៅនឹងអាគារ ហើយដែលមិនអាចដកចេញពីអាគារបាន ឬការចាក់ខ្សាច់ទៅលើដីនៅមាត់សមុទ្រជាដើម ។ ប៉ុន្តែបញ្ហាពិបាក នឹងកើតឡើងបាននៅក្នុងករណីដែលគេធ្វើការជួសជុលកែលំអអាគារឡើងវិញ ។ ក្នុងការដាក់បង្អួចទៅនឹងអាគារ នេះគឺជាការយកចលនវត្ថុដែលជាវត្ថុធាតុសំរាប់បង្អួចនោះ មកដាក់ភ្ជាប់ទៅនឹងអាគារ ដូច្នេះមិនមានអ្វីពិបាកយល់ទេ ។ ប៉ុន្តែបើសិនជាការសង់ផ្នែកបន្ថែមទៅនឹងអាគារនោះ បានប្រើប្រាស់មួយផ្នែកនៃជញ្ជាំងរបស់អាគារ ហើយបន្ថែមសំណង់មួយផ្នែកនៅជាប់នឹងជញ្ជាំងនោះ គេចោទសួរថាតើករណីនេះគឺជាការភ្ជាប់អាគារមួយ (អចលនវត្ថុ) ទៅនឹងអាគារមួយទៀត (អចលនវត្ថុ) មែនដែរឬទេ ។ នៅមានគំនិតយល់ខុសៗគ្នាចំពោះសំនួរនេះ។

## ៣.៤. កម្មសិទ្ធិអវិភាគ

កន្លងមក យើងបាននិយាយថា នៅលើវត្ថុមួយមានសិទ្ធិប្រត្យ័ក្សដូចគ្នាតែមួយប៉ុណ្ណោះ (គោលការណ៍វត្ថុមួយសិទ្ធិមួយ) ។ ឧទាហរណ៍ ដី "ក" ជាកម្មសិទ្ធិរបស់បុគ្គល A ដូច្នេះបុគ្គល A អាចបង្កើតសិទ្ធិលើផ្ទៃដី និងហ៊ីប៉ូតេកជាមួយបុគ្គល B បាន ។ ប៉ុន្តែ មិនអាចមានបុគ្គល C ផ្សេងពីបុគ្គល A មកប្រកាសកម្មសិទ្ធិលើដីនោះបានឡើយ ។ ប៉ុន្តែបុគ្គល A អាចមានកម្មសិទ្ធិរួមជាមួយបុគ្គលផ្សេងទៀតលើដី "ក" នោះបាន ។ នេះគេហៅថា កម្មសិទ្ធិអវិភាគ ។ មាត្រា ២៤៩ ចែងថា ម្ចាស់កម្មសិទ្ធិអវិភាគ អាចប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគបាន ទៅតាមសមាមាត្រនៃចំណែករបស់ខ្លួនក្នុងកម្មសិទ្ធិទាំងមូល (មាត្រា ២៤៩) ។ ភាគចំណែក អាចត្រូវបានកំណត់ទៅតាមការសម្រេចចិត្តរបស់ម្ចាស់កម្មសិទ្ធិអវិភាគនិមួយៗបាន ។ ប្រសិនបើពុំមានការកំណត់បែងចែកដូចនោះទេ គេត្រូវសន្មត់ថាម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗទទួលបានភាគចំណែកស្មើៗគ្នា (មាត្រា ២៥០) ។ នៅពេលចុះបញ្ជីកម្មសិទ្ធិអវិភាគទាក់ទងនឹងអចលនវត្ថុ គេចាំបាច់ត្រូវកត់ត្រាអំពីភាគចំណែកដែលម្ចាស់កម្មសិទ្ធិអវិភាគនិមួយៗមាន (មាត្រា ៣៩ នៃច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ) ។ ទោះជាយ៉ាង

ណាក៏ដោយ ម្ចាស់កម្មសិទ្ធិម្នាក់ៗ អាចប្រើប្រាស់ភាគទាំងមូលនៃវត្ថុកម្មសិទ្ធអវិភាគបាន ។ ពោលគឺមិនមែនមានន័យថា ដោយសារមានកម្មសិទ្ធិតែមួយភាគដប់នៃកម្មសិទ្ធិអវិភាគ គឺខ្លួនអាចប្រើប្រាស់បានតែមួយភាគដប់នៃវត្ថុកម្មសិទ្ធិអវិភាគនោះទេ ។ ប៉ុន្តែប្រសិនបើមានការព្រមព្រៀងគ្នារវាងម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗ អំពីការប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគនោះ ការប្រើប្រាស់វត្ថុត្រូវស្របទៅតាមការព្រមព្រៀងនេះ ។

ម៉្យាងទៀត ម្ចាស់កម្មសិទ្ធិម្នាក់ៗ អាចទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគបានគ្រប់ពេល ។ ប៉ុន្តែមាត្រា ២៥៦ កថាខ័ណ្ឌទី ១ ចែងថា មិនអាចហាមបានទេចំពោះការចុះកិច្ចសន្យាមិនទាមទារការចែកចំណែកក្នុងអំឡុងពេលមិនលើសពីប្រាំឆ្នាំបានទេ ។

ក្រៅពីនេះ អ្នកសិក្សាស្រាវជ្រាវ បានបង្កើតទ្រស្តីពីរទៀតដែលទាក់ទងទៅនឹងកម្មសិទ្ធិអវិភាគដែរ គឺមាន របស់សមូហភាព និងរបស់សាធារណៈ ។ វត្ថុរបស់សមូហភាព មានន័យទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន (សូមអានជំពូកទ ៤ វគ្គ III.៩) ។ ដោយសារវត្ថុរបស់សមូហភាព មានគោលបំណងជាក់លាក់ ដែលត្រូវបានកំណត់ដោយក្រុមហ៊ុន ដូចនេះការចាត់ចែងវត្ថុរបស់សមូហភាពត្រូវបានកម្រិត ហើយការទាមទារបែងចែកវត្ថុសមូហភាពក៏ត្រូវបានហាមឃាត់ដែរ (មាត្រា ៧៦៧) ។ ត្រង់នេះហើយដែលខុសពីកម្មសិទ្ធិអវិភាគ ។ ម៉្យាងទៀត វត្ថុរបស់សាធារណៈ សំដៅទៅលើសិទ្ធិប្រើប្រាស់សម្បត្តិសាធារណៈ ដូចជាព្រៃឈើ ភ្នំ វាលស្រែសាធារណៈរួមជាមួយអ្នកភូមិជាមួយគ្នាផ្សេងទៀត ។ ដូចនេះ បុគ្គលម្នាក់ៗ មិនអាចមានភាគចំណែកទៅលើរបស់សាធារណៈបានទេ ។

## ៣.៥. កម្មសិទ្ធិអវិភាគក្នុងអាគារតែមួយ

ចំពោះសំណង់អាគារដែលមានបន្ទប់ជាផ្ទះល្វែងច្រើន បន្ទប់នីមួយៗនៃអាគារតែមួយមានកម្មសិទ្ធិជាច្រើនដាច់ៗពីគ្នា ។ នេះគេហៅថា សិទ្ធិលើកម្មសិទ្ធិអវិភាគក្នុងអាគារតែមួយ ដែលគ្រប់គ្រងដោយ "ច្បាប់ស្តីពីកម្មសិទ្ធីអវិភាគក្នុងអាគារតែមួយ" (ហៅកាត់ថា ច្បាប់ស្តីពីកម្មសិទ្ធិអវិភាគលើអាគារ អនុម័តិនៅឆ្នាំ ១៩៦២ ហើយបានធ្វើវិសោធនកម្មនៅឆ្នាំ ១៩៨៣) ។

ច្បាប់ស្តីពីកម្មសិទ្ធិអវិភាគលើអាគារនេះ បែងចែងផ្នែកក្នុងរបស់អាគារជាពីរប្រភេទ គឺផ្នែកផ្តាច់មុខ (បន្ទប់ដាច់ដោយឡែកដែលជាកម្មវត្ថុនៃកម្មសិទ្ធិឯករាជនីមួយៗ) និងផ្នែករួម ដែលម្ចាស់

កម្មសិទ្ធិអវិភាគក្នុងអាគារ អាចមានសិទ្ធិប្រើរួមគ្នាបាន ។ ថែមពីលើនោះ គឺសិទ្ធិប្រើប្រាស់ដីដែលជាទីតាំងនៃសំណង់អាគារដែលជាកម្មវត្ថុនៃកម្មសិទ្ធិអវិភាគនេះ (ភាគច្រើនត្រូវបានកំណត់ជាកម្មសិទ្ធិ ប៉ុន្តែក៏មានករណីខ្លះវាជាសិទ្ធិលើផ្ទៃដី ឬសិទ្ធិជួលដែរ ។ សិទ្ធិប្រើប្រាស់ដីនេះត្រូវជាសិទ្ធិអវិភាគ ឬសិទ្ធិប្រហាក់ប្រហែលនឹងសិទ្ធិអវិភាគ រវាងម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗក្នុងអាគារសមស្របទៅនឹងចំណែកដែលម្ចាស់កម្មសិទ្ធិនីមួយៗមានជាកម្មសិទ្ធិផ្តាច់មុខរបស់ខ្លួន) ។ សិទ្ធិប្រើប្រាស់នេះត្រូវចាត់ទុកជាចំណែកមួយក្នុងផ្នែកផ្តាច់មុខ ។ (ម្ចាស់កម្មសិទ្ធិអវិភាគក្នុងអាគារមិនអាចចាត់ចែងសិទ្ធិប្រើប្រាស់ដីនេះ ដោយផ្តាច់ចេញពីសិទ្ធិដែលមានទៅលើផ្នែកផ្តាច់មុខបានឡើយ) ។ ម្យ៉ាងទៀត ដើម្បីធានាស្វ័យភាពរបស់ម្ចាស់កម្មសិទ្ធិអវិភាគក្នុងអាគារ គេបានបង្កើតឱ្យមានក្រុមចាត់ចែងការងារនៅតាមអាគារ ហើយមានចែងជាបញ្ញត្តិទាក់ទងនឹងបទបញ្ជាផ្ទៃក្នុងនិងវិធីធ្វើសេចក្តីសំរេចនៅអង្គប្រជុំ ដើម្បីសំរួលដល់ប្រតិបត្តិការរបស់ក្រុមចាត់ចែងការងារ ដោយផ្អែកលើឆន្ទៈរួមរបស់ម្ចាស់កម្មសិទ្ធិអវិភាគក្នុងអាគារ ដែលជាសមាជិករបស់ក្រុមចាត់ចែងការងារនោះ ។

## ៤. សិទ្ធិប្រត្យ័ក្សប្រើប្រាស់និងអាស្រ័យផល ក្រៅពីកម្មសិទ្ធិ

### ៤.១. សិទ្ធិលើផ្ទៃដី

សិទ្ធិលើផ្ទៃដី គឺជាសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ ដើម្បីទទួលបានកម្មសិទ្ធិលើអាគារ និងដើមឈើនៅលើដីនោះ (មាត្រា ២៦៥) ។ ដោយហេតុថាចំណុចសំខាន់បំផុតនៃសិទ្ធិលើផ្ទៃដីគឺសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ ដូច្នេះសិទ្ធិនេះមិនមែនទាក់ទងតែជាមួយនឹងអាគារឬដើមឈើទេ ។ មិនចាំបាច់ថាវត្ថុទាំងអស់នេះត្រូវឋិតនៅលើផ្ទៃដីនោះទេ ។ ជាទូទៅ កម្មសិទ្ធិករនៃដី និងកម្មសិទ្ធិករនៃអាគារ ត្រូវចុះកិច្ចសន្យាដើម្បីធ្វើឱ្យសិទ្ធិលើផ្ទៃដីកើតឡើង ប៉ុន្តែក៏អាចកើតមានសិទ្ធិលើផ្ទៃដីក្នុងករណីសន្តតិកម្ម និងអាជ្ញាយុកាលនៃលទ្ធកម្មផងដែរ ។

សិទ្ធិលើផ្ទៃដី មានលក្ខណៈស្រដៀងគ្នាទៅនឹងសិទ្ធិជួលដែរ (យោងតាមច្បាប់ស្តីពីការជួលដីនិងអាគារ ការបូកបញ្ចូលគ្នានូវសិទ្ធិលើផ្ទៃដីដែលមានអាគារជាកម្មវត្ថុ និងសិទ្ធិជួលដី ត្រូវហៅរួមគ្នាថាជាសិទ្ធិជួលដី) ។ សិទ្ធិលើផ្ទៃដីខុសពីសិទ្ធិជួលដីត្រង់ថា សិទ្ធិលើផ្ទៃដីជាសិទ្ធិប្រត្យក្ស ដូច្នេះវាជាសិទ្ធិប្រើប្រាស់ដោយផ្ទាល់លើដីដែលជាកម្មវត្ថុនោះ ។ ចំណែកឯសិទ្ធិជួលដី ជាសិទ្ធិលើបំណុល

ដូច្នេះគឺជាសិទ្ធិសំរាប់ទាមទារការប្រើប្រាស់ដី ។ ហេតុដូច្នេះ គេទទួលស្គាល់នូវលក្ខណៈអាចធ្វើអនុប្បទានបាន និងអាចធ្វើសន្តតិកម្មបាន នូវសិទ្ធិលើផ្ទៃដី (ម្ចាស់សិទ្ធិលើផ្ទៃដី អាចធ្វើអនុប្បទានសិទ្ធិនោះឱ្យទៅអ្នកដទៃបាន) ។ ផ្ទុយទៅវិញ ក្នុងសិទ្ធិជួលដី គឺមានការរឹតត្បិតចំពោះលទ្ធភាពសំរាប់ធ្វើអនុប្បទាន (មាត្រា ៦១២) ។ម្យ៉ាងទៀត គេទទួលស្គាល់ថាម្ចាស់សិទ្ធិលើផ្ទៃដីមានសិទ្ធិទាមទារអាចគេចុះបញ្ជីសិទ្ធិនេះបាន (អាចទាមទារកម្មសិទ្ធិករឱ្យទៅចុះបញ្ជីអំពីសិទ្ធិលើផ្ទៃដីនេះបាន) ប៉ុន្តែសិទ្ធិករជួលពុំអាចទាមទារឱ្យគេចុះបញ្ជីបានទេ បើពុំមានការយល់ព្រមពីកម្មសិទ្ធិករអំពីរឿងនេះទុកជាមុន ។ ក្រៅពីនេះ បើយើងមើលទៅលើរយៈពេលស្នាក់នៅ ក៏ឃើញថា សិទ្ធិលើផ្ទៃដីគឺជាសិទ្ធិដែលមានប្រៀបខ្លាំងជាងសិទ្ធិជួលនោះដែរ ។

## ៤.២. សិទ្ធិបង្កបង្កើនផលជាអចិន្ត្រៃយ៍

សិទ្ធិបង្កបង្កើនផលជាអចិន្ត្រៃយ៍ គឺជាសិទ្ធិប្រត្យក្សសំរាប់ប្រើប្រាស់ដីរបស់អ្នកដទៃ ដើម្បីធ្វើស្រែចំការនិងចិញ្ចឹមសត្វ ។ សិទ្ធិនេះមានលក្ខណៈស្រដៀងទៅនឹងសិទ្ធិលើផ្ទៃដីដែរ ប៉ុន្តែខុសគ្នានៅត្រង់ការដែលត្រូវបង់ថ្លៃបង្កបង្កើនផល (មាត្រា ២៧០) ។ គេយល់ថាសិទ្ធិនេះ ត្រូវបានប្រើប្រាស់ច្រើនកាលពីសម័យមីជីក្នុងប្រទេសជប៉ុន ប៉ុន្តែគេមិនសូវឃើញមានការប្រើប្រាស់ច្រើននៅសម័យបច្ចុប្បន្ននេះទេ (មានតែក្នុងទំនាក់ទំនងនៃការជួលប៉ុណ្ណោះ) ។

## ៤.៣. សេវភាព

សេវភាព សំដៅទៅលើសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ ដើម្បីជាប្រយោជន៍ដល់ដីរបស់ខ្លួន (មាត្រា ២៨០) ។ ដីរបស់អ្នកដទៃដែលផ្តល់ផលប្រយោជន៍ ហៅថា "ដីបម្រើ" ចំណែកឯដីដែលទទួលប្រយោជន៍ ហៅថា "ដីប្រើ" ។ ឧទាហរណ៍ ការដើរឆ្លងកាត់ដីរបស់អ្នកដទៃដើម្បីចូលមកដល់ដីរបស់ខ្លួន ឬការប្រើដីអ្នកដទៃដើម្បីបូមយកទឹកមកប្រើជាដើម ។ តើសេវភាពខុសពីទំនាក់ទំនងដីដែលនៅជាប់គ្នាយ៉ាងដូចម្តេច ? វាខុសគ្នាត្រង់ថា ក្នុងទំនាក់ទំនងដីដែលនៅជាប់គ្នា ច្បាប់បានកំណត់នូវការរឹតត្បិតត្រឹមតែជាអប្បបរិមាប៉ុណ្ណោះ ក្នុងការអនុវត្តកម្មសិទ្ធិរបស់អ្នកជិតខាងគ្នារៀង១ខ្លួន ។ ប៉ុន្តែក្នុងករណីដែលការរឹតត្បិតនេះមិនគ្រប់គ្រាន់ គេត្រូវធ្វើកិច្ចសន្យា

បង្កើតសេវភាព ។ ម្យ៉ាងទៀត គេអាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលបាន បើសិនជាគេពិតមែនតែបានអនុវត្តសេវភាពជាប់ៗគ្នាមក (មាត្រា ២៨៣) ប៉ុន្តែប្រសិនបើសេវភាពត្រូវបានបង្កើតហើយតែមិនបានអនុវត្តទេនោះ វាក៏ត្រូវរលត់ដោយអាជ្ញាយុកាលដែរ (មាត្រា ២៩១) ។

### ៤.៤. សិទ្ធិប្រើប្រាស់សម្បត្តិសាធារណៈ

សិទ្ធិប្រើប្រាស់សម្បត្តិសាធារណៈ សំដៅទៅលើសិទ្ធិប្រត្យ័ក្សតាមច្បាប់ប្រពៃណី ក្នុងការប្រើប្រាស់ព្រៃឈើ ភ្នំ វាលស្រែ ដែលជារបស់អ្នករស់នៅក្នុងភូមិជាមួយគ្នា ។ ដោយសារក្រមរដ្ឋប្បវេណីជប៉ុន ទទួលស្គាល់ថាមានសិទ្ធិប្រើប្រាស់សម្បត្តិសាធារណៈដែលមានលក្ខណៈជាកម្មសិទ្ធិអវិភាគ និងមានសិទ្ធិប្រើប្រាស់សម្បត្តិសាធារណៈដែលមិនមានលក្ខណៈជាកម្មសិទ្ធិអវិភាគនោះ ដូច្នេះខ្លឹមសារនៃសិទ្ធិនេះត្រូវបានទុកឱ្យធ្វើការបកស្រាយទៅតាមទំលាប់ ។

## ៥. សិទ្ធិកាន់កាប់

### ៥.១. ទ្រឹស្តីជាមូលដ្ឋាន

ជាការរំលឹកឡើងវិញទេ ទោះបីថាសិទ្ធិកាន់កាប់ជាសិទ្ធិប្រត្យ័ក្សក៏ដោយ ក៏វាខុសគ្នាទាំងស្រុងនឹងសិទ្ធិប្រត្យ័ក្សដទៃផ្សេងទៀត (កម្មសិទ្ធិនិងសិទ្ធិប្រត្យក្សមានកម្រិត ដែលជាប្រភេទសិទ្ធិបំបែកចេញពីកម្មសិទ្ធិ) ។ ការរៀបចំជាកម្រងបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី ធ្វើយើងមើលឃើញថាក្រមនេះ រៀងដូចជាមានចែងអំពី"សិទ្ធិកាន់កាប់"យ៉ាងដូច្នោះ ប៉ុន្តែតាមការពិតអ្វីដែលជាកម្មវត្ថុនៃកិច្ចការពារដោយច្បាប់នោះ គឺជាស្ថានភាពនៃព្រឹត្តការណ៍ជាក់ស្តែងមួយដែលគេហៅថាជា "ការកាន់កាប់"នោះ ។ ពោលគឺ ច្បាប់ការពារនូវស្ថានភាពនៃការគ្រប់គ្រងលើវត្ថុ តាមរូបភាពមួយជាក់លាក់ ដោយចាត់ទុកការគ្រប់គ្រងនោះថាជាការកាន់កាប់ ។ ក្នុងករណីនេះ គេមិនគិតថាតើអ្នកដែលកំពុងគ្រប់គ្រងវត្ថុ ពិតជាមានសិទ្ធិសំរាប់ធ្វើការគ្រប់គ្រង (ហៅថា សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត) មែនឬមិនមែននោះទេ ។ (ហេតុដូច្នេះ មានករណីនៃការប្តឹងប្តល់ខ្លះ ភាគីដែលឈ្នះបានកិច្ចការពារនៅដំណាក់កាលដំបូង ដោយសារការអះអាងអំពីការកាន់កាប់ជាក់ស្តែងនោះបែរជាអាចចាញ់ទៅវិញនៅពេលដែលប្តឹងប្តល់អំពីបញ្ហានៃសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត) ។

## ៥.២. ការកើតមានការកាន់កាប់

ដែលហៅថាជាការកាន់កាប់ គឺជាការ "ក្ដាប់ទុកនូវវត្ថុអ្វីមួយដោយមានឆន្ទៈទុកសំរាប់ខ្លួនឯង" (មាត្រា ១៨០) ។ តាមនិយមន័យនេះ គឺថាចាំបាច់ត្រូវមានការក្ដាប់ទុកដែលជាការគ្រប់គ្រងលើរូបវត្ថុ និងឆន្ទៈទុកសំរាប់ខ្លួនឯង ។ ប៉ុន្តែចំពោះឆន្ទៈទុកសំរាប់ខ្លួនឯងនេះ សព្វថ្ងៃនេះត្រូវបានយល់ក្នុងធូទំលំទំលាយ ។ យើងអាចគិតថា វាមានន័យត្រឹមការទទួលស្គាល់ថា ឱ្យតែពេលដែលបុគ្គលណាម្នាក់ក្ដាប់ទុកវត្ថុ ដោយឈរលើជំហថាខ្លួនត្រូវទទួលបានផលប្រយោជន៍ពិតជាក់ស្ដែង ទោះដោយចំពោះ ឬដោយប្រយោលក្ដី គឺបុគ្គលនោះមានឆន្ទៈចង់ក្ដាប់ទុកវត្ថុសំរាប់ខ្លួនគេជាដរាបមែន ។ ចំពោះការក្ដាប់ទុកទៀតសោត មិនចាំបាច់មានន័យថាក្ដាប់វត្ថុតាមន័យរូបវិទ្យាក៏បានដែរ គឺថាប្រសិនបើវាស្ថិតនៅក្នុងស្ថានភាពមួយ ដែលទស្សនៈទូទៅក្នុងសង្គមអាចនឹងចាត់ទុកថាបុគ្គលនោះកំពុងគ្រប់គ្រងលើវត្ថុនោះមែន គឺវាជាការគ្រប់គ្រាន់ (ឧទាហរណ៍ ពេលធ្វើដំណើរទៅក្រៅដោយទុកវត្ថុនៅផ្ទះជាដើម នេះក៏អះអាងបានថាជាការក្ដាប់ទុកដែរ) ។ ហើយដូចនឹងមានការរៀបរាប់នៅខាងក្រោយ ការក្ដាប់ទុក អាចផ្ទេរទៅឱ្យអ្នកតំណាង ឬអ្នកជំនួយបាន ។ ប៉ុន្តែបើសិនជាត្រូវបាត់បង់ការក្ដាប់ទុកនូវវត្ថុកាន់កាប់ក្នុងន័យនេះ គឺសិទ្ធិកាន់កាប់ត្រូវរលត់ (មាត្រា ២០៣) ។

## ៥.៣. រូបភាពនៃការកាន់កាប់

### ៥.៣.១. ការកាន់កាប់ដោយខ្លួនឯង និងការកាន់កាប់ដោយតំណាង

អ្នកកាន់កាប់ដែលក្ដាប់ទុកវត្ថុដោយខ្លួនឯង ហៅថា អ្នកកាន់កាប់ដោយខ្លួនឯង ។ ចំណែកអ្នកកាន់កាប់ដែលឱ្យអ្នកតំណាងក្ដាប់ទុកវត្ថុ ហៅថា អ្នកកាន់កាប់ដោយតំណាង (មាត្រា ១៨១) ។ ឧទាហរណ៍ ការជួលផ្ទះ គឺអ្នកជួលផ្ទះជាអ្នកកាន់កាប់ដោយខ្លួនឯង ។ ចំណែក ឯម្ចាស់ផ្ទះជាអ្នកកាន់កាប់ដោយប្រយោល ។ ប៉ុន្តែ អ្នកកាន់កាប់ដោយតំណាងក្នុងករណីនេះ មានប្រើពាក្យក្នុងក្រមរដ្ឋប្បវេណីថាជា "អ្នកតំណាង" ក៏ដោយ ក៏វាមានលក្ខណៈខុសគ្នាទៅនឹងអ្នកតំណាងអាស្រ័យការបញ្ជាញឆន្ទៈ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីមាត្រា ៩៩ ។ អ្នកតំណាងក្នុងករណី

នេះ គ្រាន់តែសំដៅលើបុគ្គលដែលមានទំនាក់ទំនងបែបណាមួយជាមួយម្ចាស់កាន់កាប់ដើម តាមរយៈនៃទំនាក់ទំនងក្នុងអង្គហេតុពាក់ព័ន្ធនឹងការគ្រប់គ្រងវត្ថុតែប៉ុណ្ណោះ ។ ឱ្យតែបុគ្គលនោះធ្វើការកាន់កាប់ក្នុងឆន្ទៈដើម្បីម្ចាស់កាន់កាប់ដើមមែន ។ ចំណែកអ្នកជួយធ្វើការផ្ទះ និងបុគ្គលិកបំរើការនៅភោជនីយដ្ឋាន ជាអ្នកជួយម្ចាស់ផ្ទះនិងម្ចាស់ហាងក្នុងការកាន់កាប់ ប៉ុន្តែមិនអាចក្លាយជាអ្នកដែលធ្វើការកាន់កាប់ដោយតំណាងបានទេ ។

### ៥.៣.២. ការកាន់កាប់វត្ថុរបស់ខ្លួន និងការកាន់កាប់វត្ថុរបស់អ្នកដទៃ

អ្នកកាន់កាប់ មានពីរប្រភេទ គឺអ្នកកាន់កាប់វត្ថុរបស់ខ្លួនដោយមាន"ឆន្ទៈកាន់កាប់"វត្ថុនោះ និងអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ (មាត្រា ១៨៥) ។ ការបែងចែកនេះ គឺធ្វើឡើងដោយយោងទៅលើការសិក្សាកន្លងមក អំពីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ (មាត្រា ១៦២) និងការកាន់កាប់វត្ថុគ្មានម្ចាស់ (មាត្រា ២៣៩) ។

អ្នកទិញវត្ថុ គឺជាអ្នកកាន់កាប់ខ្លួនឯង ចំណែកឯអ្នកជួល គឺជាអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ ។ ប៉ុន្តែបើអ្នកជួលទិញយកវត្ថុដែលជួលនោះ នឹងនាំឱ្យកើតមានការកាន់កាប់ដោយសារប្រភពសិទ្ធិថ្មី គឺអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ ក្លាយជាអ្នកកាន់កាប់វត្ថុរបស់ខ្លួន (មាត្រា ១៨៥) ។ ក្នុងយុត្តិសាស្ត្រតុលាការថ្មីៗនេះ គេចាត់ទុកថាសន្តតិកម្ម ក៏អាចក្លាយទៅជាប្រភពសិទ្ធិថ្មីដែរ ។

## ៥.៤. លទ្ធកម្មនៃសិទ្ធិកាន់កាប់

លទ្ធកម្មនៃការកាន់កាប់ មានពីរយ៉ាង គឺទីមួយ លទ្ធកម្មពីដំបូង និងទីពីរ លទ្ធកម្មដោយបន្តពីអ្នកដទៃ ។ ក្នុងករណីទីមួយសំដៅទៅលើការរើសបានវត្ថុបាត់ ចំណែកឯករណីទីពីរសំដៅទៅលើកិច្ចសន្យាលក់ ពោលគឺការផ្ទេរសិទ្ធិកាន់កាប់ពីអ្នកលក់ទៅអ្នកទិញ ដោយរក្សាទុកឱ្យការកាន់កាប់នោះនៅមានលក្ខណៈដើមដដែល ។ ករណីទីពីរនេះមានសារៈសំខាន់ណាស់ ។ លទ្ធកម្មដោយបន្តពីអ្នកដទៃ ក៏រួមបញ្ចូលទាំងករណីសន្តតិកម្មផងដែរ ។

អ្នកធ្វើលទ្ធកម្មដោយបន្តការកាន់កាប់ពីអ្នកដទៃ អាចធ្វើការអះអាងអំពីការកាន់កាប់របស់អ្នកមុនបាន និងអះអាងអំពីការកាន់កាប់របស់ខ្លួនដែលទើបកើតថ្មីនោះក៏បានដែរ (មាត្រា ១៨៧

កថាខ័ណ្ឌទី ១) ។ ប៉ុន្តែការអះអាងអំពីការកាន់កាប់របស់អ្នកមុន ត្រូវនាំមកនូវវិការៈទាំងអស់ក្នុងកាន់កាប់របស់អ្នកមុនផងដែរ (មាត្រា ១៨៧ កថាខ័ណ្ឌ ទី ២) ។

## ៥.៥. ប្រសិទ្ធភាពនៃការកាន់កាប់

### ៥.៥.១. សិទ្ធិទាមទារឱ្យការពារការកាន់កាប់

នៅពេលដែលទទួលការរារាំងពីអ្នកដទៃ មកលើការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់អាចទាមទារឱ្យមានការបញ្ឈប់និងបង្ការការរារាំង ដោយប្តឹងទាមទារឱ្យការពារការកាន់កាប់របស់ខ្លួនបាន ដោយមិនចាំបាច់គិតថាតើការកាន់កាប់នោះផ្អែកលើមូលដ្ឋាននៃសិទ្ធិត្រឹមត្រូវ ឬមិនត្រឹមត្រូវទេនោះ (ចាប់ពីមាត្រា ១៩៧ តទៅ) ។ ការទាមទារអាចមានជាបីករណី ពោលគឺ ការទាមទារឱ្យទុកការកាន់កាប់នៅដដែល ការទាមទារឱ្យរក្សាការពារការកាន់កាប់ និងការទាមទារឱ្យស្តារការកាន់កាប់មកវិញ ។

ដោយហេតុថា សិទ្ធិទាមទារឱ្យការពារការកាន់កាប់ គឺជាសិទ្ធិសំរាប់បញ្ឈប់និងបង្ការាល់ការរារាំងចំពោះការគ្រប់គ្រងលើវត្ថុរបស់ខ្លួន ដូច្នេះវាមិនមានទំនាក់ទំនងអ្វីទាល់តែសោះជាមួយនឹងការប្តឹងប្តល់ទាក់ទងនឹងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត (ដូចជាការទាមទារការបញ្ឈប់និងបង្ការលើការរារាំង ដោយឈរលើមូលដ្ឋាននៃកម្មសិទ្ធិជាដើម) នោះទេ (មាត្រា ២០២ កថាខ័ណ្ឌទី ១) ។ អាស្រ័យហេតុនេះ បុគ្គលដដែលអាចប្តឹងទាមទារឱ្យការពារការកាន់កាប់ផង និងការពារកម្មសិទ្ធិផងបានក្នុងពេលតែមួយ ។

### ៥.៥.២.ការសន្មត់នៃសិទ្ធិ

អ្នកកាន់កាប់ ត្រូវបានសន្មត់ថាមានប្រភពសិទ្ធិត្រឹមត្រូវស្របច្បាប់ ក្នុងការកាន់កាប់វត្ថុនោះ (មាត្រា ១៨៨) ។ ប្រសិនបើអ្នកដែលអះអាងថាខ្លួនជាកម្មសិទ្ធិករ ហើយអាចបង្ហាញថាខ្លួនកំពុងតែកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអះអាងនោះ អ្នកនោះនឹងត្រូវបានសន្មត់ថាជាកម្មសិទ្ធិករមែន ។ ដូច្នេះអ្នកដែលប្តឹងតវ៉ាពីរឿងនេះ ត្រូវបង្ហាញភស្តុតាងថាអ្នកកាន់កាប់នោះពុំមានកម្មសិទ្ធិទេ ។ ប៉ុន្តែក្នុងករណីអចលនវត្ថុ ការចុះបញ្ជីមានអាទិភាពខ្ពស់ ហេតុដូច្នេះការសន្មត់នៃសិទ្ធិដោយផ្អែកលើការកាន់កាប់ អាចអនុវត្តបានតែចំពោះអចលនវត្ថុដែលមិនទាន់ចុះបញ្ជីតែប៉ុណ្ណោះ ។

### ៥.៥.៣. សិទ្ធិទទួលបានផ្លែផ្ការបស់អ្នកកាន់កាប់ដោយសុចរិត

អ្នកដែលកាន់កាប់ដីដោយយល់ច្រឡំថាខ្លួនមានកម្មសិទ្ធិលើដីនោះ ប៉ុន្តែតាមពិតទៅគឺគ្មានទេនោះ អាចទទួលផ្លែផ្កាពីដើមឈើនៅលើដីនោះបាន ។ នេះគេហៅថា សិទ្ធិទទួលបានផ្លែផ្កា របស់អ្នកកាន់កាប់ដោយសុចរិត (មាត្រា ១៨៩ កថាខ័ណ្ឌទី ១) ។ បើពុំនោះសោតទេ ក្រោយមកទៀតបើសិនជាកម្មសិទ្ធិករពិតប្រាកដទាមទារដល់ទៅការសងផ្លែផ្កាទាំងនោះវិញ គឺវាមានជ្រុលហួសហេតុពេកសំរាប់អ្នកកាន់កាប់ដោយសុចរិត ។ ចំពោះបញ្ហានៃថ្លៃឈ្នួលផ្ទះ ដែលជាផលស៊ីវិលនោះ ក៏ត្រូវអនុវត្តដូចគ្នាដែរ ។

# ជំពូកទី ៤

# ច្បាប់ស្តីពីសិទ្ធិលើបំណុល (១)

## -អំពីកិច្ចសន្យា-

I. ទម្រង់ច្បាប់ស្តីពីសិទ្ធិលើបំណុល (កាតព្វកិច្ច)

១. សិទ្ធិលើបំណុលក្នុងន័យជាសិទ្ធិទៅលើបុគ្គល

២. សិទ្ធិលើបំណុលក្នុងន័យជាទ្រព្យធន

៣. រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសិទ្ធិលើបំណុល និងលំដាប់សិក្សា

II. ការសិក្សាចំណុចសំខាន់ៗអំពីទិដ្ឋភាពទូទៅនៃកិច្ចសន្យា

១. ការបង្កើតកិច្ចសន្យា

២. ប្រភេទនៃកិច្ចសន្យា

៣. សុពលភាពនៃកិច្ចសន្យា

៤. ការមិនអនុវត្តកាតព្វកិច្ច និងការរំលាយកិច្ចសន្យា

III. ការសិក្សាចំណុចសំខាន់ៗអំពីទិដ្ឋភាពលំអិតនៃកិច្ចសន្យា

១. កិច្ចសន្យាលក់

២. កិច្ចសន្យាប្រទានកម្ម (កិច្ចសន្យាធ្វើអំណោយ)

៣. កិច្ចសន្យាជួល (ភតិសន្យា)

៤. កិច្ចសន្យាខ្ចីប្រើ

៥. កិច្ចសន្យាខ្ចីបរិភោគ

៦. កិច្ចសន្យាម៉ៅការ

៧. កិច្ចសន្យាអាណត្តិ

៨. កិច្ចសន្យាបញ្ញើ

៩. កិច្ចសន្យាបង្កើតក្រុមហ៊ុន

១០. កិច្ចសន្យាធម្មតាដទៃទៀត

១១. ការការពារអ្នកប្រើប្រាស់ និងរយៈវេលាអាចរំលាយកិច្ចសន្យាបាន

# I. ទម្រង់ច្បាប់ស្តីពីសិទ្ធិលើបំណុល (ភាតព្វកិច្ច)

## ១. សិទ្ធិលើបំណុលក្នុងន័យជាសិទ្ធិលើបុគ្គល

ក្រមរដ្ឋប្បវេណីកំណត់នូវសិទ្ធិរបស់យើងម្នាក់ៗដោយបែងចែកជា សិទ្ធិទៅលើវត្ថុ និងសិទ្ធិទៅលើបុគ្គល ។ សិទ្ធិទៅលើបុគ្គលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីត្រង់គន្ថីទី ៣ អំពីសិទ្ធិលើបំណុល ដែលហៅថាច្បាប់ស្តីពីសិទ្ធិលើបំណុល ។

សិទ្ធិលើបំណុលនេះ ជាដំបូងបាននាំចូលមកក្នុងប្រទេសជប៉ុននាជំនាន់មុីជី តាមរយៈក្រមរដ្ឋប្បវេណីទំនើបនៅអឺរ៉ុប (ដំបូងបង្អស់គឺប្រទេសបារាំង) ដែលកាលនោះគេបានបកប្រែថាជា "សិទ្ធិលើបុគ្គល" ។ ផ្អែកលើការបកប្រែនេះយើងអាចយល់បានថានេះគឺជាសិទ្ធិរបស់បុគ្គលម្នាក់ទៅលើបុគ្គលម្នាក់ទៀត ដោយទាមទារឱ្យអនុវត្តនូវសកម្មភាពអ្វីមួយជាដើម ។ ការប្រើពាក្យថា "សកម្មភាពអ្វីមួយជាដើម" នេះ គឺមកពីតាមធម្មតាសកម្មភាពសំដៅលើសកម្មភាពដែលត្រូវធ្វើ ដូចជាការបង់ប្រាក់កាស ឬការប្រគល់វត្ថុជាដើម ប៉ុន្តែក្នុងករណីខ្លះពាក្យនេះក៏សំដៅលើសកម្មភាពដែលមិនត្រូវធ្វើផងដែរ ដូចជា "ការមិនបើកហាងរកស៊ីដូចគ្នា" ឬ "ការមិនបញ្ចេញសូរស័ព្ទថ្លង់ឡូឡានៅពេលយប់" ជាដើម ។ ហើយជួនកាលគេហៅសរុបសកម្មភាពដែលត្រូវធ្វើ និងសកម្មភាពដែលមិនត្រូវធ្វើ ដោយបញ្ចូលគ្នាថាជា "(*kyufu*) តាវកាលិក ឬកម្មវត្ថុនៃកិច្ចសន្យា" ។ តាវកាលិកដែលជាកម្មវត្ថុរបស់សិទ្ធិលើបំណុល សំដៅជាទូទៅលើអ្វីដែលមានតម្លៃជាសេដ្ឋកិច្ចក៏ពិតមែនហើយ ក៏ប៉ុន្តែក្រមរដ្ឋប្បវេណីបានចែងថា ទោះបីជាសកម្មភាពនោះពុំអាចទូទាត់ជាប្រាក់កាសកើតក៏ដោយ ក៏អាចចាត់ទុកថា ជាកម្មវត្ថុរបស់សិទ្ធិលើបំណុលបានដែរ (មាត្រា ៣៩៩) ។ ប៉ុន្តែបើសកម្មភាពនោះមានលក្ខណៈជាការប្រតិបត្តិខាងចិត្តសាស្ត្រ ឬសីលធម៌សុទ្ធសាធវិញ គេពិបាកនឹងហៅថាជាសិទ្ធិលើបំណុលណាស់ ។ ឧទាហរណ៍ដូចជាការទាមទារថា "ត្រូវធ្វើបុណ្យរៀងរាល់ឆ្នាំឱ្យអ្នកដែលស្លាប់បាត់ទៅ" នេះអាចក្លាយជាកាតព្វកិច្ចបាន ប៉ុន្តែចំពោះការតម្រូវឱ្យអ្នកណាម្នាក់ "ត្រូវបួងសួងថ្វាយបង្គំព្រះរាល់ព្រឹក" នោះ យើងយល់ថាមិនអាចមានតម្លៃជា កាតព្វកិច្ចបានឡើយ)។ ការសិក្សាច្បាប់ស្តីអំពីសិទ្ធិលើបំណុល គឺជាការសិក្សាស្វែងយល់អំពីលក្ខណៈនិងប្រភពនៃការបង្កើតសិទ្ធិលើបំណុលទាំងឡាយនេះឯង ។

## ២. សិទ្ធិលើបំណុលក្នុងន័យជាទ្រព្យធន

អ្នកដែលធ្លាប់បានសិក្សាសេដ្ឋកិច្ចវិទ្យា ឬគណនេយ្យវិទ្យាប្រហែលជាយល់ហើយថា នៅក្នុងចំណោមទ្រព្យធនដែលបុគ្គលណាម្នាក់ ឬក្រុមហ៊ុនណាមួយមាននោះ ក្រៅពីរបស់ដូចជាអចលទ្រព្យនិងចលនទ្រព្យចេញ នៅមានសិទ្ធិលើបំណុលក្នុងរូបភាពជាសិទ្ធិទៅលើប្រាក់ឱ្យខ្ចី និងប្រាក់ដាក់ធានាគារជាដើមផងដែរ ។ ឧទាហរណ៍ដូចជាក្រុមហ៊ុនជួលវត្ថុ ឬក្រុមហ៊ុនឥណតានជាដើមដែលមានប្រវត្តិនៅក្មេងខ្ចីនៅឡើយ ពិតមែនតែក្រុមហ៊ុនទាំងនោះមានទ្រព្យធនជាអចលនទ្រព្យតិចតួចនៅក្នុងដៃក៏ដោយ ទៅតាមមុខអាជីវកម្មរបស់ខ្លួនក្រុមហ៊ុនទាំងនេះច្រើនតែរក្សានូវទ្រព្យធនរបស់ខ្លួន ក្នុងរូបភាពជាសិទ្ធិលើបំណុលលើប្រាក់ឈ្នួល ឬតាមរយៈការឱ្យខ្ចីប្រាក់ឥណទានជាដើម ដែលមានបរិមាណដ៏ច្រើនលើសលប់។

នៅក្នុងពិភពនៃក្រមរដ្ឋប្បវេណីនេះ កាលពីដើមគេច្រើនតែវាយតម្លៃដោយផ្តោតទៅលើការមានវត្ថុជាកម្មសិទ្ធិដែលជាសិទ្ធិប្រត្យ៉ក្ស ក៏ប៉ុន្តែនៅពេលក្រោយៗមករហូតមកទល់សព្វថ្ងៃនេះ សិទ្ធិលើបំណុលបានក្លាយទៅជាសិទ្ធិដែលមានចំណាត់ថ្នាក់សំខាន់ជាទីបំផុត។ នេះជាដំណើរវិវត្តន៍មួយ ស្របគ្នានឹងប្រវត្តិនៃការទទួលស្គាល់ថា សិទ្ធិលើបំណុលក៏មានលក្ខណៈជាទ្រព្យធនដ៏សំខាន់ដែរ។ ច្បាប់អាណាចក្ររ៉ូមនាកាលដំបូងបានចែងថាសិទ្ធិលើបំណុលជា "ច្រវាក់ច្បាប់" ដែលចងភ្ជាប់បុគ្គលម្នាក់ជាមួយបុគ្គលម្នាក់ទៀត ដូច្នេះគេមិនអាចផ្ទេរសិទ្ធិនេះទៅតតិយជនបានតាមចិត្តឡើយ។ ប៉ុន្តែក្រោយមកច្បាប់អាណាចក្ររ៉ូម បានទទួលស្គាល់ការផ្ទេរសិទ្ធិលើបំណុលនេះបន្តិចម្តងៗវិញ ហើយច្បាប់រដ្ឋប្បវេណីទំនើបសព្វថ្ងៃនៃបណ្តាប្រទេសនានា ក៏ទទួលស្គាល់នូវការផ្ទេរសិទ្ធិលើបំណុលនេះបានដោយសេរីដែរ ។ ជាលទ្ធផល តម្លៃជាទ្រព្យធននៃសិទ្ធិលើបំណុលបានកើតមានឡើង។ សព្វថ្ងៃនេះ ដោយហេតុថាសិទ្ធិលើបំណុលត្រូវបានចាត់ទុកថា ជាទ្រព្យធនដែលអាចប៉ាន់តម្លៃបាន ហើយអាចទូទាត់បានស្រួលជាងអចលនទ្រព្យផងនោះ សារៈសំខាន់របស់វាកាន់តែកើតមានឡើងជាលំដាប់ នៅក្នុងសង្គមធ្វើអាជីវកម្មទិញដូរសព្វថ្ងៃ។ ម្យ៉ាងទៀត បើយើងក្រឡេកមើលតាមទិដ្ឋភាពមួយជ្រុងផ្សេងវិញ យើងនឹងឃើញថាកាលពីជំនាន់សក្តិភូមិ ទំនាក់ទំនងរវាងអ្នកគ្រប់គ្រង និងអ្នកដែលត្រូវគេគ្រប់គ្រង បានកើតមានឡើងតាមរយៈអ្នកមាននិងអ្នកគ្មានដីធ្លី តែសព្វថ្ងៃនេះយើងអាចនិយាយបានថា ទំនាក់ទំនងនេះបានប្រែរូបភាពទៅជាចំណងរវាងអ្នក

គ្រប់គ្រង និងអ្នកត្រូវគេគ្រប់គ្រង នៅក្នុងវិស័យសេដ្ឋកិច្ច តាមរយៈទំនាក់ទំនងនៅក្នុងសិទ្ធិលើបំណុលវិញ (តែនេះក៏មិនអាចចាត់ថាជាបាតុភូតប្រែប្រួលប្រសើរបានទេ)។ ទោះជាយ៉ាងណាក្តី យើងតោងចងចាំថា ច្បាប់ស្តីពីសិទ្ធិលើបំណុលគឺជាផ្នែកមួយមានសារៈសំខាន់ណាស់នៅក្នុងការសិក្សាអំពីក្រមរដ្ឋប្បវេណី ។

## ៣. រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសិទ្ធិលើបំណុល និងលំដាប់សិក្សា

ដូចបានធ្វើការអត្ថាធិប្បាយនៅជំពូកទី ១ (លំនាំសិក្សាច្បាប់រដ្ឋប្បវេណី) រួចហើយថា ក្រមរដ្ឋប្បវេណីបានបញ្ចូលផ្នែកសិទ្ធិលើបំណុលនៅក្នុងគន្ថីទី ៣ ហើយបានកំណត់នូវលក្ខណៈនៃសិទ្ធិលើបំណុល ប្រមជាមួយនឹងដំណើរការកើតមាននិងរលត់ទៅវិញ នូវសិទ្ធិលើបំណុលនេះនៅក្នុងជំពូកទី ១ ។ នៅក្នុងការសិក្សា គេហៅផ្នែកនេះថា "ទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល" ។ រួចហើយចាប់ពីជំពូកទី ២ ទៅជំពូកទី ៥ ច្បាប់បានកំណត់នូវប្រភពនៃការកកើតសិទ្ធិលើបំណុលដោយចែកចេញជា ៤ ផ្នែកគឺ: កិច្ចសន្យា ការគ្រប់គ្រងដោយឈឺឆ្អាល សេចក្តីចំរើនដោយឥតហេតុ និងអំពើអនីត្យានុកូល ។ នៅក្នុងការសិក្សា គេហៅផ្នែកទាំង ៤ នេះថាជា "ទិដ្ឋភាពលំអិតនៃសិទ្ធិលើបំណុល" ។ បើយើងប្រៀបធៀបទិដ្ឋភាពទូទៅជាមួយនឹងទិដ្ឋភាពលំអិត យើងនឹងឃើញថា ការរៀបរាប់នៅក្នុងទិដ្ឋភាពលំអិតមានលក្ខណៈជាក់ស្តែងជាង ហើយស្រួលយល់ជាង ។ អាស្រ័យហេតុនេះ ជាគោលការណ៍ យើងនឹងលើកយកទិដ្ឋភាពលំអិតនៃផ្នែកនីមួយៗ នៃសិទ្ធិលើបំណុលមកធ្វើការអត្ថាធិប្បាយជាមុន រួចហើយទើបចូលទៅទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុលតាមក្រោយ ។ ត្រង់នេះ វាមានភាពផ្ទុយគ្នានឹងលំដាប់នៃចំណាត់ថ្នាក់នៅក្នុងក្រមរដ្ឋប្បវេណី។ ជាបឋម យើងចាប់ផ្តើមពីច្បាប់ស្តីពីកិច្ចសន្យា ក៏ប៉ុន្តែចំពោះផ្នែកខ្លះដូចជាសំណងនៃការខូចខាតជាដើម យើងនឹងបញ្ចូលទៅក្នុងផ្នែកច្បាប់ស្តីពីកិច្ចសន្យាដែលមានការបកស្រាយជាលំអិត នៅក្នុងវិសាលភាពនៃការសិក្សាអំពីទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល ។

# II. ការសិក្សាចំណុចសំខាន់ៗអំពីនិដ្ឋភាពទូទៅនៃកិច្ចសន្យា

## ១. ការបង្កើតកិច្ចសន្យា

### ១.១. និយមន័យនៃកិច្ចសន្យា

ដូចបានធ្វើការអត្ថាធិប្បាយរួចមកហើយថា ក្រមរដ្ឋប្បវេណីសម័យទំនើបបានទទួលស្គាល់នូវ "គោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា" ដូច្នេះតាមរយៈការធ្វើកិច្ចសន្យា វៀរលែងតែមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អនៅក្នុងសង្គមចេញ យើងម្នាក់ៗអាចបង្កើតសិទ្ធិលើបំណុល និងកាតព្វកិច្ចបានជាច្រើនបែបច្រើនយ៉ាង។ រួចហើយយើងក៏បានដឹងដែរថា ដោយហេតុថា សិទ្ធិលើបំណុលមានអានុភាពចងភ្ជាប់ចំពោះតែភាគីពាក់ព័ន្ធប៉ុណ្ណោះ ដូច្នេះគេអាចបង្កើតវាឡើងដោយសេរី ។

ឥឡូវយើងសិក្សាលំអិតបន្ថែមទៀតអំពីការបង្កើតកិច្ចសន្យា។ គេឱ្យនិយមន័យកិច្ចសន្យាថាជា "សកម្មភាពគតិយុត្តដែលបង្កើតនូវទំនាក់ទំនងជា សិទ្ធិនិងករណីកិច្ចក្នុងច្បាប់ ដែលបុគ្គល ២ រូប ឬច្រើនរូប ជាគូភាគីបានស្រុះស្រួលគ្នាជាឯកច្ឆ័ន្ទ ក្នុងការបង្ហាញឆន្ទៈសុំបង្កើតកិច្ចសន្យា និងការបង្ហាញឆន្ទៈខាងស្វីការជាមួយគ្នាទៅវិញទៅមក" ។ ឧទាហរណ៍ដូចជា កិច្ចសន្យាលក់ក្នុងករណីដែលឈ្មោះ A និយាយទៅកាន់ឈ្មោះ B ថាទំនិញនេះលក់ថ្លៃ ៥ ម៉ឺនយ៉េន ហើយបើឈ្មោះ B តបទៅឈ្មោះ A វិញថាសុខចិត្តទិញទំនិញនោះក្នុងតម្លៃ ៥ ម៉ឺនយ៉េន ពេលនោះកិច្ចសន្យាត្រូវបានបង្កើត ។ តាមធម្មតាភាគីនៃកិច្ចសន្យាភាគច្រើនមានគ្នា ២ នាក់ ក៏ប៉ុន្តែនៅក្នុងកិច្ចសន្យាតែមួយក៏អាចមានការចូលរួមច្រើនគ្នា ដោយមានម្ចាស់បំណុលច្រើននាក់ និងកូនបំណុលច្រើននាក់ផងដែរ។

### ១.២. កិច្ចសន្យាអំពីសិទ្ធិលើបំណុល

ជាទូទៅ កាលណាយើងនិយាយអំពីកិច្ចសន្យា យើងរមែងសំដៅលើកិច្ចសន្យាដែលពាក់ព័ន្ធទៅនឹងសិទ្ធិលើបំណុល និងកាតព្វកិច្ច ពោលគឺកិច្ចសន្យាអំពីសិទ្ធិលើបំណុល ។ ហើយកិច្ចសន្យាលក់ដែលយើងធ្លាប់ឮធ្លាប់ដឹងច្រើនជាងគេនោះ ជាឧទាហរណ៍ចំបងមួយតំណាងឱ្យកិច្ចសន្យាបែបនេះ

តែម្ដង ។ នៅក្នុងការទិញលក់នេះ មានការកកើតឡើងនូវសិទ្ធិលើបំណុលក្នុងការទាមទារការបង់ប្រាក់ និងសិទ្ធិលើបំណុលក្នុងការទាមទារឱ្យប្រគល់ទំនិញ (ជាការប្រាកដណាស់ដែលថាតាមរយៈការទិញលក់នេះ កម្មសិទ្ធិទៅលើតាវកាលិក (កម្មវត្ថុនៃកិច្ចសន្យា) ក៏ត្រូវផ្ទេរទៅជាមួយផងដែរ ។ ក្នុងន័យនេះយើងឃើញថាមានកត្តាផ្ទេរសិទ្ធិប្រត្យ័ក្សនៅក្នុងនោះ ។ ក៏ប៉ុន្តែយើងត្រូវយល់ថាកិច្ចសន្យាដែលបង្កើតសិទ្ធិលើបំណុលនិងកាតព្វកិច្ច តោងមានដោយទាំងកត្តានៃការផ្ទេរសិទ្ធិប្រត្យ័ក្ស ហើយកិច្ចសន្យាបែបនេះក៏ត្រូវចាត់ទុកថាជាកិច្ចសន្យាអំពីសិទ្ធិលើបំណុលដែរ) ។ បើដូច្នេះតើគ្មានកិច្ចសន្យាអំពីសិទ្ធិប្រត្យ័ក្សទេឬ? ចំពោះសំណួរនេះ យើងឃើញថា កិច្ចសន្យាដែលបង្កើតសិទ្ធិលើផ្ទៃដីជាដើម គឺជាកិច្ចសន្យាដែលមានខ្លឹមសារចែងតែអំពីសិទ្ធិប្រត្យ័ក្សមួយមុខប៉ុណ្ណោះ គេហៅថាជាកិច្ចសន្យាអំពីសិទ្ធិប្រត្យ័ក្ស ។ម្យ៉ាងទៀត ចំពោះការរៀបអាពាហ៍ពិពាហ៍ដែលជាការឯកភាពគ្នាបង្កើតទំនាក់ទំនងតាមផ្លូវច្បាប់ ដោយផ្អែកលើច្បាប់ស្ដីពីគ្រួសារនោះ គេហៅថា ជាកិច្ចសន្យាអំពីឋានៈ ។ (តទៅនេះ ពាក្យថា "កិច្ចសន្យា" នៅក្នុងសៀវភៅនេះ គឺសំដៅទៅលើ "កិច្ចសន្យាអំពីសិទ្ធិលើបំណុល") ។

## ១.៣.អត្ថន័យនៃបទបញ្ញត្តិស្ដីពីកិច្ចសន្យា

ផ្អែកលើគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា សេចក្ដីនៅក្នុងកិច្ចសន្យាអាចមានច្រើនបែបច្រើនយ៉ាងបានទៅតាមនោះដែរ ។ នៅក្នុងចំណោមសេចក្ដីទាំងនោះ ក្រមរដ្ឋប្បវេណីកំណត់បទបញ្ញត្តិសំរាប់កិច្ចសន្យាចំនួន ១៣ ប្រភេទ ។ ក៏ប៉ុន្តែសូមបញ្ជាក់ជាថ្មីម្ដង ទៀតថា នៅក្នុងក្រមរដ្ឋប្បវេណី ជាពិសេសត្រង់ច្បាប់ស្ដីពីសិទ្ធិលើបំណុលនេះ ភាគីទាំងអស់បង្កើតវិធានដោយសេរីទៅតាមឆន្ទៈរបស់រៀងៗខ្លួន និងទៅតាមការព្រមព្រៀងដោយសេរីរវាងគ្នានឹងគ្នា ដោយឈរលើ "គោលការណ៍ស្វ័យភាពខាងឆន្ទៈ" និង"គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន" ។ ដូច្នេះបទបញ្ញត្តិទាំងប៉ុន្មាន ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនោះ គឺគ្រាន់តែមានលក្ខណៈជួយបំពេញភាពខ្វះចន្លោះ នៅពេលដែលគូភាគីពុំបានបង្កើតវិធានរបស់ខ្លួន ដោយកំណត់បញ្ជាក់ឱ្យបានល្អិតល្អន់តែប៉ុណ្ណោះ ។ បទបញ្ញត្តិទាំងនេះ ជាបទបញ្ញត្តិតាមការស្ម័គ្រចិត្ត ។

## ២. ប្រភេទនៃកិច្ចសន្យា

### ២.១.កិច្ចសន្យាតាមបែបផែន និងកិច្ចសន្យាក្រៅបែបផែន

ក្រមរដ្ឋប្បវេណី បានជ្រើសរើស និងកំណត់នូវកិច្ចសន្យា ១៣ ប្រភេទ ដោយយល់ថាជាកិច្ចសន្យាដែលអ្នកផងទាំងពួងនិយមប្រើប្រាស់ជាហូរហែរមក ហើយឱ្យឈ្មោះថាជា កិច្ចសន្យាតាមបែបផែន ។ រីឯកិច្ចសន្យាផ្សេងពីនេះត្រូវបានឱ្យឈ្មោះថាជា កិច្ចសន្យាក្រៅបែបផែន ។ ដោយហេតុថា កិច្ចសន្យាទាំង ១៣ ប្រភេទនេះ សុទ្ធតែមានឈ្មោះដែលត្រូវបានកំណត់ដោយក្រម គេនិយមហៅថាជា កិច្ចសន្យាមានឈ្មោះ ។ ចំណែកឯកិច្ចសន្យាក្រៅបែបផែនវិញ ត្រូវបានអ្នកខ្លះហៅថាជា កិច្ចសន្យាគ្មានឈ្មោះ ។ ដែលហៅថាគ្មានឈ្មោះនេះមិនមែនមានន័យថាគ្មានសារៈសំខាន់នោះទេ ព្រោះថាកិច្ចសន្យាជួល (lease contract)ក្តី កិច្ចសន្យាឱ្យខ្ចីប្រាក់តាមឥណទាន(credit contract)ក្តី ពិតមែនតែគ្មានឈ្មោះនៅក្នុងប្រភេទទាំងនេះទេក៏ដោយ ក៏តែងមានសារៈសំខាន់ណាស់នាពេលបច្ចុប្បន្ននេះ។ ផ្ទុយទៅវិញ នៅក្នុងកិច្ចសន្យាតាមបែបផែនទាំង ១៣ ប្រភេទទៀតសោត មានកិច្ចសន្យាខ្លះសឹងតែលែងត្រូវបានប្រើប្រាស់ទៅហើយ ។

មួយវិញទៀត នៅក្នុងករណីដែលឆន្ទៈនៃភាគីធ្វើកិច្ចសន្យានោះមិនច្បាស់លាស់ គេមិនដឹងថាត្រូវចាត់ទុកកិច្ចសន្យានោះជាប្រភេទនៃកិច្ចសន្យាណាមួយទេ (ការបកស្រាយកិច្ចសន្យា) ។ នៅឯមហាវិទ្យាល័យ និស្សិតដែលសិក្សាច្បាប់រដ្ឋប្បវេណីតែងបានទទួលមេរៀនថា នេះជាកិច្ចសន្យាលក់ ឬក៏ថានោះជាភតិសន្យា ។ល ។ ក៏ប៉ុន្តែនៅក្នុងសង្គមជាក់ស្តែងវិញ ការបកស្រាយផ្ទាល់នូវកិច្ចសន្យា ឬការបកស្រាយនូវឆន្ទៈរបស់ភាគីធ្វើកិច្ចសន្យា តែងជួបនឹងបញ្ហាស្មុគស្មាញជារឿយៗ ។ ដើម្បីយល់ដឹងក្នុងរឿងនេះ យើងនឹងសិក្សាដោយបែងចែកប្រភេទកិច្ចសន្យាទៅតាមលក្ខណៈពិសេសរបស់វា ដោយផ្តោតការយកចិត្តទុកដាក់លើកិច្ចសន្យាតាមបែបផែន ។

### ២.២. កិច្ចសន្យាត្រឹមការព្រមព្រៀង និងកិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ

ជាដំបូង គឺការបែងចែកកិច្ចសន្យាជាកិច្ចសន្យាត្រឹមការព្រមព្រៀង និងកិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ ។ សព្វថ្ងៃនេះ ភាគច្រើននៃកិច្ចសន្យាជាកិច្ចសន្យាត្រឹមការព្រមព្រៀង ។ ដែលហៅថា ត្រឹមការព្រមព្រៀងនេះ គឺមានន័យថាកិច្ចសន្យានឹងមានសុពលភាពពេញលេញតាមរយៈ

ការបង្ហាញឆន្ទៈព្រមព្រៀងគ្នាតែប៉ុណ្ណោះ ។ ឧទាហរណ៍ដូចជាកិច្ចសន្យាលក់ជាដើម គឺជាកិច្ចសន្យាត្រឹមការព្រមព្រៀងគ្នា (នៅប្រទេសខ្លះចំពោះការលក់ដែលប្រកបដោយតម្លៃខ្ពស់ គេតម្រូវឱ្យធ្វើកិច្ចសន្យាជា លាយល័ក្សអក្សរ ។ ប៉ុន្តែនៅប្រទេសជប៉ុនក្រមរដ្ឋប្បវេណីមិនទាមទារឱ្យធ្វើកិច្ចសន្យាជាលាយល័ក្សអក្សរទេ ។ ថ្វីត្បិតតែយ៉ាងដូច្នេះក៏ដោយ តាមធម្មតាភាគីទាំងសងខាងតែងធ្វើកិច្ចសន្យានេះជាលាយល័ក្សអក្សរ ទុកជាភស្តុតាងទៅថ្ងៃក្រោយ ។ ផ្ទុយទៅវិញ ក្នុងការលក់ឬជួលដីធ្លីដែលមានភ្នាក់ងារកណ្តាល (គួកជេ) ជាអ្នករត់ការជាដើម គូភាគីត្រូវទទួលកាតព្វកិច្ចអនុវត្តតាមច្បាប់ពិសេសផ្សេងៗ ដូចជាច្បាប់ស្តីពីការធ្វើអាជីវកម្មលើដីសំណង់និងអាគារ ហើយត្រូវរៀបចំនិងប្រគល់កិច្ចសន្យាដែលបានធ្វើឡើងជាលាយល័ក្សអក្សរ) ។

ហើយមានកិច្ចសន្យាមួយភាគតូចក្រៅពីនេះ ដែលគេហៅថាកិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ ។ មានន័យថា គ្រាន់តែមានការបង្ហាញឆន្ទៈព្រមព្រៀងគ្នាប៉ុណ្ណោះ គឺនៅមិនទាន់គ្រប់គ្រាន់ទេ លុះត្រាតែបានប្រគល់តាវកាលិកហើយ ទើបមានការកើតឡើងនៃកិច្ចសន្យាដែលនឹងចាប់មានអានុភាព ។ ឧទាហរណ៍ដូចជា ការខ្ចីប្រើដែលជាកិច្ចសន្យាឱ្យខ្ចីដើម្បីប្រើប្រាស់ដោយពុំយកថ្លៃ (មាត្រា ៥៩៣) ជាដើម ។ ក្នុងករណីនេះ អ្នកឱ្យខ្ចីជាអ្នករងការខាតបង់តែម្នាក់ឯង ដូច្នេះបើគ្រាន់តែបង្ហាញឆន្ទៈថាព្រមឱ្យខ្ចីនិងព្រមខ្ចីប៉ុណ្ណោះ គឺមិនទាន់មានកិច្ចសន្យានៅឡើយទេ លុះត្រាតែបានប្រគល់វត្ថុដែលឱ្យខ្ចីនោះសិន ទើបចាត់ទុកថាមានកិច្ចសន្យា ។

## ២.៣. កិច្ចសន្យាអញ្ញមញ្ញ និងកិច្ចសន្យាឯកតោភាគី

បន្ទាប់តទៅនេះ គឺការបែងចែកកិច្ចសន្យាជា កិច្ចសន្យាអញ្ញមញ្ញ និងកិច្ចសន្យាឯកតោភាគី ។ ដូចមានក្នុងការទិញលក់ជាដើម កិច្ចសន្យាណាដែលបង្កើតជាកាតព្វកិច្ចចំពោះភាគីទាំងសងខាង (ពោលគឺអ្នកលក់មានកាតព្វកិច្ចប្រគល់ទំនិញ ហើយអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃទំនិញ)នោះ គេឱ្យឈ្មោះថាជាកិច្ចសន្យាអញ្ញមញ្ញ ។ ចំពោះភតិសន្យា (នឹងអធិប្បាយនៅខាងក្រោយ) ដែលកើតមានឡើងនៅពេលជួលផ្ទះក៏ដូច្នោះដែរ ពោលគឺភតិកៈ មានកាតព្វកិច្ចបង់ថ្លៃឈ្នួលផ្ទះ និងមានកាតព្វកិច្ចប្រគល់ផ្ទះឱ្យវិញនៅពេលដែលការជួលបានចប់រួចរាល់ហើយ រីឯភតិបតីវិញ ត្រូវមានកាតព្វកិច្ចរៀបចំផ្ទះជួលនោះ ឱ្យស្ថិតក្នុងលក្ខណៈមួយអាចឱ្យប្រើការបាន ។ នេះគឺជាកិច្ចសន្យាអញ្ញមញ្ញ ។

ផ្ទុយទៅវិញ ក្នុងកិច្ចសន្យាប្រទានកម្ម (នឹងមានអធិប្បាយនៅខាងក្រោយ)វិញ គូភាគីគ្រាន់តែនិយាយត្រូវរ៉ូវគ្នាថា "ខ្ញុំប្រគល់វត្ថុឱ្យ-ខ្ញុំព្រមទទួល" តែប៉ុណ្ណោះ គឺមានលក្ខណៈគ្រប់គ្រាន់សំរាប់ឱ្យកិច្ចសន្យានេះកើតឡើងបាន។ ប៉ុន្តែចំពោះអ្នកទទួលអំណោយ (បដិគាហក) ពុំកើតមានកាតព្វកិច្ចអ្វីទេ ។ គឺមានតែអ្នកធ្វើអំណោយ (ទាយក) ទេ ដែលមានកាតព្វកិច្ចប្រគល់វត្ថុនោះ ។ ចំពោះកិច្ចសន្យាខ្ចីប្រើ (ដែលបានពិពណ៌នាខាងលើស្រាប់) ក៏ដូចគ្នាដែរ ។ កិច្ចសន្យានេះចាប់កើតឡើងនៅពេលដែលបានប្រគល់វត្ថុឱ្យខ្ចីប្រើ បន្ទាប់មកគឺកើតមានកាតព្វកិច្ចទៅលើអ្នកខ្ចីប្រើដោយតម្រូវឱ្យសងវត្ថុនោះទៅម្ចាស់ដើមវិញតែប៉ុណ្ណោះ ។ ដូចនេះ ក្នុងន័យថាកើតមានកាតព្វកិច្ចទៅលើតែភាគីម្ខាងនោះគេហៅកិច្ចសន្យានេះថា កិច្ចសន្យាឯកតោភាគី បង្កើតកាតព្វកិច្ចទៅលើភាគីតែម្ខាង។ របៀបបែងចែកបែបនេះមានសារៈសំខាន់ណាស់ ព្រោះថាមានបទបញ្ញត្តិខ្លះកំណត់អំពីអានុភាពនៃកិច្ចសន្យា និងការរំលាយកិច្ចសន្យា ដែលអនុវត្តចំពោះតែកិច្ចសន្យាអញ្ញមញ្ញប៉ុណ្ណោះ។

## ២.៤. កិច្ចសន្យាដែលយកតម្លៃថ្នូរ និងកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ

មានការបែងចែកកិច្ចសន្យាម្យ៉ាងទៀត គឺការបែងចែកជាកិច្ចសន្យាដែលយកតម្លៃថ្នូរ និងកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ។ ការបែងចែកនេះអាស្រ័យទៅលើបញ្ហាថា តើជាកិច្ចសន្យាដែលភាគីទាំងសងខាងទូទាត់ទៅតាមការផ្តល់តាវកាលិកទៅវិញទៅមក ដូចជាការបង់ប្រាក់ដើម្បីយកទំនិញនៅពេលទិញលក់ជាដើម (តាវកាលិកដែលផ្តល់គ្នាទៅវិញទៅមកនេះមិនចាំបាច់ត្រូវមានតម្លៃជាក់ស្តែងស្មើគ្នាតាមរូបមន្តសេដ្ឋកិច្ចឡើយ ។ បើភាគីទាំងសងខាងយល់ថាសមស្របទៅវិញទៅមកហើយ គឺជាការគ្រប់គ្រាន់) ឬមួយក៏ជាកិច្ចសន្យាដែលភាគីម្ខាងមិនទទួលយកការទូទាត់ពីភាគីម្ខាងទៀតទេ ដូចក្នុងករណីនៃប្រទានកម្មដែលមានតែភាគីម្ខាងទេជាអ្នកប្រគល់ទ្រព្យសម្បត្តិនោះ ឬយ៉ាងណា?

ការបែងចែកបែបនេះក៏មានសារៈសំខាន់ណាស់ដែរ ព្រោះថាការយកតម្លៃថ្នូរ ឬការមិនយកតម្លៃថ្នូរនេះ នឹងញាំងឱ្យកំរិតនៃការធានា (នឹងមានអធិប្បាយនៅខាងក្រោម) ប្រែប្រួលទៅតាមនោះដែរ (កិច្ចសន្យាដែលយកតម្លៃថ្នូរដូចជាក្នុងការទិញលក់ជាដើម នឹងនាំមកនូវការទទួលខុសត្រូវធានាក្នុងកំរិតមួយធ្ងន់ធ្ងរ ។ បើទំនិញដែលលក់នោះមានតម្លៃពុំសមស្របនឹងតម្លៃប្រាក់ដែលបាន

បង់នោះ អ្នកលក់នឹងត្រូវទទួលខុសត្រូវ ។ ផ្ទុយទៅវិញ កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ដូចជាក្នុងការធ្វើប្រទានកម្មជាដើម ទោះបីជាវត្ថុដែលជាអំណោយនោះមានស្នាមឆ្កូតយ៉ាងណាក៏ដោយ ដោយហេតុថាជាវត្ថុទទួលបានដោយទទេនោះ ជាគោលការណ៍គឺតម្រូវឱ្យអ្នកទទួលត្រូវអត់ធ្មត់ ។ ដូច្នេះបទបញ្ញត្តិស្តីពីការទទួលខុសត្រូវក្នុងការធានាក៏មានលក្ខណៈធូរស្រាលដែរ ។

## ៣. អានុភាពនៃកិច្ចសន្យា

### ៣.១.សុពលភាពនៃកិច្ចសន្យា

តាមការពិត ក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន មិនមានចែងបទបញ្ញត្តិជាមូលដ្ឋានស្តីពីអានុភាពនៃកិច្ចសន្យាទេ ។ ដើម្បីឱ្យកិច្ចសន្យាអាចមានអានុភាពបាន ចាំបាច់ត្រូវមានអត្ថន័យស្របច្បាប់ (ភាពស្របច្បាប់) មានលទ្ធភាពអនុវត្តបាន (លទ្ធភាព) និងមានការកំណត់ច្បាស់លាស់ (ភាពច្បាស់លាស់) ។ ឧទាហរណ៍ ការចុះកិច្ចសន្យាលក់អាគារមួយខ្នង ដែលត្រូវភ្លើងឆេះបាត់តាំងពីមុនពេលចុះកិច្ចសន្យានោះ គឺជាករណីមួយដែលមិនមានតាវកាលិក មិនអាចអនុវត្តកាតព្វកិច្ចទៅបានទេពីដំបូងទី ។ កិច្ចសន្យានេះត្រូវក្លាយជាមោឃៈដោយសារអលទ្ធភាព ។ សិទ្ធិលើបំណុល និងកាតព្វកិច្ច មិនអាចកើតមានបានទេ ។ ប៉ុន្តែឧទាហរណ៍ថា ប្រសិនជាអ្នកទិញបានទទួលការខូចខាត ដោយសារបានជឿថាអាចទិញផ្ទះនេះបានមែន ហើយបានទិញគ្រឿងសង្ហារឹមមកសំរាប់ចូលទៅនៅ ។ នេះតម្រូវឱ្យមានការទទួលខុសត្រូវចំពោះសំណងខូចខាតលើផលប្រយោជន៍នៃការជឿទុកចិត្ត បង្កឡើងមកពី "កំហុសក្នុងការបង្កើតកិច្ចសន្យា" ។ ផ្ទុយទៅវិញ ចំពោះកិច្ចសន្យាផ្ទេរសិទ្ធិលើបំណុល ទាក់ទងដល់ប្រាក់ចំណេញ ដែលអាចនឹងទទួលបានដោយសារការលក់ទំនិញនោះមិនមែនជាអលទ្ធភាពទេ ។ ឱ្យតែបានកំណត់ច្បាស់លាស់អំពីរយៈពេលចាប់ផ្តើម និងរយៈពេលត្រូវបញ្ចប់ គឺគេអាចទទួលស្គាល់បាននូវភាពច្បាស់លាស់នៃកិច្ចសន្យា ។ នេះជាកិច្ចសន្យាមានអានុភាព ។

## ៣.២. អានុភាពជាចំណង និងអានុភាពដោយធៀប

ជាបឋម ដោយផ្អែកលើមូលដ្ឋាននៃការព្រមព្រៀងគ្នារវាងភាគីទាំងសងខាង អានុភាពនៃកិច្ចសន្យាបង្កើតឱ្យមានចំណងកាតព្វកិច្ចរវាងភាគី (ត្រូវតែអានុវត្តតាមកិច្ចសន្យា)។ ដូច្នេះនៅពេលដែលភាគីម្ខាងមិនអានុវត្តតាមកិច្ចសន្យាភាគីម្ខាងទៀតអាចប្តឹងទៅតុលាការបង្ខំឱ្យអនុវត្តតាមឬមួយក៏តម្រូវឱ្យបង់សំណងចំពោះការខូចខាត ជំនួសឱ្យការធ្វើសកម្មភាពដែលបានសន្យាពីដំបូងទី (លើកលែងតែនៅក្នុងកិច្ចសន្យានោះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាពិសេសថាគ្មានការ បង្ខិតបង្ខំឱ្យអនុវត្តតាមទេនោះ)។ ម៉្យាងទៀត ជាគោលការណ៍អានុភាពនៃកិច្ចសន្យាគឺជាអានុភាពដោយធៀបដែលចងតែភាគីក្នុងកិច្ចសន្យាតែប៉ុណ្ណោះ។ ឧទាហរណ៍ដូចជាគេអាចធ្វើកិច្ចសន្យាដោយផ្តល់ផលប្រយោជន៍ទៅជនទី ៣ បាន នៅក្នុងការលក់ទិញរវាងឈ្មោះ A និង ឈ្មោះ B ជាដើម ដោយមានបន្ថែមការព្រមព្រៀងគ្នាថា ប្រាក់ថ្លៃទំនិញនោះត្រូវបង់ផ្ទាល់ទៅជនទី៣ ឈ្មោះ C (កិច្ចសន្យាដែលធ្វើឡើងសំរាប់តតិយជន នឹងមានអធិប្បាយនៅខាងក្រោយ ។ ចាប់ពីមាត្រា ៥៣៧ តទៅ) ក៏ប៉ុន្តែនេះមិនមែនមានន័យថា ជាការព្រមព្រៀងគ្នាដាក់ករណីយកិច្ចលើជនទី៣ នោះឡើយ ។

## ៣.៣. សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា

ជាងនេះទៅទៀត ចំពោះកិច្ចសន្យាឧបតោភាគី ច្បាប់បានកំណត់ឱ្យមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ដោយផ្អែកលើអានុភាពនៃវត្តមានរបស់កិច្ចសន្យា ។ ឧទាហរណ៍ដូចជាក្នុងការទិញលក់ជាដើម អ្នកទិញអាចតវ៉ា (ធ្វើការអះអាងតទល់នឹងការទាមទាររបស់ភាគីម្ខាងទៀត) ថាលុះណាតែអ្នកលក់ប្រគល់ទំនិញឱ្យខ្លួន ទើបខ្លួនព្រមបង់ថ្លៃឱ្យ ។ ហើយផ្ទុយទៅវិញ អ្នកលក់អាចតវ៉ាបានថា លុះណាតែអ្នកទិញបង់ថ្លៃឱ្យខ្លួន ទើបខ្លួនប្រគល់ទំនិញឱ្យ (មាត្រា ៥៣៣ ។ ការតវ៉ានេះអាចអនុវត្តបានរហូតដល់ពេលដែលភាគីម្ខាងទៀតបានផ្តល់ការអនុវត្តកាតព្វកិច្ចរបស់គេ ពោលគឺជាការបង់ថ្លៃជាដើម) ។ ដូច្នេះសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នានៃភាគីទាំងសងខាងនេះ ជាការជំរុញឱ្យមានការអនុវត្តកាតព្វកិច្ចរបស់គ្នាទៅវិញទៅមក ហើយជាលទ្ធផលចុងក្រោយធ្វើឱ្យមានការផ្តល់តាវកាលិកទៅវិញទៅមកបាន ។ ជាធម្មតាទេ ប្រសិនបើភាគីទាំងសងខាងបានកំណត់ជាមួយគ្នាដោយមូលហេតុណាមួយនោះថានឹងបង់ប្រាក់ជាមុន នេះត្រូវក្លាយទៅជាវិធានដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នា ហើយគេមិនអាចប្រើសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាបានទេ ។ ម្យ៉ាងទៀត ទោះបីជាភាគីដែលបានប្រើសិទ្ធិ

តវ៉ាហើយ ប៉ុន្តែក្រោយមកត្រូវអាក់ខានទៅវិញ ក៏មិនត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនេះដែរ (អំពីការមិនអនុវត្តកាតព្វកិច្ច និងការរំលាយកិច្ចសន្យាចោលឬការបង់សំណងនៃការខូចខាត កើតមកពីការមិនអនុវត្តកាតព្វកិច្ចនេះ នឹងមានអធិប្បាយនៅ ៤ ខាងក្រោយ) ។

## ៣.៤. ការទទួលបន្ទុកហានិភ័យ

ចំពោះកិច្ចសន្យាឧបតោភាគីដែលទាក់ទងនឹងកាតព្វកិច្ចនៃភាគីទាំងសងខាង នៅមានរបបមួយទៀតដែលគេហៅថា ការទទួលបន្ទុកហានិភ័យ ។ ឧទាហរណ៍ដូចជាចំពោះកិច្ចសន្យាលក់ភូមិគ្រឹះ ដែលនៅចន្លោះក្រោយពេលធ្វើកិច្ចសន្យានឹងមុនពេលប្រគល់ភូមិគ្រឹះនោះ ស្រាប់តែត្រូវភ្លើងឆេះព្រៃ រាតត្បាតដុតបំផ្លាញភូមិគ្រឹះខូចខ្ទេចខ្ទីអស់ទៅ ។ ក្នុងករណីដូចនេះ ការបាត់បង់តាវកាលិក (ភូមិគ្រឹះ) នៅក្រោយពេលចុះកិច្ចសន្យានិងមុនពេលប្រគល់វត្ថុនេះ ពុំមែនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់កូនបំណុល (អ្នកលក់ភូមីគ្រិះ) នោះឡើយ ។ ប៉ុន្តែត្រូវចោទជាបញ្ហាថា តើអ្នកណាជាអ្នកទទួលបន្ទុកលើការខូចខាតនេះ អ្នកលក់ដែលជាកូនបំណុលឬអ្នកទិញដែលជាម្ចាស់បំណុល? ចំពោះកូនបំណុលដែលជាអ្នកលក់នោះ ប្រសិនបើតាវកាលិកនេះមិនអាចរកវត្ថុផ្សេងមកជំនួសកើតទេ គឺកាតព្វកិច្ចប្រគល់ភូមីគ្រឹះមិនអាចអនុវត្តបានទេ ហើយត្រូវរលត់ ។ ដោយហេតុថា ការខូចខាតនេះមិនមែនជាការទទួលខុសត្រូវរបស់កូនបំណុលទេ ដូច្នេះមិនបង់សំណងចំពោះការខូចខាតក៏មិនអីដែរ ។ (ផ្ទុយទៅវិញ ក្នុងករណីដែលការខូចខាតកើតឡើងដោយសារមូលហេតុជាបន្ទុករបស់កូនបំណុលនោះ កាតព្វកិច្ចដែលកូនបំណុលមិនបានអនុវត្តនឹងមិនបាត់ទៅណាទេ គឺនៅរហូតដោយប្រែក្លាយទៅជាកាតព្វកិច្ចចំពោះសំណងនៃការខូចខាត ។ សូមអានវគ្គទី ៤.១. និង៤.២) ។ បញ្ហានៅត្រង់ថា តើភាគីអ្នកទិញដែលបានធ្វើកិច្ចសន្យារួចទៅហើយនោះ ត្រូវបង់ថ្លៃឬក៏មិនត្រូវបង់? តាមពិតទៅ ត្រូវភាគីទាំងពីរសំរេចទុកជាមុនទាំងអស់គ្នាក៏ប៉ុន្តែបើមិនបានសំរេចទុកជាមុនទេ ក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងទូលំទូលាយថា នៅក្នុងករណីទិញលក់ជាដើម (ករណីនៃកិច្ចសន្យាអញ្ញមញ្ញ ដែលមានគោលបំណងកំណត់ ឬផ្ទេរកម្មសិទ្ធិលើវត្ថុអ្វីមួយ) ម្ចាស់បំណុលជាអ្នកទទួលបន្ទុក (មាត្រា ៥៣៤) ហើយនៅក្នុងករណីផ្សេងដូចជាការជួលជាដើម (ករណីកិច្ចសន្យាអញ្ញមញ្ញដែលគ្មានភ្ជាប់នូវការកំណត់ ឬការផ្ទេរកម្មសិទ្ធិទេនោះ)

កូនបំណុលជាអ្នកទទួលបន្ទុកវិញ (មាត្រា ៥៣៦) ។ ក៏ប៉ុន្តែ មានការរិះគន់យ៉ាងខ្លាំងចេញពីទ្រឹស្តីសិក្សា ដោយយល់ថាគោលការណ៍ដាក់បន្ទុកលើម្ចាស់បំណុលនេះ មិនសមស្របនឹងសង្គមសព្វថ្ងៃនេះទេ (តាមធម្មតាគេរមែងធ្វើកិច្ចសន្យាពិសេសដោយមានកំណត់ជាទូទៅថា កូនបំណុលជាអ្នកទទួលបន្ទុកចំពោះគ្រោះថ្នាក់នាំឱ្យមានការបាត់បង់ ពោលគឺថាទន្ទឹមនឹងការបាត់បង់កាតព្វកិច្ចប្រគល់តាវកាលិកនោះ សិទ្ធិលើបំណុលទាមទារឱ្យគេបង់ថ្លៃក៏ត្រូវរស់ដែរ ។

**ការទទួលបន្ទុកហានិភ័យ គោលការណ៍ដាក់បន្ទុកលើកូនបំណុល និងគោលការណ៍ដាក់បន្ទុកលើម្ចាស់បំណុល**

ការទទួលបន្ទុកហានិភ័យ គឺជាបញ្ហាដែលមានចំពោះកិច្ចសន្យាអញ្ញមញ្ញ។ ក្នុងកិច្ចសន្យាអញ្ញមញ្ញ សិទ្ធិលើបំណុលនិងកាតព្វកិច្ចកើតមានទៅលើភាគីទាំងសងខាង។ ដូច្នេះនៅពេលនិយាយថា ការទទួលបន្ទុកហានិភ័យតាមគោលការណ៍ដាក់បន្ទុកលើម្ចាស់បំណុល ឬតាមគោលការណ៍ដាក់បន្ទុក លើកូនបំណុលនោះ សូមប្រយ័ត្នកុំច្រឡំម្ចាស់បំណុលទៅនឹងកូនបំណុលឱ្យសោះ។ ការកំណត់ថា អ្នកណាជាកូនបំណុល ហើយអ្នកណាជាម្ចាស់បំណុលនោះ គឺអាស្រ័យទៅលើទ្រព្យធនដែលបានវិនាសបាត់បង់។ មានន័យថា បើលើកឧទាហរណ៍នៃភូមិគ្រឹះដែលត្រូវភ្លើងឆេះមកនិយាយ ភាគីអ្នកទិញដែលមានសិទ្ធិទាមទារការប្រគល់ភូមិគ្រឹះដល់ខ្លួននោះគឺជាម្ចាស់បំណុល ហើយភាគីអ្នកលក់ដែលមានកាតព្វកិច្ចត្រូវប្រគល់ភូមិគ្រឹះឱ្យគេនោះគឺជាកូនបំណុល។ អាស្រ័យហេតុនេះ គោលការណ៍ដាក់បន្ទុកលើម្ចាស់បំណុល គឺជាការកំណត់ឱ្យម្ចាស់បំណុលទទួលបន្ទុកហានិភ័យ ។ អ្នកទិញដែលជា ម្ចាស់បំណុលមានសិទ្ធិទាមទារឱ្យគេប្រគល់ភូមិគ្រឹះមកខ្លួននោះ មិនអាចទទួលបាននូវតាវកាលិកទេ (កាតព្វកិច្ចដែលត្រូវអនុវត្តដោយអ្នកលក់ជាកូនបំណុលនោះត្រូវរលត់បាត់) ប៉ុន្តែកាតព្វកិច្ចបង់ប្រាក់របស់អ្នកទិញត្រូវបន្តទៅទៀតមិនបានរលត់ទេ ។

## ៣.៥. កិច្ចសន្យាដែលធ្វើឡើងសំរាប់តតិយជន

ឧទាហរណ៍ដូចជាការសន្យាបន្ថែមនៅក្នុងការទិញលក់រវាងឈ្មោះ A និងឈ្មោះ B ដែលកំណត់ថានឹងបង់ប្រាក់ថ្លៃទំនិញឱ្យទៅឈ្មោះ C ផ្ទាល់ជាដើម ។ កិច្ចសន្យាដែលផ្តល់ផលប្រយោជន៍ទៅតតិយជនក្រៅពីភាគីនៃកិច្ចសន្យានេះ គេហៅថា កិច្ចសន្យាដែលធ្វើឡើងសំរាប់តតិយជន

(ចាប់ពីមាត្រា ៥៣៧ តទៅ)។ នេះជាកិច្ចសន្យាមួយ ក៏ប៉ុន្តែកិច្ចសន្យានេះមិនអាចកើតមានឡើងដោយឯកឯងទេ តោងភ្ជាប់ទៅនឹងកិច្ចសន្យាណាមួយទៀត ហើយមានឈ្មោះជាកិច្ចសន្យាពិសេស ឬក៏ជាកថាលក្ខន្តិកៈបន្ទាប់បន្សំ។ ដោយហេតុថា វាញ៉ាំងឱ្យកិច្ចសន្យាមានអានុភាពចងចំពោះជនផ្សេងក្រៅពីភាគីនៃកិច្ចសន្យានោះ គេចាត់ទុកនេះថាជាករណីលើកលែងដែលខុសពីការយល់ដឹងជាទូទៅចំពោះអានុភាពនៃកិច្ចសន្យា (មិនជះឥទ្ធិពលទៅលើជនណាក្រៅពីគូភាគីទេ) ។ ប៉ុន្តែក្នុងករណីនេះ ក៏មានការកំណត់ព្រំដែនដូចតទៅ:

ក. អាចធ្វើកិច្ចសន្យាបានដោយឱ្យផលប្រយោជន៍ដល់តតិយជន C តែមិនអាចធ្វើការព្រមព្រៀងគ្នាបង្ខឱ្យតតិយជន C ទទួលរងនូវផលវិបាកដោយត្រូវបំពេញកាតព្វកិច្ចជាអវិជ្ជមានណាមួយឡើយ ។

ខ. តតិយជន C ដែលជាអ្នកទទួលផលនោះមិនអាចនឹងទទួលផលប្រយោជន៍ដែលកើតឡើងតាមរយៈការព្រមព្រៀងគ្នារវាងឈ្មោះ A និង ឈ្មោះ B ដោយស្វ័យប្រវត្តិបានទេ ពោលគឺចាំបាច់ត្រូវតែតតិយជន C បង្ហាញឆន្ទៈព្រមទទួលផលផងដែរ (ការបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍) ។

គ. បើតតិយជន C បង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍ហើយ ភាគី A និង B មិនអាចដកការព្រមព្រៀងនេះចេញបានទេ តែបើមិនទាន់មានការបង្ហាញឆន្ទៈទទួលផលពីតតិយជន C នៅឡើយទេ ការព្រមព្រៀងអាចដកចេញវិញបាន។

ម្យ៉ាងទៀត បន្ទាប់ពីបានបង្ហាញឆន្ទៈទទួលផលហើយ តតិយជនដែលជាអ្នកទទួលផលអាចទាមទារឱ្យកូនបំណុលផ្តល់តាវកាលិកមកខ្លួនដោយចំពោះបាន ។ នៅក្នុងករណីនេះ កូនបំណុលអាចអះអាងនូវគ្រប់សិទ្ធិទាំងអស់ ដូចដែលខ្លួនមានទៅលើម្ចាស់បំណុលនោះបានដែរ (មានន័យថាឧទាហរណ៍ដូចជាក្នុងករណីអ្នកលក់ A និងអ្នកទិញ B បានធ្វើកិច្ចសន្យាលក់ជាមួយគ្នាហើយបានធ្វើកិច្ចសន្យាសំរាប់តតិយជនដោយកំណត់ថា ត្រូវប្រគល់ប្រាក់ថ្លៃទំនិញទៅឱ្យឈ្មោះ C ផ្ទាល់ថែមទៀតផង ។ ក្រោយពីឈ្មោះ C បានបង្ហាញឆន្ទៈថាសុខចិត្តទទួលផលប្រយោជន៍ហើយ ឈ្មោះ C ទៅទារប្រាក់ថ្លៃទំនិញពី B ។ បើសិនជា B នៅមិនទាន់បានទទួលទំនិញពី A នៅឡើយទេ

ហើយមានសិទ្ធិតវ៉ាជាមួយ A ទាមទារឱ្យអនុវត្តព្រមគ្នានោះ B ក៏អាចប្រើសិទ្ធិតវ៉ានេះចំពោះ C បានដូចគ្នាផងដែរ) ។

## ៤. ការមិនអនុវត្តកាតព្វកិច្ច និងការរំលាយកិច្ចសន្យា

តើយើងត្រូវធ្វើដូចម្ដេចប្រសិនបើភាគីម្ខាងទៀតមិនគោរព ហើយមិនអនុវត្តតាមកិច្ចសន្យាទេនោះ? ជាការពិតណាស់ យើងអាចទៅពឹងពាក់តុលាការបង្ខំឱ្យភាគីម្ខាងទៀតគោរពតាមកិច្ចសន្យា (អនុវត្តកាតព្វកិច្ចដោយបង្ខំ) ក៏បានដែរ ។ ក៏ប៉ុន្តែក្នុងករណីបានហួសរយៈវេលាកំណត់ ឬក៏ក្នុងករណីដែលភាគីម្ខាងទៀតបានធ្វើបាត់វត្ថុជាកម្មវត្ថុនៃកិច្ចសន្យា មិនអាចអនុវត្តកាតព្វកិច្ចបានទេ តើយើងគួរធ្វើដូចម្ដេចទៅវិញ? នៅក្នុងរណីនេះ តាមក្រមរដ្ឋប្បវេណី យើងមានមធ្យោបាយ ២ បែប ។ ទីមួយ គឺទាមទារឱ្យភាគីជាដៃគូបង់សំណងនៃការខូចខាត ដែលកើតមានពីការមិនអនុវត្តកាតព្វកិច្ច ។ ទីពីរ គឺរំលាយកិច្ចសន្យាចោល ដោយហេតុថាភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ច ។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន អនុញ្ញាតឱ្យរើសយកការរំលាយកិច្ចសន្យាក៏បាន ឬរើសយកការទាមទារសំណងក៏បាន ឬរើសយកទាំងពីរក៏បានដេរ (មាត្រា ៥៤៥ កថាខ័ណ្ឌទី ៣) ។ ក៏ប៉ុន្តែបទញ្ញត្តិស្តីពីសំណងនៃការខូចខាត ត្រូវបានចែងនៅក្នុងផ្នែកស្តីពីបទបញ្ញត្តិទូទៅនៃសិទ្ធិលើបំណុល ចំណែកឯការរំលាយកិច្ចសន្យា មានចែងនៅក្នុងបទបញ្ញត្តិជាក់លាក់ស្តីពីសិទ្ធិលើបំណុលទៅវិញ ។ នៅទីនេះ យើងនឹងពន្យល់ដោយគួបផ្សំផ្នែកទាំងពីរនេះបញ្ចូលគ្នាតែម្តង ។

### ៤.១. ករណីនៃការមិនអនុវត្តកាតព្វកិច្ច

តាមការកំណត់នៃក្រមរដ្ឋប្បវេណី ដើម្បីឱ្យកូនបំណុលទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន លុះត្រាតែមានមូលហេតុដែលជាបន្ទុករបស់កូនបំណុល ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះជាមុនសិន។ ពោលគឺចាំបាច់ត្រូវមានកំហុស ឬចេតនា កើតឡើងពីភាគីកូនបំណុល (ត្រូវប្រយ័ត្នពីចំណុចនេះផង ព្រោះបញ្ញត្តិចែងក្នុងមាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណី ដែលកំណត់និយមន័យឱ្យពាក្យថាមិនអនុវត្តកាតព្វកិច្ចនោះ មានចំណុចខ្លះពិបាកយល់ណាស់ដែរ) ។ បើគ្មានកំហុសទេ គឺមិនមានការទទួលខុចត្រូវឡើយ។ នេះជាគោលការណ៍មូលដ្ឋាននៃក្រមរដ្ឋប្បវេណី

ពោលគឺ គោលការណ៍ទទួលខុសត្រូវលើកំហុស ។ បើយ៉ាងដូច្នេះ ការអនុវត្តកិច្ចសន្យាមិនបានដោយហេតុមកពីមានគ្រោះធម្មជាតិ ដូចជារញ្ជួយផែនដី ឬផ្ទុះភ្នំភ្លើងជាដើមនោះ មិនចាត់ទុកថាជាការមិនអនុវត្តកាតព្វកិច្ចទេ ។ម្យ៉ាងទៀត បានជាប្រើពាក្យថា ភាគីកូនបំណុល គឺព្រោះថាមិនកំរិតត្រឹមតែចេតនា ឬកំហុសរបស់កូនបំណុលផ្ទាល់ខ្លួនតែប៉ុណ្ណោះទេ ។ គេត្រូវរាប់បញ្ចូលផងដែរនូវកំហុស ឬចេតនា របស់ជនណាដែលបានជួយដល់កូនបំណុល ក្នុងការអនុវត្តកាតព្វកិច្ចនោះដែរ ។ ការមិនអនុវត្តកាតព្វកិច្ច មានចែកចេញជា ៣ ប្រភេទដូចតទៅ :

ក. ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ដោយមិនបានប្រតិបត្តិឱ្យទាន់រយៈពេលកំណត់ក្នុងកិច្ចសន្យា ។

ខ. អលទ្ធភាពក្នុងការអនុវត្តន៍ដោយសារបាត់បង់លទ្ធភាពមិនអាចអនុវត្តបានដូចការសន្យា

គ. ការអនុវត្តន៍មិនពេញលក្ខណៈដូចជាបានអនុវត្តទាន់ពេលកំណត់មែន ប៉ុន្តែសេចក្តីនោះមិនដូចសន្យា ឬមួយក៏មិនបានពេញលេញជាដើម ។

## ៤.២. សំណងនៃការខូចខាត

ប្រសិនបើការអនុវត្តកាតព្វកិច្ចមានការយឺតយ៉ាវ គេអាចទាមទារសំណងនៃការខូចខាតទាំងឡាយដែលកើតឡើងនៅក្នុងអំឡុងពេលយឺតយ៉ាវនោះបាន (ហៅថាសំណងនៃការយឺតយ៉ាវ)។ ចំពោះករណីអលទ្ធភាពក្នុងការអនុវត្តន៍ គេអាចទាមទារប្រាក់ជាសំណងជំនួសឱ្យតាវកាលិកដែលត្រូវផ្តល់តាមកិច្ចសន្យានោះ (ហៅថាសំណងបំពេញ)។ ចំពោះព្រំដែននៃសំណងនៃការខូចខាតនេះ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានកំណត់នៅក្នុងមាត្រា ៤១៧ ដោយចែកចេញជាការខូចខាតធម្មតា និងការខូចខាតពិសេស។ ចំពោះការខូចខាតដែលត្រូវកើតមានឡើងក្នុងកាលៈទេសៈធម្មតា គឺត្រូវបង់សំណងទៅតាមការខូចខាតក្នុងក្របខ័ណ្ឌជាសំណងធម្មតា។ រីឯការខូចខាតដែលកើតមានឡើងដោយសារកាលៈទេសៈពិសេសណាមួយវិញ គេត្រូវពិនិត្យបញ្ជាក់ថាតើ សាមីខ្លួនអាចស្មានដឹងបានជាមុនអំពីការខូចខាតនោះដែរឬទេ? (អាចប្រមាណមើលទុកជាមុនបាន ឬមិនបាន) ហើយចំពោះតែផ្នែកខូចខាតដែលអាចស្មានដឹងជាមុនបានតែប៉ុណ្ណោះទេ ទើបត្រូវបញ្ចូលទៅក្នុង

ក្របខ័ណ្ឌជាសំណងដែលត្រូវសង។ តើអ្វីទៅដែលជាការខូចខាតធម្មតា ហើយអ្វីទៅដែលជាការខូចខាតពិសេសនោះ ចំឡើយគឺត្រូវអាស្រ័យទាំងស្រុងទៅលើករណីជាក់ស្ដែងនីមួយៗវិញ ។ យើងលើកឧទាហរណ៍ដូចជាករណីបានធ្វើកិច្ចសន្យាទិញផ្ទះរួចរាល់ហើយ ប៉ុន្តែដោយហេតុថា ការប្រគល់ផ្ទះមានការយឺតយ៉ាវ ១ ខែហួសពេលកំណត់នៃការសន្យា ជាហេតុនាំឱ្យអ្នកទិញត្រូវទៅជួលផ្ទះគេនៅអស់រយៈពេល ១ ខែដែរនោះ ករណីនេះមតិភាគច្រើនយល់ថា ថ្លៃឈ្នួលផ្ទះគឺជាការខូចខាតធម្មតា។ ក៏ប៉ុន្តែប្រសិនបើមានការសន្យាជាមួយអ្នកផ្សេងទៀតថា បន្ទាប់ពីទិញផ្ទះហើយនឹងលក់បន្តក្នុងតម្លៃខ្ពស់ ហើយដោយហេតុថាមានការយឺតយ៉ាវក្នុងការប្រគល់ផ្ទះ បណ្ដាលឱ្យការលក់បន្តនេះត្រូវអាក់ខានទៅវិញ ។ បើសិនជាអ្នកទិញផ្ទះបានទាមទារសំណងចំពោះភាគចំណេញដែលត្រូវបាត់បង់ដោយសារតែការខកខានមិនអាចលក់បន្តបានទេនោះ ការខូចខាតនេះ (ប្រសិនបើអ្នកទិញជាជនសាមញ្ញធម្មតា) នឹងអាចចាត់ទុកបានថាជាការខូចខាតពិសេស ដូច្នេះមានតែក្នុងករណីដែលអ្នកលក់អាចស្មានដឹងជាមុនបាននូវការលក់បន្តរបស់អ្នកទិញនោះទេ ទើបអ្នកទិញអាចទទួលសំណងនៃការខូចខាតបានក្នុងក្របខ័ណ្ឌនៃសំណងពិសេស។



## ៤.៣.ការរំលាយកិច្ចសន្យា

មធ្យោបាយដោះស្រាយម្យ៉ាងទៀត គឺការរំលាយកិច្ចសន្យា ។ ក្នុងករណីដែលកូនបំណុលមិនអនុវត្តតាមកាតព្វកិច្ចទេ ម្ចាស់បំណុលអាចបង្ហាញឆន្ទៈជាឯកតោភាគីចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូងទីបាន (តាមផ្លូវច្បាប់ការរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថាជាអំពើក្នុងប្រភេទសកម្មភាពឯកតោភាគី) ។ ការបង្ហញឆន្ទៈដូចនេះ មានអានុភាពតម្រូវឱ្យភាគីទាំងអស់ធ្វើបដិទានឡើងវិញ (ការធ្វើឱ្យត្រឡប់មកដូចស្ថានភាពនាកាលដំបូងទីវិញ) ។ ពោលគឺកើតមានករណីយកិច្ចត្រូវធ្វើឱ្យស្ថានភាពត្រឡប់មករកអ្វីដែលមានតាំងពីមុនពេលធ្វើកិច្ចសន្យា (មាត្រា ៥៤៥ កថាខ័ណ្ឌទី ១) ។ ក៏ប៉ុន្តែ អានុភាពនៃបដិទាននេះ មិនត្រូវធ្វើឱ្យមានផលប៉ះពាល់ទៅលើតតិយជនបានឡើយ ។ នេះបានសេចក្តីថា មុនពេលរំលាយកិច្ចសន្យា ប្រសិនជាមានតតិយជនណាម្នាក់បានទិញទំនិញបន្តពីភាគីអ្នកទិញរួច ហើយព្រមទាំងមានល័ក្ខខ័ណ្ឌតតាំងគ្រប់គ្រាន់ថែមទៀតនោះ គឺការរំលាយកិច្ចសន្យាមិនត្រូវធ្វើឱ្យមានការខូចខាតដល់សិទ្ធិដែលតតិយជនបានទទួលនោះទេ (មាត្រា ៥៤៥ កថាខ័ណ្ឌទី ១ បដិញ្ញា)។

ម្យ៉ាងវិញទៀត អានុភាពប្រតិសកម្ម ដែលជាអានុភាពនៃការវិលត្រឡប់មករកស្ថានភាពដើមវិញ ឱ្យបានដូចមុនពេលធ្វើកិច្ចសន្យានោះ អាចនឹងកើតមានឡើងបានចំពោះតែកិច្ចសន្យាណាដែលមានលក្ខណៈជាការអនុវត្តន៍តែមួយដងចប់ជាស្ថាពរ ។ តួយ៉ាងដូចជាកិច្ចសន្យាលក់ជាដើម ។ ក៏ប៉ុន្តែចំពោះភតិសន្យា ដែលជាកិច្ចសន្យាមានរយៈវេលាអនុវត្តន៍ជាបន្តបន្ទាប់នោះ ពុំអាចមានអនុភាពប្រតិសកម្មទេ ។ អានុភាពនៃការរំលាយកិច្ចសន្យានឹងកើតមានឡើង ចាប់ពីពេលរំលាយនោះរហូតទៅអនាគតតែប៉ុណ្ណោះ (ព្រោះថាវាគ្មានន័យអ្វីទាល់តែសោះក្នុងការសងប្រាក់ថ្លៃឈ្នួលផ្ទះដែលខ្លួនបានទទួលពីអតីតកាល ឬសងទៅវិញនូវផលប្រយោជន៍ទាំងប៉ុន្មាន ដែលបានទទួលមកពីការប្រើប្រាស់នាពេលអតីតកាលនោះទេ)។ រីឯមធ្យោបាយរំលាយកិច្ចសន្យាទៀតសោត ឧបមាថា បើមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ជាគោលការណ៍ គេត្រូវកំណត់រយៈពលជាក់លាក់ឱ្យអនុវត្តតាមកិច្ចសន្យាជាថ្មីម្តងទៀត (ហៅថាការដាស់តឿន) រួចហើយបើនៅគ្មានការគោរពដដែលទៀតទេនោះ ទើបគេអាចរំលាយកិច្ចសន្យាចោលបាន (មាត្រា ៥៤១) ។ ក៏ប៉ុន្តែនៅក្នុងបណ្តាកិច្ចសន្យាទាំងឡាយ រមែងមានចំណុចខ្លះដែលគេហៅថា សកម្មភាពដែលត្រូវធ្វើតាម

រយៈពេលកំណត់ ដែលត្រូវតែអនុវត្តតាមពេលកំណត់ជាដាច់ខាត បើពុំនោះទេគឺពុំមានន័យអ្វីឡើយ (ឧទាហរណ៍ដូចជាកិច្ចសន្យាធ្វើម្ហូបការជាដើម បើមិនធ្វើនៅថ្ងៃរៀបអាពាហ៍ពិពាហ៍ទេ គឺពុំមានន័យអ្វីឡើយ) ។ នៅក្នុងករណីនេះការរំលាយកិច្ចសន្យាអាចធ្វើបានភ្លាម ដោយមិនចាំបាច់ធ្វើការដាស់តឿនទេ (មាត្រា ៥៤២) ។ ចំពោះករណីអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច គេក៏អាចរំលាយកិច្ចសន្យាបានភ្លាមដែរ ដោយពុំចាំបាច់ត្រូវធ្វើការដាស់តឿនទេ ព្រោះថាគ្មានប្រយោជន៍អ្វីនឹងដាស់តឿនភាគីដែលគ្មានលទ្ធភាពអនុវត្តកាតព្វកិច្ចបានទេនោះ (មាត្រា ៥៤៣) ។ ចំណែកឯករណីនៃការអនុវត្តន៍មិនពេញលក្ខណៈវិញ ប្រសិនបើភាគីម្ខាងទៀតមានលទ្ធភាពនឹងអនុវត្តឱ្យចប់សព្វគ្រប់បាននាពេលអនាគតនោះ មុននឹងរំលាយកិច្ចសន្យាចោលគេត្រូវធ្វើការដាស់តឿន ដូចគ្នានឹងករណីមានការយឺតយ៉ាវក្នុងការអនុវត្តន៍កាតព្វកិច្ចដែរ ។ ប៉ុន្តែបើសិនជាគ្មានលទ្ធភាពនឹងអនុវត្តឱ្យបានចប់សព្វគ្រប់នាពេលអនាគតទេនោះ គេអាចរំលាយកិច្ចសន្យាភ្លាម ដោយពុំចាំបាច់ធ្វើការដាស់តឿនទៀតឡើយ ។

## III. ការសិក្សាចំណុចសំខាន់ៗអំពីនិដ្ឋភាពលំអិតនៃកិច្ចសន្យា

### ១. កិច្ចសន្យាលក់

#### ១.១. កំណត់សំគាល់ទូទៅ

ចូរយើងក្រឡេកមកមើលកិច្ចសន្យាសំខាន់ៗខ្លះ នៅក្នុងបណ្ដាកិច្ចសន្យាតាមបែបផែន ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីម្ដង។ ដូចបានពិពណ៌នាជាញឹកញាប់ណាស់មកហើយថា កិច្ចសន្យាលក់ គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ ជាកិច្ចសន្យាអញ្ញមញ្ញ ហើយជាកិច្ចសន្យាត្រឹមការព្រមព្រៀងផង ។ មាត្រា ៥៥៩ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា បទបញ្ញត្តិទាំងឡាយស្ដីពីកិច្ចសន្យាលក់ត្រូវផ្អែកលើមូលដ្ឋាននៃការអនុវត្តកិច្ចសន្យាដទៃទៀតដែលយកតម្លៃថ្នូរ ។ ម៉្យាងទៀត ក្រមរដ្ឋប្បវេណីពុំមានកំណត់នូវករណីយកិច្ចត្រូវតែធ្វើកិច្ចសន្យាជាលាយលក្ខអក្សរជាចាំបាច់ទេ ក្នុងការបង្កើតកិច្ចសន្យាលក់ ក៏ដូចជាកិច្ចសន្យាដទៃផ្សេងទៀតដែរ ។ ដូច្នេះ យោងតាមក្រមរដ្ឋប្បវេណី ទោះបីជាការទិញលក់នោះមានតម្លៃខ្ពស់យ៉ាងណាក៏ដោយ កិច្ចសន្យាអាចកើតមានឡើងបាន

ដោយផ្អែកលើការព្រមព្រៀងតែប៉ុណ្ណោះ ថ្វីត្បិតតែគ្មានសរសេរជាលាយល័ក្សអក្សរក៏ដោយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកទិញជាអ្នកប្រើប្រាស់ទូទៅ ឬកិច្ចសន្យានោះពាក់ព័ន្ធនឹងតម្លៃប្រាក់ច្រើនលើសលប់ ច្បាប់ពិសេសផ្សេងៗបានកំណត់បញ្ញត្តិស្តីពីករណីកិច្ចចាំបាច់ ក្នុងការធ្វើកិច្ចសន្យាជាលាយល័ក្សអក្សរ (តួយ៉ាងដូចជាច្បាប់ស្តីពីសកម្មភាពជំនួញកំណត់ ឬច្បាប់ស្តីពីអាជីវកម្មជួញដូរដីសំណង់និងអាគារជា ដើម) ។

## ១.២.ការសន្យាលក់ទិញជាមុន

គេអាចសន្យាជាមួយគ្នាទុកជាមុនថា នឹងធ្វើកិច្ចសន្យាលក់បានដោយគ្រាន់តែនិយាយថា "សុខចិត្តទិញ" និង "សុខចិត្តលក់" ។ កិច្ចសន្យាទុកជាមុននេះក៏ជាកិច្ចសន្យាមួយ ហើយមានអានុភាពចងបង្ខំឱ្យអនុវត្តតាមដែរ ។ ភាគីម្ខាងដែលត្រូវភាគីម្ខាងទៀតទាមទារសុំភ្ជាប់កិច្ចសន្យាពិតប្រាកដនៅថ្ងៃក្រោយនោះ ត្រូវតែទទួលយល់ព្រមជាមុននេះ ។ ប្រសិនបើ ភាគីដៃគូមិនព្រមទទួលធ្វើកិច្ចសន្យាពិតប្រាកដដោយយកលេសទៅតាមចិត្តខ្លួននោះ គេអាចប្តឹងសុំតុលាការចេញសាលក្រមជំនួសឱ្យការបង្ហាញឆន្ទៈយល់ព្រមបាន ។ ក៏ប៉ុន្តែប្រសិនបើភាគីធ្វើព្រងើយកន្តើយបន្តទៅទៀតដោយមិនព្រមសហការទេនោះ ទោះបីជាដឹងថាខ្លួនឈ្នះហើយក្តីក៏ដោយ ក៏ប្រហែលជាពុំមាននរណាចង់ធ្វើកិច្ចសន្យាដែលស្មុគស្មាញបែបនេះទេដែរ ។ អាស្រ័យហេតុនេះក្រមរដ្ឋបវេណីនៃប្រទេសជប៉ុនបានបញ្ញត្តិថា ចំពោះប្រភេទនៃកិច្ចសន្យាលក់ដែលនិយមធ្វើឡើងញឹកញាប់ជាងគេនោះ ល្គឹកណាមានដាក់លក្ខខ័ណ្ឌទិញលក់ជាមុន ហើយប្រសិនបើមានការសុំធ្វើកិច្ចសន្យាពិតប្រាកដនាអនាគតពីភាគីម្ខាង ពេលនោះកិច្ចសន្យាពិតប្រាកដនឹងត្រូវកើតឡើងភ្លាមដោយមិនចាំបាច់មានការយល់ព្រមសាជាថ្មីពីភាគីម្ខាងទៀតនោះឡើយ (មាត្រា ៥៥៦ កថាខ័ណ្ឌទី ១) ។ ចំពោះសេចក្តីថា "កិច្ចសន្យានេះត្រូវបានធ្វើឡើងស្របទៅតាមសេចក្តីនៃការសន្យាគ្នាទុកជាមុនទាំងស្រុង" ក្នុងពាក្យជំនាញគេចែងថា "បំពេញតាមការសន្យា" ហើយហៅភាគីដែលអាចបំពេញតាមកិច្ចសន្យា (អ្នកមានសិទ្ធជំរុញការសន្យាទុកជាមុនឱ្យទៅជាកិច្ចសន្យាពិតប្រាកដ) ថាជា "អ្នកមានសិទ្ធិបំពេញតាមការសន្យា"។

## ១.៣.ប្រាក់កក់

ប្រាក់កក់ គឺជាប្រាក់ឬអ្វីមួយដែលបង់ទុកជាមុន នៅពេលភ្ជាប់កិច្ចសន្យាក្នុងការលក់ដូរជាដើម ។ ឧទាហរណ៍ដូចជាក្នុងការសន្យាទិញវត្ថុតម្លៃ ១ លានរៀល ដែលបានបង់ប្រាក់កក់ចំនួន ១ សែនរៀលជាដើម ។ បញ្ហាគឺនៅត្រង់ថា តើប្រាក់កក់មានមុខងារអ្វីដែរ? ចំពោះប្រាក់កក់នេះ អ្នកព្រាងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន បានពិនិត្យយោងទៅលើទំលាប់ដែលមាននៅក្នុងប្រទេសជប៉ុន ដោយបានចាត់ទុកថាប្រាក់កក់ គឺជាប្រាក់ធានានៅពេលមានការរំលាយកិច្ចសន្យា ។ នៅពេលដែលអ្នកទិញបង់ប្រាក់កក់ទៅឱ្យអ្នកលក់ ក្នុងរយៈវេលាដែលពុំទាន់មានភាគីណាមួយអនុវត្តកិច្ចសន្យានៅឡើយទេនោះ អ្នកទិញអាចរំលាយកិច្ចសន្យាបានដោយបោះបង់ប្រាក់កក់នេះចោល ។ ចំណែកឯអ្នកលក់ក៏អាចរំលាយកិច្ចសន្យាបានដែរ ដោយបង់ប្រាក់ទៅអ្នកទិញក្នុងចំនួនជា ២ ដងលើប្រាក់កក់នេះ (មាត្រា ៥៥៧ កថាខ័ណ្ឌទី ១ ។ ក្នុងករណីនេះ ដោយសារគេចាត់ទុកថាជានីតិវិធីសំរាប់លុបចោលទំនាក់ទំនងនៃកិច្ចសន្យា តាមរយៈនៃការចាត់ចែងចំនួនប្រាក់កក់ ដូច្នេះមិនអាចទទួលយកបានទេចំពោះការទាមទារសំណងខូចខាតដទៃទៀត) ។ ពោលគឺនៅពេលដែលភាគីណាមួយបែកចិត្តលែងចង់បន្តកិច្ចសន្យាតទៅទៀត ទោះបីដោយប្រការណាក៏ដោយ ភាគីនោះគ្រាន់តែបោះបង់ចោល ឬសងប្រាក់កក់នោះជា ២ ដងទៅវិញប៉ុណ្ណោះ គឺគេអាចរំលាយកិច្ចសន្យាចោលបាន ។ មានន័យថា ប្រាក់កក់មានតួនាទី ផ្តល់ឱ្យភាគីនីមួយៗនូវការរក្សាសិទ្ធិក្នុងការរំលាយកិច្ចសន្យា (មាត្រា ៥៤០ កថាខ័ណ្ឌទី ១ ។ គេអាចចែងកំណត់អំពីករណីអ្វីខ្លះ ដែលសិទ្ធិរំលាយកិច្ចសន្យាអាចកើតមានឡើងបាន ដោយផ្អែកលើកិច្ចព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា) ។ ដោយហេតុថា នេះជាបញ្ញត្តិតាមការស្ម័គ្រចិត្ត គេអាចកំណត់លក្ខណៈនៃប្រាក់កក់ផ្សេងពីនេះទៀតក៏បានដែរ (ឧបមាដូចជាថា បើភាគីណាមួយមិនអនុវត្តកិច្ចសន្យា ភាគីម្ខាងទៀតនឹងរឹបអូសប្រាក់កក់ជាដើម) ។ ក៏ប៉ុន្តែយុត្តិសាស្ត្រច្បាប់បានកំណត់ថា ក្នុងករណីដែលមិនអាចកំណត់បានច្បាស់លាស់អំពីលក្ខណៈពិតរបស់ប្រភេទប្រាក់កក់ពិសេសណាមួយទេនោះ តុលាការនឹងសន្មត់ថា ជាប្រាក់សំរាប់ការរំលាយកិច្ចសន្យា (ទោះជាប្រាក់កក់ប្រភេទណាក្តី យ៉ាងហោចណាស់ក៏មានតួនាទីជាភស្តុតាងបញ្ជាក់អំពីការកើតមានកិច្ចសន្យាដែរ ហៅថាប្រាក់កក់សំរាប់បង្ហាញពីកិច្ចសន្យា) ។

## ១.៤.ការទទួលខុសត្រូវក្នុងការធានា

ដោយហេតុថាការទិញលក់ គឺជាកិច្ចសន្យានូវការប្តូរថ្នូរស្មើគ្នារវាងទឹកប្រាក់នឹងវត្ថុ ហើយដោយគិតដល់ភាពស្មើគ្នានៃថ្នូរ ឬភាពយុត្តិធម៌រវាងគូភាគី ក្រមរដ្ឋប្បវេណីបានកំណត់នូវទិដ្ឋភាពផ្សេងៗជាច្រើនស្តីពីការរ៉ាប់រងដែលអ្នកលក់ត្រូវគោរពតាម ។ ការធានារ៉ាប់រងទាំងនេះ ត្រូវអនុវត្តចំពោះករណីផ្សេងៗដូចជា ករណីដែលតាមការពិតចំនួនទាំងមូលឬមានមួយផ្នែកនៃវត្ថុលក់នោះជាកម្មសិទ្ធិរបស់អ្នកដទៃផ្សេងពីអ្នកលក់ពិតប្រាកដ ករណីវត្ថុលក់មិនគ្រប់ចំនួន ឬករណីដែលសិទ្ធិមានជាប់ទៅនឹងវត្ថុនោះមិនមានលក្ខណៈគ្រប់គ្រាន់តាមការដែលគេរំពឹងថាត្រូវមាន ឬករណីដែលអ្នកដទៃបែរជាមានសិទ្ធិប្រើប្រាស់ទៅលើកម្មវត្ថុនៃកិច្ចសន្យានោះ ជាដើម (ពីមាត្រា ៥៦១ ដល់មាត្រា ៥៧២) ។ នៅក្នុងករណីទាំងអស់នេះ អ្នកលក់ត្រូវទទួលខុសត្រូវចំពោះមុខអ្នកទិញក្នុងការបង់សំណងនៃការខូចខាត ឬមួយបើកម្មវត្ថុនៃកិច្ចសន្យាពុំអាចសំរេចជាស្ថាពរបានទេនោះគេត្រូវរំលាយកិច្ចសន្យាចោល ។

ដូចបានពិពណ៌នាខាងលើស្រាប់ យោងតាមក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន ទោះបីវត្ថុនោះជាកម្មសិទ្ធិរបស់អ្នកដទៃសុទ្ធសាធក៏ដោយ ក៏គេអាចធ្វើកិច្ចសន្យាលក់វត្ថុនោះបានដែរ ។ មានន័យថាបើឈ្មោះ B យកវត្ថុរបស់ឈ្មោះ A ទៅធ្វើកិច្ចសន្យាលក់ទៅអោយឈ្មោះ C នោះក៏ជាកិច្ចសន្យាមួយមានសុពលភាពដែរ (គេហៅថាជា ការលក់វត្ថុអ្នកដទៃ) ។ ជាធម្មតាទេដែលថាក្នុងករណីនេះឈ្មោះ B ត្រូវមានកាតព្វកិច្ចទទួលកម្មសិទ្ធិពីឈ្មោះ A មកវិញដើម្បីផ្ទេរទៅឈ្មោះ C (មាត្រា ៥៦០) ។ បើធ្វើយ៉ាងនេះពុំបានទេ ឈ្មោះ B ត្រូវទទួលខុសត្រូវក្នុងការធានា ពោលគឺទទួលករណីកិច្ចរំលាយកិច្ចសន្យាចោល និងបង់សំណងនៃការខូចខាត (មាត្រា៥៦១) ។ ក្រៅពីនេះ ឧទាហរណ៍ដូចជានៅក្នុងផ្ទៃដី ១០០ ម៉ែត្រទ្វេគុណ មានចំនួន ២០ ម៉ែត្រទ្វេគុណជារបស់អ្នកដទៃជាដើម ពោលគឺក្នុងករណីដែលមួយផ្នែកនៃកម្មវត្ថុនៃកិច្ចសន្យាកំពុកតែជាកម្មសិទ្ធិរបស់អ្នកដទៃ អ្នកទិញអាចទាមទារឱ្យកាត់តម្លៃនៃផ្នែកនោះចោលបាន ឬមួយដោយហេតុថាគ្មានន័យនឹងទិញតែផ្នែកដែលសេសសល់នោះទេ អ្នកទិញក៏អាចរំលាយកិច្ចសន្យាចោលបានដែរ (មាត្រា ៥៦៣ កថាខ័ណ្ឌទី ១ និងទី ២ ។ ក្នុងករណីនៃអ្នកទិញសុចរិត គេថែមទាំងអាចទាមទារសំណងនៃការខូចខាតបានទៀតផង (មាត្រាដដែល កថាខ័ណ្ឌទី ៣) ។

ចំពោះករណីនៃតាវកាលិកដែលតម្រូវឱ្យមានសិទ្ធិប្រើប្រាស់ភ្ជាប់ទៅជាមួយ តែបែរជាគ្មានសិទ្ធិនោះទេវិញ ឬផ្ទុយទៅវិញតាវកាលិកនោះត្រូវជាប់សិទ្ធិប្រើប្រាស់របស់អ្នកដទៃ ដែលហៅថាជាវិការៈនៃសិទ្ធិនោះ ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាពុំអាចសំរេចបានដោយសារតែមានវិការៈនៃសិទ្ធិ គេអាចរំលាយកិច្ចសន្យាបាន (ព្រមទាំងទាមទារសំណងនៃការខូចខាតផង) ឬបើពុំនោះទេគេអាចទាមទារសំណងនៃការខូចខាតបាន (មាត្រា ៥៦៦) ។ ជាងនេះទៅទៀត ក្នុងករណីដែលអ្នកទិញត្រូវបាត់បង់កម្មសិទ្ធិ ដោយសារកម្មវត្ថុនៃកិច្ចសន្យាមានភ្ជាប់ហ៊ីប៉ូតេក (សូមអានជំពូកទី ៧ វគ្គ II. ១.១.) ដែលត្រូវបានយកមកអនុវត្ត (លក់ដោយបង្ខំ) ជាធម្មតាទេ អ្នកទិញអាចលុបកិច្ចសន្យាចោលបាន ហើយបើសិនជាមានការខូចខាត គេអាចទាមទារសំណងនៃការខូចខាតបានថែមទៀត (មាត្រា ៥៦៧) ។

ម្យ៉ាងទៀត ដូចបានរៀបរាប់ខ្លះៗរួចមកហើយនៅជំពូកទី១ អំពីសារៈសំខាន់នៃការទទួលខុសត្រូវក្នុងការធានាវិការៈ ក្នុងករណីដែលមានស្នាមឆ្កូត ឬវិការៈបន្តិចនៅលើកម្មវត្ថុនៃកិច្ចសន្យាដែលគេមិនបានចាប់អារម្មណ៍ភ្លាមៗ ។ នេះមានលក្ខណៈខុសគ្នាទៅនឹងការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ព្រោះថាការលក់ដូរគឺសំដៅលើការទូទាត់ថ្នូរស្មើគ្នាទៅវិញទៅមក ដូច្នេះទោះបីជាអ្នកលក់គ្មានចេតនាឬគ្មានកំហុសក្តី ក៏ត្រូវតែទទួលខុសត្រូវដែរ (មានន័យថា អ្នកលក់ត្រូវតែទទួលខុសត្រូវចំពោះស្នាមលើទំនិញ ទោះបីជាអ្នកលក់ខ្លួនឯងពុំបានធ្វើឱ្យមានស្នាម ហើយលក់ដោយពុំបានដឹងថាមានស្នាមក៏ដោយ) ។ ក្នុងករណីនេះ អ្នកទិញអាចទាមទារការរំលាយកិច្ចសន្យាឬសំណងនៃការខូចខាតបាបពីអ្នកលក់ ក្នុងរយៈពេល ១ ឆ្នាំ បន្ទាប់ពីបានរកឃើញស្នាមខូចខាតដែលមានលាក់បាំងនោះ (អនុវត្តតាមមាត្រា ៥៦៦ ដូចមានកំណត់ដោយមាត្រា ៥៧០ នៃក្រមរដ្ឋប្បវេណី) ។ ចំពោះការទទួលខុសត្រូវក្នុងការធានាវិការៈនេះ ភាគីទាំងសងខាងអាចធ្វើកិច្ចសន្យាពិសេសបាន ដើម្បីបន្ថយរយៈពេលត្រូវធានា ឬសន្យាថាមិនទទួលខុសត្រូវក៏បានដែរ កុំឱ្យតែមានការផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អនៅក្នុងសង្គម។

## ២. កិច្ចសន្យាប្រទានកម្ម

### ២.១.កំណត់សំគាល់ទូទៅ

កិច្ចសន្យាប្រទានកម្ម គឺជាកិច្ចសន្យាមួយតំណាងឱ្យកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ហើយជាកិច្ចសន្យាឯកតោភាគី ។ ដោយហេតុថាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ដូចកិច្ចសន្យាប្រទានកម្មនេះនាំឱ្យមានការខាតបង់ទៅលើភាគីអ្នកធ្វើអំណោយតែម្ខាងទេនោះ មានប្រទេសជាច្រើននិយមចាត់ទុកនេះជា កិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ ឬកិច្ចសន្យាតាមទម្រង់កំណត់ ក្នុងគោលបំណងកុំឱ្យមានការថ្វេះធ្វេយក្នុងការធ្វើកិច្ចសន្យា ។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន ចាត់ទុកកិច្ចសន្យានេះថា ជាកិច្ចសន្យាត្រឹមការព្រមព្រៀង ប៉ុន្តែក្នុងករណីសន្យាគ្នាដោយផ្ទាល់មាត់ មិនមានសរសេរជាលាយលក្ខអក្សរទេនោះ ច្បាប់បានកំណត់ថាកិច្ចសន្យាបានកើតមានឡើងមែន តែអាចលុបចោលវិញបានប្រសិនបើនៅមិនទាន់បានអនុវត្តនៅឡើយទេនោះ (មាត្រា ៥៥០)។ ពាក្យថាលុបចោលនេះមានន័យត្រឹមតែការដកកិច្ចសន្យាចេញវិញតែប៉ុណ្ណោះ ពុំមែនសំដៅទៅលើការលុបចោលដែលមានអានុភាពប្រត្តិសកម្មពាក់ព័ន្ធទៅដល់អតីតកាលនោះទេ ។ ជាគោលការណ៍ ចំពោះកិច្ចសន្យាប្រទានកម្មនេះ គេមិនតម្រូវឱ្យទាយកទទួលខុសត្រូវក្នុងការធានាវិការៈ នៅលើកម្មវត្ថុនៃកិច្ចសន្យានោះទេ ក៏ប៉ុន្តែបើទាយកដឹងជាមុនថាវត្ថុនោះមានវិការៈដែរ ហើយនៅតែឱ្យវត្ថុដោយគ្មានប្រាប់ឱ្យគេដឹងអំពីវិការៈនោះ ច្បាប់តម្រូវឱ្យទាយកទទួលខុសត្រូវក្នុងការធានា ចំពោះតែចំណែកនៃការខូចខាតណាដែលកើតមានមកពីការជឿទុកចិត្តប៉ុណ្ណោះ។

### ២.២.ប្រទានកម្មពិសេសផ្សេងៗ

#### ២.២.១.ប្រទានកម្មដែលមានជាប់បន្ទុក

នេះក៏ជាប្រភេទកិច្ចសន្យាដែលមិនយកតម្លៃថ្នូរដែរ ក៏ប៉ុន្តែដោយមានភ្ជាប់នូវបន្ទុកអ្វីមួយតម្រូវឱ្យអ្នកទទួលអំណោយ (បដិគាហក) ប្រតិបត្តិតាមនោះ គេហៅកិច្ចសន្យាបែបនេះថាជា កិច្ចសន្យាប្រទានកម្មដែលមានជាប់បន្ទុក ។ ឧទាហរណ៍ដូចជាការសន្យាថា "នឹងប្រគល់អំណោយជាដីក្នុងតម្លៃប្រមាណ ១០០ លានយ៉េនឱ្យទៅអ្នក ប៉ុន្តែទាល់តែអ្នកថែទាំបោសសំអាតផ្នូរដូនតា

ហើយធ្វើបុណ្យរាល់ឆ្នាំផង" ជាដើម ។ នៅក្នុងករណីនេះ ដោយសារតែមានការកំណត់នូវបន្ទុកដែលបដិគាហកត្រូវទទួលយកជាថ្នូរនោះ ច្បាប់ចាត់ទុកកិច្ចសន្យានេះថាមានលក្ខណៈជា កិច្ចសន្យាអញ្ញមញ្ញ (ដែលយកតម្លៃថ្នូរ) ។ យោលទៅលើការកំណត់នូវបន្ទុកនេះ ច្បាប់បានតម្រូវឱ្យទាយកទទួលខុសត្រូវក្នុងការធានា ដូចភាគីអ្នកលក់នៅក្នុងការទិញលក់ដែរ (មាត្រា ៥៥១ កថាខ័ណ្ឌទី ២) ហើយបានកំណត់ឱ្យយកបទបញ្ញត្តិស្តីពីកិច្ចសន្យាអញ្ញមញ្ញ មកអនុវត្តចំពោះករណីនេះដែរ (មាត្រា ៥៥៣) ។

## ២.២.២. ប្រទានកម្មដោយមូលហេតុមរណៈភាព

ប្រទានកម្មដែលបានមកដោយសារមរណភាពរបស់ទាយកហៅថាជា ប្រទានកម្មដោយមូលហេតុមរណៈភាព ។ ឧទាហរណ៍ដូចជា កិច្ចសន្យាដែលទាយក បានធ្វើកាលនៅរស់រានថា "យើងនឹងប្រគល់ដីធ្លីនេះដល់ឯងនៅពេលយើងស្លាប់" ហើយបដិគ្គាហកតបថា "ខ្ញុំនឹងទទួលដោយក្តីរីករាយ" ជាដើម។ នៅមានរបៀបធ្វើប្រទានកម្មស្រដៀងនឹងកិច្ចសន្យាប្រភេទនេះដែរ គឺទាយកសរសេរទុកនៅក្នុងមតិកសាសន៍របស់ខ្លួនថា "ដីនេះនឹងប្រគល់ឱ្យទៅអ្នកនេះ ឬអ្នកនោះ"ជាដើម (សូមអានជំពូកទី ៩ វគ្គទី II. ៤.២.) ។ នេះគឺជាសកម្មភាពដោយបុគ្គលណាម្នាក់ឯង ដើម្បីធ្វើឱ្យកើតមានឡើងនូវអានុភាពនៃប្រទានកម្ម អាស្រ័តលើការបង្ហាញឆន្ទៈជាឯកតោភាគី ។ ភាគីម្ខាងទៀតពុំបានដឹងអ្វីសោះឡើយ ។ ប្រទានកម្មដោយមូលហេតុមរណៈភាព និងអច្ច័យទាន មានលក្ខណៈកតិយុត្តខុសគ្នា ក៏ប៉ុន្តែមានមុខនាទីស្រដៀងគ្នាច្រើន។ ហេតុដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបានកំណត់ឱ្យយកបទបញ្ញត្តិស្តីពីអច្ច័យទាន មកអនុវត្តដូចគ្នាដែរចំពោះប្រទានកម្មដោយមូលហេតុមរណៈភាពផងដែរ បើសិនជាមិនមានការផ្ទុយនឹងលក្ខណៈនៃប្រទានកម្មនោះ (មាត្រា ៥៥៤) ។ ប៉ុន្តែដោយហេតុថាអច្ច័យទានត្រូវផ្អែកលើមតិកសាសន៍ ហើយអាស្រ័យលើបញ្ញត្តិនៃមតិកសាសន៍នោះ (ដើម្បីឆ្លុះបញ្ចាំងនូវឆន្ទៈចុងក្រោយរបស់មតិកជន) អច្ច័យទានអាចត្រូវបានសរសេរកែប្រែប៉ុន្មានដងក៏បានដែរ។ រីឯប្រទានកម្មដោយមូលហេតុមរណៈភាពវិញ ជាកិច្ចសន្យាដែលមានភាគីជាដៃគូ ធ្វើអោយភាគីជាដៃគូនោះជឿជាក់ថា ខ្លួនប្រាកដជានឹងបានទទួលប្រទានកម្មនោះ ។ ប៉ុន្តែយុត្តិសាស្រ្តច្បាប់ និងទ្រឹស្តីសិក្សាជាទូទៅ ចាត់ទុកថា ចំពោះប្រទានកម្មដោយមូលហេតុមរណៈភាព ទាយកអាចដកកិច្ចសន្យារបស់ខ្លួនចេញបានដោយសេរី។ ក៏ប៉ុន្តែក្នុងករណី

ដែលកិច្ចសន្យានៃប្រទានកម្មដោយមូលហេតុមរណៈភាពនេះមានជាប់បន្ទុក (កិច្ចសន្យាប្រទានកម្មដោយមូលហេតុមរណភាពដែលមានជាប់បន្ទុក) ដែលបដិគាហកបានបំពេញរួចហើយនោះ យុត្តិសាស្ត្រច្បាប់បានបញ្ជាក់ថា ជាគោលការណ៍គេមិនអាចដកកិច្ចសន្យានេះចេញវិញបានទេ (ឧទាហរណ៍ ក្នុងករណីដែលកិច្ចសន្យាបានចែងថា "បើឯងចេញប្រាក់ជួយចិញ្ចឹមយើងរាល់ឆ្នាំរហូតដល់ឯងចូលនិវត្តនោះ ពេលយើងស្លាប់ទៅយើងនឹងឱ្យដីយើងនេះដល់ឯង" អាស្រ័យហេតុនេះ ភាគីជាបដិគាហកបានចំណាយប្រាក់ជួយចិញ្ចឹមទាយករៀងរាល់ឆ្នាំ តាមពាក្យសន្យារហូតដល់ទីបញ្ចប់មែននោះ ទាយកមិនអាចដកប្រទានកម្មដោយមូលហេតុមរណៈភាពនេះបានទៀតទេ) ។

## ៣. ភតិសន្យា

### ៣.១.កំណត់សំគាល់ទូទៅ

កិច្ចសន្យាស្តីពីការបង់ថ្លៃឈ្នួលដើម្បីជួលវត្ថុហៅថា ភតិសន្យា ។ កិច្ចសន្យានេះក៏ជាកិច្ចសន្យាអញ្ញមញ្ញ ដែលយកតម្លៃថ្នូរ និងជាកិច្ចសន្យាត្រឹមការព្រមព្រៀងដែរ ក៏ប៉ុន្តែមិនមែនធ្វើតែមួយលើកចប់សព្វគ្រប់ដូចកិច្ចសន្យាលក់ទេ ផ្ទុយទៅវិញគឺជាកិច្ចសន្យាដែលបន្តក្នុងមួយរយៈពេលកំណត់ ហើយនៅពេលអនុវត្តសិទ្ធិជួលវត្ថុនេះទៀតសោត ក្រៅពីសិទ្ធិទាមទារឱ្យផ្តល់នូវវត្ថុជួល នៅមានសិទ្ធិប្រើប្រាស់វត្ថុជួលនេះថែមទៀត ។ នេះគឺជាលក្ខណៈពិសេសនៃ ភតិសន្យា ។ ត្រង់ចំណុចនេះ ក្រៅពីលក្ខណៈជាសិទ្ធិលើបំណុល សិទ្ធិជួលក៏មានលក្ខណៈជាសិទ្ធិប្រត្យក្សផងដែរ ។ ក្នុងន័យនេះហើយ ដែលសិទ្ធិជួលអចលនទ្រព្យអាចចុះបញ្ជីបាន ។ ច្បាប់បានការពារសិទ្ធិជយលនេះដោយកំណត់ថា កាលណាបានចុះបញ្ជីហើយ ទោះបីជាម្ចាស់នៃអចលនទ្រព្យត្រូវបានផ្លាស់ប្តូរក៏ដោយ ក៏គេអាចលើកយកសិទ្ធិជួលមកតតាំងបានដែរ (មាត្រា ៦០៥) ។ ក៏ប៉ុន្តែនៅក្នុងសភាពជាក់ស្តែង ដោយហេតុថាជាទូទៅពុំសូវមានកិច្ចសហប្រតិបត្តិការពីភតិបតីទេ ក្នុងការចុះបញ្ជីនេះ ដូច្នេះបទបញ្ញត្តិនេះកម្របានយកមកអនុវត្តន៍ណាស់ (មានវិធីការពារផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ពិសេសផ្សេងវិញ) ។ សិទ្ធិជួលមានលក្ខណៈខុសគ្នាទៅសិទ្ធិលើផ្ទៃដី ដែលជាសិទ្ធិប្រត្យក្ស នៅត្រង់ថា ច្បាប់មិនទទួលស្គាល់សិទ្ធិរបស់ភតិកៈក្នុងការផ្ទេរសិទ្ធិ ឬជយលបន្ត ដោយសេរីនោះទេ ។ បើចង់ផ្ទេរសិទ្ធិ ឬជួលបន្តគឺត្រូវមានការយល់ព្រមពីភតិបតី (មាត្រា ៦១២

កថាខ័ណ្ឌទី ១)។ បើមិនធ្វើដូច្នេះទេ ម្ចាស់កម្មសិទ្ធិអាចលុបកិច្ចសន្យាចោលបាន (មាត្រាដដែល កថាខ័ណ្ឌទី ២) ។ ក៏ប៉ុន្តែ ដើម្បីការពារកុំឱ្យម្ចាស់កម្មសិទ្ធិអនុវត្តបញ្ញត្តិច្បាប់នេះដោយបំពាននោះ យុត្តិសាស្ត្រច្បាប់បានកំណត់ ការលុបកិច្ចសន្យានេះឱ្យនៅត្រឹមករណីដែលមានការផ្ទេរសិទ្ធិ ឬជួលបន្ត ដោយគ្មានការអនុញ្ញាត្តិ ហើយដែលអាចធ្វើឱ្យបាត់បង់ជមនឿទុកចិត្តគ្នាទៅវិញទៅមកបានរវាងភតិកៈនិងភតិបតីតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ដោយហេតុថាកិច្ចសន្យាជួលជាកិច្ចសន្យាដែលមានរយៈវេលាបន្តនោះ ការរំលាយកិច្ចសន្យានេះ មិនមានអានុភាពប្រតិសកម្មទៅលើអតីតកាលទេ គឺគ្រាន់តែអស់សុពលភាពសំរាប់អនាគតកាលតែប៉ុណ្ណោះ ។

## ៣.២.ករណីកិច្ចរបស់ភតិកៈ និងករណីកិច្ចរបស់ភតបតី

ភតិកៈមានករណិយកិច្ចត្រូវបង់ថ្លៃឈ្នួលជាថ្នូរចំពោះការប្រើប្រាស់ ត្រូវប្រើប្រាស់វត្ថុដោយផ្អែកទៅតាមវិធីប្រើប្រាស់ ហើយមានករណីយកិច្ចត្រូវប្រគល់វត្ថុវិញនៅពេលបញ្ចប់កិច្ចសន្យា ។ ទន្ទឹមនឹងពេលនោះ ភតិបតីមានករណីយកិច្ចត្រូវជួលឱ្យបានជាប់លាប់ នូវវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ក្នុងស្ថាភាពមួយដែលសំរួលដល់ការប្រើប្រាស់និងអាស្រ័យផលស្របតាមអត្ថន័យដើមនៃកិច្ចសន្យា ។ ដូច្នេះ ប្រសិនបើមានទឹកភ្លៀងជ្រាបចូលផ្ទះដែលជាកម្មវត្ថុនៃការជួលនោះ ភតិបតីមានករណីយកិច្ចត្រូវជួលជុល (មាត្រា ៦០៦) ។ ក្នុងករណីដែលភតិកៈបានចេញថ្លៃជួលជុលនេះហើយ គឺភតិកៈអាចទាមទារភ្លាមឱ្យភតិបតីសងប្រាក់ចំណាយនោះមកវិញបាន ដោយសារភតិបតីជាអ្នកទទួលបន្ទុកលើសោហ៊ុយចាំបាច់នេះ (មាត្រា ៦០៨ កថាខ័ណ្ឌទី ១ ។ បើសិនជាសោហ៊ុយមានចំនួនលើសពីចំណាយចាំបាច់ទៅទៀត ឧទាហរណ៍ដូចជាករណីដែលប្រាក់នោះបានក្លាយទៅជាចំណាយដែលជួយបង្កើនតម្លៃនៃផ្ទះដោយសារការកែលំអជាដើម ហើយបើសិនជាកំណើនតម្លៃនោះនៅតែមានជាបន្តនៅពេលដែលបញ្ចប់ការជួល ភតិកៈអាចទាមទារបានឱ្យមានការសងនៅពេលដែលបញ្ចប់កិច្ចសន្យា (មាត្រាដដែល កថាខ័ណ្ឌទី ២) ។

## ៣.៣. ការការពារភតិកៈ

ការជួលផ្ទះ ឬការជួលដីដើម្បីអាស្រ័យនៅក៏ត្រូវបានហៅសរុបថា ការជួល ដែរ ។ ដោយយល់ឃើញថាបទបញ្ញត្តិទាំងឡាយនៅក្នុងក្រមរដ្ឋប្បវេណី ទាក់ទងនឹងការជួលនេះ សំដៅជាទូទៅលើកិច្ចសន្យាជួលវត្ថុមកប្រើប្រាស់ដោយបង់ប្រាក់ឈ្នួល ហើយទាំងរយៈពេលជួលក្ដី ទាំងចំណុចផ្សេងៗជាច្រើនទៀតក្ដី មានលក្ខណៈធ្វើឱ្យភតិកៈចាញ់ប្រៀបខ្លាំងនោះ នៅឆ្នាំ ១៩២១ ច្បាប់ពិសេសបានត្រូវបង្កើតឡើង គឺច្បាប់ស្ដីពីការជួលដីនិងច្បាប់ស្ដីពីការជួលផ្ទះ។ ច្បាប់ស្ដីពីការជួលដីត្រូវអនុវត្តទៅលើបណ្ណាផលុបភោគ និងសិទ្ធិជួលអចលនទ្រព្យក្នុងគោលបំណងទទួលកម្មសិទ្ធិលើសំណង់ ។ រីឯច្បាប់ស្ដីពីការជួលផ្ទះត្រូវអនុវត្តទៅលើសិទ្ធិជួលសំណង់និងផ្ទះសំបែង ។ ច្បាប់ពិសេសទាំងពីរនេះ ត្រូវបានធ្វើវិសោធនកម្មជាថ្មីបន្តមកទៀត ធ្វើឱ្យមានការការពារអ្នកសុំជួលដីនិងអ្នកសុំជួលផ្ទះយ៉ាងខ្លាំង រួចហើយក្រោយសង្គ្រាមលោកលើកទី២ នៅពេលដែលកើតមានបញ្ហាចោទពីការខ្វះផ្ទះសំបែងសំរាប់ប្រជារាស្ត្ររស់នៅ គោលការណ៍ច្បាប់ដែលបានកំណត់តាមរយៈយុត្តិសាស្ត្រ ក៏បានបែរមុខព្រួញទៅរកការធ្វើយ៉ាងណាឱ្យភតិបតី ពិបាកនឹងរំលាយកិច្ចសន្យាផងដែរ ។ ការនេះបានឆ្លុះបញ្ចាំងឱ្យឃើញនូវស្ថានភាពសង្គមនាសម័យនោះ ។ ក៏ប៉ុន្តែដំណើរការនេះបានធ្វើឱ្យភាគីភតិបតី ពិបាកនឹងបញ្ចប់កិច្ចសន្យាណាស់ ប្រសិនបើខ្លួនពុំអាចលើកហេតុផលមកបញ្ជាក់ឱ្យបានច្បាស់លាស់មែនទែន ថាខ្លួនត្រូវការយកអចលនវត្ថុមកវិញសំរាប់ប្រើប្រាស់ទេនោះ ។ សព្វថ្ងៃនេះមានលេចចេញនូវមតិដែលយល់ថា ច្បាប់នេះមានការតឹងតែងទៅលើភតិបតិជ្រុលពេក ។ ដូច្នេះហើយបានជាច្បាប់វិសោធនកម្មថ្មីស្ដីពីការជួលផ្ទះ ដែលអនុម័តនៅឆ្នាំ ១៩៩១ បានពិនិត្យបញ្ហានេះឡើងវិញ ដោយបញ្ចូលនូវរបបជួយសំរួលផលប្រយោជន៍ដល់ភតិបតីផងដែរ ដូចជាការកំណត់ថា ក្នុងករណីបើគូភាគីបានដាក់រយៈពេលជួលចាប់ពី ៥០ ឆ្នាំឡើងទៅ គឺសិទ្ធិរបស់ភតិកៈត្រូវរលត់អស់នៅពេលដែលផុតរយៈកាលជួល ៥០ ឆ្នាំនេះ ហើយក៏គ្មានការបន្តកិច្ចសន្យានេះសារជាថ្មីឡើងវិញដែរ ។ នេះគេហៅថា ជាសិទ្ធិជួលដីមានកំណត់អំឡុងពេល (មាត្រា ២២ ច្បាប់ស្ដីពីការជួលដីនិងជួលផ្ទះ) ។ ក៏ប៉ុន្តែ ច្បាប់ថ្មីនេះអនុវត្តតែទៅលើភតិសន្យាទាំងឡាយណាដែលបានធ្វើក្រោយការអនុម័តច្បាប់ថ្មីនេះតែប៉ុណ្ណោះ ចំពោះកិច្ចសន្យាមុនៗគេត្រូវអនុវត្តច្បាប់ចាស់ស្ដីពីការជួលដី និងច្បាប់ចាស់ស្ដីពីការជួលផ្ទះនោះដដែល ។

## ៤. កិច្ចសន្យាខ្ចីប្រើ

ដែលហៅថាការឱ្យខ្ចីប្រើ គឺជាការប្រគល់វត្ថុឱ្យប្រើដោយមិនទារថ្លៃ ឬតាវកាលិកអ្វីមកពីការប្រើប្រាស់វត្ថុដែលបានឱ្យខ្ចីនោះទេ ពោលគឺជាការឱ្យខ្ចីវត្ថុប្រើប្រាស់ដោយឥតយកថ្លៃ។ ដូច្នេះ អ្នកខ្ចីដែលប្រើប្រាស់វត្ថុដោយឥតបង់ថ្លៃជាអ្នកទទួលផលតែម្នាក់ឯង។ អាស្រ័យហេតុនេះ កិច្ចសន្យានេះជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ និងជាកិច្ចសន្យាឯកតោភាគី ដែលមិនអាចធ្វើឡើងដោយការសន្យាផ្ទាល់មាត់បានទេ តោងធ្វើជាកិច្ចសន្យាតម្រូវការប្រគល់វត្ថុដែលនឹង មានសុពលភាពនៅពេលបានឱ្យខ្ចីវត្ថុសំរាប់ប្រើប្រាស់ពិតប្រាកដមែន (មាត្រា ៥៩៣)។ ចំពោះការ ឱ្យខ្ចីប្រើនេះ ច្បាប់បានកំណត់ឱ្យយកបទបញ្ញត្តិស្ដីពីប្រទានកម្ម មកអនុវត្តសំរាប់ការទទួលខុសត្រូវក្នុងការធានា (មាត្រា ៥៩៦) ។ ហើយដើម្បីការពារអ្នកឱ្យខ្ចីប្រើ (ម្ចាស់វត្ថុ) ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា នៅក្នុងករណីនៃកិច្ចសន្យាដែលពុំមានកំណត់អំឡុងពេលឱ្យខ្ចីប្រើប្រាស់ទេ អ្នកខ្ចីប្រើមានកាតព្វកិច្ចនឹងបង្វិលវត្ថុដែលខ្ចីប្រើនោះ ទៅម្ចាស់ដើមវិញជាបន្ទាន់ បន្ទាប់ពីបានសំរេចគោលបំណងហើយ ។

## ៥. កិច្ចសន្យាខ្ចីបរិភោគ

ដែលហៅថាការឱ្យខ្ចីបរិភោគ គឺជាកិច្ចសន្យាដែលតម្រូវឱ្យប្រគល់ត្រឡប់មកវិញនូវវត្ថុ ដែលមានប្រភេទដូចគ្នា គ្រប់ចំនួន និងមានគុណភាពស្មើទៅនឹងវត្ថុដែលបានឱ្យខ្ចី បន្ទាប់ពីវត្ថុឱ្យខ្ចីនោះត្រូវបានប្រើប្រាស់អស់ទៅហើយ។ ឧទាហរណ៍ដូចជាការខ្ចីអង្ករបស់អ្នកជិតខាងយកមកបរិភោគរួចហើយសងអង្ករផ្សេងវិញ ឬការខ្ចីប្រាក់ចាយហើយសងវិញជាដើម ។ ការខ្ចីប្រាក់ពីធនាគារត្រូវបានចាតទុកថាជាកិច្ចសន្យាខ្ចីបរិភោគ។ ចំពោះការខ្ចីបរិភោគដែលតម្រូវឱ្យប្រគល់វត្ថុដែលមានប្រភេទដូចគ្នា គ្រប់ចំនួន ស្មើគុណភាព ដោយគ្មានបង់ការប្រាក់នោះ ក្រមរដ្ឋប្បវេណីកំណត់ថាជាកិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ។ ក៏ប៉ុន្តែចំពោះកិច្ចសន្យា ដែលមានភ្ជាប់នូវការប្រាក់ដូចជាការខ្ចីប្រាក់ពីធនាគារជាដើមវិញ យើងយល់ថា មានលទ្ធភាពអាចបកស្រាយបានថាជាកិច្ចសន្យាត្រឹមការព្រមព្រៀង។

ទាក់ទងនឹងអត្រានៃការប្រាក់សំរាប់ការខ្ចីបរិភោគមានការប្រាក់ ច្បាប់ស្តីពីការកម្រិតការប្រាក់បានកំណត់អត្រាជាអតិបរិមានៃការប្រាក់ ។ រាល់ការសន្យានូវការប្រាក់ដែលមានអត្រាហួសពីការកំណត់នោះ ចំណែកលើសនោះត្រូវចាត់ទុកជាមោឃៈ (ចំណែកដែលមានក្នុងវង្វង់នៃការកំណត់ត្រូវមានសុពលភាពដដែល) ។ ប៉ុន្តែ ចំពោះការខ្ចីប្រាក់បរិភោគដែលជាមុខរបររបស់អ្នកធ្វើអាជីវកម្មប្រាក់កំចីនោះ ត្រូវផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មឱ្យប្រាក់កំចី ។ ហើយតាមពិតគេបានទទួលស្គាល់នូវអត្រានៃការប្រាក់ដែលកំណត់ដោយច្បាប់នេះ ក្នុងអត្រាខ្ពស់ជាងការកំណត់នៃច្បាប់ស្តីពីការកម្រិតការប្រាក់នោះ ។

# ៦. កិច្ចសន្យាម៉ៅការ

## ៦.១.កំណត់សំគាល់ទូទៅ

កិច្ចសន្យាជួលជាងឱ្យសង់ផ្ទះជាដើមហៅថា កិច្ចសន្យាម៉ៅការ ។ គោលបំណងនៃកិច្ចសន្យាប្រភេទនេះមានលក្ខណៈពិសេសត្រង់ថា វាមិនមែនជាការផ្តល់នូវកម្លាំងធ្វើការងារសុទ្ធសាធទេ គឺជាការសន្យាបំពេញដោយពេញលេញនូវកិច្ចការអ្វីមួយ។ នេះជាកិចសន្យាដែលយកតម្លៃថ្នូរអប្បាមញ្ញ និងជាកិច្ចសន្យាត្រឹមការព្រមព្រៀង ។ ការបង់កម្រៃត្រូវធ្វើឡើងព្រមពេលជាមួយនឹងការប្រគល់តាវកាលិក (មាត្រា ៦៣៣) ។ ការជួលតន្ត្រីករឱ្យប្រគុំភ្លេងក៏ស្ថិតនៅក្នុងប្រភេទម៉ៅការនេះដែរ ។ ប៉ុន្តែចំពោះការងារដែលមិនមានវត្ថុសំរបស់ប្រគល់នេះ ការបង់កម្រៃត្រូវធ្វើឡើងបន្ទាប់ពីការងារបានធ្វើចប់ (មាត្រា ៦៣៣ បដិញ្ញា) ។ ចំពោះការជួលឱ្យសង់សំណង់ជាដើមដែលមានការចាប់ផ្តើមពីការចាក់គ្រឹះឡើងទៅនោះ ច្បាប់មានកំណត់នូវបញ្ញត្តិដោយឡែកសំរាប់វិធីលុបចោល ឬការទទួលខុសត្រូវក្នុងការធានា ។ (លិខិតស្នាមជាកិច្ចសន្យាគំរូ ដែលមជ្ឈដ្ឋានក្រុមហ៊ុនសំណង់កំពុងប្រើប្រាស់ ត្រូវបានធ្វើឡើងដោយយោងទៅលើវិធានទាំងនោះ)។

## ៦.២.ការទទួលខុសត្រូវក្នុងការធានាវិការៈ

ប្រសិនបើមានវិការៈនៅលើការងាររបស់ខ្លួន ភាគីម៉ៅការត្រូវទទួលខុសត្រូវក្នុងការធានា ចំពោះវិការៈនេះ ដែលក្រមរដ្ឋប្បវេណីបានកំណត់ជាពិសេសសំរាប់កិច្ចសន្យានេះតែម្តង ខុសគ្នាពី បទបញ្ញត្តិស្តីពីការធានារ៉ាប់រងនៅក្នុងការលក់ដូរ។ ចំណុចខុសគ្នាពីការទទួលខុសត្រូវក្នុងការធានា ចំពោះវិការៈ នៅក្នុងការលក់ដូរមានដូចតទៅ:

**ក.** មិនកំណត់ត្រឹមតែវិការៈអាថ៌កំបាំងដែលមិនបានដឹងនោះទេ (មាត្រា៦៣៤-មាត្រា៦៣៦)

**ខ.** ម្ចាស់ការមានសិទ្ធិទាមទារឱ្យជួសជុលវិការៈ (មាត្រា ៦៣៤ ។ ចំពោះ ការលក់ទិញ យើងឃើញមានការបកស្រាយទទួលស្គាល់ចំណុចនេះដែរ តែពុំឃើញមានចែងនៅក្នុងមាត្រា ទេ)។

**គ.** អ្នកម៉ៅការមិនទទួលខុសត្រូវក្នុងការធានាទេ ក្នុងករណីដែលការខូចខាតនេះកើតមានឡើង ដោយ សារ សម្ភារៈដែលម្ចាស់ការផ្តល់ឱ្យសំរាប់ការសាងសង់នោះ មានគុណភាពមិនល្អជាដើម (មាត្រា ៦៣៦) ។

**ឃ.** ចំពោះកិច្ចសន្យាម៉ៅការសង់អាគារ និងសំណង់ទាំងឡាយនៅលើផ្ទៃដី ដោយសារ អានុភាពនៃការទទួលខុសត្រូវក្នុងការធានានោះ ម្ចាស់ការពុំមានសិទ្ធិនឹងរំលាយ កិច្ចសន្យា ចោលទេ(មាត្រា ៦៣៥ បដិបញ្ញា)។ នេះគឺមកពីមូលហេតុថា ប្រសិនបើមានការរំលាយ កិច្ចសន្យា នោះនឹងនាំឱ្យមានកាតព្វកិច្ចធ្វើបដិទានឡើងវិញ ដូចជាត្រូវជីកគាស់គ្រឹះសំណង់ ចេញ ហើយលប់ដីឱ្យដូចដើម វិញជាដើម ដែលបង្កនូវការចំណាយសោហ៊ុយច្រើនឥតគណនា ។ ដូច្នេះហើយបានជាដោះស្រាយត្រឹមតែទាមទារឱ្យជួសជុល និង ទាមទារសំណងនៃការ ខូចខាត តែប៉ុណ្ណោះ ។

**ង.** ការធានារ៉ាប់រងនេះមានរយៈវេលាវែង ។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន បានកំណត់ថា ចំពោះកិច្ចសន្យាម៉ៅការធម្មតា ការធានារ៉ាប់រងនេះ មានរយៈវេលា១ឆ្នាំ បន្ទាប់ពីថ្ងៃប្រគល់ លទ្ធផលឱ្យហើយ (ចំពោះការប្រគុំភ្លេងដែលជាការងារអរូបីជាដើម ការធានារ៉ាប់រងមាន រយៈវេលា១ឆ្នាំចាប់ពីការងារប្រគុំភ្លេងបានចប់សព្វគ្រប់ហើយ) (មាត្រា៦៣៧) ក៏ប៉ុន្តែចំពោះ កិច្ចសន្យាម៉ៅការ ដូចជាការងារសង់សំណង់ជាដើម ការធានារ៉ាប់រងទៅលើគំរោងសំណង់ ឬ

ទៅលើផ្ទៃដី (ដូចជាស្រុតដីជាដើម) មានរយៈវេលា៥ឆ្នាំ ហើយការធានារ៉ាប់រងទៅលើសំណង់ជាប់មាំ តួយ៉ាងដូចជាអាគារសង់អំពីថ្មជាដើមមានរយៈវេលា១០ឆ្នាំ (មាត្រា ៦៣៨ កថាខ័ណ្ឌទី ១) ។ នេះគឺមកពីការយល់ថាការរកឃើញវិការៈ (ស្នាមប្រេះខូចខាតជាដើម) នៅលើសំណង់រមែង ប្រើពេលយូរ ។

### ៦.៣. ការរំលាយកិច្ចសន្យា

លក្ខណៈពិសេសនៃការរំលាយកិច្ចសន្យាម៉ៅការគឺ ម្ចាស់ការ (ម្ចាស់សំណង់ជាដើម) អាចរំលាយកិច្ចសន្យាបានគ្រប់ពេលទាំងអស់ នៅក្នុងរយៈវេលាដែលម៉ៅការនោះពុំទាន់ចប់សព្វគ្រប់នៅឡើយ ដោយបង់សំណងនៃការខូចខាតទៅឱ្យអ្នកម៉ៅការ (មាត្រា ៦៤១)។ នេះគឺមកពីមានការគិតគូរដល់ករណីដែលម្ចាស់ស្រាប់លែងត្រូវការការងារមៅការ បន្ទាប់ពីបានជួលមៅការហើយនោះ ម្ចាស់ការអាចរំលាយកិច្ចសន្យានេះបាន ឱ្យតែបានសងសំណងនៃការខូចខាតដែលកើតមាន ដល់អ្នកម៉ៅការនោះ ។

## ៧. កិច្ចសន្យាអាណត្តិ

### ៧.១. កំណត់សំគាល់ទូទៅ

អាណត្តិ គឺជាកិច្ចសន្យាពឹងពាក់ជនណាម្នាក់អោយធ្វើអ្វីមួយជំនួសខ្លួន អ្វីដែលពឹងឱ្យធ្វើជំនួសនោះ មិនថាជាសកម្មភាពគតិយុត្ត ដូចជាការជួយធ្វើកិច្ចសន្យា ឬជាអំពើ ជាក់ស្តែងដូច ជាការថែមើលកូនឱ្យនោះ។ នេះជាកិច្ចសន្យាត្រឹមការព្រមព្រៀងដែល គូភាគីឯកភាពគ្នាកំណត់ជាកិច្ចសន្យាដែលយកតម្លៃថ្នូរ ឬមិនយកតម្លៃថ្នូរក៏បានដែរ ។ ជាគោលការណ៍បញ្ហា អាណត្តិនេះអាស្រ័យទៅលើអ្នកទទួលការពឹងពាក់ (អាណត្តិគាហក) ទាំងស្រុងនៅក្នុងការបំពេញ ករណីកិច្ចរបស់ខ្លួន។ ដូចនេះអាណត្តិគាហក ត្រូវតែបំពេញកិច្ចការដោយយកចិត្តទុកដាក់ក្នុងឋានៈជាអ្នកគ្រប់គ្រងសុចរិតត្រឹមត្រូវ ករណីយកិច្ចប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិត) ជាចាំបាច់ (មាត្រា ៦៤៤) ។

កិច្ចសន្យាអាណត្តិ គួរឈរលើមូលដ្ឋានជឿទុកចិត្តគ្នាទៅវិញទៅមក ប៉ុន្តែជាគោលការណ៍ អាណត្តិទាយក អាចរំលាយកិច្ចសន្យានៅពាក់កណ្តាលទីបាន។ ក្នុងករណីនេះ អាណត្តិគាហក អាចទាមទារការសង សោហ៊ុយ ឬកម្រៃដែលមានមកទល់ពេលរំលាយកិច្ចសន្យាបាន (មាត្រា ៦៤៨ កថាខ័ណ្ឌទី ៣)។

ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនចែកអាណត្តិ និងការតំណាងដាច់ដោយឡែកពីគ្នា ប៉ុន្តែនៅ ក្នុងករណីខ្លះអាណត្តិគាហកអាចក្លាយជាអ្នកតំណាងផងដែរក៏មាន ។

យើងបានសិក្សារួចមកហើយ កិច្ចសន្យាអាណាព្យាបាលតាមការស្ម័គ្រចិត្ត (សូមអានជំពូកទី ២ វគ្គ ២.៣.៣) ដែលយោងតាមច្បាប់ស្តីពីអាណាព្យាបាលតាមការស្ម័គ្រចិត្ត គឺជាកិច្ចសន្យាអាណត្តិ ដែលសាមីខ្លួនផ្តល់សិទ្ធិតំណាងទៅឱ្យអ្នកអាណាព្យាបាលតាមការស្ម័គ្រចិត្ត ដើម្បីជួយក្នុងកិច្ចការគ្រប់គ្រងទ្រព្យសម្បត្តិនិងជីវភាព នៅពេលដែលខ្លួនធ្លាប់ចូលទៅក្នុងស្ថានភាពមិនមានលទ្ធភាពគ្រប់គ្រាន់សំរាប់ធ្វើការវិនិច្ឆ័យដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។ ដូច្នេះ ចំពោះករណីណាដែលមិនមានចែងក្នុងច្បាប់ពិសេសស្តីពអាណាព្យាបាលតាមការស្ម័គ្រចិត្តនោះ គេត្រូវយកបញ្ញត្តិនៃក្រមរដ្ឋប្បវេណីទាក់ទងនឹងកិច្ចអាណត្តិ មកអនុវត្ត ។

## ៧.២. ភាតព្វកិច្ចនៃអាណត្តិទាយក (សិទ្ធិនៃអាណត្តិគាហក)

អាណត្តិគាហក ដែលបានត្រូវគេពឹងពាក់ឱ្យធ្វើអ្វីមួយអាចទាមទារ សោហ៊ុយទាំងឡាយពីអាណត្តិទាយកបាន ក្នុងករណីដែលខ្លួនបានចំណាយ ជាចាំបាច់ទៅលើការរត់ការផ្សេងៗដើម្បីបំពេញកិច្ចការដែលត្រូវបានពឹងពាក់នោះ (មាត្រា៦៥០ កថាខ័ណ្ឌទី ១)។ ដូចគ្នានឹងនេះដែរ ប្រសិនបើក្នុងខណៈបំពេញមុខងារដែលត្រូវបានពឹងពាក់អាណត្តិគាហកត្រូវជំពាក់បំណុលគេជំនួសអាណត្តិទាយកនោះ អាណត្តិគាហកអាចឱ្យអាណត្តិទាយក សងជំនួសខ្លួនបានដែរ (មាត្រាដដែល កថាខ័ណ្ឌទី ២)។ ម្យ៉ាងវិញទៀត ដើម្បីបំពេញមុខងារដែល ត្រូវបានពឹងពាក់ប្រសិនបើ អាណត្តិគាហកត្រូវទទួលការខូចខាតអ្វីមួយដែលមិនមែនមកពីកំហុស ខ្លួននោះ អាណត្តិគាហកក៏ អាចទាមទារឱ្យអាណត្តិទាយកចេញថ្លៃសំណងនៃការខូចខាតនេះបានដែរ (មាត្រាដដែល កថាខ័ណ្ឌទី ៣)។ បើឈរលើគោលជំហររបស់អាណត្តិទាយកវិញ យើងឃើញថាការទទួលនូវកាតព្វកិច្ចសង

សំណងដែលអាណត្តិគាហកបានបង្កើតនេះមានលក្ខណៈជាការទទួល ខុសត្រូវទាំងគ្មានកំហុស។ ក៏ប៉ុន្តែនៅទីនេះអ្វីដែលហៅថាជាការខូចខាតបណ្តាលមកពីការបំពេញមុខងារដែលត្រូវបានពឹងពាក់នោះ គឺមានដូចជាការឆ្លងរោគដោយសារបានទទួលការងារ ថែរក្សាអ្នកជំងឺមានរោគចម្លងជាដើម ពោលគឺដោយហេតុមកពីការងារទទួលនោះជាការងារមានគ្រោះថ្នាក់។ រីឯក្នុងករណីដូចជាត្រូវគេពឹងឱ្យទៅភ្ជាប់កិច្ចសន្យា ហើយនៅពេលកំពុងធ្វើដំណើរ ស្រាប់តែមានគ្រោះថ្នាក់ចរាចរបណ្តាលឱ្យមានរបួសនោះ មិនត្រូវរាប់បញ្ចូលថាជាការទទួលរងនូវ ការខូចខាតទេ។

## ៨. កិច្ចសន្យាបញ្ញើ

កិច្ចសន្យាស្តីពីការផ្ញើវត្ថុសំរាប់រក្សាទុកនោះគេហៅថាជាកិច្ចសន្យាបញ្ញើ។ កិច្ចសន្យានេះនឹងមានសុពលភាពនៅពេលដែលភាគីម្ខាងទៀតបានទទួលវត្ថុដែលខ្លួនបានសន្យាថានឹងយកមកទុកថែរក្សាឱ្យ (មាត្រា ៦៥៧) ពោលគឺជាកិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ ។ អ្នកដែលផ្ញើវត្ថុហៅថា អ្នកផ្ញើ ហើយ អ្នកដែលត្រូវគេផ្ញើវត្ថុនោះហៅថា អ្នកទទួលបញ្ញើ ។ ការផ្ញើនេះមានបញ្ញើដោយមិនយកកម្រៃ និងបញ្ញើដោយឱ្យបង់ថ្លៃ ។ ចំពោះបញ្ញើដោយមិនយកកម្រៃ ច្បាប់បានបញ្ញត្តិអំពីករណីយកិច្ចប្រុងប្រយ័ត្ន ដែលតម្រូវឱ្យអ្នក ទទួលបញ្ញើមានករណីយកិច្ច ប្រុងប្រយ័ត្នរក្សាទុកបញ្ញើនោះ ដោយ"ការយកចិត្តទុកដាក់ដូចគ្នានឹងទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងដូច្នោះ" (មាត្រា ៦៥៩) ។ ការប្រុងប្រយ័ត្ននេះ មានកំរិតទាបជាង"ករណីយកិច្ចប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិត" ដែលមានក្នុងករណីនៃអាណត្តិជាដើម (ចំពោះបញ្ញើដោយឱ្យបង់ថ្លៃវិញ អ្នកទទួលបញ្ញើប្រាកដជាត្រូវមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិតដោយខានមិនបាន) ។

## ៩. កិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុន គឺជាកិច្ចសន្យាបង្កើតជាក្រុម ដែលភាគីទាំងអស់វិនិយោគទ្រព្យធនរៀងៗខ្លួនក្នុងគោលបំណងប្រកបអាជីវកម្មដោយសហការគ្នា ដែលជាហេតុញាំង ឱ្យកិច្ចសន្យានេះមាន សុពលភាព ឡើង (មាត្រា ៦៦៧ កថាខណ្ឌទី ១)។ នៅទីនេះការវិនិយោគទ្រព្យធនមិនសំដៅតែ

ទៅលើការផ្តល់ថវិកាប៉ុណ្ណោះទេ តែក៏អាចជាការផ្តល់នូវកម្លាំងពលកម្មផ្សេងៗផងដែរ (មាត្រា ដដែលកថាខ័ណ្ឌទី ២) ។ ប៉ុន្តែ លក្ខ័ខណ្ឌដែលចាំបាច់នៅក្នុងកិច្ចសន្យា នេះគឺត្រូវតែមានការប្រកប អាជីវកម្មដោយសហការគ្នា ។

លក្ខណៈពិសេសមួយនៃក្រុមហ៊ុន គឺទម្រង់ជាកម្មសិទ្ធិរួមនូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដែលបានមកពីការដាក់ទុកចូលគ្នា ឬក៏បានមកពីការធ្វើលទ្ធកម្មដោយកិច្ចសហការគ្នា ។ បញ្ញត្តិនៃមាត្រា ៦៦៨ កំណត់ថា ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែលបានមកពីការដាក់ទុករបស់សមាជិក ឬវិធីផ្សេងៗ ត្រូវ"ស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងមូល" ។ ប៉ុន្តែ ទ្រឹស្តីសិក្សានាំមុខ ហៅកម្មសិទ្ធិអវិភាគរបស់ក្រុមហ៊ុនថាជា"កម្មសិទ្ធិរួមគ្នា" ។ ប្រសិនបើនេះពិតជានិយមន័យចង្អៀតនៃកម្មសិទ្ធិអវិភាគ ដែលមានន័យថា ម្ចាស់កម្មសិទ្ធិអវិភាគ ម្នាក់ៗមានចំណែករបស់ខ្លួនក្នុងទ្រព្យរួមនោះ ហើយអាចទាមទារយកតែចំណែក របស់ផងខ្លួនចេញមកបាន ។ ក៏ប៉ុន្តែក្នុងករណីក្រុមហ៊ុន សមាជិកម្នាក់ៗមានភាគរបស់ខ្លួននៅក្នុងគណនីតែប៉ុណ្ណោះ មិនអាចនឹងទាមទារឱ្យបែង ចែកបានឡើយ ពីព្រោះលក្ខណៈពិសេសរបស់ក្រុមហ៊ុនទុក ទ្រព្យទាំងអស់នោះជារបស់ក្រុមហ៊ុនទាំងមូល ។ហើយក្នុងករណីដែលក្រុមហ៊ុនទៅធ្វើជំនួញជាមួយអ្នកណាម្នាក់ បានផលអ្វីមួយនោះក៏ដូចគ្នាដែរការទាមទារសិទ្ធិលើបំណុលត្រូវធ្វើឡើងដោយសមាជិកទាំងអស់របស់ក្រុមហ៊ុន ។(សមាជិកណាក៏ដោយមិនអាចទៅទារយកភាគជាចំណែករបស់ខ្លួនបានឡើយ) ។

## ១០. កិច្ចសន្យាតាមបែបផែនដទៃទៀត

កិច្ចសន្យាតាមបែបផែនផ្សេងៗទៀត ដែលក្រមរដ្ឋប្បវេណីបានចែងកំណត់នោះ រួមមានកិច្ចសន្យានៃការដូរគ្នាទៅវិញទៅមកនូវកម្មសិទ្ធិទៅលើវត្ថុក្រៅពីប្រាក់កាស ដែលគេឱ្យឈ្មោះថាកិច្ចសន្យាដូរគ្នា (មាត្រា ៥៨៦ ។ អាចគិតប្រដូចនឹងការទិញនិងលក់ដែលជាការដូរវត្ថុជាមួយ នឹងប្រាក់) កិច្ចសន្យាជួលមនុស្សឱ្យធ្វើការដែលគេហៅថា កិច្ចសន្យាការងារ (មាត្រា ៦២៣ ។ សព្វថ្ងៃនេះ កិច្ចសន្យាការងារនៃក្រុមហ៊ុននានាជាទូទៅធ្វើឡើងដោយយោងតាមច្បាប់ពិសេសផ្សេងៗដែលមានដូចជា ច្បាប់ស្តីពីបទដ្ឋានការងារ ជាដើម ។ ដូច្នេះហើយបទបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីច្រើន តែយកទៅអនុវត្តលើកិច្ចសន្យាជួលអ្នកបំរើឱ្យធ្វើការងារក្នុងផ្ទះតែប៉ុណ្ណោះ ពុំសូវជាមានសារៈ

សំខាន់ទៀតទេ) កិច្ចសន្យាដែលភាគីម្ខាងសន្យាទៅភាគីម្ខាងទៀត ឬ ទៅតតិយជនថា ខ្លួននឹងបង់ប្រាក់ឬវត្ថុអ្វីមួយជាប្រចាំ (រាល់ឆ្នាំ ឬរាល់ខែ) រហូតដល់ភាគីណាមួយនៃកិច្ចសន្យា ទទួលមរណភាពដែលគេហៅថាកិច្ចសន្យាធនលាភសាមយិកមួយជីវិត(មាត្រា៦៨៩ ។ ឧទាហរណ៍ដូចជាទទួលយកប្រាក់ទុនដើម ឬហ៊ុនដើមជាមុន រួចហើយបង់ការប្រាក់ ឬភាគលាភដែលចំណេញនោះជារៀងរាល់ពេលជាដើម ។ នៅប្រទេសជប៉ុនពុំសូវមានការធ្វើកិច្ចសន្យានេះទេ) និងកិច្ចសន្យាដែលភាគីទាំងសងខាងព្រមបញ្ឈប់ជម្លោះជាមួយគ្នា ដោយធ្វើការអត់ឱនឱ្យគ្នា ទៅវិញទៅមកដែលគេហៅថាកិច្ចសន្យាសះជា (មាត្រា ៦៩៥) ។ ចំពោះកិច្ចសន្យាសះជា ភាគីទាំងសងខាងរៀបចំជាមួយគ្នាទៅតាមឆន្ទៈរបស់ខ្លួនក៏មាន ឬក៏ពឹងជំនួយពីចៅក្រម ដោយធ្វើ ទៅតាមការវិនិច្ឆ័យរបស់តុលាការក៏មាន (ម្យ៉ាងទៀត ស្រដៀងគ្នានឹងសះជានេះដែរគឺការដោះស្រាយតាមការជជែកគ្នារវាងភាគីទាំងសងខាង។ ត្រង់នេះមានន័យសំដៅលើកិច្ចសន្យាសះជា ក៏ប៉ុន្តែផ្ទុយពី កិច្ចសន្យាសះជាដែលកើតឡើងដោយការធ្វើសម្បទានទៅវិញទៅមកទាំងសងខាង ការដោះស្រាយតាមការជជែកគ្នាមានការបោះបង់នូវការទាមទារនៃភាគីណាម្ខាង ដើម្បីបញ្ចប់វិវាទ (ក្រៅតុលាការ) ។

## ១១. ការការពារអ្នកប្រើប្រាស់ និងរយៈពេលអាចរំលាយកិច្ចសន្យាបាន

### ១១.១.របប Cooling-Off

ប្រសិនបើគូភាគីភ្ជាប់កិច្ចសន្យាជាមួយគ្នាហើយ គូភាគីត្រូវតែគោរពតាម គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ក្នុងការអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួន ។ ភាគីម្ខាងៗមិនត្រូវបញ្ឈប់ការអនុវត្តន៍កាតព្វកិច្ចនេះតាមទំនើងចិត្តខ្លួនទេ វៀរលែងតែករណីរំលាយកិច្ចសន្យា មានប្រាក់កក់ចេញ។ ទោះជាយ៉ាងដូច្នេះក៏ដោយ គង់នៅមានការធ្វើកិច្ចសន្យាដោយចាញ់បោកពាក្យ សំដីផ្អែមល្ហែមរបស់ ឈ្មួញទុច្ចរិតខ្លះផងដែរ ។ ជាធម្មតាទេដែលថា ប្រសិនបើកិច្ចសន្យានេះ ធ្វើឡើងដោយមានការឆបោក ឬដោយមានការភ័ន្តច្រឡំនោះ គេអាចដកការបង្ហាញឆន្ទៈចេញដោយទុកជាមោឃៈបានឬក៏អាច រំលាយកិច្ចសន្យាបានប្រសិនបើភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ច ។ ក៏ប៉ុន្តែបើត្រឹមតែថាដោយជឿ តាមសំដីរបស់ឈ្មួញ ឬដោយចាញ់បរិយាកាសទាក់ទាញនាពេលនោះតែប៉ុណ្ណោះទេ ករណីបែបនេះ ភាគច្រើនមិនអាចអះអាងថាជាការឆបោក ឬ ការភ័ន្តច្រឡំបានទេ

(ព្រោះថាខ្លួនឯងជាអ្នកសំរេចចិត្ត ចុងក្រោយដើម្បីធ្វើកិច្ចសន្យានោះ) ហើយបើករណីភាគីម្ខាងទៀតបាននាំទំនិញមកប្រគល់ជូនដូចដែលបានសន្យារួចហើយនោះ គឺពុំអាចសុំរំលាយកិច្ចសន្យាចោលដោយ សំអាងលើមូលហេតុថាមិនបានអនុវត្តកាតព្វកិច្ចនោះបានទេ ។ ដើម្បីការពារអ្នកប្រើប្រាស់នៅក្នុង ករណីដូចប្រភេទខាងលើ ដែលក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិ ចែងទុកនោះ ច្បាប់ពិសេសខ្លះបាន ត្រូវអនុម័តឡើងដោយទុកពេលវេលាមួយរយៈ ផ្តល់ឱកាសឱ្យអ្នកទិញមានលទ្ធភាពនឹងរំលាយកិច្ចសន្យា ទៅវិញបានផងបន្ទាប់ពីធ្វើការគិតសញ្ជឹងក្រោយពេលទិញ រួចហើយដែលគេហៅថារបប *cooling-off* (របបផ្តល់នូវរយៈវេលាអាចរំលាយកិច្ចសន្យាបាន) ។

របបនេះបានត្រូវបញ្ញត្តិនៅក្នុង ច្បាប់ស្តីពីការជួញដូរតាមវិធីដោយឡែក ច្បាប់ស្តីពីការលក់ដោយបង់រំលោះ (បង់ថ្លៃជាវគ្គ) ច្បាប់ស្តីពីការធ្វើអាជីវកម្មលើអចលនទ្រព្យជាដើម ។ ច្បាប់ទាំងនេះបានកំណត់នូវករណីយកិច្ចឱ្យឈ្មួញអ្នកលក់ប្រគល់ជាសំបុត្រស្នាម (ជាលាយល័ក្សអក្សរ) នៅក្នុងពេលភ្ជាប់កិច្ចសន្យា ហើយកំណត់ថា អ្នកទិញអាចរំលាយកិច្ចសន្យា (ពាក្យប្រើនៅក្នុងបញ្ញត្តិនៃច្បាប់ហៅថាការដកពាក្យសុំទិញ ឬការរំលាយកិច្ចសន្យា) បានដោយធ្វើជាលាយល័ក្សអក្សរនៅក្នុងរយៈវេលាមួយ (ចំនួន ៨ ថ្ងៃចំពោះការលក់ទំនិញតាមផ្ទះ) រាប់ចាប់ពីថ្ងៃដែលបានទទួលលិខិតស្នាមជាកិច្ចសន្យានោះមក (សូមបញ្ជាក់ថាការរំលាយកិច្ចសន្យារបៀបនេះ អាចធ្វើទៅបានចំពោះតែករណីច្បាប់ពិសេសណាដែលមានកំណត់អំពីការរំលាយកិច្ចសន្យាតាមរបប *cooling-off* តែប៉ុណ្ណោះ) ។

## ១១.២.ការបង្កើតច្បាប់ថ្មីស្តីពីកិច្ចសន្យាជាមួយអ្នកប្រើប្រាស់

បទបញ្ញត្តិសំរាប់គ្រប់គ្រងមុខរបរដោយឡែកនិមួយៗ ឬច្បាប់ស្តីពីការជួញដូរ កំណត់ក្នុងវិស័យពាណិជ្ជកម្មដូចបានរៀបរាប់នៅខាងលើ មិនប្រាកដជាអាចផ្តល់នូវការការពារ គ្រប់គ្រាន់ដល់អ្នកប្រើប្រាស់បានទេ ។ ត្រង់នេះ គេចង់ឃើញមានការរៀបចំច្បាប់ទូទៅមួយ ដែលអាចការពារអ្នកប្រើប្រាស់បានពីវិធីលក់ដូរមានលក្ខណៈអាក្រក់ ឬពីកិច្ចសន្យាទិញលក់ឬផ្គត់ផ្គង់ទំនិញនិងសេវាកម្មដែលមិនមានលក្ខណៈត្រឹមត្រូវ ។ ហេតុដូច្នេះ ច្បាប់ស្តីពីកិច្ចសន្យាជាមួយអ្នកប្រើប្រាស់ត្រូវបានអនុម័តនាខែមេសា ឆ្នាំ ២០០០ ហើយចូលជាធរមាននាខែមេសា ឆ្នាំ ២០០១ (អនុវត្តចំពោះរាល់កិច្ចសន្យាណា ដែលបានបង្កើតក្រោយថ្ងៃច្បាប់នេះចូលជាធរមាន) ។ តាមរយៈ

នៃច្បាប់នេះ គេអាចលុបចោលកិច្ចសន្យាណា ដែលបានបង្កើតឡើងដោយសារមានការបទស្រាយដោយភូតភរអំពីប្រការដ៏សំខាន់ណាមួយ ឬដោយសារមានការពន្យល់ធ្វើឱ្យគេជឿលើហេតុការណ៍អ្វីមួយដែលនៅមិនទាន់ប្រាកដនៅឡើយ ដូចជាបញ្ហាទំនិញឡើងថ្លៃជាដើម ឬក៏ដោយសារកិច្ចសន្យានោះត្រូវបានបង្កើតឡើង ក្នុងសភាពការណ៍ដែលអ្នកលក់បានមកអង្គុយរហូតក្នុងផ្ទះរបស់អតិថិជនមិនព្រមចេញទៅ (ការមិនព្រមចេញទៅវិញ) ឬឃាត់ទុកអតិថិជននៅកន្លែងលក់ដូរមិនឱ្យចេញទៅវិញទេ (ការឃាត់ទុក) បើសិនជាគេមិនព្រមចុះកិច្ចសន្យាជាមួយទេនោះ ។ ម្យ៉ាងទៀត ប្រការណាក្នុងកិច្ចសន្យាដែលបង្កឱ្យអតិថិជនចាញ់ប្រៀបតែម្នាក់ឯង (ដូចជាការចែងថា "ទោះជា ក្នុងករណីណាក៏ដោយ យើងនឹងមិនទទួលខុសត្រូវអ្វីទាល់តែសោះ" នោះ) ត្រូវបានចាត់ទុកជាមោឃៈ ។

# ជំពូកទី ៥

# ច្បាប់ស្តីពីសិទ្ធិលើបំណុល (២)

# ~ច្បាប់ស្តីពីអំពើអនីត្យានុកូល~


I. ការកើតមានសិទ្ធិលើបំណុលក្រៅកិច្ចសន្យា

II. ការសិក្សាអំពីចំណុចសំខាន់នៃអំពើអនីត្យានុកូល

១. តើអំពើអនីត្យានុកូលជាអ្វី?

២. គោលគំនិតស្តីពីសំណងខូចខាតបណ្តាលមកពីអំពើអនីត្យានុកូល

៣. លក្ខខណ្ឌកំណត់នៃអំពើអនីត្យានុកូល

៤. អានុភាពនៃអំពើអនីត្យានុកូល

៥. អំពើអនីត្យានុកូលពិសេស

៦. បទបញ្ញត្តិដទៃផ្សេងទៀតស្តីពីអំពើអនីត្យានុកូល

៧. ច្បាប់ស្តីពីការធានាសំណងជំងឺចិត្តពាក់ព័ន្ធនឹងរថយន្ត

៨. ច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល

II. ការសិក្សាអំពីចំណុចសំខាន់នៃការគ្រប់គ្រងដោយឈឺឆ្អាលនិងសេចក្តីចំរើនដោយឥតហេតុ

១. ការគ្រប់គ្រងដោយឈឺឆ្អាល

២. សេចក្តីចំរើនដោយឥតហេតុ

# I. ប្រភពនៃការកើតមានសិទ្ធិលើបំណុលក្រៅកិច្ចសន្យា

ក្នុងផ្នែកបទបញ្ញត្តិលំអិត មានចែងអំពីបុព្វហេតុ ៤ យ៉ាងដែលនាំឱ្យកើតមានសិទ្ធិលើ បំណុល ។ កិច្ចសន្យាគឺជាមូលហេតុចំបងក្នុងមូលហេតុទាំង ៤ នេះ ។ ប៉ុន្តែ នៅមានការកំណត់នូវមូលហេតុ ៣ ទៀត គឺការគ្រប់គ្រងដោយឈឺឆ្អាល សេចក្តីចម្រើនដោយឥតហេតុ និងអំពើអនីត្យានុកូល ។ ក្នុងនោះ ការគ្រប់គ្រងដោយឈឺឆ្អាល និងសេចក្តីចំរើនដោយឥតហេតុ ត្រូវបានចាត់ទុកថាជាបុព្វហេតុ នាំឱ្យកើតមានសិទ្ធិលើបំណុលក្នុង ករណីពិសេស។ ចំណែកអំពើអនីត្យានុកូលវិញ គឺវាមានសារសំខាន់បន្ទាប់ ពីកិច្ចសន្យា។ នៅក្នុងមេរៀននេះ យើងនឹងពិនិត្យមើលអំពីបុព្វហេតុទាំងអស់តាមលំដាប់លំដោយបញ្ញាស់ នៃមាត្រាច្បាប់ដោយធ្វើការសិក្សាអំពីអំពើអនីត្យានុកូលមុន ដោយសារភាពសំខាន់ជាងគេនៃប្រភពនេះ ។

# II. ការសិក្សាអំពីចំណុចសំខាន់នៃអំពើអនីត្យានុកូល

## ១. តើអំពើអនីត្យានុកូលជាអ្វី?

អំពើអនីត្យានុកូល គឺជាករណីបង្កឱ្យមានការខូចខាតមកលើជនដទៃ ដោយការប្រព្រឹត្ត ល្មើសនឹងច្បាប់ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា តម្រូវឱ្យមានសំណងនៃការខូចខាត ដែលអនុញ្ញាតិឱ្យជនរងគ្រោះមានសិទ្ធិទាមទារសំណងនៃការខូចខាតពីចារីបាន ។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ត្រង់មាត្រា ៧០៩ មានចែងថា "ជនដែលបំពានដោយកំហុសចេតនា ឬកំហុសអចេតនា ទៅលើសិទ្ធិឬផលប្រយោជន៍របស់ជនដទៃដែលមានការការពារដោយច្បាប់ ត្រូវ មានទទួលខុសត្រូវសង ក្នុងការសងការខូចខាតដែលកើតមានដោយនោះ" ។ មាត្រានេះបានពោល ពាក្យថា "បំពានលើសិទ្ធិរបស់ជនដទៃ" ។ ដូច្នេះ កាលពីមុនធ្លាប់មានគេចោទជាសំណួរថា តើ អំពើអនីត្យានុកូល មិនមានរាប់បញ្ចូលនូវការបំពានបែបណាមួយដែលមិនប៉ះពាល់ដល់សិទ្ធិនោះមែន ឬទេ? សព្វថ្ងៃនេះ ពាក្យនេះត្រូវបានបកស្រាយមកថាជាការ "បង្កឱ្យមានការខូចខាតមកលើជន ដទៃ ដោយការប្រព្រឹត្តល្មើសនឹងច្បាប់ " ។ ក្នុងការធ្វើវសោធនកម្មច្បាប់ គេក៏បានរៀបចំឃ្លាឃ្លោងតាម រូបភាពមួយដែលធ្វើឱ្យចំណុចនេះមានការច្បាស់ជាងមុន ។

ហេតុដូច្នេះ ឧទាហរណ៍ជាក់ស្តែងអំពីអំពើអនីត្យានុកូលមានជាច្រើនបែបច្រើនយ៉ាង គឺមិនមែនមានតែគ្រោះថ្នាក់ចរាចរ ការបំពុលបរិស្ថាន កំហុសក្នុងការអនុវត្តន៍វិជ្ជាពេទ្យ ដែលគេហៅថា

ជាអំពើអនីត្យានុកូលផ្នែកអង្គហេតុប៉ុណ្ណោះទេ គឺថែមទាំងមានអំពើអនីត្យានុកូល ក្នុងទំនាក់ទំនងពាណិជ្ជកម្មផងដែរ តួយ៉ាងដូចជាការបំពានលើផលចំណេញក្នុងការរកស៊ី (ដូចជាការដណ្តើមអតិថិជនរបស់គេ) ឬ ការដណ្តើមយកកិច្ចសន្យាតាមវិធីអាក្រក់ (ការបំពានសកម្មលើសិទ្ធិលើបំណុល) ជាដើម ។ សំណងនៃការខូចខាតនេះមិនមែនសំរាប់តែ ចេញសងចំពោះការខូចខាតជាទ្រព្យ សម្បត្តិប៉ុណ្ណោះទេ គឺរួមមានទាំងការសងសំណងខូចខាត សំរាប់ផ្នែក ស្មារតី (ដែលហៅថាជម្ងឺចិត្ត) ផងដែរ ។

## ២. គោលគំនិតស្តីពីសំណងនៃការខូចខាតបណ្តាលមកពីអំពើអនីត្យានុកូល

នៅទីនេះ យើងនឹងពិចារណាអំពីគោលគំនិតនៃអំពើអនីត្យានុកូល ដោយធ្វើការប្រៀបធៀបទៅនឹងទោសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ។ សំណងខូចខាតផ្នែករដ្ឋប្បវេណីមានភាពខុសគ្នាទាំងស្រុងទៅនឹងទោសបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌ (ដែលមានរាប់បញ្ចូលទាំងការពិន័យជាប្រាក់ផង) ។ ការតម្រូវឱ្យសងសំណងខូចខាតក្នុងអំពើអនីត្យានុកូល មិនមែនជាការដាក់ទណ្ឌកម្មចំពោះជនប្រព្រឹត្តខុសនោះទេ ។ សំណងនេះ គឺដើម្បីតម្រូវឱ្យជនប្រព្រឹត្តខុសរួមចំណែកចែករំលែកដោយយុត្តិធម៌នូវការខូចខាតដែលខ្លួនបានបង្កមកលើជនរងគ្រោះ តាមវិធីជួសជុលការខូចខាតជូនជនរងគ្រោះទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកស្មារតី ។ ទោះជាមានករណីខ្លះដែលអំពើមួយអាចមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌផង និងជាកំហុសផ្នែករដ្ឋប្បវេណីផងក៏ដោយ ក៏នៅមានករណីមួយចំនួនទៀត ដែលអំពើមួយអាចជាបទល្មើសព្រហ្មទណ្ឌតែមិនមែនជាអំពើអនីត្យានុកូលទេ ។ ផ្ទុយទៅវិញ ក៏មានករណីខ្លះទៀតដែលអំពើមួយអាចជាអំពើអនីត្យានុកូលផ្នែករដ្ឋប្បវេណី តែមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ។ នេះគឺដោយហេតុថា ល័ក្ខខ័ណ្ឌកំណត់នៃអំពើអនីត្យានុកូលមិនមែនដូចគ្នានឹងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌនោះទេ ។ ហើយនេះក៏ដោយសារតែគោលគំនិតនៃរបបទាំងពីរនេះមានភាពខុសគ្នាដូចបានរៀបរាប់ខាងលើ ។ ឧទាហរណ៍ បុគ្គលម្នាក់បានបើកឡានទៅបុកបុគ្គលម្នាក់ទៀតដោយចេតនាបង្កឱ្យជនរងគ្រោះត្រូវរងរបួស ។ ក្នុងករណីនេះ ជនរងគ្រោះមានសិទ្ធិទាមទារឱ្យចារីចេញថ្លៃពេទ្យនិងសំណងខូចខាត ដែលបណ្តាលមកពីការខកខានមិនបានទៅប្រកបមុខរបរដោយសារការរងរបួស។ ទន្ទឹមនឹងនេះ ចារីក៏ត្រូវទទួលការចោទប្រកាន់ពីបទបង្ករបួសស្នាមដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌដែរ ។ ប៉ុន្តែបើសិនជាអ្នកប្រព្រឹត្តគ្រាន់តែបង្កឱ្យមានស្នាមឆ្កូតនៅលើម៉ូតូ ឡានរបស់អ្នកដទៃ ដោយកំហុសអចេតនាប៉ុណ្ណោះ គឺមិនមានការចោទជា

-១៣៥- ជំពូកទី ៥ ច្បាប់ស្តីពីសិទ្ធិលើបំណុល-(២) ច្បាប់ស្តីពីអំពើនីត្យានុកូល

បណ្តឹងអាជ្ញាតាមច្បាប់ព្រហ្មទណ្ឌទេ ។ អ្នកប្រព្រឹត្តត្រូវសងសំណងខូចខាត ដែលបណ្តាលមកពីអំពើអនីត្យានុកូល ។ ផ្ទុយទៅវិញ ទោះជាមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្មទណ្ឌក៏ដោយ បើមិនមានការខូចខាតដល់ទ្រព្យសម្បត្តិ និងស្មារតីរបស់អ្នកដទៃទេនោះ គឺមិនមានកំហុសនៃអំពើអនីត្យានុកូលឡើយ ។

## ៣. លក្ខខណ្ឌកំណត់នៃអំពើអនីត្យានុកូល

អំពើអនីត្យានុកូលជាទូទៅដែលមានចែងក្នុងមាត្រា ៧០៩ ត្រូវបានកំណត់ដោយលក្ខខណ្ឌ ៤ យ៉ាង ។ ទី១-កំហុសចេតនា ឬកំហុសអចេតនារបស់ចារី ។ ទី២-ភាពខុសច្បាប់ក្នុងសកម្មភាពប្រព្រឹត្តិរបស់ចារី ។ ទី៣-មានការខូចខាត ។ ទី៤-រវាង សកម្មភាពរបស់ចារីនិងការខូចខាតរបស់ជនរងគ្រោះ ត្រូវមានការទាក់ទងគ្នាជាហេតុផលច្បាស់លាស់។

### ៣.១. កំហុសចេតនា និងកំហុសអចេតនា

ត្រង់នេះ យើងអាចសង្កេតឃើញនូវគោលការណ៍មួយក្នុងចំណោមគោលការណ៍ធំៗ ៣ នៃក្រមរដ្ឋប្បវេណី ពោលគឺ"គោលការណ៍ទទួលខុសត្រូវចំពោះកំហុសអចេតនា" ។ គោលការណ៍ នេះគឺផ្អែកលើគោលគំនិតថា បើសិនជាយើងម្នាក់ៗត្រូវទទួលខុសត្រូវចំពោះអ្វីៗទាំងអស់ ដោយមិនគិតពីកំហុសចេតនា ឬកំហុសអចេតនាទេនោះ គឺសកម្មភាពរបស់យើងជាបុគ្គលម្នាក់ៗត្រូវប្រឈមនឹងការរឹតត្បិតជាច្រើន មិនអាចលូតលាស់បានឡើយ ។ ប៉ុន្តែ ក្នុងការធានាឱ្យសកម្មភាពរបស់បុគ្គលម្នាក់ៗអាចប្រព្រឹត្តិទៅបានដោយសេរីនោះ ក៏ត្រូវមានការទទួលខុសត្រូវដែរ ហេតុដូច្នេះការទទួលខុសត្រូវនេះត្រូវបានកំណត់នៅត្រឹមករណីដែលមានកំហុសចេតនា ឬកំហុសអចេតនាតែប៉ុណ្ណោះ ។ ជាគោលការណ៍ គោលគំនិតនេះ មានអានុភាពជាបន្តរហូតមកដល់សព្វថ្ងៃ ។ ក៏ប៉ុន្តែដោយសារតែសង្គមពាណិជ្ជកម្មក្នុងសម័យនេះបានលូតលាស់ដល់កំរិតមួយខ្ពស់ ដែលនាំឱ្យកើតឡើងនូវការប៉ះទង្គិចខូចខាតតាមទិដ្ឋភាពផ្សេងៗជាច្រើននោះ គេក៏បានពិចារណាឱ្យចាប់អនុវត្តការទទួលខុសត្រូវដោយមិនគិតពីកំហុសអចេតនាក្នុងករណីខ្លះផងដែរ។ ចំពោះគោលគំនិតនៃកំហុសអចេតនាទៀតសោតកាលពីមុនគេពិចារណាទៅលើទិដ្ឋភាពអត្តនោមតិ ដោយសំដៅលើការធ្វេសប្រហែសខាងចិត្តសាស្ត្ររបស់បុគ្គលជាចារីម្នាក់ៗ ។ ប៉ុន្តែបច្ចុប្បន្ននេះ ដោយសារតែគេយល់ថា បើសិនជាអាចគិត

ទុកជាមុនបាន ហើយធ្វើការប្រុងប្រយ័ត្នតាមនោះ គឺចរិមុខជាអាចជៀសវាងមិនឱ្យបញ្ហាកើត ឡើងបាន ។ ជាលទ្ធផលគេចោទអ្នកប្រព្រឹត្តពីការដែលអ្នកនោះមិនបានអនុវត្តករណីយកិច្ចដើម្បីជៀសវាងលទ្ធផល នេះពោលគឺជាការបំពានលើករណីយកិច្ចជៀសវាងលទ្ធផល ដែលអាចធ្វើការវិនិច្ឆ័យជាសច្ចានុមតិបាន ។

ក្នុងករណីអំពើអនីត្យានុកូល ភាគីជនរងគ្រោះដែលទាមទារឱ្យសងសំណងនៃការខូចខាត ត្រូវបញ្ជាក់ភស្តុតាងថា ចរិបានប្រកបដោយកំហុសចេតនា ឬកំហុសអចេតនាមែន ។(នេះមានលក្ខណៈផ្ទុយពីករណីនៃកិច្ចសន្យា។ភាគីនៃកិច្ចសន្យា មានជំហរត្រូវអនុវត្តកាតព្វកិច្ចលើគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ។ ដូច្នេះ ក្នុងករណីដែលមិនបានអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាទេ ម្ចាស់សិទ្ធិលើបំណុល ដែលទាមទារ សំណងខូចខាត មិនចាំបាច់ត្រូវបង្ហាញភស្តុតាងពីកំហុសចេតនាឬអចេតនា ឬមូលហេតុដទៃទៀតដែលជាបន្ទុកទទួលខុសត្រូវរបស់កូនបំណុលនោះទេ គឺកូនបំណុលនោះឯងដែលត្រូវបង្ហាញភស្តុតាងថា ខ្លួនមិនមានកំហុសអ្វី ទេ ដើម្បីបានរួចពីកាតព្វកិច្ចចេញសំណងខូចខាត ។)

## ៣.២. ភាពខុសច្បាប់

ល័ក្ខខ័ណ្ឌទី ២ សំរាប់កំណត់អំពើអនីត្យានុកូល គឺជាភាពខុសច្បាប់ (ពោលគឺអំពើបំពានដែលមានលក្ខណៈខុសច្បាប់) ។ ដូចបានរៀបរាប់ខាងលើ ស្តីពីការបកស្រាយពាក្យពេចន៍នៃបញ្ញត្តិមាត្រា ៧០៩ ដែលគេបានយក "ភាពខុសច្បាប់" នេះមកជំនួសឱ្យពាក្យថា "បំពាន...លើសិទ្ធិ" ។ ឧទាហរណ៍ ក្នុងពេលប្រកួតកីឡាហ្ស៊ូដូ កីឡាករបានប្រើក្បាច់ត្រឹមត្រូវ តាមច្បាប់ ដែលបានការអនុញ្ញាតក្នុងការប្រកួតកីឡាហ្ស៊ូដូ ហើយបង្កឱ្យដៃគូប្រកួតត្រូវរងរបួស ។ ក្នុងករណីនេះ ដោយហេតុថាមិនមានភាពខុសច្បាប់នោះ ដូច្នេះជាទូទៅគឺមិនក្លាយទៅជាអំពើអនីត្យានុកូលបានទេ ។ ឬក្នុងករណី ដែលបុគ្គលម្នាក់ត្រូវរងការវាយ ប្រហារពីគេ ហើយដើម្បីឱ្យបានរួចផុតពីការវាយប្រហារ បុគ្គលនោះមិនមានជំរើសអ្វីផ្សេងក្រៅអំពី ការតដៃបង្កឱ្យអ្នកវាយប្រហារត្រូវរងរបួសវិញ នេះគឺជាករណីនៃការការពារជាធម្មានុរូប ដែលអាច ជាហេតុនាំឱ្យមានការរួចពីភាពខុសច្បាប់បាន ។

ក្នុងករណីដែលការវិនិច្ឆយលើវត្តមានឬអវត្តមាននៃភាពខុសច្បាប់នេះ មិនអាចនាំមកនូវសេចក្តីសន្និដ្ឋានបានច្បាស់លាស់ទេនោះកត្តាកំណត់ចុងក្រោយត្រូវផ្អែកលើការថ្លឹងថ្លែងប្រៀប ធៀបរវាងប្រភេទនិងលក្ខណ៍នៃផលប្រយោជន៍ដែលត្រូវរងការបំពាន ជាមួយនឹងទម្រង់រូបភាពនៃសកម្មភាពបំពាន។ (ថ្វីត្បិតតែផលប្រយោជន៍ដែលត្រូវរងការបំពានមានលក្ខណ៍តិចតួចក៏ដោយបើ

សិនជារបៀបនៃការបំពាននោះមានលក្ខណៈទុច្ចរិតហួសហេតុគឺភាពខុសច្បាប់ក៏ត្រូវចាត់ទុកថាធ្ងន់ធ្ងរដែរ)។នេះគឺជាទ្រឹស្តីចំបងនាពេលបច្ចុប្បន្ន។ ប៉ុន្តែនាពេលថ្មីៗមានលេចឡើងនូវទ្រឹស្តីពីរដែលមានទិសដៅខ្វែងគ្នាស្តីពីល័ក្ខខ័ន្ឌនៃភាពខុសច្បាប់នេះ។ ទ្រឹស្តីមួយអះអាងថាត្រូវធ្វើការវិនិច្ឆ័យដោយចែកឱ្យដាច់ពីគ្នារវាង ភាពខុសច្បាប់ និងកំហុសចេតនាឬអចេតនា ។ ចំណែកទ្រឹស្តីមួយទៀតអះ អាងថានៅទីបញ្ចប់ត្រូវធ្វើការវិនិច្ឆ័យលើបញ្ហាកំហុសអចេតនាតែមួយមុខគត់ ។ ទៅក្នុងការវាយតំលៃអំពីល័ក្ខខ័ណ្ឌនៃភាពខុសច្បាប់ទៀតផង។ (ឧទាហរណ៍ដូចជាករណីដែល ឈ្មោះ Y បានដណ្តើមឱកាសរកស៊ីរបស់ X ដោយប្រើវិធីបង្ខំឈ្មោះ A ដែលបានចុះកិច្ចសន្យា ជាមួយ X ហើយនោះឱ្យផ្ទេរកិច្ចសន្យាមកខ្លួនវិញ ។ ថ្វីត្បិតតែនេះជាករណីនៃអំពើអនីត្យានុកូល ផ្នែកពាណិជ្ជកម្មក៏ដោយ ក៏មានពេលខ្លះគេចាត់ទុកថាជាករណីប្រកួតប្រជែងធម្មតាលើទីផ្សារ សេរី ។ ដូច្នេះមានការលំបាកដើម្បីវិនិច្ឆ័យឱ្យបានដាច់ណាត់ថា តើមានភាពខុសច្បាប់ ឬយ៉ាងណា នោះ ។ ដើម្បីបញ្ជាក់ឱ្យបានថានេះជាករណីនៃអំពើអនីត្យានុកូល គេយល់ថាត្រូវបង្ហាញ ឱ្យឃើញនូវឆន្ទះ (ខាំងជាងចេតនា) របស់ ឈ្មោះ Y ព្យាយាមចង់បង្កឱ្យមានការខូចខាត (ឆន្ទៈព្យាបាទ) មកលើឈ្មោះ X ដែលបានគេដណ្តើមកិច្ចសន្យានោះ ។ បើគ្រាន់តែជាការដណ្តើមដោយចេតនា គឺមិនមានលក្ខណៈកំហុស គ្រាប់គ្រាន់ទេ) ។

## ៣.៣.ការកើតឡើងនៃការខូចខាត

ល័ក្ខខ័ណ្ឌទី ៣ គឺការកើតមានឡើងនូវការខូចខាត ។ ទោះជាមានអំពើខុសច្បាប់យ៉ាងណាក៏ដោយបើមិនមានជនរងគ្រោះពីការខូចខាតទេនោះ គឺមិនមានអំពើអនីត្យានុកូល ឡើយ ។ ដូចបានរៀបរាប់រួចហើយ ការខូចខាតនេះមានរាប់បញ្ចូលទាំងការខូចខាតជាទ្រព្យ សម្បត្តិផង និងការខូចខាតជាស្មារតី (សំណងជំងឺចិត្ត) ផង ។ ចំពោះការខូចខាតជាទ្រព្យសម្បត្តិមានចែកចេញជាពីរ ប្រភេទគឺ ការខូចខាតសកម្មដូចជាការចំណាយទាំងប៉ុន្មានមកលើថ្នាំពេទ្យ និងការ ខូចខាតអសកម្ម ដូចជា ការបាត់បង់ចំណូល បណ្តាលមកពីការរងរបួសត្រូវឈប់សំរាកពីការងារ ហើយមិនអាចទទួលបាន ប្រាក់ចំណូលជាដើម ។ ជាងនេះទៅទៀតក្នុងផលប្រយោជន៍ដែលត្រូវបានបំពាននោះ គេមានរាប់បញ្ចូលនូវផលប្រយោជន៍ទាក់ទងនឹង

លក្ខណៈបុគ្គល ដែលមានជាកិត្តិយស និងសិទ្ធិនៃជីវភាពឯកជនផងដែរ (មាត្រា ៧១០) ។ ចំពោះការបំពានលើអាយុជីវិត ពោលគឺមរណភាពបង្កឡើងមកពីអំពើអនីត្យានុកូលនោះ គេទទួលស្គាល់ជាពិសេសសិទ្ធិទាមទារសំណងជម្ងឺចិត្តរបស់ឪពុកម្តាយ សហព័ទ្ធ ឬកូនរបស់ជនរងគ្រោះដែលត្រូវទទួលមរណភាព (មាត្រា ៧១១) ។ ចំពោះជនដទៃផ្សេងទៀត បើសិនជាអាចបង្ហាញភស្តុតាងឱ្យឃើញថាបានទទួលរងការខូចខាតផ្លូវស្មារតីនោះ ក៏មានសិទ្ធិទាមទារសំណង ជម្ងឺចិត្តដែរ ។

## ៣.៤.ទំនាក់ទំនងនៃហេតុផល

ល័ក្ខខ័ណ្ឌទី ៤ គឺជាការកំណត់ទំនាក់ទំនងហេតុផលច្បាស់លាស់ ។ ចាំបាច់ត្រូវបង្ហាញឱ្យឃើញនូវការទាក់ទងគ្នាជាហេតុផលសមស្រប រវាងអំពើប្រព្រឹត្ត និងការខូចខាតដែលកើតមានឡើង ។ ក៏ប៉ុន្តែ ក្នុងករណីមួយចំនួនដូចជាការបំពុលបរិស្ថានជាដើមជនរងគ្រោះមានការលំបាកដើម្បីបញ្ជាក់ភស្តុតាងថាមានសារធាតុបំពុលបែបណាខ្លះបានចូលទៅក្នុងខ្លួនប្រាណរបស់គេតាមវិធីណា ហើយញ៉ាំងឱ្យកើតមានជាជំងឺយ៉ាងណានោះ។ ហេតុដូច្នេះយុត្តិសាស្ត្រច្បាប់មិនបានតម្រូវ ឱ្យមាន ការលើកយកភស្តុតាងជាវិទ្យាសាស្ត្រតឹងរឹងសំរាប់ញ្ជាក់ហេតុផលទេ ។ បើសិនជាជនរងគ្រោះអាចបង្ហាញភស្តុតាងជាភវនីយហេតុដើម្បីឱ្យឃើញនូវហេតុផលសមស្របសំរាប់ជឿបាននោះ គឺគេត្រូវចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ ។

## ៣.៥.សមត្ថភាពក្នុងការទទួលខុសត្រូវ

ប្រធានបទនេះមានខ្លឹមសារប្រាសចាកបន្តិចពីការកំណត់ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល។ ប៉ុន្តែដើម្បីឱ្យចារីទទួលខុសត្រូវសងការខូចខាតបាននោះចាំបាច់ត្រូវតែចារីនោះមានសមត្ថភាព ក្នុងការទទួលខុសត្រូវ( ពោលគឺសមត្ថភាពគ្រប់គ្រាន់សំរាប់ទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល)។ បុគ្គលដែលជាចារីនោះ ត្រូវមានសមត្ថភាពយល់ដឹង ឬធ្វើការវិនិច្ឆ័យបានដិតដល់ ចំពោះលទ្ធផលដែលអាចកើតឡើងពីអំពើរបស់ខ្លួន។ចំពោះបុគ្គលដែលមិនមានសមត្ថភាពនេះទេ គេចាត់ទុកថាជាជនគ្មានសមត្ថភាពក្នុងការទទួលខុសត្រូវដែលត្រូវបានលើកលែង ពីការទទួលខុសត្រូវចំពោះ អំពើ

អនីត្យានុកូលរបស់ខ្លួន ។ ជនគ្មានសមត្ថភាពក្នុងការទទួលខុសត្រូវ ដូចបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ត្រូវបានបែងចែកជាពីរប្រភេទ ។ មាត្រា ៧១២ ចែងពីប្រភេទនៃអនីតិជនដែលមិនមានសតិបញ្ញាគ្រប់គ្រាន់សំរាប់យល់អំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយនិងមាត្រា ៧១៣ ចែង អំពីជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ។ ចំពោះករណីនៃអនីតិជនគេត្រូវពិនិត្យទៅតាមករណី និមួយៗក៏ប៉ុន្តែជាទូទៅគេបាន កំណត់យកអាយុប្រមាណ ១២ ឆ្នាំជាអាយុមូលដ្ឋានសំរាប់ធ្វើការពិចារណា។ អាស្រ័យហេតុនេះចំពោះកុមារនៅសាលាបឋមសិក្សាដែលបានយកថ្មមកដំកល់លេងនៅលើផ្លូវដែកបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរកើតឡើង កុមារនោះនឹងមិនទទួលខុសត្រូវ ចំពោះអំពើអនីត្យានុកូលទេ។ ប៉ុន្តែបើសិនជាអំពើនេះបានប្រព្រឹត្តិឡើងដោយសិស្សម្នាក់ប្រចាំសាលាមធ្យមសិក្សាកំរិតខ្ពស់វិញទោះជាអនីតិជនក៏ដោយក៏ត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែរ(ដោយគេចាត់ទុកថាអនីតិជននេះមានសតិបញ្ញាគ្រប់គ្រាន់សំរាប់យល់អំពីការទទួល ខុសត្រូវរបស់ខ្លួន)។

ចំពោះករណីរបស់ជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី មាត្រា ៧១៣ ផ្នែកបដិបញ្ញាមានចែងថាបញ្ញត្តិនៃមាត្រានេះមិនអនុវត្តចំពោះករណីនៃការបាត់បង់សតិបញ្ញាមួយរយៈខ្លីបណ្តាលមកពីកំហុសចេតនាឬអចេតនារបស់ខ្លួន។ ហេតុដូច្នេះ ករណីនៃជនដែលផឹកស្រាស្រវឹង ហើយទៅបង្កឱ្យអ្នកដទៃរងរបួស គឺមិនអាចរួចផុតពីការទទួសខុសត្រូវសងសំណងនៃការខូចខាតទេ ។ ហើយក្នុងករណីដែលអ្នកប្រព្រឹត្តត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះក៏ មិនមានន័យថាគ្មានអ្នកណាម្នាក់ត្រូវទទួលខុសត្រូវទាល់តែសោះទេ។ ដូចនឹងមានរៀបរាប់នៅខាងក្រោមយោងតាមមាត្រា ៧១៤ អ្នកដែលមាន កាតព្វកិច្ចគ្រប់គ្រងជនទាំងនេះ (ក្នុងករណីនៃកុមារជាអ្នកប្រព្រឹត្តឪពុកម្តាយដែលជាអ្នកតំណាងដែលច្បាប់បានកំណត់នោះគឺជាអ្នកមានកាតព្វកិច្ចគ្រប់គ្រង) នឹងត្រូវគេចាត់ទុកថាមិនបានអនុវត្តនូវកាតព្វកិច្ច គ្រប់គ្រងរបស់ខ្លួន ដូច្នេះត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលជំនួសឱ្យអ្នកប្រព្រឹត្តវិញ ។

# ៤. អានុភាពនៃអំពើអនីត្យានុកូល

## ៤.១. គោលការណ៍សងការខូចខាតជាប្រាក់

ជាគោលការណ៍ សំណងជំងឺចិត្តក្នុងរឿងក្តីអំពើអនីត្យានុកូលត្រូវធ្វើឡើងដោយវិធីចេញសងជាប្រាក់កាស (មាត្រា ៧២២ កថាខ័ណ្ឌទី ១) ។ ចំពោះ ករណីនៃការបរិហាកេរ្តិ៍តុលាការអាចចេញសាលក្រមបញ្ជាឱ្យអនុវត្តនូវដំណោះស្រាយសមស្រប សំដៅស្តារកិត្តិយសរបស់ជនរងគ្រោះឡើងវិញដោយតម្រូវឱ្យចារីចុះផ្សាយនូវការកែតម្រូវនៅ លើទំព័រសារពត៏មានដើម្បីជំនួសឱ្យ ឬបន្ថែមទៅលើសំណងកៃការខូចខាត (មាត្រា ៧២៣) ។

## ៤.២. វិសាលភាពនៃសំណងខូតខាត

មិនមានបញ្ញត្តិនៃមាត្រាណាមួយកំណត់អំពីបញ្ហានេះទេ ។ ដូច្នេះ ជាគោលការណ៍ រាល់ការខូចខាតទាំងអស់ដែលកើតឡើងមកពីអំពើអនីត្យានុកូល ត្រូវជាកម្មវត្ថុនៃសំណងខូចខាត ។ ក៏ប៉ុន្តែ គេចាំបាច់ត្រូវបដិសេធផងដែរចំពោះការទាមទារសំណងដែលមានបរិមាណច្រើនហួសហេតុ (ឧទាហរណ៍ដូចជាករណីនៃគ្រោះថ្នាក់នាវាចរបណ្តាលឱ្យនាវាត្រូវលិចទៅក្នុងសមុទ្រ បន្ទាប់ពីមានការប៉ះទង្គិច ។ ក្រោយមកសង្គ្រាមបានកើតឡើងភ្លាមញាំងឱ្យតំលៃនៃការជួលម៉ៅនាវាត្រូវឡើងខ្ពស់ ។ ហើយម្ចាស់នាវាដែលរងគ្រោះ គណនាការខូចខាតរបស់ខ្លួនដោយផ្អែកលើតំលៃខ្ពស់នេះវិញជាដើម) ។ ត្រង់នេះ យុត្តិសាស្ត្រច្បាប់បានកំណត់ថា ចាំបាច់ត្រូវមានទំនាក់ទំនងជាហេតុផលសមស្រប រវាងអំពើប្រព្រឹត្តិនិងការខូចខាតដែលកើតមានឡើង ។ ទ្រឹស្តីនៃយុត្តិសាស្ត្រច្បាប់នេះ កើតមានឡើងក្នុងក្របខ័ណ្ឌនៃមាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណី (មានរៀបរាប់រួចមកហើយក្នុងជំពូកទី ៤ ស្តីពីការមិនអនុវត្តតាមកតាព្វកិច្ច) ហើយក៏អាចយកទ្រឹស្តីដដែលមកអនុវត្តក្នុងករណីនេះដែរ ដោយវិធីបកស្រាយប្រៀបប្រដូច ។ ពិតមែនតែតាមរយៈនៃការសង្កេតជាទូទៅគេឃើញថាការតម្រូវឱ្យសងទៅតាមវិសាលភាពសមស្របនឹងការខូចខាតនេះ គឺជាគំនិតត្រឹមត្រូវ ។ ក៏ប៉ុន្តែគំនិតនេះបានមកពីទ្រឹស្តីនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់ ដែលរបៀបរបបកំណត់អំពីសំណងនៃការខូចខាតមិនដូចគ្នានឹងច្បាប់របស់ជប៉ុនទេ ហើយក៏មិនមានបញ្ញត្តិអ្វីដែលកំណត់ព្រំដែននៃវិសាលភាពសំរាប់សំណងខូចខាតដែរ ។ ហេតុដូច្នេះ ការបកស្រាយតាមរបៀបនេះ

ចំពោះច្បាប់របស់ប្រទេសជប៉ុនក៏បានចោទឡើងជាបញ្ហាខ្លះៗដែរ ។ (ព្រោះតែនៅប្រទេសជប៉ុន ការមិនអនុវត្តកាតព្វកិច្ចត្រូវដោះស្រាយតាមបញ្ញត្តិនៃមាត្រា ៤១៦ ដែលបែងចែកការខូចខាតជាពីរប្រភេទ គឺការខូចខាតជាធម្មតានិងការខូចខាតពិសេស ដោយអនុវត្តនូវគោលការណ៍សំណងមានកំណត់ ។ អាស្រ័យហេតុនេះ មានការរិះគន់ខ្លះថាមិនត្រូវការនាំចូលនូវពាក្យជំនាញថ្មីស្ដីពីទំនាក់ទំនងនៃហេតុផលសមស្រប ដូចដែលមានប្រើនៅក្នុងកាលៈទេសៈរបស់ប្រទេសអាល្លឺម៉ង់នោះទេ) ។

## ៤.៣. ការទូទាត់នូវកំហុស

ក្នុងករណីគ្រោះថ្នាក់ចរាចរជាដើម បើភាគីរងគ្រោះក៏មានកំហុសដែរនោះ តុលាការនឹងពិចារណាសំរេចអំពីចំនួនទឹងប្រាក់នៃការខូចខាត ដោយផ្អែកលើការទូទាត់នូវកំហុសរវាងភាគីទាំងពីរ ។ ឧទាហរណ៍ បើសិនជាការខូចខាតមានទ្រង់ទ្រាយជា ១ លានយ៉េន ហើយតុលាការបានរកឃើញថាភាគីរងគ្រោះក៏មានរួមចំណែក ៣០ ភាគរយក្នុងកំហុសដែលនាំមកនូវការខូចខាតនេះដែរ (ឧបមាដូចជាគ្រោះថ្នាក់ចរាចរបានកើតឡើង ដោយមូលហេតុថាអ្នកបើកបរមិនចាប់អារម្មណ៍មើលទៅមុខ ប៉ុន្តែដោយសារតែជនរងគ្រោះក៏មានកំហុសដែរមកពីខ្លួនបានបញ្ចេញឡានមកកណ្ដាលថ្នល់យ៉ាងប្រញាប់ប្រញាល់) តុលាការអាចញែកកំហុសនេះចេញជាពីរចំណែក គឺ ៧០% និង ៣០% ហើយសំរេចឱ្យទូទាត់សំណាងនៃការខូចខាតមកជនរងគ្រោះចំនួន ៧០ ម៉ឺនយ៉េន ។

# ៥. អំពើអនីត្យានុកូលពិសេស

## ៥.១. កំណត់សំគាល់ទូទៅ

ក្រៅអំពីអំពើអនីត្យានុកូលទូទៅ ដែលមានចែងក្នុងមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណីនៅមានបញ្ញត្តិមួយចំនួនផ្សេងទៀត ដែលចែងអំពីអំពើអនីត្យានុកូលពិសេស ។ អំពើអនីត្យានុកូលពិសេសទាំងនេះមានលក្ខណៈពិសេស ដោយសារតែល័ក្ខខ័ណ្ឌបង្កើតអំពើទាំងនេះមានរាប់បញ្ចូលផងដែរ នូវទិដ្ឋភាពនៃការទទួលខុសត្រូវខ្លះដែលមិនមែនមកពីកំហុសទេនោះ ។ ពោលគឺជាករណី

ដែលពាក់ព័ន្ធទៅនឹងអំពើដែលសាមីខ្លួនមិនបានប្រព្រឹត្តក៏ពិតមែន ក៏ប៉ុន្តែអ្នកប្រព្រឹត្តអំពើនោះមានទំនាក់ទំនងពិសេសជាមួយសាមីខ្លួន ហេតុដូច្នេះសាមីខ្លួនក៏ត្រូវទទួលខុសត្រូវមួយកំរិតដែរ ។ (ដូចនឹងមានបរិយាយខាងក្រោមនេះ បើសិនជាគេទទួលស្គាល់ថា សាមីខ្លួនបានធ្វើការជ្រើសរើស និងត្រួតពិនិត្យអ្នកប្រព្រឹត្តអំពើនោះ ដោយមានការយកចិត្តទុកដាក់ប្រុងប្រយ័ត្នគ្រប់គ្រាន់ គឺសាមីខ្លួនអាចនឹងទទួលបាននូវការលើកលែង ។ ព្រោះតែមានកាលៈទេសៈលើកលែងបែបនះហើយ ទើបយើងអាចសន្និដ្ឋានបានថា បញ្ញត្តិទាំងនេះមិនមែនជាការតម្រូវឱ្យមានការទទួលខុសត្រូវចំពោះគ្រប់ករណីខូចខាតទាំងអស់ដែលមិនមែនបណ្តាលមកពីកំហុសនោះទេ) ។

## ៥.២.ការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យលើជនដែលមិនមានសមត្ថភាពក្នុងការទទួលខុសត្រូវ

មាត្រា ៧១៤ មានចែងថា ក្នុងករណីនៃអំពើប្រព្រឹត្តរបស់ជនដែលមិនមានសមត្ថភាពក្នុងការទទួលខុសត្រូវ អ្នកមានករណីយកិច្ចត្រួតពិនិត្យជនទាំងនោះ (ឧទាហរណ៍ ចំពោះកុមារតូចនៅសាលាបឋមសិក្សាគឺឪពុកម្ដាយជាអ្នកត្រួតពិនិត្យ ហើយចំពោះជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី គឺអ្នកអាណាព្យាបាល ឬនាយមន្ទីរពេទ្យវិកលចរិត ជាអ្នកត្រួតពនិត្យ) ឬអ្នកត្រួតពិនិត្យជំនួស (សំរាប់ករណីកុមារតូចនៅសាលាបឋមសិក្សា គឺមានចាងហ្វាងសាលាជាដើម) ត្រូវទទួលខុសត្រូវសងសំណងខូចខាត ។ មាត្រានេះក៏មានចែងអំពីការលើក លែងចំពោះករណីដែលមិនមានការធ្វេសប្រហែសក្នុងកិច្ចការត្រួតពិនិត្យ ប៉ុន្តែការអះអាងដើម្បីធ្វើឱ្យគេទទួលស្គាល់ថា ពិតជាមិនមានការធ្វេសប្រហែសនោះមិនមែនងាយស្រួលឡើយ ។

## ៥.៣. ការទទួលខុសត្រូវរបស់និយោជក

យោងតាមមាត្រា ៧១៥ ការទទួលខុសត្រូវរបស់និយោជក តម្រូវឱ្យនិយោជក ឬអ្នកដែលធ្វើការត្រតពិនិត្យជំនួសនិយោជក ត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលប្រព្រឹត្តឡើងដោយនិយោជិត ក្រៅពីការទទួលខុសត្រូវរបស់នយោជិតខ្លួនឯង ក្នុងពេលកំពុងបំពេញគម្រោង

ការងាររបស់និយោជកផ្ទាល់ ។ ក៏ប៉ុន្តែ ការទទួលខុសត្រូវនេះនឹងត្រូវលើកលែងចោល បើសិនជាគេរកឃើញថា និយោជក ឬអ្នកត្រួតពិនិត្យជំនួស បានយកចិត្តទុកដាក់ត្រឹមត្រូវនៅពេលតែងតាំង និងត្រួតពិនិត្យនិយោជិតនោះ ។ ហើយព្រមទាំងមានបញ្ញត្តិចែងអនុញ្ញាតឱ្យនិយោជក និងអ្នកត្រួតពិនិត្យជំនួស បន្ទាប់ពីបានសងសំណងទៅឱ្យជនរងគ្រោះហើយនោះ អាចទាមទារសំណងពីនិយោជិតដែលបានប្រព្រឹត្តអំពើអនីត្យានុកូលនោះ មកវិញបាន (មាត្រា ៧១៥ កថាខ័ណ្ឌទី ៣) ។ ដោយ ហេតុថាបញ្ញត្តិស្តីពីការទាររកសំណងពីនិយោជិកមកវិញនេះ អាចញ៉ាំងឱ្យមានករណីមិនគប្បីដែលនិយោជិតត្រូវក្លាយទៅជាអ្នកចេញសំណងទាំងអស់នោះ យុតិសាស្រ្តច្បាប់ និងទ្រឹសីសិក្សាថ្មីៗបានកំណត់ថាមានករណីខ្លះត្រូវធ្វើការពិចារណាទៅតាមគោលការណ៍សច្ចធម៌ មិនអាចទាររកសំណងទាំងស្រុងពីនិយោជិតមកវិញបានទេ ។

## ៥.៤. អំពើអនីត្យានុកូលរួម

មាត្រា ៧១៩ មានចែងអំពីអំពើអនីត្យានុកូលរួម ។ ឧទាហរណ៍ ជនម្នាក់ត្រូវជនមួយក្រុមដែលមានគ្នាច្រើននាក់ព័ទ្ធវាយ ហើយមិនដឹងជាត្រូវកណ្តាប់ដៃរបស់ នរណាទេជននោះត្រូវសន្លប់បាត់ស្មារតី ។ ក្នុងករណីនេះ បើសិនជាគេកំណត់ថាមិនឱ្យទាមទារសំណងបានទេ ពីព្រោះជនរងគ្រោះមិនអាចសំគាល់ជនដៃដល់បានទេនោះ គឺយើងមិនមានវិធីអ្វីដើម្បីការពារជនរងគ្រោះទេ ។ ដូច្នេះមាត្រានេះបានចែងថា ក្នុងករណីបែបនេះ សមាសភាពនៃក្រុមអ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវរួមគា ។ (ពោលគឺ បើសិនជា D ត្រូវក្រុមជន ៣ នាក់ ដែលមានឈ្មោះ A, B និង C វាយប្រហារ ហើយត្រូវទាមទាររកឈ្មោះណាក៏បានដែរ ក្នុងចំណោម ៣ នាក់នោះឱ្យសងសំណងខូចខាត) ។ គំនិតនេះក៏អាចយកមកអនុវត្តបានដែរ សំរាប់ករណីគ្រោះថ្នាក់ចរាចរវវាងឡាន X និងឡាន Y ហើយបណ្តាលឱ្យ Z ដែលជាអ្នកដើរកាត់ទីកន្លែងកើតហេតុនោះត្រូវរងរបួស។ (X និង Y បានក្លាយជាអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម) ។ ជាងនេះទៅទៀត អ្នកញុះញង់ និងអ្នកជំនួយដែលបានជំរុញនិងជួយសំរួលដល់ការប្រព្រឹត្ត នោះ ក៏ត្រវចាត់ទុកថា អ្នកប្រព្រឹតរួមដែរ (មាត្រាដដែល កថាខ័ណ្ឌទី ២) ។

## ៥.៥. ការទទួលខុសត្រូវកាន់កាប់សត្វ

អ្នកកាន់កាប់សត្វឬអ្នកគ្រប់គ្រងសត្វជំនួសអ្នកកាន់កាប់ ត្រូវទទួលខុសត្រូវសងសំណង ចំពោះការខូចខាតដែលសត្វនោះបានបង្កមកលើអ្នកដទៃ (មាត្រា ៧១៨ កថាខ័ណ្ឌទី ១ និង ២) ។ ឧបមាដូចជាករណី ដែលសត្វចិញ្ចឹមក្នុងផ្ទះរត់គេចចេញទៅខាងក្រៅខាំឱ្យមានរបួសដល់អ្នកដទៃ អ្នកកាន់កាប់សត្វនោះត្រូវទទួលខុសត្រូវ (ដែលហៅថាជាអ្នកកាន់កាប់គឺមិនបែងចែកថាជាម្ចាស់ ឬមិនមែនម្ចាស់របស់សត្វនោះទេ គឺជាអ្នកដែលចិញ្ចឹមសត្វនោះពិតប្រាកដតែម្តង) ។ ចំពោះសត្វដែលរត់ចេញពីស្ថានីយ៏ពេទ្យសត្វទៅធ្វើឱ្យអ្នកដទៃរងរបួសនោះ គឺនាយកស្ថានីយ៏ពេទ្យសត្វ ដែលជាអ្នកតំណាងគ្រប់គ្រងត្រូវទទួលខុសត្រូវ ។ បើសិនជាករណីសត្វបានរត់គេចចេញទៅក្រៅ ហើយធ្វើឱ្យអ្នកដទៃរបួសនោះ គឺត្រូវយកមាត្រា ៧១៨ មកអនុវត្ត ។ ក៏ប៉ុន្តែចំពោះករណីដែលម្ចាស់ជាអ្នកដោះលែងសត្វនោះឱ្យវាទៅខាំអ្នកដទៃ នោះគឺជាអំពើអនីត្យានុកូលរបស់ខ្លួនម្ចាស់នោះផ្ទាល់ដែលត្រូវយកមាត្រា ៧០៩ មកអនុវត្តវិញ ។

## ៥.៦.ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

យោងតាមមាត្រា ៧១៧ បើសិនជាការរៀបចំថែរក្សាសំណង់ដែលជាប់នឹងដី ដូចជាផ្ទះសម្បែង ឬរបងសួនជាដើម មានវិការៈ ធ្វើឱ្យមានការខូចខាតដល់អ្នកដទៃ (ឧទាហរណ៍ ដូចជាករណីដែលឥដ្ឋមួយដុំបានធ្លាក់មកពីលើរបងសួន ធ្វើឱ្យអ្នកដំណើរត្រូវរងរបួស) គេត្រូវអនុវត្តនូវការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនេះជា ៣ តំណាក់ការ ។ បើសិនជាអំពើអនីត្យានុកូលនេះកើតឡើងមកពីការសាងសង់ ទីមួយគឺអ្នកកាន់កាប់ដែលធ្វើការគ្រប់គ្រងផ្ទាល់លើសំណង់នោះ (បើសិនជាករណីនៃផ្ទះជួល អ្នកកាន់កាប់នេះគឺជាអ្នកជួលផ្ទះតែម្តង) ត្រូវទទួលខុសត្រូវចំពោះសំណងខូចខាត ។ ក៏ប៉ុន្តែ បើសិនជាអ្នកកាន់កាប់បានយកចិត្តទុកដាក់តាមសេចក្តីចាំបាច់ ដើម្បីចាត់វិធានការការពាររួចហើយនោះ គឺការទទួលខុសត្រូវធ្លាក់មកម្ចាស់កម្មសិទ្ធិកររបស់សំណងវិញ (បើសិនជាករណីនៃផ្ទះជួល អ្នកទទួលខុសត្រូវគឺជាម្ចាស់កម្មសិទ្ធិរបស់ផ្ទះជួលនោះ) (មាត្រា ៧១៤

-១៤៥-ជំពូកទី ៥ ច្បាប់ស្តីពីសិទ្ធិលើបំណុល-(២) ច្បាប់ស្តីពីអំពើនីត្យានុកូល

កថាខ័ណ្ឌទី ១) ។ ហើយក្នុងករណីមានអ្នកផ្សេងទៀត ដែលត្រូវរួមចំណែកក្នុងការទទួលខុសត្រូវនេះដែរ (ដូចជាករណីដែលឥដ្ឋនោះធ្លាក់ដោយសារតែការងាររៀបឥដ្ឋរបស់អ្នកម៉ៅការមិនបានល្អ) អ្នកកាន់កាប់ ឬម្ចាស់កម្មសិទ្ធិ ដែលបានសងសំណាងខូចខាតទៅឱ្យជនរងគ្រោះរួចហើយ អាចមានសិទ្ធិទាមទារសំណងពីអ្នកនោះ (ដូចជាអ្នកម៉ៅការជាដើម) វិញបាន (មាត្រាដដែល កថាខ័ណ្ឌទី ៣) ។

## ៦. បទបញ្ញត្តិដទៃផ្សេងទៀតស្តីពីអំពើអនីត្យានុកូល

គភ៌ក្នុងផ្ទៃពោះមានសិទ្ធិទាមទារសំណងនៃការខូចខាត ដូចកូនបានចាប់កំណើតយ៉ាងដូច្នេះដែរ ។ បញ្ញត្តិនេះមានចែងនៅមាត្រា ៧២១ ។ ឧទាហរណ៍ ជនម្នាក់ត្រូវស្លាប់ដោយសារគ្រោះថ្នាក់ចរាចរបន្សល់ទុកនូវភរិយាដែលកំពុងមានគភ៌ ។ ភរិយានិងគភ៌នោះ អាចទាមទារសំណងនៃការខូចខាតជាចំណែករបស់ពីរនាក់បាន ។ បញ្ញត្តិនេះបានចែងឡើងសំដៅរកដំណោះស្រាយឱ្យជនរងគ្រោះ ។

បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃសិទ្ធិទាមទារសំណងនៃការខូចខាង មានចែកជាពីរ ។ បើចាប់គិតពីពេលដែលអំពើកើតឡើងនោះ គឺអាជ្ញាយុកាលមានរយៈពេល ២០ ឆ្នាំ ប៉ុន្តែបើចាប់គិតពីពេលដែលស្គាល់ពីអត្ត សញ្ញាណរបស់ចារី និងការខូចខាតនោះ គឺអាជ្ញាយុកាលមានរយៈពេល ៣ ឆ្នាំ ។

## ៧. ច្បាប់ស្តីពីការធានាសំណងនៃការខូចខាតពាក់ព័ន្ធនឹងរថយន្ត

ចំពោះករណីនៃគ្រោះថ្នាក់ចរាចរបណ្តាលមកពីរថយន្តវិញ គេអនុវត្តនូវ "ច្បាប់ស្តីពីការធានាការទទួលខុសត្រូវក្នុងការសងនូវការខូចខាតពាក់ព័ន្ធនឹងរថយន្ត" ដែលជាច្បាប់រដ្ឋប្បវេណីពិសេស (ហៅកាត់ថា ច្បាប់ស្តីពីសំណងនៃការខូចខាតសំរាប់រថយន្ត) ។ ច្បាប់នេះផ្អែកលើគោលគំនិតស្តីពី "ភាគីអ្នកផ្តត់ផ្គង់ការដឹកជញ្ជូន" ដោយតម្រូវឱ្យអ្នកខ្លះដែលមិនមែនជាអ្នកបើកបរផ្ទាល់ក៏ដោយ ប៉ុន្តែជាអ្នកកាន់កាប់រថយននោះ (ថ្វីត្បិតតែក្នុងករណីជាច្រើនអ្នកនេះក៏ជាអ្នកបើកបរផ្ទាល់ផងដែរ) ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតដែរ ។ (ជាការពិតហើយអ្នក

បើកបរផ្ទាល់ត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ដោយអនុលោមតាមមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី) ។ម្យ៉ាងវិញទៀត ច្បាប់នេះមានចែងពីការបង្កើតរបបធានារ៉ាប់រងដោយបង្ខំ សំរាប់អនុវត្តកាតព្វកិច្ចសងសំណងខូចខាត ។ អ្នកកាន់កាប់រថយន្តទាំងឡាយចាំបាច់ត្រូវទិញការធានារ៉ាប់រងនេះ ហើយប្រាក់សំណងសំរាប់ការខូចខាតនឹងត្រូវដកចេញពីរបបធានារ៉ាប់រងនេះ ។ អាស្រ័យហេតុនេះ ជនរងគ្រោះដោយសារគ្រោះថ្នាក់ចរាចរ នឹងបើកប្រាក់សំណងខូចខាតពីរបបនេះមកជាមុនសិន ហើយបើសិនជានៅខ្វះទៀតទើបគេទាមទារសំណងនៃការខូចខាតផ្អែកលើអំពើអនីត្យានុកូល ស្របតាមមាត្រានៃក្រមរដ្ឋប្បវេណី ។(សូមរំលឹកថាច្បាប់ពិសេសនេះសំដៅតែលើការខូចខាតដែលពាក់ព័ន្ធដល់ខ្លួនប្រាណរបស់មនុស្ស ដូចជាថ្លៃពេទ្យជាដើម ។ ច្បាប់នេះមិនមានធានាចំពោះការខូចខាតលើសំភារៈទេ ។ ហេតុដូច្នេះ រាល់ការខូចខាតទៅលើសំភារៈ និងសំលៀកបំពាក់ ។ល។ របស់ជនរងគ្រោះនឹងត្រូវទាមទារសំណង ដោយអនុលោមតាមមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី) ។

## ៨. ច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល

ចំពោះករណីដែលមានការខូចខាតបណ្តាលមកពីទំនិញមានវិការៈ គេត្រូវអនុវត្តច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផលដែលបានចូលជាធរមានកាលពីខែ ៧ ឆ្នាំ ១៩៩៥ ។(ច្បាប់នេះបកប្រែជាភាសាអង់គ្លេសហៅថាជា Product Liability ហើយជាទូទៅគេហៅតាមអក្សរកាត់ថាជាច្បាប់ PL) ។ ច្បាប់នេះ បានយកគោលគំនិតអំពី "វិការៈ" របស់ផលិតផលមកជំនួស "កំហុស" ដែលជាល័ក្ខខ័ណ្ឌកំណត់នៃអំពើអនីត្យានុកូល ។ ក្នុងករណីដែលវិការៈនៃផលិតផលបានបណ្តាលឱ្យមានការប៉ះពាល់ដល់អាយុជីវិត ខ្លួនប្រាណ ឬទ្រព្យសម្បត្តិរបស់អ្នកដទៃ ច្បាប់នេះតម្រូវឱ្យផលិតករទទួលខុសត្រូវ ចំពោះការខូចខាតដែលកើតមានឡើង (មាត្រា ៣ ច្បាប់ PL) ។ ក៏ប៉ុន្តែចំពោះការខូចខាតដែលកើតមានទៅលើផលិតផលនេះផ្ទាល់តែម្តង ផលតិករមិនត្រូវទទួលខុសត្រូវនៅចំពោះមុខច្បាប់នេះទេ (បដិបញ្ញានៃមាត្រា ៣) ។ ជាការពិតណាស់ ដោយហេតុថាច្បាប់នេះជាច្បាប់រដ្ឋប្បវេណីពិសេស ហើយត្រូវអនុវត្តទន្ទឹមគ្នានឹងច្បាប់រដ្ឋប្បវេណី (តាមលំដាប់លំដោយគេ

ត្រូវអនុវត្តច្បាប់ពិសេសមុន រួចហើយបើឃើញមានខ្វះនូវការចែងបែបណាមួយនោះ ទើបគេយកច្បាប់រដ្ឋប្បវេណីទូទៅមកអនុវត្តបង្គ្រប់) ។ ក្នុងករណីនេះ គេអាចទាររកសំណងចំពោះការខូចខាតដែលមានលើផលិតផលនោះបាន ដោយផ្អែកលើបញ្ញត្តិទូទៅស្តីពីអំពើអនីត្យានុកូល បញ្ញត្តិស្តីពីការទទួលខុសត្រូវក្នុងការធានាវិការៈ ហើយនិងបញ្ញត្តិស្តីពីការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ដែលមានចែងក្នុងច្បាប់រដ្ឋប្បវេណីស្រាប់ (មាត្រា ៦ នៃច្បាប់ PL ដដែល) ។

ជាការសំខាន់ណាស់ដែលយើងគប្បីត្រូវយល់ដឹងអំពីមូលហេតុ ដែលច្បាប់ពិសេសបែបនេះត្រូវបានគេតាក់តែងឡើង ។ ចូរយើងពិចារណាអំពីករណីនៃគ្រោះអគ្គីភ័យមួយដែលកើតមានឡើងមកពីការឆេះគ្រឿងអេឡិចត្រូនិចដែលគេទិញមកហើយកំពុងតែប្រើប្រាស់ ។ គ្រោះអគ្គីភ័យបានបណ្តាលឱ្យឆេះអស់របស់របរក្នុងផ្ទះ ។ យើងឃើញថា គេអាចទាមទារសំណងនៃការខូចខាតពីហាងលក់គ្រឿងអេឡិចត្រូនិច ឬពីរោងចក្រផលិតបាន ។ ប៉ុន្តែការប្តឹងចំពោះហាងលក់គ្រឿងអេឡិចត្រូនិចនោះ ទំនងជានឹងនាំមកនូវសេចក្តីសន្និដ្ឋានបានថា ហាងលក់មិនអាចប្រមាណដឹងបានជាមុនថាផលិតផលមានវិការៈនោះទេ ។ ហើយក៏មិនមានប្រការអ្វីដែលអាចធ្វើសេចក្តីសន្និដ្ឋានបានចំពោះកំហុសរបស់ហាងលក់ ដើម្បីសំរួលដល់ការប្តឹងថា ហាងនោះខកខានមិនបានអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាលក់នោះទេ ។ បើសិនជាចង់ប្តឹងអំពីការទទួលខុសត្រូវ អាស្រ័យបញ្ញត្តិស្តីពីអំពើអនីត្យានុកូលវិញ ក៏គេមិនងាយរកកំហុសរបស់ហាងឃើញដែរ ។ ដូច្នេះគេគ្រាន់តែអាចរកការទទួលខុសត្រូវរបស់ហាងក្នុងការធានាវិការៈតែប៉ុណ្ណោះ (ទោះជាមិនមានកំហុស ក៏អាចទាមទារបានដែរ) ។ ក៏ប៉ុន្តែ ក្នុងករណីនៃការទទួលខុសត្រូវលើការធានាវិការៈនេះ តាមពិតទៅគឺគេចេញសំណងខូចខាត ឱ្យបានត្រឹមកំរិតទឹកប្រាក់ស្មើរនឹងតំលៃគ្រឿងអេឡិចត្រូនិចតែប៉ុណ្ណោះ (ពីព្រោះនេះជាការទទួលខុសត្រូវចំពោះតំលៃដើមនៃកិច្ចសន្យាលក់ ដោយមិនគិតអំពីកត្តាកំហុសទេ) ។ ចុះចំពោះរោងចក្រផលិតវិញ តើគេមានវិធីដោះស្រាយបែបអ្វី? រោងចក្រផលិតមិនមែនជាដៃគូជាប់កិច្ចសន្យាលក់ជាមួយអ្នកទិញទេ ដូច្នេះអ្នកទិញពិបាកនឹងរកការទទួលខុសត្រូវរបស់រោងចក្រក្នុងការអនុវត្តកាតព្វកច្ចនៃកិច្ចសន្យានោះ ។ ចំណែកការប្តឹងចំពោះអំពើអនីត្យានុកូលវិញ ពិតមែនតែការប្តឹងនេះអាចធ្វើទៅបាន ចំពោះអ្នកដែលមិនមែនជាដៃគូកិច្ចសន្យាក៏ដោយ ប៉ុន្តែជនរងគ្រោះត្រូវបញ្ជាក់បង្ហាញផស្តុតាងថា ចារីបានប្រព្រឹត្តអំពើនេះ ដោយមានកំហុសចេតនា

ឬអចេតនា ។ អ្នកទិញដែលជាជនសាមញ្ញនោះអាចត្រូវ ប្រឈមមុខនឹងការលំបាកយ៉ាងខ្លាំង ក្នុងការរកភស្តុតាងបញ្ជាក់ឱ្យឃើញថា រោងចក្រពិតជាបានប្រព្រឹត្តនូវកំហុសយ៉ាងណាមួយ ក្នុងដំណាក់ការផលិតកម្មនោះ ។ ហេតុដូច្នេះ បានជាគេអនុម័តនូវច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល ដែលសំរួលឱ្យជនរងគ្រោះអាចប្តឹងតតាំងនឹងរោងចក្រផលិតបាន ដោយមិនបាច់បង្ហាញអំពីកំហុសរបស់រោងចក្រទេ គឺគ្រាន់តែត្រូវបញ្ជាក់ថាទំនិញពិតជាមានវិការៈមែនតែប៉ុណ្ណោះ ។ ដោយហេតុពាក្យថា "វិការៈ" នេះមានកំណត់និយមន័យថាជា "ការខ្វះនូវលក្ខណៈសុវត្ថិភាពដែលផលិតផលនោះត្រូវមានជាធម្មតា" (មាត្រា ២ កថាខ័ណ្ឌទី ២) ដូច្នេះ បើសិនណាយើងគិតអំពីករណីនៃទំនិញ ដូចជាទូរទស្សន៍ជាដើម ដែលត្រូវឆេះនៅពេលកំពុងប្រើប្រាស់តាមធម្មតានោះ គឺយើងអាច ឃើញថាការបញ្ជាក់ភស្តុតាងអំពីវិការៈនេះ មានភាពងាយស្រួលច្រើនជាងការបញ្ជាក់ភស្តុតាងអំពីកំហុស ។

ច្បាប់នេះកំណត់ថាផលិតករគឺជាជនដែលផលិត កែច្នៃ ឬនាំចូលនូវផលិតផលជាដើម (ថ្វីត្បិតតែជននោះមិនបានផលិតដោយខ្លួនឯងក៏ដោយ) ដោយរាប់បញ្ចូលទាំងជនដែលបានបង្ហាញឈ្មោះយីហោ សញ្ញាពាណិជ្ជកម្ម និងសញ្ញាណផ្សេងទៀតរបស់ខ្លួន នៅលើផលិតផលនោះក្នុងតួនាទីខ្លួនជាផលិតករ (មាត្រា ២ កថាខ័ណ្ឌទី ៣) ។

ក៏ប៉ុន្តែ ការតម្រូវឱ្យផលិតករទទួលខុសត្រូវចំពោះរាល់ការខូចខាត ដោយគិតទាំងវិការៈដែលសូម្បីតែប្រើវិធីត្រួតពិនិត្យមានបច្ចេកទេសខ្ពស់ក៏មិនអាចរកឃើញទេនោះ គឺជាការតម្រូវមួយមិនសមហេតុផលចំពោះភាគីអ្នកផលិត ។ ដូច្នេះ ច្បាប់នេះមានចែងអំពី "ការតតាំងដោយអះអាងអំពីគ្រោះថ្នាក់ក្នុងការអភិវឌ្ឍន៍" ដោយកំណត់ថា ផលិតករអាចទទួលបាននូវការលើកលែងឱ្យរួចពីការទទួលខុសត្រូវ បើសិនជាផលិតករអាចបញ្ជាក់ភស្តុតាងឱ្យបានឃើញថា នៅពេលដែលគេប្រគល់ផលិតផលមកឱ្យអ្នកទិញនោះ គេមិនអាចប្រមាណនូវវិការៈរបស់ផលិតផលបានទេ ទោះជាប្រើបច្ចេកទេសវិជ្ជាសាស្ត្រយ៉ាងណាក៏ដោយ (មាត្រា ៤ កថាខ័ណ្ឌទី ១) ។

# III. ការសិក្សាអំពីចំណុចសំខាន់នៃការគ្រប់គ្រងដោយឈឺឆ្អាល និងសេចក្ដីចំរើនដោយឥតហេតុ

## ១. ការគ្រប់គ្រងដោយឈឺឆ្អាល

### ១.១. និយមន័យ

មូលហេតុទី ៣ ដែលនាំឱ្យមានការកើតឡើងនៃសិទ្ធិលើបំណុល គឺការគ្រប់គ្រងដោយឈឺឆ្អាល ។ បើស្ដាប់ទៅ ពាក្យនេះមានការពិបាកយល់ មិនដឹងថាត្រូវប្រើក្នុងកាលៈទេសៈយ៉ាងណាទេ ។ ប៉ុន្តែ ចូរយើងពិចារណាអំពីករណីនៃជនម្នាក់ ដែលបានបំពេញនូវការងារអ្វីមួយដើម្បីជាប្រយោជន៍ដល់ជនម្នាក់ផ្សេងទៀត ទោះជាមិនមានការពឹងពាក់ពីអ្នកណាក៏ដោយ ។ ដូចបានរៀបរាប់នៅក្នុងការសិក្សាស្ដីពីកិច្ចសន្យានៅជំពូកទី ៤ រួចហើយ បើមានការពឹងពាក់ពីអ្នកដទៃ ហើយមានការព្រមព្រៀងគ្នាជាមុនថា នឹងសំរេចឱ្យបាននូវអ្វីមួយជូន នោះគឺជាកិច្ចសន្យាអាណត្តិ ។ ក្នុងករណីនៃកិច្ចសន្យា គេអាចទារសំណងចំពោះរាល់ចំណាយផ្សេងៗបាន ។ បើសិនជាគូភាគីបានព្រមព្រៀងគាជាមុនហើយថា នឹងគណនាកំរៃសំរាប់ការងារអ្វីមួយនោះ គឺត្រូវមានសិទ្ធិទាមទារកំរៃផងដែរ ។ ក៏ប៉ុន្តែ បើសិនជាយើងពិចារណាពីករណីមួយទៀតដែលម្ចាស់ផ្ទះជិតខាងបាននាំក្រុមគ្រួសារទៅដើរលេងនៅខាងក្រៅ នៅពេលដែលខ្យល់ព្យុះបក់មកធ្វើឱ្យដំបូលនៃផ្ទះជិតខាងនោះត្រូវបាក់បែក ។ ដោយយល់ថានេះជាការខូចខាតធ្ងន់ធ្ងរ ហើយមានគ្រោះថាក់ផងនោះ យើងបានជួសជុលដំបូលនោះដោយការសំរេចរបស់ខ្លួនយើងផ្ទាល់ ហើយគិតថានេះជាកិច្ចការល្អដែលគួរធ្វើ ទោះជាមិនមានការផ្ដែផ្ដាំទុកជាមុនពីម្ចាស់ផ្ទះឱ្យជួយថែមើលអ្វីក៏ដោយ ។ ដោយសារតែមិនមានការពឹងពាក់ទុកជាមុន នេះមិនមែនជាកិច្ចសន្យាអាណត្តិ ឬកិច្ចសន្យាអ្វីទេ ។ ប៉ុន្តែផ្ទុយទៅវិញ បើសិនជាច្បាប់មិន ឱ្យតំលៃអ្វីទៅនឹងទង្វើរនេះទេ យើងនឹងត្រូវគេប្ដឹងថា បានបំពានលើទ្រព្យសម្បត្តិរបស់អ្នកដទៃ ហើយថែមទាំងអាចត្រូវទទួល

ខុសត្រូវចំពោះអំពើអនីត្យានុកូលផង ។ នេះនឹងនាំឱ្យអ្នកផងទាំងពួងក្នុងសង្គមឈប់ជួយគ្នាទៅវិញទៅមក ។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីកំណត់ថា ក្នុងករណីបែបនេះ ទោះជាយើងមិនមានសិទ្ធិទាមទារកំរៃក៏ដោយ ក៏យើងអាចទាមទារឱ្យគេចេញសងវិញបាននូវត្រឹមចំណាយដែលយើងបានបង់ខាតដែរ (ពោលគឺ ចំណាយដែលនាំប្រយោជន៍មកដល់សាមីខ្លួននោះ) ។ នេះគឺជាករណីនៃការគ្រប់គ្រងដោយឈឺឆ្អាល (ចាប់ពីមាត្រា ៦៩៧ តទៅ) ។

## ១.២. លក្ខខណ្ឌបង្កើត និងអានុភាព

ដើម្បីបង្កើតនូវការគ្រប់គ្រងដោយឈឺឆ្អាល ចាំបាច់ត្រូវតែច្បាស់ថាយ៉ាងហោចណាស់នៅខណៈពេលនៃការគ្រប់គ្រងនេះ មិនមានប្រការអ្វីបំពានលើអត្ថប្រយោជន៍និងឆន្ទៈរបស់សាមីខ្លួនជាភាគីទទួលនោះទេ ។ ក្នុងករណីដែលអំពើមួយត្រូវបានទទួលស្គាល់ថា ជាការគ្រប់គ្រងដោយឈឺឆ្អាលហើយនោះ ភាពខុសច្បាប់នឹងត្រូវបដិសេធចោលដោយចាត់ទុកអំពើនេះថាជាអំពើស្របច្បាប់វិញ ។ អ្នកគ្រប់គ្រងមានសិទ្ធិទាមទារឱ្យសាមីខ្លួនសងមកវិញ នូវរាល់ចំណាយទាំងអស់ដែលអ្នកគ្រប់គ្រងបានបង់ខាតដើម្បីជាប្រយោជន៍របស់សាមីខ្លួននោះ (មាត្រា ៧០២ កថាខ័ណ្ឌទី ១) ។ ដូច្នេះ បើសិនជាអ្នកគ្រប់គ្រងបានបង់ប្រាក់ចំណាយរួចហើយនោះ អ្នកគ្រប់គ្រងអាចទាមទារឱ្យសាមីខ្លួនសងមកវិញបាន ក៏ប៉ុន្តែបើសិនជាអ្នកគ្រប់គ្រងកំពុងតែជំពាក់បំណុលគេ (ឧទាហរណ៍ អ្នកគ្រប់គ្រងបានហៅជាងសំណង់មកជួសជុលដំបូលផ្ទះជិតខាង ប៉ុន្តែនៅមិនទាន់បង់ប្រាក់ជួសជុលនោះទេ) ហើយបើសិនជាប្រាក់ចំណាយនោះបាននាំមកនូវផលប្រយោជន៍មែន អ្នកគ្រប់គ្រងអាចទាមទារឱ្យសាមីខ្លួនបង់ប្រាក់នោះជំនួសខ្លួនបាន ដូចនៅក្នុងករណីនៃកិច្ចសន្យាអាណត្តិយ៉ាងដូច្នោះដែរ (មាត្រា ៦៥០ កថាខ័ណ្ឌទី ២ នឹងត្រូវយកមកអនុវត្ត ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ៧០២ កថាខ័ណ្ឌទី ២) ។

បន្ទាប់ពីបានចាប់ផ្តើមការងារគ្រប់គ្រងហើយ អ្នកគ្រប់គ្រងត្រូវអនុវត្តដូចគ្នានឹងអាណត្តិគាហកនៃកិច្ចសន្យាអាណត្តិនោះដែរ គឺត្រូវមានករណីយកិច្ចយកចិត្តទុកដាក់ក្នុងឋានៈខ្លួនជាអ្នកគ្រប់គ្រងសុចរិត ហើយត្រូវអនុវត្តការគ្រប់គ្រងដោយវិធីសមស្របដើម្បីផ្តល់ជាអត្ថប្រយោជន៍មកសាមីខ្លួន (មាត្រា ៦៩៧ កថាខ័ណ្ឌទី ១) ។ ក្នុងករណីដែលអ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រង

ដោយឈឺឆ្អាល ដើម្បីជួយសាមីខ្លួនឱ្យចេញផុតពីគ្រោះថ្នាក់បន្ទាន់ហើយ បើសិនណាការងារនេះមិនមែនធ្វើឡើងដោយទុច្ចរិត ឬមានកំហុសអ្វីធ្ងន់ធ្ងរទេនោះ អ្នកគ្រប់គ្រងមិនត្រូវមានការទទួលខុសត្រូវអ្វីទាល់តែសោះចំពោះសំណងនៃការខូចខាត ដែលកើតចេញមកពីការងារនេះទេ ។ (ឧទាហរណ៍ ពេលចុះទៅជួយអ្នកដែលកំពុងលង់ទឹក អ្នកចុះទៅជួយនោះបានទាញរហែកអាវរបស់ជនលង់ទឹក ។ បើសិនជាការទាញរហែកអាវនេះជាលទ្ធផលចាំបាច់ ដែលត្រូវកើតមានឡើងទន្ទឹមគ្នានឹងការជួយសង្គ្រោះ ដែលអ្នកចុះទៅជួយមិនអាចជៀសវាងបានទេ នោះគឺអ្នកគ្រប់គ្រងមិនត្រូវទទួលខុសត្រូវចំពោះការខូចខាតនេះឡើយ) ។ នេះគេហៅថាជាការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់ ( មាត្រា ៦៩៨) ។

## ២. សេចក្តីចំរើនដោយឥតហេតុ

### ២.១. និយមន័យ

មូលហេតុទី ៤ ដែលនាំឱ្យមានការកើតឡើងនៃសិទ្ធិលើបំណុល គឺសេចក្តីចំរើនដោយឥតហេតុ។ នេះគឺជាករណីដែលជនណាម្នាក់បានទទួលសេចក្តីចំរើនផល ដោយគ្មានមូល ហេតុសមស្របខាងផ្លូវច្បាប់ទេ ។ ឧទាហរណ៍ ដូចជាករណីដែលលុយរបស់ជនណាម្នាក់ ត្រូវបានបង្វិលចូលទៅក្នុងកុងធនាគាររបស់យើង ដោយការភ័ន្តច្រឡំ ។ អ្នកដែលមានសិទ្ធិពិតប្រាកដអាចមានសិទ្ធិទាមទារឱ្យយើងប្រគល់លុយនោះទៅគេវិញបាន ពីព្រោះនេះជាករណីនៃសេចក្តីចំរើនដោយឥតហេតុ ។ ប៉ុន្តែក្នុងករណីនៃសេចក្តីចំរើនដោយឥតហេតុនេះ វិសាលភាពនៃសិទ្ធិទាមទារការប្រគល់វត្ថុទៅវិញ ត្រូវប្រែប្រួលទៅតាមកត្តាកំណត់ថា តើជាករណីសុចរិត ឬជាករណីទុច្ចរិតនោះ ។ បើជាករណីសុចរិត គឺអ្នកទទួលសេចក្តីចំរើនផលមិនបានដឹងជាមុនថាផលនោះមិនមែនជាផលរបស់ខ្លួននៅឡើយទេ ។ ចំពោះករណីនេះ គេគ្រាន់តែទាមទារឱ្យប្រគល់ទៅវិញនូវបរិមានស្របទៅតាមកំរិតនៃផលដែលមានជាក់ស្តែងនាពេលបច្ចុប្បន្ន ដែលហៅថាជាសេចក្តីចំរើនដែលមានបច្ចុប្បន្ន (មាត្រា ៧០៣) ។ ចំណែកក្នុងករណីទុច្ចរិតវិញ ដែលអ្នកទទួលសេចក្តីចំរើនផលបានដឹងយ៉ាងច្បាស់នៅពេលទទួលផលថា នេះមិនមែនជារបស់ខ្លួនទេ អ្នកទទួលសេចក្តីចំរើនផលនេះត្រូវប្រគល់ទៅវិញនូវផលទាំងអស់ ដែលខ្លួនគេទទួលបានដោយបូកទាំង

ការប្រាក់ទៀតផង ។ ជាងនេះទៅទៀត បើអក្អដែលមានសិទ្ធិពិតប្រាកដបានប្រទះនឹងការខូចខាតហើយនោះ គឺអ្នកទទួលសេចក្តីចំរើនផលត្រូវតែសងសំណងនៃការខូចខាតផងដែរ (មាត្រា ៧០៤) ។

## ២.២.លក្ខខណ្ឌកំណត់

ការប្តឹងចំពោះសេចក្តីចំរើនដោយឥតហេតុ ត្រូវបំពេញនូវល័ក្ខខ័ណ្ឌមួយចំនួនជាមុន ដូចតទៅ: ទីមួយ ត្រូវមានការចំរើនផល ។ ទីពីរ ត្រូវមានការខូចខាត ។ ទីបី ការចំរើនផលនិងការខូចខាតត្រូវមានការពាក់ព័ន្ធគ្នា (ហេតុការដែលបាននាំមកឱ្យមានការចំរើនផលនេះ ក៏ជាកត្តាបណ្តាលឱ្យមានការខូចខាតនោះដែរ) ។ ទីបួន សេចក្តីចំរើនផលមិនមែនបានមកពីហេតុផលសមស្របតាមផ្លូវច្បាប់ទេ ។ ហេតុដូច្នេះ ទោះបីមានសេចក្តីចំរើនផលក៏ដោយ បើមិនមានអ្នកណារងការខូចខាតទេនោះ គឺមិនអាចចាត់ទុកបានថាជាសេចក្តីចំរើនដោយឥតហេតុទេ (ជាការពិតណាស់ ការខូចខាតដែលត្រូវរៀបរាប់ក្នុងករណីនេះមិនមែនសំដៅទៅលើការខាតបង់ទ្រព្យសម្បត្តិតែប៉ុណោះទេ គឺមានរាប់បញ្ចូលទាំងការខកខានមិនបានបង្កើនទ្រព្យសម្បត្តិ ដោយសារតែមានការរារាំង បណ្តាលមកពីសេចក្តីចំរើនដោយឥតហេតុនោះទៀតផង) ។ ពីព្រោះតែសំណងចំពោះសេចក្តីចំរើនដោយឥតហេតុនេះត្រូវបានកំណត់ឡើង ដោយប្រើវិធីគណនាដែលយកតាមតួលេខមួយណាតិចជាងគេ ក្នុងចំណោមតួលេខដែលបង្ហាញឱ្យឃើញរវាងការចំរើនផលនិងការខាតបង់ ។ ដូច្នេះ បើសិនជាជនណាមាក់ត្រូវរងការខាតបង់នូវប្រាក់ចំនួន ៥០ ម៉ឺនយ៉េន ចំណែកការចំរើនផលរបស់ជនមាក់ទៀត ដែលពាក់ព័ន្ធក្នុងរឿងដដែលនេះ គិតជាប្រាក់ត្រូវមានចំនួន ១ លានយ៉េន គឺចំនួនប្រាក់ដែលត្រូវយកមក ពិចារណាក្នុងការកំណត់សំណងចំពោះសេចក្តីចំរើនដោយឥតហេតុនេះ មានចំនួនសរុបត្រឹម ៥០ម៉ឺនយ៉េនតែប៉ុណ្ណោះ ។

## ២.៣. អានុភាព

ដូចមានរៀបរាប់ខាងលើហើយ វិសាលភាពនៃសិទ្ធិទាមទារឱ្យប្រគល់ផលមកវិញនេះប្រែប្រួលទៅតាមកត្តាសុចរិត ឬទុច្ចរិត របស់អ្នកចំរើនផល ។ បើជាករណីសុចរិត គឺអ្នកចំរើនផល

មិនបានដឹងថាផលដែលខ្លួនបានទទួលនោះមិនមែនជារបស់ខ្លួនទេនៅពេលទទួល ។ ចំពោះករណីនោះ គេគ្រាន់តែទាមទារឱ្យប្រគល់មកវិញ នូវផលដែលមានជាក់ស្ដែងប៉ុណ្ណោះ ដែលហៅថាជាសេចក្ដីចំរើនដែលមានបច្ចុប្បន្ន (មាត្រា ៧០៣) ។ ចំណែកក្នុងករណីទុច្ចរិត គឺអ្នកដែលចំរើនផល បានដឹងយ៉ាងច្បាស់ថា ផលដែលខ្លួនបាននេះមិនមែនជារបស់ខ្លួនទេ ។ អ្នកចំរើនផលនេះត្រូវប្រគល់មកវិញនូវផលទាំងអស់ ដែលទទួលបានដោយបូកទាំងការប្រាក់ទៀតផង ។ ជាងនេះទៅទៀត បើអ្នកដែលមានសិទ្ធិពិតប្រាកដបានរងនូវការខូចខាតហើយនោះ អ្នកចំរើនផលត្រូវតែសងសំណងនៃការខូចខាតផងដែរ (មាត្រា ៧០៤) ។ ពោលគឺ ជនដែលបានទទួលផលជាសំភារៈដោយសុចរិត ហើយបានប្រើប្រាស់និងធ្វើឱ្យខូចសំភារៈនោះ ដោយមិនបានដឹងជាមុនថាខ្លួនកំពុងប្រើរបស់អ្នកដទៃផងនោះ ជននេះត្រូវប្រគល់សំភារៈខូចនោះទៅឱ្យគេវិញតែប៉ុណ្ណោះ ។ បើជាទឹកលុយវិញ គឺអាចប្រគលតែចំនួនប្រាក់ដែលមាននៅក្នុងការកាន់កាប់របស់ខ្លួនបានហើយ ។ ប៉ុន្តែបើសិនជាបានយកលុយនោះទៅទុកជាចំណាយជីវភាពប្រចាំថ្ងៃ គឺចំណែកលុយនោះក៏ត្រូវយកមកគិតជាផលដែលមាននាបច្ចុប្បន្នដែរ ។

## ២.៤. ករណីលើកលែងនៃសេចក្ដីចំរើនដោយឥតហេតុ

មានករណីលើកលែងមួយចំនួន ដែលគេមិនអាចមានសិទ្ធិទាមទារការប្រគល់ផលលាភមកវិញបានទេ ទោះជាសេចក្ដីចំរើននោះមិនបានមកពីហេតុផលសមស្របតាមផ្លូវច្បាប់ក៏ដោយ ។ ក្នុងនោះមានករណីនៃការសងបំណុលដែលមិនបានជំពាក់ ពោលគឺករណីដែលសាមីខ្លួនបានសងសំណងឱ្យគេ ដោយដឹងថាខ្លួនមិនបានជំពាក់បំណុលគេទេ (មាត្រា ៧០៥) ។ ហើយក្រៅពីនេះនៅមានការផ្ដល់តាវកាលិកដោយមូលហេតុខុសច្បាប់ទៀតផង (មាត្រា ៧០៨) ។ ដោយសារនេះជាបញ្ញត្តិចែងមិនឱ្យទាមទារការប្រគល់មកវិញនូវតាវកាលិក ដែលបានផ្ដល់ឱ្យដោយមូលហេតុខុសច្បាប់ទេនោះ វាមានសក្ខណៈជាសមមូលស្មើទៅនឹងបញ្ញត្តិចែងអំពីអំពើគតិយុត្តិដែលប្រឆាំងនឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អរបស់សង្គម ដែលមានចែងក្នុងមាត្រា ៩០ ដូចដែលបានរៀបរាប់ជូនខាងលើ ។ ឧទាហរណ៍ កិច្ចសន្យាដែលតម្រូវឱ្យភាគីអ្នកចាញ់ល្បែងស៊ីសង

ត្រូវបង់ប្រាក់ គឺជាកិច្ចសន្យាមោឃៈ ពីព្រោះថាការសន្យានេះមានលក្ខណៈបំពានលើសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទំម្លាប់ល្អរបស់សង្គម ។ កិច្ចសន្យាមោឃៈ មិនអាចនាំឱ្យកើតមានសិទ្ធិនិងកាតព្វកិច្ចទេ ។ ដូច្នេះ តាមការពិត អ្នកចាញ់ល្បែងស៊ីសងមិនមានកាតព្វកិច្ចត្រូវបង់ប្រាក់ទេ ។ ក៏ប៉ុន្តែ បើសិនជាជនណាម្នាក់ចាញ់ល្បែងស៊ីសង ហើយបានឱ្យលុយទៅគេនៅនឹងកន្លែងនោះរួចក្រោយមកអះអាងថាអំពើនេះមោឃៈ ហើយប្តឹងទៅតុលាការទាមទារឱ្យគេសងសុយមកវិញ ។ នេះក៏គេមិនអាចទទួលស្គាល់បានទេដែរ ។ ដោយមូលហេតុថា ច្បាប់មិនសំដៅទៅជួយការពារទេជនណាដែលបានប្រព្រឹត្តអំពើប្រឆាំងនឹងសង្គមដោយខ្លួនឯងផ្ទាល់ រួចនៅពេលដែលឃើញថាខ្លួនត្រូវខាតបង់ប្រយោជន៍ហើយចង់រកវិធីស្តារការខាតបង់មកវិញតាមផ្លូវច្បាប់នោះ (បើពុំនោះសោតទេ ជាលទ្ធផលចុងក្រោយ ច្បាប់នឹងក្លាយទៅជាឧបករណ៍សំរាប់ការពារអំពើប្រឆាំងនឹងសង្គមទៅវិញ) ។ អំពើនេះគឺជាការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់ ហើយត្រូវបានបញ្ញត្តិដោយគោលការណ៍ Clean Hands ដែលគេបានអះអាងតាំងពីបុរាណកាលមក នៅប្រទេសមួយចំនួន ដូចជាប្រទេសអង់គ្លេសជាដើម (គោលការណ៍នេះកំណត់ថា មនុស្សដែលនាំបណ្តឹងក្តីចូលមកតុលាការ ចាំបាច់ត្រូវតែជាមនុស្សដែលបាត់ដៃមិនមានការប្រឡាក់ទេ) ។

# ជំពូកទី ៦
# ច្បាប់ស្តីពីសិទ្ធិលើបំណុល (៣)
# ~ទិដ្ឋភាពទូទៅ~

I. ទម្រង់នៃទិដ្ឋភាពទូទៅអំពីសិទ្ធិលើបំណុល

១. អត្ថន័យទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល

២. លក្ខណៈជាមូលដ្ឋាននៃសិទ្ធិលើបំណុល

៣. សារសំខាន់នៃបញ្ញត្តិនៅក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល សារៈសំខាន់នៅក្នុងការអនុវត្តន៍កិច្ចការអាជីវកម្មជាក់ស្តែង

II. ការសិក្សាចំនុចសំខាន់ៗក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល

១. ប្រភេទនៃសិទ្ធិលើបំណុល

២. ការមិនអនុវត្តកាតព្វកិច្ច

៣. ការថែរក្សាទ្រព្យធននៅក្រោមការទទួលខុសត្រូវ

៤. ទំនាក់ទំនងនៅក្នុងសិទ្ធិលើបំណុលដែលមានពហុភាគី

៥. អនុប្បទានសិទ្ធិលើបំណុល

៦. ការរលត់សិទ្ធិលើបំណុល

III. ក្រមរដ្ឋប្បវេណីនៅក្នុងកិច្ចការផ្លូវច្បាប់នៃសហគ្រាស

# I. ទម្រង់នៃទិដ្ឋភាពទូទៅអំពីសិទ្ធិលើបំណុល

## ១. អត្ថន័យនៃទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល

ដូចបានពិពណ៌នារួចមកហើយ ទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុលគឺជាផ្នែកដែលកំណត់នូវលក្ខណៈចរិត អានុភាព ការផ្ទេរ និងការរលត់នៃសិទ្ធិលើបំណុល ។ ផ្នែកនេះស្ថិតនៅក្នុងជំពូកទី ១ នៃគន្ថីទី ៣ (អំពីសិទ្ធិលើបំណុល) នៅក្នុងក្រមរដ្ឋប្បវេណី ។ ជាបឋម ក្រមរដ្ឋប្បវេណីបានកំណត់វគ្គមួយស្តីពីកម្មវត្ថុនៃសិទ្ធិលើបំណុល ។ គប្បីយល់ថាកម្មវត្ថុដែលពិពណ៌នានៅទីនេះមិនមែនសំដៅទៅលើមូលហេតុដែលជំរុញឱ្យធ្វើអ្វីមួយ ឬគោលបំណងបែបណាមួយទេ គឺសំដៅទៅលើខ្លឹមសារនិងមុខសញ្ញានៃសិទ្ធិលើបំណុល ។ នៅក្នុងវគ្គបន្ទាប់មកទៀត មានបញ្ញត្តិអំពីសុពលភាពនៃសិទ្ធិលើបំណុល ដែលចែងអំពីករណីនៃការបំពានផ្សេងៗទៅលើចំណងកាតព្វកិច្ចដែលជាមូលដ្ឋាននៃសិទ្ធិលើបំណុល សំរាប់គ្រប់គ្រងទំនាក់ទំនងរវាងម្ចាស់បំណុលនិងកូនបំណុល ។ ជាក់ស្តែង គឺមានចែងអំពីការអនុវត្តកាតព្វកិច្ចដោយបង្ខំ សំណងនៃការខូចខាតដោយសាការមិនអនុវត្តកាតព្វកិច្ច ហើយនឹងការរក្សាការពារទ្រព្យសម្បត្តិសំរាប់ការអនុវត្តដោយបង្ខំ ។ល។ ចំពោះសំណងនៃការខូចខាត បណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ច យើងបានធ្វើអត្ថាធិប្បាយពន្យល់ខ្លះៗរួចមកហើយ (អំពីកិច្ចសន្យា) ។ វគ្គទី ៣ ចែងអំពីទំនាក់ទំនងពហុភាគីជាម្ចាស់បំណុលនិងកូនបំណុល ដែលសំដៅទៅលើករណីដែលមានម្ចាស់សិទ្ធិលើបំណុល និងកូនបំណុលជាច្រើននាក់ ។ វគ្គជាបន្តមកទៀតចែងអំពីអនុប្បទាននៃសិទ្ធិលើបំណុល ពោលគឺការផ្ទេរសិទ្ធិបំណុលទៅឱ្យជនដទៃតាមកិច្ចសន្យា ។ រួចហើយជំពូកចុងក្រោយចែងអំពីការរលត់សិទ្ធិលើបំណុល បន្ទាប់ពីបានធ្វើការសងបំណុលចប់សព្វគ្រប់ជាដើម ។

## ២. លក្ខណៈជាមូលដ្ឋាននៃសិទ្ធិលើបំណុល

ដូចបានសិក្សារួចមកហើយថា សិទ្ធិប្រត្យក្សគឺជាសិទ្ធិដែលគេអាចអះអាងចំពោះអ្នកណាក៏បាន ព្រោះជាសិទ្ធិផ្តាច់មុខ និងជាសិទ្ធិដាច់ខាត ។ ដូច្នេះហើយបានជាច្បាប់មានកំណត់ទុកជាមុននូវប្រភេទផ្សេងៗនៃសិទ្ធិនេះ ។ ផ្ទុយនឹងសិទ្ធិប្រត្យក្ស សិទ្ធិលើបំណុលគឺជាសិទ្ធិរបស់បុគ្គល

ម្នាក់ ធ្វើការទាមទារចំពោះបុគ្គលម្នាក់ទៀត ឱ្យប្រគល់អ្វីមួយ ឬឱ្យធ្វើអ្វីមួយ ។ ជាគោលការណ៍ សិទ្ធិនេះមានអានុភាពរវាងភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ពោលគឺមានលក្ខណៈជាសិទ្ធិដែលចងភ្ជាប់ភាគីដោយធៀប (សាបេក្ខភាពនៃសិទ្ធិលើបំណុល) ។ ហេតុដូច្នេះហើយបានជារវាងភាគីទាំងអស់ គេអាចបង្កើតកាតព្វកិច្ច ដែលមានន័យច្រើនបែបច្រើនយ៉ាងបានដោយសេរី កុំឱ្យតែប៉ះពាល់ទៅលើសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទំលាប់ល្អនៅក្នុងសង្គម ។ ម្យ៉ាងទៀត សិទ្ធិលើបំណុលនេះគ្មានលក្ខណៈដាច់ខាត ឬលក្ខណៈផ្តាច់មុខដូចសិទ្ធិប្រត្យ័ក្សឡើយ ហើយក៏គ្មានកំណត់ថាត្រូវតែគោរពតាមគោលការណ៍សិទ្ធិមួយលើវត្ថុមួយ (សិទ្ធិមួយមិនអាចមានទៅលើវត្ថុលើសពីមួយបានទេ) ដែរ ។ ឧទាហរណ៍ ដូចជាករណីថាអ្នកចំរៀង A បានទៅភ្ជាប់កិច្ចសន្យាសំដែងជាមួយសាលមហោស្រព B រួចហើយបានទៅភ្ជាប់កិច្ចសន្យាសំដែងនៅថ្ងៃនិងវេលាម៉ោងដូចគ្នាជាមួយសាលមហោស្រព C ទៀតជាដើម ។ ក្នុងករណីនេះកិច្ចសន្យាទាំងពីរ មានសុពលភាពដូចគ្នា ។ សិទ្ធិទាមទារឱ្យចេញសំដែង និងច្រៀងចំរៀងដែលសាលមហោស្រព B មានទៅលើឈ្មោះ A ទាំងប៉ុន្មាន សាលមហោស្រព C ក៏មានទៅលើឈ្មោះ A ដូចគ្នាដែរ ។ សិទ្ធិទាំងពីរនេះកើតមានឡើងដោយគ្មានបញ្ហាអ្វីឡើយ (ក្នុងករណីនេះ ទាំង B និង C សុទ្ធតែមិនមានអាទិភាពលើគ្នាទេ ។ នេះគេហៅថាជា គោលការណ៍សមភាពរវាងម្ចាស់សិទ្ធិលើបំណុល) ។ ជាការពិតណាស់ដែលថា អ្នកចំរៀង A មានខ្លួនតែមួយ ហើយបើបណ្តោយឱ្យសភាពការណ៍នេះមានដំណើរការជ្រុលទៅមុខ អ្នកចំរៀង A នឹងចេញសំដែងបានតែនៅសាលមហោស្រពណាមួយប៉ុណ្ណោះ ។ នេះមិនមានន័យថា សាលមហោស្រពដែលអ្នកចំរៀង A មិនបានទៅសំដែងនោះត្រូវបាត់បង់សិទ្ធិនោះទេ ។ គឺគ្រាន់តែប្តូរទៅជាសិទ្ធិទាមទារសំណងនៃការខូចខាតវិញ ដោយសារ A មិនអនុវត្តកាតព្វកិច្ចតែប៉ុណ្ណោះ ។

ដោយហេតុថាសិទ្ធិលើបំណុលជាសិទ្ធិដោយធៀប ហើយជាមូលដ្ឋាន គឺមានអំណាចទាមទារ ឬអំណាចប្តឹង ចំពោះតែភាគីម្ខាងទៀតតែប៉ុណ្ណោះ (សិទ្ធិអំណាចក្នុងការយកជំលោះមកប្តឹង) ។ ទោះជាមានទទួលរងការរំខានពីតតិយជនក៏ដោយ ជាគោលការណ៍ គេពុំអាចបញ្ឈប់ ឬបង្អាការរារាំងពីតតិយជនបានឡើយ ។ ប៉ុន្តែ ដូចមានក្នុងឧទាហរណ៍ខាងលើស្រាប់ គេគ្រាន់តែអាចទាមទារនូវសំណងចំពោះការខូចខាត ដែលបណ្តាលមកពីភាគីម្ខាងទៀតមិនបានអនុវត្ត

កាតព្វកិច្ចតែប៉ុណ្ណោះ ប្រសិនបើមូលហេតុនៃការទទួលខុសត្រូវមានស្ថិតនៅជាមួយភាគីម្ខាងទៀតមែន ។ ប៉ុន្តែ ចំពោះករណីលើកលែង ដូចជាសិទ្ធិជួលដែលបានចុះក្នុងបញ្ជី (ជាទូទៅក្រៅពីការផ្ទេរសិទ្ធិលើបំណុលចេញ គឺមិនមានរបបអ្វីសំរាប់ធ្វើការប្រកាសជាសាធារណៈអំពីវត្តមាននៃសិទ្ធិលើបំណុលទេ ។ ក៏ប៉ុន្តែ ដោយឡែកចំពោះសិទ្ធិជួលអចលនទ្រព្យវិញ គេមានរៀបចំនូវរបបចុះបញ្ជី) យុត្តិសាស្ត្រច្បាប់និងទ្រឹស្តីសិក្សា បានទទួលស្គាល់ចំពោះការទាមទារឱ្យបញ្ឈប់និងបង្កាការរាំងពីតតិយជន ដែលគ្មានសិទ្ធិអ្វីនោះ ។ តាមការពិត ចំពោះសិទ្ធិលើបំណុលដទៃទៀត ប្រសិនបើមានអំពើអនីត្យានុកូលក្នុងជំនួញណាមួយ (ដូចដែលបានពិពណ៌នាមុនៗរួចមកហើយនោះ) ដោយប្រើអំពើទុច្ចរិតកញ្ឆក់ដណ្តើមកិច្ចសន្យា រារាំងដល់ការអនុវត្តន៍សិទ្ធិលើបំណុលរបស់អ្នកដទៃ ហើយបើសិនជាអំពើអនីត្យានុកូលនេះត្រូវបានរកឃើញ គេអាចទាមទារឱ្យតតិយជនបង់សំណងនៃការខូចខាតបាន ។ សូមបញ្ជាក់ថា ការទាមទារសំណងនៃការខូចខាតពិតតិយជននេះអាចធ្វើទៅបាន ព្រោះតែមានការរកឃើញនូវអំពើអនីត្យានុកូលតែប៉ុណ្ណោះ គឺមិនមែនដោយសារអានុភាពនៃសិទ្ធិលើបំណុលនោះ ទេ ។

## ៣. សារន័យនៃបញ្ញត្តិនៅក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល សារៈសំខាន់នៅក្នុងការអនុវត្តន៍កិច្ចការអាជីវកម្មជាក់ស្តែង

ទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល ក៏ដូចជាច្បាប់ស្តីពីប្រាតិភោគប្រត្យ័ក្សដែរ គឺជាវិស័យមួយដែលឆ្លុះបញ្ចាំងនូវទំនាក់ទំនងផលប្រយោជន៍ដ៏ស្មុគស្មាញជាទីបំផុត នៅក្នុងសង្គមធ្វើជំនួញ ។ ដូច្នេះ បើយើងបានយល់អំពីការអនុវត្តន៍កិច្ចការជាក់ស្តែងនោះ យើងនឹងយល់រឹតតែច្បាស់នូវខ្លឹមសារនៃមេរៀននេះថែមទៀតជាពុំខាន ។ សូមចាប់អារម្មណ៍ថា ទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុលនិងច្បាប់ស្តីពីប្រាតិភោគប្រត្យ័ក្សនេះ មានការទាក់ទងនឹងចំណុចសំខាន់ៗសឹងតែទាំងអស់ក្នុងកិចការច្បាប់របស់សហគ្រាស ដែលមានជាធ្វើប្រាតិភោគ ការគ្រប់គ្រង និងការប្រមូលមកវិញនូវសិទ្ធិលើបំណុល ។

បើលើកបញ្ហាប្រាតិភោគមកពិភាក្សាឱ្យបានជាក់ស្តែង យើងឃើញថា ចំពោះវត្ថុ ពោលគឺចលនទ្រព្យ ឬអចលនទ្រព្យ ដែលយកទៅដាក់បញ្ចាំដើម្បីខ្ចីប្រាក់នោះ គេហៅថា ប្រាតិភោគជាវត្ថុ) ។

ប៉ុន្តែបើកូនបំណុលពុំមានចលនទ្រព្យ ឬអចលនទ្រព្យ គ្រប់គ្រាន់សំរាប់ដាក់ជាប្រាតិភោគទេ គេត្រូវអាស្រ័យលើទ្រព្យសម្បត្តិទាំងមូលរបស់បុគ្គលណាម្នាក់ ក្រៅពីកូនបំណុលនោះ ដើម្បីតុកធ្វើជាប្រាតិភោគ ។ នេះគេហៅថា ប្រាតិភោគដោយបុគ្គល ។ ជាឧទាហរណ៍តំណាងឱ្យ ប្រាតិភោគដោយបុគ្គលនេះ គឺការធានាដែលមានពិភាក្សានៅខាងក្រោម ។ បើប្រៀបទៅនឹងប្រាតិភោគជាវត្ថុទ្រព្យសម្បត្តិទាំងមូលរបស់បុគ្គល ដែលត្រូវជាប់ការធានា រមែងមានភាពប្រែប្រួលចុះឡើង គ្មានលំនឹងឡើយ ។ ក៏ប៉ុន្តែក្នុងករណីនៃប្រាតិភោគជាវត្ថុ គេត្រូវចុះបញ្ជី ហើយនៅពេលប្រគល់វត្ថុទៀតសោត ក៏គេត្រូវបំពេញបែបបទផ្សេងៗទៀតដែរ ដែលបង្កើតនូវភាពស្មុគស្មាញច្រើនបែបយ៉ាង ។ ចំណែកប្រាតិភោគដោយបុគ្គលវិញ គឺមានភាពងាយស្រួលណាស់ ដោយគេគ្រាន់តែធ្វើកិច្ចសន្យាមួយច្បាប់ប៉ុណ្ណោះ ពោលគឺត្រឹមតែមានការព្រមព្រៀងគ្នារវាងភាគីទាំងអស់តែប៉ុណ្ណោះ ។

លើសពីនេះទៅទៀត សព្វថ្ងៃយើងសង្កេតឃើញមានការនិយមខ្លាំងឡើងៗ នូវការយកសិទ្ធិលើបំណុល ទៅបង្កើតជាប្រាតិភោគដើម្បីខ្ចីទុន ឬក៏លក់សិទ្ធិនេះដើម្បីប្រមូលទុនសំរាប់សហគ្រាសជាដើម ។ តាំងពីដំបូងទីមក ច្បាប់បានកំណត់ដែរនូវការយល់ព្រមចំពោះការធ្វើអបុប្បទានសិទ្ធិលើបំណុលនេះ ក៏ប៉ុន្តែបើសង្កេតទៅលើសេចក្តីនៃបទបញ្ញត្តិយើងឃើញថា ក្នុងក្រមរដ្ឋប្បវេណី ពុំមានការស្មានទុកថាមានការបង្វិលសិទ្ធិលើបំណុលនេះចុះឡើងយ៉ាងសកម្ម ដើម្បីប្រមូលទុនដូច្នេះឡើយ ។ ដំណើរការនេះគេហៅថា ចរន្តកម្មនៃសិទ្ធិលើបំណុល។ ហេតុដូច្នេះទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុលនេះ ក៏មានទំនាក់ទំនងជាប់ជាមួយនឹងបញ្ហាឈានមុខនាបច្ចុប្បន្នកាលដែរ ។

# II. ការសិក្សាចំនុចសំខាន់ៗក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល

## ១. ប្រភេទសិទ្ធិលើបំណុល

យោងតាមគោលការណ៍សេរីភាពនៃកិច្ចសន្យា គេអាចបង្កើតសិទិលើបំណុលបានគ្រប់បែបគ្រប់យ៉ាង ប៉ុន្តែក្នុងនោះគេអាចបែងចែកទៅតាមប្រភេទនៃសិទ្ធិលើបំណុលមួយចំនួន ។ ឧទាហរណ៍ ដូចជាការចែកចេញជា សិទ្ធិលើបំណុលទាក់ទងនឹងវត្ថុដែលបានកំណត់ជាក់លាក់ និងសិទ្ធិលើ

បំណុលដែលបានកំណត់ប្រភេទនៃវត្ថុដែលមានសារៈសំខាន់ជាពិសេស ។

## ១.១. សិទ្ធិលើបំណុលទាក់ទងនឹងវត្ថុដែលបានកំណត់ជាក់លាក់

បើយើងគិតពីបញ្ហាលក់ផ្ទាំងគំនូរ ឬលក់ដីធ្លី យើងនឹងឃើញថាវត្ថុលក់ដូរនេះពុំអាចមានពីរដូចគ្នាឡើយ។ ដូច្នេះសិទ្ធិលើបំណុលគឺជាសិទ្ធិទាមទារតាវកាលិកជាវត្ថុ ដែលបានកំណត់ជាក់លាក់ ។ នេះគេហៅថា សិទ្ធិលើបំណុលទាក់ទងនឹងវត្ថុដែលបានកំណត់ជាក់លាក់ ។ ក្នុងករណីនៃសិទ្ធិលើបំណុលទាក់ទងនឹងវត្ថុដែលបានកំណត់ជាក់លាក់នេះ កូនបំណុលមានកាតព្វកិច្ចនឹងប្រុងប្រយ័ត្នថែរក្សាតាវកាលិក ក្នុងឋានៈខ្លួនជាអ្នកគ្រប់គ្រងល្អរហូតដល់ពេលប្រគល់វត្ថុនោះ (មាត្រា៤០០ ។ ដូច្នេះ ក្នុងករណីតាវកាលិកជាវត្ថុជាក់លាក់សំរាប់លក់ ហើយនៅក្រោយពេលភ្ជាប់កិច្ចសន្យា បើបណ្តែតបណ្តោយទុកវត្ថុនោះចោលហាលភ្លៀងហាលខ្យល់ ធ្វើឱ្យមានការខូចខាតនោះ គឺវាត្រូវក្លាយទៅជាការមិនអនុវត្តកាតព្វកិច្ច ហើយត្រូវមានការទទួលករណីយកិច្ចសងសំណងនៃការខូចខាត) ។ ក្នុងករណីដែលតាវកាលិកត្រូវបាត់ មុនពេលប្រគល់វត្ថុ (ដោយហេតុថាមិនមានអ្វីអាចជាវត្ថុជំនួសទេនោះ) វានឹងទៅជាការមិនអាចអនុវត្តកាតព្វកិច្ចបាន ហើយត្រូវក្លាយទៅជាសិទ្ធិទាមទារសំណងនៃការខូចខាតវិញ។

## ១.២. សិទ្ធិលើបំណុលដែលបានកំណត់ប្រភេទនៃវត្ថុ

### ១.២.១. ទ្រឹស្តីទូទៅ

ឧបមាដូចជាការលក់ស្រាបៀរម៉ាក A ដបធំមួយឡូជាដើម ដែលអាចយកស្រាបៀរម៉ាកដដែលដបផ្សេងមកជំនួសបានគេហៅថា សិទ្ធិលើបំណុលទាក់ទងនឹងប្រភេទនៃវត្ថុ ។ ចំពោះសិទ្ធិលើបំណុលដែលបានកំណត់ប្រភេទនៃវត្ថុ (ដោយហេតុថាមានវត្ថុជំនួសបាន) ក្រមរដ្ឋប្បវេណីពុំមានកំណត់នូវករណីយកិចរបស់កូនបំណុលក្នុងការគ្រប់គ្រងថែរក្សាវត្ថុទេ ប៉ុន្តែជាជំនួសនឹងករណីយកិច្ចនេះ ច្បាប់បានកំណត់ថា ប្រសិនបើតាវកាលិកត្រូវបាត់បង់មុនពេលប្រគល់នោះ កូនបំណុលមានករណីយកិច្ចស្វះស្វែងរកវត្ថុផ្សេង ដែលមានប្រភេទដូចគ្នាពីទីផ្សារមក ដើម្បីប្រគល់

ឱ្យ (ពោលគឺ ឧបមាថា ហាងលក់ស្រាបៀរដែលត្រូវបានអ្នកទិញបញ្ជាឱ្យយកស្រាបៀរទៅឱ្យនោះ បើដបស្រាបៀរនោះបែកនៅក្នុងហាងរបស់ខ្លួន ម្ចាស់ហាងត្រូវយកស្រាបៀរដបផ្សេងម៉ាកដដែលទៅឱ្យអ្នកទិញ) ។

### ១.២.២. ការកំណត់សិទ្ធិលើបំណុលដែលបានកំណត់ប្រភេទនៃវត្ថុ

ទោះបីដូចនៅក្នុងឧទាហរណ៍ស្រាបៀរខាងលើក៏ដោយ នៅពេលអនុវត្តកិច្ចសន្យានៅដំណាក់កាលណាមួយ ជួនកាលអាចមានការកំណត់ជាក់លាក់ថា "ត្រូវយកមួយឡូនេះ" ទោះជាក្នុងចំណោមស្រាបៀរប្រភេទតែមួយក៏ដោយ ។ ចំពោះការបញ្ជាទិញស្រាបៀរ (តាមទូរស័ព្ទជាដើម) តាមធម្មតាគ្មានការកំណត់ថាយកដបណាទេ មុនពេលម្ចាស់ហាងយកទៅឱ្យដល់ផ្ទះអ្នកទិញហើយបង្ហាញប្រាប់ថា "នេះស្រាបៀរដែលបានបញ្ជា"នោះ។ ក៏ប៉ុន្តែ ចំពោះស្រាវិស្គីសំរាប់ជាជមន្ទូនដែលអ្នកទិញបានមកទិញដល់ហាងដោយរើសយកពីទូរវិញ នៅពេលដែលខ្ចប់ស្អាតបាត ហើយអ្នកទិញបានបញ្ជាឱ្យយកទៅឱ្យដល់ផ្ទះភ្ញៀវនោះ គេអាចនិយាយបានថានៅដំណាក់កាលនេះមានការកំណត់យកដបណាមួយជាក់លាក់ហើយ ។ នេះគេហៅថាជាការ "កំណត់" នូវសិទ្ធិលើបំណុលដែលបានកំណត់ប្រភេទនៃវត្ថុ ។

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ក្នុងករណីដែលកូនបំណុលបានប្រគល់វត្ថុសន្យា ទៅម្ចាស់បំណុលរួចជ្រះស្រឡះហើយក្តី ឬមួយនៅពេលដែលមានការយល់ព្រមពីម្ចាស់បំណុលនូវការកំណត់វត្ថុត្រូវប្រគល់នោះក្តី ចាប់ពីពេលនោះតទៅ វត្ថុនោះត្រូវចាត់ថាជាវត្ថុដែលត្រូវប្រគល់ (មាត្រា ៤០១ កថាខ័ណ្ឌទី ២) ។ ជាលទ្ធផលបន្ទាប់ពីមានការកំណត់ជាក់លាក់នូវកម្មវត្ថុហើយ សិទ្ធិលើបំណុលដែលបានកំណត់ប្រភេទនៃវត្ថុ ត្រូវបានចាត់ទុកដូច សិទ្ធិលើបំណុលទាក់ទងនឹងវត្ថុដែលបានកំណត់ជាក់លាក់ដែរ ហើយកូនបំណុលមានករណីយកិច្ចនឹងគ្រប់គ្រងថែរក្សាឱ្យបានល្អ នូវវត្ថុសន្យានោះ (នេះគឺជាការពង្រឹងដល់ករណីយកិច្ចគ្រប់គ្រងថែរក្សាដែលមានន័យថា ប្រសិនបើវត្ថុសន្យានោះវិនាសបាត់បង់ កូនបំណុលមានករណីយកិច្ចត្រូវសងសំណងនៃការខូចខាតទៅឱ្យម្ចាស់បំណុល ប៉ុន្តែពុំមានករណីយកិច្ចនឹងទៅរកវត្ថុប្រភេទដូចគ្នាមកជំនួសទេ )។

### ១.២.៣. សិទ្ធិលើបំណុលដែលមានដាក់កំរិតព្រំដែននៃប្រភេទវត្ថុ

បែបបទមួយទៀតនៃសិទ្ធិលើបំណុលដែលបានកំណត់ប្រភេទនៃវត្ថុ គឺការដាក់កំរិតព្រំដែននៃប្រភេទវត្ថុ (ដូចជាភូមិភាគជាដើម) ដែលគេហៅថា សិទ្ធិលើបំណុលដែលមានដាក់កំរិតព្រំដែននៃប្រភេទវត្ថុ ។ ឧទាហរណ៍ ដូចជាថាមានកាតព្វកិច្ចប្រគល់អង្ករសុម៉ាលីដែលទុកក្នុងឃ្លាំង A ចំនួន ៣០០គីឡូក្រាមជាដើម។ នៅក្នុងករណីដូចនេះ ប្រសិនបើអស់អង្ករសុម៉ាលីនៅក្នុងឃ្លាំងA នោះនឹងត្រូវចាត់ទុកថាគ្មាន លទ្ធភាពនឹងអនុវត្តកាតព្វកិច្ចជាបន្តទៅទៀតទេ ហើយក៏គ្មានទទួលករណីយកិច្ចទៅរកវត្ថុប្រភេទដដែលពីទីផ្សារមកជំនួសវិញទេ (មានន័យថា ប្រសិនបើអង្ករសុម៉ាលីក្នុងឃ្លាំង A ត្រូវភ្លើងឆេះខ្ទេចអស់នោះ កូនបំណុលនឹងនៅសល់តែករណីកិច្ចមួយទេ គឺត្រូវសងសំណងនៃការខូចខាតប៉ុណ្ណោះ)។

## ១.៣. សិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់

ចំពោះសិទ្ធិលើបំណុលដែលតម្រូវឱ្យសងជាប្រាក់ ដែលគេហៅថា សទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ គឺជា សិទ្ធិលើបំណុលដែលបានកំណត់ប្រភេទនៃវត្ថុ ដែលយើងអាចនិយាយបានថា ជាសិទ្ធិលើបំណុលដែលមានលក្ខណៈហ្មត់ចត់ណាស់ ហេតុដូច្នេះហើយទើបមានកំណត់នូវបទបញ្ញត្តិពិសេស១ សំរាប់កាតព្វកិច្ចសងជាប្រាក់នេះ ។ អត្រាការប្រាក់ដែលច្បាប់បានកំណត់សំរាប់កិច្ចការរដ្ឋប្បវេណី គឺ ៥ ភាគរយក្នុងមួយឆ្នាំ (មាត្រា៤០៤) ។

## ១.៤. សិទ្ធិលើបំណុលដែលជាប្រាក់ដើម និងសិទ្ធិលើបំណុលដែលជាការប្រាក់

នៅក្នុងករណីខ្ចីប្រាក់ មានសិទ្ធិលើបំណុលដែលជាប្រាក់ដើម និងសិទ្ធិលើបំណុលដែលជាការប្រាក់ ក៏ប៉ុន្តែម្ចាស់បំណុលអាចបំបែកសិទ្ធិលើបំណុលជាការប្រាក់ ដែលកើតមានរួចហើយដើម្បីយកមកដោះស្រាយដាច់ដោយឡែកពីបាន ។ ឧបមាថាបើម្ចាស់បំណុលមានប្រាក់ដើម ៥ លានយ៉េនឱ្យខ្ចី ហើយទទួលផលការប្រាក់ ២៥ ម៉ឺនយ៉េនក្នុងមួយឆ្នាំ១ ។ ជាការពិតណាស់ដែលថាម្ចាស់បំណុលអាចផ្ទេរសិទ្ធិទាមទារប្រាក់ដើម (ដែលមានការប្រាក់ភ្ជាប់ជាមួយផងនោះ) ទៅអ្នកដ

ទៃបាន ។ ក៏ប៉ុន្តែ ប្រសិនបើការប្រាក់មួយឆ្នាំមុនដែលកើតមានហើយនោះមិនទាន់បានទទួលទេ ម្ចាស់បំណុលអាចធ្វើអានុប្បទានសិទ្ធិលើបំណុលជាការប្រាក់ចំនួន ២៥ ម៉ឺនយ៉េននោះ ទៅអ្នកដទៃក៏បានដែរ ។

### ១.៥. សិទ្ធិលើបំណុលតាមការជ្រើសរើស

ដូចក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាថាយក "កង់មួយគ្រឿង ឬប្រាក់ចំនួន ១ លានយ៉េន" មកធ្វើជាតាវកាលិកជាដើម សិទ្ធិលើបំណុលដែលគេបានកំណត់ជ្រើសរើសយកវត្ថុមួយក្នុងចំណោមវត្ថុជាច្រើនផ្សេងៗ មកធ្វើជាតាវកាលិកនោះ ហៅថាជាសិទ្ធិលើបំណុលតាមការជ្រើសរើស (មាត្រា ៤០៦) ។ ដោយហេតុថា វត្ថុដែលត្រូវបានជ្រើសរើសនោះ មានលក្ខណៈខុសគ្នាយ៉ាងច្បាស់លាស់ពីមួយទៅមួយ ដូច្នេះសិទ្ធិលើបំណុលនេះខុសគ្នាទាំងស្រុងទៅនឹង "សិទ្ធិលើបំណុលដែលមានកំណត់វត្ថុជាក់លាក់នៅក្នុងប្រភេទនៃវត្ថុ" ដែលអនុញ្ញាតិឱ្យគេជ្រើសរើសវត្ថុជំនួសបានក្នុងប្រភេទនៃវត្ថុតែមួយ ដូចជាថា "អាចរើសបីយ៉ែរមួយកេះនេះ ឬមួយកេះនោះ (ដែលសុទ្ធតែជាបីយ៉ែនោះ) បាន" ។

## ២. ការមិនអនុវត្តកាតព្វកិច្ច

### ២.១. ការអនុវត្តន៍កាតព្វកិច្ចដោយបង្ខំ

ការទទួលកម្លាំងជំនួយពីអាជ្ញាធររដ្ឋដើម្បីបង្ខំឱ្យភាគីជាដៃគូអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅពេលដែលភាគីដៃគូនោះមិនគោរពកិច្ចសន្យាហៅថាការអនុវត្តន៍ដោយបង្ខំ ។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុននិងច្បាប់ស្តីពីការអនុវត្តន៍កិច្ចការរដ្ឋប្បវេណីនៃប្រទេសជប៉ុន បានកំណត់នូវវិធីធ្វើការបង្ខំឱ្យអនុវត្តកាតព្វកិច្ចដោយចែកជា៣ប្រភេទដូចខាងក្រោមនេះ ។

#### ២.១.១. ការបង្ខំផ្ទាល់

នេះជាវិធីដែលអាជ្ញាធររដ្ឋចេញមុខបង្ខំផ្ទាល់ទៅកូនបំណុលឱ្យសងប្រាក់ ឬប្រគល់វត្ថុ ទោះបីជាកូនបំណុលមានឆន្ទៈដូចម្តេចក៏ដោយ។ពោលគឺភ្នាក់ងារអនុវត្តប្រចាំអាជ្ញាធររដ្ឋនឹងចេញ

ទៅដល់កន្លែងកូនបំណុលតែម្តង។

### ២.១.២. ការឱ្យតតិយជនអនុវត្តជំនួស

នេះជាវិធីដែលឱ្យតតិយជន (ជនទី៣) អនុវត្តសេចក្តីនៃកាតព្វកិច្ចនេះជំនួសឱ្យកូនបំណុល ហើយអជ្ញាធររដ្ឋនឹងធ្វើការទាមទារសោហ៊ុយទាំងឡាយពីកូនបំណុល។ ឧទាហរណ៍ដូចជាក្នុងករណីដែលសហគ្រាសសំណង់មួយបានបញ្ឈប់ការសាងសង់នៅពាក់កណ្តាលទី គេអាចពឹងសហគ្រាសសំណង់មួយផ្សេងទៀតឱ្យបន្តការសាងសង់នោះបានដោយទាមទារសោហ៊ុយដែលបានចំណាយទាំងឡាយពីសហគ្រាសដើមមកវិញ ។

### ២.១.៣. ការបង្ខំមិនចំពោះ

នេះជាវិធីដែលត្រូវអនុវត្តនៅក្នុងករណីដែលទាំងការបង្ខំផ្ទាល់ និងការឱ្យតតិយជនអនុវត្តជំនួស សុទ្ធតែមិនអាចយកមកអនុវត្តបាន ។ តុលាការបញ្ជាឱ្យកូនបំណុលបង់ប្រាក់មួយចំនួនរហូតដល់ពេលបានបំពេញកាតព្វកិច្ចរបស់ខ្លួន ពោលគឺជាវិធីគាបសង្កត់តាមផ្លូវចិត្តសាស្រ្តទៅលើកូនបំណុល ដើម្បីបង្ខំឱ្យគេអនុវត្តកាតព្វកិច្ច។ ឧទាហរណ៍ វិធីនេះនឹងត្រូវអនុវត្ត ក្នុងករណីដែលមានការបំពានជាបន្តបន្ទាប់លើកាតព្វកិច្ចមិនឱ្យបញ្ចេញសូរស័ព្ទថ្លង់ឡូឡានោះ (តុលាការអាចចេញសាលក្រម "បញ្ជាឱ្យបង់ប្រាក់ ១០ ម៉ឺនយ៉េនក្នុងមួយថ្ងៃរហូតដល់ថ្ងៃឈប់ធ្វើឱ្យថ្លង់ឡូឡាជាដើម)។

នៅប្រទេសជប៉ុន ជំរើស ២.១.២. មិនអាចអនុវត្តបានទេ បើសិនជាគេអាចអនុវត្តនូវ ជំរើស ២.១.១. ។ ហើយជំរើស ២.១.៣. ធ្លាប់អនុវត្តបានតែក្នុងករណីដែលគ្មានលទ្ធភាពសំរេចបាននូវជំរើស ២.១.១. និង ២.១.២. ។ ប៉ុន្តែវិសោធនកម្មនៃច្បាប់ស្តីពីការអនុវត្តរឿងរដ្ឋប្បវេណី បានជួយពង្រីកវិសាលភាពនៃការអនុវត្តវិធីបង្ខំមិនចំពោះ ។

## ២.២. សំណងចំពោះការខូចខាតដោយសារមិនអនុវត្តកាតព្វកិច្ច

### ២.២.១. លក្ខណៈទូទៅ

បញ្ហានេះយើងបានពិពណ៌នាត្រួសៗរួចខ្លះហើយនៅក្នុងជំពូកទី៤ (អំពីកិច្ចសន្យា) ។ ការមិនអនុវត្តកាតព្វកិច្ច (គ្មានការអនុវត្តន៍ទៅតាមសេចក្តីនៃកិច្ចសន្យា) ចែកចេញជា៣ប្រភេទគឺៈ ការយឺតយ៉ាវក្នុងការអនុវត្តន៍ អលទ្ធភាពក្នុងការអនុវត្តន៍ និងការអនុវត្តន៍មិនបានពេញលេញ ។ ទាំង៣ប្រភេទនេះជាមូលហេតុតម្រូវឱ្យកូនបំណុលបង់សំណងនៃការខូចខាត ដោយសារមិនអនុវត្តកាតព្វកិច្ចកាលណាមានហេតុផលថាជាកំហុសខាងកូនបំណុល(ដោយចេតនាក្តី ឬដោយកំហុសរបស់កូនបំណុលផ្ទាល់ក្តី ឬមួយដោយចេតនា ឬដោយកំហុសរបស់អ្នកជួយអនុវត្ត កាតព្វកិច្ចក្តី។ ក៏ប៉ុន្តែបើមានរញ្ជួយផែនដីដែលជាករណីប្រធានស័ក្តិ(មិនអាចជៀសរួច) ធ្វើឱ្យដាច់ផ្លូវជាហេតុនាំឱ្យមានការយឺតយ៉ាវ ក្នុងការអនុវត្តន៍កាតព្វកិច្ចជាដើមវិញ ដោយហេតុថានេះមិនមែនជាកំហុសខាងកូនបំណុលទេ ដូច្នេះកូនបំណុលនឹងមិនទទួលខុសត្រូវចំពោះការមិនបានអនុវត្តកាតព្វកិច្ចនោះឡើយ )។

### ២.២.២. ទំហំនៃសំណងការខូចខាត

ក្រមរដ្ឋប្បវេណីបានកំណត់នូវទំហំនៃសំណងដូចតទៅៈ កូនបំណុលត្រូវទទួលបន្ទុកបង់សំណងនៃការខូចខាតណាដែលអាចកើតឡើងជាធម្មតា ដោយសារតែការមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។ នេះគេហៅថាការខូចខាតធម្មតា រីឯការខូចខាតដែលកើតឡើងដោយសារមានព្រឹត្តិការណ៍ពិសេសណាមួយវិញនោះ កូនបំណុលត្រូវទទួល បន្ទុកបង់តែសំណងនៃការខូចខាតណាដែលខ្លួនអាចប្រមើលដឹងជាមុនបានតែប៉ុណ្ណោះ (មាត្រា ៤១៦ ហៅថាទ្រឹស្តីដាក់ទំហំនៃសំណង) ។ ថាតើអ្វីទៅជាការខូចខាតធម្មតា ហើយអ្វីទៅជាការខូចខាតពិសេសនោះ? ទាំងនេះអាស្រ័យទៅលើករណីជាក់ស្តែងនីមួយៗ។ ឧទាហរណ៍ដូចជាកិច្ចសន្យាលក់ផ្ទះជាដើម នៅក្នុងករណីដែលអ្នកលក់ A ប្រគល់ផ្ទះដោយមានការយឺតយ៉ាវ ១ ខែដែលជាហេតុនាំឱ្យអ្នកទិញ B បង្ខំចិត្តទៅជួលផ្ទះផ្សេងនៅបណ្តោះអាសន្ន ១ ខែដែរនោះ ជាទូទៅយើងអាចចាត់ទុកថា នេះគឺជាការខូចខាតធម្មតា។

ក៏ប៉ុន្តែក្នុងករណីដែលអ្នកទិញ B បានធ្វើកិច្ចសន្យាលក់បន្តទៅអ្នកដទៃផ្សេងទៀត ហើយរងការខាតបង់នូវភាគចំណេញដោយហេតុមកពីការប្រគល់ផ្ទះធ្វើដោយយឺតយ៉ាវ បណ្តាលឱ្យ B ត្រូវលុបចោលកិច្ចសន្យាលក់បន្តជាទូទៅ យើងអាចចាត់ទុកថា នេះគឺជាការខូចខាតពិសេស។ ប្រសិនបើអ្នកលក់ A (ដែលមានតួនាទីជាកូនបំណុល) បានដឹងអំពីការលក់បន្តនេះជាមុន ឬក៏អាចប្រមើលដឹងទុកជាមុនបាននោះ ទើបសំណងនេះត្រូវនៅក្នុងបន្ទុករបស់កូនបំណុល (គឺអ្នកលក់ A ) ។

### ២.២.៣. ការទូទាត់នូវកំហុស

ក្នុងសំណងនៃការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច អាចមានការកាត់បន្ថយចំនួនទឹកប្រាក់នៃសំណងបាន ដោយពិចារណាអំពីកំរិតនៃកំហុសរបស់ភាគីម្ចាស់បំណុលនោះ ។ (មាត្រា ៤១៨ ។ សឹងតែដូចគ្នាទៅនឹងការទូទាត់នូវកំហុសក្នុងអំពើអនីត្យានុកូល (មាត្រា ៧២២) ដែលបានសិក្សារួចមកហើយ ។ សូមអានជំពូកទី ៥ វគ្គ II.៤.៣.) ។

### ២.២.៤. ការកំណត់ជាមុននូវចំនួននៃសំណងការខូចខាត

ភាគីនៃកិច្ចសន្យា អាចសន្យាកំណត់ទុកជាមុនបាន នូវចំនួននៃសំណងសំរាប់ការខូចខាត ។ ក្នុងករណីនេះ តុលាការមិនអាចតម្លើង ឬកាត់បន្ថយចំនួនដែលបានសន្យាគ្នានេះបានទេ ។ (មាត្រា ៤២០ កថាខ័ណ្ឌទី ១) ។

### ២.២.៥. ឧបាទេសកម្មនៃអ្នកសង

នៅពេលដែលម្ចាស់បំណុលទទួលបានសំណងទាំងមូលនៃវត្ថុ ឬសិទ្ធិ ដែលជាកម្មវត្ថុនៃសិទ្ធិលើបំណុលនោះ កូនបំណុលត្រូវទទួលបានដោយស្វ័យប្រវត្ត នូវឋានៈជាអ្នកជំនួសឱ្យម្ចាស់បំណុល ទាក់ទងដល់វត្ថុ ឬសិទ្ធិ ដែលជាកម្មវត្ថុនៃសំណងនោះ ។ នេះគេហៅថាជា ឧបាទេសកម្មនៃអ្នកសង (មាត្រា ៤២២ ។ សូមអានវគ្គ ៣.១.) ។ ឧទាហរណ៍ អ្នកដែលបានសងតាមចំនួននៃសំណងទាំងមូលទៅឱ្យម្ចាស់បំណុល (កម្មសិទ្ធិកនៃទំនិញ) សំរាប់ទំនិញដែលត្រូវបាត់ នៅក្រោមការគ្រប់គ្រងរបស់ខ្លួនអាស្រ័យកិច្ចសន្យានោះ ក្រោយមកបើសិនជាគេរកឃើញទំនិញមកវិញ អ្នកសងត្រូវបានទទួលនូវកម្មសិទ្ធិលើទំនិញនោះ (ជំនួសឱ្យកម្មសិទ្ធិករដើម) ។

## ២.៣. ការយឺតយ៉ាវរបស់ម្ចាស់បំណុលក្នុងការទទួល

ម្យ៉ាងវិញ នៅក្នុងករណីដែលកូនបំណុលត្រៀមនឹងអនុវត្តកាតព្វកិច្ចរបស់ខ្លួនមែន តែម្ចាស់បំណុលមិនទទួលយកការអនុវត្តន៍នេះ គេឱ្យឈ្មោះថាការយឺតយ៉ាវក្នុងការទទួល ។ មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ម្ចាស់បំណុលត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវ ដែលកើតឡើងពីការប្រកែកមិនព្រមទទួល ឬពីការមិនទទួលយកសំណាងដល់ កូនបំណុលបានប្រគល់ឱ្យខ្លួន (ការប្រគល់សំណាងមានន័យថា ប្រសិនបើកិច្ចសន្យាថាជាកាតព្វកិច្ចត្រូវយកទៅប្រគល់ឱ្យ គឺការយកវត្ថុសន្យានោះទៅប្រគល់ជាក់ស្តែងដល់ម្ចាស់បំណុល ហើយប្រសិនបើកិច្ចសន្យាថា ជាកាតព្វកិច្ចដែលម្ចាស់បំណុលត្រូវទៅយក នោះគឺការជូនដំណឹងរបស់កូនបំណុលប្រាប់ឱ្យមកយកតាវកាលិកដែលខ្លួនបានត្រៀមប្រគល់ចប់សព្វគ្រប់ហើយនោះ) ។ ពោលឱ្យចំទៅគឺថាកូនបំណុលរួចផុតពីការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះ ហើយចំពោះការគ្រប់គ្រងតាវកាលិកទៀតសោត ដែលកាលពីមុនកូនបំណុលត្រូវមានកាតព្វកិច្ចគប់គ្រងថែរក្សាឱ្យបានល្អក្នុងឋានៈខ្លួនជាអ្នកគ្រប់គ្រងល្អនោះ ឥឡូវត្រូវបានបន្ថយមកនៅត្រឹមការថែរក្សាធម្មតាទុកដូចជារបស់ផងខ្លួនមកវិញ ពោលគឺមានការទម្លាក់កំរិតកាតព្វកិច្ចគ្រប់គ្រងតាវកាលិក (ចំពោះ"ការថែរក្សាធម្មតាទុកដូចជារបស់ផងខ្លួន" ចូរអានជំពូក ទី២ស្តីពីកិច្ចសន្យាផ្ញើទុកគ្មានសំណង)។ ម្យ៉ាងទៀត ចំពោះបញ្ហាថាតើអ្នកណា ជាអ្នកត្រូវទទួលបន្ទុកគ្រោះហានិភ័យនៅក្នុងករណីដែលតាវកាលិកត្រូវវិនាសបាត់បង់មុនពេលប្រគល់នោះគេយល់ថា ទោះបីជាមានការព្រមព្រៀងពីមុនមកយ៉ាងដូចម្តេចក៏ដោយការទទួលបន្ទុកគ្រោះហានិភ័យ ដែលកើតមានឡើងដោយសារការយឺតយ៉ាវក្នុងការទទួលនេះ ត្រូវធ្លាក់ទៅលើម្ចាស់បំណុលវិញ។ ក៏ប៉ុន្តែនៅមានការជជែកពិភាក្សាគ្នាពុំដាច់ស្រេចនៅឡើយថា តើនេះជាលទ្ធផលចេញមកពីការយឺតយ៉ាវក្នុងការទទួល ឬមួយក៏ជាលទ្ធផលចេញមកពីការប្រគល់សំណាង (មាត្រា ៤៩២) ទេ? មួយវិញទៀត ទស្សនៈភាគច្រើនយល់ថាការយឺតយ៉ាវក្នុងការទទួលនេះ ជះឥទ្ធិពលតាមផ្លូវច្បាប់ក្នុងកំរិតមួយដូចបានរៀបរាប់ខាងលើតែប៉ុណ្ណោះ ហើយមិនចាត់ថានេះជា "ការមិនអនុវត្តកាតព្វកិច្ច" របស់ម្ចាស់បំណុលឡើយ (មានទស្សនៈមួយទៀតដែលគិតថាការទទួល គឺជាកាតព្វកិច្ចហើយម្ចាស់បំណុលមិនអនុវត្តកាតព្វកិច្ច

នេះ) ។ មានន័យថា ភាគីកូនបំណុលគ្មានសិទ្ធិរហូតដល់ទៅទាមទារបញ្ញាសទៅ ម្ចាស់បំណុលវិញ ដោយសុំធ្វើការរំលាយកិច្ចសន្យា ឬសុំឱ្យបង់សំណងចំពោះការខូចខាត (សំណងជំងឺចិត្តពិការមិនទទួលវត្ថុសន្យា) នោះឡើយ ។ ចំពោះបញ្ហានេះទស្សនៈចំបងសព្វថ្ងៃបានអះអាងនូវទស្សនៈសំរបសំរួលមួយថា នៅក្នុងកិច្ចសន្យាដែលម្ចាស់បំណុលមានកាតព្វកិច្ចទទួលយក តួយ៉ាងដូចជាកិច្ចសន្យាលក់ជាដើម គេគប្បីទទួលស្គាល់នូវការមិនអនុវត្តកាតព្វកិច្ចរបស់ម្ចាស់បំណុលនេះ (ពោលគឺទស្សនថាបើអ្នកទិញមិនទទួលតាវកាលិកទេ ចាត់ទុកថាអ្នកទិញមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន)។

# ៣. ការថែរក្សាទ្រព្យធននៅក្រោមការទទួលខុសត្រូវ

## ៣.១. អ្វីទៅដែលហៅថាការថែរក្សាទ្រព្យធន នៅក្រោមការទទួលខុសត្រូវ?

ដូចជាក្នុងករណីទទួលទុនពីធនាគារជាដើម តាមធម្មតាធនាគារដែលជាអ្នកឱ្យខ្ចីប្រាក់តែងតែទទួលយកទ្រព្យធានា (ហ៊ីប៉ូតែក វត្ថុបញ្ចាំ) ពីអ្នកខ្ចីប្រាក់ ។ ក៏ប៉ុន្តែនៅក្នុងរបររកស៊ីធ្វើជំនួញដែលធ្លាប់ធ្វើជាហូរហែជាមួយគ្នាដូចជាការយកទំនិញមកប្រគល់ជាមុនទើបទទួលប្រាក់ជាក្រោយជាដើមទោះបីជាប្រាក់ថ្លៃទំនិញនោះនៅកប់ជាច្រើនដងក៏ដោយជាទូទៅពុំមានការយកវត្ថុទៅដាក់បញ្ចាំធានារាល់តែលើកនោះទេ នេះគឺមកពីមានការទុកចិត្តគ្នាទៅវិញទៅមក ។ នៅក្នុងករណីដូចខាងលើគេឱ្យឈ្មោះម្ចាស់បំណុលបែបនេះថា ម្ចាស់បំណុលទូទៅ ចែកដាច់ពី ម្ចាស់បំណុលដែលដាក់អាទិភាពទៅលើការហូតយកទ្រព្យធានាធ្វើជាសំណង ។ បើដូច្នេះដើម្បីធ្វើឱ្យការទាមទារសំណងរបស់ម្ចាស់បំណុលទូទៅសំរេចទៅបាន លុះត្រាតែកូនបំណុលមានទ្រព្យធនគ្រប់គ្រាន់ល្មមសងបានជាមុនសិន។ ទ្រពធនរបស់កូនបំណុលទាំងអស់ ដែលអាចទូទាត់ដើម្បីសងម្ចាស់បំណុលបានហៅថាទ្រព្យធននៅក្រោមការទទួលខុសត្រូវ។ ទ្រព្យធននៅក្រោមការទទួលខុសត្រូវនេះ មានការថយចុះឬកើនថែមទៅតាមសភាពការប្រែប្រួលជាយថាហេតុនៃកូនបំណុល វិស័យដូចជា ប៉េងប៉ោងដែលម្តងធូរម្តងតឹងដូច្នោះដែរ។ ដូច្នេះពោលឱ្យខ្លី ចំពោះបំណុល ១លានរៀល តោងកូនបំណុលមានទ្រព្យធននៅក្រោមការទទួលខុសត្រូវជាងមួយលានរៀល ទើបអាចទូទាត់គ្នាដោយគ្មានបញ្ហា

ក៏ប៉ុន្តែ បើទ្រព្យធននៅក្រោមការទទួលខុសត្រូវមានតែ ៨សែន ឬ៦សែនរៀលវិញ ម្ចាស់បំណុលនឹងពុំអាចប្រមូលប្រាក់សំណងឱ្យបានគ្រប់ចំនួនឡើយ។ ហេតុដូច្នេះហើយដើម្បីការពារភាពគ្មានលំនឹងនៃម្ចាស់បំណុលទូទៅ និងក្នុងគោលបំណងការពារការប្រមូល ទ្រព្យធននៅក្រោមការទទួលខុសត្រូវនៃកូនបំណុលក្នុងចំនួនមួយកំរិត ក្រមរដ្ឋប្បវេណីបានរៀបចំរបបមួយដោយអនុញ្ញាតឱ្យម្ចាស់បំណុលទូទៅជ្រៀតជ្រែកទៅក្នុងការជំរះទ្រព្យធនរបស់កូនបំណុលបាន ។ នេះគឺជាសិទ្ធិឧបាទេសកម្ម (សិទ្ធិដាក់ជំនួស) របស់ម្ចាស់បំណុល និងសិទ្ធិលុបចោលដោយម្ចាស់បំណុល។ ក៏ប៉ុន្តែ ដោយហេតុថាតាមពិតទៅកូនបំណុលអាចនឹងជំរះទ្រព្យធនរបស់ខ្លួនបានដោយសេរីនោះ ច្បាប់អនុញ្ញាតចំពោះការចូលជ្រៀតជ្រែកពីម្ចាស់បំណុល ដោយដាក់កំរិតឱ្យធ្វើក្នុងក្របខ័ណ្ឌការពារបំណុលរបស់ខ្លួនប៉ុណ្ណោះ (សូមបញ្ជាក់ថាឧបាទេសកម្មមានន័យថា ជាការដាក់ជំនួសជនណាម្នាក់ដោយការផ្ទេរឋានៈខុសគ្នានឹងន័យរបស់ពាក្យថាតំណាងជនណាម្នាក់ ចូរអានជំពូកដដែលនេះ (៦) ការរលត់សិទ្ធិលើបំណុល ខ.ការសង (៣) ឧបាទេសកម្មដោយការសង ផង) ។

## ៣.២. សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល

### ៣.២.១. លក្ខណៈទូទៅ

ឥឡូវយើងលើកឧទាហរណ៍មួយមកពិភាក្សាដូចតទៅក្នុងការធ្វើជំនួញគ្មានដាក់ទ្រព្យធានា ម្ចាស់បំណុល Aបានឱ្យកូនបំណុលBជំពាក់ប្រាក់១០លានរៀល ។ រួចហើយឈ្មោះ Bមានកូនបំណុល C ដែលជំពាក់ប្រាក់ ១៥លានរៀលពុំទាន់ទារបាន ។ ក្រៅពីបំណុល១៥លានរៀលនេះចេញ ឈ្មោះBពុំមានទ្រព្យធនអ្វីជាធំដុំឡើយ មិនតែប៉ុណ្ណោះឈ្មោះBមិនបានទាមទារបំណុលពីឈ្មោះCទេ ទុកចោលរហូតមក ដែលអាចនឹងផុតអាជ្ញាយុកាល ហើយអាចបាត់បង់សិទ្ធិទាមទារបំណុលនេះ។ នៅក្នុងករណីនេះ ច្បាប់អនុញ្ញាតឱ្យឈ្មោះAយកឋានៈរបស់ឈ្មោះBមកប្រើជំនួសដើម្បីតាមទារ បំណុលពីឈ្មោះ C ដែលគេហៅថា សិទ្ធិឧបាទេសកម្ម (សិទ្ធិដាក់ជំនួស)របស់ម្ចាស់បំណុល (មាត្រា ៤២៣) ។ មានន័យថាសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល គឺជាសិទ្ធិដែលម្ចាស់បំណុលយកសិទ្ធិទាមទាររបស់កូនបំណុលខ្លួន ដែលមានទៅលើកូនបំណុលទី ៣

(ដែលជាកូនបំណុលរបស់កូនបំណុល) មកប្រើជំនួសដើម្បីការពារសិទ្ធិប្រមូលបំណុលរបស់ខ្លួន ។




### ៣.២.២. អានុភាព

ក៏ប៉ុន្តែក្នុងករណីនេះ ច្បាប់អនុញ្ញាតឱ្យឈ្មោះA ធ្វើការទាមទារតែក្នុងកំរិតទំហំបំណុលរបស់ខ្លួនទេ ពោលគឺមានកំរិតត្រឹមតែ ១០លានរៀលប៉ុណ្ណោះ ។ មួយវិញទៀតដោយហេតុថាជាការទាមទារជំនួសឈ្មោះB នេះ បំណុលគប្បីត្រូវសងទៅឈ្មោះ B ជាមុនសិន ក៏ប៉ុន្តែប្រសិនបើបំណុល ទាមទារនោះជាទឹកប្រាក់ ច្បាប់អនុញ្ញាតឱ្យឈ្មោះ A មានអាទិភាពទទួលការសងនេះមុនដោយធ្វើការទូទាត់ទឹកប្រាក់ជាមួយនឹងបំណុល ដែលឈ្មោះB ជំពាក់ខ្លួនឱ្យអស់សិន (ជំពូកដដែល ៦) ការរលត់សិទ្ធិលើបំណុល ) ។

### ៣.២.៣. ទំហំ និងល័ក្ខខ័ណ្ឌនៃការអនុវត្តន៍

សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលអាចយកទៅអនុវត្តលើសិទ្ធិទាមទារក្រៅពីប្រាក់ដូចជាសិទ្ធិទាមទារនូវវត្ថុជាក់លាក់ដែរ ដើម្បីការពារសិទ្ធិរបស់ខ្លួន (សិទ្ធិទាមទារឱ្យប្រគល់វត្ថុជាក់លាក់ណាមួយក្រៅពីទឹកប្រាក់ ឧទាហរណ៍មានដូចជា សិទ្ធិជួល សិទ្ធិទាមទារការចុះបញ្ជីផ្ទេរដីធ្លីជាដើម)។ ឧបមាថាឈ្មោះ A បានជួលដីរបស់ឈ្មោះ B ដោយចុះកិច្ចសន្យាជាមួយឈ្មោះ B តែម្តង

រួចមកឈ្មោះ C ដែលជាអ្នកគ្មានសិទ្ធិបានរំលោភចូលមកក្នុងដីនោះ ហើយចាប់ផ្តើម ប្រើប្រាស់ដីនោះ ពោលគឺធ្វើការរារាំងសិទ្ធិជួលរបស់ឈ្មោះ A ។ ដោយហេតុថា សិទ្ធិជួលនេះ ជាសិទ្ធិលើបំណុល ប្រសិនបើឈ្មោះ A គ្មានបញ្ជីដី (មាត្រា ៦០៥) ឬគ្មានបន្ទាល់ (ភស្តុតាង) សំរាប់អះអាងវិញទេនោះ ឈ្មោះA មិនអាចអះអាងតទល់នឹងតតិយជន (ពោលគឺឈ្មោះC) បាន ឡើយ ។ អាស្រ័យហេតុនេះ ដើម្បីការពារសិទ្ធិជួលរបស់ខ្លួនដែលបានទទួលពីឈ្មោះ B ឈ្មោះ A អាចអនុវត្តជំនួស ឈ្មោះ B (ដែលជាម្ចាស់ដីមានសិទ្ធិទាមទារឱ្យទាត់ចោលការរារាំងមកលើកម្មសិទ្ធិរបស់ខ្លួន) បាននូវសិទ្ធិទាមទារឱ្យទាត់ចោលការរារាំងដែលឈ្មោះ C បានប្រព្រឹត្ត។

ដូចពិពណ៌នារួចហើយថា ដោយហេតុថា សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល គឺជាសិទ្ធិដែលជ្រៀតជ្រែកទៅលើការជំរះបំណុលរបស់អ្នកដទៃនោះជាដាច់ខាត សិទ្ធិនេះត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌដែលឧបាទេសិក (អ្នកទទួលស្នងសិទ្ធិ) ធ្វើដើម្បីការពារបំណុលរបស់ខ្លួនតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ចំពោះការការពារសិទ្ធិទាមទារនូវវត្ថុជាក់លាក់ដូចជាសិទ្ធិទាមទារបញ្ជីដីជាដើម ប្រសិនបើគ្មានមធ្យោបាយការពារណាផ្សេងទៀតទេគេអាចអនុវត្តសិទ្ធិឧបាទេសកម្មជាម្ចាស់បំណុលនេះបានដោយមិនគិតថាកូនបំណុលនោះមានទ្រព្យធន ឬក៏គ្មានទ្រព្យធនទេ ។

## ៣.៣. សិទ្ធិលុបចោលដោយម្ចាស់បំណុល

### ៣.៣.១. លក្ខណៈទូទៅ

គេហៅសិទ្ធិលុបចោលដោយម្ចាស់បំណុល ម្យ៉ាងទៀតថាសិទ្ធិលុបចោលអំពើបោកបន្លំ។ លើកយកឧទាហរណ៍មួយថា ម្ចាស់បំណុលឈ្មោះ A មានកូនបំណុលម្នាក់ឈ្មោះ B ជំពាក់ប្រាក់ ១០លានរៀល ។ ដើម្បីរត់គេចពីការទាមទាររបស់ម្ចាស់បំណុល ឈ្មោះ B បានយកដី ដែលជាកម្មសិទ្ធិតែមួយគត់របស់ខ្លួនមានតម្លៃជាប្រាក់ប្រមាណ ៥០ លានរៀលទៅធ្វើជាអំណោយ ទៅដល់ឈ្មោះ D (បដិគ្គាហក) ដែលជាញាតិលោហិតរបស់ខ្លួន ។ ក្នុងករណីនេះ ដើម្បីការពារបំណុល១០លានរៀលរបស់ខ្លួន ម្ចាស់បំណុលឈ្មោះ A អាចលុបចោលកិច្ចសន្យា ធ្វើអំណោយ (កិច្ចសន្យាប្រទានកម្ម) រវាង

ឈ្មោះ B និង ឈ្មោះ D ដែលជាអំពើបោក បន្លំបាន(មាត្រា៤២៤) ។ មានន័យថា សិទ្ធិលុបចោលដោយម្ចាស់បំណុលជារបបមួយសំរាប់បំបាត់អំពើឆបោកចោលចេញ ក្នុងគោលបំណងប្រមូលយកទ្រព្យធននៅក្រោមការទទួលខុសត្រូវរបស់កូនបំណុលដែលឃ្លាតចាកចេញនោះ ឱ្យមកបញ្ចូលក្នុងការទទួលខុសត្រូវរបស់កូនបំណុលវិញ (ប្រដូចទៅនឹងការផ្ទុំប៉េងប៉ោង (ទ្រព្យធនរបស់កូនបំណុល) ដែលកូនបំណុលបានបន្ធូរ ដោយចេតនានោះឱ្យប៉ោងមកវិញដូច្នោះឯង) ។

សិទ្ធិលុបចោលដោយម្ចាស់បំណុល




### ៣.៣.២. អានុភាព

ជាគោលការណ៍ សិទ្ធិលុបចោលដោយម្ចាស់បំណុលនឹងអនុវត្តបាននៅក្នុងក្របខ័ណ្ឌ ដែលមានការប៉ះពាល់ខូចខាតដល់សិទ្ធិទាមទាររបស់ម្ចាស់បំណុលខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ ។ ដូច្នេះ ប្រសិនបើឈ្មោះ B ជំពាក់បំណុល១០លានរៀល ហើយប្រាក់ដែលឈ្មោះ Bធ្វើអំណោយទៅឈ្មោះ Dនោះមានតម្លៃ៥០លានរៀលឈ្មោះ Aមានសិទ្ធិលុបចោលកិច្ចសន្យាធ្វើអំណោយនោះត្រឹមតម្លៃប្រាក់១០លានរៀលតែប៉ុណ្ណោះ។ ក៏ប៉ុន្តែដោយហេតុថា ដីធ្លីជាទ្រព្យធនដែលមិនអាចបំបែកបាន (អវិភាគភាពនៃទ្រព្យ)នោះ គេអាចលុបចោលអំណោយទាំងមូលបាន ។ បន្ទាប់ពីដីនោះត្រឡប់មកក្នុងដៃឈ្មោះ B វិញហើយ គេនឹងធ្វើការលក់ដេញថ្លៃ រួចហើយឈ្មោះ A នឹងហូតយក ១០ លានរៀល ដែលជាភាគនៃបំណុលរបស់ខ្លួនពីតម្លៃដីនោះបាន ។ សូមបញ្ជាក់ថា នៅក្នុងករណីនេះ ម្ចាស់បំណុលទូទៅផ្សេងទៀតក្រៅពីឈ្មោះ A ក៏អាចចូលរួមទាមទារបំណុល

របស់ខ្លួនបានដែរ ។ ដូច្នេះយើងឃើញថា ជាគោលច្បាប់ សិទ្ធិលុបចោលនេះអនុវត្តឡើងសំរាប់ជាផលប្រយោជន៍ដល់ម្ចាស់បំណុលទូទៅទាំងអស់គ្នា(មាត្រា ៤២៥) ក៏ប៉ុន្តែក្នុងករណីដែលទ្រព្យនោះជាប្រាក់កាសវិញ តាមពិតទៅដូចគ្នានឹងសិទ្ធិឧបាទេសកម្មដែរ ម្ចាស់បំណុលដែលបានអនុវត្តសិទ្ធិលុបចោលមានអាទិភាពក្នុងការដក ហូតយកទ្រព្យធននេះមុនគេ ។ ជាក់ស្តែងនៅពេលមានការលុបចោលអំពើបោកបន្លំតាវ៉ាកាលិកជាប្រាក់ កូនបំណុល (ឈ្មោះ B) អាចនឹងមិនទទួលមកវិញបាននូវតាវ៉ាកាលិកដែល A បានដកហូតនោះទេ ។ នៅក្នុងករណីនេះ ជាបឋមច្បាប់អនុញ្ញាតិឱ្យម្ចាស់បំណុល (ឈ្មោះ A) ទាមទារទទួលយកប្រាក់អំណោយនោះ ផ្ទាល់តែម្តងបានរួចហើយបន្ទាប់ពីបានធ្វើការទូទាត់ប្រាក់ទទួលជាមួយនឹងបំណុលហើយ ម្ចាស់បំណុលមានអាទិភាពទទួលយកតម្លៃប្រាក់ជាភាគនៃបំណុលរបស់ខ្លួនបានតែម្តង ។

### ៣.៣.៣. លក្ខខណ្ឌចាំបាច់

ខុសពីសិទ្ធិឧបាទេសកម្ម សិទ្ធិលុបចោលនៃម្ចាស់បំណុលអាចអនុវត្តបាន តែទៅលើកាតព្វកិច្ចសងជាប្រាក់ (បំណុលជំពាក់ជាប្រាក់) តែប៉ុណ្ណោះ ។ ដើម្បីអះអាងថាជាអំពើបោក បន្លំមែនឬមិនមែននោះ គេត្រូវពិចារណានៅក្នុងល័ក្ខខ័ណ្ឌថា អំពើនោះមានលក្ខណៈឆបោកដែលជាល័ក្ខខ័ណ្ឌសត្យានុម័ត (គិតទៅតាមធាតុពិតដែលគ្មានការប្រែប្រួល) ផង និងថាកូនបំណុលមានចេតនាធ្វើឱ្យមានការខូចខាតដល់ម្ចាស់បំណុល ព្រមជាមួយថាអ្នកទទួលអំណោយមានគំនិតទុច្ចរិតដែលជាល័ក្ខខ័ណ្ឌអត្តនោម័ត (គិតទៅតាមគំនិតម្នាក់ៗ) ផង ។ មួយវិញទៀត ដូចបានពិពណ៌នារួចហើយថា សិទ្ធិឧបាទេសកម្មអាចអនុវត្តនៅក្រៅសេចក្តីសំរេចរបស់តុលាការក៏បានដែរ ក៏ប៉ុន្តែ សិទ្ធិលុបចោលត្រូវតែអនុវត្ត ដោយទទួលសេចក្តីសំរេចរបស់តុលាការជាដាច់ខាត ។

## ៤. ទំនាក់ទំនងនៅក្នុងសិទ្ធិលើបំណុលដែលមានពហុភាគី

### ៤.១. ចំណុចសិក្សាអំពីទំនាក់ទំនងពហុភាគី

ខុសពីកិច្ចសន្យា ដែលមានភាគីម្ចាស់បំណុលម្នាក់ទល់នឹងភាគីកូនបំណុលម្នាក់ កិច្ចសន្យាដែលជួនកាលមានភាគីម្ចាស់បំណុលច្រើនរូប ឬជួនកាលមានភាគីកូនបំណុលច្រើនរូបវិញ រមែង

កើតមានបញ្ហាផ្សេងៗច្រើនបែបច្រើនយ៉ាងណាស់ ដែលយើងនឹងសាកល្បងរៀបសំរួលដូចតទៅ ។ យើងសង្កេតឃើញមានការវែកញែកបញ្ហាបែបនេះ យោលទៅតាមវិធីផ្សេងៗដូចជាយោលទៅលើកាតព្វកិច្ចអាចបែងចែកបាន ឬ ទៅលើកាតព្វកិច្ចមិនអាចបែងចែកបានជាដើម ។ លើកករណីកូនបំណុលមានច្រើនរូប ហើយបំណុលនោះជាទឹកប្រាក់មកពិភាក្សា បញ្ហាដែលយើងត្រូវរៀបសំរួលនោះគឺៈ

(១) តើម្ចាស់បំណុលអាចទាមទារបំណុលពីកូនបំណុល ដែលមានគ្នាច្រើនរូបតាមរបៀបណាដែរ? (ទំនាក់ទំនងផ្នែកក្រៅៈ រវាងម្ចាស់បំណុល និងកូនបំណុល)។

(២) នៅពេលមានហេតុមួយកើតឡើងរវាងកូនបំណុលម្នាក់ (ក្នុងបណ្តាកូនបំណុលទាំងឡាយ) ជាមួយនិងម្ចាស់បំណុល ដូចជាថាមានការលើកលែងកាតព្វកិច្ចរបស់កូនបំណុលណាម្នាក់ជាដើម តើអាចមានឥទ្ធិពលជះទៅលើកូនបំណុលឯទៀតយ៉ាងណាដែរ? (ទំនាក់ទំនងតាមចំណងឥទ្ធិពល)។

(៣) ប្រសិនបើកូនបំណុលណាម្នាក់សងបំណុលទាំងមូលហើយ តើកូនបំណុលនោះអាចទាមទារសំណងពីកូនបំណុលឯទៀតបានឬទេ? (ទំនាក់ទំនងខាងការទារសំណងផ្ទៃក្នុងរវាងកូនបំណុលគ្នាឯង)។

ចំនុចដែលត្រូវចងចាំគឺថា យើងអាចលើកយកចំណុចទាំង៣នេះទៅអនុវត្តលើទំនាក់ទំនងរវាងភាគីច្រើនរូបនៅគ្រប់ប្រភេទនៃកិច្ចសន្យាបានហើយអាចរៀបសំរួលបញ្ហាទាំងអស់នោះបាន ។ បន្ទាប់មក គឺត្រូវសិក្សាយល់អំពីមុខងារនៃការធានា នៅក្នុងទំនាក់ទំនងពហុភាគីនេះ ។ ក៏ប៉ុន្តែមុខងារនៃការធានានេះ មិនសុទ្ធតែត្រូវមានជាចាំបាច់សំរាប់គ្រប់ប្រភេទនៃកិច្ចសន្យាទេ នៅក្នុងក្រមរដ្ឋប្បវេណី មុខងារនៃការធានាមានសារៈសំខាន់ខ្លាំងចំពោះកាតព្វកិច្ច ដោយសាមគ្គីភាព (ការទទួលខុសត្រូវដោយរួមសាមគ្គីគ្នា) ហើយរឹតតែខ្លាំងណាស់ទៅទៀតចំពោះកាតព្វកិច្ចនៃការធានា ដែលសឹងតែពោលបានថា ការបង្កើតឱ្យមានភាគីច្រើនរូបគឺដើម្បីបំរើមុខងារនៃការធានានេះឯង។

## ៤.២. វិភាគភាពនៃសិទ្ធិលើបំណុល និងវិភាគភាពនៃកាតព្វកិច្ច

ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនកំណត់ថា នៅចំពោះមុខសិទ្ធិទាមទារមួយ (ឬកាតព្វកិច្ចមួយ) នៅក្នុងករណីដែលមានម្ចាស់បំណុលច្រើនរូប ឬមានកូនបំណុលច្រើនរូប ប្រសិនបើគ្មានការព្រមព្រៀងជាពិសេសណាមួយរវាងសាមីជនទាំងអស់ទេជាគោលកាណ៍សិទ្ធិទាមទារ(ឬកាតព្វកិច្ច) នោះត្រូវបែងចែកគ្នាក្នុងបណ្តាម្ចាស់បំណុល និងកូនបំណុលទាំងអស់ (មាត្រា ៤២៧) ។ រួចហើយភាគនៃការបែងចែកនេះទៀតសោត ប្រសិនបើសាមីជនទាំងអស់មិនបានកំណត់ថាដាក់យ៉ាងណាៗទេនោះ ត្រូវបែងចែកឱ្យស្មើភាគគ្នា ។ ឧទាហរណ៍ថា បើកូនបំណុលមានគ្នា ៣ នាក់បានខ្ចីប្រាក់ ៣ លានរៀលពីធនាគារ កូនបំណុលម្នាក់ៗត្រូវបំពេញកាតព្វកិច្ចសងបំណុល ១ លានរៀលដែលជាចំណែករបស់ខ្លួន (វិភាគភាពនៃកាតព្វកិច្ច) ។ ហើយបើមានគ្នាពីរនាក់កាន់កាប់វត្ថុមួយរួមគ្នាវិញ ប្រសិនបើភាគីមួយក្នុងចំណោមពីរនាក់នេះលក់វត្ថុនោះ តម្លៃ ៣ លានរៀលទៅឱ្យអ្នកដទៃ នោះគឺម្នាក់ៗមានសិទ្ធិទៅលើប្រាក់ចំនួន ១ លាន ៥ សែនរៀលក្នុងក្របខ័ណ្ឌនៃសិទ្ធិលើបំណុល (វិភាគភាពនៃសិទ្ធិលើបំណុល) ។ ក៏ប៉ុន្តែ មតិមួយចំនួនយល់ថា ប្រសិនបើគេគោរពគោលការណ៍នេះខ្លាំងពេក ជាពិសេសក្នុងករណីវិភាគភាពនៃកាតព្វកិច្ច ម្ចាស់បំណុលនឹងជួបឧបស័គ្គច្រើនជាពុំខាន (ចូរអាន ឃ. កាតព្វកិច្ចដោយសាមគ្គីភាព ដែលពិពណ៌នានៅផ្នែកខាងក្រោយ) ។

## ៤.៣. អវិភាគភាពនៃសិទ្ធិលើបំណុល និងអវិភាគភាពនៃកាតព្វកិច្ច

យោលទៅតាមចរិតលក្ខណៈរបស់វា តាវកាលិកខ្លះពុំអាចធ្វើការបែងចែកបានឡើយ។ នៅក្នុងករណីនេះ ជាការច្បាស់ណាស់ដែលថាពុំមានការបែងចែកសិទ្ធិលើបំណុល ឬការបែងចែកកាតព្វកិច្ចឡើយ ពោលគឺគេត្រូវអនុវត្តនូវកាតព្វកិច្ចនោះទាំងមូលតែម្តង (មាត្រា ៤២៨)។ ឧទាហរណ៍ដូចជាថាជន២នាក់ធ្វើកិច្ចសន្យាទិញរថយន្តមួយគ្រឿងជាមួយគ្នាក្នុងករណីនេះ គេមិនអាចកាត់រថយន្តជា២កំណាត់ចែកម្ចាស់២រូបបានទេ ដូច្នេះត្រូវម្ចាស់ណាម្នាក់ទទួលយករថយន្តទាំងមូលនោះទៅប្រើដោយធ្វើដូចម្តេចឱ្យម្ចាស់ម្នាក់ទៀតពេញចិត្តផងដែរ(អវិភាគភាពនៃសិទ្ធិលើបំណុល) ។ ផ្ទុយទៅវិញក្នុងករណីដែលម្ចាស់ ២រូបមានរថយន្តមួយគ្រឿងជាមួយគ្នា បើម្ចាស់ណាម្នាក់បាន

លក់រថយន្តនោះទៅឱ្យអ្នកដទៃម្នាក់ទៀតក៏ត្រូវបានចាត់ទុកថាបានអនុវត្តកាតព្វកិច្ច (ការប្រគល់រថយន្ត) ខ្លួនដែរ (អវិភាគភាពនៃកាតព្វកិច្ច) ។ ម្យ៉ាងទៀត វត្ថុ ឬកាតព្វកិច្ចខ្លះអាចប្រគល់ ឬអនុវត្តដោយបែងចែកបានដែរ ក៏ប៉ុន្តែយោលទៅតាមការព្រមព្រៀងគ្នារវាងសាមីជនទាំងអស់ គេអាចចាត់ទុកថាជាសិទ្ធិលើបំណុលមិនអាចបែងចែក (អវិភាគភាពនៃសិទ្ធិលើបំណុល) ឬកាតព្វកិច្ចមិនអាចបែងចែក(អវិភាគភាពនៃកាតព្វកិច្ច) បានដែរ(មាត្រា៤២៨ ឧទាហរណ៍ដូចជាក្នុងកិច្ចសន្យាលក់ធ្យូង១តោន ប្រសិនបើអ្នកទិញបំបែកយកម្តងបន្តិចៗ នោះនឹងធ្វើឱ្យអំពល់ដល់អ្នកលក់ជាមិនខាន ក្នុងករណីដូចនេះ គេអាចធ្វើការព្រមព្រៀងមួយចាត់ទុកថាជាកាតព្វកិច្ចអវិភាគីយបាន) ។

## ៤.៤. កាតព្វកិច្ចដោយសាមគ្គីភាព

### ៤.៤.១. អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

យើងយល់ថាកាតព្វកិច្ចនៃការធានាមានសារៈសំខាន់ជាទីបំផុត នៅក្នុងជីវភាពជាក់ស្តែង ដូច្នេះដើម្បីសិក្សាបញ្ហានេះ ជាបឋមយើងចាំបាច់ត្រូវដឹងអំពី កាតព្វកិច្ចដោយសាមគ្គីភាព ជាមុនសិន។ ឥឡូវគិតថាមានឈ្មោះ B, C, D ៣ នាក់បានមូលមតិគ្នាទៅខ្ចីប្រាក់៩០លានរៀលពីធនាគារ ដើម្បីទុកធ្វើទុនសំរាប់បើកហាងមួយជាមួយគ្នា ។ ក្នុងករណីនេះ ប្រសិនបើពុំមានការសំរេចជាមួយគ្នារវាងម្ចាស់បំណុល (ពោលគឺធនាគារ) និងកូនបំណុល ៣ រូបថាយ៉ាងណាៗទេនោះ ដូចបានពិពណ៌នារួចមកហើយថា ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុននឹងកំនត់ទុកជាកាតព្វកិច្ចបែងចែក(វិភាគភាពនៃកាតព្វកិច្ច) ហើយការបែងចែកនេះ មានលក្ខណៈស្របទៅតាមគោលការណ៍ ច្បាប់ (បែងចែកជាភាគស្មើគ្នា) (មាត្រា៤២៧) ។ ប្រសិនបើកាតព្វកិច្ចត្រូវបែងចែកតាមបែប ផែន សាមញ្ញ លុះដល់រយៈពេលកំណត់ហើយ ម្ចាស់បំណុល(ធនាគារ A )នឹងទារប្រាក់បំណុលពីឈ្មោះ B, C, D ក្នុងម្នាក់ៗ៣០លានរៀលដាច់ដោយឡែកពីគ្នាតែប៉ុណ្ណោះ ។ បើដូច្នេះ នៅពេលដែលកូនបំណុលណាម្នាក់ ឧបមាថាឈ្មោះ B បានរត់គេចខ្លួនបាត់ ឬក៏រកទ្រព្យសង គ្មាន (អសោធនីយ) ជាដើមទោះបី ជាទារបានពីកូនបំណុល២រូបទៀតម្នាក់ៗ៣០លានរៀលក៏ដោយ ម្ចាស់បំណុលត្រូវខាតបង់ប្រាក់៣០ លានរៀលដោយសារខ្លួនទារពីឈ្មោះBមិនបាននោះដដែល។ បើតែយ៉ាងនេះទេ ម្ចាស់បំណុលមិនសប្បាយចិត្តឡើយ ។ ឥឡូវគិតថាម្ចាស់បំណុល A បានធ្វើកិច្ចសន្យាឱ្យខ្ចីប្រាក់

៩០លានរៀលជាមួយ នឹងកូនបំណុល B, C, D ដោយដាក់ថាជាកូនបំណុលរួមសាមគ្គីម្តង ។ បើដូច្នេះមែន នៅពេលដល់ថ្ងៃកំណត់ហើយ ម្ចាស់បំណុល A អាចទាមទារជាទឹកប្រាក់បំណុល ៩០លានរៀលទាំងមូលពីកូន បំណុលណាម្នាក់ក៏បានដែរ ពី B ក្តី C ក្តី D ក្តី ។ ប្រាកដណាស់ដែលថាម្ចាស់បំណុលA មិនអាចទាមទារជាទឹកប្រាក់បូកសរុប ២៧០ លានយ៉េននោះកើតទេក៏ប៉ុន្តែ ដោយហេតុថាកាតព្វកិច្ចដោយ សាមគ្គីភាព គឺជាកាតព្វកិច្ចតម្រូវឱ្យកូនបំណុលរួមសាមគ្គីគ្នា ម្នាក់ៗអាចសងរហូតស្មើនឹងតម្លៃបំណុលទាំងមូលតែម្តង ហេតុដូច្នេះហើយម្ចាស់បំណុលអាចជ្រើសរើសយកកូនបំណុលណាម្នាក់ ក្នុងបណ្តាកូនបំណុលទាំងឡាយ មកបង្ខំឱ្យសងបំណុលទាំងមូលរបស់ខ្លួនក៏បាន ឬក៏ទារបំណុលដោយបំបែកជាចំណែកបែបណាមួយក៏បានដែរ (មាត្រា ៤៣២ មានន័យដូច្នេះឯង) ។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានកំនត់នូវល័ក្ខខ័ណ្ឌនៃកាតព្វកិច្ចសាមគ្គីនេះ ដោយផ្អែកលើការសន្និដ្ឋានថា តោងមានចេតនារួមសាមគ្គីជាមួយគ្នាដោយអត្តនោម័តរវាងកូនបំណុលមែន (ឧទាហរណ៍ខាងលើ កូនបំណុលទាំង ៣ បានបង្ហាញឆន្ទៈដោយមូលមតិគ្នាខ្ចីប្រាក់ក្នុងគោលបំនងបើកហាងជាមួយគ្នា។គេហៅថា "មានទំនាក់ទំនងរួមសាមគ្គីគ្នាជាអត្តនោម័ត"ជាដើម)។ ជាធម្មតាទេដែលថាប្រតិបត្តិក្នុងលក្ខណៈជាកាតព្វកិច្ចដោយសាមគ្គីភាពក្តី ឬមិនប្រតិបត្តិក្តីវាជាសេរីភាពពេញទីរបស់សាមីជនគ្រប់រូប ។ ហើយម្យ៉ាងទៀត សាមីជនគ្រប់រូបអាចធ្វើការព្រមព្រៀងគ្នាជាពិសេសណាមួយបានតាមចំណូលចិត្តផងដែរគ្រាន់តែថាបើធ្វើកិច្ចសន្យាដាក់ជាកាតព្វកិច្ច ដោយសាមគ្គីភាពនោះនឹងមានបែបបទដូចខាងក្រោមនេះ ។ ចំពោះឧទាហរណ៍ខាងលើ ឧបមាថានៅក្នុងរង្វង់កូនបំណុលរួមសាមគ្គី គេអាចកំនត់ថា នាចុងបញ្ចប់ ម្នាក់ៗត្រូវទទួលចំណែកនៃបន្ទុកលើប្រាក់បំណុលចំនួន ៣០ លានយ៉េនយ៉ាងដូច្នេះក៏បានដែរ (ចូរអានន័យនៃពាក្យចំណែកនៃបន្ទុក) ក៏ប៉ុន្តែនៅចំពោះមុខម្ចាស់បំណុល កូនបំណុលណាក៏ដោយតោងមានកាតព្វកិច្ចនឹងបង់ថ្លៃបំណុលទាំងមូល នៅពេលមានការទាមទារមកលើរូបខ្លួន ។ ចំពោះម្ចាស់បំណុលវិញ ទោះបីជាកូនបំណុលណាម្នាក់បាត់ខ្លួនទៅណាក៏ដោយ ឱ្យតែទារពីកូនបំណុលឯទៀតបាននោះគឺអស់បញ្ហាហើយពោលគឺអានុភាពនៃសិទ្ធិលើបំណុលនេះបានពង្រីកដល់កំរិតហ្នឹង។ បើបកស្រាយម្យ៉ាងទៀតគឺថាកូនបំណុលម្នាក់ៗបានយកខ្លួនទៅដាក់ជានិក្ខេបជំនួសគ្នាទៅវិញទៅមក។ក៏ប៉ុន្តែដោយហេតុថាកាតព្វកិច្ចដោយសាមគ្គីភាពនេះកើតឡើងបានដោយសារតែមានទំនាក់ទំន

ងចងភ្ជាប់គ្នា ជាអត្តនោម័ត (យោលទៅតាមគំនិតម្នាក់ៗ) រវាងកូនបំណុលដូចគ្នានោះ។

**ចំណែកនៃបន្ទុក**

ចំណែកនៃបន្ទុកគឺ អាត្រា ឬភាគនៃបន្ទុក ។ ដូច្នេះនៅក្នុងករណីដែលមានកូនបំណុល ៣ នាក់ឈ្មោះ B, C, D ជំពាក់បំណុល៩០លានរៀល ប្រសិនបើគ្មានការសន្យាពិសេសណាទេ ហើយបើគិតតាមការបែងចែកស្មើភាគគ្នា ម្នាក់ៗត្រូវទទួលបន្ទុក៣០លានរៀល ។ នៅក្នុងស្ថានភាពនេះ បើឈ្មោះ B បានសង ១៨លានរៀលទៅម្ចាស់បំណុលហើយនោះ ឈ្មោះ B អាចទារយកពីឈ្មោះ C និងពីឈ្មោះ D ក្នុងម្នាក់ៗ ៦លានរៀលមកវិញបាន ។ ក៏ប៉ុន្តែសូមបញ្ជាក់ជាថ្មីម្តងទៀត ហើយសូមកុំច្រឡំឱ្យសោះថានៅក្នុង ករណី កាតព្វកិច្ចដោយសាមគ្គីភាពនេះថ្វីត្បិតតែនៅក្នុងរង្វង់កូនបំណុលគេម្នាក់ៗអាចទាមទារប្រាក់ដែលខ្លួនបានបង់ជូសគ្នាក៏ដោយ ប៉ុន្តែនៅចំពោះមុខម្ចាស់បំណុលវិញកូនបំណុលម្នាក់ៗមានកាតព្វកិច្ចសងបំណុលទាំងមូល(៩០លានរៀល) ដូចនេះកូនបំណុលម្នាក់ៗ មិនអាចប្រកែកអះអាងថា ខ្លួននឹងសងតែចំណែកដែលជាបន្ទុករបស់ខ្លួននោះបានឡើយ។

ដូច្នេះបើមានព្រឹត្តិការណ៍ណាមួយកើតឡើងចំពោះកូនបំណុលណាម្នាក់ នោះអាចនឹងជះឥទ្ធិលទៅលើកូនបំណុលដទៃទៀតបាន ហើយនេះជាកត្តាមួយដែលបែរជាធ្វើឱ្យការអនុវត្តន៍សិទ្ធិលើបំណុលចុះទន់ខ្សោយទៅវិញក៏មានដែរ (នឹងពិពណ៌នាបន្ទាប់ទៅនេះ) ។

## ៤.៤.២. ហេតុគេនដែលនាំឱ្យមានអានុភាពដាច់ខាតនៃកាតព្វកិច្ចដោយសាមគ្គីភាព

ដោយហេតុថា កាតព្វកិច្ចដោយសាមគ្គីភាពកើតមានឡើង ដោយសារតែមានទំនាក់ទំនងចងភ្ជាប់គ្នាជាអត្តនោម័តរវាងកូនបំណុលដូចគ្នានោះ យើងអាចសន្និដ្ឋានបានថាហេតុការណ៍ ដែលកើតមានឡើងរវាងម្ចាស់បំណុលជាមួយកូនបំណុលណាម្នាក់ អាចនឹងមានឥទ្ធិពលមួយកំរិតទៅលើកូនបំណុលដទៃទៀតបាន ។ ឧទាហរណ៍ដូចជាថាបើកូនបំណុលណាម្នាក់ទទួលការទាមទារបំណុល

ពីម្ចាស់បំណុលតាមផ្លូវការហើយកូនបំណុលដទៃទៀតក៏ចាត់ទុកថា បានទទួលការទាមទារតាមផ្លូវការដូចគ្នាដែរ (មាត្រា ៤៣៤) ។ ក្នុងករណីដែលហេតុភេទកើតមានទៅលើរូបកូនបំណុលម្នាក់ជះឥទ្ធិពលទៅលើកូនបំណុលដទៃទៀត គេពោលថាហេតុភេទនេះមានអនុភាពដាច់ខាត (ចំពោះហេតុភេទដែលមិនមានអានុភាពទៅលើកូនបំណុលដទៃទៀតវិញ គេថាជាហេតុភេទបង្កើតអានុភាពប្រៀបធៀបតែប៉ុណ្ណោះ) ។ កាតព្វកិច្ចដោយសាមគ្គីសម្បូណ៌ទៅដោយហេតុភេទមានអានុភាពដាច់ខាតច្រើនណាស់ ។ ក្រឡេកមើលមួយភ្លែតទៅ យើងឃើញហាក់បីដូចជាហេតុភេទទាំងនេះជួយខាងភាគីម្ចាស់បំណុលច្រើន ក៏ប៉ុន្តែផ្ទុយទៅវិញនៅក្នុងករណីខ្លះ ហេតុភេទនេះបែរជាបង្អន់អានុភាពនៃសិទ្ធិលើបំណុលទៅវិញ ពោលគឺធ្វើឱ្យការទាមទាររបស់ម្ចាស់បំណុលរអាក់រអួលទៅវិញក៏មានដែរ ។ ទាំងនេះមកអំពីការកកើតមានជាស្ថាពរនៃអញ្ញត្រកម្ម (ការលើកលែង) និងការផុតអាជ្ញាយុកាល (ការផុតរយៈពេល) ។ មានន័យថាប្រសិនបើមានការលើកលែងបំណុលចំពោះកូនបំណុលណា បំណុលសំរាប់កូនបំណុលដទៃទៀតក៏នឹងត្រូវថយទៅតាមនោះដែរ ដោយរួចផុតពីចំណែកបន្ទុកនៃកូនបំណុល ដែលលើកលែងនោះ (មាត្រា ៤៣៧ ចំពោះឧទាហរណ៍ខាងលើ បើម្ចាស់បំណុល A លើកលែងចំណែកបន្ទុកទាំងអស់របស់កូនបំណុល B ចំនែកបន្ទុក ៣០ លានយ៉េនរបស់កូនបំណុល Bនេះ នឹងជះឥទ្ធិពលទៅលើការលើកលែងចំពោះកូនបំណុល C និង D ផងដែរ ។ មានន័យថា ចាប់ពីពេលនោះមក កាតព្វកិច្ចដោយសាមគ្គីភាពសំរាប់ឈ្មោះ C និង D ដែលត្រូវសងនោះ នៅសល់តែ ៦០ លានយ៉េនប៉ុណ្ណោះ) ។ ម្យ៉ាងទៀត នៅពេលដែលកូនបំណុលណាម្នាក់ផុតអាជ្ញាយុកាល (ដូចជាត្រូវផ្អាកដំណើរអាជ្ញាយុកាលជាដើម) កូនបំណុលដទៃទៀតក៏នឹងត្រូវរួចពីចំណែកបន្ទុកនៃកូនបំណុលផុតអាជ្ញាយុកាលនោះដែរ (មាត្រា ៤៣៩) ។

## ៤.៥. កាតព្វកិច្ចនៃការធានា

### ៤.៥.១. លក្ខណៈទូទៅ

បន្ទាប់ពីបានយល់ដឹងខាងលើហើយ ឥឡូវយើងធ្វើអត្ថាធិប្បាយអំពីកាតព្វកិច្ចនៃការធានាម្តង ។ការធានានេះក៏គ្មានអ្វីក្រៅពីយកបុគ្គលមកដាក់ជានិក្ខេបដូចដែលបានពិពណ៌នារួចមកហើយនោះទេ ដូច្នេះយើងគោងប្រយ័ត្នហើយត្រូវប្រយ័ត្នថែមទៀត កាលណាដាក់ខ្លួនជាអ្នកធានាអ្វីមួយ ។

ការធានានេះចែកចេញជា ការធានាធម្មតា និង ការធានាដោយសាមគ្គីទៀត ហើយដែលយើងត្រូវប្រុងប្រយ័ត្នជាពិសេសនោះ គឺការធានាដោយសាមគ្គី ។ ចំពោះការធានានេះ យើងម្នាក់ៗធ្លាប់ឮដែរហើយនៅក្នុងជីវភាពរស់នៅ ហើយក៏ប្រហែលជាមានការយល់ដឹងខ្លះរួចមកហើយដែរ ក៏ប៉ុន្តែបញ្ហានៅត្រង់ថាតើការយលដឹងនេះត្រឹមត្រូវឬទេ? នៅទីនេះយើងនឹងសាកល្បងធ្វើអត្ថាធិប្បាយដូចខាងក្រោមនេះ ។

## ៤.៥.២. កិច្ចសន្យាធានា និងភាតព្វកិច្ចនៃការធានា

លើបញ្ហាថាឈ្មោះ A ជាម្ចាស់បំណុល ហើយឈ្មោះ B ជាកូនបំណុល ហើយនៅពេល ដែលឈ្មោះ B ទៅពឹងឈ្មោះ C ឱ្យធ្វើជាអ្នកធានាឱ្យខ្លួន សួរថាតើឈ្មោះ C ត្រូវធ្វើកិច្ចសន្យាជាមួយអ្នកណា? ចម្លើយគឺមិនមែនជាមួយឈ្មោះ B ទេ ។ កិច្ចសន្យាធានានេះត្រូវធ្វើជាមួយម្ចាស់បំណុល A ។ អាស្រ័យហេតុនេះក្នុងករណីដែលឈ្មោះ B បាននិយាយថា"ខ្ញុំមិនធ្វើឱ្យលោកកើតអំពល់ដោយសារខ្ញុំទេ ព្រោះមានអ្នកធានាឱ្យខ្ញុំផ្សេងទៀតដែរ" ហើយឈ្មោះ C ជឿសំដីនេះសុខចិត្តធ្វើអ្នកធានាឱ្យ បន្ទាប់មកស្រាប់តែដឹងរឿងពិតថាគ្មានអ្នកធានាផ្សេងទេនោះ ឈ្មោះ C ដែលជាអ្នកធានាមិនអាចទៅរំលាយកិច្ចសន្យាជាមួយ A ដែលគ្មានពាក់ព័ន្ធនឹងរឿងនេះបានឡើយ ។ ក្រោយមកទៀត លុះដល់ថ្ងៃកំណត់(ថ្ងៃណាត់) សងបំណុលហើយ ម្ចាស់បំណុល A នឹងមកទារឈ្មោះ C ឱ្យសងបំណុលឱ្យខ្លួន ។ សួរថា តើនៅពេលនោះឈ្មោះ C អាចនិយាយទៅកាន់ ឈ្មោះ A ថា "តោងទៅទារពីឈ្មោះ B ជាមុនសិនបានដែរឬទេ?" ចម្លើយគឺថា ប្រសិនបើជា អ្នកធានាធម្មតា គេអាចនិយាយដូចនេះបានមែន ក៏ប៉ុន្តែនៅក្នុងករណីជាអ្នកធានារួមសាមគ្គីវិញ គេមិនអាចនិយាយដូចនេះបានឡើយ ។

## ៤.៥.៣. ការធានាធម្មតា និងការធានាដោយសាមគ្គីភាព

មាត្រា ៤៤៦ នៃក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានកំណត់ថា អ្នកធានា គឺជាអ្នកដែលអនុវត្តកាតព្វកិច្ច (ដូចជាសងបំណុលជាដើម) នៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចនោះ។ នៅក្នុងករណីជាអ្នកធានាធម្មតា អ្នកធានានោះអាចឆ្លើយតបទល់នឹងម្ចាស់បំណុលបានដោយសារខ្លួនមានសិទ្ធិឆ្លើយតវ៉ា២ប្រភេទគឺៈ សិទ្ធិឆ្លើយតវ៉ាឱ្យដាស់តឿន ដូចជាថា "គួរទៅទារពីកូនបំណុល

ជាមុនសិន” និង សិទ្ធិឆ្លើយតវ៉ាឱ្យសើរើ ដូចជាថា “កូនបំណុលប្រាកដជាមានទ្រព្យធន ដូច្នេះគួរទៅរឹបអូសយកជាមុនសិន” ជាដើម ។ ពោលគឺ អ្នកធានាធម្មតាមាននាទីជាអ្នកឈរនៅពីក្រោយខ្នងកូនបំណុលតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ចំពោះអ្នកធានារួមសាមគ្គីវិញ គឺមិនដូច្នេះទេ ពោលគឺគ្មានសិទ្ធិអះអាងទាំង ២ ប្រភេទខាងលើនេះ នៅចំពោះមុខម្ចាស់បំណុលឡើយ អ្នកធានារួមសាមគ្គីមាន កាតព្វកិច្ចដូចគ្នានឹងកូនបំណុលរួមសាមគ្គី (ដែលបានពិពណ៌នា ខាងមុខរួចមកហើយ) ដែរ (មាត្រា ៤៥៤ និង ៤៥៨) ។ មានន័យថាអ្នកធានារួមសាមគ្គីទទួលល័ក្ខខ័ណ្ឌដូចគ្នានឹងកូនបំណុលដែរ ដូច្នេះនៅពេលដល់ថ្ងៃកំណត់សងបំណុល ហើយម្ចាស់បំណុលមិនទៅទារពីកូនបំណុលតាំងពីដំបូងទីក៏បាន ហើយបង្វែរមុខព្រួញសំដៅទៅទារអ្នកធានារួមសាមគ្គីឱ្យសងបំណុលទាំងអស់ក៏បានដែរ ។ ត្រង់ចំនុចនេះមានអ្នកខ្លះគិតថាការធានាដោយសាមគ្គីភាពដែលមានគ្នាច្រើននឹងជួយសំរួលដល់ការសងបំណុល ដោយអាចរំលែកបន្ទុកចែកគ្នាបាន ដូច្នេះធូរស្រាលជាងការធានាធម្មតា ។ សូមបញ្ជាក់ថាវាមិនដូច្នោះទេ ពោលគឺផ្ទុយស្រឡះតែម្តង ។



### ៤.៥.៤. ការធានារួម

ការធានាដែលមានគ្នាច្រើននាក់ហៅថា ការធានារួម ។ ក្នុងករណីការធានារួម ដែលជាការធានាធម្មតានោះ មានការបែងចែករំលែកបន្ទុកគ្នាមែន (មាត្រា៤៥៦ ឧបមាថា មានអ្នកធានាធម្មតាចំនួន២នាក់ទៅលើបំណុល ៤លានរៀល ម្នាក់ៗទទួលបន្ទុក២លានរៀល)។ ប៉ុន្តែ ក្នុងករណីការធានាដោយសាមគ្គីភាពវិញ ទោះបីជាមានអ្នកធានាផ្សេងទៀតប៉ុន្មាននាក់ក៏ដោយដូចបានពិពណ៌នាស្ដីពីកូនបំណុលរួមសាមគ្គីដូច្នោះដែរ អ្នកធានាម្នាក់ ដែលកាលណាត្រូវម្ចាស់បំណុលទាមទារ ជាបឋមត្រូវសងបំណុលទាំងអស់ជាមុនសិន (ឧបមាថាមានអ្នកធានារួមសាមគ្គីចំនួន ២នាក់ ទៅលើបំណុល ៤លានរៀលក៏ដោយ ម្នាក់ៗមានកាតព្វកិច្ចសងបំណុល ៤លានរៀល នៅពេលមាន ការទាមទារពីម្ចាស់បំណុល ។ ចូរចងចាំថា ដែលហៅថាធានាដោយសាមគ្គីភាពនេះ មិនមែនការរួម សាមគ្គីគ្នារវាងអ្នកធានាដូចគ្នាទេនោះ តែជាការរួមសាមគ្គីគ្នាជាមួយកូនបំណុលទៅវិញ)។

### ៤.៥.៥. ការធានាបំណុលអណ្ដែត

តាមធម្មតា ការធានា គឺធ្វើឡើងក្នុងគោលបំណងដាក់ជានិក្ខេប ទៅលើបំណុល ឬទៅលើកាតព្វកិច្ចណាមួយ ក៏ប៉ុន្តែឧបមាថា បើម្ចាស់បំណុលនិងកូនបំណុលជាអ្នករកស៊ីជំនួញច្រើនលើកច្រើនគ្រាជាមួយគ្នាជាហូរហែមក (ដូចជាថាទិញទំនិញចូលរាល់ថ្ងៃ ហើយបង់ថ្លៃទំនិញនៅរាល់ដំណាច់ខែជាដើម)ចំនួនទឹកប្រាក់ជំពាក់ (ឬប្រាក់ជឿ) ប្រចាំខែរមែងកើនឡើង ឬថយចុះពុំទៀងទាត់ឡើយ ។ នៅក្នុងករណីបែបនេះ ប្រសិនបើគេនាំគ្នាធ្វើកិច្ចសន្យាធានាគ្រប់តែប្រាក់ជំពាក់នីមួយៗនោះឃើញថាជាប់រវល់គ្មានធ្វើអ្វីកើតទេ ។ ដូច្នេះហើយដើម្បីធានាចំពោះប្រាក់ជំពាក់នេះ គេតោងកំរិតចំនួនទឹកប្រាក់ និងរយៈពេលត្រឹមណាមួយ (ឧទាហរណ៍ដូចជាកំរិតចំនួនទឹកប្រាក់ខ្ពស់បំផុត ៣០ លានយ៉េនក្នុងរយៈវេលា ៣ ឆ្នាំជាដើម) ហើយធ្វើការធានានៅក្នុងក្របខ័ណ្ឌនោះដែលជាល័ក្ខខ័ណ្ឌអាចឱ្យគេធ្វើកិច្ចសន្យាកើត ។ គេហៅការធានានេះថា ការធានាបំណុលអណ្ដែត ។ រួចហើយបើគេពង្រីកបែបបទនេះទៅទៀត គេនឹងឈានទៅចាប់បានគំនិតមួយសំរាប់ការធានាបន្ត ដែលក្រៅពីការធានាដោយបូកសរុបចេញមានការធានាប្រាក់ឈ្នួលនៅក្នុងកិច្ចសន្យាជួលដែលមានកំរិតពេលវេលាមួយរយៈកាល ។

### ៤.៥.៦. ការធានាដោយស្ថាប័ន

បច្ចុប្បន្ននេះមានស្ថាប័ន ដែលបង្កើតដោយច្បាប់ពិសេសសំរាប់ប្រកបអាជីវកម្មធានានេះដែរ។ ឧទាហរណ៍ដូចជា សមាគមធានាឥណទាន នៅក្នុងប្រទេសជប៉ុនជាដើមដែលបង្កើតឡើងសំរាប់ជួយសហគ្រាសតូចតាច ក្នុងការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ (តួយ៉ាងដូចជាធនាគារជាដើម)។ សមាគមខាងលើនេះតាំងខ្លួនជាអ្នកធានាឱ្យ ដោយទទួលកំរៃជើងសារបន្តិចបន្តួចពីសហគ្រាសតូចតាចនោះ ។ ក៏ប៉ុន្តែ ដើម្បីរក្សាផលប្រយោជន៍នៃស្ថាប័នខ្លួន សមាគមធានាឥណទានខាងលើតែងតម្រូវឱ្យសហគ្រាសតូចតាចទាំងឡាយ (ដែលជាកូនបំណុលនោះ) ចាត់តាំងអ្នកធានារួមសាមគ្គី ឬភ្ជាប់កិច្ចសន្យាពិសេសណាមួយ ដែលសំរួលឱ្យខ្លួនមានប្រៀបក្នុងការទាមទារសំណងនាដំណាក់ការចុងក្រោយ ។

### ៤.៥.៧. ការធានាមនុស្ស

សូមបញ្ជាក់ថា ការធានាមនុស្ស នៅទីនេះមានលក្ខណៈខុសគ្នាបន្តិចទៅ នឹងកិច្ចសន្យាធានាមនុស្ស ដូចជាថាធានាក្មួយម្នាក់នៅពេលចូលធ្វើការក្នុងក្រុមហ៊ុនណាមួយជាដើមនោះ។ ខុសគ្នាពីការធានាទាំងឡាយ ដែលសំដៅទៅលើការធានាប្រាក់បំណុលរបស់កូនបំណុល ការធានាមនុស្សសំដៅទៅលើការធានានៅពេលមានកើតការខូចខាតទៅលើក្រុមហ៊ុន ដែលសាមីខ្លួននឹងចូលទៅធ្វើការនោះ។ ពោលគឺជាកិច្ចសន្យាធានាការខូចខាតមួយប្រភេទ ក៏ប៉ុន្តែគេពុំអាចប៉ាន់ស្មានបានទុកជាមុននូវទំហំនៃការខូចខាតនោះកើតទេ។ នៅក្នុងករណីនេះ បន្ទុកដែលធ្លាក់មកលើអ្នកធានាអាចនឹងមានទំហំធំមហិមាបាន ដូច្នេះហើយបានជាច្បាប់ស្តីពីការធានាមនុស្សបានត្រូវបង្កើតឡើង ដោយដាក់កំរិតរយៈវេលាសុពលភាពនៃកិច្ច សន្យាដាក់កាតព្វកិច្ចឱ្យម្ចាស់ក្រុមហ៊ុន (អ្នកជួលមនុស្ស) ប្រកាសប្រាប់អ្នកធានាពេលណាកិច្ចការ របស់សាមីខ្លួនត្រូវផ្លាស់ប្តូរ ។ ល ។ ដើម្បីជួយសម្រាល បន្ទុកដល់អ្នកធានាមនុស្ស ។

## ៤.៥.៨.ការធានាដោយជួយផ្តល់ប្រាតិភោគប្រត្យ័ក្ស

នៅទីនេះ យើងនឹងបកស្រាយអំពីពាក្យថា ការធានាដោយជួយផ្តល់ប្រាតិភោគប្រត្យ័ក្ស ទុកជាមុន ។ ថ្វីត្បិតតែមានពាក្យធានាប្រើជាមួយមែនក៏ដោយ ពាក្យនេះខុសគ្នាដាច់ស្រឡះពីន័យនៃការធានានៅក្នុងច្បាប់ស្តីពីសិទ្ធិលើបំណុល ។ អ្នកធានាដោយជួយផ្តល់ប្រាតិភោគប្រត្យ័ក្ស គឺជាតតិយជន (ជនទី៣) ដែលផ្តល់ប្រាតិភោគប្រត្យ័ក្សនៅក្រោមកម្មសិទ្ធិរបស់ខ្លួនទៅឱ្យកូនបំណុល ដែលគេឱ្យឈ្មោះថាជា "ជនប្រគល់ប្រាតិភោគប្រត្យ័ក្សជួយអ្នកដទៃ" ។ ពោលគឺក្នុងករណីដូចជា ឈ្មោះ C បានជួយកូន បំណុល B ដោយប្រគល់ដីរបស់ខ្លួនទៅឈ្មោះ B ឱ្យដាក់បញ្ចាំសំរាប់ម្ចាស់បំណុល A ជាដើម។ ខុសពីអ្នកធានាទូទៅ ដែលមានកាតព្វកិច្ចធានាចំពោះបំណុលទាំងមូលរបស់កូនបំណុលនោះ អ្នកធានាដោយជួយផ្តល់ប្រាតិភោគប្រត្យ័ក្សមានកាតព្វកិច្ចត្រឹមប្រាតិភោគប្រត្យ័ក្ស ដែលខ្លួនបានប្រគល់តែប៉ុណ្ណោះ ពោលគឺគ្មានកាតព្វកិច្ចនឹងសងបំណុលណាមួយទៅម្ចាស់បំណុលឡើយ (មានន័យថា បើកូនបំណុល B មិន សងបំណុលទៅម្ចាស់បំណុល A ទេ ឈ្មោះ C នឹងបាត់បង់ដីដែលដាក់ជាការធានានោះតែប៉ុណ្ណោះគ្មានការសងបំណុលណាមួយដោយផ្ទាល់ទៅឱ្យឈ្មោះ A ទេ ) ។

# ៥. អនុប្បទានសិទ្ធិលើបំណុល

## ៥.១. លក្ខណៈទូទៅ

ឥឡូវយើងពិភាក្សាអំពីការផ្ទេរសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលម្តង។ សិទ្ធិលើបំណុលដែលយើងពិភាក្សានៅទីនេះ គឺជាសិទ្ធិទាមទារ ដែលឈ្មោះ A មានទៅលើឈ្មោះ B ដោយសារឱ្យខ្ចីប្រាក់ ១ លានរៀល ដែលជាធម្មតាគេហៅថាជា សិទ្ធិលើបំណុលកំណត់ឈ្មោះ ។ សូមប្រយ័ត្ន កុំ

ការផ្ទេរសិទ្ធិលើបំណុល(សិទ្ធិទាមទារ)




សិទ្ធិទាមទាររបស់ A ទៅលើB ដែល A បានផ្ទេរទៅ C តាមកិច្ចសន្យា ជាមួយ C នោះ នឹងប្តូរទៅជាសិទ្ធិទាមទាររបស់ C ទៅលើ B

ច្រឡំនឹងមូលធនប័ត្រ (securities) ដែលមានចែងនៅក្នុងច្បាប់ខាងវិស័យពាណិជ្ជកម្មឱ្យសោះ ។ មូលធនប័ត្រតួយ៉ាងដូចជារូបិយណត្ត (bill) ឬមូលប្បទានប័ត្រ (cheque) ជាដើមបានយករូបភាពសន្លឹកក្រដាសមកតាងឱ្យសិទ្ធិលើបំណុល (ដែលជាសិទ្ធិរបស់មនុស្សទៅលើមនុស្ស) ។ ហើយតាមរយៈនៃវិធីចារនៅខ្នងប័ណ្ណទុកជាការប្រើប្រាស់ជាដើម ការប្រគល់ប័ណ្ណ នាំឱ្យមានការផ្ទេរសិទ្ធិក្នុងន័យបំរើគោលបំណងសំរួល និងពង្រីកចរន្តភាពនៃសិទ្ធិលើបំណុលតែម្តង ។ រីឯករណីសិទ្ធិលើបំណុលកំណត់ឈ្មោះនេះ មិនមានលក្ខណៈដូចមូលធនប័ត្រទេ ។ ទោះបីជាមានលិខិតបញ្ជាក់នូវសិទ្ធិលើបំណុលនេះក៏ដោយ ក៏លិខិតនះគ្រាន់តែជាលិខិតបញ្ជាក់នូវសិទ្ធិអំណាចតែប៉ុណ្ណោះ ហើយការប្រគល់សិទ្ធិអំណាចនឹងអាចធ្វើទៅបានលុះត្រាតែមានសេចក្តីព្រមព្រៀងគ្នារវាងសាមុីជនជាដាច់ខាត។ ដូចបានពិពណ៌នារួចហើយថាច្បាប់អាណាចក្ររ៉ូមនាគ្រាដំបូងបានចែងថាសិទ្ធិលើបំណុល

គឺជាច្រវាក់តាមផ្លូវច្បាប់ ដែលចងភ្ជាប់មនុស្ស និងមនុស្ស យោលលើគំនិតនេះទើបនាកាលនោះពុំមានការអនុញ្ញាតឱ្យធ្វើការផ្ទេរសិទ្ធិដោយសេរីឡើយ ក៏ប៉ុន្តែច្បាប់បច្ចុប្បន្ននេះ នៅប្រទេសណាក៏ដោយការផ្ទេរសិទ្ធិលើបំណុលនេះត្រូវបានអនុញ្ញាតឱ្យធ្វើដោយសេរី (មាត្រា ៤៦៦) ។ ការផ្ទេរបានដោយសេរីនេះ មានន័យថា នៅពេលមានការព្រមព្រៀងគ្នារវាងម្ចាស់បំណុលជាមួយនឹងអ្នកណាម្នាក់ ម្ចាស់បំណុលអាចផ្ទេរសិទ្ធិលើបំណុលទៅអ្នកនោះបាន ដោយពុំចាំបាច់ទទួលការយល់ព្រមពីកូនបំណុលឡើយ ។

## ៥.២. ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

ដូចគ្នានឹងការផ្ទេរសិទ្ធិប្រត្យក្សដែរ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានជ្រើសរើសយកគោលការណ៍តំរូវឱ្យការផ្ទេរសិទ្ធិបំពេញនូវ ល័ក្ខខ័ណ្ឌចាំបាច់សំរាប់អះអាងការផ្ទេរសិទ្ធិនេះតទល់នឹងតតិយជន ។ នេះជាការយកតាមបទបញ្ញាត្តិនៅក្នុងក្រមរដ្ឋប្បវេណីបែបប្រទេសបារាំង ។ ពោលគឺឱ្យតែមានសេចក្តីព្រមព្រៀងគ្នា រវាងអ្នកប្រគល់និងអ្នកទទួលការផ្ទេរសិទ្ធិនឹងអនុវត្តទៅបាន ក៏ប៉ុន្តែដើម្បីអះអាងអំពីការផ្ទេរសិទ្ធិនេះចំពោះមុខកូនបំណុល ឬតតិយជនបាន (នៅពេលមានការជំទាស់ប្រឆាំង) គេត្រូវបំព្រួញនីតិវិធីតាមល័ក្ខខ័ណ្ឌចាំបាច់ដោយខានពុំបានឡើយ ។ ដូចយើងដឹងស្រាប់ហើយថា ចំពោះអចលនទ្រព្យ ល័ក្ខខ័ណ្ឌចាំបាច់នោះគឺការចុះបញ្ជី ក៏ប៉ុន្តែចំពោះសិទ្ធិលើបំណុលមានដាក់ឈ្មោះវិញ ល័ក្ខខ័ណ្ឌចាំបាច់សំរាប់អះអាង គឺការជូនដំណឹងទៅកូនបំណុលតាមរយៈលិខិតបញ្ជាក់មានចុះថ្ងៃខែជាក់លាក់ (មាត្រា ៤៦៧ ខ២) ។ ក៏ប៉ុន្តែបើចំពោះតែទំនាក់ទំនងជាមួយនឹងកូនបំណុលទេ គឺមានការងាយស្រួលបន្តិចមកដោយតម្រូវឱ្យមានតែការជូនដំណឹងទៅកូនបំណុល ឬតម្រូវឱ្យមានសេចក្តីយល់ព្រមរបស់កូនបំណុល ប៉ុណ្ណោះ ឥតចាំបាច់មានលិខិតបញ្ជាក់មានចុះថ្ងៃខែជាក់លាក់ឡើយ (មាត្រា ៤៦៧ ខ១) ។ យើងឃើញហើយថា ការជូនដំណឹងទៅកូនបំណុលក្តី សេចក្តីយល់ព្រមរបស់កូនបំណុលក្តី ពោលគឺល័ក្ខខ័ណ្ឌឥតចាំបាច់សំរាប់អះអាងតតាំងទាំងឡាយសុទ្ធតែមានពាក់ព័ន្ធជាមួយកូនបំណុលជាដរាប ។ នេះមកពីហេតុថាខុសពីសិទ្ធិប្រត្យក្ស សិទ្ធិលើបំណុលជាសិទ្ធិដែល នឹងអនុវត្តបានជា ស្ថាពរ លុះណាតែមានការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ។ ដូច្នេះហើយបានជាគេត្រូវផ្តល់ដំណឹងទៅកូនបំណុល ប្រាប់ឱ្យដឹងថាត្រូវសង

បំណុលទៅឱ្យ អ្នកណាម្នាក់ជាបឋមសិន ។ បើអ្នកផ្ដើមគំនិតផ្ទេរសិទ្ធិទាមទារបានប្រាប់ទៅកូនបំណុលហើយនោះ ជនណាដែលចង់ដឹងអំពីស្ថានភាពនៃសិទ្ធិលើបំណុលនេះ ជននោះអាចទៅសួរកូនបំណុលបានភ្លាម ពោលគឺ តាមរយៈការ សំរួលឱ្យកូនបំណុលដើរតួដូចជាមជ្ឈមណ្ឌលផ្ដល់ពត៌មានបែបនេះ នឹងធ្វើឱ្យគេអាចបំពេញមុខនាទីជូនដំណឹងជាសាធារណៈបានមួយកំរិតថែមទៀត ទោះបីជាបានពេញលក្ខណៈក៏ដោយ ។ រីឯលិខិតបញ្ជាក់មានចុះថ្ងៃខែជាក់លាក់វិញ មានមុខនាទីបញ្ជាក់ឱ្យដឹងអំពីថ្ងៃខែជាក់លាក់ ដែលបានធ្វើលិខិតដូច្នេះតោងជាលិខិតផ្លូវការ (លិខិតយថាភូត) ធ្វើឡើងដោយសារការី ឬក៏ជាលិខិតបញ្ជាក់ ដែលមានបោះត្រាចុះថ្ងៃខែដោយស្ថាប័នរដ្ឋជាដើម ។

## ៥.៣. ការចុះថ្ងៃខែជាក់លាក់ និងអនុប្បទានសិទ្ធិលើបំណុលជាច្រើនដង

ហេតុអ្វីបានជាត្រូវការឱ្យមានចុះថ្ងៃខែជាក់លាក់? ពីព្រោះថាខុសពីការចុះបញ្ជីនូវដំណើរការប្រែប្រួលនៃសិទ្ធិប្រត្យ័ក្ស ការជូនដំណឹងទៅកូនបំណុល ឬការយល់ព្រមរបស់កូនបំណុល ដែលជាល័ក្ខខ័ណ្ឌចាំបាច់សំរាប់អះអាងតទល់នេះ អាចមានច្រើនច្បាប់ (ធ្វើលិខិតផ្សេងៗជាន់គ្នាច្រើនច្បាប់) ដូច្នេះដើម្បីឱ្យដឹងថាក្នុងបណ្ដាលិខិតទាំងនោះ តើលិខិតមួយណាបានធ្វើត្រឹមត្រូវ(ពេញលក្ខណៈ)មុនគេ គេត្រូវប្រើវិធីយកបន្ទាល់ថា មួយណាធ្វើមុន មួយណាធ្វើក្រោយមកសំរេច ។ ក្នុងន័យនេះ នៅក្នុងករណីដែលមានការផ្ទេរសិទ្ធិលើបំណុលតែមួយដែលធ្វើច្រើនដង (ផ្ទេរសិទ្ធិតែមួយទៅជនច្រើនរូបទីទៃពីគ្នា) អ្នកដែលមានសិទ្ធិនឹងទទួលនោះមិនមែនអ្នកដែលបានធ្វើកិច្ចសន្យាផ្ទេរមុនគេនោះទេ តែជាអ្នកដែលបានរៀបចំល័ក្ខខ័ណ្ឌចាំបាច់សំរាប់អះអាងនោះត្រឹមត្រូវមុនគេ (ចូរចងចាំសេចក្ដីនេះឱ្យបានច្បាស់)។ នៅប្រទេសជប៉ុនវិធីទទួលការចុះថ្ងៃខែជាក់លាក់ដែលងាយស្រួលធ្វើជាងគេ គឺការធ្វើ សំបុត្រប្រៃសណីយ៍មានបញ្ជាក់សេចក្ដីធ្វើនៅមន្ទីរទូរគមនាគមន៍ ។

វិធីនេះងាយស្រួលមែន ក៏ប៉ុន្តែបានបន្សល់ទុកនូវបញ្ហាធំមួយ។ ព្រោះថាថ្ងៃខែចុះជាក់លាក់ធ្វើនៅមន្ទីរគមនាគមន៍នេះ គឺជាថ្ងៃខែផ្ញើសំបុត្រ ដូច្នេះនៅចំណុចពេលនោះកូនបំណុល (ដែលជាអ្នកមាននាទីចំបងពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌចាំបាច់សំរាប់អះអាងនេះ) មិនទាន់បានដឹងអ្វីនៅឡើយទេ។ ចំពោះបញ្ហានេះ ជាពិសេសដើម្បីដោះស្រាយបញ្ហាមានការផ្ទេរសិទ្ធិត្រួតគ្នា ថាតើល័ក្ខខ័ណ្ឌណា

មួយមានប្រៀបជាងនោះ ទ្រឹស្តីឈានមុខនៅប្រទេសជប៉ុនបានចាត់ថា (នៅក្នុងករណីលិខិតមានចុះថ្ងៃខែជាក់លាក់) លិខិតដែលបានផ្ញើទៅដល់កូនបំណុលមុនគេ ជាលិខិតមានប្រៀបជាង ។

**ការចុះថ្ងៃខែជាក់លាក់ និង សំបុត្រប្រៃសណីយ៍មានបញ្ជាក់សេចក្តី**

នៅប្រទេសជប៉ុន ដើម្បីផ្ញើសំបុត្រប្រៃសណីយ៍មានបញ្ជាក់សេចក្តី គេត្រូវយកលិខិត ៣ ច្បាប់ដូចគ្នា (លិខិតដើម ១ ច្បាប់ និងលិខិតចម្លង ២ ច្បាប់) ព្រមជាមួយស្រោមសំបុត្រទៅប្រគល់ឱ្យមន្ទីរទូរគមនាគមន៍ ។ រួចហើយមន្ទីរគមនាគមន៍ នឹងបោះត្រាចុះថ្ងៃខែលើលិខិតទាំងនោះដោយផ្ញើ ១ ច្បាប់ទៅអាស័យដ្ឋានអ្នកទទួល តម្កល់ទុក ១ ច្បាប់នៅមន្ទីរទូរគមនាគមន៍ និងប្រគល់១ច្បាប់មកអ្នកផ្ញើ(បេសកៈ)វិញ ទុកសំរាប់ប្រើប្រាស់តាម ត្រូវការ។

## ៥.៤. ការចុះបញ្ជីស្របតាមច្បាប់ពិសេសស្តីពីអនុប្បទានសិទ្ធិលើបំណុល

ក្នុងករណីដែលធ្វើការប្រមូលសិទ្ធិលើបំណុលផ្តុំគ្នាតែមួយ ដើម្បីលក់សិទ្ធិទាំងនេះចេញហើយប្រមូលទ្រព្យធនមកវិញ (ធ្វើចរន្តកម្មនៃសិទ្ធិលើបំណុល) ឬធ្វើប្រាតិភោគដោយអនុប្បទានដើម្បីទទួលបាននូវថវិកា ពោលគឺជា (ការធ្វើប្រាតិភោគដោយអនុប្បទានលើសិទ្ធិលើបំណុលផ្តុំគ្នាតែមួយ)នោះ បើសិនជាត្រូវជូនតំណឹងដល់កូនបំណុលម្នាក់ៗ គឺជាការងារមួយស្មុគស្មាញដោយត្រូវចំណាយពេលវេលាច្រើនទៀតផង ។ ហេតុដូច្នេះ នៅឆ្នាំ ១៩៩៨ ច្បាប់ពិសេសស្តីពីអនុប្បទានសិទ្ធិលើបំណុល ត្រូវបានអនុម័តឡើង ហើយកំណត់ឱ្យរៀបចំការចុះបញ្ជីតាមប្រព័ន្ធពត៌មានវិជ្ជាអេឡិចត្រូនិច ដោយផ្ទុកពត៌មានជាច្រើនស្តីពីអនុប្បទាន ដែលធ្លាប់តែតំកល់ជាឯកសារសរសេរ ។ នេះបានបង្កើតឡើងជាប្រព័ន្ធមួយ ដែលគេទទួលស្គាល់ថាដូចគ្នានឹងការជូនដំណឹងដោយប្រើលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្ថាពរនោះដែរ ដូចមានចែងក្នុងមាត្រា ៤៦៧ កថាខ័ណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី (ប៉ុន្តែប្រព័ន្ធនេះសំរួលដល់ការចុះបញ្ជី ដោយគ្មានធ្វើការជូន

ដំណឹងដល់កូនបំណុលទេ ។ ដូច្នេះ អានុប្បទានិកអាចមានលក្ខខ័ណ្ឌគ្រប់គ្រាន់សំរាប់តតាំងនឹងតតិយជនបាន តាមរយៈនៃការចុះបញ្ជីនេះ ។ ប៉ុន្តែបើសិនជាចង់ឱ្យកូនបំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនគេបានដែរនោះ ចាំបាច់ត្រូវមានការជូនដំណឹងមួយផ្សេងទៀតឱ្យទៅកូនបំណុលតាមវិធីផ្ញើលិខិតបញ្ជាក់អំពីចំណុចដែលត្រូវបានចុះក្នុងបញ្ជី) ។ នេះគឺជាការចុះបញ្ជីតាមប្រព័ន្ធអេឡេត្រូនិចមុនដំបូងបង្អស់នៅប្រទេសជប៉ុន ហើយសព្វថ្ងៃត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការអនុវត្តជាក់ស្តែង ។

## ៥.៥. អានុប្បទានសិទ្ធលើបំណុលដែលមានកំណត់ឈ្មោះ និងការតតាំងនៃកូនបំណុល

កូនបំណុល ដែលត្រូវរងការធ្វើអានុប្បទានសិទ្ធិលើបំណុលនោះ អាចបន្តការតតាំងនឹងម្ចាស់ថ្មីនៃសិទ្ធិលើបំណុល (អានុប្បទានិក) បាន ស្របតាមកំរិតនៃការតតាំងនឹងម្ចាស់សិទ្ធិលើបំណុលចាស់ (អានុប្បទានយី) (ដូចជាថា ខ្លួនបានសងសំណងមួយផ្នែកហើយ ឬអះអាងអំពីការទូទាត់បំណុលគ្នាទៅវិញទៅមកដោយសារភាគីម្ខាងទៀត ក៏កំពុងត្រូវជាប់បំណុលត្រូវសងមកវិញដែរ ។ ល ។) រហូតទល់ពេលដែលទទួលបាននូវការជូនដំណឹងអំពីអានុប្បទាននោះ (មាត្រា ៤៦៨ កថាខ័ណ្ឌទី ២) ។ ចំពោះកូនបំណុល បញ្ញត្តិនេះមានលក្ខណៈធម្មតាទេ ព្រោះថាកិច្ចសន្យាអានុប្បទាននោះត្រូវបានបង្កើតឡើងដោយមិនមានការចូលរួមរបស់ផងខ្លួនទេនោះ ការដែលខ្លួនត្រូវធ្លាក់ក្នុងស្ថានភាពអន់ជាងមុនពេលធ្វើអានុប្បទាននោះ គឺមិនសមហេតុផលទេ ។ ប៉ុន្តែ គោលការណ៍នេះនឹងមិនអាចរក្សាបានទេ បើសិនជាកូនបំណុលយល់ព្រមដោយមិនបានតវ៉ានឹងអានុប្បទានសិទ្ធិលើបំណុលនោះ ។ ឱ្យតែបានធ្វើការយល់ព្រមដោយមិនបានតវ៉ា គឺកូនបំណុលត្រូវបាត់បង់នូវរាល់លទ្ធភាពក្នុងការអះអាងតតាំងនឹងអានុប្បទាយី តាមដែលខ្លួនធ្លាប់អះអាងចំពោះអានុប្បទានិកយ៉ាងដូច្នេះ ។ អានុភាពនៃបាត់បង់ការតតាំងនេះ អាចគិតបានថាជាវិធីការពារដល់អានុប្បទានិក ដោយឈរលើជំហរដាក់ទណ្ឌកម្មលើកូនបំណុល ដែលបានឱ្យការយល់ប្រមដោយមិនមានការតវ៉ានោះ ។ ដោយហេតុថានេះមានអានុភាពខ្លាំងណាស់ អានុប្បទានិកចាំបាច់ត្រូវមានភាពសុចរិតដើម្បីអាចនឹងទទួលនូវកិច្ចការពារអាស្រ័យបទបញ្ញត្តិនេះ ។

## ៥.៦. ការទទួលយកកាតព្វកិច្ច និងអនុប្បទានឋានៈក្នុងកិច្ចសន្យា

ថ្វីត្បិតតែគ្មានបទបញ្ញត្តិកំណត់អំពីការផ្ទេរកាតព្វកិច្ច (ការទទួលយកកាតព្វកិច្ច) ក៏ដោយ តាមរយៈយុត្តិសាស្ត្រច្បាប់ និងតាមរយៈទ្រឹស្តីសិក្សាសព្វថ្ងៃនេះ គេទទួលស្គាល់នូវការផ្ទេរកាតព្វកិច្ចនេះ។ ដោយហេតុថាបំណុលដែលនឹងមានលទ្ធភាពជំរះបាន ទាល់តែកូនបំណុលមានសមត្ថភាព នឹងសងបានជាមុនសិននោះ ដូច្នេះការផ្លាស់ប្តូរកូនបំណុលជាហេតុធ្វើឱ្យលទ្ធភាពនៃការជំរះបំណុល ប្រែប្រួលទៅតាមនោះដែរ នេះជាបញ្ហាមួយធំណាស់សំរាប់ម្ចាស់បំណុល ។ ដូចនេះ កិច្ចសន្យា ទទួលយកកាតព្វកិច្ចត្រូវតែធ្វើឡើងដោយមានការចូលរួមពីសាមីជនទាំង ៣ ភាគី គឺម្ចាស់បំណុល កូនបំណុល និងអ្នកទទួលយកកាតព្វកិច្ច ឬមួយប្រសិនបើធ្វើឡើងរវាងភាគីកូនបំណុល និងភាគី អ្នកទទួលយកកាតព្វកិច្ចវិញត្រូវតែមានការយល់ព្រម (ការទទួលស្គាល់) ពីភាគីម្ចាស់បំណុលជាដាច់ខាត។

ម្យ៉ាងទៀត មិនចំពោះតែសិទ្ធិលើបំណុលណាមួយ ឬក៏កាតព្វកិច្ចណាមួយទេ គេក៏អាចផ្ទេរទៅអ្នកទី៣ (តតិយជន) បានដែរនូវសិទ្ធិលើបំណុលរួមជាមួយនឹងកាតព្វកិច្ចបូកសរុបទាំងមូល ដែលកើតចេញពីកិច្ចសន្យា ដែលគេហៅថាអនុប្បទានឋានៈក្នុងកិច្ចសន្យា ។ នៅក្នុងករណីផ្ទេរ ឋានៈនៅលើកិច្ចសន្យានេះ ដោយហេតុថាមានការទទួលយកកាតព្វកិច្ច រួមជាមួយផងនោះ នៅពេលដែលភាគីអ្នកផ្ទេរ និងភាគីអ្នកទទួលជាអ្នកធ្វើកិច្ចសន្យា គេត្រូវតែទទួលការយល់ព្រម(ការទទួលស្គាល់) ពីភាគីជាដៃគូម្ខាងទៀតជាចាំបាច់ ។ ម្យ៉ាងទៀត សូមកុំភ្លេចថាអនុប្បទានឋានៈក្នុងកិច្ចសន្យានេះ មិនត្រឹមតែអោបក្រសោបនូវការផ្ទេរសិទ្ធិលើបំណុល និងការទទួលយកកាតព្វកិច្ចតែប៉ុណ្ណោះទេ តែក្រសោបទាំងសិទ្ធិលុបចោល ព្រមជាមួយសិទ្ធិរំលាយកិច្ចសន្យា ដែលជាសិទ្ធិផ្ទាល់របស់ភាគីធ្វើកិច្ចសន្យាផងដែរ ។

# ៦. ការរលត់សិទ្ធិលើបំណុល

## ៦.១. លក្ខណៈទូទៅ

ភាគខាងចុងនៃសៀវភៅស្តីពីបទបញ្ញត្តិទូទៅ នៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានកំនត់អំពីបុព្វហេតុនៃការរលត់សិទ្ធិលើបំណុល ។ ជាគោលការណ៍ការរលត់សិទ្ធិលើបំណុលកើតឡើងដោយសារកូនបំណុលបានបំពេញកាតព្វកិច្ច ខ្លួនចប់បរិបូរណ៍ទៅតាមសេចក្តី នៃកិច្ចសន្យា ។ ក្រៅពីនេះ ច្បាប់បានកំណត់ថាការផាត់វត្ថុដទៃឱ្យជាសំណង (ការសងវត្ថុ ផ្សេងជំនួស) ដោយយោលទៅតាមកិច្ចសន្យាដែលបានធ្វើជាមួយគ្នាក្តីការ ដែលម្ចាស់បំណុលមិនទទួលយកសំណងក្តី ឬ ការយកសំណងទៅតំកល់ទុក នៅកន្លែង តំកល់ទុក វត្ថុប្រចាំមន្ទីរយុត្តិធម៌ នៅពេលដែលពុំដឹងថានរណាជា ម្ចាស់បំណុលជាដើមក្តី ការទូទាត់បំណុលគ្នាទៅវិញទៅមករវាងភាគីទាំងសងខាង (ព្យាកុលភាពៈ ភាពជាម្ចាស់បំណុលផង ជាកូនក្តីបំណុលផង) ក្តីក៏ជាបុព្វហេតុធ្វើឱ្យរលត់សិទ្ធិលើបំណុលដែរ ។ ចូរចងចាំថា ក្នុងបណ្តាបុព្វហេតុ ទាំងនេះការទូទាត់បំណុលគ្នាទៅវិញទៅមកនេះមានមុខងារជានិក្ខេប (ពោលគឺថាបើដៃគូមិនសងក៏ដោយក៏ខ្លួនអាចប្រមូលបំណុលបានមកវិញដែរដោយទូទាត់ជាមួយនឹងបំណុលរបស់ដៃគូបាន) ផងនិងជាមធ្យោបាយប្រមូលបំណុលមួយយ៉ាងងាយស្រួលជាទីបំផុត នៅក្នុងការរកស៊ី ធ្វើជំនួញជួញប្រែជាមួយគ្នាផង ។

## .២. ការសង

### ៦.២.១. សំណើផ្តល់ការសង

ជាធម្មតាទេ កាលណាមានការសងទៅតាមសេចក្តីដើម នៃកាតព្វកិច្ចជាជាក់ស្តែងហើយកាតព្វកិច្ចនឹងអស់(រលត់) ទៅតាមនោះដែរ ។ ក៏ប៉ុន្តែ ឧបមាដូចជាក្នុងករណីដែលថា ភាគីម្ខាងទៀតមិនព្រមទទួលបំណុលដោយគ្មានសំអាងលើហេតុផលសមស្របឬក៏ថាភាគីម្ខាងទៀតមិននៅនឹងទីកន្លែង ជាហេតុមិនអាចសងបំណុលទៅឱ្យគេបាន ប្រសិនជាកូនបំណុលបានស្នើផ្តល់ការ

សងហើយនោះ កូនបំណុលនឹងបានរួចពីការទទួលខុសត្រូវចំពោះការមិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន។ ចំពោះការស្នើផ្តល់ការសងនេះ ក្រៅពី "សំណើផ្តល់តាវកាលិកជាជាក់ស្តែង" ដោយយកតាវកាលិកទៅកាន់ទីកន្លែងសន្យា (មាត្រា៤៩៣)ចេញ នៅមាន "សំណើផ្ទាល់មាត់" ផងដែរ (មាត្រា ៤៩៣ វគ្គខាងលើនៃបទបដិបញ្ញត្តិ) ក្នុងករណីដែលម្ចាស់បំណុលប្រកែកមិនព្រមទទួលបំណុល ប៉ុន្តែ កូនបំណុលបានត្រៀមនឹងផ្តល់ការសងជាស្រេច ហើយបានជូនដំណឹងឱ្យម្ចាស់បំណុលមកទទួលបំណុលនោះ ។ សំណើផ្ទាល់មាត់ដែលមានការត្រៀមខ្លួនហើយ និងការជូនដំនឹងនេះត្រូវបានទទួល ស្គាល់ថាមានអានុភាពជាសំណើផ្តល់ការសងដែរ ។ ក្នុងករណីដែលការសងនេះ តម្រូវឱ្យមាន សកម្មភាពជាក់ស្តែងពីសំណាក់ម្ចាស់បំណុលផ្ទាល់ (ដូចជាក្នុងករណីដែលកិច្ចសន្យាបានកំណត់ថា ម្ចាស់បំណុលត្រូវបានទទួលបំណុល ឬថាម្ចាស់បំណុលត្រូវតែកំណត់អំពីទីកន្លែងប្រគល់បំណុលជាដើម)នោះ កូនបំណុលក៏អាចធ្វើសំណើផ្តល់ការសងដោយសំណើរ ផ្ទាល់មាត់បានដែរ (មាត្រា ៤៩៣)។

## ៦.២.២. ការសងដោយតតិយជន

ការសងអាចធ្វើទៅបានដោយតតិយជន (ជនទី៣) ដែរ (មាត្រា៤៧៤) ។ ការសងដោយតតិយជននេះ ជាការសងដោយសុចរិត ឬក៏ក្នុងករណីដែលថា បើមិនសងនេះទេខ្លួននឹងត្រូវខាតបង់ផលប្រយោជន៍អ្វីមួយជាដើម (ឧទាហរណ៍ដូចជាដោយហេតុកូនបំណុល B មិនអាចសងម្ចាស់បំណុល Aបាននោះ ឈ្មោះ C បង្ខំចិត្តត្រូវសងជំនួសឈ្មោះ B ព្រោះថាបើពុំធ្វើដូច្នោះទេវត្ថុបញ្ចាំ(និក្ខេប)ដែលខ្លួនបានប្រគល់ហើយដែលខ្លួនមិនចង់ឱ្យបាត់បង់នោះនឹងត្រូវដាក់លក់ឡាយឡុងជាពុំខាន)។ក៏ប៉ុន្តែយោលទៅតាមលក្ខណៈនៃកាតព្វកិច្ច(ដូចជាបំណុលជាដើម)ប្រភេទខ្លះគេមិនអនុញ្ញាតឱ្យអ្នកដទៃធ្វើការសងជំនួសបានទេដូចជាកាតព្វកិច្ចប្រគុំភ្លេងរបស់តន្ត្រីករណាម្នាក់ជាដើម។

## ៦.២.៣.ការកាត់បំណុល

ក្នុងករណីដែលកូនបំណុលត្រូវទទួលបន្ទុកនូវកាតព្វកិច្ចច្រើនដែលមានប្រភេទតែមួយដូចគ្នា (ឧទាហរណ៍ បំណុលមួយជាទឹកប្រាក់ ៥ លានយ៉េន និងបំណុលមួយទៀតជាទឹកប្រាក់ ៦ លានយ៉េន) ចំពោះម្ចាស់បំណុលម្នាក់ ប៉ុន្តែមិនអាចធ្វើការសងបំណុលបានគ្រប់គ្រាន់ ដើម្បីឱ្យបំណុលទាំងអស់រលត់នោះទេ (ឧទាហរណ៍ សងបានតែ ៤ លានយ៉េន) ។ ជាបឋម អ្នកសងអាចសំរេចបានថា គួរសងចំណែកបំណុលណាមុន (មាត្រា ៤៨៨ កថាខ័ណ្ឌទី ១) ។ បើសិនជាអ្នកសងមិនធ្វើការសំរេចបានទេ អ្នកទទួលការសងអាចសំរេចបាន (មាត្រាដដែល កថាខ័ណ្ឌទី ២) ។ បើសិនជាទាំងអ្នកសង ទាំងអ្នកទទួលការសង មិនបានធ្វើការសំរេចនេះទេ គេត្រូវដោះស្រាយតាមលំដាប់លំដោយ ដែលមានចែងក្នុងបញ្ញត្តិនៃមាត្រា ៤៨៩ (ការកាត់បំណុលតាមច្បាប់កំណត់) ។

## ៦.២.៤.ឧបាទេសកម្មដោយការសង

ក្នុងករណីដែលមានការសងបំណុលជំនួសដោយតតិយជន តតិយជនអាចទារសំណងនោះពីកូនបំណុលមកវិញបាន លើកលែងតែការសងជំនួសនេះ បានធ្វើឡើងដោយមានឆន្ទៈជូនជាអំណោយ។ ក៏ប៉ុន្តែ បើគ្រាន់តែប្រើសិទ្ធិទាមទារសំណងនេះ ដោយនិយាយថា "ត្រូវសងខ្ញុំវិញ" តែប៉ុណ្ណោះទេ អំណាចបង្ខំឱ្យគេសងនោះមានលក្ខណៈទន់ខ្សោយណាស់។ នៅក្នុងករណីបែបនេះ ច្បាប់បានកំណត់នូវរបបមួយដើម្បីធានានូវការអនុវត្តសិទ្ធិទាមទារសំណងនេះ ដែលហៅថាជារបបឧបាទេសកម្មដោយការសង (ចាប់ពីមាត្រា៤៩៩តទៅ) ។ ឧបាទេសកម្មមានន័យថា ជាការដាក់អ្នកណាម្នាក់ឱ្យជំនួសអ្នកផ្សេងទៀតក្នុងឋានៈដូចគ្នា ដូច្នេះមានន័យខុសគ្នានឹងការតែងតាំងតំណាង ។ នៅទីនេះ តតិយជនដែលបានធ្វើការសងហើយនោះ នឹងចូលជំនួសក្នុងឋានៈជាម្ចាស់បំណុលហើយទទួលសិទ្ធិទាំងប៉ុន្មានដែលរលត់ទៅហើយនោះដែលម្ចាស់បំណុលមានទៅលើកូនបំណុលយកមកប្រើបានទាំងអស់ ។ ឧបមាថាក្នុងករណីដែលកូនបំណុល B មានដាក់ និក្ខេប ឬក៏មានដាក់អ្នកធានាចំពោះបំណុលដែលខ្លួនជំពាក់ម្ចាស់បំណុល A តតិយជន C នឹងទទួលជំហរពីឈ្មោះA ដើម្បីប្រមូលបំណុលមកវិញដោយអាចអនុវត្តសិទ្ធិដកយកនិក្ខេបឬទាមទារឱ្យ អ្ន

កធានាធ្វើការសងឱ្យខ្លួនវិញបាន ។ ឧបាទេសកម្មដោយការសងមានចែកចេញជាពីរប្រភេទគឺៈ ឧបាទេសកម្មដោយ ស្ម័គ្រចិត្ត និង ឧបាទេសកម្មកំណត់ដោយច្បាប់ ។ ក្នុងករណីតតិយជនជាអ្នកធានាដែលបាន ជួយផ្តល់ប្រាតិភោគប្រត្យ័ក្សជំនួសកូនបំណុលដូចមាននៅក្នុងឧទាហរណ៍ខាងលើ ដោយហេតុថា បើខ្លួនមិនសងជំនួសទេ នឹងត្រូវប្រឈមនឹងការខូចខាតផលប្រយោជន៍នោះ គឺជាអ្នកដែលមានជាប់ជំពាក់ជាផលប្រយោជន៍នៅក្នុងការសងករណីនេះគេហៅថាឧបាទេសកម្មកំណត់ដោយច្បាប់ ដែលត្រូវទទួលឧបាទេសកម្ម (ការទទួលជំនួសក្នុងឋានៈជាម្ចាស់បំណុល) ជាស្វ័យប្រវត្តិ (មាត្រា៥០០) ។ រីឯករណីតតិយជនណា ដែលសងជំនួសដោយគ្មានជាប់ជំពាក់ផលប្រយោជន៍អ្វីមួយទេគេហៅថាជាឧបាទេសកម្ម ដោយការស្ម័គ្រចិត្តហើយបើគ្មានសេចក្តីយល់ព្រមពីម្ចាស់បំណុលទេនឹងពុំអាចទទួលឧបាទេសកម្មបានឡើយ រួចហើយបើចង់ធ្វើការអះអាងចំពោះមុខកូនបំណុល ឬ ចំពោះមុខជនដទៃ ណាម្នាក់ថាខ្លួនជាឧបាទេសិកដោយស្ម័គ្រចិត្តនោះលុះត្រាតែមានល័ក្ខខ័ណ្ឌចាំបាច់សំរាប់ការអះអាង ដូចគ្នានឹងករណីផ្ទេរសិទ្ធិទាមទារមានដាក់ឈ្មោះដូច្នោះដែរ (មាត្រ៤៩៩) ។

## ៦.២.៥. ការសងទៅជនគ្មានសិទ្ធិទទួល

ជាការពិតណាស់ដែលថា ប្រសិនបើកូនបំណុលមិនបានសងបំណុលទៅឱ្យម្ចាស់បំណុលពិតប្រាកដ ឬក៏ទៅឱ្យអ្នកដែលម្ចាស់បំណុលប្រគល់សិទ្ធិឱ្យទទួល (ដូចជាអ្នកតំណាងជាដើម) ទេនោះការបំពេញកាតព្វកិច្ចនឹងត្រូវចាត់ថាគ្មានសុពលភាពឡើយ។ ក៏ប៉ុន្តែច្បាប់បានកំណត់អំពីការលើកលែងចំពោះការសងទៅឧបភោគី (ជនដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសិទ្ធិករ) (មាត្រា៤៧៨) ឬទៅអ្នកកាន់វិក័យប័ត្រ (មាត្រា៤៨០) ដោយចាត់ទុកថាការបំពេញកាតព្វកិច្ចមានសុពលភាពដែរ ។ ការសងបំណុលទៅឧបភោគីនេះ ពិតមែនតែពុំមែនជាការសងទៅ ម្ចាស់បំណុលពិតប្រាកដក៏ដោយ តែជាការសងដោយទៀងត្រង់របស់កូនបំណុល ដែលឃើញអ្នកនោះហាក់បីដូចជាម្ចាស់បំណុលពិតប្រាកដមែន (យោងតាមយុត្តិសាស្ត្រច្បាប់នេះគឺជាអំពើទៀងត្រង់គ្មានកំហុស) ។ ចំពោះករណីនៃ ការសងបំណុលដោយជឿទុកចិត្តទៅ លើភិនភាគខាង

ក្រៅថាជាម្ចាស់បំណុលនោះ ច្បាប់កំណត់ថា ការសងនេះមានសុពលភាព ។ តាមពិតទៅនេះជាបទបញ្ញត្តិលើកលែងមួយដោយយល់ថាអ្នកណា ក៏មានការភ័ន្តច្រឡំដែរ ក៏ប៉ុន្តែនៅប្រទេសជប៉ុនគេបានយកបទបញ្ញត្តិនេះទៅប្រើយ៉ាងទូលំទូលាយខាងវិស័យបង់ប្រាក់ឱ្យទៅអ្នកមកបើកប្រាក់នៅធនាគារទោះបីជាអ្នកនោះមិនមែនជាសាមីខ្លួនដែលបានផ្ញើប្រាក់ក៏ដោយ (បទបញ្ញត្តិនេះបានយកតាមបទបញ្ញាត្តិនៃក្រមរដ្ឋប្បវេណីនៃប្រទេសបារាំង ក៏ប៉ុន្តែនៅប្រទេសបារាំងបទបញ្ញាត្តិនេះបានត្រូវយកមកប្រើដោយកំរិតទៅលើតែករណីដែលមានការភ័ន្តច្រឡំចៀសមិនរួចតែប៉ុណ្ណោះ។ ការយកមកប្រើយ៉ាងទូលំទូលាយដូចខាន រៀបរាប់ខាងលើបែបនេះ គឺជាលក្ខណៈពិសេសនៃច្បាប់របស់ប្រទេសជប៉ុន) ។ ចំពោះជនដែលមាន វិក័យប័ត្រវិញ ទោះបីពុំមែនជាម្ចាស់បំណុលពិតប្រាកដក៏ដោយតែជាអ្នកមានវិក័យប័ត្រពិតប្រាកដច្បាប់បានចាត់ទុកថាជាជនមានសទ្ធិទទួលយកបំណុល ហើយបានកំណត់ថាការសងបំណុលទៅជន នេះមានសុពលភាព ។

## ៦.៣. ការសងដោយយកវត្ថុជំនួស

ឧទាហរណ៍ដូចជាក្នុងករណីដែលឈ្មោះ A បានឱ្យឈ្មោះ B ខ្ចីប្រាក់ចំនួន១០លានរៀល ហើយដោយមានការយល់ព្រមពីឈ្មោះ A ឈ្មោះ B បានយកផ្ទះដែលជាកម្មសិទ្ធិរបស់ខ្លួន មកសងជំនួសកម្ចី(ប្រាក់ខ្ចី) នោះវិញជាដើម ។ ការយកវត្ថុដទៃមកសងជំនួសវត្ថុដែលបានខ្ចីដោយមានការយល់ព្រមពីម្ចាស់បំណុល ដើម្បីរំលត់សិទ្ធិលើបំណុលដូចឧទាហរណ៍ខាងលើនេះ គេហៅថាការសងដោយយកវត្ថុជំនួស (មាត្រា៤៨២) ។ ដោយហេតុថា ការសងដោយយកវត្ថុដទៃមកសងជំនួសតម្រូវឱ្យមានការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុល នេះគឺជាកិច្ចសន្យា ។ ម្យ៉ាងទៀតប្រសិនបើពុំមានការយកវត្ថុដទៃទៅសងជំនួសជាក់ស្តែងទេនោះគេមិនទទួលស្គាល់ថាការសងនេះមានសុពលភាពឡើយពោលគឺជា កិច្ចសន្យាអំពីការប្រគល់វត្ថុ ។ ក្នុងករណីខ្លះគេអាចសន្យាអំពីការសងដោយវត្ថុជំនួសដែលមាន(ឬក៏ជាកិច្ចសន្យាដាក់ល័ក្ខខ័ណ្ឌអំពីការសងដោយយកវត្ថុជំនួស)ដូចជាពាក្យសន្យាថា "បើខ្ញុំមិនមានលទ្ធភាពសងកម្ចីទេនោះខ្ញុំនឹងប្រគល់ផ្ទះនេះជូន" ។ នេះជាកិច្ច សន្យាដែលធ្វើឡើងក្នុងគោលបំណងដាក់ជាការធានា ។

## ៦.៤. ការយកសំណងទៅដំកល់ទុក

ក្នុងករណីដែលកូនបំណុលមានចេតនានឹងសងបំណុល ប៉ុន្តែម្ចាស់បំណុលពុំសុខចិត្តទទួល ឬម្ចាស់បំណុលបាត់ខ្លួនពុំដឹងជានៅទីណាទេ បើសិនជាកូនបំណុលបានធ្វើ សំណើផ្តល់ការសង ហើយនោះ គឺកូនបំណុលនឹងបានរួចពីការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។ ក៏ប៉ុន្តែកូនបំណុលមិនទាន់បានរួចពីកាតព្វកិច្ចនៅឡើយទេ ។ ដើម្បីរំលត់កាតព្វកិច្ចនេះ កូនបំណុលត្រូវអនុវត្តវិធីមួយគឺ ការយកសំណងទៅដំកល់ទុក។ ក្នុងការប្រតិបត្តិជាក់ស្តែងនៅប្រទេសជប៉ុន គេត្រូវយកវត្ថុដែលជាសំណងនោះទៅដំកល់ទុកនៅកន្លែងដំកល់វត្ថុ នៅមន្ទីរយុត្តិធម៌ណាមួយនៅទូទាំងប្រទេសជប៉ុន ដោយសូមឱ្យរំលត់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលចោល។ ក៏ប៉ុន្តែក្នុងករណីដែលអាចសងបំណុលបានជាធម្មតាដូចសេចក្តីក្នុងកិច្ចសន្យាការយកសំណងទៅដំកល់ទុក នេះពុំត្រូវបានអនុញ្ញាតឡើយ ពោលគឺការដំកល់ទុកនេះតម្រូវឱ្យមានបុព្វហេតុជាចាំបាច់ ។ បុព្វហេតុទីមួយគឺម្ចាស់បំណុលប្រកែកមិនព្រមទទួល ឬមួយក៏មិនអាចទទួលសំណងបាន ។ បុព្វហេតុទីពីរ គឺ ការមិនអាចស្គាល់ឱ្យបានច្បាស់អំពីម្ចាស់បំណុល ហើយដែលមិនមែនជាកំហុសរបស់កូនបំណុលទេនោះ ។ ឧទាហរណ៍ដូចជាករណី ម្ចាស់បំណុលស្លាប់ទៅ ហើយពុំដឹងថាតើនរណាជាទាយាទ(អ្នក ស្នងមរតក)ច្បាស់លាស់ ឬដូចជាករណីមានការ ផ្ទេរសិទ្ធិលើបំណុលតែមួយ ដែលផ្ទេរច្រើនដងទៅជនច្រើនរូបជាហេតុ ដែលមិនអាចដឹងឱ្យបានច្បាស់លាស់ថាតើនរណាជាម្ចាស់បំណុលថ្មីពិតប្រាកដ ទេនោះ (មាត្រា៤៩៤) ។

## ៦.៥.ការទូទាត់

លើកយកករណីថាឈ្មោះ A បានឱ្យឈ្មោះ B ខ្ចីប្រាក់ចំនួន៥លានរៀល ហើយឈ្មោះ B បានលក់ទំនិញទៅឱ្យឈ្មោះ A មានតម្លៃជាប្រាក់ ២លានរៀលដែលមិនទាន់បានបង់ប្រាក់ នៅឡើយមកពិភាក្សា។នៅក្នុងករណីខាងលើប្រសិនបើឈ្មោះ B បានបង្ហាញឆន្ទៈថាខ្លួននឹងផាត់ប្រាក់ថ្លៃទំនិញ ២ លានរៀលដែលជាសិទ្ធិទាមទាររបស់ខ្លួនទៅនឹងមួយភាគនៃបំណុលដែលខ្លួន

ជំពាក់នោះ ឈ្មោះ B អាចប្រកែកមិនសងមួយភាគ (២លានរៀល) នៃបំណុលនោះបាន ។ នេះគេហៅថាការទូទាត់ ។ ការទូទាត់នេះនៅក្នុងករណីដែលម្ចាស់បំណុល និងកូនបំណុល មានបំណុលប្រភេទដូចគ្នា (ដូចជាម្នាក់មានសិទ្ធិទាមទារប្រាក់ ហើយម្នាក់ទៀត ក៏មានសិទ្ធិទាមទារប្រាក់ដែរជាដើម។ គេហៅភាពដែល បុគ្គលម្នាក់ ជាម្ចាស់បំណុលផង ហើយជាកូនបំណុលផងថាព្យាកុលភាព) ហើយប្រសិនបើភាគីណាមួយបានបង្ហាញឆន្ទៈទូទាត់នោះទំហំតម្លៃស្មើគ្នាទៅវិញទៅមកនឹងត្រូវ រលត់ជាមួយគ្នា(មាត្រា៥០៥)។ គេហៅ សិទ្ធិលើបំណុលរបស់ភាគីផ្តើមគំនិតទូទាត់ថា សិទ្ធិលើបំណុលសកម្មហើយហៅសិទ្ធិលើ បំណុលរបស់ភាគីដែល ទទួលការទូទាត់ថាសិទ្ធិលើបំណុលអកម្ម ។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានចែងកំណត់នូវបទបញ្ញាត្តិអំពីការទូទាត់ ដែលកើត ឡើងដោយការបង្ហាញ ឆន្ទៈតាមចំណូលចិត្តឯកតោភាគីតែប៉ុណ្ណោះក៏ប៉ុន្តែភាគីទាំងសងខាងមានសេរីភាពពេញទីក្នុងការព្រមព្រៀងគ្នា ធ្វើកិច្ចសន្យាទូទាត់នេះ ។ នៅក្នុងករណីដែលមានភាគីតែម្ខាងបង្ហាញឆន្ទៈទូទាត់នោះសិទ្ធិលើបំណុលទាំងសងខាងមិនត្រឹមតែត្រូវមានប្រភេទដូចគ្នាប៉ុណ្ណោះ ទេតែចាំបាច់ត្រូវចូលដល់ពេលកំណត់ត្រូវសង ដូចគ្នាទៀតផង (មាត្រា៥០៥ ខ ១)។ ល័ក្ខខ័ណ្ឌគ្រប់គ្រាន់សំរាប់ធ្វើឱ្យការទូទាត់មានដំណើរការបាននេះ គេហៅថាល័ក្ខខ័ណ្ឌពេញលេញសំរាប់ការ ទូទាត់។ក៏ប៉ុន្តែនៅក្នុងករណី ដូចជាថាម្ចាស់បំណុល A ចូលដល់រយៈពេលទារសំណង (ឈ្មោះ B ត្រូវសងទៅឈ្មោះ A ) ហើយ តែម្ចាស់បំណុល B មិនទាន់ចូលដល់រយៈពេលទារសំណងនៅឡើយទេ (ឈ្មោះ A មិនទាន់សងទៅឈ្មោះ B ក៏បាន ដែរ) នោះ ភាគី A អាចធ្វើការទូទាត់បាន ដោយបោះបង់ចោល នូវផលចំណេញអាស្រ័យពេលវេលា ដែលខ្លួនមានសិទ្ធិនឹងទទួល ។

## III. ក្រមរដ្ឋប្បវេណីនៅក្នុងកិច្ចការផ្លូវច្បាប់នៃសហគ្រាស

ដូចបានពិពណ៌រួចមកហើយថានៅក្នុងកិច្ចអនុវត្តន៍ជាក់ស្ដែង បញ្ហាដែលស្មុគស្មាញជាងគេនោះគឺបញ្ហាទាមទារបំណុលនិងបញ្ហាអនុវត្តទៅលើនិក្ខេបដែលជាបញ្ហាពាក់ព័ន្ធជាពិសេសទៅនឹងផ្នែកទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល និងច្បាប់ស្ដីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស ។ រួចហើយយើងក៏បានពិពណ៌នាផងដែរថាគឺនៅក្នុងដំណាក់កាលនេះហើយដែលច្បាប់រដ្ឋប្បវេណីបានគូសបង្ហាញយ៉ាងច្បាស់ជាទីបំផុតនូវការអះអាងតទល់គ្នាអំពីផលប្រយោជន៍រវាងគ្រប់ភាគី។ ចំណេះដឹងដូចបានធ្វើអត្ថាធិបប្បាយខាងលើនេះមានសារះប្រយោជន៍ធំធេងណាស់ចំពោះនិស្សិតរាល់រូបដែលរៀនច្បាប់ទោះបីជាដើម្បីប្រឡងចូលធ្វើជាអ្នកឯកទេសច្បាប់ក្ដីជាបុគ្គលិកក្រុមហ៊ុនឯកជនដូចជាធនាគារក្រុមហ៊ុនពាណិជ្ជកម្មឬរោងចក្រឧស្សាហកម្មណាមួយក្ដី។ ឥឡូវយើងនឹងលើកយកឧទាហរណ៍ជាក់ស្ដែងមួយមកបង្ហាញដូចតទៅៈ ឧបមាថាក្រុមហ៊ុនដែលយើងបានវិនិយោគទុនឬក៏បានធ្វើជំនួញលក់ជឿជាមួយនោះបានធ្លាក់ក្នុងស្ថានភាពដុនដាបខាតបង់យ៉ាងធ្ងន់ទាំងនៅជំពាក់បំណុលយើងនៅឡើយផង។នៅពេលនោះអ្នកទាំងឡាយដែលកាន់កិច្ចការផ្លូវច្បាប់សំរាប់សហគ្រាសប្រាកដជាបញ្ចេញតិរិះខ្លួនទាំងអស់ដែលមាននៅក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុលនិងក្នុងច្បាប់ស្ដីពីសិទ្ធិ ប្រាតិភោគប្រត្យ័ក្ស ហើយស្ទុះស្ទារប្រជែងគ្នាទៅប្រមូល បំណុលខ្លួនមកវិញជាពុំខាន ។ ជាដំបូងប្រសិនបើក្រុមហ៊ុនជិតរលំនោះមានដាក់និក្ខេបដើម្បីថានាបំណុលជាដើម យើងត្រូវអនុវត្តការដក យកនិក្ខេបនោះសិន។ បន្ទាប់មកក្នុងករណីមានដាក់អ្នកធានា (ការធានាដោយបុគ្គល)វិញ យើងអាច គិតបានថា អ្នកធានាអាចនឹងរលំជាមួយក្រុមហ៊ុននោះផងក៏មិនដឹង ដូច្នេះយើងត្រូវប្រញាប់ប្រញាល់ ចាត់ចែងរឿងនេះជាបន្ទាន់ផងដែរមុនពេលដែលអ្នកធានាត្រូវបាត់បង់ទ្រព្យធនរបស់គេ។ រួច ហើយចំពោះបំណុលណា ដែលគ្មានដាក់ប្រាតិភោគ វិញយើងត្រូវសើរើថាតើក្រុមហ៊ុនយើងមានជំពាក់បំណុលក្រុមហ៊ុននោះទេពោលគឺស្រាវជ្រាវរកថាមានសិទ្ធិទាមទារបញ្ច្រាសរបស់ក្រុមហ៊ុននោះមកវិញទេហើយប្រសិនបើមានមែន ជាបឋមយើងត្រូវធ្វើការទូទាត់ដើម្បីប្រមូលចំណែកនេះ ទុកសិន ។

បន្តមកទៀត ប្រសិនបើក្រុមហ៊ុននោះមានសិទ្ធិទាមទារបំណុលទៅលើតតិយជន (ជនទី៣) យើងត្រូវទាមទារយកបំណុលនោះមកជំនួសប្រាក់លក់ជឿពោលគឺតំរូវអោយធ្វើការផ្ទេរសិទ្ធិទាមទារក្នុងលក្ខណៈជាការផាត់វត្ថុដទៃអោយជាសំណង ក៏ប៉ុន្តែយោលទៅតាមកាលៈទេសៈ ការផ្ទេរសិទ្ធិទាមទារនេះអាចត្រូវចោលដោយអ្នកមានសិទ្ធិទាមទារដទៃទៀត(ដែលជាម្ចាស់បំណុលដែរ)ដោយលើកយកសិទ្ធិលុបចោលអំពើបោកបន្លំ (សិទ្ធិលុបចោលដោយម្ចាស់បំណុល) មកអនុវត្តទៅលើបំណុលនោះ។ដោយហេតុថាម្ចាស់បំណុលណាដែលបានអនុវត្តសិទ្ធិលុបចោលអំពើបោកបន្លំមុនគេរមែង មានប្រៀបក្នុងការប្រមូលបំណុលនោះ យើងក៏ត្រូវឃ្លាំមើលសកម្មភាពរបស់ម្ចាស់បំណុលដទៃទៀតជាបណ្តើរផង និងរំពៃមើលឱកាសដើម្បីអនុវត្តសិទ្ធិលុបចោលនោះជាបណ្តើរផងដែរ ។ បើពិនិត្យដូច្នេះទៅ យើងនឹងឃើញថាអ្វីៗ ដែលយើងបានគិតស្មានថាគ្រាន់តែជាវិធានចារទុកចោលនៅលើទំព័រសៀវភៅមេរៀនតែប៉ុណ្ណោះទេនោះមានសារៈសំខាន់ណាស់នៅក្នុងកិច្ចការអនុវត្តជាក់ស្តែងព្រោះថាវិធានទាំងនេះនឹងក្លាយទៅជាអាវុធដ៏សក្តិសិទ្ធិមួយប្រកបទៅដោយប្រសិទ្ធិភាពតាមផ្លូវច្បាប់ទៀតផងសំរាប់ប្រើនៅក្នុងសង្គ្រាមវិវាទរវាង សហគ្រាសទាំងឡាយដែលប្រជែងគ្នាពីមួយ វិនាទីទៅមួយវិនាទីនោះ ។

## កិច្ចការផ្លូវច្បាប់នៃសហគ្រាស

កិច្ចការផ្លូវច្បាប់នៃសហគ្រាសមានដំណើរវិវត្តន៍ចេញពីកិច្ចការផ្លូវច្បាប់សំរាប់ដោះស្រាយវិវាទទៅជាកិច្ចការផ្លូវច្បាប់ដើម្បីការពារហើយឆ្លងមួយតំណាក់ទៀតទៅជាកិច្ចការផ្លូវច្បាប់ ជាយុទ្ធសាស្រ្ត (strategy)។ ដែលហៅថាកិច្ចការផ្លូវច្បាប់ជាយុទ្ធសាស្រ្តគឺកិច្ចការសហគ្រាសដែលពាក់ព័ន្ធទៅនឹងច្បាប់នានាសំរាប់អនុវត្តធ្វើជំនួញអោយមានប្រសិទ្ធិភាពដោយថ្លឹងគ្រោះថ្នាក់និងផលចំណេញដែលអាចកើតមានដល់សហគ្រាស។ ដោយយល់នូវសារៈសំខាន់ដូច្នេះហើយ ទើបសហគ្រាសទំនើបៗនាបច្ចុប្បន្ននាំគ្នាពង្រឹងផ្នែកច្បាប់នេះនៅក្នុងការគ្រប់គ្រងសហគ្រាសរបស់ខ្លួន ។

# ជំពូកទី ៧

# ច្បាប់ស្តីពីសិទ្ធិប្រត្យ័ក្ស (២)

# ច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

I. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

១. និយមន័យនិងលក្ខណៈទូទៅនៃសិទ្ធិប្រាតិភោគប្រត្យ័ក្ស

២. តួនាទីនៃសិទ្ធិប្រាតិភោគប្រត្យ័ក្សនិងឋានៈនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

II. ការសិក្សាពីចំនុចសំខាន់ៗនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

១. សិទ្ធិប្រាតិភោគប្រត្យ័ក្សដែលកំណត់ដោយការសន្យា

២. សិទ្ធិប្រាតិភោគប្រត្យ័ក្សដែលច្បាប់បានកំណត់

៣. ប្រាតិភោគវិសាមញ្ញ

# I. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

## ១. និយមន័យនិងលក្ខណៈទូទៅនៃសិទ្ធិប្រាតិភោគប្រត្យ័ក្ស

### ១.១. និយមន័យ

យើងសាកល្បងគិតមើលថា តើយើងត្រូវធ្វើដូចម្តេចនៅពេលដែលយើងផ្តល់ហិរញ្ញប្បទាន (ផ្តល់ប្រាក់ខ្ចី) ដល់បុគ្គលណាម្នាក់ផ្សេងទៀត។ ទោះបីជាក្នុងទំនាក់ទំនងរវាង ឪពុកម្តាយ និងកូន ឬរវាងបងប្អូន មានករណីជាច្រើនដែលដៃគូមានការទំនុកចិត្តគ្នា ហើយឱ្យខ្ចីដោយព្រមព្រៀងគ្នាជាធម្មតាចំពោះការប្រាក់ និងពេលវេលាសងប្រាក់វិញក៏ដោយ ក៏ហេតុការណ៍នេះមិនអាចកើតមានទេនៅក្នុងការជួញដូរជាទូទៅ។ ក្នុងករណីស្ទើរតែទាំងអស់ ភាគីអ្នកឱ្យខ្ចីនឹងទទួលយកអ្វីមួយធ្វើជាប្រាតិភោគសំរាប់ករណីដែលអ្នកខ្ចីមិនអាចសងបំណុលមកវិញបាន។ មានមធ្យោបាយមួយគឺយកទ្រព្យរបស់អ្នកខ្ចីមកធ្វើជាប្រាតិភោគហើយនៅពេលដែលអ្នកខ្ចីមិនអាចសងបំណុលវិញបានអ្នកឱ្យខ្ចីអាចប្តូរទ្រព្យនេះទៅជាសាច់ប្រាក់ (តាមរយៈការលក់ដោយ បង្ខំ) ដើម្បីប្រមូលកម្ចីមកវិញ។ ការធានាបែបនេះ គឺជាការធានាដោយវត្ថុ (ការធានាបែបនេះ មានភាពខុសគ្នាទៅនឹងការធានាមួយទៀតហៅថាការធានាមនុស្ស ដែលតំរូវឱ្យចាត់តាំងអ្នកធានាជាដើម ដូចមានរៀបរាប់នៅក្នុងជំពូកមុន)។ ពាក់ព័ន្ធនឹងទ្រព្យ ដែលបានយកមកធ្វើជាប្រាតិភោគនៅក្នុងករណីនេះ ម្ចាស់បំណុលដែលបានផ្តល់ហិរញ្ញប្បទានមិនគ្រប់គ្រងតម្លៃ ប្រើប្រាស់របស់ទ្រព្យនោះទេ ប៉ុន្តែគ្រប់គ្រងលើតម្លៃដោះដូរ (ពោលគឺការកំណត់ថាតើទ្រព្យនោះត្រូវមានម្លៃប៉ុន្មានបើត្រូវការប្តូរទៅជាសាច់ប្រាក់)។

ទោះបីជាសិទ្ធិគ្រប់គ្រងដោយផ្ទាល់លើទ្រព្យស្ថិតនៅក្នុងសិទ្ធិប្រត្យ័ក្សក៏ដោយ ក៏សិទ្ធិគ្រប់គ្រងរបៀបនេះ ត្រូវបានគេហៅថា សិទ្ធិប្រាតិភោគប្រត្យ័ក្ស។

## ១.២. លក្ខណៈច្បាប់

ហេតុដូច្នេះ សិទ្ធិប្រាតិភោគប្រត្យ័ក្សមានភាពបន្ទាប់បន្សំដែលចែករំលែកភ័ព្វវាសនាជាមួយនឹងសិទ្ធិលើបំណុល ដែលបង្កើតសិទ្ធិប្រាតិភោគប្រត្យ័ក្សនេះ (បើសិនជាសិទ្ធិលើបំណុលត្រូវរលត់ នោះសិទ្ធិប្រាតិភោគប្រត្យ័ក្សក៏ត្រូវរលត់ដែរ។ ហើយក៏មានភាពទៅជាមួយគ្នាដែរ ក្នុងទំនាក់ទំនងជាមួយនឹងសិទ្ធិលើបំណុល ពោលគឺបើសិនជាសិទ្ធិលើបំណុលត្រូវបានផ្ទេរ នោះសិទ្ធិប្រាតិភោគប្រត្យ័ក្សក៏ត្រូវបានផ្ទេរដែរ)។ ម៉្យាងវិញទៀត ដើម្បីធ្វើឱ្យសិទ្ធិប្រាតិភោគប្រត្យ័ក្សមានអានុភាពកាន់តែខ្លាំង ច្បាប់ក៏មានចែងផងដែរអំពីអវិភាគភាព ដែលតាមរយៈនេះម្ចាស់បំណុលអាចអនុវត្តបាននូវសិទ្ធិប្រាតិភោគប្រត្យ័ក្ស លើវត្ថុទាំងមូលដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យ័ក្សរហូតដល់ពេលដែលម្ចាស់បំណុលនោះបានទទួលសំណងនៃសិទ្ធិលើបំណុលទាំងអស់ (មាត្រា ២៩៦)។ លើសពីនេះទៅទៀត នៅពេលកើតមានការជួសជុលសំណង ដោយសារ ការបាត់បង់ ឬការខូចខាត ឬនៅពេលមានថ្លៃឈ្នួល ឬការបង់ប្រាក់តាមរយៈការជួល ឬការលក់នូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ សិទ្ធិប្រាតិភោគប្រត្យ័ក្សក៏អាចមានអានុភាពមកលើសំណង ឬថ្លៃឈ្នួល ឬការបង់ប្រាក់ទាំងនោះបានដែរ តាមរយៈឧបាទេសកម្មលើវត្ថុ ។ ក្នុងចំណោម

ប្រភេទទាំងបួននៃសិទ្ធិប្រាតិភោគប្រត្យ័ក្ស មានសិទ្ធិប្រាតិភោគប្រត្យ័ក្សដល់ទៅបីប្រភេទដែលទទួលស្គាល់នូវឧបាទេសកម្មលើវត្ថុនេះ (ដូចជាមាត្រា ៣០៤ ជាដើម។ សិទ្ធិឃាត់ទុកដែលនឹងមានរៀបរាប់នៅផ្នែកខាងក្រោយពុំទទួលស្គាល់ឧបាទេសកម្មលើវត្ថុទេ ពីព្រោះសិទ្ធិនេះពុំមានអានុភាពទទួលសំណងដោយអាទិភាពផ្អែកលើតម្លៃនៃវត្ថុនោះឡើយ)។

## ១.៣. ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យ័ក្ស

ដូចដែលបានរៀបរាប់បង្ហាញនៅក្នុងជំពូកទី៣ខាងដើម សិទ្ធិប្រាតិភោគប្រត្យ័ក្សមានពីរប្រភេទ ពោលគឺសិទ្ធិប្រាតិភោគប្រត្យ័ក្សដែលកំណត់ដោយការសន្យាដែលកើតឡើងចេញពីកិច្ចសន្យារវាងភាគី និងសិទ្ធិប្រាតិភោគប្រត្យ័ក្សដែលច្បាប់បានកំណត់នៅពេលមានស្ថានភាពជាក់លាក់កំណត់ណាមួយ។ ក្រមរដ្ឋប្បវេណីបានចែងកំណត់ថា ឯកសិទ្ធិ និងសិទ្ធិឃាត់ទុកគឺជាសិទ្ធិប្រាតិភោគប្រត្យ័ក្សដែលច្បាប់បានកំណត់ ចំណែកសិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក គឺជាសិទ្ធិប្រាតិភោគប្រត្យ័ក្សដែលកំណត់ដោយការសន្យា។ ចំពោះក្រុមហ៊ុនជួញដូរនាពេលបច្ចុប្បន្ន សិទ្ធិប្រាតិភោគប្រត្យ័ក្សដែលកំណត់ដោយការសន្យាមានសារៈសំខាន់ខ្លាំងជាង ហើយជាពិសេសហ៊ីប៉ូតែកទៀតសោតមានសារៈសំខាន់ណាស់។ ម្យ៉ាងវិញទៀត ទោះបីជាក្រមរដ្ឋប្បវេណីទទួលស្គាល់តែបួនប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យ័ក្សនេះក៏ដោយ ក៏បន្ថែមពីនេះ នៅមានរបៀបរបបជួញដូរផ្សេងៗទៀតដែលបានច្នៃប្រឌិតកើតចេញមកពីការអនុវត្តន៍នានា និងបានបង្កើតឱ្យមាន

ការធ្វើប្រាតិភោគសំអាងលើវត្ថុ ហើយដែលត្រូវបានទទួលស្គាល់ដោយវិធានទំនៀមទំលាប់ ឬដោយករណីយុត្តិសាស្ត្ររបស់តុលាការផងដែរ។ សិទ្ធិប្រាតិភោគប្រត្យក្សបែបនេះ គេហៅថា ប្រាតិភោគវិសាមញ្ញ (ដែលនឹងមានពន្យល់ដោយសង្ខេបនៅផ្នែកខាងក្រោយនៃជំពូកនេះ) ។

## ២. តួនាទីនៃសិទ្ធិប្រាតិភោគប្រត្យ័ក្ស និងឋានៈនៃច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

ទោះបីជាសិទ្ធិប្រាតិភោគប្រត្យក្សត្រូវគេហៅថាជាសិទ្ធិប្រត្យ័ក្សក៏ដោយ ក៏សិទ្ធិប្រាតិភោគប្រត្យ័ក្សនេះគ្រាន់តែជាសិទ្ធិគ្រប់គ្រងលើតម្លៃដោះដូរនៃវត្ថុតែប៉ុណ្ណោះ។ ដូចបានពន្យល់រួចស្រាប់នៅផ្នែកស្តីអំពីលក្ខណៈគតិយុត្តិខាងលើនេះ សិទ្ធិប្រាតិភោគប្រត្យ័ក្សគឺ គ្មានអ្វីក្រៅពីសិទ្ធ ដែលបានបង្កើតឡើងដើម្បីជាការធានាចំពោះសិទ្ធិលើបំណុល ដែលសន្មត់ថាមានអត្ថិភាពរួច ហើយមានតម្លៃសមស្របទៅនឹងតម្លៃនៃវត្ថុដែលត្រូវតំកល់សំរាប់ការធានានោះ។ ដូច្នេះការសិក្សាពីសិទ្ធីប្រាតិភោគប្រត្យ័ក្ស ទន្ទឹមគ្នានឹងច្បាប់ស្តីពីសិទ្ធិលើបំណុល គឺជារឿងមួយ សមហេតុសមផល។

បើនិយាយឱ្យបានជាក់ស្តែង ឧបមាថា អីឡូវនេះ កូនបំណុល “x” មាន ទ្រព្យសម្បត្តិទាំងអស់ (ទ្រព្យសម្បត្តិស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ដែលអាចយកមកធ្វើជាសំណងបានជាដើម) តម្លៃសរុប ១០០០ ម៉ឺនយេន ដែលក្នុងនោះ មានដីឡូ "ក" មួយកន្លែងដែលមានតម្លៃ ៥០០ម៉ឺនយេន។ ឧបមាបន្តទៀតថា កូនបំណុលនេះមានម្ចាស់បំណុល ចំនួនប្រាំនាក់ A, B, C, D, E ដែលមានសិទ្ធិលើបំណុលចំនួន ៥០០ ម៉ឺនយេន ក្នុងម្នាក់ៗ។

ប្រសិនជាគ្មានអ្នកណាក្នុងចំណោមម្ចាស់បំណុលទាំងប្រាំនាក់ មានសិទ្ធិប្រាតិភោគប្រត្យក្ស ពាក់ពន្ធ័នឹងសិទ្ធិលើបំណុលនេះទេ ហើយដោយសារតែមិនបានទទួលសំណងពីកូនបំណុលទេ នោះ ម្ចាស់បំណុលទាំងប្រាំ A, B, C, D និង E ក៏បានចាត់និតិវិធីអនុវត្តដោយបង្ខំ។ ក្នុងករណី នេះ យោងតាមគោលការណ៍សមភាពរបស់ម្ចាស់បំណុល ប្រាំនាក់នោះអាចចែកគ្នាដោយ សមភាពនូវទឹកប្រាក់ចំនួន ១000 ម៉ឺនយេនដែលជាទ្រព្យសម្បត្តិរបស់ X ដោយម្នាក់ៗ ទទួលបានមកវិញចំនួន ២០០ម៉ឺនយេនតែប៉ុណ្ណោះ (សេចក្តីលំអិត សូមសិក្សាពីច្បាប់ស្តីពីការ អនុវត្តសាលក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ នៅក្នុងករណីនេះ ប្រសិបជាមានតែម្ចាស់បំណុល A ម្នាក់គត់ ដែលបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សក្រោមរូបភាពជា ហ៊ីប៉ូតែក (ដែលនឹងមាន រៀបរាប់បង្ហាញក្នុងផ្នែកខាងក្រោយនេះ) លើដីឡូ "ក" របស់កូនបំណុល X ហើយ បើកូនបំណុលមិនបានសងបំណុលទេ បន្ទាប់ពីរយៈកាលកំណត់សំរាប់ការសងនោះបានមកដល់ ម្ចាស់បំណុល A នឹងអនុវត្តហ៊ីប៉ូតែកលើដីឡូ "ក" នេះបាន (ការលក់ដោយបង្ខំ)។ ហើយក្នុង ករណីដែលដីឡូ "ក" នេះលក់បានតម្លៃ ៥០០ម៉ឺនយេន ទឹកប្រាក់ដែលបានមកពីការលក់ ចំនួន៥០០ម៉ឺនយេននេះ អាចយកមកធ្វើជាសំណងដល់ម្ចាស់បំណុល A ដោយមានអាទិភាពមុន ម្ចាស់បំណុលផ្សេងៗទៀត។ ហេតុដូច្នេះ ម្ចាស់បំណុលបួននាក់ផ្សេងទៀត អាចទទួលសំណង ដោយសមភាពបានត្រឹមតែពីក្នុងចំនួន ៥០០ ម៉ឺនយេននៃទ្រព្យសម្បត្តិ ដែលនៅសល់តែប៉ុណ្ណោះ ពោលគឺ ម្នាក់ៗទទួលបានសំណងចំនួន ១២៥ ម៉ឺនយេន។ មានន័យថាសិទ្ធិប្រាតិភោគប្រត្យក្ស

ដូចជាហ៊ីប៉ូតែកជាដើម នឹងនាំឱ្យមានការទទួលសំណងដោយមានអាទិភាព។

តាមពិតទៅ ចំពោះមធ្យោបាយធានាសិទ្ធិលើបំណុលនេះ មានការធានាផ្សេងៗ ដូចជាការធានាដោយបុគ្គលផងដែរ ដែលបានសិក្សាក្នុងជំពូកមុនជាដើម។ ចំពោះករណីខាងក្រោមនេះ ឧបមាថា Y គឺជាអ្នកធានារបស់ X ចំពោះ B ។ ឱ្យតែ Y មានសាធនភាព គ្រប់គ្រាន់ គឺ B អាចទទួលបានសំណងសរុបចំនួន ៥០០ ម៉ឺនយេនពី Y (ឬពី Y និង X រួមគ្នា)។ ក៏ប៉ុន្តែការធានាដោយបុគ្គលបែបនេះ គឺមានភាពមិនប្រាកដប្រជា អាស្រ័យទៅតាមទ្រព្យធនសកម្មដែលអាចមានការផ្លាស់ប្តូរ របស់អ្នកធានា។ ផ្ទុយពីការធានាបែបនេះ ប្រាតិភោគប្រត្យក្សជាហ៊ីប៉ូតែកជាដើម គឺមានភាពច្បាស់លាស់ និងប្រាកដប្រជា។ ប៉ុន្តែ ដោយសារនេះជាប្រភេទនៃសិទ្ធិប្រត្យក្សដែលនាំឱ្យមានអាទិភាព និតិវិធីបង្កើតប្រាតិភោគនេះតម្រូវឱ្យមានការចុះបញ្ជីជាដើម មានលក្ខណៈពិបាកជាងការធានាដោយបុគ្គលដែលអាចធ្វើឡើងបានដោយគ្រាន់តែចុះកិច្ចសន្យាតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលតម្លៃលើទីផ្សារនៃអចលនវត្ថុធ្លាក់ចុះ ខ្លាំង គឺសិទ្ធិប្រាតិភោគប្រត្យក្ស ក៏ត្រូវមានលក្ខណៈដូចគ្នានឹងការធានាដោយបុគ្គលដែរ ដែលបង្កឱ្យមានភាពប្រថុយប្រថានពុំអាចធានានូវការសងបំណុលឱ្យបានគ្រប់ចំនួនឡើយ។ ហេតុ ដច្នេះ ដើម្បីធានាការប្រមូលមកវិញនូវសិទ្ធិលើបំណុល គេត្រូវការអនុវត្តតាមវិធីសាស្រ្តផ្សេងៗ ទាំងអស់ដែលមានចែងកំណត់នៅក្នុងក្របខ័ណ្ឌនៃបញ្ញត្តិទូទៅស្តីពីសិទ្ធិលើបំណុល និងច្បាប់ស្តីពីសិទ្ធិប្រាតិភោគប្រត្យក្ស បន្ទាប់ពីបានធ្វើការពិចារណាគ្រប់ជ្រុងជ្រោយរួចមក ។

# II. ការសិក្សាពីចំនុចសំខាន់ៗនៃច្បាប់ស្ដីពីសិទ្ធិប្រាតិភោគប្រត្យ័ក្ស

## ១. សិទ្ធិប្រាតិភោគប្រត្យ័ក្សដែលកំណត់ដោយការសន្យា

### ១.១. ហ៊ីប៉ូតែក

#### ១.១.១.សេចក្ដីផ្ដើមត្រួសៗ

សិទ្ធិប្រាតិភោគប្រត្យក្សដែលកំណត់ដោយការសន្យា រួមមានសិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែក ។ ដោយសារសិទ្ធិប្រាតិភោគប្រត្យក្ស គឺគ្រាន់តែផ្ដល់ការគ្រប់គ្រងលើតម្លៃសេដ្ឋកិច្ចនៃ វត្ថុ ទោះបីជាករណីហ៊ីប៉ូតែកតម្រូវឱ្យមានការចុះបញ្ជីការបង្កើតហ៊ីប៉ូតែកលើដីធ្លី ឬអាគារក៏ ដោយ ក៏មិនចាំបាច់ផ្ទេរការកាន់កាប់អាគារឬដីធ្លីនោះទៅឱ្យម្ចាស់បំណុលដែរ ហើយអ្នកខ្ចីប្រាក់ ពោលគឺកូនបំណុល នៅតែអាចប្រើប្រាស់ដីធ្លី ឬអាគារនោះដដែល (យោងតាមមាត្រា ៣៦៩) ។ នៅពេលដែលកូនបំណុលមិនអាចសងប្រាក់បាន ម្ចាស់បំណុលអនុវត្តហ៊ីប៉ូតែកដែលបានចុះបញ្ជី ពោលគឺអាចធ្វើការលក់ដោយបង្ខំនូវដីធ្លី ឬអាគារនោះតាមរយៈតុលាការ ហើយអាចទទួលបាន សំណងដោយមានអាទិភាពមុនម្ចាស់បំណុលដទៃទៀត ពីចំនួនទឹកប្រាក់ដែលលក់បាន ។ នៅក្នុង ការជួញដូរជាក់ស្ដែងនៅក្នុងសង្គម ហ៊ីប៉ូតែកគឺជាសិទ្ធិប្រាតិភោគប្រត្យក្សដ៏សំខាន់ជាទីបំផុត ។

## ១.១.២. ការចុះបញ្ជី និងតួនាទីរបស់ហ៊ីប៉ូតែក

ការចុះបញ្ជីហ៊ីប៉ូតែកសំរាប់ទុកបង្ហាញជាសាធារណៈ រឹតតែមានសារសំខាន់ទៅទៀត ពីព្រោះហ៊ីប៉ូតែក គឺជាសិទ្ធិប្រត្យក្សអរូបិយ (មិនអាចវាយតម្លៃពីលក្ខណៈខាងក្រៅបាន) ដែលគ្រប់គ្រងតែទៅលើតម្លៃនៃកម្មវត្ថុ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកខាងលើរួចមកហើយនោះ ។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីកំណត់យក ត្រឹមអចលនវត្ថុដែលមានប្រកាសជាសាធារណៈនៅក្នុងសៀវភៅបញ្ជី និងសិទ្ធិប្រត្យក្សលើអចលនវត្ថុមួយចំនួនតែប៉ុណ្ណោះ ដែលអាចធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបាន (មាត្រា ៣៦៩ ។ ក្រៅពីនេះ ច្បាប់ពិសេសមួយចំនួន មានកំណត់នូវ ប្រព័ន្ធចុះបញ្ជី ឬការចុះបញ្ជី ដើម្បីអាចយកអាគានិងគ្រឿងបរិក្ខាររោងចក្រ កប៉ាល់ និងមូលនិធិ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកក៏បានដែរ) ។

លើសពីនេះទៅទៀត ហ៊ីប៉ូតែកតាំងពីមុនមក គឺជាប្រព័ន្ធមួយដើម្បីធានាចំពោះសិទ្ធិលើបំណុលនីមួយៗ ។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនដែលយកលំនាំតាមក្រមរដ្ឋប្បវេណីប្រទេសបាំរាំង មាននិន្នាការខ្លាំងទៅរកការធានាបែបនេះ (ប៉ុន្តែ ប្រទេសមួយចំនួនដូចជាប្រទេសអាល្លឺម៉ង់ជាដើម មិនមែនគ្រាន់តែចាត់ទុកហ៊ីប៉ូតែកថាជាប្រព័ន្ធធានាសិទ្ធិលើបំណុលតែប៉ុណ្ណោះទេ ថែមទាំងបានអនុម័តច្បាប់ចាត់ទុកហ៊ីប៉ូតែក ថាជាកម្មវត្ថុនៃការធ្វើវិនិយោគទៀតផង ។ ប្រទេសទាំងនេះរំពឹងថា ហ៊ីប៉ូតែកនឹងទៅជាទ្រព្យដែលអាចដាក់លក់និងបង្វិលចុះឡើងនៅក្នុងទីផ្សារបាន) ។ ដោយសារមានការគ្រប់គ្រងលើតម្លៃនៃកម្មវត្ថុ របស់ហ៊ីប៉ូតែក

ដើម្បីធានាបំណុលនីមួយៗដូច្នេះហើយ ទើបជាធម្មតាមានលេចឡើងនូវទស្សនៈមួយស្តីពីការរៀបចំលំដាប់អាទិភាពនៃហ៊ីប៉ូតែក ។ ពោលគឺកូនបំណុលអាចនឹងបង្កើតហ៊ីប៉ូតែកច្រើន នៅក្នុងសិទ្ធិប្រាតិភោគប្រត្យក្សតែមួយ ហើយអាចចុះបញ្ជីហ៊ីប៉ូតែកទាំងនោះបាន ។ ឧទាហរណ៍ថា ជាដំបូងនៅពេលខ្ចីប្រាក់ចំនួន ៥០០០ ម៉ឺនយេន ពីម្ចាស់បំណុល B កូនបំណុល A បង្កើតហ៊ីប៉ូតែកលើដីធ្លី "ក" ដែល A កាន់កាប់ ហើយដែលអាចប៉ាន់ប្រមាណថាលក់បានចំនួនទឹកប្រាក់សរុប ១០០ លានយេន បន្ទាប់មកបានចុះបញ្ជីហ៊ីប៉ូតែកនេះ (ហ៊ីប៉ូតែកនេះហៅថា ហ៊ីប៉ូតែកទី១) ។ ក្រោយមក កូនបំណុល A ខ្ចីប្រាក់ចំនួន ៤០០០ ម៉ឺនយេន ពីម្ចាស់បំណុល C ហើយបានបង្កើត និងចុះបញ្ជីហ៊ីប៉ូតែកលើដីធ្លី "ក" ដូចគ្នាជា ប្រាតិភោគធានាសិទ្ធិលើបំណុលនេះ (ហៅថា ហ៊ីប៉ូតែកទី២) ។ មិនត្រឹមតែប៉ុណ្ណោះទេ កូនបំណុល A ខ្ចីប្រាក់ចំនួន ២០០០ ម៉ឺនយេនទៀតពីម្ចាស់បំណុល D ហើយក៏បានបង្កើត និងចុះបញ្ជីហ៊ីប៉ូតែកលើដីធ្លី "ក" ដូចគ្នាម្តងទៀត ជាប្រាតិភោគធានាសិទ្ធិលើបំណុលនេះ (ហៅថា ហ៊ីប៉ូតែកទី៣) ។ ក្នុងករណីដែលផុតកំណត់ពេលត្រូវសងហើយ ប៉ុន្តែកូនបំណុល A នៅតែមិនអាចសងបំណុលទៅម្ចាស់បំណុលណាមួយក្នុងចំណោមម្ចាស់បំណុលទាំង៣ B, C, D នោះ យើងសន្មុតថាម្ចាស់បំណុលបានបែរទៅរកការអនុវត្តន៍ហ៊ីប៉ូតែកតែម្តង (នៅក្នុងការអនុវត្តន៍ជាក់ស្តែង គឺមានបញ្ហាទាក់ទងនឹងការប្រាក់ផង ប៉ុន្តែការសិក្សានៅក្នុងផ្នែកនេះ មិនពិចារណាពីបញ្ហានេះទេ ។ សូមមើលកថាខ័ណ្ឌទីមួយ មាត្រា ៣៧៤) ។ ឧបមាថា នៅពេលអនុវត្តជាក់ស្តែង ដីធ្លី "ក"

លក់បានទឹកប្រាក់ចំនួន ១០០ លានយេន តាមរយៈការលក់ដោយបង្ខំ ។ ដោយសារ B មានអាទិភាពព្រោះខ្លួនស្ថិតនៅលំដាប់ទី១ B អាចទទួលបានដំបូងគេបង្អស់ នូវទឹកប្រាក់សំណងសរុបចំនួន ៥០០០ ម៉ឺនយេន ពីទឹកប្រាក់ ១០០ លានយេន ដែលបានពីការលក់នោះ ។ បន្ទាប់មកម្ចាស់បំណុល C អាចទទួលបានសំណងសរុបចំនួន ៤០០០ ម៉ឺនយេន ពីទឹកប្រាក់ដែលនៅសល់ចំនួន ៥០០០ ម៉ឺនយេន ។ ចុងក្រោយបង្អស់ ទោះបីជាម្ចាស់បំណុល D ដែលមានហ៊ីប៉ូតែកក្នុងលំដាប់ ទី៣ បានឱ្យខ្ចីប្រាក់ចំនួន ២០០០ ម៉ឺនយេនក៏ដោយក៏ម្ចាស់បំណុលនេះ អាចទទួលបានសំណងត្រឹមតែចំនួន ១០០០ ម៉ឺនយេនតែប៉ុណ្ណោះ ពីទឹកប្រាក់ដែលបានលក់ ដីធ្លី "ក" ដោយបង្ខំ និងដែលជាចំណែកនៅសល់បន្ទាប់ពី B និង C ទាំងពីរខាងលើបានទទួលសំណងរួចមក (ចំនួនទឹកប្រាក់ ១០០០ ម៉ឺនយេន ដែលនៅសល់ នឹងត្រូវបានបន្តទាមទារឱ្យសងដោយគ្មានអ្វីធានាទាំងអស់) ។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលមានហ៊ីប៉ូតែក២ជាដើម) បានទទួលប្រាក់សំណងដោយយោងទៅតាមកិច្ចសន្យា ហើយការចុះបញ្ជីហ៊ីប៉ូតែករបស់ម្ចាស់បំណុលនេះត្រូវបានលុបចោល នោះលំដាប់នៃសិទ្ធិហ៊ីប៉ូតែក របស់ម្ចាស់បំណុល D ដែលស្ថិតនៅក្នុងលំដាប់ទី៣ នឹងឡើងលំដាប់មួយកំរិតវិញ (នៅក្នុងឧទាហរណ៍ខាងលើ លំដាប់ទី៣នឹងក្លាយទៅជាលំដាប់ទី២ ហើយម្ចាស់បំណុល D ដោយអនុវត្តហ៊ីប៉ូតែកអាចទទួលបានសំណងសរុបចំនួន ២០០០ ម៉ឺនយេន បន្ទាប់ពីម្ចាស់ បំណុល B) ។ តាមពិតទៅប្រសិនបើដីធ្លី "ក" ត្រូវបានលក់ដោយបង្ខំ ហើយបានទទួលទឹកប្រាក់តែ ៥០០០ ម៉ឺនយេន

ដោយសារតម្លៃទីផ្សារនៃដីធ្លីនេះធ្លាក់ចុះ នោះមានតែម្ចាស់បំណុល B ទេ ដែលមានហ៊ីប៉ូតែកក្នុងលំដាប់ទី១ តែម្នាក់គត់ ដែលអាចទទួលសំណងចំនួន ៥០០០ ម៉ឺនយេន ហើយម្ចាស់បំណុលដែលមានលំដាប់ហ៊ីប៉ូតែកបន្ទាប់ មិនអាចទទួលសំណងបាន សូម្បីតែមួយសេន ។



## ១.១.៣. ទំនាក់ទំនងរវាងសិទ្ធិប្រើប្រាស់ និងហ៊ីប៉ូតែក

ដោយសារហ៊ីប៉ូតែកគ្រប់គ្រងតែលើតម្លៃនៃវត្ថុដែលជាកម្មវត្ថុហ៊ីប៉ូតែក ហើយបន្សល់ទុកឱ្យកម្មសិទ្ធិករនូវសិទ្ធិប្រើប្រាស់វត្ថុនោះ កម្មសិទ្ធិករ បន្ទាប់ពីបានបង្កើតហ៊ីប៉ូតែកហើយក៏ដោយ អាចអាស្រ័យផលដោយបង្កើតភតិសន្យា ពាក់ពន្ធ័នឹងអចលនវត្ថុនោះបាន ។ ដើម្បីការពារភតិកៈនៅក្នុងករណីនេះ ភតិសន្យារយៈពេលខ្លី (មិនហួសពីអំឡុងពេលដែលមានចែងក្នុងមាត្រា ៦០២ ។ ចំពោះដីធ្លីក្នុងអំឡុងពេលប្រាំឆ្នាំ ចំពោះអាគារក្នុងអំឡុងពេលបីឆ្នាំ) ត្រូវបានចែងកំណត់ទុកជាមុនថា អាចយកមកតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក ទោះបីជាបានចុះបញ្ជីរួចបន្ទាប់ពីបង្កើតហ៊ីប៉ូតែកហើយក៏ដោយ (មាត្រា ៣៩៥ ចាស់) ។ ប៉ុន្តែ នៅពេលថ្មីៗនេះ ករណីភតិសន្យារយៈពេលខ្លី ដែលត្រូវបានបង្កើតឡើង ក្នុងគោលបំណងដើម្បីបង្អាក់ការអនុវត្តន៍ហ៊ីប៉ូតែក មានការកើនឡើងច្រើន នាំឱ្យមាត្រានេះត្រូវបានធ្វើនិរាករណ៍ តាមរយៈវិសោធនកម្មនៃក្រមរដ្ឋប្បវេណីនៅក្នុងឆ្នាំ ២០០៣ ហើយបង្កើតឱ្យមានរយៈពេលអនុគ្រោះចំនួនប្រាំមួយខែដល់ភតិកៈ ដែលត្រូវបានបង្ខំឱ្យចាកចេញនិងប្រគល់អចលនវត្ថុ តាមរយៈការអនុវត្តន៍ហ៊ីប៉ូតែក (ការលក់ដោយបង្ខំ) (មាត្រា ៣៩៥ ថ្មី) ។

## ១.១.៤. ហ៊ីប៉ូតែក និងសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យ័ក្ស

ដោយហេតុថា ហ៊ីប៉ូតែក គឺជាប្រភេទមួយនៃសិទ្ធិប្រត្យ័ក្ស ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង ចំពោះការបំពាននានា ។ ប៉ុន្តែ ដោយសារហ៊ីប៉ូតែកគឺជាសិទ្ធិគ្រប់គ្រងតម្លៃ ការជជែកពិភាក្សាគ្នាបានកើតឡើងស្តីអំពីបញ្ហាថា តើការបំពានកើតមានឡើងនៅពេលណា ហើយនៅពេលណាដែលអាចបញ្ឈប់ការរារាំងចំពោះការបំពាននោះបាន ។ ទស្សនៈភាគច្រើនយល់ឃើញថា ការបញ្ឈប់ការរារាំង (ការទាមទារឱ្យធ្វើបដិទាន ឬការទាមទារឱ្យបញ្ឈប់ការរើចេញជាដើម) អាចធ្វើទៅបាន ប្រសិនបើតម្លៃនៃកម្មវត្ថុធ្លាក់ចុះរហូតដល់កំរិតមួយដែលមិនអាចធានារក្សាទុកហ៊ីប៉ូតែកបាន ដោយសារតែការបំផ្លាញផ្ទះ ឬអាគារ និងការកាប់ផ្តួលរំលំដោយគ្មានហេតុផលនូវព្រៃភ្នំជាដើម ដែលជាអចលនវត្ថុជាប់ហ៊ីប៉ូតែក ។

## ១.១.៥. ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

នៅក្នុងប្រភេទហ៊ីប៉ូតែក ក្រមរដ្ឋប្បវេណីក៏ទទួលស្គាល់ផងដែរ នូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។ ហ៊ីប៉ូតែកធម្មតា នឹងត្រូវបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលមានការកំណត់ជាក់លាក់ (ឧទាហរណ៍ថា សិទ្ធិលើបំណុលរបស់ A ចំពោះប្រាក់ខ្ចីរបស់ B ចំនួន ៥០០ ម៉ឺនយេន) ប៉ុន្តែ ការបង្កើត និងការលុបចោលហ៊ីប៉ូតែកចំពោះសិទ្ធិលើបំណុលនីមួយៗផ្សេងៗគ្នាគឺមានបញ្ហាលំបាក ប្រសិនបើ A និង B ធ្វើការជួញដូរជានិរន្តន៍ ។ អាស្រ័យហេតុនេះ

ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានបង្កើតឡើង ដើម្បីអាចធានាយ៉ាងទូលំទូលាយដល់សិទ្ធិលើបំណុលដែលគ្មានការកំណត់ជាក់លាក់ (ក្នុងចំនួនអតិបរមា ពោលគឺកំណត់រហូតដល់កំរិតខ្ពស់បំផុតនៃទំហំជួញដូរ ដើម្បីធានាសិទ្ធិលើបំណុល) ។ ដោយសារតែមានបញ្ហាផ្សេងៗកើតឡើងទាក់ទងនឹងចំនុចនេះ ក្រមរដ្ឋប្បវេណីបានបន្ថែមបញ្ញត្តិពិស្តារជាច្រើន ដើម្បីទុកដាក់បញ្ហាទាំងនេះឱ្យមានលក្ខណៈគ្រប់គ្រាន់ (មាត្រា ៣៩៨-២ រហូត ដល់មាត្រា ៣៩៨-២២) ។

## ១.១.៦. ទំហំនៃវត្ថុដែលជាកម្មវត្ថុជាប់ហ៊ីប៉ូតែក

មាត្រា ៣៧០ (ក្នុងបញ្ញត្តិចំបង) បានចែងថា ហ៊ីប៉ូតែកមានវិសាលភាពគ្របដណ្តប់ លើវត្ថុដែលក្លាយទៅជា ភាគមួយនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក (វត្ថុតាំងភ្ជាប់) ។ ពាក់ព័ន្ធនឹងវត្ថុតាំងភ្ជាប់នេះ មានទស្សនៈយល់ស្របគ្នាថា ហ៊ីប៉ូតែកមានវិសាលភាពគ្របដណ្តប់លើវត្ថុតាំងភ្ជាប់ (ឧទាហរណ៍ ដូចជារបងថ្ម ថ្មចិញ្ចើមថ្នល់ រុក្ខជាតិ និងកូនរុក្ខជាតិជាដើមដែលពាក់ព័ន្ធនឹងករណីដីធ្លី ។ សូមមើល មាត្រា ២៤២) ។ ប៉ុន្តែទស្សនៈខ្វែងគ្នាបានកើតឡើងទាក់ទងនឹងបញ្ហាថាតើត្រូវរួមបញ្ចូល ឬមិនត្រូវរួមបញ្ចូលនូវវត្ថុចំណុះនានាដែរឬទេ (ដូចជាប្រភេទថ្មដែលដាក់ស្ថិតនៅលើដីធ្លី ថ្មក្នុងសួនច្បារដែលអាចយកចេញបាន កន្ទេលតាតាមី បែបជប៉ុននិងគ្រឿងសង្ហារឹមជាដើមដែលដាក់បញ្ចូលទៅក្នុងអាគារ ។ ⇨ ពាក្យគន្លឹះ: វត្ថុចំបង វត្ថុចំណុះ វត្ថុដើម ផល ។ សូមមើលមាត្រា ៨៧) ។ ប៉ុន្តែផ្ទុយទៅវិញ

ផលធម្មជាតិគឺជាផលដែលបង្កើតជាភាគមួយរួមបញ្ចូលទៅក្នុងអចលនវត្ថុ ប៉ុន្តែដោយសារអ្នកបង្កើតហ៊ីប៉ូតែកមានសិទ្ធិកាន់កាប់ និងសិទ្ធិអាស្រ័យផលលើវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ អានុភាពនៃហ៊ីប៉ូតែក ជាគោលការណ៍ ពុំគ្របដណ្តប់លើផលធម្មជាតិនេះទេ (កថាខ័ណ្ឌទី១ នៃមាត្រា ៣៧១ បញ្ញត្តិចំបង ) ។

ម្យ៉ាងវិញទៀត ហ៊ីប៉ូតែកក៏មានវិសាលភាពគ្របដណ្តប់ផងដែរ លើសិទ្ធិដែលកើតឡើងបន្ទាប់បន្សំពីវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក (សិទ្ធិដែលមានជាបន្ទាប់បន្សំលើអចលនវត្ថុដែលជាប់ហ៊ីប៉ូតែក) ។ ឧទាហរណ៍ ក្នុងករណីបង្កើតហ៊ីប៉ូតែក លើអាគារដែលស្ថិតនៅលើដីជួល ហ៊ីប៉ូតែកមានវិសាលភាពគ្របដណ្តប់ សិទ្ធិជួលដីធ្លី ហើយអ្នកដែលដេញថ្លៃបានអាគារនេះ (អ្នកដែលបានទិញអាគារនេះតាមរយៈការលក់ដោយបង្ខំ) នឹងទទួលកាន់កាប់អាគារនេះ ព្រមជាមួយនឹងសិទ្ធិជួលដីធ្លីផង ប៉ុន្តែសូមមើល ផ្នែកទី៣.៣ ក្នុងជំពូកទី ៤ នៃសៀវភៅនេះ ស្តីពីទំនាក់ទំនងរបស់បញ្ហានេះទៅនឹងបញ្ហាសិទ្ធិជួលនៃក្រមរដ្ឋប្បវេណី និងបញ្ហានៃច្បាប់ស្តីពីការជួលដីធ្លី និងផ្ទះ) ។

### ១.១.៧. ឧបាទេសកម្មលើវត្ថុ

ឧទាហរណ៍ថា B បានទទួលហិរញ្ញប្បទានពី A ដោយ B បានបង្កើតហ៊ីប៉ូតែកលើផ្ទះ ឬអាគារ "ក" (ម្ចាស់បំណុល A ហៅថា ម្ចាស់បំណុលហ៊ីប៉ូតែក កូនបំណុល B ហៅថាអ្នកបង្កើត

ហ៊ីប៉ូតែក) ។ នៅក្នុងករណីដែលផ្ទះ ឬ អាគារ "ក" នេះត្រូវបានភ្លើងឆេះរលំអស់ នោះA នឹងបាត់បង់នូវប្រាតិភោគធានាទាំងស្រុង ។ ប៉ុន្តែ ប្រសិនបើ B មានប័ណ្ណធានារ៉ាប់រងអគ្គីភ័យចំពោះផ្ទះ ឬអាគារ "ក" នេះ ហើយក្នុងករណីអាចទាមទារសំណងខូចខាតពី ក្រុមហ៊ុនធានារ៉ាប់រងដែលធានារ៉ាប់រងលើផ្ទះ ឬអាគារនេះបាន អានុភាពនៃហ៊ីប៉ូតែក គួរតែអាចបន្តមានលើសិទ្ធិទាមទារប្រាក់ធានារ៉ាប់រងអគ្គីភ័យនេះទៀត (A អាចដកយកពីប្រាក់ធានារ៉ាប់រងអគ្គីភ័យនេះដើម្បីប្រមូលមកវិញ នូវប្រាក់ហិរញ្ញប្បទាន) ។ លក្ខណៈបែបនេះ គេហៅថា ឧបាទេសកម្ម លើវត្ថុដែលសំដៅលើលទ្ធភាពអាចពង្រីកបន្តអានុភាពនៃហ៊ីប៉ូតែកទៅលើ "ទឹកប្រាក់ ឬវត្ថុ ផ្សេងទៀត" ដែលអ្នកបង្កើតហ៊ីប៉ូតែក (នៅក្នុងករណីខាងលើសំដៅដល់ B) ត្រូវទទួលបាននៅក្នុងករណីមានការបាត់បង់ ឬការខូចខាងនៃកម្មវត្ថុប្រាតិភោគ (ឬក្នុងករណីកម្មវត្ថុនោះ ត្រូវបានលក់ ឬជួល) ។ ក្រៅអំពីករណីនៃហ៊ីប៉ូតែក ក្រមរដ្ឋប្បវេណីប្រទេសជប៉ុន ក៏ទទួលស្គាល់ឧបាទេសកម្មលើវត្ថុនេះផងដែរ ចំពោះករណីនៃឯកសិទ្ធិ និងសិទ្ធិលើការបញ្ចាំ (មាត្រា ៣៧២ និងមាត្រា ៣០៤) ដែលនឹងមានរៀបរាប់នៅខាងក្រោយ ។ សាលក្រមតុលាការក៏ទទួលស្គាល់ផងដែរនូវឧបាទេសកម្មលើវត្ថុចំពោះបំណុលលើថ្លៃឈ្នួល ។ ជាឧទាហរណ៍ ម្ចាស់បំណុលហ៊ីប៉ូតែកនៃអាគារ ដែលមានអ្នកជួលចូលមកនៅជាប្រចាំនោះ អាចអនុវត្តហ៊ីប៉ូតែកតាមរយៈការលក់អាគារដោយបង្ខំ ឬអាចប្រមូលបំណុលលើថ្លៃឈ្នួលបានតាមរយៈឧបាទេសកម្មលើវត្ថុ ដោយពុំចាំបាច់ធ្វើការលក់ដោយបង្ខំឡើយ ។

## ១.១.៨. សិទ្ធិប្រើប្រាស់ដីធ្លីដែលកំណត់ដោយច្បាប់

ឧទាហរណ៍ថានៅពេលទទួលហិរញ្ញប្បទានពី A ទោះជា B មានដីធ្លី និងអាគារនៅលើដីធ្លីដែលស្ថិតនៅក្នុងការកាន់កាប់របស់ខ្លួនក៏ដោយ B គ្រាន់តែបានបង្កើតហ៊ីប៉ូតែកលើអាគារតែប៉ុណ្ណោះ (ដូចដែលបានរៀបរាប់បង្ហាញនៅក្នុងផ្នែកខាងមុខរួចមកហើយ នៅក្នុងប្រទេស ជប៉ុន ដីធ្លី និងអាគារ ត្រូវបានសន្មត់ថា ជាអចលនវត្ថុដាច់ដោយឡែកពីគ្នា ។ សូមមើលផ្នែកទី I (១) នៃជំពូកទី ៣) ។ បន្ទាប់មក ឧបមាបន្តទៀតថា C ទិញបានអាគារនោះតាមរយៈការលក់ដោយបង្ខំដែលអនុវត្តហ៊ីប៉ូតែកនៅពេល B ពុំអាចសងបំណុលបាន (A នឹងដកយកប្រាក់កម្ចីពីក្នុងថ្លៃលក់នោះ) ។ តាមរយៈការធ្វើបែបនេះ ទោះបីជា C បានទទួលសិទ្ធិកាន់កាប់លើអាគារក៏ដោយ ក៏ C ក្លាយទៅជាមិនមានសិទ្ធិប្រើប្រាស់ដីធ្លីនោះ ។ ហេតុដូច្នេះ នៅក្នុងករណីដែលនៅពេលបង្កើតហ៊ីប៉ូតែក មានអាគារដែលស្ថិតនៅលើដីធ្លី ហើយដែលអាគារ និងដីធ្លីទាំងនោះ គឺជារបស់កម្មសិទ្ធិករតែម្នាក់ (នៅក្នុងឧទាហរណ៍ខាងលើ គឺ B) ហើយនៅពេលដែលការលក់ដោយបង្ខំនូវអាគារ ឬដីធ្លី ដែលបានយកមកធ្វើជា ហ៊ីប៉ូតែកនោះនឹងធ្វើឱ្យមានកម្មសិទ្ធិករពីរផ្សេងគ្នា ពោលគឺកម្មសិទ្ធិករនៃអាគារនិងកម្មសិទ្ធិករនៃដីធ្លីជាបុគ្គលខុសគ្នា (នៅក្នុងករណីខាងលើ C គឺជាកម្មសិទ្ធិករនៃអាគារ) តាមក្រម រដ្ឋប្បវេណី អ្នកបង្កើតហ៊ីប៉ូតែកដែលជាកម្មសិទ្ធិករនៃដីធ្លី ត្រូវបានកំណត់ថាបានបង្កើតសិទ្ធិប្រើ ប្រាស់ដីធ្លីនៅពេលលក់ដោយបង្ខំ សំរាប់ជាប្រយោជន៍ដល់កម្មសិទ្ធិករថ្មីនៃអាគារ (C) ។

មានការរៀបរាប់អំពីសិទ្ធិប្រើប្រាស់ដីធ្លី នៅផ្នែកខាងមុខនៃសៀវភៅនេះរួចមកហើយ (សូមមើលជំពូក ទី៣) ដើមឡើយសិទ្ធិប្រើប្រាស់ដីធ្លី កើតមានឡើងតាមរយៈកិច្ចសន្យាបង្កើតរវាង គូភាគី ក៏ប៉ុន្តែ នៅតាមស្ថានភាពជាក់លាក់មួយចំនួន សិទ្ធិប្រើប្រាស់ដីធ្លី ត្រូវបានកំណត់ផ្តល់ឱ្យដោយច្បាប់ ។ នេះគឺជាសិទ្ធិប្រើប្រាស់ដីធ្លីដែលកំណត់ដោយច្បាប់ (មាត្រា ៣៨៨) ។

## ១.២. សិទ្ធិលើការបញ្ចាំ

សិទ្ធិលើការបញ្ចាំ គឺនៅតែជាសិទ្ធិដែលគ្រប់គ្រងតែលើតម្លៃសេដ្ឋកិច្ចតែប៉ុណ្ណោះ ប៉ុន្តែខុសពីហ៊ីប៉ូតែកត្រង់ថា សិទ្ធិលើការបញ្ចាំតំរូវឱ្យប្រគល់វត្ថុដែលដាក់បញ្ចាំនោះ ទៅឱ្យម្ចាស់ បំណុល (ម្ចាស់បំណុលជាអ្នកកាន់កាប់វត្ថុនោះ) ។ សិទ្ធិលើការបញ្ចាំមិនតំរូវឱ្យផ្ទេរកម្មសិទ្ធិទេ ហើយម្ចាស់បំណុលកាន់កាប់វត្ថុរបស់កូនបំណុល ក្នុងលក្ខណៈជាការរក្សាទុកនូវវត្ថុនោះ ។ ប្រសិនបើកូនបំណុលមិនអាចសងប្រាក់ខ្ចីបានទេ នោះម្ចាស់បំណុលអាចប្រមូលបំណុលដោយមានអាទិភាព តាមរយៈការលក់ដោយបង្ខំនូវវត្ថុនោះជាដើម (យោងតាមមាត្រា ៣៤២) ។ សិទ្ធិលើការបញ្ចាំ អាចត្រូវបានបង្កើតឡើងដោយដាក់បញ្ចាំនូវចលនវត្ថុ អចលនវត្ថុ ឬសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀតដូចជាសិទ្ធិលើបំណុលផ្សេងៗជាដើមបានដូចគ្នា ។ ហើយថ្វីត្បិតតែបញ្ញត្តិស្តីពីសិទ្ធិលើការបញ្ចាំនេះ អាចយកមកអនុវត្តបានជាវិធីសមស្រប ចំពោះករណីចលនវត្ថុក្តី (ពីព្រោះ ប្រសិនជាទុកឱ្យកូនបំណុលអាចប្រើប្រាស់ចលនវត្ថុនោះ បានដោយគ្មានការអនុញ្ញាតិ

ទេនោះ នឹងមានបញ្ហាកើតឡើងកាលបើកូនបំណុលបែរជាលក់ហើយប្រគល់ចលនវត្ថុនោះ ទៅឱ្យតតិយជនណាផ្សេង) ក៏ក្នុងករណីនៃអចលនវត្ថុវិញ គឺគេច្រើនតែប្រើវិធីបង្កើតហ៊ីប៉ូតែក ដែលទុកឱ្យកូនបំណុលអាចបន្តមានសិទ្ធិប្រើប្រាស់អចលនវត្ថុនោះបាន (នាពេលថ្មីៗនេះ សូម្បីតែចំពោះចលនទ្រព្យក៏ដោយ ក៏មានការនិយមប្រើប្រាស់កាន់តែច្រើនផងដែរ នូវសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលនឹងមានរៀបរាប់នៅផ្នែកខាងក្រោយនៃជំពូកនេះ) ។

## ២. សិទ្ធិប្រាតិភោគប្រត្យក្សដែលច្បាប់បានកំណត់

### ២.១. សិទ្ធិឃាត់ទុក

ឧបមាថា A ជាអតិថិជនបានទៅពឹងពាក់ B ដែលជាជាងជួសជុលនាឡិកា សុំឱ្យ B ជួសជុលនាឡិការដៃរបស់ខ្លួន ក្នុងតម្លៃមួយម៉ឺនយេន ។ នៅពេលជួសជុលរួចហើយ ប្រសិនបើជាងនាឡិកា B ប្រគល់នាឡិកានោះទៅឱ្យ A វិញ ដោយពុំបានយកប្រាក់ថ្លៃឈ្នួលពី A ទេនោះ B នឹងក្លាយទៅជាមិនមានអ្វីទាល់តែសោះ សំរាប់ធានាដល់ការទាមទារថ្លៃឈ្នួល (មធ្យោបាយបង្ខំដោយប្រយោល) ។ ហេតុដូច្នេះ នៅក្នុងករណីបែបនេះ ក្រមរដ្ឋប្បវេណីបានចែងកំណត់វិធានមួយ ដែលអនុញ្ញាតឱ្យ B ឃាត់ទុកនាឡិកាដៃនោះ រហូតដល់ពេលដែលប្រាក់ឈ្នួលត្រូវបានបង់ចប់ (ដោយគ្មានទាក់ទងទៅនឹងឆន្ទៈរបស់គូភាគីទេ) ។ នេះគឺជាសិទ្ធិឃាត់ទុកដែលជា សិទ្ធិប្រាតិភោគប្រត្យក្សដែលច្បាប់បានកំណត់ ។ បើនិយាយតាមវាក្យស័ព្ទច្បាប់

សិទ្ធិឃាត់ទុក គឺមានន័យថា ជា"សិទ្ធិដែលអ្នកកាន់កាប់ (ជាងនាឡិកា B) វត្ថុ (នាឡិកាដៃ) របស់អ្នកដទៃ អាចធ្វើការឃាត់ទុកវត្ថុនោះបាន ប្រសិនបើអ្នកកាន់កាប់នោះមានសិទ្ធិលើបំណុល (សិទ្ធិលើបំណុលមួយម៉ឺនយេន ដែលជាថ្លៃឈ្នួលសំរាប់ការជួសជុលនាឡិកា) ដែលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ រហូតដល់ពេលដែលអ្នកកាន់កាប់វត្ថុបានទទួលការសងចំពោះសិទ្ធិលើបំណុលនោះ" (ប៉ុន្តែ សិទ្ធិឃាត់ទុកពុំមានអានុភាពនាំដល់ការទទួលសំណងពីចំនួនទឹកប្រាក់ដែលបានមកពី ការចាត់ចែងប្តូរជាប្រាក់ នូវកម្មវត្ថុដែលបានឃាត់ទុកនោះទេ (អានុភាពទទួលសំណងដោយមានអាទិភាព) ។ បន្ថែមពីនេះ ប្រសិនបើចង់ប្រៀបធៀបសិទ្ធិឃាត់ទុកនេះជាមួយនឹង សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ដែលបានរៀបរាប់បង្ហាញរួចហើយក្នុងជំពូកទី ៤ ខាងលើសូមមើលផ្នែកទី III-៣ (៣) នៃជំពូកទី ៤) ។

## ២.២. ឯកសិទ្ធិ

ឧបមាថា X ជាបុគ្គលិកបំរើការងារនៅក្នុងហាង Y មួយដែលជួបការលំបាកក្នុងការស្វែងរកហិរញ្ញប្បទាន ហើយ X ពុំបានទទួលប្រាក់បៀវត្សចំនួន ២០ ម៉ឺនយេន ដែល Y ត្រូវបង់ឱ្យខ្លួននោះទេ ។ ម្យ៉ាងវិញទៀត ឧបមាថា Z គឺជាអតិថិជនដែលមាន សិទ្ធិលើបំណុលប្រាក់ខ្ចី ដែល Y បានខ្ចីចំនួន ១៨០ ម៉ឺនយេន ហើយ Y ពុំបានសងបំណុលនេះទេ ទោះបីជាផុតរយៈពេលកំណត់ត្រូវសងក៏ដោយ ហេតុដូច្នេះ គេត្រូវអនុវត្តដោយបង្ខំ (មានន័យថាលក់ដោយបង្ខំនូវទ្រព្យសម្បត្តិនេះ ដើម្បីប្តូរទៅជាទឹកប្រាក់សំរាប់សងបំណុល) ចំពោះទ្រព្យសម្បត្តិរបស់ Y (ដែល

មានតម្លៃត្រឹមតែ ១០០ ម៉ឺនប៉ុណ្ណោះ) ។ នៅក្នុងករណីនេះ ប្រសិនបើ X ទាមទារចំណែករបស់ខ្លួនដែរនោះ Z និង X ត្រូវចែករំលែកគ្នានូវទ្រព្យសម្បត្តិរបស់ Y ។ ប៉ុន្តែដោយហេតុថាសិទ្ធិលើបំណុលសរុបរបស់ X និង Z ត្រូវមានសមាមាត្រជា ១ភាគ៩ នោះបើយោងតាមគោលការណ៍សមភាពនៃម្ចាស់បំណុល ដែលមានចែងក្នុងច្បាប់ស្តីពីការអនុវត្តន៍សាលក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន នោះទឹកប្រាក់សរុបចំនួន ១០០ ម៉ឺនយេនរបស់ Y ត្រូវចែករំលែកឱ្យទៅ X ចំនួន ១០ ម៉ឺនយេន និងឱ្យទៅ Z ចំនួន ៩០ ម៉ឺនយេន ។ ប៉ុន្តែបើយោងទៅតាមទស្សនៈគោលនយោបាយសង្គម ទឹកប្រាក់សរុបទាំងអស់ គួរតែធានាដល់ជីវភាពរស់នៅរបស់ X ពីព្រោះសិទ្ធិលើបំណុលប្រាក់បៀវត្ស គឺជាសិទ្ធិលើបំណុល ដែលមានតម្លៃសំរាប់ជីវភាពរស់នៅរបស់ X ។ ហេតុដូច្នេះហើយបានជាក្រមរដ្ឋប្បវេណីកំណត់ថា ជា "សិទ្ធិប្រាតិភោគប្រត្យក្សដែលច្បាប់បានកំណត់ ដែលតាមរយៈនោះអ្នកមានសិទ្ធិលើបំណុលកំណត់ជាក់លាក់ណាមួយ (សំដៅលើ X ក្នុងករណីខាងលើ) អាចទទួលបានការសង ពីទ្រព្យរបស់កូនបំណុល (Y) ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត (Z) (បើនិយាយពីឧទាហរណ៍ខាងលើ គឺអាចទទួលបានសំណង ដោយមានអាទិភាពក្នុងចំនួនទឹកប្រាក់សរុបទាំងអស់ ២០ ម៉ឺនយេន)" ។ សិទ្ធិបែបនេះគេហៅថា ឯកសិទ្ធិ ។ ក្រមរដ្ឋប្បវេណីមានចែងពីឯកសិទ្ធិនេះចាប់ពីមាត្រា ៣០៦ តទៅ ហើយបែងចែកឯកសិទ្ធិជាបីប្រភេទ: គឺឯកសិទ្ធិទូទៅដែលមានអានុភាពលើទ្រព្យទាំងអស់របស់កូនបំណុល ឯកសិទ្ធិលើចលនវត្ថុដែលមានអានុភាពលើ

ចលនវត្ថុជាក់លាក់របស់កូនបំណុល និងឯកសិទ្ធិលើអចលនវត្ថុដែលមានអានុភាពលើអចលនវត្ថុជាក់លាក់របស់កូនបំណុល ។ ប៉ុន្តែ ក្រោយពេលដែលកូនបំណុលបានប្រគល់ចលនវត្ថុរបស់ខ្លួន ដែលជាកម្មវត្ថុនៃ ឯកសិទ្ធិ ទៅឱ្យតតិយជនដែលបានធ្វើលទ្ធកម្មហើយ នោះឯកសិទ្ធិមិនថាជាឯកសិទ្ធិទូទៅ ឬ ឯកសិទ្ធិលើចលនវត្ថុ មិនអាចអនុវត្តលើចលនវត្ថុនោះបានតទៅទៀតឡើយ (ពោលគឺពុំមានអានុភាពតាម សូមមើលមាត្រា ៣៣៣) ។

## ៣. ប្រាតិភោគវិសាមញ្ញ

សិទ្ធិប្រាតិភោគប្រត្យក្សទាំង ៤ ប្រភេទ ដែលបានរៀបរាប់ខាងលើ ហើយដែលមានចែងក្នុងក្រមរដ្ឋប្បវេណី គឺជាប្រាតិភោគសាមញ្ញ ។ ក្រមរដ្ឋប្បវេណីពុំមានបទប្បញ្ញត្តិចែងប្រាតិភោគផ្សេងៗទៀត ក្រៅពីប្រាតិភោគសាមញ្ញទាំងនេះឡើយ ប៉ុន្តែនៅពេលដែលមិនអាចសងបំណុលបាន គំនិតផ្សេងៗជាច្រើនបានលេចឡើងទាក់ទងនឹងទំរង់ផ្សេងៗនៃប្រាតិភោគដែលផ្ទេរសំណងបំណុលនេះ តាមរយៈការដាក់វត្ថុដែលជាកម្មវត្ថុផ្ទាល់នៃប្រាតិភោគ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម្ចាស់បំណុល (ឧទាហរណ៍ថា គោលបំណងគឺចង់ធ្វើការធានា ប៉ុន្តែកំណត់ទុកជាមុនថា ការធានានេះ គឺធ្វើក្នុងទំរង់មួយដែលត្រូវប្រគល់កម្មវត្ថុនៃប្រាតិភោគសំរាប់មួយរយៈសិន ហើយនៅពេលដែលពុំអាចសងបំណុលបានទេនោះ គេក៏ប្រគល់សិទ្ធិលើកម្មវត្ថុនោះទៅឱ្យម្ចាស់បំណុលតែម្តងទៅ) ។ មធ្យោបាយរបៀបនេះ ត្រូវបានទទួលស្គាល់ដោយ

ករណីយុត្តិសាស្ត្ររបស់ តុលាការ ឬ វិធានទំនៀមទំលាប់ ។ ប្រាតិភោគបែបនេះ គេហៅថា ប្រាតិភោគវិសាមញ្ញ ។ ប្រាតិភោគវិសមញ្ញនេះរួមមាន សិទ្ធិប្រាតិភោគសំរាប់ចុះបញ្ជីបណ្តោះអាសន្ន សិទ្ធិប្រាតិភោគដោយអនុប្បទាន និងសិទ្ធិរក្សាទុកកម្មសិទ្ធិ (ដោយហេតុថា ប្រាតិភោគវិសាមញ្ញទាំងនេះពុំមែន ជាប្រភេទថ្មីនៃសិទ្ធិប្រត្យក្សដែលត្រូវបានបង្កបង្កើតឡើងជាថ្មីទេនោះ ប្រាតិភោគវិសាមញ្ញទាំងនេះពុំមានលក្ខណៈអ្វីផ្ទុយនឹង គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់ឡើយ ។ ក្នុងចំនោមប្រាតិភោគវិសាមញ្ញទាំងនេះ ប្រាតិភោគសំរាប់ចុះបញ្ជីបណ្តោះអាសន្ន ត្រូវបានបញ្ញត្តិដោយច្បាប់ពិសេសមួយ) ។ ជាពិសេស សិទ្ធិប្រាតិភោគដោយអនុប្បទាន បានក្លាយទៅជាមានសារៈសំខាន់សំរាប់ក្រុមហ៊ុនជួញដូរសព្វថ្ងៃ ។

### ៣.១. ប្រាតិភោគសំរាប់ចុះបញ្ជីបណ្តោះអាសន្ន

ឧបមាថា B ខ្ចីប្រាក់ពី A ហើយមិនអាចសងបំណុលបាន ទៅតាមរយៈពេលកំណត់ត្រូវសងនោះ B ឬតតិយជន (អ្នកធានាដោយវត្ថុ) ធ្វើកិច្ចសន្យាប្តូរការអនុវត្តន៍ដើម ដោយប្រគល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យ A ។ ប្រភេទជួញដូរដោយមានប្រាតិភោគដែលរក្សាទុកនូវសិទ្ធិរំពឹងទុកថានឹងមានការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិដោយចុះបញ្ជីជាបណ្តោះអាសន្នបែបនេះ គេហៅថា "សិទ្ធិប្រាតិភោគសំរាប់ចុះបញ្ជីបណ្តោះអាសន្ន" ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង នេះគឺជាវិធីនៃការចុះ"កិច្ចសន្យាសងបំណុលដោយយកវត្ថុជំនួស" ឬ "កិច្ចសន្យាសងបំណុលដោយយកវត្ថុជំនួស និងដោយមានល័ក្ខខ័ណ្ឌបង្អង់" ដែលមានការចែងថា

"វត្ថុនេះនឹងត្រូវយកសងជំនួស នៅពេលដែលពុំអាចសងបំណុលបាន" ឬការចុះ"កិច្ចសន្យាលក់"ផ្សេងៗទៀត ដែលចែងថា "វត្ថុនេះនឹងយកទៅលក់ នៅពេលដែលពុំអាចសងបំណុលបាន" បន្ទាប់មក គេធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិជាបណ្តោះអាសន្នទុកជាមុនសិន (ដោយហេតុថា ការចុះបញ្ជីបណ្តោះអាសន្ន នឹងត្រូយកមកធ្វើជាការចុះបញ្ជីជាស្ថាពរ នៅពេលដែលពិតជាមិនអាចសងបំណុលបានទេនោះ ដូច្នេះការចុះបញ្ជីបណ្តោះអាសន្ននេះមានអានុភាពអាចរក្សាទុកលំដាប់ជាអាទិភាពបាន ទោះបីជាក្នុងអំឡុងពេលនោះ មានអ្នកដ៏ទៃទៀតធ្វើការផ្ទេរបញ្ជីហើយក៏ដោយ) (តាមការពិត ទោះបីជាគ្មានចុះបញ្ជីបណ្តោះអាសន្នក៏ដោយ ក៏កិច្ចសន្យាមានសុពលភាពដែរ) ។ វិធីបែបនេះ ត្រូវបានគេអនុវត្តកាន់តែទូលាយឡើង ដោយសារមានចំណាប់អារម្មណ៍ចំពោះលទ្ធភាពដែលអាចធ្វើលទ្ធកម្មវត្ថុ ដែលមានតម្លៃទឹកប្រាក់ច្រើនជាងទឹកប្រាក់ដែលបានខ្ចី (ឧទាហរណ៍ ដូចជាចំពោះការខ្ចីប្រាក់ ចំនួន ១០០ ម៉ឺនយេន គេធ្វើកិច្ចសន្យាសងបំណុលដោយយកវត្ថុជំនួស ដែលវត្ថុនោះមានតម្លៃ ២០០ ម៉ឺនយេន) ហើយនៅក្នុងឆ្នាំ ១៩៨៧ ច្បាប់ពិសេសដែលគេហៅថា ច្បាប់ស្តីពីសិទ្ធិប្រាតិភោគសំរាប់ចុះបញ្ជីបណ្តោះអាសន្នត្រូវបានអនុម័តឡើង ដើម្បីជៀសវាងកុំឱ្យអ្នកផ្តល់ហិរញ្ញប្បទាន ឬអ្នកឱ្យខ្ចីកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីមធ្យោបាយនេះ ដោយចែងបទប្បញ្ញត្តិតំរូវឱ្យមានករណីយកិច្ចបង់ទឹកប្រាក់ដែលលើស (ប្រាក់ជំរះ) ដោយសារចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ខុសពីតម្លៃនៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ។

## ៣.២. ប្រាតិភោគដោយអនុប្បទាន

ប្រាតិភោគដោយអនុប្បទានសំដៅលើទំរង់ជួញដូរមួយ ដែលក្នុងនោះ B បានធ្វើ អនុប្បទានតាមលក្ខណៈផ្លូវការ នូវទ្រព្យរបស់ខ្លួនទៅឱ្យ A នៅពេលដែល A ឱ្យប្រាក់ខ្ចីទៅ B ហើយក្នុងករណីដល់ពេលកំណត់ត្រូវសង បើ B អាចសងបំណុលបាន A ត្រូវប្រគល់ទ្រព្យនោះជូនទៅ B វិញ ប៉ុន្តែប្រសិនបើ B មិនអាចសងបំណុលបានទេ A នឹងធ្វើលទ្ធកម្មនូវទ្រព្យនោះតែម្តង ។ ទាក់ទងនឹងប្រាតិភោគដោយអនុប្បទាននេះដែរ ការលពីមុនបញ្ហាធំបំផុតគឺជាបញ្ហានីត្យានុកូលភាព ឬភាពសមស្របតាមច្បាប់ ពីព្រោះប្រាតិភោគដោយអនុប្បទានមានទំរង់ (ជាការលក់ទិញ) ធំហួសហេតុ លើសពីសារធាតុពិត (នៃការខ្ចីនិងការ ឱ្យខ្ចី) ទៅទៀត នោះ ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ករណីយុត្តិសាស្ត្របានទទួលស្គាល់ថា អំពើបែបនេះពុំមែនជាអំពើគេចវេសពីច្បាប់ឡើយ ។ ប៉ុន្តែ ដោយសារនៅក្នុងការធ្វើអាជីវកម្មជាក់ស្តែង ប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើងជាញឹកញាប់ ហើយក្នុងករណីជាច្រើន អ្នកឱ្យខ្ចីទទួលយកបាននូវផលចំណេញយ៉ាងលើសលុប ដូច្នេះសាលក្រមតុលាការក៏បានតម្រូវឱ្យអ្នកទិញ (អ្នកឱ្យខ្ចី) មានករណីយកិច្ចបង់ជំរះ ដូចគ្នានឹងករណីនៃប្រាតិភោគសំរាប់ចុះបញ្ជីបណ្តោះអាសន្នដែរ ។ ម្យ៉ាងវិញទៀត សូម្បីតែអីឡូវនេះ ក៏មានការជជែកពិភាក្សាគ្នាជាច្រើនដែរពាក់ព័ន្ធនឹងទ្រឹស្តីនានា ថាតើប្រាតិភោគដោយអនុប្បទានត្រូវបានរៀបចំឡើងជាការផ្ទេរកម្មសិទ្ធិ (ដោយទទួលស្គាល់អ្នកឱ្យខ្ចីថា ជាកម្មសិទ្ធិករ ។ ពោលគឺជា ការរៀបចំតាមបែបកម្មសិទ្ធិ) ឬមួយ

ត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាការបង្កើតនូវសិទ្ធិប្រាតិភោគនោះ (ដោយទទួលស្គាល់ថា អ្នកឱ្យខ្ចីបានទទួលតែសិទ្ធិប្រាតិភោគតែប៉ុណ្ណោះ ។ ពោលគឺជា ការរៀបចំបង្កើតជាសិទ្ធិប្រាតិភោគ) ។ គេយល់ឃើញថា ករណីយុត្តិសាស្ត្រ បានរក្សាទុកជាមូលដ្ឋានថា នេះជាការរៀបចំតាមបែបកម្មសិទ្ធិ ហើយធ្វើការកែតំរូវបន្ថែមដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃប្រាតិភោគ ប្រសិនបើ ចាំបាច់ ។ ពាក់ព័ន្ធទៅនឹងចំនុចនេះដែរ ប្រាតិភោគដោយអនុប្បទានបានក្លាយទៅជាវិធី វៃអង្គាសប្រាក់ដែលត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ដែលមានជាសិទ្ធិលើបំណុលជាដើម ដោយពុំកំណត់ត្រឹមចលនវត្ថុ និងអចលនវត្ថុឡើយ (ចំពោះករណីសិទ្ធិលើបំណុល និងចលនវត្ថុ គេច្រើនតែប្រមូលវត្ថុជាច្រើនគ្នា ដើម្បីរៀបចំធ្វើការធានា ក្នុងទំរង់ជា ប្រាតិភោគដោយអនុប្បទានលើចលនវត្ថុផ្តុំគ្នា និង អនុប្បទានសិទ្ធិលើបំណុលផ្តុំគ្នា ។ នៅក្នុងករណីនេះ ចំពោះចលនវត្ថុ នាពេលកន្លងមក ធ្លាប់មានតែវិធីយកតាមល័ក្ខខ័ណ្ឌតតាំងដែលមិនអាចយល់ច្បាស់បានពីខាងក្រៅ តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ចលនវត្ថុ ទេនោះ (សូមមើល ផ្នែកទី II-២ (៥) ៣ នៃជំពូកទី៣) ក៏ការធ្វើវិសោធនកម្មនៅក្នុងឆ្នាំ ២០០៤ លើច្បាប់ស្តីពីករណីពិសេសនៃការធ្វើអនុប្បទានសិទ្ធិលើបំណុល បានបង្កើតនូវប្រព័ន្ធចុះបញ្ជីការធ្វើអនុប្បទានចលនវត្ថុ ដែលដូចគ្នានឹងការចុះបញ្ជីការធ្វើអនុប្បទានសិទ្ធិលើបំណុលដែរ (សូមមើលផ្នែកទី ៥ (៤) ជំពូកទី ៦) ។ ហេតុដូច្នេះ វិធីប្រកាសជាសាធារណៈឱ្យបានច្បាស់លាស់ក៏ត្រូវបានប្រើផងដែរចំពោះចលនវត្ថុ ។ ប៉ុន្តែ ជាពិតប្រាកដណាស់ដោយហេតុថា

ការចុះបញ្ជីគឺជាល័ក្ខខ័ណ្ឌតតាំង ដែលមានតម្លៃស្មើនឹងការប្តូរលក្ខណៈនៃការកាន់កាប់ និងការប្រគល់វត្ថុជាដើម ដូច្នេះប្រសិនបើមានអ្នកណាម្នាក់ប្តូរលក្ខណៈនៃការកាន់កាប់បានមុនគេ អ្នកនោះនឹងមានអាទិភាពមុនគេ ។ ម្យ៉ាងវិញទៀត តាមរយៈវិសោធនកម្មនេះ ច្បាប់ថ្មីត្រូវបានប្តូរឈ្មោះទៅជា ច្បាប់ស្តីពីករណីពិសេសនៃការធ្វើអនុប្បទានសិទ្ធិលើបំណុលនៃចលនវត្ថុ)។

### ៣.៣. ការរក្សាទុកកម្មសិទ្ធិ

ឧបមាថា អ្នកលក់បណ្តាក់ A (សំដៅលើការលក់ ក្នុងទំរង់មួយដោយបង់ប្រាក់ជា ចំណែកៗ ដូចជាការបង់បណ្តាក់ប្រចាំខែជាដើម) លក់ទំនិញឱ្យទៅ B ដោយប្រគល់ទំនិញភ្លាមៗ ប៉ុន្តែ ឧទាហរណ៍ថា តម្លៃទំនិញ នឹងត្រូវបានបង់គ្រប់ចំនួនមួយឆ្នាំក្រោយ ។ ការសន្យាបែបនេះតែងកើតឡើងជាញឹកញាប់ ដោយ A នៅរក្សាទុកនូវកម្មសិទ្ធិលើទំនិញរបស់ខ្លួនរហូតដល់ ពេល B សងតម្លៃទំនិញគ្រប់ចំនួន (នៅក្នុងរយៈពេលមួយឆ្នាំនេះ ទោះបីជា B ប្រើប្រាស់ទំនិញនេះក៏ដោយ ក៏ B មិនអាចក្លាយជាកម្មសិទ្ធិករនៃទំនិញនេះដែរ) ។ នេះគឺជារបៀបការងារមួយដែលអាចធានាបានថា តាមរយៈនៃការរក្សាទុកនូវកម្មសិទ្ធិរបស់ A យ៉ាងនេះ B នឹងត្រូវបង់តម្លៃទំនិញដែលនៅសល់ ។ នេះក៏ជាប្រភេទកិច្ចសន្យាដែលមានសុពលភាព ហើយត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយ ។ ក្រមរដ្ឋប្បវេណីមានចែងពីឯកសិទ្ធិលើចលនវត្ថុ ដែលជាមធ្យោបាយមួយសំរាប់ធានាសិទ្ធិលើបំណុលតម្លៃទំនិញ របស់អ្នកលក់ចលនវត្ថុ ដែលបានប្រគល់ទំនិញជូនជាមុន ដូចមានរៀបរាប់ខាងលើ (កថាខ័ណ្ឌទី ៦ នៃមាត្រា ៣១១) ។ ប៉ុន្តែ ជាទូទៅ

ចំពោះករណីខាងលើ គឺតែងតែមានចុះកិច្ចសន្យាពិសេសទុកជាមុនដែលកម្មសិទ្ធិមិនត្រូវបានផ្ទេរឡើយរហូតដល់ពេលបង់តម្លៃទំនិញអស់ ហើយប្រសិនបើមិនអាចបង់តម្លៃទំនិញបានទេ អ្នកលក់ច្រើនតែលុបកិច្ចសន្យាចោល ហើយយកទំនិញជាកម្មវត្ថុនោះមកវិញ ដោយផ្អែកលើកម្មសិទ្ធិដែលមាន ។ វិធីបែបនេះគេហៅថា "ការរក្សាទុកនូវកម្មសិទ្ធិ" ។ វិធីបែបនេះគឺស្រដៀងគ្នានឹងសិទ្ធិប្រាតិភោគដោយអនុប្បទានដែរ ប៉ុន្តែ ខុសគ្នាត្រង់ថា គោលបំណងគឺពុំមែនជាការខ្ចីប្រាក់ឡើយ ហើយអ្នកទុញមានឆន្ទះធ្វើលទ្ធកម្មនូវវត្ថុ ដែលជាកម្មវត្ថុពាក់ព័ន្ធ ។ នៅមានទ្រឹស្តីផ្សេងៗខ្វែងគំនិតគ្នានៅឡើយ ប៉ុន្តែករណីយុត្តិសាស្ត្រកំណត់លើកតំកើងការរៀបចំតាមបែបកម្មសិទ្ធិ (ពោលគឺទទួលស្គាល់អ្នកលក់ថាជាអ្នកដែលមានតួនាទីជា កម្មសិទ្ធិករនៃទំនិញនោះ) ជាបញ្ញត្តិទំនាក់ទំនងគតិយុត្តិជាមួយភាគីខាងក្រៅ (នៅក្នុងករណីដែលមានវិវាទកើតឡើង ដោយសារអ្នកលក់បានលក់ទំនិញឱ្យទៅតតិយជន) ។

# ជំពូកទី ៨
# ច្បាប់ស្តីពីញាតិ

I. អត្ថន័យ និងមុខងារនៃច្បាប់គ្រួសារ

II. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីញាតិ

១. ខ្លឹមសារស្តីពីច្បាប់ស្តីពីញាតិ

២. ទស្សនៈទូទៅស្តីពីញាតិ

III. ការសិក្សាអំពីចំណុចសំខាន់ៗរបស់ច្បាប់ស្តីពីញាតិ

១. អាពាហ៍ពិពាហ៍

២. ការលែងលះគ្នា

៣. ទំនាក់ទំនងរវាងឪពុកម្តាយ កូនបង្កើត និងកូនចិញ្ចឹម

៤. អំណាចមេបា អំណាចអាណាព្យាបាលៈ ហិតូបត្ថម្ភ និងអ្នកជំនួយ

# I. អត្ថន័យ និងមុខងារនៃច្បាប់គ្រួសារ

ការសិក្សារួចមកហើយទៅលើបទបញ្ញត្តិទូទៅ ច្បាប់ស្តីពីសិទ្ធិប្រត្យក្សនិងសិទ្ធិលើបំណុលដែល មានរៀបរាប់រហូតមកទល់ជំពូកមុននេះ ត្រូវបានគេចាត់ចូលទៅផ្នែក ច្បាប់ស្តីពីទ្រព្យសម្បត្តិនៃនីតិរដ្ឋប្បវេណី ។ ផ្ទុយទៅវិញ ចំណែកច្បាប់ស្តីពីញាតិ (គន្ថីទី ៤ ស្តីពីញាតិនៃនីតិរដ្ឋប្បវេណី) និងច្បាប់ ស្តីពីសន្តតិកម្ម (គន្ថីទី៥ ស្តីពីសន្តតិកម្មនៃនីតិរដ្ឋប្បវេណី) ត្រូវបានគេចាត់ចូលជាវិស័យច្បាប់គ្រួសារ (ពីមុនគេធ្លាប់ហៅថា ជាច្បាប់ស្តីពីឋានៈបុគ្គល) ។ ច្បាប់គ្រួសារគឺជាវិស័យច្បាប់ដែលមានសារៈសខាន់ណាស់ នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ហើយសព្វថ្ងៃនេះ នៅក្នុងឱកាសនៃការប្រឡងផ្សេងៗ មិនសូវមានសំណួរច្រើនដែលសួរអំពីវិស័យច្បាប់គ្រួសារទេ បើប្រៀបធៀបទៅនឹងវិស័យច្បាប់ស្តីពីទ្រព្យសម្បត្តិ ។ ប៉ុន្តែក្នុងច្បាប់ស្តីពីសន្តតិកម្ម មានចំណុចជាច្រើនដែលមានខ្លឹមសារពាក់ព័ន្ធនឹង ច្បាប់ស្តីពីទ្រព្យសម្បត្តិ ។ ក្នុងមួយផ្នែកនៃច្បាប់ស្តីពីញាតិ ក៏មានចំណុចដែលមានការភ្ជាប់ទៅនឹងបញ្ហានៃ ច្បាប់ទ្រព្យសម្បត្តិ ។ ម្យ៉ាងទៀត ការយល់ដឹងអំពីច្បាប់នេះ ក៏ជាទិដ្ឋភាពសំខាន់មួយដែរ ក្នុងការប្រមូលចំណេះទុកជាមុន សំរាប់សឹក្សាច្បាប់ស្តីពីពន្ធលើសន្តតិកម្ម ។ ល ។ បន្ទាប់តទៅនេះ ដោយយកចិត្តទុក ដាក់ចំពោះចំណុចទាំងអស់ខាងលើ យើងនឹងសាកល្បងរៀបរាបឱ្យបានយ៉ាង

ងាយយល់អំពីចំណែកនៃ ច្បាប់ស្តីពីគ្រួសារ ដោយផ្តោតសំខាន់ជាពិសេសមកលើចំណុចដែល ទាក់ទងនឹងច្បាប់ស្តីពីទ្រព្យសម្បត្តិ ។

## II. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីញាតិ

### ១. ខ្លឹមសារស្តីពីច្បាប់ស្តីពីញាតិ

គន្ថីស្តីពីញាតិនៅក្នុងក្រមរដ្ឋប្បវេណី ចាប់ផ្តើមពីបទបញ្ញត្តិទូទៅដែលកំណត់អំពីទស្សនៈទូទៅ ស្តីពីញាតិ ដូចមានរៀបរាប់នៅក្នុងផ្នែកខាងក្រោមនេះ ។ រួចជំពូកទី ២ ស្តីពីអាពាហ៍ពិពាហ៍ មានចែងអំពីការរៀប អាពាហ៍ពិពាហ៍ មោឃភាពនិងការលុបចោលអាពាហ៍ពិពាហ៍ អានុភាពនៃអាពាហ៍ពិពាហ៍ ហើយថែមទាំងមានចែងអំពីប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ និងការលែងលះគ្នា ។ ជំពូកទី ៣ អំពីឪពុកម្តាយ និងកូន មានចែងជាបញ្ញត្តិស្តីពីកូនបង្កើតនិងកូនចិញ្ចឹម ។ បន្ទាប់មកទៀត ជំពូកទី ៤ ចែងអំពីញាតិ ជំពូកទី ៥ ចែងអំពីអាណាព្យាបាល និងជំពូកទី ៦ ចែងអំពីអាហារកាតព្វកិច្ច ។ ក្នុងចំណោមជំពូកទាំងនេះ វិសោធនកម្មដែលចូលជាធរមាននាខែមេសា ឆ្នាំ ២០០០ បានកែប្រែ និង បញ្ចូលបញ្ញត្តិបន្ថែមទៅក្នុង ជំពូកទី ៥ ។ នេះនឹងមានរៀបរាប់នៅខាងក្រោម ។

## ២. ទស្សនៈទូទៅស្តីពីញាតិ

### ២.១. ញាតិ និងថ្នាក់ញាតិ

ក្រមរដ្ឋប្បវេណី ចាត់ទុកថាជា"ញាតិ" ចំពោះបីករណី ។ ទីមួយ គឺញាតិលោហិតក្នុង ៦ ថ្នាក់ ។ ទីពីរ គឺសហព័ទ្ធ ។ ទីបី គឺញាតិពន្ធក្នុងបីថ្នាក់ (មាត្រា ៧២៥) ។ ការកំណត់ទំហំរបស់ញាតិបែបនេះ មិនសូវមានអត្ថន័យប៉ុន្មានទេនាពេលបច្ចុប្បន្ន ។ ប៉ុន្តែជាបឋមយើងគួរស្វែងយល់អំពីរបៀបគណនាថ្នាក់ញាតិ ក្នុងលក្ខណៈជាចំណេះដឹងទូទៅ ។ ថ្នាក់ញាតិ ត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាង ញាតិ (មាត្រា ៧២៦ កថាខ័ណ្ឌទី ១) ។ ដូច្នេះ ឪពុកនិងកូនខ្លួនឯងគឺជាញាតិនៅក្នុង ១ ថ្នាក់ ។ ជីតានិង ចៅ ត្រូវជាញាតិនៅក្នុង ២ ថ្នាក់ ។ ប្រសិនជាញាតិផ្ទាល់ដែលមានដូចជាករណីនៃឪពុកនិងកូន ឬជីតា និងចៅនេះ (ត្រូវជាទំនាក់ទំនងខ្សែរទទឹងនៅក្នុងតារាងពង្សាវលី) គឺជាការងាយស្រួលទេ ។ ប៉ុន្តែ ចំពោះ ករណីនៃសាខាញាតិដូចជាបងប្អូនបង្កើតឬបងប្អូនជីដូនមួយជាដើម (មានទំនាក់ទំនងតាមខ្សែបណ្តោយ នៅក្នុងតារាងពង្សាវលី) គេត្រូវគណនាចំនួនតំណពូជដោយគិតចាប់ពីជនម្នាក់ ឡើងទៅដល់បុព្វជន ដូចគ្នាជាមួយជនម្នាក់ទៀត រួចគិតចាប់ពីបុព្វជននោះចុះរហូតមកដល់ជនម្នាក់ទៀតនោះ (មាត្រា ៧២៦ កថាខ័ណ្ឌទី ២) ។ ហេតុដូច្នេះ បងប្អូនត្រូវជាញាតិនៅក្នុង ២ ថ្នាក់ ដោយគិតចាប់ពី បង ឡើងដល់ឪពុកម្តាយ ហើយចុះមកដល់ ប្អូន ។ ចំណែកករណីនៃបងប្អូនជីដូនមួយ (ឧទាហរណ៍

ដូចជាកូនរបស់ពូ ខាងឪពុកជាដើម) គឺត្រូវជាញាតិនៅក្នុង ៤ ថ្នាក់ ដោយគិតចាប់ពី សាមីខ្លួន → ឪពុក → ជីតា → ពូខាងឪពុក → ប្អូនជីដូនមួយ ។

## ២.២. ញាតិលោហិត និងញាតិពន្ធ

ញាតិលោហិត គឺជាក្រុមអ្នកមានបុព្វជនរួមគ្នា ហើយដែលហៅថាមានទំនាក់ទំនងឈាមជ័រ ។ម្យ៉ាងទៀត រវាងកូនចិញ្ចឹម (សូមអានផ្នែកទី III. ៣ នៃជំពូកនេះ) និងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះនឹងត្រូវកើតមានទំនាក់ទំនងញាតិភាពដូចគ្នានឹង ញាតិលោហិត គិតចាប់ពីថ្ងៃដែលបានសុំកូន (មាត្រា ៧២៧) ។ ប៉ុន្តែ ញាតិភាពនេះត្រូវបាន បញ្ចប់ដោយការកាត់កាល់ (ការរលាយសុំកូន) (មាត្រា ៧២៩) ។ ញាតិពន្ធ គឺជាក្រុមអ្នកមានទំនាក់ទំនងបង្កើតឡើងដោយសារ អាពាហ៍ពិពាហ៍ (សូនអានផ្នែកទី III នៃជំពូកនេះ) ដូចជាប្អូនស្រីខាងភរិយានិងម្តាយរបស់ស្វាមី ជាដើម ។ ដូច្នេះ ទំនាក់ទំនងញាតិពន្ធត្រូវបញ្ចប់ដោយសារការលែងលះគ្នា (មាត្រា ៧២៨ កថាខ័ណ្ឌទី ១ ។ ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់បានបង្ហាញឆន្ទៈ បញ្ចប់ទំនាក់ទំនងញាតិពន្ធនោះ ក៏ត្រូវបញ្ចប់ដូចគ្នាដែរ ។ សូមមើលកថាខ័ណ្ឌទី ២ នៃមាត្រាដដែល) ។ នៅពេលគណនាថ្នាក់ញាតិក្នុងចំណោមញាតិពន្ធ គប្បីចាត់ទុកប្តីប្រពន្ធថាជាឯកតារួមគ្នាមួយ ។

# III. ការសិក្សាអំពីចំណុចសំខាន់ៗរបស់ច្បាប់ស្តីពីញាតិ

## ១. អាពាហ៍ពិពាហ៍

### ១.១. ការរៀបអាពាហ៍ពិពាហ៍

ចំពោះអាពាហ៍ពិពាហ៍ដែលផ្អែកលើគោលការណ៍អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គេត្រូវទទួលស្គាល់ថាជាប្តីប្រពន្ធលុះត្រាតែមានការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅស្ថាប័នរដ្ឋ (មាត្រា ៧៣៩) ។ ដូច្នេះការរៀបអាពាហ៍ពិពាហ៍ តម្រូវឱ្យមានជាបឋមឆន្ទៈរៀបអាពាហ៍ពិពាហ៍រវាងគូភាគីដែលជា លក្ខខណ្ឌសារធាតុចាំបាច់ (អាពាហ៍ពិពាហ៍ក៏ជាកិច្ចសន្យាម្យ៉ាងដែរ) ។ លើសពីនេះទៅទៀតការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងការទទួលពាក្យនោះ គឺជាលក្ខខណ្ឌ ចាំបាច់ជារូបភាព ។ ទោះជាបាន រៀបចំពិធីការនៅតាមវិហារ ឬវត្តអារ៉ាម ហើយមានរៀបចំពិធីសាយមង្គលការយ៉ាងគគ្រឹកគគ្រេងក៏ដោយចំពោះប្តីប្រពន្ធដែលមិនបានដាក់ពាក្យសុំរៀប អាពាហ៍ពិពាហ៍ទេនោះ គឺច្បាប់ចាត់ទុកថាគេគ្រាន់តែមានទំនាក់ទំនងរស់នៅជាមួយគ្នាតែប៉ុណ្ណោះ ។ នៅប្រទេសជប៉ុន ទាក់ទងនឹងអាយុគ្រប់លក្ខណៈ រៀបអាពាហ៍ពិពាហ៍ ច្បាប់បានកំណត់ថាបុរសដែលមានអាយុមិនគ្រប់ ១៨ ឆ្នាំ ឬនារីមានអាយុមិនគ្រប់ ១៦ ឆ្នាំទេ គឺមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ (មាត្រា ៧៣១) ។ ហើយទ្វេពន្ធភាព ក៏ត្រូវបាន ហាមឃាត់ (មាត្រា ៧៣២) ។ ក្រៅពីនេះ

ច្បាប់ហាមឃាត់ចំពោះនារីមិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី ទៀតបានទេ ក្នុងអំឡុងពេល ៦ ខែ គិតចាប់ពីថ្ងៃរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍មុន (កថាខណ្ឌទី ១ នៃមាត្រា ៧៣៣ ។ នេះគឺដើម្បីកុំឱ្យមានការកើតឡើងនូវបញ្ហាស្តីពីការកំណត់រកឪពុករបស់កូនដែលបានចាប់កំណើត) ។ ច្បាប់ក៏មានចែងផងដែរ អំពីការហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិជិតគ្នា នៅក្នុងកំរិតមួយកំណត់ មិនថាជាបុរស ឬនារីឡើយ (កថាខណ្ឌទី ១ ជាដើមនៃមាត្រា ៧៣៤) និងការចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់ឪពុកម្តាយ នៅពេលអនីតិជនរៀបអាពាហ៍ពិពាហ៍ (កថាខ័ណ្ឌទី ១ នៃមាត្រា ៧៣៧) ។ អំពីការហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិជិតគ្នានោះ យើងនឹងបន្សល់ ឱ្យបានយ៉ាងល្អិតល្អន់ជាងនេះបន្តិចថា ជាបឋម ច្បាប់ហាមមិនឱ្យមានអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ (ដូចជាឪពុកម្តាយនិងកូនជាដើម) ឬសាខាញាតិលោហិតក្នុង ៣ ថ្នាក់ (ឧទាហរណ៍ ដូចជារវាងកូន របស់បងនិងប្អូនជាដើម) (កថាខ័ណ្ឌទី ១ នៃមាត្រា ៧៣៤ ។ ដូច្នេះបើសិនជារវាងបងប្អូនជីដូនមួយវិញ នោះគេអាចរៀបអាពាហ៍ពិពាហ៍បានព្រោះតែជាញាតិនៅក្នុង ៤ ថ្នាក់) ។ រវាងកូនចិញ្ចឹមនិងឪពុកឬ ម្តាយក៏ដូចគ្នាដែរ មិនអនុញ្ញាតិឱ្យរៀបអាពាហ៍ពិពាហ៍បានទេ ដោយសារថាទំនាក់ទំនងនៃញាតិលោហិត ផ្ទាល់ត្រូវបានកើតមានឡើង គិតចាប់ពីថ្ងៃសុំកូនមក ។ ក៏ប៉ុន្តែ រវាងកូនចិញ្ចឹម និងកូនរបស់ឪពុកម្តាយចិញ្ចឹម អាចរៀបអាពាហ៍ពិពាហ៍បាន (សូនមើលផ្នែកបដិញ្ញាក្នុងកថាខ័ណ្ឌទី ១ នៃមាត្រា ៧៣៤)។ លើស ពីនេះទៅទៀត អាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ (ឧទាហរណ៍ដូច

ជារវាងឪពុកក្មេកនិងកូនប្រសាស្រីជាដើម) ក៏ត្រូវបានហាមឃាត់ដែរ ។ ចំពោះករណីនេះ ថ្វីបើសហព័ទ្ធណាម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់បានសំដែងឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធនោះរួចហើយក៏ដោយ ក៏ត្រូវ អនុវត្តយ៉ាងដូចគ្នាផងដែរ (មាត្រា ៧៣៥) ។

## ១.២. នាមត្រកូលរបស់ប្តីប្រពន្ធ

ក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ននេះ នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធត្រូវតែជ្រើសរើសយក នាមត្រកូលមួយរួមគ្នា ។ នេះគេហៅថាជាគោលការណ៍ ប្តីប្រពន្ធរួមត្រកូលជាមួយគ្នា (មាត្រា ៧៥០) ។ ផ្អែកតាមទម្រង់បែបបទ គឺគេមិនអាចអះអាងបានថានេះមានភាពផ្ទុយទៅនឹងសមភាពរវាងប្តីប្រពន្ធ នោះទេ ។ ប៉ុន្តែជាការពិត មានប្តីប្រពន្ធចំនួនជិត ៩៨ ភាគរយបានជ្រើសរើសយកតាមត្រកូលរបស់ប្តី ។ នាពេលបច្ចុប្បន្ន គេកំពង់តែពិចារណាអំពីការធ្វើវិសោធនកម្មច្បាប់ សំដៅកំណត់នូវខ្លឹមសារទទួលស្គាល់ ជំរើសរបស់ប្តីប្រពន្ធ ដើម្បីទុកត្រកូលរបស់រៀងៗខ្លួនឱ្យនៅដដែលបាន ក្នុងករណីណាដែលប្តីប្រពន្ធមានបំណងចង់រក្សាទុកនាមត្រកូលរបស់រៀងៗខ្លួនឱ្យនៅដដែលនោះ បើទោះជាបានរៀបអាពាហ៍ពិពាហ៍ ហើយក៏ដោយ ។

## ១.៣. ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

ប្តីប្រពន្ធអាចសំរេចដោយសេរីតាមរយៈនៃកិច្ចសន្យាជាមួយគ្នាបាន អំពីរបៀបគ្រប់គ្រងទំនាក់ទំនងទ្រព្យសម្បត្តិក្នុងអាពាហ៍ពិពាហ៍ (កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន មានកំណត់ការរិតត្បិតខ្លះថា ប្រសិនជាប្តីប្រពន្ធមិនបានចុះបញ្ជីកិច្ចសន្យានេះមុនពេលដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍ទេ គឺមិនអាចតតាំងចំពោះប្រតិសិទ្ធិរបស់ប្តីប្រពន្ធ ឬតតិយជនបានឡើយ (មាត្រា ៧៥៦) ហើយមិនអាចធ្វើការកែប្រែបានទេក្រោយ ពេលដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍រួចរាល់ហើយនោះ (កថាខ័ណ្ឌទី ១ នៃមាត្រា ៧៥៨) ។ ក្នុងករណីដែលមិនមានកិច្ចសន្យាដោយឡែកណាមួយ មុននឹង ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទេ គឺត្រូវអនុវត្តតាមបញ្ញត្តិស្តីពីប្រពន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ មានចែងនៅក្នុងក្រមរដ្ឋប្បវេណី (មាត្រា ៧៥៥) ។ ហេតុដូច្នេះ នៅប្រទេសជប៉ុន ក្នុងករណីជា ច្រើនគេអនុលោមទៅតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។

បើអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ គឺទ្រព្យសម្បត្តិដែលមានតាំងពីមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលសាមីជនទទួលបានក្នុងនាមរបស់ខ្លួនគេផ្ទាល់ (ពោលគឺក្នុងនាមរបស់ប្តីឬប្រពន្ធរៀង១ខ្លួន) ក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយនោះ ត្រូវបញ្ចូលជាទ្រព្យសម្បត្តិ ផ្ទាល់ខ្លួន ។ ចំពោះករណីណាដែលសិទ្ធិទទួលទ្រព្យសម្បត្តិមិនច្បាស់ទេ

គេត្រូវសន្មតថាជាទ្រព្យសម្បត្តិ រួមរបស់ប្តីនិងប្រពន្ធ (មាត្រា ៧៦២ ។ ការសន្មត់នេះ មានន័យថា ជាការចាត់ទុកតាមផ្លូវច្បាប់ជាបណ្តោះអាសន្នហើយបើសិនណាភាគីអាចបង្ហាញភស្តុតាង ផ្ទុយពីនេះបានការសន្មត់នេះក៏អាចនឹងត្រូវ លុបចោលបានដែរ) ។ នេះគេហៅថា ជាប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ។

ម្យ៉ាងទៀត ចំពោះសោហ៊ុយអាពាហ៍ពិពាហ៍ ពោលគឺជាសោហ៊ុយសំរាប់ជីវភាពរស់នៅរបស់ប្តី ប្រពន្ធ និងសោហ៊ុយចិញ្ចឹមបីបាច់កូនដែលនៅមិនទាន់ពេញវ័យ ។ ល ។ ប្តីប្រពន្ធត្រូវមានចំណែកបន្ទុក លើសោហ៊ុយទាំងនេះ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងកត្តាផ្សេងៗទៀត (ហៅថា កាតព្វកិច្ចចែកបន្ទុកលើសោហ៊ុយអាពាហ៍ពិពាហ៍ ។ មាត្រា ៧៦០ ។ សោហ៊ុយអាពាហ៍ពិពាហ៍នេះ មិន សំដៅទៅលើចំណាយសំរាប់ពិធីអាពាហ៍ពិពាហ៍ទេ) ។

## ១.៤.ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះបំណុលគេហកិច្ចប្រចាំថ្ងៃ

ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះបំណុលនៃគេហកិច្ចប្រចាំថ្ងៃ ត្រូវបានកំណត់ក្នុង បញ្ញត្តិនៃច្បាប់ ដែលជាទិដ្ឋភាពមួយនៃលក្ខណៈពិសេសរបស់ច្បាប់ស្តីពីទ្រព្យសម្បត្តិក្នុងទំនាក់ទំនង ប្តីប្រពន្ធជាមួយនឹងជនដែលស្ថិតនៅក្រៅទំនាក់ទំនងនេះ ។ មាត្រា ៧៦១ នៃក្រមរដ្ឋប្បវេណីចែងថា នៅពេលដែលសហព័ទ្ធណាម្ខាង មានការពាក់ព័ន្ធក្នុងសកម្មភាពគតិយុត្តិជាមួយតតិយជនទាក់ទងនឹងគេហកិច្ចប្រចាំថ្ងៃនោះ សហព័ទ្ធម្ខាងទៀតត្រូវទទួលខុសត្រូវដោយ

សាមគ្គីភាពចំពោះបំណុលដែល កើតមានឡើងដោយសារសកម្មភាពនេះ (ប៉ុន្តែ ក្នុងករណីដែលមានការផ្តល់ដំណឹងជាមុនអំពីសេចក្តី សំរេចថានឹងមិនទទួលខុសត្រូវចំពោះតតិយជនទេ គឺគេមិនយកបញ្ញត្តិនេះមកអនុវត្តឡើយ) ។ បំណុល ដែលសហព័ទ្ធម្ខាងមានបន្ទុកទទួលរ៉ាប់រងក្នុងពេលដែលត្រូវខ្ចីប្រាក់និងទិញទំនិញផ្សេងៗ សំរាប់ការរស់ នៅ ស្បៀងអាហារ និងសំលៀកបំពាក់ ដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធនោះ ប្រសិនបើមានលក្ខណៈ ជាគេហកិច្ចនិងមានលក្ខណៈប្រចាំថ្ងៃគឺពីនាក់ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការអនុវត្តន៍កាតព្វកិច្ចនេះ ។ ឧទាហរណ៍ដូចជាចំពោះការអនុវត្តកាតព្វកិច្ចដែលប្រពន្ធជាអ្នកបង្កើតឡើងនោះប្តីក៏ត្រូវទទួលខុសត្រូវដែរ ។ នេះត្រូវអនុវត្តចំពោះរាល់បំណុលក្នុងការទូទាត់ថ្លៃភ្លើង ថ្លៃជួលផ្ទះ និងថ្លៃទិញសំភារៈអគ្គីសនីសំរាប់ប្រើប្រាស់ក្នុងគ្រួសារ ជាដើម ។ ពោលគឺជាបញ្ញត្តិសំដៅផ្តល់កិច្ចការពារដល់ភាគីជាដៃគូក្នុងការជួញដូរដោយតម្រូវឱ្យសហព័ទ្ធម្ខាងទៀតទទួលខុសត្រូវដោយសាមគ្គីភាពផងដែរចំពោះរាល់បំណុលដែលទាក់ទងនឹងជីវភាពសហគមន៍រួមរវាហប្តីនិងប្រពន្ធ (ពីព្រោះគេមិនអាចដាក់ បំណុលសង្ខេបលើសហគមន៍មួយដែលរស់នៅជាមួយគ្នានោះទេ) ហើយដែលមិនមែនជាបំណុលផ្ទាល់ ខ្លួនរបស់ប្តី ឬប្រពន្ធទេ ។ ហេតុដូច្នេះ អ្វីដែលអាចចាត់ទុកបានថាជាបំណុលនៃគេហកិច្ចប្រចាំថ្ងៃ គឺប្រាកដជាមានព្រំដែនកំណត់ ។ ឧទាហរណ៍ ចំពោះសកម្មភាពចាត់ចែងអចលនវត្ថុដែលជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហព័ទ្ធម្ខាង គឺមិនអាចចាត់ទុកបានថាជាគេហកិច្ចប្រចាំថ្ងៃទេ ។

## ១.៥. កិច្ចសន្យារវាងប្តី និងប្រពន្ធ

ក្នុងករណីដែលមានកិច្ចសន្យាមួយត្រូវបានបង្កើតឡើង ឧទាហរណ៍ដូចជាប្រទានកម្មរវាងប្តីនិងប្រពន្ធជាដើម សហព័ទ្ធណាម្ខាងអាចលុបកិច្ចសន្យានោះចោលនាពេលណាក៏បានដែរ ក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍នោះ (មាត្រា ៧៥៤) ។ បញ្ញត្តិនេះ មានគោលបំណងទុកការអនុវត្តកិច្ចសន្យារវាង ប្តីនិងប្រពន្ធ ឱ្យស្ថិតនៅក្នុងក្របខ័ណ្ឌនៃមនោសញ្ចេតនានិងសីលធម៌ ដោយចាត់ទុកថាមិនគប្បីបង្ខំការ អនុវត្តតាមផ្លូវច្បាប់នោះទេ ។ ប៉ុន្តែ ការរិះគន់ពីផ្នែកទ្រឹស្តីសិក្សាក៏មានច្រើនដែរ ។

## ១.៦. កំជាប់ពាក្យ និងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ

ការសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ (រៀបការ) ជាមួយគ្នានោះ ជាទូទៅក្នុងសង្គមគេហៅថា កំជាប់ពាក្យ ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិចែងអំពីកំជាប់ពាក្យទេ ។ ដូច្នេះការវាយតំលៃត្រូវតែផ្អែកលើយុត្តិសាស្ត្រច្បាប់និងទ្រឹស្តីសិក្សា ។ បើសិនជាយើងគិតថា កំជាប់ពាក្យគឺជាកិច្ចសន្យាអំពីអាពាហ៍ពិពាហ៍នាពេលអនាគតនោះ គឺការបដិសេធចោលជាឯកតោភាគីត្រូវចាត់ទុកជាការមិនអនុវត្តកាតព្វកិច្ច (សូមអានជំពូកទី ៦) ។ ម្យ៉ាងទៀត បើសិនជាយើងគិតថាការបដិសេធនេះបានបង្កឱ្យមាន ការខូចខាត (ខាងទ្រព្យសម្បត្តិក្តី ខាងសតិអារម្មណ៍ក្តី) ដល់អ្នកដទៃ ដោយគ្មានមូលហេតុសមរម្យ ដោយកំហុសចេតនា ឬដោយកំហុសអចេតនានោះ

គឺត្រូវចាត់ទុកថាជាអំពើអនិត្យានុកល ។ ទោះជា យ៉ាងណាក៏ដោយ ការបដិសេធជាឯកតោភាគីនិងដោយទំនើងចិត្ត នឹងក្លាយទៅជាកម្មវត្ថុនៃសំណងការ ខូចខាត ។

ការបង្កើតកំជាប់ពាក្យ មិនចាំបាច់ត្រូវមានបែបបទអ្វីទេ ។ នៅក្នុងសង្គមគេអនុវត្តការលើក ជំនូនយ៉ាងទូលំទំលាយ ក៏ប៉ុន្តែនេះជាការធ្វើតាមទំនៀមទម្លាប់តែប៉ុណ្ណោះ ។ ការដែលបានភ្ជាប់កំជាប់ ពាក្យ ឬមិនបានភ្ជាប់នោះ មិនមែនវិនិច្ឆ័យដោយផ្អែក លើការឱ្យជំនូនទៅវិញទៅមក ឬមិនបានឱ្យនោះទេ ។ តាមផ្លូវច្បាប់ ជំនូនត្រូវគិតថាជាប្រទានកម្មមួយប្រភេទដែលបញ្ជាក់អំពីការបង្កើតកំជាប់ពាក្យ ។ ជាធម្មតា ជំនូនត្រូវបានលើកឱ្យគ្នាទៅវិញទៅមកដោយសារមានការបង្កើតកំជាប់ពាក្យ ហើយនិង ដោយសារមានគោលបំណងចង់រៀបអាពាហ៍ពិពាហ៍នៅថ្ងៃក្រោយ ហេតុដូច្នេះបើសិនជាកំជាប់ពាក្យ ត្រូវរលាយ គឺចាំបាច់ត្រូវសងជំនូនទៅវិញ ។ ជាទូទៅ ការទាមទារឱ្យសងមកវិញនេះនឹងធ្វើឡើងដោយ ផ្អែកលើមូលដ្ឋាននៃសេចក្ដីចម្រើនដោយឥតហេតុ (សូមអាន ជំពូកទី ៥) ក៏ប៉ុន្តែយោងតាម យុត្តិសាស្ត្រច្បាប់ប្រសិនបើភាគីអ្នកផ្ដល់ជំនូនត្រូវទទួលខុសត្រូវចំពោះការ រលាយនៃកំជាប់ពាក្យនោះ គឺពុំអាចទាមទារសំណងមកវិញបានទេ ។ នេះគឺជាការដាក់ពិន័យម្យ៉ាង ដែលអាចចាត់ទុកថាជាវិធីជួយដល់ភាគីម្ខាងទៀតរក្សាផលប្រយោជន៍នៃទ្រព្យដែលបានមកពីជំនូននោះ ដើម្បីទុកជាសំណងខូចខាតដែលបង្កឡើងដោយសារអំពើអនីត្យានុកូល( បើសិនជាសំណងខូចខាត កើតឡើងក្នុង

ទ្រង់ទ្រាយធំជាងតំលៃនៃទ្រព្យសម្បត្តិដែលបានមកពីជំនូននោះ គេក៏អាចទាមទារសំណង បន្ថែមទៀតបានដែរ) ។

ពាក្យថា "ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ"ក៏មិនមានបញ្ញត្តិនៅក្នុងក្រមដែរ ។ ក្នុងចំណោមករណីផ្សេងៗ ដែលបុរសនិងនារីមួយគូបានបង្កើតជីវភាពរួមគ្នា (ករណីដែលរស់នៅក្នុងផ្ទះជាមួយគ្នា ហើយនិងរំលែករាល់ការចំណាយចំណូល ។ ល ។ រួមគ្នា) ដោយមិនមានដាក់ពាក្យសុំរៀប អាពាហ៍ពិពាហ៍ទេ ក៏ប៉ុន្តែទោះជាមិនបានដាក់ពាក្យសុំក៏ដោយ បើសិនជាគូបុរសនារីនេះមានឆន្ទៈរៀប អាពាហ៍ពិពាហ៍ជាមួយគ្នា ជាទូទៅគេហៅថាជាការរស់ នៅជាមួយគ្នាជាប្តីប្រពន្ធ(ជាភាសាជប៉ុន គេហៅថា "ណៃអេន") (ចំពោះករណីដែលមិនមាន ឆន្ទៈរៀបអាពាហ៍ពិពាហ៍ទេ គេហៅថាជាការរស់នៅ ជាមួយគ្នាតែប៉ុណ្ណោះ) ។ ដោយសារការអនុវត្តគោលការណ៍អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ទោះបីជីវភាព រស់នៅពិតមែនតែមានលក្ខណៈជាទំនាក់ទំនងអាពាហ៍ពិពាហ៍យ៉ាងដូច្នោះក៏ដោយ បើសិនជាមិនបានដាក់ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទេនោះ គឺវាជាការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ប៉ុន្តែសាមីខ្លួនមិនអាចទទួលបាននូវកិច្ចការពារតាមផ្លូវច្បាប់ទេ ។ ដោយគិតថានេះមានបញ្ហា ទើបបានជាយុត្តិសាស្ត្រច្បាប់និងទ្រឹស្តីសិក្សា បានប្រឹងប្រែងរកកិច្ចការពារតាមផ្លូវសំរាប់អ្នកដែលរស់នៅជាមួយគ្នាជាប្តីប្រពន្ធនោះ ។ ទ្រឹស្តីសិក្សាសព្វថ្ងៃនេះអះអាងថា គួរចាត់ទុកការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនេះថាជាទំនាក់ទំនងប្រហាក់ប្រហែលនឹងអាពាហ៍ពិពាហ៍ហើយការបដិសេធទំនាក់ទំនងនេះចោល

គឺសមតែចាត់ទុកថាជា អំពើអនីត្យានុកូល (ទ្រឹស្តីអំពីអាពាហ៍ពិពាហ៍មិនពេញលក្ខណៈ) ។ បើនិយាយតាមការជាក់ស្តែងនៅក្នុងទំនាក់ទំនងនៃការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដែលមិនមានការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះទេ គឺគេមិនអាចទទួលស្គាល់បានទេ នូវអនុភាពអាពាហ៍ពិពាហ៍ ដែលពាក់ព័ន្ធនឹងការចុះបញ្ជីគ្រួសារ ។ ប៉ុន្តែ ជាលទ្ធផលនៃជីវភាពរស់នៅជាមួយគ្នា មានគំនិតជាច្រើនយល់ឃើញថា គេអាចបកស្រាយតាមវិធី ប្រៀបប្រដូច សំដៅកំណត់អំពីករណីយកិច្ចរួមរស់នឹងគ្នាសហការនិងសង្គ្រោះគ្នាទៅវិញទៅមក កាតព្វកិច្ចចែកចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះ បំណុលនៃគេហកិច្ចប្រចាំថ្ងៃ និងការចែកទ្រព្យ ជាដើម ។

## ២. ការលែងលះគ្នា

### ២.១. នីតិវិធីនៃការលែងលះគ្នា

ក្នុងករណីដែលទំនាក់ទំនងរវាងប្តីនិងប្រពន្ធមិនមានដំណើរការល្អប្រសើ គឺនឹងបង្កើតឱ្យមានបញ្ហាលែងលះគ្នា ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន មានចែងអំពីការលែលះគ្នា ដោយផ្អែក លើកិច្ចពិភាក្សា ដែលភាគីអាចលែងលះគ្នាបានដោយការយល់ស្របគ្នាតែប៉ុណ្ណោះ (មាត្រា ៧៦៣) និង ការលែងលះគ្នាតាមរយៈតុលាការ ដែលត្រូវតែឱ្យតុលាការទទួលស្គាល់ ។ ក្នុងវិធីលែងលះគ្នាតាមរយៈ តុលាការ ចាំបាច់ត្រូវមានមូលហេតុនៃការលែងលះគ្នា

ដូចជាការផិតក្បត់ ឬការបោះបង់សហពន្ធ ម្ខាងទៀតចោលដោយគ្មានមូលហេតុត្រឹមត្រូវ ទើបអាចទទួលស្គាល់ឱ្យលែងលះគ្នាបាន ។ ប៉ុន្តែនៅពេល ដែលមានហេតុការណ៍ធ្ងន់ធ្ងរ ធ្វើឱ្យអាពាហ៍ពិពាហ៍ពិបាកនឹងបន្តទៅមុខបាននោះ ក៏អាចទទួលស្គាល់បាន ថាជាមូលហេតុនៃការលែងលះគ្នាដែរ (មាត្រា ៧៧០) ។ អំពីចំណុចនេះ អង្គជំនុំជម្រះពេញអង្គរបស់តុលាការកំពូលបានសំរេចនៅឆ្នាំ ១៩៨៥ ថាការទាមទារឱ្យលែងលះគ្នាដែលភាគីមានកំហុសបានសុំពោលគឺជាភាគីដែលត្រូវទទួលខុសត្រូវចំពោះការបង្កឱ្យមានជំលោះនៃការលែងលះគ្នានោះ ក៏អាចទទួល យកបានដែរ ។ ក្រៅអំពីវិធីពីរយ៉ាងដែលមានរៀបរាប់ខាងលើនេះ នៅមានបញ្ញត្តិចែងអំពីការលែងលះ គ្នាតាមសន្ធានកម្ម និងតាមការសំរេចរបស់តុលាការគ្រួសារផងដែរ ។

## ២.២. ការចែកទ្រព្យ

ភាគីម្ខាងនៃការលែងលះគ្នាអាចទាមទារការចែកទ្រព្យពីសហពន្ធម្ខាងទៀត ដែលបានលែងលះគ្នាហើយនោះ ។ បើសិនជាភាគីទាំងសងខាងមិនអាច ស្រុះស្រួលគ្នាតាមរយៈនៃការពិភាក្សាគ្នាបានទេនោះ តុលាការគ្រួសារត្រូវសំរេចថាតើអាចចែកទ្រព្យនោះបានឬមិនបាន ហើយនិងអំពីបរមាណនៃទ្រព្យដែលត្រូវចែក (មាត្រា ៧៦៨)។ នៅពេលនោះតុលាការត្រូវគិតគូរពិចារណាអំពីចំនួន ទ្រព្យដែលប្តីប្រពន្ធទទួលបានមកពីកិច្ចសហការជាមួយគ្នា និងអំពីព្រឹត្តិការណ៍ដទៃផ្សេងទៀត ។

ម្យ៉ាងទៀត នៅមានបញ្ហានៃទំនាក់ទំនងរវាងចំណែកទ្រព្យនិងទឹកប្រាក់នៃជម្ងឺចិត្ត ។ គេអាចគិត ថា មានករណីខ្លះ ទឹកប្រាក់នៃជម្ងឺចិត្តក្នុងការលែងលះគ្នា ត្រូវបានគិតបញ្ចូលទៅក្នុងការចែងទ្រព្យ ។ ប៉ុន្តែ យោងតាមយុត្តិសាស្ត្រច្បាប់ ទោះជាក្នុងករណីដែលការចែកទ្រព្យត្រូវបានសំរេចរួចរាល់អស់ហើយ ក៏ដោយ តុលាការអាចឱ្យគេធ្វើការទាមទារទឹកប្រាក់នៃ ជម្ងឺចិត្តដោយឡែកផ្សេងទៀតក៏បានដែរបើសិនជាតុលាការគិតថាសំណងនៃការខូចខាតមិនទាន់បានរួមបញ្ចូលទៅក្នុងការចែកទ្រព្យនោះទេ ឬយល់ឃើញ ថាចំនួនទឹកប្រាក់និងវិធីចែកទ្រព្យ មិនទាន់គ្រប់គ្រងសំរាប់ជួសជុលការឈឺចាប់ផ្នែកសតិអារមណ៍របស់ អ្នកទាមទារនោះទេ ។

លើសពីនេះទៅទៀតក្នុងករណីនៃការចែកទ្រព្យដោយកិច្ចពិភាក្សាគ្នា មានពេលខ្លះវាជាការលាក់ទុកនូវទ្រព្យសម្បត្តិពិតប្រាកដដែលអាចមានឧទាហរណ៍ដូចជាប្តីលែងលះប្រពន្ធហើយចែកទ្រព្យគ្នា ដើម្បីគោលបំណងរត់កិច្ចពីការដេញដោលពីសំណាក់ម្ចាស់បំណុល ។ ដូច្នេះ បើសិនជាចំនួនទឹកប្រាក់នៃ ចំណែកទ្រព្យមានច្រើនហួសហេតុ ខុសពីខ្លឹមសារដែលមានចែងក្នុងមាត្រា ៧៦៨ នៃក្រមរដ្ឋប្បវេណី ហើយបើសិនជាមានព្រឹត្តិការណ៍ពិសេសដែលនាំឱ្យមានការយល់ឃើញថាការចែកទ្រព្យនេះ គឺជាវិធី ចាត់ចែងទ្រព្យដោយបន្លំ គេអាចចាត់ទុកចំនួនទាំងអស់ឬមួយផ្នែកនៃចំណែកទ្រព្យនោះ ថាជាកម្មវត្ថុ ដែលត្រូវលុបចោល ដោយអនុវត្ត សិទ្ធិលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ (មាត្រា ៤២៤) ។

# ៣. ទំនាក់ទំនងរវាងឪពុកម្តាយ កូនបង្កើត និងកូនចិញ្ចឹម

## ៣.១. ឪពុកម្តាយនិងកូនបង្កើត

កូនកើតមកពីប្តីប្រពន្ធដែលមានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ត្រូវបានគេហៅថាកូនមានខាន់ស្លា (មាត្រា ៧៧២ ដែលមានរៀបរាបនៅខាងក្រោមនេះ មានចែងកំណត់អំពីការសន្មត់ នៃបិតាភាពនិងការសន្មត់នៃភាពមានខាន់ស្លា) ។ កូនកើតមកពី បុរសនារីមួយគូដែលពុំមានដាក់ពាក្យសុំ រៀបអាពាហ៍ពិពាហ៍នោះទេ ហៅថាកូនឥតខាន់ស្លា ។ ភាពខុសគ្នារវាងកូនទាំងពីរប្រភេទនេះ សំខាន់មាននៅត្រង់ចំណុចថា កូនឥតខាន់ស្លា ទទួលបាន មរតក៏ស្មើនឹងពាក់កណ្តាលនៃភាគចំណែកនៃមរតក (នៅក្នុងជំពូក ៣ ២ នឹងមានការរៀបរាប់ បន្ថែមអំពីភាគចំណែកនៃមរតក) ដែលទុកសំរាប់ ឱ្យកូនមានខាន់ស្លា (មាត្រា ៩០០ កថាខ័ណ្ឌទី៤)។ ពាក់ព័ន្ធនឹងបញ្ហានេះនាពេលបច្ចុប្បន្នគេកំពុងតែពិភាក្សាអំពីការកែទំរង់ច្បាប់សំដៅធ្វើ ឱ្យមានភាពស្មើគ្នា ។

នៅក្នុងទំនាក់ទំនងរវាងឪពុកម្តាយនិងកូនមានខាន់ស្លា ពោលគឺទំនាក់ទនងសាច់ឈាមជាធម៌ជាតិរវាងឪពុកម្តាយនិងកូនបង្កើតនេះ មាន២ករណីដូចតទៅ ។ ករណីទំនាក់ទំនងរ វាងម្តាយនិងកូន គឺភាគច្រើនអាចបញ្ជាក់បានយ៉ាងងាយស្រួលដោយអង្គហេតុនៃការសំរាលកូននោះ ។ ចំណែកទំនាក់ទំនងរវាងឪពុកនិងកូនវិញ មានករណីជាច្រើនដែលការបញ្ជាក់អំពីទំនាក់ទំនងនេះមានការពិបាក ។ មាត្រា ៧៧២ កថាខ័ណទី ១ ចែងថា ទារកនៅក្នុងគភ៍ប្រពន្ធដែល មាននៅ

ក្នុងពេលមានចំនង អាពាហ៍ពិពាហ៍ ត្រូវបានសន្មត់ថាជាកូនរបស់ប្តី ។ ការសន្មត់ខាងលើនេះត្រូវបានបដិសេធតែក្នុងករណីមាននិតិវិធីច្បាប់ពិសេសប៉ុណ្ណោះ (ដោយសារប្តីបានបដិសេធអំពីភាពមានខាន់ស្លានោះ ដូចមានចែងក្នុង មាត្រា ៧៧៤) ។ ផ្ទុយទៅវិញ ក្នុងករណីដែលទារកកើតនៅពេលដែលម្តាយពុំមានចំនងអាពាហ៍ពិពាហ៍ទេនោះ គេបានគ្រោងទុកនូវវិធីសំរាប់ធ្វើការទទួលស្គាល់ ។ វិធីទទួលស្គាល់ដោយស្ម័គ្រចិត្ត គឺជាការ ទទួលស្គាល់ដោយស្ម័គ្រចិត្ត អំពីទំនាក់ទំនងឪពុកនិងកូនដោយបុគ្គលដែលអះអាងថាខ្លួនជាឪពុកនោះ ។ ក្នុងករណីនេះ គេសន្មត់ថាអ្នកដែលបានធ្វើការទទួលស្គាល់នេះគឺជាឪពុកពិតមែន (មាត្រា ៧៧៩ ។ មាត្រានេះមានចែកអំពីការទទួលស្គាល់ជាម្តាយផងដែរ ។ ការចែងនេះ គឺសំរាប់ករណីពិសេសដែល ម្តាយត្រូវលើកភស្តុតាងបញ្ជាក់អំពីអង្គហេតុនៃការមានគភ៌និងការសំរាលកូន ដូចជាក្នុងករណីកូនវង្វេង ឬកូនត្រូវគេបោះបង់ចោល) ។ ម្យ៉ាងទៀត អ្នកតំណាងដែលច្បាប់បានកំណត់ របស់កូននិងបច្ឆាញាតិអាចដាក់បណ្តឹងទាមទារឱ្យទទួលស្គាល់បានទៅតុលាការដើម្បីឱ្យជួយបញ្ជាក់អំពីទំនាក់ទំនងឪពុកនិងកូន (មាត្រា ៧៨៧ ។ នេះហៅថាជាការទទួលស្គាល់ដោយបង្ខំ) ។

គេអាចផ្តល់ឋានៈជាកូនមានខាន់ទៅឱ្យកូនឥតខាន់ស្លាបានក្នុងករណីពីរ ។ ករណីទីមួយគឺចំពោះកូនដែលឪពុកបានធ្វើការទទួលស្គាល់ហើយកូននោះអាចទទួលបានឋានៈជាកូនមានខាន់ស្លាដោយសារ ការរៀបអាពាហ៍ពិពាហ៍របស់ឪពុកនិងម្តាយ (មាត្រា ៧៨៩ កថាខ័ណ្ឌទី ១) ។ ហើយនិងករណីទីពីរ គឺឪពុកម្តាយទទួលស្គាល់កូននោះនៅពេលកំពុងមានចំណងអាពាហ៍ពិពាហ៍ ។

ក្នុងករណីនេះកូនត្រូវ ទទួលបានឋានៈជាកូនមានខាន់ស្លា ចាប់គិតពីពេលឪពុកម្តាយធើការទទួលស្គាល់នោះ (មាត្រា ៧៨៩ កថាខ័ណ្ឌទី ២) ។

## ៣.២. កូនចិញ្ចឹម

កូនចិញ្ចឹម គឺជាការទទួលកូនរបស់អ្នកដទៃ ដែលពុំមានជាប់សាច់ញាតិជាមួយអ្នកសុំនោះទុកជា កូនតាមផ្លូវច្បាប់របស់ខ្លួន ដោយមានការព្រមព្រៀងគ្នារវាងភាគដែលពាក់ព័ន្ធ (មាត្រា ៧៩២) ។ កូនចិញ្ចឹម មិនត្រូវបានកាត់ផ្តាច់ទំនាក់ទំនងញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតនិងពីសាច់ញាតិដទៃ ទៀតឡើយ ដូច្នេះកូនចិញ្ចឹមនោះនឹងមាន ឪពុកម្តាយ៤នាក់ ។ (**ជំពូកទី ៩ ផ្នែកទី II ១(១)** នឹង រៀបរាប់អំពីសិទ្ធិរបស់កូនចិញ្ចឹមក្នុងការទទួលសន្តតិកម្មពីឪពុក ម្តាយបង្កើត។ ប៉ុន្តែ ដោយសារមាន ករណីខ្លះ គេចង់សុំទារករបស់អ្នកដទៃមកចិញ្ចឹម ហើយចង់ឱ្យមានការរលត់ទំនាក់ទំនងញាតិភាពជាមួយ ឪពុកម្តាយបង្កើតទៀតផងនោះ នាឆ្នាំ ១៩៨៧ ប្រទេសជប៉ុនបានកំណត់ឱ្យមានប្រព័ន្ធសុំកូនពិសេស ដើម្បីឆ្លើយតប ទៅនឹងតម្រូវការនេះ (ក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ៨១៧ កថាខ័ណ្ឌទី ២ តទៅ) ។

ជាគោលការណ៍ ការសុំក្មេងអាយុក្រោម ៦ ឆ្នាំមកចិញ្ចឹមត្រូវមានសាលក្រមសំរេចពីតុលាការគ្រួសារ។ កូនចិញ្ចឹមពិសេស ពុំមានទំនាក់ទំនងជាមួយឪពុកម្តាយបង្កើតជាបន្តទៀតឡើយ (ហើយក៏ពុំមានសិទ្ធិសន្តតិកម្មដែរ)។ វិធីចុះបញ្ជីអត្រានុកូលដ្ឋានទៀតសោតក៏ខុសប្លែកពីកូនចិញ្ចឹមធម្មតាដែរ។ គឺត្រូវព្យាយាមជៀសវាងមិនអោយដឹងយ៉ាងងាយស្រួលថាជាកូនចិញ្ចឹមនោះទេ។

(ចពោះករណីនៃការ សុំចុះកំណើតទារកដែលទើបនឹងកើតរបស់អ្នកដទៃ ថាជាទារករបស់ខ្លួន ដែលគេហៅថាជា "ការសុំកូន ចញ្ចឹមនៅពេលទារកទើបនឹងកើតភ្លាមៗ" នោះ មានទ្រឹស្តីសិក្សា និង សាលក្រមរបស់តុលាការថ្នាក់ទាប លើកឡើងថា ការចុះកំណើតនេះមិនមានសុពលភាពទេ ហើយទំនាក់ទំនងនេះមិនអាចក្លាយទៅរវាង ឪពុកម្តាយនិងកូនបង្កើតបានទេ គឺត្រូវទទួលស្គាល់ការចុះលិខិតបញ្ជាក់សុំកូនវិញ ។ ប៉ុន្តែតុលាការកំពូល មិនទាន់ទទួលស្គាល់ការលើកឡើងនេះឡើយ) ។

ទំនាក់ទំនងរវាងឪពុកម្តាយនិងកូនចិញ្ចឹមដែលផ្អែកលើការសុំកូនមធម្មតាអាចបញ្ចប់ទៅបាន ដោយការកាត់កាល់ (ប៉ុន្តែ ជាគោលការណ៍ គេមិនទទួលស្គាល់ចំពោះការរលាយទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនចិញ្ចឹមដែលបានមកពីការសុំកូនពិសេសនោះ តាមរយៈនៃការកាត់កាល់ទេ (មាត្រា ៨១៧ កថាខ័ណ្ឌ ១០(២)) ។ ពិព្រោះថាសុំកូនពិសេស សំដៅលើការប្រឹងប្រែង របស់ភាគីទាំងអស់ដើម្បី បង្កើតនូវទំនាក់ទំនងមួយដែលដូចគ្នាទៅនឹងឪពុកម្តាយនិងកូនបង្កើតយ៉ាងដូច្នោះ) ។ គំនិងជាមូលដ្ឋាន អំពីការកាត់កាល់នេះ មានលក្ខណៈដូចគ្នានឹងការលែងលះដែរ ។ មានការកាត់កាល់តាមផ្លូវតុលាការ និង ការកាត់កាល់តាមការព្រមព្រៀង ។ ម្យ៉ាងទៀត ប្រសិនបើភាគីម្ខាងនៃការសុំកូនត្រូវស្លាប់ ហើយភាគី ម្ខាងទៀតដែលនៅរស់ ចង់កាត់កាល់សុំកូននោះ អាចធ្វើយ៉ាងដូច្នេះបានលុះត្រាតែមានទទួលការ អនុញ្ញាតពីតុលាការគ្រួសារជាមុនសិន (មាត្រា ៨១១ កថាខ័ណ្ឌទី ៦ ។ នេះគេហៅថាជាការកាត់កាល់ ក្រោយមរណភាព) ។

# ៤. អំណាចមេបា អំណាចអាណាព្យាបាល ហិតូបត្ថម្ភកៈ និងអ្នកជំនួយ

## ៤.១. ទ្រឹស្តីជាមូលដ្ឋាន

ច្បាប់គ្រួសារបច្ចុប្បន្នត្រូវគិតគូរអំពីការការពារកូន ការការពារសហព័ទ្ធ និងការការពារជនចាស់ជារាផងដែរ។ ដោយប្រឈមមុខនឹងសង្គមមួយដែលអាត្រានៃមនុស្សចាស់ជរា កំពុងកើនច្រើនឡើង នោះ គេត្រូវព្យាយាមចោទឡើងជាថ្មីម្តងទៀតនូវបញ្ហាអំពីអាណាព្យាបាលនិងហិតូបម្ភ ដោយផ្អែកលើ ទស្សនៈថ្មី (នេះហៅថាជាបញ្ហានៃអាណាព្យាបាលសំរាប់នីតិជន ។ ទាក់ទងទៅនឹងបញ្ហានេះ គេបាន ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីនៅខែធ្នូឆ្នាំ១៩៩៩ ដែលត្រូវបានចូលជាធរមាននៅខែមេសាឆ្នាំ ២០០០។ ត្រង់នេះ ក៏មានការគិតគូផងដែរអំពីទស្សនៈរៀបចំសង្គមឱ្យ មានភាពប្រក្រតីដោយគោរពចំពោះឆន្ទៈនិងសិទ្ធិសំរេចរបស់សាម័យខ្លួនអ្នកចាស់ជរាផ្ទាល់ ហើយថែមទាំងសំរួលឱ្យជនពិការអាចមានជីវភាព រស់នៅជាធម្មតាក្នុងគ្រួសារនិងនៅមូលដ្ឋានផងដែរ) ។

## ៤.២. អំណាចមេបា

### ៤.២.១. អំណាចមេបា និងអ្នកមានអំណាចមេបា

កូនមិនទាន់ពេញវ័យត្រូវស្ថិតនៅក្រោមអំណាចមេបា (មាត្រា៨១៨) ។ ពោលគឺថាកូននោះត្រូវស្ថិតនៅក្រោមការបីបាច់រក្សា អប់រំ និងគ្រប់គ្រងទ្រព្យសម្បត្តិពីមេបា ។ ម្យ៉ាងទៀត អនីតិជន

នឹង ត្រូវចាត់ទុកថាជានីតិជនក្រោយពេលរៀបអាពាហ៍ពិពាហ៍ (មាត្រា ៧៥៣) ហើយក្នុងករណីនេះ អនីតិជន នោះនឹងត្រូវចេញផុតពីការគ្រប់គ្រងក្រោមអំណាចមេបា ។

អ្នកមានអំណាចមេបាគឺជាឪពុកម្តាយរបស់អនីតិជន (មាត្រា ៨១៨ កថាខ័ណ្ឌទី ១) ។ ឪពុកម្តាយ ចិញ្ចឹមក៏អាចជាអ្នកមានអំណាចមេបាដូចឪពុកម្តយបង្កើតដែរ (មាត្រា ៨១៨ កថាខ័ណ្ឌទី ២) ។ ទ្រឹស្តី សិក្សានៅមិនទាន់បែងចែកឱ្យបានច្បាស់ថា ក្នុងករណីដែលឪពុកម្តាយចិញ្ចឹមមាន អំណាចមេបានោះតើឪពុកម្តាយបង្កើតនឹងបាត់បង់អំណាចមេបា ឬមួយគ្រាន់តែទុកឱ្យអំណាចមេបា របស់ឪពុកម្តាយចិញ្ចឹម មានអាទិភាពជាង ឬយ៉ាងណាទេនោះ ។ ម្យ៉ាងទៀត ឪពុកម្តាយគ្រប់រូបមិន មែនសុទ្ធតែអាចក្លាយ ជាអ្នកមាអំណាចមេបាឡើយ ។ ដូចជាករណីដែលឪពុកម្តាយជាអនីតិជន ពេលនោះអំណាចមេបា ត្រូវបានអនុវត្តដោយអ្នកមានអំណាចមេបា (ឬអ្នកអាណាព្យាបាល) លើឪពុកឬម្តាយដែលជាអនីតិជន នោះជំនួសវិញ (មាត្រា ៨៣៣ និងមាត្រា ៨៦៧ កថាខណ្ឌ ១) ។ ទោះជាមិនមានការកំណត់ជា បញ្ញត្តិច្បាប់ក៏ដោយ ក៏ទ្រឹស្តីភាគច្រើនអះអាងថា ឪពុកឬម្តាយដែល ត្រូវចាត់ទុកជាជនដែលត្រូវបាន កម្រិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដោយផ្អែកតាម ក្រមចាស់នោះនឹងមិនអាចអនុវត្តអំណាច មេបាបានឡើយ (ហើយយុត្តិសាស្ត្រតុលាការថែម ទាំងបានបកស្រាយផងដែរថាករណីនៃអ្នកដែលមាន ស្ថានភាពប្រហាក់ប្រហែលនឹងជនដែល ត្រូវបានកម្រិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដោយផ្អែកតាមក្រមចាស់នោះ ក៏មិនអាច អនុវត្តអំណាចមេបាដែរ) ។

### ៤.២.២. ខ្លឹមសារនៃអំណាចមេបា

ខ្លឹមសារនៃអំណាចមេបា មានជាបឋម ការគ្រប់គ្រងថែរក្សា ពោលគឺជាអនុវត្តនូវការគ្រប់គ្រង ថែរក្សា និងអប់រំកូន ។ នេះគឺជាសិទ្ធិនិងករណីកិច្ចរបស់អ្នកដែលមានអំណាចមេបា (មាត្រា ៨២០) ។ ម្យ៉ាងទៀត ខ្លឹមសារទីពីរ គឺការគ្រប់គ្រងទ្រព្យសម្បត្តិ ។ មេបាត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ត្រូវតំណាងអោយកូនចំពោះរាល់សកម្មភាពគតិយុត្តិដែល ទាក់ទងទៅនឹងទ្រព្យសម្បត្តិ (សិទ្ធិគ្រប់គ្រង ទ្រព្យសម្បត្តិ មាត្រា ៨២៤) ។ ប៉ុន្តែបើសកម្មភាពរបស់អ្នកមានអំណាចមេបាបង្កើតកាតព្វកិច្ច ដែលមានកម្មវត្ថុជាសកម្មភាពរបស់កូននោះ អ្នកមានអំណាចមេបាត្រូវទទួលការយល់ព្រមពីកូនជាមុន សិន (មាត្រាដដែល ។ ឧទហរណ៍ ទាក់ទងនឹងការឱ្យកូនសម្តែងល្ខោនក្នុងទូរទស្សន៍ ប្រសិនបើ មិនមានការយល់ព្រមពីកូនទេ មេបាមិនអាចចុះកិច្ចសន្យាជាមួយអ្នកកម្មវិធីទូរទស្សន៍បានឡើយ) ។ ពាក្យ ថា"ដាយ ហ៊ិអូស្សឺ" ដែលមានចែងនៅក្នុងមាត្រា ៨២៤ គួរប្រែមកថាជា "ការតំណាង" ។ អ្នកមាន អំណាចមេបា គឺជាអ្នកតំណាងដែលច្បាប់បានកំណត់របស់កូន (មិនមែនជាតំណាងដែលផ្អែកលើកិច្ច សន្យាប្រគល់សិទ្ធិតំណាងទេ ។ គឺជាបុគ្គលដែលបានទទួលឋានៈជាអ្នកតំណាងដោយការកំណត់របស់ ច្បាប់) ។ ជាគោលការណ៍ អ្នកមានអំណាចមេបាមានសិទ្ធគ្រប់គ្រងលើទ្រព្យសម្បត្តិទាំងអស់របស់កូន ប៉ុន្តែអ្នកមានអំណាចមេបាមិនអាចអនុវត្តសិទ្ធិគ្រប់គ្រងនេះបានទេ ចំពោះទ្រព្យសម្បត្តិណាដែលអ្នកមាន អំណាច

មេបាបានផ្តល់សិទ្ធិអោយកូនចាត់ចែងក្នុងគោលដៅមានការកំណត់ទុកជាមុន (មាត្រា ៥) និងទ្រព្យសម្បត្តិសំរាប់អាជីវកម្មគ្រប់គ្រងដោយកូនដែលបានការអនុញ្ញាតិធ្វើអាជីវកម្មនោះ (មាត្រា ៦) ។

### ៤.២.៣. សកម្មភាពដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានភាពផ្ទុយគ្នា

សកម្មភាពប្រគល់ទ្រព្យសម្បត្តិរបស់កូនទៅអ្នកមានអំណាចមេបាជាផលប្រយោជន៍របស់អ្នកមានអំណាចមេបា ប៉ុន្តែវានាំឱ្យមានការខូចផលប្រយោជន៍ដល់កូន ។ សកម្មភាពដែលនាំឱ្យផលប្រយោជន៍របស់ឪពុកឬម្តាយមានអំណាចមេបានិងកូនមានភាពផ្ទុយគ្នាបែបនេះ គេហៅថាជាសកម្មភាពដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានភាពផ្ទុយគ្នា។ ចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានភាពផ្ទុយគ្នាបែបនេះ អ្នកមានអំណាចមេបាត្រូវទាមទារឱ្យតុលាការគ្រួសារជ្រើសតាំងតំណាង ពិសេសសំរាប់កូន (មាត្រា ៨២៦ កថាខ័ណ្ឌទី ១) ។ ប្រសិនបើមានកូនច្រើននាក់ហើយផលប្រយោជន៍កូនម្នាក់មានភាពផ្ទុយគ្នានឹងផលប្រយោជន៍របស់កូនដទៃទៀតនោះ ក៏គេត្រូវធ្វើការទាមទារដូចគ្នា ដែរ (មាត្រា ៨២៦ កថាខ័ណ្ឌទី ២) ។

## ៤.៣. អាណាព្យាបាល ហិតូបត្ថម្ភ និងអ្នកជំនួយ

### ៤.៣.១. និយមន័យ

អាណាព្យាបាលគឺជារបបមួយដែលបង្កើតឡើងដើម្បីការពារអនីតិជនដែលមិនអាចទទួលបានកិច្ចការពារពីអ្នកមានអំណាចមេបា និងដើម្បីការពារនិតិជននៅក្រោមអាណាព្យាបាល (ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិក្រោមបញ្ញត្តិនៃក្រមចាស់)។ បុគ្គលដែលបំពេញតួនាទី អាណាព្យាបាល ហៅថាអ្នកអាណាព្យាបាល ។ ដូច្នេះ សំរាប់អនីតិជនជាបឋមអ្នកមានអំណាចមេបា ត្រូវធ្វើជាអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជននោះ ។ ប៉ុន្តែបើគ្មានអ្នកមានអំណាចមេបា រី ក៏ក្នុងករណីដែលអ្នកមានអំណាចមេបានោះ មិនមានសិទ្ធិគ្រប់គ្រងអនិតិជន ពេលនោះត្រូវចាត់តាំង អោយមានអ្នកអាណាព្យាបាលសំរាប់អនីតិជន ។ អ្នកអាណាព្យាបាល ក៏ជាអ្នកតំណាងដែលច្បាប់បាន កំណត់ដែរ ។ សំរាប់នីតិជននៅក្រោមអាណាព្យាបាល ចាំបាច់ត្រូវមានអ្នកអាណាព្យាបាលសំរាប់នីតិជន ។ម្យ៉ាងទៀត គេក៏អាចចាត់តាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល សំរាប់ត្រួតពិនិត្យលើអ្នកអាណាព្យាបាល នោះបានដែរ (ចាប់ពីមាត្រា ៨៤៨ តទៅ) ។ ចំណែក ហិត្តូបត្ថម្ភ គឺជាប្រព័ន្ធដែលបង្កើតឡើងដើម្បីការពារជននៅក្រោមហិតូបត្ថម្ភ(ក្រមចាស់កំណត់ថាជាអ្នកដែលមានស្ថានភាពប្រហាក់ប្រហែលនឹងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ)។ បុគ្គលដែលបំពេញតួនាទីហិតូបត្ថម្ភកៈ នេះ ហៅថា ហិតូបត្ថម្ភកៈ ។ គួរសំគាល់ថា តាមក្រមរដ្ឋប្បវេណីចាស់ ហិត្តូបត្ថម្ភកៈ

គ្រាន់តែមានសិទ្ធិផ្ដល់ការយល់ស្របឬមិនយល់ស្របនៅពេលអ្នកដែលមានស្ថានភាពប្រហាក់ប្រហែលនឹងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនោះ ធ្វើសកម្មភាពខ្លះដែលបានកំណត់ទុកជាមុន តែប៉ុណ្ណោះ ។ ប៉ុន្តែ ក្រមថ្មីបានផ្ដល់សិទ្ធិឱ្យហិត្វូបត្ថម្ភកៈ លប់ចោលសកម្មភាពណាដែលជននៅក្រោមហិត្វូបត្ថម្ភបានអនុវត្តដោយមិនមានការយល់ស្របពីហិត្វូបត្ថម្ភកៈ ។ ហើយលើសពីនេះទៅទៀតហិត្វូបត្ថម្ភកៈថែមទាំងមានសិទ្ធិតំណាងផងដែរនៅក្នុងសកម្មភាពទាំងឡាយណាដែលភាគីបានជ្រើស រើសកំណត់ទុកជាមុន ។ ម្យ៉ាងទៀត តាមក្រមថ្មីនេះដែរគេក៏បានបង្កើតឱ្យមានប្រព័ន្ធជំនួយថ្មីសំរាប់ជនដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីកំរិតស្រាលដែលមិនធ្លាប់ជាកម្មវត្ថុការពារនៃក្រមចាស់នោះទេ។ (នេះក៏មានរៀបរាប់នៅក្នុងផ្នែកស្ដីពីបញ្ញត្តិទូទៅនៃក្រមរដ្ឋ ប្បវេណី ។ សូមអានជំពូកទី ២ III២ (៣)) ។

### ៤.៣.២. ការចាប់ផ្ដើមអាណាព្យាបាល

អាណាព្យាបាល ត្រូវចាប់ផ្ដើមនៅពេលដែលគ្មានអ្នកអនុវត្តអំណាចមេបាចំពោះអនីតិជនទេ ឬនៅពេលដែលអ្នកមានអំណាចមេបានោះមិនមានសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិ ឬមួយនៅពេលដែល មានសាលក្រមរបស់តុលាការគ្រួសារ កំណត់ការចាប់ផ្ដើមអាណាព្យាបាល ចំពោះនីតិជននៅក្រោម អាណាព្យាបាល (មាត្រា ៨៣៨)។

### ៤.៣.៣.ការជ្រើសតាំងអ្នកអាណាព្យាបាល និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល

អ្នកអាណាព្យាបាលសំរាប់អនីតិជនអាចត្រូវបានកំណត់តាមមតកសាសន៍របស់អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់បាន។ ម្យ៉ាងទៀត នៅពេលឪពុកឬម្តាយម្ខាង ដែលអនុវត្តអំណាចមេបាតែពុំមានអំណាចគ្រប់គ្រងទេនោះឪពុកឬម្តាយម្ខាងទៀតអាចកំណត់អ្នកអាណាព្យាបាលបាន (មាត្រា ៨៣៩) ។ ប្រសិនបើពុំមានការកំណត់ទាំងនេះទេ តុលាការគ្រួសារអាចជ្រើសតាំងអ្នកអាណាព្យាបាលសំរាប់អនីតិជនតាមការទាមទាររបស់អនិតិជននៅក្រោមអាណាព្យាលបាលនោះ ឬរបស់ញាតិ ឬអ្នក ដទៃទៀតដែលមានពាក់ព័ន្ធផលប្រយោជន៏ (មាត្រា ៨៤០) ។ អ្នកអាណាព្យាបាលអនីតិជន ត្រូវ មានតែម្នាក់គត់ (មាត្រា ៨៤២) ។ ចំណែកអ្នកអាណាព្យាបាលសំរាប់នីតិជនវិញ អាចត្រូវបាន ជ្រើសតាំងដោយឆន្ទានុសិទ្ធិរបស់តុលាការគ្រួសារ នៅពេលដែលតុលាការចេញសាលក្រមឱ្យចាប់ផ្តើម អាណាព្យាបាលនោះ ។ ទោះជាក្នុងករណីដែលអ្នកអាណាព្យាបា សំរាប់នីតិជន ត្រូវបានជ្រើសតាំង ហើយក៏ដោយ បើសិនជាតុលាការចាត់ទុកថាចាំបាច់ តុលាការក៏អាចជ្រើសតាំងអ្នកអាណព្យាបាល សំរាប់នីតិជនថែមទៀតបានដែរតាមការទាមទាររបស់នីតិជននៅក្រោមអាណាព្យាបាល ឬញាតិរបស់គេ ឬអ្នកដទៃទៀតដែលមានពាក់ព័ន្ធផលប្រយោជន៏ឬតាមការទាមទាររបស់អ្នកអាណាព្យាបាលផ្ទាល់ឬដោយប្រើឆន្ទនុសិទ្ធិរបស់តុលាការ (មាត្រា ៨៤៣) ។ អំពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល គឺមាន ការតែងតាំងតាមរបៀបខុសគ្នា។ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលណាសំរាប់អនីតិជន អាចត្រូវបាន កំណត់ដោយ

បុគ្គលដែលជាអ្នកអាចកំណត់អ្នកអាណាព្យាបាលសំរាប់អនីតិជនបាន ឬអាចត្រូវបានជ្រើស តាំងដោយតុលាការគ្រួសារ ។ ចំណែកអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសំរាប់នីតិជនវិញ គឺត្រូវជ្រើសតាំងតុលាការគ្រួសារ (ចាប់ពីមាត្រា ៨៤៨ តទៅ) ។

### ៨.៣.៤. តួនាទីរបស់អ្នកអាណាព្យាបាល និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល

អ្នកអាណាព្យាបាលសំរាប់អនីតិជន មានតួនាទីស្ទើរតែដូចគ្នានឹងអ្នកមានអំណាចមេបាដែរ ប៉ុន្តែ មានកំរិតខ្លះៗ (មាត្រា ៨៥៧) ។ អ្នកអាណាព្យាបាលសំរាប់នីតិជនមាន តួនាទីចាត់ចែងកិច្ចការទាក់ទងទៅនឹងជិវភាពនិងការថែទាំព្យាបាលរបស់នីតិជននៅក្រោមអាណាព្យាបាល ហើយនិងជាអ្នកតំណាងដែលច្បាប់បានកំណត់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការគ្រប់ គ្រងទ្រព្យសម្បត្តិនោះផងដែរ (មាត្រា ៨៥៨ និង ៨៥៩) ។ ចំពោះរាល់សកម្មភាពទាំងអស់នេះ ក្រមថ្មីមានបញ្ញត្តិបន្ថែម តម្រូវឱ្យមានការគោរពឆន្ទៈរបស់នីតិជននៅក្រោមអាណាព្យាបាល (មាត្រា ៨៥៨) ។ ចំណែកឯអ្នកត្រួតពិនិត្យអ្នកអាណាព្យាលបាលមានតួនាទីត្រូវត្រួតពិនិត្យកិច្ចការរបស់អ្នក អាណាព្យាបាល ។ ក្នុងករណីដែលគ្មានអ្នកអាណាព្យាបាលទេអ្នកត្រួតពិនិត្យនេះ ត្រូវទាមទារ ឱ្យតុលាការគ្រួសារ ជ្រើសតាំងអ្នកអាណាព្យាបាលនោះ ដោយពុំមានការយឺតយ៉ាវឡើយ (មាត្រា ៨៥១) ។

### ៤.៣.៥. ហិតូបត្ថម្ភកៈ និងអ្នកជំនួយ

ហិតូបត្ថម្ភកៈ មានអំណាចផ្តល់ការយល់ព្រមទៅសកម្មភាពមួយចំនួនកំណត់ របស់អ្នកដែលមានស្ថានភាពប្រហាក់ប្រហែលនឹងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ (ដូចជា ការលក់ដូរអចលនវត្ថុ ការធានា ការធ្វើប្រទានកម្ម ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ជាដើម) (មាត្រា ១២) ។ ម្យ៉ាងទៀត ហិតូបត្ថម្ភកៈក៏មានសិទ្ធិលុបចោល ឬសិទ្ធិតំណាងក្នុងសកម្មភាពជាក់លាក់ មួយចំនួនផងដែរ (សូមអានជំពូកទី **២** III ២(៣)) ។ ក្នុងប្រព័ន្ធអ្នកជំនួយដែលទើបនឹងបានបង្កើតថ្មីនោះអ្នកជំនួយក៏បានទទួលដូចគ្នាដែរនូវសិទ្ធិផ្តល់ការយល់ព្រម សិទ្ធិធ្វើការលុបចោល ឬសិទ្ធិតំណាង ចំពោះ សកម្មភាពគតិយុត្តិជាក់លាក់មួយចំនួនដែលភាគីបានជ្រើសរើសទុកជាមុន (សូមអានជំពូកទី ២ III ២(៣)) ។

# ជំពូកទី ៩

# ច្បាប់ស្តីពីសន្តតិកម្ម

I. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីសន្តតិកម្ម

១. រចនាសម្ព័ន្ធនៃសន្តតិកម្ម

II. ការសិក្សាអំពីចំនុចសំខាន់ៗរបស់ច្បាប់សន្តតិកម្ម

១. សន្តតិកម្មតាមច្បាប់

២. ការយល់ព្រម និងការបោះបង់សន្តតិកម្ម

៣. ការបែងចែកមតក

៤. សន្តតិកម្មតាមមតកសាសន៍

៥. ការបំបែកទ្រព្យសម្បត្តិ

៦. នត្ថិភាពនៃសន្តតិកម្ម

# I. ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីសន្តតិកម្ម

## ១. រចនាសម្ព័ន្ធនៃសន្តតិកម្ម

### ១.១. ការទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចតាមរយៈនៃការធ្វើសន្តតិកម្ម

បុគ្គលម្នាក់ដែលទទួលមរណភាពនឹងបាត់បង់នូវសមត្ថភាពទទួលសិទ្ធិ ។ ពោលគឺថាមិនអាចតាំងខ្លួនជាកម្មសិទ្ធិករ ឬជាម្ចាស់បំណុលបានទៀតឡើយ ។ ដូច្នេះហើយ ទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ ត្រូវមានការគិតគូរថា តើមានបុគ្គលណាផ្សេងទៀត នឹងទទួលបន្តជាម្ចាស់សិទ្ធិថ្មី លើទ្រព្យសម្បត្តិទាំងនោះដែរឬទេ ។ ចំណែកឯកាតព្វកិច្ចវិញ ប្រសិនបើគ្មានកូនបំណុលថ្មី ទទួលបន្តទេនោះ សុវត្ថិភាពរបស់ម្ចាស់បំណុលក៏មិនអាចធានាបានដែរ ។ វិធានទាំងឡាយ ទាក់ទងដល់ការទទួលបន្តនេះ សុទ្ធតែត្រូវបានកំណត់នៅក្នុងបញ្ញត្តិនៃច្បាប់ស្តីពីសន្តតិកម្ម ។ បុគ្គលដែលនឹងទទួលបន្តនូវ សិទ្ធិ និងករណីយកិច្ច ពីមនុស្សដែលស្លាប់ទៅ ហៅថា សន្តតិជន រីឯបុគ្គលដែលធ្វើសន្តតិកម្មនោះ ហៅថាមត៌កជន ។

### ១.២. សន្តតិកម្មតាមមត៌កសាសន៍ និងសន្តតិកម្មតាមច្បាប់

វិធានជាមូលដ្ឋានស្តីពីសន្តតិកម្មមានពីរ ។ វិធានទីមួយ គឺសន្តតិកម្មតាមមត៌កសាសន៍ ។ ដោយសារមានការទទួលស្គាល់នូវគោលការណ៍ស្វ័យភាពនៃឆន្ទៈ និងស្វ័យភាពបុគ្គលឯកជនជាគោលការណ៍គឺបុគ្គលម្នាក់ៗអាចធ្វើការសំរេចចិត្តដោយសេរីផងដែរ អំពីឋានៈនៃទ្រព្យសម្បត្តិ

របស់ខ្លួនក្រោយពេលដែលខ្លួនស្លាប់ទៅ ។ នេះអាចនឹងអនុវត្តទៅបាន តាមវិធីធ្វើមតិកសាសន៍ដែលជាសកម្មភាពឯកតោភាគី ។ ខ្លឹមសារមតិកសាសន៍អាចកំណត់ថា ម្ចាស់បណ្ដាំធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់របស់ខ្លួន ទៅឱ្យបុគ្គលណាម្នាក់ដែលមិនមែនជាញាតិលោហិត ឬធ្វើទាយជទានទៅឱ្យទីកន្លែងណាមួយជាដើម ក៏ប៉ុន្តែនៅប្រទេសជប៉ុន មានបង្កើតនូវប្រព័ន្ធមួយហៅថា ភាគបម្រុងនៃមតិកសាសន៍ ដែលមានដាក់កំហឹតយ៉ាងជាក់លាក់មកលើការធ្វើមតិកសាសន៍បៀបនេះ ដែលយើងនឹងពិពណ៌នាបន្ថែមនៅខាងក្រោយ (មានការធានានូវសិទ្ធិលើចំណែកណាមួយនៃមតិកចំពោះឪពុកម្ដាយ សហព័ទ្ធ និងកូន របស់ម្ចាស់បណ្ដាំ) ។ ប៉ុន្តែប្រសិនបើគ្មានការទាមទារនូវភាគបម្រុងនៃមតិកសាសន៍នេះទេ មតិកសាសន៍នោះ នឹងមានសុពលភាពដូចដែលម្ចាស់បណ្ដាំបានធ្វើ ។

វិធានទីពីរ គឺសន្តតិកម្មតាមច្បាប់ ដែលតាមរយៈវិធាននេះ ការបែងចែកទ្រព្យសម្បត្តិរបស់បុគ្គលដែលស្លាប់ ទៅឱ្យសាច់ញាតិស្របតាមសមាមាត្រមួយជាក់លាក់ ត្រូវបានកំណត់ដោយច្បាប់ ។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ទទួលស្គាល់ទាំងសន្តតិកម្មតាមមតកសាសន៍ទាំងសន្តតិកម្មតាមច្បាប់ ។ ប៉ុន្តែ មានការខ្វែងគំនិតគ្នាខាងផ្នែកទ្រឹស្ដី ចំពោះសំណួរថាគួតែយកវិធានណាមួយមកធ្វើជាគោលការណ៍ចំបងនោះ ។ មានអំណះអំណាងខ្លាំងក្លាមួយបានលើកឡើងថាបើក្រឡេកមើលពីទស្សនៈវិស័យរបស់ស្វ័យភាពនៃឆន្ទៈសន្តតិកម្មតាមមតិកសាសន៍គឺជាវិធានបញ្ញត្តិជាគោលការណ៍ ចំណែកឯសន្តតិកម្មតាមច្បាប់វិញគ្រាន់តែជាវិធានបំពេញ បន្ថែម

សំរាប់ពេលដែលមិនមានការចែងកំណត់ក្នុងមតិកសាសន៍តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែបើផ្អែកទៅតាមការអនុវត្តន៍របស់ប្រទេសជប៉ុនវិញ ដោយមិនទាន់មានការនិយមសរសេរ ជាលិខិតមតិកសាសន៍ សន្តតិកម្មតាមច្បាប់ហាក់ដូចជាត្រូវបានគេចាត់ទុកថាជាបញ្ញត្តិគោលការណ៍ ចំណែកឯការបែកចែកមតិកតាមមតិកសាសន៍ ត្រូវបានធ្វើឡើងលុះត្រាតែគ្មាន បំណងបែងចែកទៅតាមការកំណត់នៅក្នុងសន្តតិកម្មតាមច្បាប់តែប៉ុណ្ណោះ ។ នេះគឺជាការគំនិតយល់ឃើញទូទៅ ។

## ១.៣. អានុភាពនៃសន្តតិកម្ម

សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់ មតិកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម (មាត្រា៨៩៦) ។ ប៉ុន្តែ ត្រូវបានលើកលែងចំពោះវត្ថុទាំងឡាយណាដែលជារបស់ផ្តាច់មុខទាំងស្រុងរបស់ មតិកជន (សិទ្ធិ និងករណីកិច្ចដែលមរតកជនមានសំរាប់តែខ្លួនឯង)។ សិទ្ធិផ្តាច់មុខរបស់មតកជនមានដូចជា សិទ្ធិទាមទារអាហារកាតព្វកិច្ច និងសិទ្ធិទទួលបានជំនួយជីវភាពប្រចាំថ្ងៃជាដើម ។ ចំណែកករណីកិច្ចផ្តាច់មុខវិញ មានដូចជាកាតព្វកិច្ចធានា ដែលមានចែងនៅក្នុងកិច្ចសន្យាធានាចំពោះបុគ្គលណាម្នាក់ជាដើម ។ ក្នុងករណីដែលមានសន្តតិជនច្រើននាក់ មតិកត្រូវបែងចែកក្នុងចំណោមសហសន្តតិជនទាំងនោះ (មាត្រា៨៩៨) ហើយសន្តតិជនម្នាក់ៗត្រូវទទួលបន្តនូវ សិទ្ធិ និង ករណីកិច្ចរបស់ មតិកជន តាមសមាមាត្រនៃចំណែកមតិកដែលខ្លួនទទួលបាន (មាត្រា៨៩៩) ។

# II. ការសិក្សាអំពីចំនុចសំខាន់ៗរបស់ច្បាប់សន្តតិកម្ម

## ១. សន្តតិកម្មតាមច្បាប់

### ១.១. សន្តតិជនតាមច្បាប់

ផ្អែកលើសន្តតិកម្មតាមច្បាប់ ជាលទ្ធផលនៃមរណភាពរបស់មតកជន បុគ្គលដែលច្បាប់បានកំណត់នឹងក្លាយទៅជាសន្តតិជន (យោងតាមមាត្រា៨៨២ ចំនុចចាប់ផ្តើមសន្តតិកម្មគឺបន្ទាប់ពីមរណភាពរបស់មតកជន) ។ តើអ្នកណានឹងក្លាយទៅជាសន្តតិជន (សន្តតិជនតាមច្បាប់) ដែលទទួលបន្តមតកតាមការកំណត់របស់ច្បាប់នេះ? ដំបូង ប្រសិនបើមតកជនមាន សហព័ទ្ធ (ពោលគឺក្នុងករណីប្តីជាមតកជននោះប្រពន្ធគឺជាសន្តតិជន) សហព័ទ្ធនោះត្រូវក្លាយជា សន្តតិជនជានិច្ច (មាត្រា៨៩០) ហើយមានលំដាប់ស្មើគ្នានឹងញាតិលោហិតរបស់មតកជន ដែលមានអធិប្បាយខាងក្រោមនេះដែរ (ប៉ុន្តែ បុគ្គលដែលរស់នៅជាមួយគ្នាដូចប្តីប្រពន្ធប៉ុន្តែមិនបានចុះលិខិតអាពាហ៍ពិពាហ៍មិនត្រូវបានច្បាប់ទទួលស្គាល់សិទ្ធិសន្តតិកម្មឡើយ) ។ សន្តតិជន ដែលជាញាតិលោហិតនោះ ត្រូវបានចាត់ជាលំដាប់ផ្សេងៗ ។ សន្តតិជនលំដាប់ទីមួយគឺកូនរបស់មតកជន (មាត្រា៨៨៧ កថាខ័ណ្ឌទី១) ។ ប៉ុន្តែក្នុងករណីដែលកូនរបស់មតកជនស្លាប់ មុនពេលចាប់ផ្តើមសន្តតិកម្ម (ពោលគឺមុនមរណភាពរបស់មតកជន) កូនរបស់បុគ្គលនោះ (ក្នុងករណីនេះ គឺជាចៅរបស់មតកជន) ដែលជាបច្ឆាញាតិផ្ទាល់ (ចៅគឺជាញាតិលោហិតជំនាន់ក្រោយដែលមានទំនាក់ទំនងខ្សែផ្ទាល់នឹងមតកជន) ត្រូវក្លាយជាសន្តតិជនជំនួស (នេះហៅថា សន្តតិកម្មជំនួស យោង

តាមមាត្រា ៨៨៧ កថាខ័ណ្ឌទី២) ។ លើសពីនេះទៅទៀត ទាក់ទងនឹងសន្តតិកម្មនេះ ក្រមរដ្ឋប្បវេណីទទួលស្គាល់នូវសិទ្ធិសន្តតិកម្មរបស់ទារកនៅក្នុងគភ៌ដែរ ដោយមានចែងជាបញ្ញត្តិចាត់ទុកទារកនៅក្នុងគភ៌ ដូចគ្នានឹងមនុស្សដែលបានចាប់កំណើតមានជីវិតរួចហើយនោះ (មាត្រា ៨៨៦ កថាខ័ណ្ឌទី១ ។ ប៉ុន្តែ បញ្ញត្តិនេះមិនអនុវត្តចំពោះកូនដែលកើតហើយស្លាប់នោះទេ យោងតាមមាត្រា ៨៨៦ កថាខ័ណ្ឌ ទី២) ។ ក្នុងករណីដែលមតកជន គ្មានទាំងកូន គ្មានទាំងចៅនោះ សន្តតិជននឹងត្រូវបានកំណត់ទៅតាមលំដាប់លំដោយដូចតទៅ ។ ដំបូងគឺបុព្វញាតិផ្ទាល់របស់សន្តតិជន ត្រូវក្លាយជាសន្តតិជនលំដាប់ទីពីរ (ឳពុកម្តាយ ជីដូនជីតាដែលជាញាតិលោហិតជំនាន់មុនហើយដែលមានទំនាក់ទំនាក់ខ្សែផ្ទាល់នឹងមតកជន ។ ប៉ុន្តែឳពុកម្តាយរបស់មតកជន មានអាទិភាពជាងជីដូនជីតារបស់មតកជន) ។ បន្ទាប់មកទៀតគឺបងប្អូនបង្កើតរបស់មតកជន ដែលជាសន្តតិជនលំដាប់ទីបី ។ ហេតុដច្នេះ គួឱ្យកត់សំគាល់ថាក្នុងចំណោមសន្តតិជនជាញាតិលោហិត បើសិនជាមានកូន (ឬបច្ឆាញាតិផ្ទាល់របស់កូននោះ) គឺបុព្វញាតិផ្ទាល់ ដូចជាឳពុកម្តាយជាដើម មិនត្រូវក្លាយជាសន្តតិជនទេ ។ ហើយលុះត្រាតែគ្មានបច្ឆាញាតិ ឬបុព្វញាតិណាម្នាក់ទាល់តែសោះ ទើបបងប្អូនបង្កើត (ឬបច្ឆាញាតិរបស់ពួកគេ) អាចក្លាយជាសន្តតិជនបាន (មាត្រា ៨៨៩) ។

ដោយឡែក ជនដែលបានទទួលទោសពីបទប៉ុនប៉ងធ្វើឃាតលើមតកជន ឬជនដែលបានមតកជនធ្វើមតកសាសន៍ដោយការឆបោក ឬដោយការគម្រាមកំហែង ពុំអាចក្លាយជាសន្តតិជនបានឡើយ (មាត្រា ៨៩១ ស្តីពីមូលហេតុនៃអភ័ព្វបុគ្គលនៃសន្តតិកម្ម) ។ លើសពីនេះទៅទៀត ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង (យោងតាមកថាខ័ណ្ឌមុនគឺសន្តតិជនដែលមានលំដាប់រហូតដល់លំដាប់ទីពីរ) បើសិនបានធ្វើបាបមតកជន ឬបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់នោះ មតកជនអាចដាក់ពាក្យសុំទៅតុលាការគ្រួសារឱ្យផ្តាច់មតិកពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះបាន (មាត្រា ៨៩២ ស្តីពី ការផ្តាច់មតិកពីសន្តតិជន) ។

## ១.២. ចំណែកមតិកដែលកំណត់ដោយច្បាប់

ក្នុងករណីដែលមានមនុស្សច្រើន ជាសន្តតិជនតាមច្បាប់កំណត់ដែលមានលំដាប់ដូចគ្នា ក្រមរដ្ឋប្បវេណី មាត្រា ៩០០ចែងអំពីចំណែកមតិកដូចខាងក្រោមនេះ :

ក- បើសហព័ទ្ធ និងកូន ជាសន្តតិជន សហព័ទ្ធ និងកូននោះទទួលចំណែកមតិកស្មើគ្នា គឺម្នាក់មួយភាគពីរ ។ ប៉ុន្តែបើសិនកូនមានពីរនាក់ ចំណែករបស់កូន ត្រូវបែងចែកស្មើគ្នាជាមួយភាគពីរទៀត (ម្នាក់បានពាក់កណ្តាល) គឺមានន័យថាកូនម្នាក់ទទួលបានចំណែកត្រូវជាមួយភាគបួន ។

ខ- បើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ជាសន្តតិជន សហព័ទ្ធទទួលបានចំណែកមតិក ពីរភាគបី ចំណែកឯបុព្វញាតិផ្ទាល់ទទួលបាន មួយភាគបី ។ បើបុព្វញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមតិករបស់បុព្វញាតិផ្ទាល់នោះត្រូវបែងចែកស្មើគ្នាឱ្យដល់ម្នាក់ៗ ។

គ- បើសហព័ទ្ធ និងបងប្អូនបង្កើតរបស់មតកជនជាសន្តតិជន សហព័ទ្ធទទួលបានចំណែកមតិក បីភាគបួន ចំណែកបងប្អូនបង្កើតរបស់មតកជនទទួលបានមួយភាគបួន ។ បើបងប្អូនបង្កើតរបស់មតកជនមានចំនួនច្រើននាក់ នោះចំណែកមតិករបស់បងប្អូនបង្កើតនោះត្រូវបែងចែកស្មើគ្នាឱ្យដល់ម្នាក់ៗ ។

ឃ- ចំណែកមតិករបស់កូនអត់ខ័ន្តស្លា ត្រូវស្មើនឹងមួយភាគពីរនៃចំណែកមតិករបស់កូនមានខ័ន្តស្លា ។ ចំណែកមតិករបស់បងប្អូនដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមានមួយភាគពីរនៃចំណែកមតិករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា ។

**ពាក្យគន្លឹះ** ចំណែកមតិករបស់សហព័ទ្ធ

យោងបញ្ញត្តិជាធរមាននៃក្រមរដ្ឋប្បវេណី ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ១៩៨០ ចំណែកមតិករបស់សហព័ទ្ធ មានការកើនឡើងច្រើនជាងបញ្ញត្តិនៅក្នុងក្រមចាស់ (បញ្ញត្តិនាឆ្នាំ ១៩៤៧) ។ ការអធិប្បាយដូចខាងលើនេះ បើសិនយើងរៀបចំជាតារាង គឺមានលក្ខណៈដូចខាងក្រោម ។

| លំដាប់ទីមួយ<br>ញាតិលោហិតជាសន្តតិជន<br>និងសហសន្តតិកម្ម | | លំដាប់ទីពីរ<br>ញាតិលោហិតជាសន្តតិជន<br>និងសហសន្តតិកម្ម | | លំដាប់ទីបី<br>ញាតិលោហិតជាសន្តតិជន<br>និងសហសន្តតិកម្ម | |
|---|---|---|---|---|---|
| សហព័ទ្ធ | កូន | សហព័ទ្ធ | បុព្វញាតិផ្ទាល់ | សហព័ទ្ធ | បងប្អូនបង្កើត |
| ១ ភាគ ២ | ១ ភាគ ២ | ២ ភាគ ៣ | ១ ភាគ ៣ | ៣ ភាគ ៤ | ១ ភាគ ៤ |

មាត្រា ៩០១ នៃក្រមរដ្ឋប្បវេណី មានចែងចំពោះចំណែកមត៌ករបស់សន្តតិជនជំនួស ដែលមានបញ្ញត្តិនៅក្នុងកថាខ័ណ្ឌទី២ និង ទី៣ នៃមាត្រា ៨៨៧ នោះថា បើសិនបច្ឆាញាតិផ្ទាល់ជាសន្តតិជនជំនួស (ពោលគឺបើសិនកូនរបស់មតកជនជាសន្តតិជនទទួលមរណភាព ចៅរបស់មតកជនត្រូវក្លាយជាសន្តតិជនជំនួស) បច្ឆាញាតិផ្ទាល់នោះត្រូវទទួលចំណែកមត៌ក ស្មើគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់ខ្លួនត្រូវទទួលបាន ។ ក៏ប៉ុន្តែ បើសិនជាមានបច្ឆាញាតិផ្ទាល់ច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះទទួលបាន ត្រូវបែងចែងតាមបញ្ញត្តិនៃមាត្រា ៩០០ (យោងតាមមាត្រា ៩០១ កថាខ័ណ្ឌទី១ បើសិនជាចៅមានចំនួនច្រើននាក់ ចំណែកមត៌ករបស់កូនរបស់មតកជនដែលបានស្លាប់ទៅនោះ ត្រូវយកមកបែងចែកស្មើៗគ្នារវាងចៅៗទាំងអស់របស់មតកជននោះ) ។

ចំណែកឯករណីដែលសន្តតិជនជំនួសគឺជា កូនរបស់បងប្អូនបង្កើតរបស់មតកជនវិញ (មានន័យថាបើសិនបងប្អូនបង្កើតរបស់មតកជន ដែលក្លាយជាសន្តតិជនពិតប្រាកដរួចហើយ ទទួលមរណភាព កូនរបស់បុគ្គលនោះត្រូវក្លាយជាសន្តតិជនជំនួស) ការបែងចែកចំណែកមតិក ត្រូវធ្វើឡើងដូចគ្នានឹងការបែងចែងមតិកខាងលើនេះដែរ (មាត្រា៩០១ កថាខ័ណ្ឌទី២) ។

## ១.៣. ចំណែកមតិកដែលបានកំណត់

តាមមាត្រា ៩០២ នៃក្រមរដ្ឋប្បវេណី ដោយមិនពាក់ព័ន្ធនឹងបញ្ញត្តិនៅក្នុងមាត្រាទាំង ២ខាងលើនេះ មតកជនអាចកំណត់ចំណែកមតិករបស់សហសន្តតិជនតាមមតកសាសន៍ ឬអាចប្រគល់អាណត្តិឱ្យតតិយជនជាអ្នកកំណត់បាន ក៏ប៉ុន្តែមតកជនឬតតិយជនដែលបានទទួលអាណត្តិនោះ មិនអាចកំណត់អ្វីឱ្យផ្ទុយពីបញ្ញត្តិច្បាប់ស្តីពីភាគបម្រុងទេ (មាត្រា ៩០២ កថាខ័ណ្ឌទី១ ។ ទាក់ទងនឹងភាគបម្រុង សូមបើកមើលផ្នែក ២-៤-៤ នៅខាងក្រោម)។

លើសពីនេះទៀត បើមតកជនបានកំណត់ចំណែកមតិករបស់សន្តតិជនតែម្នាក់ ឬច្រើន នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ឬ បើមតកជនបានឱ្យគេកំណត់យ៉ាងដូច្នេះហើយ នោះ ចំណែកមតិករបស់សហសន្តតិជនផ្សេងទៀត (ចំណែកមតិកដែលមិនបានកំណត់) ត្រូវបែងចែកតាមបញ្ញត្តិនៃមាត្រាទាំង ២ ខាងលើ (មាត្រា ៩០២ កថាខ័ណ្ឌ ទី២)។

## ១.៤. សមភាពរវាងសន្តតិជន

### ១.៤.១. ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

បើសិនជាមានសន្តតិជនតាមច្បាប់ច្រើននាក់ ហើយមានសន្តតិជនខ្លះក្នុងចំណោមសហសន្តតិជនទាំងអស់នោះ បានទទួលពីមតកជននូវប្រទានកម្មពិសេសនៅពេលដែលមតកជននៅរស់ ឬបានទទួលអច្ច័យទានតាមបណ្តាំមតកសាសន៍ ក្នុងករណីខ្លះ ការគណនាចំណែកមត៌កត្រូវចាត់ទុកប្រទានកម្មនិងអច្ច័យទានទាំងនេះថា ជាចំណែកមត៌កដែលប្រគល់ឱ្យមុន ។ ច្បាប់កំណត់ថា របស់ទាំងអស់នេះត្រូវរាប់បញ្ចូលជាមត៌ក ហើយត្រូវគណនាទៅក្នុងចំណែកមត៌កភាគ (ចំពោះភាគណាដែលបានទទួលផលប្រយោជន៍រួចស្រេចហើយនោះ គឺត្រូវដកចេញពីចំណែកមត៌កដែលត្រូវទទួលបាន) ។ នេះគឺជាប្រព័ន្ធនៃការប្រមូលមកវិញនូវផលប្រយោជន៍ពិសេសដែលបុគ្គលទទួលបាន (មាត្រា ៩០៣) ។ ការទទួលផលប្រយោជន៍ពិសេស គឺមានដូចជាការទទួលនូវឧបត្ថម្ភសំរាប់ថ្លៃសាលា ខ្ពស់ជាងការទទួលបានរបស់សន្តតិជនផ្សេងទៀត ឬប្រទានកម្មជាអចលនវត្ថុសំរាប់ថ្លៃអាពាហ៍ ពិពាហ៍ជាដើម ។

### ១.៤.២. ភាគនៃវិភាគទាន

ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាម្នាក់បានធ្វើវិភាគទាន ពិសេសដើម្បីថែរក្សាឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ឬបានថែរក្សាមតកជន និង បានផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន នោះតំរូវឱ្យមានការគណនាឱ្យបានសមរម្យលើចំណែកមត៌ក

ដោយឆ្លុះបញ្ចាំងពីវិភាគទានដែលបុគ្គលនោះបានធ្វើ ។ ផ្អែកតាមការយល់ឃើញបែបនេះហើយ ទើបមានបទបញ្ញត្តិបន្ថែមអំពីភាគនៃវិភាគទាន នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩៨០ (មាត្រា ៩០៤ កថាខ័ណ្ឌទី២)។ ដូច្នេះ ក្នុងករណីដែលមានវិភាគទានដូចបានរៀបរាប់ខាងលើនេះ ច្បាប់ទទួលស្គាល់ចំនួនទឹកប្រាក់សរុបនៃចំណែកមតិក ដែលមានបូកបញ្ចូលនូវភាគនៃវិភាគទានតែប៉ុណ្ណោះ ហើយតំលៃនៃវិភាគទាននេះ តំរូវឱ្យមានការវាយតំលៃជាទឹកប្រាក់ដោយយោងលើសាលក្រមរបស់តុលាការគ្រួសារ ឬដោយផ្អែកលើការពិគ្រោះគ្នារវាងសហសន្តតិជន។

## ២. ការយល់ព្រម និងការបោះបង់សន្តតិកម្ម

សន្តតិកម្មគឺជាការទទួលបន្តនូវទំនាក់ទំនងដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិទាំងមូលរបស់មតកជន (ការទទួលបន្តទាំងស្រុង) ។ ក្នុងករណីដែលមតកជនបានជាប់បំណុលមុនពេលទទួលមរណភាព បំណុលនោះក៏ត្រូវគិតបញ្ចូលទៅក្នុងមតិកដែរ ។ អាស្រ័យលើកាលៈទេសៈនីមួយៗ មានពេលខ្លះបំណុលអាចច្រើនជាងទ្រព្យសម្បត្តិទៅទៀត ។ ក្នុងករណីបែបនេះ តើបុគ្គលដែលត្រូវបានចាត់ទុកថាជាសន្តតិជននោះ ដាច់ខាតត្រូវតែទទួលមតិកដោយសន្តតិកម្មដែរឬទេ? បើគេពិចារណាទៅលើទស្សនៈនៃស្វ័យភាពខាងឆន្ទៈរបស់បុគ្គលម្នាក់ៗ គឺគេគប្បីផ្ដល់ឱកាសឱ្យសន្តតិជនធ្វើការសំរេចចិត្តដោយខ្លួនឯង ។ ក្នុងន័យនេះហើយទើបក្រមរដ្ឋប្បវេណីទទួលស្គាល់នូវជំរើសបីដល់សន្តតិជន ទី១_ បដិសេធន៍ទាំងស្រុង នូវការទទួលបន្តទ្រព្យសម្បត្តិ

(ការបោះបង់សន្តតិកម្ម) ទី២_ ទទួលយកទាំងស្រុងនូវការទទួលបន្តទ្រព្យសម្បត្តិ (ការយល់ព្រមទាំងស្រុង) ឬ ទី៣_ ទទួលខុសត្រូវលើសំណងកាតព្វកិច្ចជាអវិជ្ជមានផ្សេងៗ ត្រឹមកម្រិតនៃទ្រព្យសម្បត្តិជាវិជ្ជមាន ដែលខ្លួនបានទទួលតាមរយៈសនតតិកម្មតែប៉ុណ្ណោះ (ការយល់ព្រមដោយមានកម្រិត) (ជាការពិតប្រាកដណាស់ មិនអាចមានជំរើសទទួលតែទ្រព្យសម្បត្តិជាវិជ្ជមានដោយមិនទទួលខុសត្រូវលើបំណុលបានទេ) ។ សន្តតិជនត្រូវធ្វើការជ្រើសរើសណាមួយក្នុងចំណោមជំរើសទាំងបីខាងលើនេះ ក្នុងអំឡុងពេល៣ខែ (អំឡុងពេលសំរាប់ពិចារណា) គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម (មាត្រា ៩១៥ កថាខ័ណ្ឌទី១) ។

**ក. ការបោះបង់សន្តតិកម្ម** បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវធ្វើសេចក្តីថ្លែងការណ៍ពីការបោះបង់សន្តតិកម្ម ទៅតុលាការគ្រួសារ (មាត្រា ៩៣៨) ហើយបុគ្គលនោះត្រូវបានចាត់ទុក ថាមិនមែនជាសន្តតិជនតាំងពីដំបូងមក (មាត្រា ៩៣៩) ។

**ខ. ការយល់ព្រមទាំងស្រុង** សន្តតិជនដែលបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកំរិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន (មាត្រា ៩២០) ។ នៅក្នុងករណីដែលសន្តតិជនបានចាត់ចែងមតកទាំងអស់ ឬមួយភាគ និងក្នុងករណីដែលសន្តតិជនមិនបានយល់ព្រមដោយមានកម្រិត ឬបោះបង់ នៅក្នុងអំឡុងពេល៣ខែ បន្ទាប់ពីបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ ផ្តើមនោះនឹងត្រូវចាត់ទុកថាសន្តតិជនបានយល់ព្រមទាំងស្រុងហើយ (មាត្រា ៩២១) ។

**គ. ការយល់ព្រមដោយមានកម្រិត** សន្តតិជនដែលមានបំណងចង់យល់ព្រមដោយមានកម្រិត

ត្រូវធ្វើសេចក្ដីថ្លែងការណ៍នៃការយល់ព្រមដោយមានកម្រិតនោះ ដោយត្រូវធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ រួចហើយដាក់ជូនតុលាការគ្រួសារ នៅក្នុងអំឡុងពេល៣ខែ បន្ទាប់ពីបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម (មាត្រា ៩២៤)។ ប៉ុន្តែបើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយមានកម្រិតនេះអាចធ្វើទៅបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ (មាត្រា ៩២៣) ពីព្រោះថា បើមិនធ្វើដូច្នេះទេ ទំនាក់ទំនងផ្លូវច្បាប់នឹងមានលក្ខណៈស្មុគស្មាញ ហេតុនេះហើយ បើទោះបីជាក្នុងចំនោមសហសន្តតិជនទាំងអស់ មានសន្តតិជនតែម្នាក់ដែលទាមទារធ្វើការបដិសេធន៍ ឬយល់ព្រមសន្តតិកម្ម ក៏ការយល់ព្រមដោយមានកម្រិតមិនអាចធ្វើទៅរួចដែរ (ផ្ទុយទៅវិញ បើសិនសហសន្តតិជនផ្សេងទៀត បោះបង់សន្តតិកម្ម ហើយនៅសល់សន្តតិជនតែម្នាក់ សន្តតិជននោះអាចធ្វើការយល់ព្រមដោយមានកម្រិតបាន) ។

## ៣. ការបែងចែកមត៌ក

ករណីដែលមានសន្តតិជនច្រើននាក់ គេត្រូវប្រមូលមត៌កទាំងអស់មកធ្វើជាកម្មសិទ្ធិរួមរបស់សហសន្តតិជនទាំងអស់នោះជាមុនសិន ទើបធ្វើការផ្ទេរចុងក្រោយនូវមត៌កដល់សន្តតិជនីមួយៗតាមនិតិវិធីនៃការបែងចែកមត៌ក ។ ការបែងចែកមត៌កមានពីរប្រភេទគឺ ការបែងចែកដោយការពិភាក្សារវាងសហសន្តតិជន និងការបែងចែកដោយតុលាការ (មាត្រា ៩០៧) ។ គេសង្កេតឃើញថា ជំលោះជាច្រើនលើបញ្ហាសន្តតិកម្ម ច្រើនកើតឡើងនៅក្នុងដំណាក់កាលបែងចែកមត៌កនេះ ។ ជាការពិតណាស់ដែលថា ប្រសើរបើអាចរៀបចំឱ្យមានការពិភាក្សារវាង

សន្តតិជនបាន ការបែងចែកដីដែលជាសន្តតិកម្មរួមអាចនឹងធ្វើទៅតាមការសំរេចរបស់សន្តតិជនទាំងអស់ ដោយមិនចាំបាច់រៀបចំចែកជាឡូត៍ដីទេ គឺទុកដូចដើមដដែលសំរាប់ប្រើប្រាស់រួមគ្នាស្របតាមចំណែកមត៌កក៏បានដែរ ។ មតកជនក៏អាចកំណត់នូវវិធីជាក់លាក់សំរាប់បែងចែកមត៌កបានដែរ នៅក្នុងមតកសាសន៍របស់ខ្លួនដូចមានអធិប្បាយនៅខាងក្រោមនេះ (មាត្រា ៩០៨) ។ ការបែងចែកមត៌កដោយតុលាការ គឺត្រូវធ្វើឡើងដោយផ្អែកតាមនិតិវិធីសវនាការរបស់តុលាការគ្រួសារ ។

# ៤. សន្តតិកម្មតាមមតកសាសន៍

## ៤.១. ទម្រង់នៃមតកសាសន៍

ដោយហេតុផលថា មតកសាសន៍ចាប់មានអានុភាព បន្ទាប់ពីមរណភាពរបស់មតកជន (យោងតាមមាត្រា ៩៨៥) ក្រមរដ្ឋប្បវេណី តម្រូវឱ្យមតកសាសន៍ធ្វើទៅតាមទម្រង់យ៉ាងហ្មត់ចត់ និងច្បាស់លាស់ ដើម្បីយល់ឱ្យបានច្បាស់លាស់នូវឆន្ទៈតាំងពីដំបូងរបស់មតកជន និងដើម្បីជៀសវាងនូវរាល់ការប៉ុនប៉ងក្លែងបន្លំពីជនដ៏ទៃទៀត (យោងតាមមាត្រា ៩៦០ បើសិនមិនអនុលោមតាមទម្រង់ដែលកំណត់ដោយក្រមរដ្ឋប្បវេណីទេ មតកសាសន៍ពុំអាចធ្វើបានឡើយ) ។ ទម្រង់ធម្មតា (មាត្រា ៩៦៧) ត្រូវកំណត់ជាបីប្រភេទ រួមមាន មតកសាសន៍ដោយលិខិតសរសេរផ្ទាល់ដៃ មតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់ ចំណែកឯទម្រង់ពិសេសវិញ (យោងតាមករណីលើកលែងរបស់មាត្រា ៩៦៧) គឺមាន

មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ និងមតកសាសន៍របស់ជនដែលស្ថិតនៅទីកន្លែងដាច់ដោយឡែក (យោងតាមបញ្ញត្តិលើកលែងនៃមាត្រា ៩៧៦ មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត គឺធ្វើនៅពេលដែលបុគ្គលណាម្នាក់កំពុងជួបប្រទះនឹងគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺធ្ងន់ធ្ងរ ឬដោយហេតុការណ៍ផ្សេងទៀត ដោយមានវត្តមានរបស់សាក្សីយ៉ាងតិចបីនាក់នៅនឹងកន្លែង ហើយដែលធ្វើឡើងតាមវិធីការប្រកាសដោយផ្ទាល់មាត់ចំពោះសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងនោះ ដើម្បីឱ្យសាក្សីរូបនោះធ្វើការកត់ត្រាទុក ។ មតកសាសន៍ដែលធ្វើតាមវិធីនេះ អាចហៅម៉្យាងទៀតថាជាមតកសាសន៍នៅដង្ហើមចុងក្រោយ) ។ ក្នុងករណីដែលមិនមានមតកសាសន៍ ឬនៅពេលដែលមតកសាសន៍មិនមានអានុភាពទេ នោះគេត្រូវរៀបចំសន្តតិកម្មតាមច្បាប់ ។

### ៩.១.១. មតកសាសន៍ដោយលិខិតសរសេរផ្ទាល់ដៃ

មតកសាសន៍ដោយលិខិតសរសេរ ផ្ទាល់ដៃ គឺជាទម្រង់មតកសាសន៍ងាយស្រួលធ្វើបំផុតដែលម្ចាស់បណ្តាំអាចសសេរបាន ដោយ មិនត្រូវការជំនួយពីជនណាម្នាក់ឡើយ ។ ប៉ុន្តែម្ចាស់បណ្តាំ ត្រូវសរសេរពាក្យទាំងអស់ ចុះថ្ងៃ ខែឆ្នាំនិងសសេរឈ្មោះដោយខ្លួនឯង ហើយត្រូវបោះត្រាលើលិខិតនោះ ។ ការបន្ថែម ការលុប ឬការកែប្រែផ្សេងទៀតពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែងដែល កែប្រែ និងសរសេរបន្ថែមនូវហេតុនៃការកែប្រែដោយមានចុះហត្ថលេខា ហើយថែមទាំងបោះ

ត្រាចំណាំកន្លែងបន្ថែម លុបចោល ឬកែប្រែទេនោះ (មាត្រា ៩៦៨) ។

## ៩.១.២. មតកសាសន៍ដោយលិខិតយថាភូត

មតកសាសន៍ដោយលិខិតយថាភូត គឺជា មតកសាសន៍ដែលសារការីធ្វើឱ្យម្ចាស់បណ្តាំតាមទម្រង់ដូចតទៅ: ១. ត្រូវមានវត្តមានរបស់ សាក្សីយ៉ាងតិចពីរនាក់ ។ ២. ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះ សារការី ។ ៣. សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយ លក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់ ឬឱ្យមើល (បញ្ញត្តិដែលទាក់ទង ដល់ការអាននេះត្រូវបានបន្ថែមនៅពេលធ្វើវិសោធនកម្មច្បាប់នៅខែមេសា ឆ្នាំ ២០០០) ។ ៤. ម្ចាស់បណ្តាំ និងសាក្សីត្រូវចុះហត្ថលេខា ឬបោះត្រា បន្ទាប់ពីបានទទួលស្គាល់ពីភាពត្រឹមត្រូវនៃកំណត់ជាលាយលក្ខណ៍អក្សរនោះហើយ ។ ៥. សារការីត្រូវចុះហត្ថលេខា និងបោះត្រាលើចំណារបន្ថែមដែលបញ្ជាក់ថា មតកសាសន៍ត្រូវបានធ្វើឡើងដោយអនុលោមតាមទម្រង់ខាងលើនេះ (មាត្រា ៩៦៩) ។ ការធ្វើតាមទម្រង់បែបនេះ មានលក្ខណៈស្មុគស្មាញ ប៉ុន្តែច្បាស់លាស់ ។ ដោយឡែក នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ម្ចាស់បណ្តាំនោះ អាចជំនួសការប្រាប់ដែលតម្រូវក្នុងចំណុចទី២បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍នោះ តាមការបកប្រែរបស់អ្នកបកប្រែភាសាដៃ ឬសសេរផ្ទាល់ដៃ ។ ដូចគ្នាដែរ ប្រសិនបើ ម្ចាស់បណ្តាំ ឬសាក្សី ជាមនុស្សដែលមិនអាចស្តាប់បាន

សារការីអាចឱ្យអ្នកបកប្រែភាសាដៃនោះ បកប្រែខ្លឹមសារនៃមតកសាសន៍ប្រាប់ម្ចាស់បណ្តាំ ឬសាក្សី ជំនួសឱ្យចំនុចទី៣ដែលតម្រូវឱ្យសារការីសូត្រឱ្យម្ចាស់បណ្តាំនិងសាក្សីស្តាប់នោះបាន (ចំនុចនេះគឺយោងតាមមាត្រា ៩៦៩ កថាខ័ណ្ឌ២ ដែលត្រូវបានបន្ថែមនៅពេលធ្វើវិសោធនកម្មច្បាប់នៅខែមេសា ឆ្នាំ ២០០០) ។

## ៩.១.៣. មតកសាសន៍ដោយលិខិតសំងាត់

មតកសាសន៍ដោយលិខិតសំងាត់ គឺជាមតកសាសន៍ដែលម្ចាស់បណ្តាំសរសេរដោយ ខ្លួនឯង ឬឱ្យអ្នកដទៃសរសេរជំនួសខ្លួន ដោយចុះហត្ថលេខា ឬបោះត្រាដោយម្ចាស់បណ្តាំ រួចហើយដាក់ក្នុងស្រោមសំបុត្របិទជិត ដែលម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើស្រោម សំបុត្រនោះ ហើយបន្ទាប់មកម្ចាស់បណ្តាំត្រូវដាក់លិខិតមតកសាសន៍នេះ នៅចំពោះមុខ សារការី និងសាក្សីពីរនាក់យ៉ាងតិច និងត្រូវធ្វើសេចក្តីថ្លែងការណ៍ថា លិខិតមតកសាសន៍នេះជារបស់ខ្លួន ឬធ្វើសេចក្តីថ្លែងការណ៍ពីជនដែលបានសរសេរ ជំនួសខ្លួន បន្ទាប់មក សារការីត្រូវសរសេរសេចក្តីថ្លែងការណ៍ទាំងនោះ នៅលើលិខិតដែល បិទពីលើស្រោមសំបុត្រនោះ ដោយមានការចុះហត្ថលេខារបស់អ្នកទាំងអស់គ្នាផង (មាត្រា ៩៧០) ។ នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន មានបំណងចង់ធ្វើ មតកសាសន៍ដោយ លិខិតសំងាត់ បុគ្គលនោះត្រូវធ្វើសេចក្តីថ្លែងការណ៍ដូចបានរៀបរាប់ខាងលើនេះ តាមរយៈការ បកប្រែរបស់អ្នកបកប្រែ ឬតាមរយៈការសរសេរដោយផ្ទាល់ដៃនៅលើលិខិតដែលបិទជិតនោះ

ក៏បានដែរ (យោងតាមមាត្រា ៩៧២ ដែលបានធ្វើវិសោធនកម្មនៅខែមេសា ឆ្នាំ ២០០០) ។

## ៤.២. អច្ច័យទាន

ជាគោលការណ៍ អត្ថន័យនៃមតកសាសន៍ អាចធ្វើឡើងដោយសេរី ។ តាមរយៈមតកសាសន៍ ម្ចាស់បណ្ដាំ អាចចែងឱ្យមានការកែប្រែសមាមាត្រនៃសន្តតិកម្ម ដែលត្រូវទទួលដោយសន្តតិជនតាមច្បាប់ ហើយនៅក្នុងមតកសាសន៍នេះ ម្ចាស់បណ្ដាំក៏អាចធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យនរណាម្នាក់ក៏បាន (ទៅឱ្យជនក្រៅពីសន្តតិជនតាមច្បាប់ក៏បានដែរ) ។ ការធ្វើដូច្នេះហៅថា អច្ច័យទាន ។ គេអាចធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិទាំងអស់ ជាសកលដល់ជនណាម្នាក់ (អច្ច័យទានសកល) ឬធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិដែលមានកំណត់ជាក់លាក់តែប៉ុណ្ណោះ (អច្ច័យទានមានកំណត់) ដល់ជនណាម្នាក់ក៏បាន ។ ក៏ប៉ុន្តែ អច្ច័យទានមិនអាចកំណត់អ្វីផ្ទុយពីបញ្ញត្តិដែលទាក់ទងនឹងភាគបម្រុងបានទេ (មាត្រា ៩៦៤) ។

ជនដែលទទួលអច្ច័យទានហៅថាអច្ច័យលាភី ។ នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាននៅពេលណាក៏បាន បើសិនខ្លួនមិនចង់ទទួលអច្ច័យទានទេនោះ (មាត្រា ៩៨៦ កថាខ័ណ្ឌទី១) ។ ករណីនេះគឺវាសមហេតុសមផល ណាស់ព្រោះថាសូម្បីតែ សន្តតិជនតាមច្បាប់ក៏អាចបោះបង់សន្តតិកម្មបានដែរ ។ អច្ច័យលាភីសកលក៏ត្រូវមាន សិទ្ធិ និងករណីកិច្ច ដូចគ្នានឹងសន្តតិជនដែរ (មាត្រា ៩៩០) ។

តទៅនេះយើងនឹងក្រលេកមើលពី ប្រទានកម្មដោយមូលហេតុមរណភាពវិញម្ដង ។

ដូចបានរៀបរាប់រួចមកហើយនៅក្នុងជំពូកទី ៤ ប្រទានកម្មដោយមូលហេតុមរណភាព គឺជាប្រទានកម្មដែលចាត់ទុកមរណភាពរបស់ទាយកថា ជាលក្ខខ័ណ្ឌបង្អង់ (បង្កើតអានុភាពដោយមរណភាព) ហើយដែលមតកជនត្រូវចុះកិច្ចសន្យាប្រទានកម្មនោះនៅពេលនៅរស់ ។ ប្រទានកម្មមានលក្ខណៈខុសគ្នាពីអច្ច័យទានដែលជាសកម្មភាពឯកតោភាគី ក៏ប៉ុន្តែដោយសារប្រទានកម្មមានតួនាទីស្រដៀងគ្នានឹងអច្ច័យទាន ដូច្នេះក្រមរដ្ឋប្បវេណីបានកំណត់យកបញ្ញត្តិពាក់ព័ន្ធនឹងអច្ច័យទាន មកអនុវត្តចំពោះ ប្រទានកម្មដោយមូលហេតុមរណភាព ផងដែរ (មាត្រា ៥៥៤) ។ នៅក្នុងច្បាប់ស្តីពីពន្ធលើសន្តតិកម្ម ប្រទានកម្មដោយមូលហេតុមរណភាព ក៏ត្រូវបានគេបញ្ចូលទៅក្នុងអច្ច័យទានផងដែរ (មាត្រា ១ នៃច្បាប់ស្តីពីពន្ធលើសន្តតិកម្ម) ។

## ៤.៣. ការលុបចោលនូវមតកសាសន៍

គោលការណ៍សេរីភាពមតកសាសន៍គឺមានរួមបញ្ចូលនូវសេរីភាពក្នុងការកំណត់ខ្លឹមសារនិងសេរីភាពក្នុងការដកហូតមកវិញនូវមតកសាសន៍។ ម្ចាស់បណ្តាំអាចលុបចោល (ដកហូតមកវិញ)នូវមតកសាសន៍មួយភាគឬទាំងមូលនៅពេលណាក៏បានអនុលោមតាមទម្រង់នៃមតកសាសន៍ (មាត្រា ១០២២) ។ ដោយហេតុថាគេត្រូវគោរព តាមឆន្ទៈចុងក្រោយបំផុតដែលម្ចាស់បណ្តាំមាននៅជិតពេលទទួលមរណៈភាពនោះគេអាចកែ ប្រែមតកសាសន៍ចុះឡើងប៉ុន្មានលើកក៏បានដែរ។ដូច្នេះនៅពេលដែលមានខ្លឹមសារផ្ទុយគ្នារវាង មតកសាសន៍ដែលបានធ្វើមុននឹងមតកសាសន៍ដែលបានធ្វើក្រោយត្រូវចាត់ទុកថាមតកសាសន៍ដែលបានធ្វើក្រោយនេះបានលុប

ចោលមតកសាសន៍ដែលបានធ្វើមុនចំពោះផ្នែកដែលផ្ទុយគ្នានេះ(មាត្រា ១០២៣ កថាខ័ណ្ឌទី១)។

## ៩.៩. ភាគបម្រុង

ដូចបានរៀបរាប់ពីខាងលើរួចមកហើយ ក្រមរដ្ឋប្បវេណីបង្កើតប្រព័ន្ធភាគបម្រុង ដែលធ្វើឱ្យមានការរឹតត្បិតមួយផ្នែក នូវសេរីភាពនៃការធ្វើមតកសាសន៍ ។ ប្រសិនបើផ្អែកទៅលើការគោរពឆន្ទៈរបស់បុគ្គលម្នាក់ៗ គេគប្បីទទួលស្គាល់នូវសេរីភាពរបស់បុគ្គលក្នុងការចាត់ចែងទ្រព្យសម្បត្តិ ទាំងពេលនៅរស់ ទាំងក្រោយពេលទទួលមរណភាព ប៉ុន្តែគេក៏គួតែផ្តល់កិច្ចការពារផងដែរ ចំពោះគ្រួសារដែលធ្លាប់ទទួលការឧបត្ថម្ភពីមរណជន និងចំពោះសេចក្តីសង្ឃឹមរបស់សន្តតិជនតាមច្បាប់ ដែលរំពឹងថាខ្លួននឹងបានទទួលបន្តទ្រព្យសម្បត្តិនោះ ។ ហេតុដូច្នេះ ហើយមតិកមួយផ្នែកជាក់លាក់ ត្រូវទុកជាភាគបម្រុង ដើម្បីធានាចំពោះសន្តតិជននូវការ ទទួលបានមតិក ។ ទោះបីជាត្រូវធានាឱ្យមានភាគបម្រុងក៏ដោយ ក៏មិនមានន័យថា ករណីនៃអច្ច័យទានលើទ្រព្យសម្បត្តិទាំងអស់ ឬប្រទានកម្មដែលបុគ្គលបានធ្វើមុននឹងទទួលមរណភាពត្រូវអស់សុពលភាពភ្លាមៗដែរនោះទេ ។ ចំពោះភាគបម្រុងដែលត្រូវបានបំពាន អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចទាមទារឱ្យធ្វើការកាត់បន្ថយនូវ អច្ច័យទាន និងទ្រព្យសម្បត្តិដែលបានធ្វើប្រទានកម្ម ត្រឹមកំរិតដែលចាំបាច់ដើម្បីបង្គ្រប់ភាគបម្រុងនោះ សំដៅប្រមូលមតិកមកវិញ ដោយយោងតាមការអនុវត្ត សិទ្ធិនៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (មាត្រា ១០៣១) ។

អ្នកដែលមានសិទ្ធិលើភាគបម្រុង ដែលត្រូវបានទទួលស្គាល់ថាអាចទទួលភាគបម្រុង គឺសន្តតិជនតាមច្បាប់ទាំងអស់ ក្រៅពីបងប្អូនបង្កើតរបស់មតកជនចេញ ។ សមាមាត្រនៃភាគបម្រុងត្រូវបែងចែកដូចតទៅ បើសិនមានតែ បុព្វញាតិផ្ទាល់ជាសន្តតិជន នោះភាគបម្រុងត្រូវជា ១ ភាគ ៣ នៃទ្រព្យសម្បត្តិរបស់មតកជន ក្រៅពីនេះ សន្តតិជនតាមច្បាប់ផ្សេងទៀត (សហព័ទ្ធ និងបច្ឆាញាតិជាដើម) ភាគបម្រុងត្រូវជា ១ ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន (មាត្រា ១០២៨) ។ ភាគបម្រុងដោយឡែកពីគ្នា របស់អ្នកដែលមានសិទ្ធិលើភាគបម្រុងម្នាក់ៗ ត្រូវគណនាទៅតាមចំណែកសន្តតិកម្មតាមច្បាប់របស់បុគ្គលម្នាក់ៗ ។ ឧទាហរណ៍ថា ក្នុងករណីដែលសហព័ទ្ធ និងកូនពីរនាក់ គឺជាអ្នកដែលមានសិទ្ធិលើភាគបម្រុង ។ ជាដំបូងបង្អស់ ភាគបម្រុងទាំងមូលគឺត្រូវជា ១ ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន ។ បន្ទាប់មក សហព័ទ្ធត្រូវទទួលបានចំណែក ១ ភាគ ២ នៃភាគបម្រុងទាំងមូលនោះ រីឯចំណែក ១ ភាគ ២ ទៀតបានទៅលើកូនទាំងពីរនាក់ ។ បន្តមកទៀតកូនទាំងពីរនាក់នោះ ម្នាក់ៗត្រូវ ទទួលបានចំណែក ១ ភាគ ២ នៃចំណែករួមរបស់ខ្លួនគេទាំងពីរ ។

ចំនុចដែលត្រូវចាប់អារម្មណ៍នៅកន្លែងនេះ គឺទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង រួមបញ្ចូលនូវទ្រព្យដែលបានបង្ខូរចេញដោយសារប្រទានកម្ម ដែលបានធ្វើក្នុងអំឡុងពេលមួយឆ្នាំ នៅមុនពេលចាប់ផ្តើមធ្វើសន្តតិកម្ម (ចំពោះប្រទានកម្មដែលត្រូវបានធ្វើឡើងដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកដែលមានសិទ្ធិលើភាគបម្រុង ទោះបី

ជាបានធ្វើលើសពីមួយឆ្នាំក៏ដោយ ក៏ត្រូវគិតបញ្ចូលដែរ) (មាត្រា ១០៣០) ។ ពីព្រោះថា បើមិនធ្វើដូច្នេះទេ នឹងបើកឱ្យមានឱកាសអាចបំផ្លាញ ប្រព័ន្ធភាគបម្រុង ដោយសារប្រទានកម្ម ដែលធ្វើមុនពេលមតកជនទទួលមរណភាពបាន ។ តាមរយៈការដែលធ្វើបែបនេះ ទ្រព្យដែល ជាមូលដ្ឋានក្នុងការគណនាភាគបម្រុង អាចត្រូវបានកំណត់ឡើង ដោយយកទ្រព្យសម្បត្តិដែល មតកជនមាននៅពេលទទួលមរណភាព (នៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម) មកបូកបន្ថែម ទ្រព្យសម្បត្តិមួយចំណែកជាក់លាក់ដែលបានធ្វើប្រទានកម្មមុននោះ រួចហើយដកនូវចំនួនប្រាក់ សរុបនៃបំណុលចេញ (មាត្រា ១០២៩ កថាខ័ណ្ឌទី ១) ។

ម៉្យាងវិញទៀត សិទ្ធិនៃការទាមទារឱ្យកាត់បន្ថយភាគបម្រុង នឹងត្រូវរលត់ដោយ អាជ្ញាយុកាល បើសិនជាមិនមានការអនុវត្តសិទ្ធិទាមទារនោះទេ ក្នុងអំឡុងពេលមួយឆ្នាំគិតចាប់ ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងអំពីអច្ច័យទាន ឬ ប្រទានកមដែលត្រូវកាត់បន្ថយនោះមក ។ សិទ្ធិទាមទារឱ្យកាត់បន្ថយនេះ ក៏ត្រូវរលត់ដោយ អាជ្ញាយុកាលផងដែរ បើអំឡុងពេល ១០ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម (មាត្រា ១០៤២) ។

## ៥. ការបំបែកទ្រព្យសម្បត្តិ

ម្ចាស់បំណុលលើទ្រព្យសម្បត្តិរបស់មតកជន (បុគ្គលដែលមតកជនជំពាក់បំណុល) ឬ អច្ច័យ លាភីដែលទទួលទ្រព្យសម្បត្តិពីមតកជនតាមរយៈអច្ច័យទាន (ក្នុងករណីដែលសន្តិតជនខ្លួន

ឯងកំពុងតែជំពាក់បំណុលគេ) ដើម្បីបង្ការ កុំឱ្យទ្រព្យសម្បត្តិ របស់ខ្លួននៅឡូកឡំជាមួយទ្រព្យសម្បត្តិរបស់សន្តតិជន និងការពារកុំឱ្យមានការរារាំងចំពោះការទទួលតាវកាលិករបស់ខ្លួន អាចដាក់ពាក្យសុំទៅតុលាការគ្រួសារ ក្នុងអំឡុងពេល ៣ ខែ បន្ទាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ឱ្យបំបែកទ្រព្យសម្បត្តិរបស់មតកជន ចេញពីក្នុងទ្រព្យសម្បត្តិរបស់សន្តតិជន ដែលត្រូវទទួលបានតាមរយៈសន្តតិកម្ម (តាមមាត្រា ៩៤១ កថាខ័ណ្ឌទី១ ហៅថា ការបំបែកទ្រព្យសម្បត្តិប្រភេទទីមួយ) ។ ហើយអ្នកដែលបានដាក់ពាក្យសុំឱ្យបំបែកទ្រព្យសម្បត្តិរបស់មតកជននោះត្រូវទទួលបាននូវសំណងពីមត៌កនោះ មុនម្ចាស់បំណុលរបស់សន្តតិជន (មាត្រា ៩៤២) ។ ផ្ទុយទៅវិញ ម្ចាស់បំណុលរបស់សន្តតិជន (ដោយពិចារណាពីករណីដែលអាចធ្វើឱ្យស្ថានភាពទ្រព្យធនរបស់សន្តតិជន កាន់តែមានការលំបាកទៅទៀត បន្ទាប់ពីការទទួលនូវទ្រព្យសម្បត្តិដោយសន្តតិកម្មដែលមានតម្លៃតិចជាងបំណុល) ដើម្បីធានានូវការអនុវត្តសិទ្ធិលើបំណុលរបស់ ខ្លួនក៏អាចប្តឹងទៅតុលាការសុំឱ្យបំបែកទ្រព្យសម្បត្តិនោះផងដែរ (តាមមាត្រា ៩៥០ ហៅថាការបំបែកទ្រព្យសម្បត្តិប្រភេទទីពីរ) ។

## ៦. នត្ថិភាពនៃសន្តតិកម្ម

ប្រសិនបើពុំដឹងច្បាស់ថាតើមានសន្តតិជនឬគ្មានទេនោះមត៌កត្រូវទុកជានីតិបុគ្គល (និតិបុគ្គលមត៌ក)(មាត្រា៩៥១)។ នៅក្នុងករណីនេះតុលាការគ្រួសារត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌កតាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ឬតំណាងអយ្យការ(មាត្រា

៩៥២កថាខ័ណ្ឌទី១។ បញ្ញត្តិស្តីពីអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមានត្រូវយកមកអនុវត្តចំពោះអ្នកគ្រប់គ្រងមតិកនេះដែរ)។ ក្នុងករណីដែលតុលាការគ្រួសារបានធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍ដែលអ្នកគ្រប់គ្រងត្រូវបានជ្រើសរើសហើយ ប៉ុន្តែនៅតែរកមិនឃើញសន្តតិជនទៀតនោះអ្នកគ្រប់គ្រងមតិកត្រូវជូនដំណឹងជាសាធារណៈពីស្ថានការណ៍នេះ ដើម្បីផ្តល់លទ្ធភាពឱ្យម្ចាស់បំណុលរបស់មតកជនឬអច្ច័យលាភីទាំងអស់អាចធ្វើសំណើទាមទារបាន(មាត្រា ៩៥៧)។ ជាមួយគ្នានេះដែរ តុលាការគ្រួសារអាចធ្វើការជូនដំណឹងជាសាធារណៈតាមសំណើររបស់អ្នកគ្រប់គ្រង ឬតំណាងអយ្យការដើម្បីស្វែងរកសន្តតិជន (មាត្រា ៩៥៨) ។ បន្ទាប់មកទៀតប្រសិនបើនៅតែមិនអាចរកឃើញសន្តតិជនទេនោះតុលាការគ្រួសារអាចសំរេចផ្តល់មតិកមួយផ្នែកឬទាំងអស់ដែលនៅសេសសល់ក្រោយការជំរះហើយទៅឱ្យជនដែលរស់នៅជាមួយនឹងមតកជនជនដែលបានខិតខំមើលថែទាំព្យាបាលមតកជនឬជនដ៏ទៃទៀតដែលមាននិស្ស័យពិសេសជាមួយមតកជនទៅតាមពាក្យសុំរបស់ជនទាំងនោះ(មាត្រា ៩៥៨ កថាខ័ណ្ឌទី៣ ស្តីពីការចែកចាយមតិកទៅឱ្យជនដែលមាននិស្ស័យពិសេស។ ប៉ុន្តែ បើមិនមានបុគ្គលណាមាននិស្ស័យពិសេសជាមួយមតកជនទេនោះមតិកដែលនៅសល់ត្រូវក្លាយទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ(មាត្រា ៩៥៩) ។

# អ្នកនិពន្ធ

## អ៊ីកិដា ម៉ាសាអូ (Ikeda Masao)

| | |
|---|---|
| ឆ្នាំ១៩៤៩ | កើតនៅទីក្រុងតូក្យូ ប្រទេសជប៉ុន |
| ឆ្នាំ១៩៧៣ | បញ្ចប់ការសិក្សានៅមហាវិទ្យាល័យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យកិយអូ |
| ឆ្នាំ១៩៧៨ | បញ្ចប់ការសិក្សាបរិញ្ញាប័ត្រច្បាប់នៅសាកលវិទ្យាល័យកិយអូ |
| បច្ចុប្បន្ន | សាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យកិយអូ |
| ឆ្នាំ១៩៩១-១៩៩៣ | សមាជិកគណៈកម្មការពិនិត្យការប្រលងលើកទី ២ យកសញ្ញាប័ត្រអ្នកវាយតំលៃអចលនទ្រព្យ |
| ឆ្នាំ ១៩៩៦ តមក | សមាជិកគណៈកម្មការពិនិត្យការប្រលងច្បាប់លើកទី ២ |
| | បណ្ឌិតច្បាប់ (ចេញពីសាកលវិទ្យាល័យកិយអូ) |


សៀវភៅណែនាំសិក្សាច្បាប់រដ្ឋប្បវេណី (ករណីប្រទេសជប៉ុន)

| | |
|---|---|
| អ្នកនិពន្ធ | ម៉ាសាអូ អ៊ីកិដា |
| អ្នកប្រែសំរួល | គង់ ទេលី |
| អ្នកបោះពុម្ព | សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា |
| | មជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ |


© 2008: Ikeda Masao, Kuong Teilee

『民法への招待』池田 真朗
Introduction to the Japanese Civil Code

សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា
Japan Jurists League for Cambodia (JJL)

មជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍
Cambodian Development Research Center (CadRec)